គ្រួសារនៃវប្បធម៌ខ្មែរ
COMMISSION DES MŒURS & COUTUMES

ភាសិតសុភាសិត

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ១ ខែមករា

ព. ស. ២៥០១ គ. ស. ១៩៥៧

ភ្នំពេញ



ភ័ទ្ធសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
-	បណ្ឌិតកថា របស់ព្រះមហា អ៊ុក-អ៊ីន	១
-	អាភាកថា របស់ភិក្ខុ កែវ-សារឿន	១៥
-	រឿងវិន្ធុរជាតក របស់ព្រះមហា ឡើក-អន់	២៧
ផ្នែកអក្សរសាស្ត្រ		
-	ប្បាប់ស្រីព្រះរាជអតីតទ្វេដោយព្រះបាទអង្គឌួង លោកបាប-ពិន ពិនត្យ	៣៩
-	រឿងសព្វសិទ្ធិ របស់ ហ្គីនភ្នំអក្សរ តន់ លោក ប៊ូ-ប៊ី ចំឡងពីសាស្ត្រស្លឹកឥតឹ	៥៣
*	ទំនៀមបេះក្រវាញ អ្នកស្រី ពេជ-សល់ រៀបរៀង	៦២
-	សុភាសិតជាតិស៊ីនីងលីបង់ លោក ភ័ឃ-ប៊ុក ប្រែរៀបរៀង	៦៦
-	រឿងសាមកុក (តមក) ឧកញ៉ា ឧ-កន ប្រែ	៧៦
-	រឿងតាយឡា លោក លាង-ហាប់-អាន ប្រែរៀបរៀង	៨៨
ផ្នែកកំណត់ទឹងប្រវត្តិការណ៍		
-	អនុសំវច្ឆរៈ ឧបោសថ្ងៃបាតលើកទី ១៥ ខែមត្តិសង្ឃ ស្រី-អ៊ូ រៀបរៀង	៩៣
-	វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង	១១៤

មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជាវ ៤៣០០

KAMBUJASURIYA

Revue religieuse et litteraire
éditée par l'Institut Bouddhique

s o m m a i r e

Partie religieuse :

-Panditakatha par vén. OUK-INN 1
-Abhakatha par vén. KEO-SARŒUN 15
-Histoire de Vidudabha par vén. DŒUK-AMARA . . . 27

Partie littéraire :

-Chbap Srey Preah Bat Ang Duong revu et corrigé par M. CHAP-PIN. 39
-Histoire de Sabbasiddhi de Phakdei Aksar TAN revue et corrigée par M. BOU-PO 53
-La cueillette des cardamomes par Mme PICH-SAL 62
-Proverbes syriens et libanais traduits par M. RAY-BUC . . 66
-Histoire de Sam Kok (suite) traduite par M. NOU-KAN . . 76
-Légende d'un chat par M. LEANG HAP-AN 88

Notes et Chroniques :

-Quinzième réunion annuelle des dignitaires religieux pour l'année 1959 par M. SREY-OU. 97
-Dictionnaire Sanskrit-Khmer (suite) par vén. PANG KHAT . . 114

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

បណ្ឌិតកថា

របស់ព្រះឧបាសក អ៊ុក-អ័ង ទេសនាតាមវិទ្យុជាតិថ្ងៃទី ១៦-១១-៥៨

ឯមាំ ឧបាសក ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធស្ស ។

ភុត្តវាសាទិភេទានំ ញាយ !

ថ្ងៃនេះជាថ្ងៃទ្រោសថ ដែលភុត្តបរិស័ទជាគ្រហស្ថ គួរសមាទានកាន់យក
ក្នុងខ្លួន នូវទ្រោសថសីល ដើម្បីញ៉ាំញ៉ីពាន: ទោស: មោហ: មាន:
ជាដើម ។ ដើម្បីធ្វើទ្រោសថឱ្យមានផលច្រើន គួរបំពេញតំណាលសេចតាម
កាលគួរ គឺការស្តាប់ធម្មទេសនា ការសាកសួរធម៌ ការហាត់ធ្វើទ្រោសថ។
ឯកាលនេះ ជាកាលគួរស្តាប់ធម្មទេសនា ។

រីឯជាតិ ផ្សាយធម្មទេសនា អំពីបណ្ឌិតកថា ជូនដាស ណ្តាប់
ចំពោះភុត្តបរិស័ទ ដើម្បីនឹងតម្រង់ទឹកទ្រោសថកាលផង ដើម្បីជួយគាំ-
ទ្រតតគន្ថស្រ្តៃយ មែមនុស្សជាតិឱ្យដាក់ចេញ អំពីពាលភាពមកគាន់
បណ្ឌិតភាព តាមន័យនៃភុត្តវស្សនេះផង ។

ព្រះពុទ្ធដាបណ្ឌិតឯកខាងសទ្ធិកាព ឥតមានអាមិស មានការ
ពិសោធន៍ត្រប់គ្រាន់ ទ្រង់ណែនាំពួកសត្វឲ្យលះបង់អំពើពាល ដែល
បណ្តាលឲ្យកើតទុក្ខទោស តំាង អន្តរាយ ទុបសគ្គ គ្រោះថ្នាក់ ទុប-
ត្រពតាមដ្ឋលត្រប់ប្រការ ឲ្យទុស្សាហ៍ចំរេញមំរើបណ្ឌិត ដែលំប្រព្រឹត្ត
ទៅដើម្បីបុទ្ធសុក្ខ សំរាមដ្ឋលត្រប់យ៉ាង ជាទាំងសុទមនុស្ស សុទ
ក្សត្រិ សុទនិព្វានគ្មានតង្វល់រវល់នឹងកើតចាស់ស្លាប់ដាអវសាន ទ្រង់
ទូន្មានខ្ញុំប្រគុលដែលជាអាល ឲ្យប្រញាប់ប្រញាល់ខ្លួនឲ្យជាបណ្ឌិត
ទ្រង់ឲ្យទៅទបខ្នែមដល់បណ្ឌិតឲ្យតែតែគាំទ្រគាតបណ្ឌិតល្អទៀង ។

សឹងមានព្រះពុទ្ធគាសិតពីរគាថាក្នុងឆម្ពទ បណ្ឌិតវគ្គ ដែលមាន
អត្ថន័យសំដែងអំពីបណ្ឌិត ទឹងធមិរបស់បណ្ឌិតជាទំនស្ន៍ថា :

កណ្ហំ ធម្មំ វិប្បហាយ សុក្កំ កាវេថ បណ្ឌិតោ
ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ
តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ
បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។

បណ្ឌិតចេញចាកអាល័យ អស្រ័យនិព្វាន ឥតអាល័យ គប្បីលះឲ្យ
ស្រឡះនូវធម៌ខ្មៅ គប្បីចំរើននូវធម៌ស បណ្ឌិតលះបង់ នូវកាមភ៌ងឲ្យ

អស់កន្លះ គប្បីប្រាថ្នាខ្លះសេចក្តីត្រេកអរក្រៃលែងក្នុងធម៌ទាំងពួក ដែលសត្វកម្រត្រេកអរក្រៃ គប្បីញុំាងខ្លួនឲ្យស្អាតផូរផង់ ចាកធម៌ទាំងឡាយជាគ្រឿងសៅហ្មងចិត្ត ។

សេចក្តីអធិប្បាយ :

ពាក្យថា « បណ្ឌិត » បានសេចក្តីថា អ្នកប្រព្រឹត្តទៅដោយបញ្ញា ដោយញាណគឺអ្នកប្រកបដោយបញ្ញាស្អាត អ្នកប្រាជ្ញ អ្នកមានប្រាជ្ញាអ្នកចេះដឹង អ្នកចេះចំដែរ៉ៈសេចក្តីច្បាស់លាស់ អ្នកចេះវែកញែកប៉ើតបង្ហាញសំដែរ៉ៈនិតន្យល់ ឲ្យងាយយល់ខ្លួនអាចិធម៌ អ្នកឈ្លាស អ្នកឆ្លៀវប្រសប់ អ្នករំដែរ៉ៈមានប្រាជ្ញាឆើបឆឺន អ្នកមានប្រាជ្ញាខ្លាប់ខ្លួន អ្នកមានប្រាជ្ញាកាប់ម្ល៉ា អ្នកចេះលៃលក អ្នកមានញាណ អ្នកមានមតិល្អ អ្នកមានភូមិតិ អ្នកចេះវែកខ្លួន អ្នកអប់រំខ្លួនដោយសុចរិត ។

ពាក្យថា ចេញចាកកាលភ័យ អាស្រ័យនូវព្រះនិព្វានគ្មានកាលភ័យ បានសេចក្តីថា ចេញចាកសំនៅតឹ ឃកវាសធម៌ ជាសំនៅតណ្ហា ជាចំណងមារ ជាគ្រឿងសង្កត់កាលភ័យចេះចិត្ត ដែលធ្លាប់ជួតគ្រាំ លះកេនគ្រហស្ថទាំងអស់ហ៊ាមរតនយកព្រះនិព្វាន ដែលចេញផុតកាលភ័យគឺតណ្ហាឲ្យជាអារម្មណ៍ ហើយបំពេញខេត្តមកនឹសាសនា ។

ពាក្យថា គប្បីលះបង់ឲ្យស្រឡះនូវធម៌ខ្មៅ បានសេចក្តីថា កាលបាន

បួសហើយ គួរលះបង់នូវអកុសលទាំងអស់ មានខុទ្ទកនិកាយជាដើម ហើយ
បំពេញចតុបារិសុទ្ធិសីលឲ្យផូរផង់ឲ្យស្អាត ឲ្យបរិបូណ៌ជាអប្បមាណ ។

ពាក្យថា តប្បច្ច័យនេនូវឆមិសៈ បានសេចក្តីថា គួរប្រឹងប្រែងព្យាយាម
តាំងសម្មប្បធាន ៤ ឲ្យមុឺងម៉ាត់ធឹងឥតរួញរាទ ៤ ឲ្យរឹងប៉ឹង ចំរើនឲ្យកុសល
ធម៌ទាំងអស់ មានសុចរិតជាដើមឲ្យបានចំរើន ធ្វើសមាធិចិត្តឲ្យមាំមួន
ដរាបដល់បានអរហត្តមគ្គ ។

ពាក្យថា លះបង់នូវតាមពាំងឲ្យអស់តទៅ បានសេចក្តីថា
លះបង់ ផ្តាច់បង់ រំលើងចោលនូវតាមពាំងតណ្ហា ទិដ្ឋិ តាម បានដល់
តាមគុណារម្មណ៍ ៥ ឧបាទានក្ខន្ធរបៀតបៀនតទៅ សវិញ្ញាណកាវិញ្ញាណកវត្ថុ ។
តាសេសុតាម បានដល់ឆន្ទៈ រាគៈ សង្កប្បៈ តណ្ហា ស្នេហៈ មុច្ឆា
អជ្ឈោសានៈ យោគៈ ឧបាទានៈ ចំពោះវត្ថុតាមខោះ ហើយអស់មានការ
រលាស់ខ្វល់ស្មុគ្រស្មាញ ព្រោះតណ្ហាវន្តធាតុ រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ
ទៅជាស្រួល ។

ពាក្យថា តប្បច្ច័យនេនូវសេចក្តីត្រេកអរក្រៃលែងកន្លងវិសេក ដែលពួក
សត្វកម្រត្រេកអរក បានសេចក្តីថា បន្ទាប់មក ចង់បាននូវសេចក្តីរីករាយ
ស្រោះស្រាយ កន្ធនៈនូវសេចក្តីរីករាយប្រកបដោយអាមិស ក្នុងព្រះនិព្វាន
ដ៏ស្ងប់ស្ងាត់ហួសពីលោស ១ខ្ន អតិសង្ការ បានដោយងាយ ព្រោះ
សេចក្តីត្រេកអររីករាយបែបនេះ ពួកសត្វដែលត្រូវតាមនីវរណ៍កង្វល់រួបរឹតដំនុះ

ជាន់ញាំញីជានិច្ច ពុំបានឧកាសត្រេកអរនឹកដល់ទេ ។

ពាក្យថា គប្បីញ៉ាំងខ្លួនឲ្យស្អាតផូរផង់ ចាកធម៌គាំងឆ្ងាយជាគ្រឿងសៅហ្មងចិត្ត បានសេចក្តីថា គប្បីដុសខាត់អាត្មនីចិត្ត ឲ្យរឹតតែផូរផង់ពិសេសជាងនោះទៅទៀត ឲ្យជ្រះលើងអំពីគំលេសរបស់ចិត្ត គឺនីវរណធម៌ ៥ យ៉ាង ។

បណ្ឌិតលោកយកនិព្វានជាអារម្មណ៍ហើយ ឈានទៅកាន់និព្វានសោយនេក្ខម្ម: ស័ល សម៌ធិ បញ្ញា ដកឋសម្រេចអរិយាខតិប្ប ។

បណ្ឌិតចែកដោយខន្ធ ដំណើរមក ដោយសង្ខេបមាន ៤០ គឺ

១ - សីប្បិយបណ្ឌិត បណ្ឌិតព្រោះស្ទាត់ខាងសិល្បៈមានសិល្បៈធ្វើជាដើម,

២- ទុគ្គណ្ហេនបណ្ឌិត បណ្ឌិតព្រោះរៀនបេះពេញរហស្រ្ត ធម្មសាស្ត្រ បរិយត្តិជាដើម,

៣- ពាហុសច្ចបណ្ឌិត បណ្ឌិតព្រោះបេះចាំច្រើន រៀនសូត្រស្តាប់ច្រើន,

៤- បណ្ឌិតូបសំសេរិបណ្ឌិត បណ្ឌិតព្រោះចូលសេពបណ្ឌិតរៀនស្តាប់ជាមួយ,

៥- សុតបណ្ឌិត បណ្ឌិតព្រោះស្តាប់អ្នកច្រើនសំដែងរៀយ ។,

៦- បិត្តបណ្តិត បណ្ឌិតព្រោះការគិតត្រិះរិះ ពាក់ព័ន្ធ
តាំងពីដើម ល្បឿន,

៧- ភារិសាបណ្តិត បណ្ឌិតព្រោះការចំរើនឡើងនូវគន្ធ ធាតុ អាយតនៈ
ឥន្ទ្រិយ សច្ច,

៨- សជាតិបណ្តិត បណ្ឌិតព្រោះមានបញ្ញាពិចារណា ដែលកើត
អំពីភាពជាតិរបស់ខ្លួន,

៩- អត្ថវិមោចនបណ្តិត បណ្ឌិតព្រោះចេះដោះស្រាយនូវអត្ថ
បទសព្ទ ឃាត់ឃាប់នៃសូត្រ,

១០- ខុបាយកោសល្លបណ្តិត បណ្ឌិតព្រោះឈ្លាសក្នុងឧបាយ
សព្វគ្រប់,

១១- ការណាការណាជាឧត្តមបណ្តិត បណ្ឌិតព្រោះស្គាល់ហេតុ
គួរ-មិន គួរ,

១២-លោកវិត្តជាឧត្តមបណ្តិត បណ្ឌិតព្រោះចេះស្គាល់វត្តទំនៀម
លោក ប្រើប្រាស់តាមសមគាម,

១៣- កាលវិបក្ខណាបណ្តិត បណ្ឌិតព្រោះប្រុងប្រយ័ត្នចាំស្គាល់
ខ្លួនតាមកាលៈទេសៈ,

១៤-បញ្ញាវិសុទ្ធិនបណ្ឌិត បណ្ឌិតព្រោះវាងវៃក្នុងការដោះស្រាយបញ្ហា ,

១៥-ធម្មសន្និបាយបណ្ឌិត បណ្ឌិតព្រោះចេះដំណើរខ្លួនដោយសន្សំនូវសីលមាន,

១៦-ឃរាវាសបណ្ឌិត បណ្ឌិតព្រោះគ្រប់គ្រងផ្ទះ តាមប្រយោជន៍ខាងក្នុងនិងក្រៅ,

១៧-អដ្ឋានយោគ្គាណាបណ្ឌិត បណ្ឌិតព្រោះចេះគោរមរឿងស្រួយ បុគ្គល បរិសទ,

១៨-កតញ្ញូកតវេទិបណ្ឌិត បណ្ឌិតព្រោះដឹងគុណគេ ហើយឆ្លើតបវិញ,

១៩-សង្គហបណ្ឌិត បណ្ឌិតព្រោះចេះសង្គ្រោះដោយទាន សំដីផ្ដែម ប្រយោជន៍ស្មោះស្ម័,

២០ អត្តត្ថប្បដិវេធបណ្ឌិត បណ្ឌិតព្រោះចេះចែរំលែងដោយល្អ ច្រាសចាកអកុសល,

២១-បដិបុគ្គលិកបណ្ឌិត បណ្ឌិតព្រោះចេះដឹងលំដាប់ក្នុងគុណដ៏សមគួរ,

២២-កល្យាណបណ្ឌិត បណ្ឌិតព្រោះមានកល្យាណកម្ម អំពើល្អជាទីគាប់ចិត្ត,

២៣-មុលនិទ្ទមបណ្ឌិត បណ្ឌិតព្រោះព្យាយោមកំចាត់មនុទ្ទិល ដោយបំពេញកុសល,

២៤-ប្បញ្ញាទុប្បយបណ្ឌិត បណ្ឌិតព្រោះចេះសន្សំបុណ្យ បន្តិចបន្តួច។

២៥-បរិប្ជាគបណ្ឌិត បណ្ឌិតព្រោះលះកំណាញ់បំពេញទាន,

២៦-សីលបណ្ឌិត បណ្ឌិតព្រោះមានសីល ៥-៨-១០-៤,

២៧-បញ្ញាបណ្ឌិត បណ្ឌិតព្រោះមានបញ្ញាដឹងនូវទុក្ខ ហេតុទុក្ខ ការរលត់ទុក្ខ ហេតុរលត់ទុក្ខ,

២៨-ពុទ្ធិបណ្ឌិត បណ្ឌិតព្រោះត្រាស់ដឹងនូវសច្ចៈ ហើយឲ្យគេត្រាស់ដឹងផង,

២៩-អនុពុទ្ធិបណ្ឌិត បណ្ឌិតព្រោះត្រាស់ដឹងនូវសច្ចៈតាមក្រោយ,

៣០-ឥទ្ធិបណ្ឌិត បណ្ឌិតព្រោះចេះអត់ធន់ធឹងសភាវធម៌ ធម្មជាតិ អន្តរាយ,

៣១- វីរិយបណ្ឌិត បណ្ឌិតព្រោះព្យាយាមកំចាត់កិលេស អកុសលលាមក ,

៣២- អរោបណ្ឌិត បណ្ឌិតព្រោះមិនមានពៀរព្យាបាទខ្លួនទឹងអ្នកដទៃ ,

៣៣- សមចរិយោបណ្ឌិត បណ្ឌិតព្រោះការប្រព្រឹត្តស្មើដោយកាយ វាចា ចិត្ត ,

៣៤- មោនបណ្ឌិត បណ្ឌិតព្រោះការដឹងនូវលោក ព្រោះស្ងៀមចាកអកុសល ,

៣៥- បច្ចវេក្ខណបណ្ឌិត បណ្ឌិតព្រោះពិចារណាឃើញត្រគូលវិយជាដើម រៀវចាកអកុសល ,

៣៦- អត្ថគ្គហណបណ្ឌិត បណ្ឌិតព្រោះមានបញ្ញាចក្ខុកាន់យកនូវប្រយោជន៍ដ៏ឆាំងពីរ ,

៣៧- អត្តបរិហិតបណ្ឌិត បណ្ឌិតព្រោះធ្វើប្រយោជន៍ឲ្យខ្លួនជាឲ្យអ្នកដទៃផង ,

៣៨- សុខីករណបណ្ឌិត បណ្ឌិតព្រោះធ្វើខ្លួនឲ្យបានស្រួលឲ្យសុខសាន្ត ,

៣៩- អត្ថវិសោធនបណ្ឌិត បណ្ឌិតព្រោះការកែខ្លួនឲ្យបានចំរើនល្អ ដោះ ,

៤០- កាមាទីនវទស្សនបណ្ឌិត បណ្ឌិតព្រោះការឃើញនូវទោសតាមគុណារម្មណ៍ ។

បណ្ឌិតទាំងនេះ មានសទិសតាតែមួយ ដោយលក្ខណៈ ៣ គឺ ការធ្វើល្អ ការនិយាយស្តីល្អ ការគិតល្អ ។ បំប្រួញមកនៅត្រឹម ៣ គឺ

១- សយម្ភូបណ្ឌិត បណ្ឌិតដោះ ដឹងឯង ដោយផលជាម៉ែឥមិ,

២- អនុបណ្ឌិត បណ្ឌិតដោះដឹង តាមសយម្ភូបណ្ឌិត ,

៣- ពីជបណ្ឌិត បណ្ឌិតដែលមានពូជជាតិបណ្ឌិតក្នុងខ្លួន ។

ក្នុងទីនេះ គួរយកពីជបណ្ឌិតជាប្រមាណ ព្រោះជាទាងដើម ។

ក្នុងលោកនេះ បុគ្គលដែលឯកែតជាមនុស្សហើយ ឯនជាបណ្ឌិតតែម្តង. តម្រូវមានណាស់ ប៉ុន្តែ បុគ្គលដែលមិនក្លាយជាបណ្ឌិតសោះនោះ មិនមានទេ បើទុកជាបុគ្គលនោះ គាន់អំពើពាលយ៉ាងណាក៏ដោយ គង់អាចកែខ្លួនបាន ដោយការសេពគប់បណ្ឌិត ព្យាយាមជាដើម ព្រោះក្នុងសន្តានរបស់គេ តែងតែមានពូជជាតិបណ្ឌិតបិតនៅ ដូចជាធាតុទ្វាតែងតែមានក្នុងទឹកស្រាំ ឬដូចជាតិរសផ្អែមតែងតែមានក្នុងផ្លែស្វាយទឹ ឬក៏ដូចពូជឈូកមាននៅក្នុងស្រះរើងទឹកក្នុងតំម្លាជូរ ។ ដូច្នេះ មនុស្សឈ្មោះថាបណ្ឌិតុ

ដោយតួដជាតិបណ្ឌិត ។ តួដជាតិបណ្ឌិតនេះនឹងដុះជាលខ្លឹង ដោយការ
រៀន ដោយការសេពគប់បណ្ឌិតកល្យាណមិត្ត ដោយឮ្យាយមជាដើម
ដូចតួដឈូកនៅក្នុងស្រះ តែងតែដុះកន្ទុយពេលមានទឹក ក្នុងវេស្សាទដូរ
ដូច្នោះ បើពុំដូច្នោះទេ មិនលូតលាស់ ដើម្បីបណ្ឌិតភាពឡើយ ដូចតួដ
ឈូកមិនដុះកន្ទុយស្រះ ឥតទឹកដូច្នោះ ។

បុគ្គលជាតិដបណ្ឌិត គប្បីដើម្បីសាងខ្លួនឲ្យជាសេយ្យមបណ្ឌិត ឬ
អនុបណ្ឌិតបាន ដោយតួយ៉ាងមបណ្តុះតួដបណ្ឌិត ដោយទង្គាន់ គប្បីមាន
សញ្ញមៈ ទម: ដោយការសេពគប់សប្បុរស ដោយការចេះចាំខ្លួនក្នុងការ
រៀន ចិន្តាស្តាន វិនិច្ឆ័យ ដោយការខៀកគន្លឹះណាគំរាមរួចរៀបចំ
មានការពិនិត្យមើលច្រើន មានស្តីលាចារៈសមរម្យស្រួលត់ស្រួត ដោយការ
ស្តាប់ តិត ចំរើន ដោយការសរសើរដឹកតួ តិមិត ចរិត អធ្យាស្រ័យការគ្រក់
ដោយទុកាយចិត្តមិនខ្ជិល ដោយការខ្មីនឹកគ្រងឹ ខន់តួន់សុភាពមួយដៀងវិញ
ដោយមានខ្មែ ស័ល ព្រហ្មវិហារ ។

ឥដបណ្ឌិត គាលបានអប់រំខ្លួនយ៉ាងនេះហើយ ឬនៃឈ្មោះថាបណ្តុះ
តួដបណ្ឌិតឲ្យដុះតាមលំដាប់ យូរ ៗ ទៅ មានថ្ងាចាស់ក្បាល មានកំឡាំង
ក្លាថា គាបមើលឃើញច្បាស់ ខ្លួវត្រៃលោក ដូចគំនរកែវិនតិរ ឈ្នះគំនរ
ខ្លួវរលោកដែលតើលនឹងវិត្រៃលក្ខណ៍ ខ្លួវក្លៀងក្លាត កើតមិតិលេស ខ្លួវ
សង្ឃរវដ្តឥតចុងឥតដើម ខ្លួវតែយក្នុងសំសារសាគរដ៏ធំធេងជ្រៅស្រឡឹង

ឃើញយកវាសធម៌ពេញដោយកង្វល់សាំញាំ ។ ឃើញថា ភោសតាម
ជាមេអសន្តិសុខ ពញ្ចពុទ្ធ វិហឹសា ជាមេភ្លើង ប្រល័យលោក ដុតពេល
លោក ឲ្យខ្ទោចក្រៀមក្រមសៅហ្មងសោកសៅ ហើយធុញព្រាន់ទីង
លោក ទីងការតើត ឲាស់ ឈឺ ស្ងាប់ ឃើញច្បាស់ខ្ទៀងអនិសង្សនៃកុម្មថា
ក្សេម ឥតកង្វល់ លះបង់កេទគ្រហស្ថគាំងអស់ ថ្វាយជីវិតបួសក្នុង
ព្រះពុទ្ធសាសនាប្រាសចាកទុក្ខរណ៍ក្នុងឆ្នូះ ។

បណ្ដើតចេញចាកអាល័យរបស់គ្រហស្ថគឺតាមតណ្ហាហើយ កំណួងចិត្ត
ចោះគោលលើព្រះនិព្វាន ដែលឥតអាល័យឲ្យជាអារម្មណ៍ជាខាងដើម
ឲ្យជាទីសម្រាប់ដើរទៅនៃចិត្ត ។ តមក លោកតាំងយកអសុភានុទិស្សនៈ
សំរាះ មត្តញ្ញុតា សទ្ធា វីរិយៈ ជាសេខាឯក ហើយតតាំងញ៉ាំញីមារ លះ
បង់ឲ្យជ្រះស្រឡះនូវធម៌ខ្មៅ គឺអកុសលធម៌ភាំងអស់ ដែលជាធម៌ទាំងចិត្តឲ្យ
ខ្មៅ ឲ្យសៅហ្មងល្អក់កករ ទាំងសត្វទៅកាន់កន្លែងខ្មៅ កំណើតខ្មៅ ឥតសីរ
សុខចំរើន ដែលជាធម៌មានឋ្ងស ៣ គឺ លោភៈ ទោសៈ មោហៈ ចែកទៅ
មានទុច្ចរិត ៣ ជាដើម ។ តមក លោកត្បាយាមចំរើនធម៌ស គឺកុសល-
ធម៌ទាំងអស់ មានសុចរិតជាដើម ដែលជាធម៌ស្អាតបរិសុទ្ធម៌ដ្ឋចត់ផ្ងរ
ផង់ឥតទោស ជាធម៌ទាំងចិត្ត ឲ្យសព្វភ្លឺថ្លា ទាំងសត្វទៅកាន់កន្លែងស្អាត
កំណើតស្អាត ទាំងសត្វទៅកាន់និព្វានដែលជាកន្លែងស្អាតចាកតណ្ហាមន្ទិល
ទុក្ខគ្រប់ប្រការ ។ លុះលោកជ្ញានចំរើនធម៌សហើយ លោកត្រូវការចង់

ចានខ្លួនអត់រាត សេចក្តីត្រេកអរដែលតន្ធឹលែងខ្លួនត្រេកអរជារបស់មនុស្ស ទេពតាទាំងអស់ ក្នុងវិស័កគឺអមតនិព្វាន ដែលស្ងប់ស្ងាត់សូន្យចាកទុបធ-គឺកិលេស ១ខ្ទ អកិសង្ខារ រម្ងាប់សង្ខារទាំងអស់ រលាស់រចាលទុប-ធិកិលេសទាំងអស់ អស់តណ្ហា ប្រាកចាកតម្រេក រលត់ទុក្ខ អស់កង្វល់ វាងវិណ្ណ គឺតណ្ហាគ្រឿងជោត ដែលពួកសត្វកំពុងត្រូវតវិញ្ញាបិទប្ចាំងមុខ ក្តែងដឹត មិនដែលទឹកឃើញ បងិ៍តកាយសប្បាយសោះ ហើយលោកតំ លះបង់ខ្លួនតាមតីយ៉ាង :

១- ទ្វិតកាម អារម្មណ៍របស់ជាទីត្រេកអរ ឆ្លាញ់នៃកាមលោក ចានដល់អារម្មណ៍ជាទីពេញចិត្ត ៥ គឺ រូប សំឡេង ក្លិន រស សម្ងស្ប្ស ចានដល់អវិញ្ញាណកវត្ថុ គឺសំពត់ មាស ប្រាក់ ផ្ទះ ស្រែ ចំការ ស្រុក ដែន លោក សវិញ្ញាណកវត្ថុគឺ ប្រពន្ធ បុត្រ ដំតា ទាសី ទាសា គោ ក្របី ដំរី សេះ ។

២- កិលេសកាម ចានដល់សេចក្តីពេញចិត្ត តម្រេក ដ្ឋកត តម្រិះតេកាម សេចក្តីតាប់ចិត្ត សេចក្តីតេកចង្រៃក្រអាល អន្ទះសា រសាប់រសល់ជ្រួលក្នុងកាម ការស្ងិតជាមជាប់ក្នុងកាម សេចក្តីត្រេកអរ ចលរលាកក្រោះកាម ការច្រឡំជ្រួល ងងុល ល្ងង់ លង់ ក្នុងកាម ការ ត្រេកអរ ជាប់ ប្រកាន់ស្អិតក្នុងកាម ការពាំងពាសារកាម លុះលះហើយ

លោកដាប់ត្តលទំនេរ ស្រាលអស់កង្វល់ អស់អំពល់ចិត្ត ។

លំដាប់ពីនោះ លោកសំអាតខ្លួនលោកឲ្យតែងស្អាតចាកតិរៈលេស ឆ្លងផ្លូវដន់លើងចាកធម៌ដែលនាំឲ្យសៅហ្មង ធម៌ដែលនាំឲ្យចិត្តសៅហ្មងបានដល់នីវរណធម៌ ៥ យ៉ាងគឺ

១- កាមច្ឆន្ទៈ សេចក្តីពាក់ចិត្តនឹងកាម,

២- ព្យាបាទៈ សេចក្តីឈ្នានឹសបំផ្លេចបំផ្លាញ,

៣- ថីនមិទ្ធៈ សេចក្តីនោកង៉ុយ,

៤- ឧទ្ធច្ចកុក្កុច្ចៈ សេចក្តីតណ្ហាតអណ្តឹកយមាយ,

៥- វិចិកិច្ឆា សេចក្តីសង្ស័យ មិនអស់ហើយ ។

បណ្ឌិតក្តត់គោលដៅនឹងព្រះនិព្វានហើយ ឃានប្រព្រឹត្តធម៌បណ្ឌិតតាំងនឹងនឹត្យក់ខាង កណ្តាលរហូតដល់ទីក្តង ដើម្បីឲ្យសម្រេចនិព្វានក៏ឃានដល់នូវទីបំផុតនៃគោលដៅ ត្រង់តារអស់អាសវៈជាទីបំផុត ។

និគមវិបាក:

តាក្យថា លះបង់នូវធម៌ខ្មៅ គួរបួលក្នុងសីល ចំរើននូវធម៌ស គួរបួលក្នុងសមាធិ,ចេញចាកអាល័យ គួរបួលក្នុងបញ្ញា, លះបង់កាមឥតកង្វល់ គួរបួលក្នុងបញ្ញា, សំអាតចិត្តឲ្យផ្លូវធង់ចាកគ្រឿងសៅហ្មងចិត្ត គួរបួលក្នុងបញ្ញា ។

X X X

អារាកថា

របស់ភិក្ខុ កែវ-សារឿន ទេសនាតាមវិទ្យុជាតិពីថ្ងៃទី ៥-៦-៥៨

ឥតោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការចំពោះព្រះដ៏ត្រៃត្ថ ដោយគោរព ។

វេលានេះ សូមសំដែងអំពីពាក្យថា «ពន្ធឹ» តាមទស្សនៈគ្រាសនសម័ព្ទ វិទ្យុជាតិកម្ពុជា ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា ធនជាវត្ថុប្រតិបត្តិ នៃពុទ្ធសាសនិកជនគ្រប់ជាន់ថ្នាក់ដូចតទៅ :

ពាក្យថា ពន្ធឹ មាន ៤ យ៉ាងគឺ

ពន្ធឹព្រះអាទិត្យ ១ ពន្ធឹព្រះចន្ទ្រ ១

ពន្ធឹភ្លើង ១ ពន្ធឹប្រាជ្ញា ១ ។

ពន្ធឹទាំង ៤ យ៉ាងនេះ សូមអធិប្បាយដូចតទៅ :

១ ពន្ធឹព្រះអាទិត្យ សម្រាប់ចុះបំភ្លឺបានតែត្រឹមវេលាថ្ងៃប៉ុណ្ណោះ បើទុសតិវេលាថ្ងៃហើយ កុំសង្ឃឹមថាមានពន្ធឹអាចនឹងចុះបំភ្លឺដល់សត្តនិកាយ ឱ្យប្រកបការងារផ្សេង ។ នោះបាន ឡើយ ។

២ ពន្ធឹព្រះចន្ទ្រក៏ចុះបំភ្លឺបានត្រឹមតែវេលាយប់ប៉ុណ្ណោះ បើទុសតិវេលាយប់ហើយ មិនអាចនឹងបំភ្លឺឱ្យដល់ធម្មជាតិឱ្យភ្លឺស្វាង ដោយសារតែពន្ធឹខ្លួនបាន ឡើយ ។

៣ – ពន្ធឹភ្លើង មានប្រទីប បង្កើងជាដើម ព្រោលបំភ្លឺបានតែត្រឹម

ត្រាំដែនរបស់ខ្លួនប៉ុណ្ណោះ បើផុតព័ត្រាំដែនរបស់ខ្លួនហើយ ក៏មិនអាចនឹងធ្លុះបញ្ចាំងបំភ្លឺបានទេ ។

បណ្តាតន្ទឺទាំង ៣ ដែលបានសំដែងមកខាងលើនេះ មានអានុភាពអាចធ្លុះបំភ្លឺបាន ចំពោះតែវត្ថុដែលមានភាវ្រាប៉ុណ្ណោះ មិនអាចធ្លុះបំភ្លឺឲ្យឃើញអាថកំបាំងស្រាលបានទេ តែធ្លុះកន្លងសន្ធានរបស់សត្វលោកឲ្យឃើញឲ្យស្គាល់ថា នេះជាហេតុនៃទុក្ខ នេះជាហេតុនៃសុខ-ជាហេតុនៃវិនាស ចម្រើន ឬថា. ឲ្យស្គាល់គុណ-ទោសបុណ្យបាបដូច្នេះ តុំបានឡើយ គ្រាន់តែបំភ្លឺឲ្យដឹងពេលយប់ថ្ងៃល្ងាចព្រឹកប៉ុណ្ណោះ ឬថា សម្រាប់ចំអិនទូវ៉ាកោជនាហារ ដែលដួយតាំទ្រជីវិតាពឲ្យរស់នៅ ដើម្បីនឹងត្រៃរ៉ះរកតន្ទឺទុត្តមវិសេសតទៅទៀត ។

៤-តន្ទឺប្រាជ្ញា ទើបអាចធ្លុះបំភ្លឺឲ្យឃើញទូវ៉ាហេតុផល នៃសុខ-ទុក្ខ-ចម្រើន-វិនាសបាន ព្រមទាំងមានកម្លាំងអាចធ្លុះបំភ្លឺឲ្យវិសេសជាងតន្ទឺដទៃ ដូចមានតុទ្ធភាសិតថា :

ឧត្តិ បញ្ញា សមា អាភា រតនំ ឥធ វិជ្ជតិ
បុគ្គលដែលសំអាតចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផុតស្រឡះចាកគ្រឿងសៅហ្មងបាន ក៏ព្រោះប្រាជ្ញា ។ កំបញ្ញានេះ លោកប្រៀបដូចកែវក្នុង នរជនអាចតយគន់គុណទោស ដែលជាមេនាំឲ្យមានទៅក្នុងចិត្ត ទោះបីបន្តិចក៏អាចសម្លឹងឃើញច្បាស់លាស់ ហើយចំរ៉ែនឬ លះបង់ចោលចេញ បើពុំក

ជាគោលធ្លាប់ប្រឡាក់ប្រឡូសមកតាំមុខ ព្រោះតែល្ងង់ខ្លៅងងឹត មិនដឹងអ្វីសោះ កំពង់ត្រឡប់ប្រសិទ្ធិល្អថាន សមដូចសុភាសិតថា បញ្ញាយ. បរិសុទ្ធិ្ធតិ បុគ្គលដែលបរិសុទ្ធបាន ដោយសារប្រាជ្ញា ។

បុគ្គលដែលឥតប្រាជ្ញាមិនអាចធ្វើខ្លួនឲ្យមានសិរីជ័យមង្គលបានទេ មានតែជនអ្នកមានប្រាជ្ញា ទើបដំកល់ខ្លួនឯងធំធងអ្នកដទៃឲ្យថ្លៃថ្លាបាន ដូចសុភាសិតថា បញ្ញា ទេវំ បសាសតិ បញ្ញាតែងក្សត្រនូវបុរស.ស្ត្រី ។ ព្រោះហេតុនោះ ជនដ្ឋកប្រាជ្ញវត្តឲ្យដាច់ថា ប្រាជ្ញានេះសំខាន់បំផុតក្នុងពេលដែលប្រកបតិច្ចការគ្រប់យ៉ាង ឲ្យបានសម្រេចគាំងអស់ ថែមទាំងអាចដោះខ្លួនឲ្យរួចអំពីសេចក្តីកន្តក់ឈឺដល់ជីវិត បានដោយងាយ ។

ន័យមួយទៀតថា បញ្ញាដែលមានតែបុគ្គលណា បុគ្គលនោះ ត្រូវរកគ្រឿងតុសម្ភារៈមកដំឯយដួយទុកតម្កល់ ឯគ្រឿងដំឯយនោះ បានដល់បញ្ញាវុឌ្ឍិធម៌ ។ បញ្ញាវុឌ្ឍិធម៌មាន ៤ យ៉ាងគឺ

១- សប្បុរិសូបនិស្សរៈ: ការចូលទៅសេពគប់សប្បុរស,

២- សទ្ធម្មស្សវនៈ: ការស្តាប់ព្រះសទ្ធម្ម,

៣- យោនិសោមនសិការៈ: ការធ្វើទុកក្នុងចិត្តដោយឧបាយ,

៤- ធម្មានុធម្មប្បដិបត្តិ ការប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ។

ទី១- សេចក្តីឈ្វេងយល់ដំនាញក្នុងការងារ ព្រមទាំងកិរិយា

ការយោគត្រឹមត្រូវល្អ ទើបបញ្ហាដែលសម្រាប់សង្កេតរកហេតុផល ទើប
កើតឡើងបាន ក៏មកពីការចូលទៅអង្គុយជិតស្និទ្ធស្នាលតប់ប្រមូទើប
លោកអ្នកស្តប់ម្ខាប់ដោយគាយៈថា ចិត្តហៅថា "សប្បុរិសូបសំសេវ" ។

ទី ២- បើចូលទៅអង្គុយជិតលោកអ្នកសប្បុរសហើយ កុំគ្រាន់
តែទៅដាំមួយនោះ ឥតបានសម្រេចគុណប្រយោជន៍អ្វីទេ ត្រូវស្តាប់ឱវាទ
របស់លោកអ្នកសប្បុរស ដែលលោកទូន្មានប្រៀនប្រដៅឱ្យមានរបៀប
រៀបរយល្អ ហើយប្រតិស្មារតីចាំស្តាប់ ចំពោះពាក្យប្រៀនប្រដៅរបស់
លោកដោយគោរព ហៅថា "សទ្ធម្មស្សវនៈ" ។

ទី ៣- បើឮសេចក្តីណា បានស្តាប់ព្រោះសទ្ធម្មដោយគោរពហើយ
ត្រូវរិះគិតហេតុផលឱ្យស្គាល់ល្អ-តាក្រក់ ដោយយោបល់ដ៏ប្រពៃ គឺឱ្យ
ត្រឹមត្រូវតាមគន្ថធម៌ ។

បណ្តាកិច្ចការគ្រប់ដំពូកក្នុងលោកនេះ ដែលបុគ្គលធ្វើហើយក្តី កំពុងធ្វើក្តី
ក៏ត្រូវតែមានយោនិសោមនសិការៈ គឺយកចិត្តទុកដាក់ក្នុងកិច្ចការ
នោះ ។ ទើបអាចសម្រេចទៅបាន បើមិនដូច្នេះទេ បញ្ហា ក៏មិនកើតមាន
ឡើយ សមដូចព្រះពុទ្ធភាសិតក្នុងគម្ពីរខុទ្ទកនិកាយថា ឆត្តិ បញ្ហា អលាភ-
យិ នោ បុគ្គលដែលមិនរំពឹងពិនិត្យល្បងមើល មិនដែលមានបញ្ហា
ឡើយ ។ ហេតុនោះ សុះត្រាតែស្ទាំមើលពិនិត្យពិចារណាឱ្យច្បាស់លាស
ទើបកើតបញ្ហាដ៏ក្តាបានបាន ។

តាលបើសិក្ខាកាម កុមារ កុមារីតាំងខ្លួយមានទ្រព្យថ្នាទីដ៏សិក្ខា
វិជ្ជាផ្លូវលោក ផ្លូវធម៌ណាមួយ តំត្រូវប្រើតំនិតគិតតាមពាក្យប្រដៅ ស្តាប់
ពាក្យសីសំលោក ព្រោះថា ពាក្យប្រៀនប្រដៅនេះ ជាមេគំនិតមួយយ៉ាងដ៏
សំខាន់បំផុត នាំឲ្យកើតបញ្ញាសេចក្តីត្រៃវិជ្ជាសំឡើងបាន សមដូចសុភា-
សិតថា សុតមយេ បញ្ញា ប្រាជ្ញាកើតឡើងដោយសារការស្តាប់ ។

ព្រោះហេតុនោះ ការដែលត្រូវរិះដោយ១ចាយដ៏ប្រពៃនេះ អ្នកប្រាជ្ញ
ទ្រង់ចាត់ថា គុណធម៌ជាគ្រឿងចំរើនបញ្ញា ដ៏សំខាន់បំផុត នេះហៅថា
"យោនិសោមនសិការៈ" ។

ខ ៤ - បើបានត្រិះរិះ ដោយយោបល់ដ៏ប្រពៃតាមគន្ថធម៌ហើយ
ត្រូវប្រតិបត្តិឲ្យសមគួរដល់ធម៌នោះ ។ កើបបានដួបប្រទះនឹងសេចក្តីសុខ-
ចំរើន តាមសមគួរដល់សេចក្តីប្រតិបត្តិបស់ខ្លួន ។ ម្យ៉ាងទៀត បុគ្គល
ពួកខ្លះ ប្រព្រឹត្តធម៌នឹងសេចក្តី តែមិនបានដួបប្រទះនឹងសេចក្តីសុខ-ចំរើនដ៏
ជាប់ជំពាក់ណាមួយ មកពីការប្រព្រឹត្តធម៌ មិនគាន់សមគួរដល់ធម៌ គឺប្រព្រឹត្ត
ត្រូវហួសហេតុជាដ៏ការចេះដឹងដ៏ជាប់ខ្លួនក៏មាន ផ្លូវថ្នាជាដ៏ការចេះដឹង
ក៏មាន បានជាមិនដួបប្រទះនឹងសេចក្តីសុខ - ចំរើន ដែលជាតម្រៃនៃ
សេចក្តីប្រតិបត្តិ ដោយត្រូវត្រាន់សោះ ។ លុះណាតែប្រតិបត្តិធម៌ឲ្យ
សមគួរដល់ធម៌នោះ ទើបប្រយោជន៍សព្វយ៉ាងសម្រេចគ្រប់បាន នេះហៅ
ថា "ធម្មានុធម្មប្បដិបត្តិ" ។

ឯពន្ធុពោលគឺបញ្ញានេះ មិនមែនមានតែក្នុងសន្តានបុរសទេ សូម្បីជាស្ត្រីក៏ដោយ គង់មានបញ្ញាដែរ ដូចសុភាសិតកន្លងមក្នុងគម្ពីរខ្លួកនិកាយថា

ឯសោ សត្ថេសុ ហាវេនសុ ឧត្តិសោ មោតិ ជណ្ហិតោ
ឥត្ថីបិ បណ្ឌិតា មោតិ តត្ថ តត្ថ វិចក្ខណា ។

បុរសមិនមែនឈ្មោះថាជាបណ្ឌិត ក្នុងទីចាំងពួនទេ ពោះបើជាស្ត្រីក៏ដោយ ឲ្យតែមានសេចក្តីឥតវៃ គឺគង់ឈ្មោះថាជាបណ្ឌិតបានដែរ ។

ម្យ៉ាងទៀត ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ត្រាស់ជាសង់តឿនឲ្យចំដុសខាត់បញ្ញាឲ្យល្អ ហើយរកត្រឿនជំនួយផ្សេងដែលនៅលាយឡំនឹងបញ្ញាដូចជាអំបិលដែលនៅលាយឡំនឹងម្ហូបសម្ល ឯបញ្ញាក៏មានគុណធម៌ដែរ ជាច្រើនយកមកផ្សងផងដែរ ។

ហេតុហ្នឹងហើយ បានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា គុណជាតិដែលសម្រេចប្រយោជន៍ដោយនាប់រហ័ស ដូចចិត្តប្រាថ្នាយ៉ាងនេះ គឺជាតួបញ្ញាដោយពិត ។

ឯធម៌ខោះ បានដល់ឥទ្ធិបាទ ៤ ឬវេសារជ្ជករណធម៌ចាំង ៥ ។

ឥទ្ធិបាទ ៤ ខោះគឺ

១_ ឆន្ទៈ: ការចូលចិត្តស្រឡាញ់ក្នុងកិច្ចការខោះ។,

២- វីរិយៈ: ការព្យាយាមប្រកបកិច្ចការខោះ។,

๓- ปิติ: ยកចិត្តទុកដាក់ក្នុងកិច្ចការនោះ ។ មិនលះបង់ធុរៈ
ចោល,

๔- វិមំសា ។ ស្ទាហ៍ពិចារណាត្រិះរិះរកហេតុផលនោះ ។ ។

សេចក្តីថា ការចូលចិត្តស្រឡាញ់រីឯផ្លូវលោកក្តី ផ្លូវធម៌ក្តី លុះតែ
ខំស្វះស្វែងរក ទើបបានជួបប្រទះនឹងចំណេះវិជ្ជាការចេះដឹង ហើយត្រូវ
មានសេចក្តីព្យាយាម ថែរក្សាទូរការចេះដឹងឲ្យមាំទាំឡើង ត្រូវជ្រុះចាត់
ចំណេះវិជ្ជាចេស៎ាយ៉ាង ឲ្យមានពន្ធឹក្តីរុងរឿង កុំឲ្យសាបសូន្យទៅវិញបាន
ខំប្រឹងប្រែងក្នុងការចេះដឹង មិនលះបង់ចោល ។ស្ទាហ៍ត្រិះរិះរកហេតុផល
បានដល់កុសលវិតក្កៈទាំង ៣ គឺសេចក្តីត្រិះរិះចេញចាកកាម ដើម្បីកាន់
ខ្ជួនកេរ ១ សេចក្តីត្រិះរិះ មិនយកចិត្តចងនឹងខ្ញុំនឹងគួន , ចំពោះសត្វនឹង
សង្សារ១, សេចក្តីត្រិះរិះមិនបៀតបៀនអ្នកដទៃ ឲ្យបានសេចក្តីវេឆ៎ខ្ពុះវ៉ា នា
ដោយសារខ្លួន ១ ។

ធម៌សម្រាប់អ្នកប្រតិបត្តិតាម ឲ្យមានបញ្ញាកើនឡើងហាន់បន្ថែមខៀត
តាមក្រមៃពន្ធឹនោះ ។ គឺវិសារជ្ជៈណាធម៌មាន ៤ យ៉ាង គឺ

๑- សទ្ធា ការជឿត្រូវដែលគួរជឿ.

๒- សីលៈ ការរក្សាកាយវាចាចិត្ត ឲ្យរៀបរាយល្អ,

๓- ពាហុសច្ចៈ ការៈដាំអ្នកសិក្សារៀនសូត្រច្រើន,

៤ វីរិយារម្ភៈ ការប្រារព្ធសេចក្តីព្យាយាម,

៥- បញ្ញា សេចក្តីដឹងច្បាស់ ចំពោះរបស់ដែលគួរដឹង ។

ខ១- សទ្ធា ការជឿចំពោះវត្ថុទាំង ៣ ប្រការ មានព្រះពុទ្ធជាដើម ដែលជាវត្ថុស័ក្តិសិទ្ធិ ប្រសើរលើសលុប ឥតរកវត្ថុដទៃប្រសើរជាងគ្មាន ។ ជំនឿបែបនេះ ជាគ្រឿងប្រកបធ្វើឲ្យបញ្ញាគាហានមួយផ្នែកដែរ ។

ខ២- សីលៈ ការរក្សាកាយវាចាចិត្តឲ្យមានរបៀបរៀបរយល្អ គឺសហធម្មិក ក្នុងព្រះពុទ្ធសាសនានេះ ជាបុគ្គលមានសីលបរិបូណ៌ ពេញលេញ សង្រួមប្រយ័ត្ន ដោយធម៌ជាគ្រឿងយុំគ្រងខ្លួន មិនធ្វេសប្រហែសក្នុងការរក្សាសិក្ខាបទទាំងឡាយ ដែលជាភូមិភាគនេះ តុល្យភាគខ្លះ ព្រមទាំងជាអ្នកសម្បូណ៌ ដោយអាចារៈដ៏ងាយដើរសមគួរ ឃើញភ័យក្នុងទោសសូម្បីមានប្រមាណតិចតួចជាប្រក្រតី ហើយសមាទានដឹងរក្សារៀនសូត្រសិក្ខាបទទាំងឡាយនោះ ។ ។

ខ៣- ពាហុស្សច្ចៈ ការៈជាអ្នកសិក្សារៀនសូត្រច្រើន ហើយទ្រទ្រង់នូវធម៌ ដែលខ្លួនបានរៀនសូត្រ ចាន់ស្តាប់ជះចាំនោះ។ ព្រមទាំងសន្សឹមនូវធម៌មានតាំពេះបទដើម-កណ្តាល-ចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថន័យព្យញ្ជនៈ តែញ្ញាប់គ្រាន់បរិសុទ្ធគ្រប់យ៉ាង មិនមាន

សេសសល់ ធម៌ទាំងពួងដែលមានសភាពដូច្នេះ លោកឯងរៀន ឯងស្តាប់ចេះដឹងច្រើន ហើយត្រូវចំសន្សំទុក ត្រិះរិះពិចារណាដោយចិត្តនឹងឯងចាក់ធ្លុះធម៌ល្អ ដោយស្មេចក្តីយល់ឃើញត្រូវ ។

ទី ៤- រ៉ីយ៉ោរ៉ម្ចុ: ការប្រារព្ធសេចក្តីព្យាយាម គឺពុទ្ធបរិស័ទក្នុងព្រះពុទ្ធសាសនា ជាបុគ្គលឯងប្រឹងប្រែង ខ្មីឃ្មាត់ ដើម្បីលះបង់នូវអកុសលធម៌ ហើយចំរើញកុសលធម៌ ជាអ្នកមានកម្លាំងកំហែងនឹងសេចក្តីប្រឹងប្រែងជាំមុន មិនលះកិច្ចធុរៈ ក្នុងកុសលធម៌ចោលឡើយ ស្មេដូចសុភាសិតថា

រ៉ីយ៉ៈណោ តិក្ខវេ អរិយសាវកោ
អកុសលំ បជហាតិ កុសលំ ភាវេតិ
សាវជ្ជំ បជហាតិ អនវជ្ជំ ភាវេតិ
សុទ្ធត្តា ន បរិហាយតិ ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវកតែងមានសេចក្តីព្យាយាមជាកម្លាំងលះបង់នូវអកុសលធម៌ទាំងឯស់ មិនឲ្យដិតជាមខៅក្នុងចិត្ត ហើយញុំងកុសលធម៌ឲ្យចម្រើនឡើង លះបង់នូវចំណែកធម៌ដែលជាទោស ហើយញុំងចំណែកធម៌ដែលជាគុណឲ្យចំរើនឡើង រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ។

ទី ៤- បញ្ញា គារធីធ្រាកដចំពោះវត្ថុដែលគួរដឹង ជាគុណជាតិប្រកបត្រមដោយបញ្ញា ជាគ្រឿងពិចារណាយើញការកើត ទីធីការលត់នៃសង្ខារទាំងពួងដោយជាក់ច្បាស់ ជាបញ្ញាដ៏ប្រសើរ អាចកំចាត់តិលេសសេចក្តីសៅហ្មងរបស់ចិត្តឥតមានសល់ ទីធីជាគ្រឿងធ្វើឲ្យដល់នូវព្រះនិព្វានអស់រៅនៃខ្លួនដោយប្រពៃ ឬពិចារណាយើញច្បាស់នូវអរិយសច្ចទាំង ៤ រហូតដល់ចានសម្រេច នូវធម៌ជាន់ខ្ពស់ មានសោតាបត្តិផលជាដើម ហើយកាច់ផ្តាច់នូវសំយោជន: ១០ យ៉ាងគឺ

១- សក្កាយទិដ្ឋិ សេចក្តីយល់ឃើញថា ខន្ធ ៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជារបស់ខ្លួនទាំងអស់,

២- វិចិកិច្ឆា សេចក្តីសង្ស័យមិនចេះដាច់ស្រេច ក្នុងខន្ធទាំង ៥ ដែលមានក្នុងកាល ៣ គឺ កាលដែលកន្លងហួសរៅហើយ អត្តាអញធ្លាប់ចានកើតជាអ្វីដែរ ឬ ទេ? ដំណតរៅមុខ អត្តាអញមានខ្លួនដែរ ឬ មិនមានទេ? ឥឡូវនេះ អញ ឬ មិនមែនអញ?

៣- សីលព្វតបរាមាស: សេចក្តីបរាជ្ញសអង្អែល ប្រកាន់វត្តប្រតិបត្តិប្រក្រតីរបស់ខ្លួន គឺប្រកាន់ថា នេះវត្តបរិសុទ្ធជាដើម,

៤- កាមច្ឆន្ទ: សេចក្តីត្រេកត្រអាលក្នុងកាមគុណ,

៥- ពាក្យបាទ: ចិត្តចង់គំនុំអកដរៃឲ្យវិនាស,

៦- រួបរាគ: សេចក្តីត្រេកត្រអាល ក្នុងរូបកាយ,

៧- អ្នរួបរាគ: សេចក្តីត្រេកត្រអាល ក្នុងអរូបកាយ,

៨- មាន: សេចក្តីបើងរើងរ៉ូស ប្រកាន់ខ្លួន,

៩- ឧទ្ធច្ច: សេចក្តីកយមាយចិត្ត,

១០- អវិជ្ជា សេចក្តីល្ងង់ខ្លៅ វង្វេងងងេងងងោង មមិនមមាំន មិនដឹងអី ។

សំយោជនធម៌ទាំង ១០ យ៉ាងនេះឯង ចង់ឲ្យក់ត្រៃតែចិត្តសត្វឲ្យ សៅហ្មង មិនឲ្យមានឥទ្ធិស្មើគ្នៃឡើងបាន ហើយញុំាងសត្វឲ្យវិលវល់ កើតស្លាប់ ក្នុងវដ្តសង្សារ ។

យោគាវចរកុលបុត្រ ដែលលោកបានតាត់ផ្តាច់ផ្តិលនូវសំយោជន ធម៌ទាំងនេះបាន តាមលំដាប់នៃអរិយមគ្គទាំង ៤ មានសោតាបត្តិមគ្គជាដើម ឲ្យជ្រះស្រឡះចាកខន្ធសន្តានទៅបាន ដោយអំណាចនៃអរិយមគ្គញាណ គឺជាប្រាជ្ញាដ៏ខ្ពស់ កាលបើយោគាវចរកុលបុត្រស្ងួនភៃគ្រឿងផ្សំនឹងបញ្ញាបានជួបប្រទះហើយ មុខជានឹងបានសម្រេចនូវសុខ-ចំរើន ក្នុងជាតិនេះ នឹងជាតិខាងមុខទៀត មិនលែងឡើយ ។

បញ្ញាបើមានក្នុងសន្តានចិត្តនៃបុគ្គលណា ហើយបុគ្គលនោះអាចរកហេតុ-ផល ដែលជាឧបាយជួយរំលែះទុក្ខទោសអ្នកដទៃ ឲ្យបានស្រាយស្រួលក្រមាំងសេចក្តីអន្តរាយរបស់ខ្លួនឯងវិញ ឥតខ្វល់សោះ ។

ការសំដែងអំពីពន្ធ ៤ ប្រការ គឺ ពន្ធព្រះចន្ទ, ពន្ធព្រះអាទិត្យ, ពន្ធភ្លើង, ពន្ធបញ្ញា, ក៏សន្មតថា ចប់តែប៉ុណ្ណេះ ឯង ។

x

x x

ឯកមរិបទ:

ពន្ធ៏ក្នុងលោកបួនប្រការ ភ្ជាប់អស្ចារ្យត្រចះចែង
ព្រះចន្ទ្របំភ្លឺលោកច្បាស់ខែង ត្រប់ខែកន្លែងក្នុងពេលយប់ ។
ឯព្រះអាទិត្យមានអាភា ភ្លឺតែវេលាថ្ងៃលើសលុប
ដល់ពេលពត្រឹអាកាសងងឹប ឲ្យងងឹតឈឹបបាត់ស្រឡឹ ។
ឯពន្ធ៏ភ្លើងផងតាំងឡាយ ដែលភ្លឺសុះសាយលើផែនដី
ដោយសារតេជុតទសប្រែងក្តី ទើបមានរស្មីភ្លឺដឹងបាន ។
រីឯពន្ធ៏គឺប្រាជ្ញា ភ្លឺឥតទបមាយល់សត្វហាន
បំភ្លឺដឹកនាំសត្វត្រប់ប្រាណ ឲ្យបានឈ្នះងាយល់ផ្លូវបាបបុណ្យ ។

រឿងវិទ្ធុរភ:

ព្រះមហា ខៀក-អម៉ រៀបរៀង

ក្នុងសម័យពុទ្ធកាល មានព្រះរាជកុមារ ៣ ព្រះអង្គគឺ បរសេនទិ (ព្រះរាជបុត្រព្រះបាមហារាសល នៅរាជធានីសាវត្ថី) ១, មហាលិ (ព្រះរាជបុត្រវង្សលិច្ឆវី នៅក្រុងវេសាលី) ១, ពន្ធុល (ព្រះរាជបុត្រមល្លក្សត្រនៅក្រុងកុសិនារ) ១ ។

ព្រះរាជកុមារទាំងភ្លេអង្គនេះ បានចេញទៅសិក្សាសិល្បសាស្ត្រនៅមហាវិទ្យាល័យនាក្រុងតក្ខសិលា, មកដួបគ្នាត្រង់សាលាមួយនៅត្រង់នគរកំសាងសុត្រតូលនឹងព្រះនាមរៀងៗខ្លួន រួចសុំបង់មិត្រទឹងគ្នា ហើយបានចូលទៅរៀន ក្នុងសំណាក់សាស្ត្រាចារ្យជាមួយគ្នា លុះរៀនចេះដឹងអស់ហើយ ក៏លាគ្រូវិលទៅគាន់ពាជធានីរៀងកល់អង្គវិញ ។ ព្រះអង្គម្ចាស់បរសេនទិ បានសំដែងសិល្បសាស្ត្របង្ហាញព្រះបិតា ហើយបានជាទិសាភ្លូព្រះទ័យនៃព្រះមហាក្សត្រជាអនេក ទើបទ្រង់អភិសេក ឲ្យគ្រងរាជ្យស្នងព្រះអង្គ ។

ឯព្រះអង្គម្ចាស់មហាលិ ក៏បានចំប្រឹងបញ្ចេញខ្លួនចំណេះទៅទ្រង់បង្ហាញដល់ព្រះរាជវង្សានុវង្សណាស់ដែរ តែអកុសល បណ្តាលឲ្យបែកព្រះនេត្រខ្វាក់ទាំងសងខាង ។ តែទោះបីដូច្នោះ ក៏គង់ព្រះរាជវង្ស

ខ្ញុំវិញ្ញ មិនលះបង់ចោលទ្រង់ដែរ ឲ្យនដួយទុបក្តុយ៉ាងពេញបន្ទុក តែ
ប្រគល់ទ្វារព្រះនគរមួយចំហៀង ដែលមានស្រុកចំណុះកប់ដែនឲ្យទៅជា
កម្មសិទ្ធិនៃព្រះពុទ្ធកុមារអង្គនេះ ។ ព្រះអង្គម្ចាស់មហាលិ ទ្រង់មិនបោះបង់
ព្យាយាមចោលសោះ ថ្វីបើព្រះនេត្រទាំងពីរពិការដូច្នោះ , មានព្រះពុទ្ធ-
បុត្រនៃវង្សលិច្ឆវី ចំនួន ៥០០ អង្គ ឲ្យនមកសិក្សាសិល្បសាស្ត្រ ក្នុង
សំណាក់ទ្រង់ ។

ចំណែកខាងព្រះអង្គម្ចាស់ពន្ធុល ក្រោយដែលឲ្យនចូលមកដល់ព្រះ
រាជធានីវិញ ព្រះរាជវង្សានុវង្សឲ្យនយកឫស្សី ៣៦០០ ដើម ហើយ
ប្រកស្ងួលដែក ទៅក្នុងដើមឫស្សីទាំងនោះឥតឲ្យសល់ រួចចងផ្គុបជា ៦០
ចាប់ ក្នុង ១ ចាប់មាន ៦០ ដើម ហើយប្រកាសប្រាប់ថា ចូលព្រះពុទ្ធ
កុមារពន្ធុល មកកាត់ឫស្សី ៦០ ចាប់នេះឲ្យដាច់ពុះ ។ លំដាប់នោះ
ព្រះពុទ្ធកុមារកាន់ដាវចេញមកហើយ លោតទៅលើកំពស់ ៨០ ហត្ថ កាប់
ខ្លាប់ កំភ្លឹងរត្រឹក ! ទ្រង់លាន់ព្រះឧស្ឋថា យើ ! អ្វីហ្នឹង ? លុះទ្រង់
ជ្រាបថា គេប្រកស្ងួលដែកក្នុងដើមឫស្សីដូច្នោះ ក៏ទ្រហោយំរៀបរាប់ថា
« បណ្តាញាតិមិត្រទាំងប៉ុន្មាននេះ គ្មានអ្នកណាម្នាក់ប្រាប់រឿងនេះ ឲ្យអញ
ឲ្យនដឹងផងសោះ ប្រសិនបើអញដឹងមុន ខឹងកាប់ដែកទាំងអស់ឲ្យ
ដាច់មិនឲ្យឫស្សីរៀតផង » ទើបទូលព្រះមាតាព្រះបិតាថា « ទូលព្រះ
បង្គំជាខ្ញុំនឹងសម្លាប់ពួកទាំងនេះ យកពរជ័យសម្បត្តិឲ្យបាន » ។ ឯព្រះមាតុ

ព្រះបិតា ចានយាត់ថា «នែបុត្រសំឡាញ់! ការត្រងឹកផ្សេងនេះ គឺជាប្រភៃណីត។ គ្មានមរតេនទេ កូនឯងមិនត្រូវបានទេ» ។ ទើបព្រះពជកុមារទូលថា «បើដូច្នោះ កូនសុំលាលោកអ្នកមានគុណទៅនៅជាមួយសំឡាញ់ ឯក្រុងសាវត្ថីហើយ» ។

ថ្ងៃនោះ ព្រះទៅបសេនទិ លុះជ្រាបថា ព្រះអង្គម្ចាស់តន្ទុលជាសំឡាញ់យោធមក ក៏ទ្រង់ទៅទទួលនាំទៅគាន់ព្រះពជនិវេសន៍, តមកទ្រង់តាំងឲ្យធ្វើជាសេនាបតី ។ ព្រះអង្គម្ចាស់សេនាបតី ចានយកព្រះមាតាព្រះបិតា ពីក្រុងកុសិនារមកឲ្យទៅជាមួយទ្រង់ ឯក្រុងសាវត្ថីវិញ ។

សម័យមួយ ព្រះចាទបសេនទិ ទ្រង់កំពុងប្រថាប់ទៅក្នុងប្រាសាទព្រះពជតំណាក់ ចានឮឮងព្រះនេត្រទៅ ឃើញកិកុសង្ឃពីរភាគអង្គកំពុងនិមន្តរជ្ជ តាមផ្លូវទៅទទួលកត្តិ ទៅគេហជាន្តមហាទជ្ជាសក ទជ្ជាសិកា អនាថបិណ្ឌិក វិសាខជាដើម ទ្រង់សាកសួរទៅពួកស្នំបំរើលុះជ្រាបពត៌មាននេះ ព្រះទៅមានព្រះពជបំណងចង់ធ្វើដូច្នោះដែរ ទើបយាងទៅគាន់វត្តជេតពន ដោយព្រះអង្គឯង ហើយនិមន្តព្រះពុទ្ធជាម្ចាស់ព្រមទាំងកិកុសង្ឃ ១ ពាន់អង្គ ឲ្យទៅទទួលចង្ហាន់ ឯព្រះពជតំណាក់ត្រង់តំណាត់៧ ថ្ងៃ។ កន្លងថ្ងៃបន្តើយ ទ្រង់បញ្ជាណាំះពោះព្រះតក្រព្រះសម្ពុទ្ធថា «សូមព្រះអង្គស្តេចមកទទួលកត្តនៅទីនេះ ពល់។ ថ្ងៃកុំបីខាន ព្រមទាំង

ព្រះសង្ឃ ๕๐๐ អង្គខៀតផង ។ ๆ ព្រះបរមគ្រូទ្រង់ត្រាស់តបទៅវិញ ថា " មហាពាជ ! តាំងតាំបុពណាគាលមក ព្រះពុទ្ធតាំនឲ្លាយ ម៉ែនដែលទទួលភិក្ខាហារតែផ្ទះមួយ ๆ ជាប់ជាន់ច្ន រឿនពល់ថ្ងៃទេ ព្រោះថា បើធ្វើដូច្នេះទៅ នឹងតាំឲ្យពួកជនម្នាក់មានសទ្ធាឯខ្លែ" ទេ។ នឹងតាំឲ្យពួកជនម្នាក់មានសទ្ធាឯខ្លែ" ទេ។ ទើបព្រះពាជាទូលបន្ថែមតទៅទៀតថា " បើដូច្នេះ សូមព្រះអង្គទ្រង់មេត្តាប្រោសអនញ្ញាតភិក្ខុ ๑ រូប ឲ្យធ្វើជាប្រធានសង្ឃឲ្យមាន " ๆ ព្រះបរមសាស្តាបានចាត់ព្រះមហាមោគ្គល្លានឲ្យទទួលការនេះ ๆ ការរៀបគន្លប្រគេនភិក្ខុសង្ឃ នោក្នុងព្រះបរមពាជវាំង បានប្រព្រឹត្តទៅដោយរៀបរយ តែក្នុងកំឡុង ๑ សប្តាហ៍ប៉ុណ្ណោះទេ ស្តីតព្រះមហាសុវ៌ត្រទ្រង់ចាត់ចែងផ្ទាល់ព្រះអង្គឯង ๆ លុះដល់ថ្ងៃទី ๘ ព្រះបាទមានព្រះទ័យរីករាយ យាងមកមិនទៀងពាត់ពេលវេលា ក្នុងការបំរើព្រះសង្ឃ ហើយថែមទាំងមិនបានបង្គាប់ដល់ជនណាម្នាក់ ឲ្យគាន់ការនេះដែលសព្រះអង្គសោះ ๆ ថ្ងៃតាមក ព្រះពាជាចេះតែធ្វើដំណើរយឺតយូរ ហាក់ដូចជាតុំស្ងួរយកព្រះទ័យទុកដាក់បំរើព្រះសង្ឃ ជាហេតុនាំឲ្យមានការរយីការយោគហួសប្រមាណ។ ចំណែកព្រះសង្ឃវិញ លែងមានសេចក្តីកត់ត្មៅចំពោះព្រះពាជនិម្មន្តន៍នេះ ដូចថ្ងៃមុន ๆ ទៀត ព្រោះថា ជួនកាលពេលទិមន្តមកដល់ តុំពាន់ឃើញមានរៀបចំគ្រាលការនេះនៅឡើយផង , រីការដ្ឋាននេះ ជាបុព្វហេតុនាំឲ្យ

ព្រះភិក្ខុសង្ឃ មានសេចក្តីរង្កៀសក្នុងភាជនៈគ្រលួស ។ លុះកន្លងមកប្រមាណ ៣ថ្ងៃ ភិក្ខុទាំងនោះតុំអាចនឹងទ្រាំទ្រខ្លួលភត្ត ក្នុងព្រះភាជនៈណាក់តទៅទៀតបាន ក៏បបួលគ្នាឈប់ឆាន់ទៅពីនោះ ទៅសល់តែព្រះមហាអានន្ទ ១អង្គគត់ ។ ថ្ងៃក្រោយមក ព្រះមហាកស្សបត្រង់ជ្រាបហេតុនោះ ទ្រង់ព្រះពិរោធចំពោះពួកភិក្ខុសង្ឃជាខ្លាំង ទើបយាងទៅវត្តជេតពន ទូលព្រះសម្ពុទ្ធជាម្ចាស់ថា "បង្អាន់ដែលខ្ញុំព្រះអង្គបាមចាត់ចែងបំរុងព្រះសង្ឃ ៥០០ រូបនោះ ឥឡូវនេះ សល់តែព្រះអានន្ទត្តែមួយអង្គប៉ុណ្ណោះ ព្រះសង្ឃឯទៀត តុំដឹងហេតុអ្វីបានជាលោកតុំត្រមនិមន្តទៅសោះ ? " ។ ព្រះបរមសាស្តាទ្រង់តុំបានថ្លែងទូវគោសកំហុសរបស់ពួកភិក្ខុទាំងនោះទេ, ទ្រង់ត្រាស់ទៅកាន់ព្រះពោជ្ឈង្គបុត្តវិញថា "មហាភាជ ! សេចក្តីសិក្ខាស្វាលរវៀមមហាភាជនីយ៍បុត្រតថាគត គ្មានបន្តិចបន្តួចសោះ បានជាបុត្រតថាគតលែងទៅ" រួចទ្រង់ប្រជុំពួកភិក្ខុសង្ឃប្រកាសប្រាប់ នូវហេតុគួរនឹងមិនគួរបួលទៅកាន់គ្រលួទាំងឡាយ ហើយទ្រង់សំដែងព្រះសូត្រ ដូចតទៅនេះ ៖

ម្នាលភិក្ខុទាំងឡាយ គ្រលួដែលប្រកបដោយអង្គ ៤ (ដូចតថាគតនឹងសំដែងខាងក្រោមនេះ) បើភិក្ខុមិនទាន់បួលទៅកេះទៅឡើយទេ មិនគួរបួលទៅជិតឡើយ, បើបួលជ្រុលទៅហើយ មិនគួរអត្តិយ (ក្នុងន័យនៃគ្រលួលែបបនេះ) សោះឡើយ:

១- គេមិនក្រែកខ្លួលភិក្ខុ ដោយសេចក្តីពេញចិត្ត,

២- គេមិនធ្វើខ្លួរអភិវាទភិក្ខុ ដោយសេចក្តីពេញចិត្ត,

៣- គេមិនពេញចិត្តនឹងឲ្យភិក្ខុអង្គុយលើអាសនៈ,

៤- គេលាក់លៀមទ្រព្យរបស់ (មានឧទាហរណ៍ដូចមានឲ្យរៀបរាប់ខាងដើម) ពីមុខភិក្ខុ,

៥- គេមានវត្ថុច្រើន គេតែងឲ្យភិក្ខុបន្តិចបន្តួចសោះតែខាន,

៦- គេមានវត្ថុយ៉ាងប្រណីត តែបែរជាគេឲ្យរបស់សៅហ្មង (ដែលគេលែងត្រូវការទៅហើយ),

៧ គេឲ្យដោយសេចក្តីមិនគោរព,

៨- គេមិនចូលមកស្តាប់ធម៌,

៩- គេមិនត្រេកអរចំពោះភិក្ខុ ដែលកំពុងនិយាយព័ន្ធធម៌តាចឹង។

ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ៩(ផ្សេងពីអង្គខាងលើនេះ) បើភិក្ខុមិនទាន់ចូលទៅរកនៅឡើយ ក៏គួរចូលទៅចុះ. បើចូលទៅជ្រុលហើយ ក៏គួរអង្គុយ (សន្ធានស្ថិតស្ថាលនឹងត្រកូលបែបនេះ)ចាន។

(អង្គទាំង៩ នៃត្រកូលដែលភិក្ខុគួរចូលទៅរកនោះ មិនចាន់សំដែងខ្មៀតទេ ព្រោះដូចគ្នាខាងលើដែរ គ្រាន់តែផ្សេងគ្នា ប៉ុណ្ណោះ) ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់បញ្ជាក់ទៀតថា មហាពាជ! សាវ័កតថាគត មិនចាន់ខ្លួលវិស្សាសៈ អំពីសំណាក់មហាពាជ ដូចតថាគត

សំដែងមកនេះសោះ ជាន់ជាសាវ័កចាំនឹងនោះលែងទៅ ។ រួចទ្រង់ទាញ
ខ្លាន់ជាតកពីព្រឹងនាយ ដែលមានដំណើរខ្លះឯងដូចគ្នាន់ធរឿងពួកតិក្ខ
ចូលទៅធាន់ ក្នុងព្រះរាជដំណាក់ដែរ ។ មកសំដែងឲ្យព្រះរាជាទ្រង់
ព្រះសណ្តាប់ឮត ដើម្បីឲ្យទ្រង់រឹតតែជាន់យល់ប្លាស់ខ្លួនលើនផលផ្ទុយ
ក្នុងការខ្លួនតុបំរើបពួជិត មិនត្រប់អង្គ (លក្ខណៈ) ។ ព្រះមហាសត្វទ្រង់
ព្រះសណ្តាប់ ខ្លួនម្ចាស់ថានេះហើយ ទ្រង់មានព្រះរៀតក្តាផ្សង ។ ដូច្នេះ
។ ដើម្បីខ្លីវែងខ្លី ខ្លួសខ្លួនកាត់ដេរមិនព្រមស្តួច ឲ្យបានព្រះសំដីដាក់ទុម
គួរតាក្មួយក្រឡាតិលលាតម៉ាំងណាដេរ ? ក្នុងកន្លែងនេះ គួរសាត្មាតញ
យកទឹតាម្ចាស់ ជាព្រះក្សាត្រិយ៍ដែលត្រាស់ទុមកឲ្យដឹងតែលោ ទើបតួតតិក
សាមណេរ លែងហ៊ានខាន់ខ្លួមតទៀតត្រូ ដៅកំណាត់ថាស
អាត្មាអញ ត្រូវលោតចាំនឹងនៅតែងនឹងតែយើញថា អាត្មាអញ ហ៊ានបាញ់
បង់ព្រះរាជទ្រព្យ", រួចទ្រង់ភ្ញាន់ដើរពីព្រះរាជសាវ៉ែដៅឲ្យត្រូតលាតក្តុ ឱ្យដែស
រកនឹតាម្ចាស់ ក្លាយព្រះអង្គឆ្លើយមកហាស ។ លុះសារនេះដែលសំ ពួត
សាក្សុះចុនចាត់ការព្រុំព្រះរាជវ៉ែព្រុំឲ្យចាំនឹងតែ ហើយក៏ចុនបង្ហាញ
យោបល់ដំណាស់ថា ព្រះមហាសត្វត្រែតអង្គនេះ ជាពួជស្តេចយាងតាម
ជាមិត្តភក្តិលេងយើង មិនតែលើកកូនយើង ថ្វាយព្រះអង្គទេ ប៉ុន្តែបើយើង
មិនត្រូមថ្វាយ មុខជានឹងមានមន្តាយៅថ្ងៃក្រោយមិនខាន, ដូច្នេះ
តើយើងគួរដោះស្រាយដូចម្តេចនេះយ៉ាំងណា ! ។ ខណៈនោះ ត្រូវអគ្គិម្ចាស់
មហានាម ជានឡើងថ្លែងថា « ខ្ញុំមានកូនក្រមុំជាស្រីខ្ញុំម្ចាក់ ឈ្មោះ

វាសភខត្តិយា(១) រួចពាំស្អាតជាតល្មមលើកថ្វាយទៅស្តេចនោះចាន ។ ។ ព្រះពរវន្ទាន្តុង្ឃ្រៀងអស់ ចានយល់ព្រមតាមមហានាម ទើបប្រើខ្ញុំតឱ្យនាំតគ្មានទៅថ្វាយព្រះបាទមហេសនទ័រញ្ជាថា ព្រះអង្គលព្រះបន្ទូលជាខ្ញុំព្រមលើកដង្តាម្ចាក់ ថ្វាយព្រះមហាក្សត្រ តាមព្រះពរបំណងហើយ នាងនោះឈ្មោះវាសភខត្តិយា ត្រូវជាបុត្រីមហានាម ។ កាលខ្ញុំតកំនាំតគ្មានទៅទូលព្រះកោតាមដំណើរ ។ ទើបព្រះមហាក្សត្រមានបន្ទូលថា បើពិតមែនជាការប្រពៃហើយ តែខ្ញុំថាបណាស់ ព្រោះធម្មតាពួកសាក្យៈប្រើនមានតតត្បុតអាក្រក់ ដូនយកខ្ញុំបំរើខ្លួនមកបន្ទុំថា ពួកសាក្យៈដែរ ដូច្នេះអ្នកឯងគប្បីយកស្ត្រីណា ដែលមិរិកាតអាហារដ្ឋ ដុំនឹងផ្តុតទើបបរិសុទ្ធ។ កាលខ្ញុំតកំនាំព្រះពរសាសន៍នេះទៅថ្វាយដំណឹងដល់ពួកសាក្យៈវិញ ។ ទើបព្រះអង្គម្ចាស់មហានាមទ្រង់យថា ល្អហើយអ្នក រួចតាំងបង្គាប់ទៅថាវស្រីដែលទ្រង់បំរុងលើកថ្វាយទៅស្តេច ឲ្យស្អិតស្អាងត្រឿងអលង្ការរួចក៏ហៅឲ្យមកបរិភោគអាហារជាមួយទ្រង់ ។ កាលខ្ញុំតឃើញដូច្នោះ អស់សង្ឃឹមយតទៅទៀត ទើបនាំទៅកាន់ក្រុងសាវត្ថី ។ ព្រះបាទមហេសនទ័ ក្រោយដែលកាលខ្ញុំតថ្វាយពតិមានសព្វគ្រប់ ទ្រង់មានព្រះពរជាមួយនឹងសោមនស្ស

១- ក្នុងមន្ទិលសូត្រទីបញ្ចប់ថា នាងនេះត្រូវជាក្មួយនៃនាងមុណ្ឌា ដែលជាខ្ញុំបំរើព្រះអង្គម្ចាស់មហានាម ហើយដែលព្រះអង្គម្ចាស់នេះ ជាអ្នកសង្គ្រាសនាងមួយ តាំងពីកើតបាននាងវាសភខត្តិយានេះ ។

ជាអនេក តំតាំងនាងនោះធ្វើជាអគ្គមហេសីធំលើសស្រីស្នំ ៥០០ នាក់ ។
មិនយូរប៉ុន្មាន ព្រះនាងបានប្រសូតព្រះកដនុសមួយព្រះអង្គ មានសម្បុរ
ដូចមាស ទើបចាត់បុរសម្នាក់ឲ្យយកដំណឹងទៅទូលព្រះអយ្យិកា ឲ្យបាន
ជ្រាបថា ព្រះនាងប្រសូតបុត្រហើយ ។ សូមឲ្យដាក់នាមដល់អយ្យបុត្រនេះ
ផង ។ ចំណែកខាងបុរសនោះ ដាមនុស្សត្រេកចក្ខុដ៏ចម្រើនផង ស្តាប់ពាក្យ
ជាជួនពរកេងិយាយមិនឮស្តាប់ឮតែរឿបពាប់សរសើរតែភ្លាមសំណាងម្តាយពរក
នោះមកដល់ហើយមួយថា វល្លកៈ ។ (ប្រែថា គាបចិត្ត) គឺស្មានថា ជាជួន
នោះដាក់ឈ្មោះឲ្យពរកថា វិរូឍកៈ គឺកំណត់ពាក្យនេះយកមកទូលស្តេច
វិញ ។ ព្រះមហាក្សត្រគឺដាក់នាមដល់ព្រះរាជបុត្រ តាមអាមាត្យតម្រង់
នោះទៅ ។ មួយទៀតដោយព្រះជន្មនៃព្រះបរមរាជ វនៃព្រះពុទ្ធដាច្បាស់
ក្នុងគគក ព្រះមហាក្សត្រគង់តាំងព្រះរាជបុត្រ ក្នុងតំណែងនៃសេនាបតី
តាំងពីទៅជាកុមារតូច ។

លុះព្រះរាជកុមារបានព្រះជន្ម ១៦ វស្សា មានព្រះរូបឆើតក្នុងចន្លោះ
សេងខាងត្រកូលព្រះអយ្យិកា ទើបសុំពរនុញ្ញាតអំពីព្រះរាជមាតា តែព្រះនាង
បានឃាត់ថា «កុំទៅឥតកូន ប្រុកព្រះអយ្យិកាកូនឯង នោះឆ្ងាយណាស់» ។
ទោះបីឃាត់ខាំងយ៉ាងណា តែព្រះកដកុមារនោះតែងទូលសុំទៅរាល់តែបាន
ទើបទៅក្រាបបង្គំលាព្រះមហាក្សត្រ ចេញរំណើរទៅដោយមានព្រះរាជ-
បរិពារយ៉ាងច្រើន ដង្ហែជូនព្រះអង្គទៅផង ។ ឯព្រះនាងវាសភខត្តិយាជាព្រះ

វិមាតា ចាន់ឆ្លើសារសម្ងាត់ទៅមុន ហ្វាយដំណឹងដល់ម្ចាស់ថា «ខ្ញុំម្ចាស់ នៅឯនាយចាន់សេចក្តីសុខសប្បាយជាទេ ប៉ុន្តែឥឡូវនេះ ព្រះអយ្យបុត្រ មានបំណងចង់មករស់នៅទីនេះ ដូច្នេះ សូមម្ចាស់កុំមានសេចក្តីទើសទាល់អ្វី សូមទ្រង់ប្រោសទទួលមួយគ្រាផងចុះ» ។ បំណែកភួងសាក្យៈ លុះបើក សំបុត្រនោះមើល ក៏ប្រកាន់ថា «យើងមិនត្រូវនឹងចំនួនសោះទេ» ទើបទៅគេណែនាំនូនបណ្តាក្សត្រក្នុង ។ តាំងពីនៃត្រកូល ឱ្យមករស់ នៅទទួលព្រះអង្គម្ចាស់សេនាតិវិញ ។ លុះទ្រង់ឃាត់មកដល់ កុមារទួច ។ តាំងនោះ ក៏នាំទៅសំណាក់នៅសណ្ឋាគារមួយ ។ លំដាប់នោះ ពួកសាក្យៈ នៃមានភរិយាប្រចន្ទ្រលៀលជា ៩ ឬ ១០ នាក់ទៅហើយ ក៏នាំគ្នាមកបង្ហាញខ្លួន ឱ្យព្រះពជកុមារស្គាល់ ហើយបង្គំលក្ខាប់ព្រះនាម ថា នេះត្រូវជាព្រះអយ្យកោ នេះត្រូវជាព្រះមាតុលា (ឪពុកមា)(*) ។ ឯព្រះពជកុមារមិនឃើញមានអ្នកណា ហ្វាយបង្គំព្រះអង្គឯសោះ ក៏សាកសួរ ទៅព្រះញាតិថា «ចុះនេះទៅណាអស់ហើយ ចានជាមិនឃើញមកសម គួរនឹងខ្ញុំ?» សាក្យៈដែលនៅតន់ជិតក៏ទូលថា «ក្មេង ។ ទៅលេងនៃត្រកូលអស់ហើយ នៅសល់តែបាស់ៗទេ» ។ នៅទីសាលសំណាក់នាស្រុកតិលពស្តុនោះ គេបានថ្វាយគ្រឿងសក្ការៈ ដល់ព្រះពជកុមារ

(*)- ជាឧដាពួកសាក្យៈមិនឱ្យក្រួកក្មេងៗមក ព្រោះមិនចង់ឱ្យចំណុះព្រះពជកុមារ, បំណែកបាស់ៗ ត្រូវតែព្រះពជកុមារថ្លាយបង្គំគេវិញ ព្រោះគេបាស់ជាងខ្លួន ។

ជារៀងច្រើន ។ កន្ទួងមកបានពីរបីថ្ងៃ ទ្រង់និវត្តមកគាន់ព្រះពជ្ឈាធីសាវត្តី វិញ ។ ក្រោយនោះ, ចាវស្រីម្នាក់ បានយកទឹកមកលាងសន្ទឹកក្តារត្រង់ កន្ទែងព្រះពជ្ឈកុមារគន់, លាងបណ្តើរ ស្រែកដេរបណ្តើរថា «កន្ទែងនេះ ឯង ដែលកូនមេវ៉ាសកទត្តិយាឥឡូវ" ។ ចៃដន្យអ្វី មានសហការីព្រះ ពជ្ឈកុមាម្នាក់ កាលចេញទៅបានក្មេចអាវុធចោលនៅទីនោះ ដល់ត្រឡប់ មកយកវិញ ស្រាប់តែឮនាងនោះ កំពុងតែប្រទេចផ្តាសា ព្រះពជ្ឈកុមារជា អនេកប្បការ, ទឹកធ្លាក់ណាស់ ក៏សួរទៅស្ត្រីនោះ ទើបគេប្រាប់ថា អ្នកឯង មិនដឹងរឿងប្ត មេវ៉ាសកទត្តិយាជាកូនបំរើទ្រង់មហានាមទេតើ ។ បាន ដំណឹងនេះគាល ណា បុរសនោះតាំងយកមកបរិហារ ប្រាប់សហការីរបស់ ខ្លួនដឹងឮសុសសាយគ្រប់ៗគ្នា កេតទៅជាគោលហាលម្ជុយយ៉ាងនេះ ។ ព្រះពជ្ឈកុមារទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏ទឹតតូចព្រះទ័យ ចង្អុំខ្ញុំ ខ្លួនថា "មិនគិតទេ រឿងនេះ លើកខ្លួនសិនចុះ ចាំមើលអញបានសោយរាជ្យ គាល ណា នឹងកាត់តបតាមអស់នោះ ឲ្យកឈ្មាមបំពាក់គាលឆ្កាងនោះ វិញ" រួចរះទៅដល់ក្រុងសាវត្តីមានពួកមន្ត្រីខ្លះ បានយករឿងនេះទៅគ្រប ទូលព្រះមហាក្សត្រ ។ ព្រះពជ្ឈាទ្រង់ព្រះឆ្នាតតួង ទឹកព្រះទ័យនឹងពួកសាក្យៈ ដែលហ៊ានមើលងាយព្រះអង្គ តើយកខ្ញុំបំរើមកឲ្យធ្វើជាមហាស័ដ្ឋុច្ចៈ ទ្រង់ឈានព្រះឧស្ឋថា «យើពួកសាក្យៈ! ម៉ឺនសមបើហ៊ានប្រព្រឹត្តអំពើថាក គាបជុច្ចៈសោះ» រួចទ្រង់ដកហូតងារព្រះអគ្គមហេសី នឹងព្រះពជ្ឈកុមារ

ពីតំណែងអស់ ប្រពន្ធហាន:ស្ទើនឹងខ្ញុំបំរើ ។ កន្លងមកបាន ៣ ថ្ងៃ ព្រះ-
សម្ពុទ្ធទ្រង់យាងទៅគាន់ព្រះពន្ធនិវេសន៍ព្រះចៅអង្គនេះ ។ ព្រះមហាក្សត្រ
ទ្រង់ធ្វើការកិច្ចរួច មានព្រះបន្ទូលទៅគាន់ព្រះមានព្រះភាគថា "បពិត្រ
ព្រះអង្គ ខ្ញុំព្រះអង្គ ទើបនឹងបានតតិមានថ្មី ។ នេះថា ព្រះឈ្មោះតិព្រះអង្គ
បានលើកខ្ញុំបំរើ រមស់ខ្លួនមកជាយខ្ញុំព្រះអង្គ ឥឡូវនេះ ខ្ញុំព្រះអង្គបានគាត់
តាល់ចោលតាំងតែយោនឹងបុត្រ ទុកហាន:ឲ្យទៅស្ទើនឹងភ្លាវត្រាវវិញ" ។
ព្រះបរមសាស្តាទ្រង់មានតុន្ទដីកាទៅព្រះចៅវិញថា ម្នេហាពង ! ពិតមែន
ហើយ ពួកសាក្យៈធ្លៃបែបនេះ មិនសមរម្យទេ, ល្អើយបុះ តថាគតសូម
ថ្លាយយោបល់ដល់មហាពងថា នាងជាសកទាគិយា ពិតជាធីតាខត្តិយពង
ហើយចែមទាំងបានអភិសេក យ៉ាងតធឹតតន្ត្រីនឹងមហាពងទៀតផង, ឯ
រឿងនុះ កំដាបុត្រក្សត្រដែរ ព្រោះថា តាមរំនៀមទំលាប់តាំងពីបរមបុពណ
មក មិនដែលយកគោត្តខាងមាតា ជាប្រមាណទេ គឺគោត្តខាងបិតាទេ
តើមហាពង ទើបយកជាប្រមាណបាន ", រួចទ្រង់លើកដៃតតាំងត្រង
នាយ ដែលមានជំណើរស្រេចទំនងរឿងនេះដែរ សំដែងឲ្យព្រះកញ្ញាទ្រង់ព្រះ
សណ្តាប់ទៀត ។ ព្រះនរបតីបានទ្រង់ព្រះសណ្តាប់ធម្មតាចប់ តំមាន
ព្រះទ័យធូរស្បើយទៅវិញ ហើយព្រះអង្គបានប្រពន្ធជំណែង អគ្គមហេសី
ទំនឹងសេនាបតីដល់ព្រះនាងឥ ទំនឹងព្រះពន្ធកុមារ ដូចដើមវិញ ។

(នៅមានត)

ខ្មែរអក្សរសាស្ត្រ

ច្បាប់ស្រី

ព្រះរាជនិពន្ធ

ព្រះបាទសម្តេច ព្រះហរិវរ្ម្យកមាតវ្ស្យកធិបតី

ព្រះអង្គឌួង ព្រះបរមរាជា

ឧត្តមប្រាជ្ញ បាប៊-ពិន និពន្ធបណ្ឌិត

នាយការិយាល័យនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

ពិនិត្យតាមច្បាប់សម្រាយនិងចារ

ច្បាប់នេះ

បែងអំពីច្បាប់ស្រី ១០៨ ចំពូក :

ស្រីសុចរិត ៨ ចំពូក		ស្រីចោក	១៨ ចំពូក
ស្រីមាយា ៤០ ចំពូក		ស្រីអាស	២០ ចំពូក
ស្រីបង្កិនប្តី ១០ ចំពូក		ស្រីមាក់ងាយប្តី	១២ ចំពូក

បែងអំពី :

ចិត្តស្រី	៣គោល
បុរសទំនឹងស្ត្រីចង់មេត្រីដោយហេតុ	៨ ប្រការ
ភរិយា	៧ ចំពូក
ស្វាមីសង្គ្រោះភរិយា	៥ ស្ថាន

លំនាំដើម

ព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សពេមាតសស្សពេធិបតី (ព្រះអង្គ ឌួង-ព្រះបរមរតនកោដ្ឋ) ព្រះអង្គជាអគ្គបណ្ឌិតខាងទេតិសាស្ត្រ, ធម្មសាស្ត្រ, អក្សរសាស្ត្រ ទឹងជាតវិឯកខាងតាត្យឃ្លោង ទ្រង់ជ្រាបក្បួនតាត្យយ៉ាងដំខាញ ចានទ្រង់ព្រះពន្ធនិពន្ធរឿងឆ្លងៗ ច្រើនបែប ជាច្បាប់ខ្លះ ជារឿងប្រលោមលោកខ្លះ ។ ខាងច្បាប់ មានច្បាប់ស្រីនេះជាដើម ។ ខាងរឿងប្រលោមលោក មានរឿងកាកីជាដើម ។

ច្បាប់ស្រី ទ្រង់ព្រះពន្ធនិពន្ធក្នុងឆ្នាំមហាសកពស ១៧៩៩ ពុលសកពស ១១៩៩ ពុទ្ធសកពស ២៣៩០ គ្រិស្តសកពស ១៨៣៧ ជាលាព្រះជន្ម ៤១ ព្រះវស្សា ។

រឿងកាកី ទ្រង់ព្រះពន្ធនិពន្ធក្នុងឆ្នាំមហាសកពស ១៧៣៧ ពុលសក-ពស ១១៧៧ ពុទ្ធសកពស ២៣៩៨ គ្រិស្តសកពស ១៨១៨ ជាលាព្រះជន្ម ១៩ ព្រះវស្សា ។

ច្បាប់ស្រីនេះ មានគោលបាំកសំខាន់ណាស់ ដោយទ្រង់ព្រះពន្ធ-និពន្ធតាមបាលី សុត្តន្តបិដក ខុទ្ទកនិកាយ ត្រង់អស័តិនិបាតជាតក ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់សំដែងចំពោះតំកូលក្សត្រិយ៍ ៥១០ រូប ត្រង់ឆ្នោកុណាលស្រះ (ស្រះជាទីគាស្រ័យនៅនៃពួកតាវ៉ើ) ជិតក្រៃហេមពាន្ត ។

ខ្ញុំគោរពចំពោះច្បាប់នេះណាស់ ហាមឃាត់យ៉ាមពិនិត្យធ្វើដង្កាត់ ចំពោះបទណាដែលតក់ខ្លះ ដោយការចារសរសេរខុសគ្នា ឲ្យត្រូវតាមច្បាប់សម្រាយនឹងជាលើដើមឡើងវិញ ហើយរបៀបភ្ជាប់ឡើង ដើម្បីរក្សាទុកនូវថ្លៃព្រះហស្តនៃព្រះមហាក្សត្រខ្មែរ ដែលទ្រង់ដាក់ឧត្តមលក្ខណៈនឹងតុន្តចក្រ-អាណាចក្រឲ្យតំរង់ទៅ នឹងដើម្បីជាសាធារណប្រយោជន៍ដល់ជនជាតិខ្មែរដែលត្រូវការរក្សាទុកនូវបវេណីដ៏ល្អរបស់ជាតិទៅអនាគត ។

ខ្ញុំសូមទទួលអំណរគុណយ៉ាងខ្ពស់ ចំពោះអ្នកទទួលភារកិច្ចក្នុងការចែក-ខេត្ត អតីតទៅក្រុមដំរេបញ្ជីនៃព្រះរាមាជកិច្ច ទំលំទៅទៅសង្កាត់លេខ ៦ ក្រុងភ្នំពេញ ដែលបានធ្វើអំណោយច្បាប់ដើមច្បាប់ស្រីនេះទុកជាព្រះរាក្តីនៃព្រះមហាក្សត្រខ្មែរតរៀងទៅ ។

១-៨-២៤៨៨-១៩៥៥

ប៉ាប-ពិន

ច្បាប់ស្រី

បទកាកគតិ

អហំ ឆាមំ កដច្ឆុឆ្បំ រុន្ធោ រញ្ញោ កម្មដ្ឋានតវេ
ទនេស្ស អត្តោ អាចរិយោ បរិមបិតា , អត្តិអញ្ញាជបុត្រ ក្នុង
ពជ្ឈបរិសុទ្ធ ក្រុងកម្ពុជា នាមអនុជនាថ ប្ចូឡជាតិក្សត្រា យល់ទូវអត្ថ
អាចារ្យចែងទុក ។ ខ្ញុំកាយថាលិ ព្រះអសីតិ ខ្ញុំជាតជាតក សំដែង
លក្ខណា ស្រីមាយាអក្រក់ , ចិត្តចើត , អាសលាមក, បង្កិន , មាក់ងាយ,
សំដែងលក្ខណា ស្រីមានអរិយា សុចរិតកបកាយ ឲ្យតស់ប្រុសស្រី
លោកិយតាំងឡាយ ដឹងដោយបរិយោយ មាយាស្ត្រី ។ ឯអត្តិអញ្ញាឯង
គន្ថតិតាវចែង ពីព្រះបាលី ជាគាថ្យាគាថ្យា ពណ៌នាសេចក្តី បទីជា
ច្បាប់ស្រី ទុកតាមអត្ថ ,

ពុទ្ធិសាសនា អតិក្កន្តា អសីតិ នោ សន្តានិតា
ទ្វេសហស្សេ[1] មហាសកពេ ឯកសប្តមត្ថកេ[2] ។
ចុល្លសកពជវេ ពាទំមួយរយេ សិបប្រាំ[3] ឆ្នាំច្រលំ ថ្ងៃសៅរ៍ទៀតទេ

១- ច្បាប់ស្រីនេះព្រះកុណាបមភោជ្ជិរ្ញវង្សព្រះពន្ធិតាក្នុង ព.ស. ២៣៨១ ។

២- ឯក ១ សប្តតិ ឯកុ ៤ ដូ ៩ រួមគ្នាជា ម.ស. ១៧៤៩ ។

៣- ប.ស. ១១៤៩ គ.ស. ១៨៣៧ ក្នុងព្រះជន្ម ៤១ ។ ព្រះពាជាអង្គនេះ ទ្រង់ច្រះសក្តព
ព.ស. ២៣៣៩ ។ ទ្រង់សោយរាជ្យ ព.ស. ២៣៩១ ក្នុងព្រះជន្ម ៥២ ។ ទ្រង់ព្រះតិរង្គត
ព.ស. ២៤០៤ គ.ស. ១៨៦១ ក្នុងព្រះជន្ម ៦៥ ។

នារីខុសប្ដីដប់ ពេចរិះឯឃប់ យកមួយសេសមាំង, រៀបរៀងសច្ចៈ
ជាបរគាគតត៌ ដំណាលទំនង ស្រីជួស្រីជា តាមចាលិចង ទុកជាគន្ធង
ក្លួនច្បាប់តរៅ ។ គ្រាន់មើលគ្រាន់មាន ចិត្តចាំប្រៀនប្រាណ កុំឲ្យ
អាស្រូវ កុំគ្រាប់មាយា ទុកជាធ្វើត្រូវ កុំគ្រាប់ចិត្តប្ដូរ ទុកជាស្មោះស្មាន,
កុំគ្រាប់ស្រីគាស តិតថាជ្រីតខ្មាស អៀនរើនរស់ប្រាណ កុំគ្រាប់ប្ដីខ្ចី
ថាមិនសាមាស្ស កុំគ្រាប់សន្តាន មាត់ងាយស្ញាម៉ ។ តិតថាគួរបេ មិនគួរ
ស្ងើរស្នេហ៍ ភប់រកដាប្ដី មារយោគាំជ្រុំ ប្លុងចាំត្រាប់ស្រី សុទ្ធសឹងអប្រិយ
គ្មានល្អមួយខ្សៀយ, គួរត្រាប់តួរត្រង់ គួរចាំគួរចង គួរកុំកន្ដើយ
មារយោសុចរិត ល្អតិតជាត្រើប ស្រីណាត្រាប់ហើយ ហៅប្រសើរស្រួល
គួរម៉ាលឲ្យប្លាស់ គួរចំឲ្យណាស់ តាមដោយវិធី អាចារ្យចែងចង
កន្ត្រងសេចក្ដី ក្នុងព្រះចុលិ នីតាយសុត្តា ។ ។

នេះទំនឹងសំដែង ចរិយាយថាវិចង ដើមបទ អត្ថា - ឥតិ ឥត្ថេ-
ឥតិ សុចរិតា ឥត្ថិលក្ខណា មង្គលច្ចេតតិ, ប្រែថាស្រីជា
កើតកបលក្ខណា ដោយខ្លួ សុចរិត មង្គលច្រាំបី ឲ្យស្រីពិនិត្យ
ចាំយកជាក្រឹត្យ គ្រប់រូបស្ត្រី ៖

១(១) - ដើមបទគាថា លោកថា ស្រីជា សុចរិតកក្តី

១- ពីព្រឹមនេះទៅមុខ ត្រង់នៃលជាកំលេខដើមៗ ទាំងប៉ុន្មាន គ្រាន់តែជាសញ្ញាប្រាប់ចំនួន ប៉ុណ្ណោះ មិនឲ្យអានទេ ។

ឫកពបស្រួតត់ ធ្ងន់ធ្ងត់សំដី ការកន្ត្រោសស្រី បរិសុទ្ធមែនមួន,

២- លោកថា ស្រីត្រង់ កាន់សុចរិតធ្ងន់ គំនិតបេះស្មួន អស់ទ្រព្យសម្បត្តិ ប្រយ័ត្នថែជួន ទុកជាគ្មានប្តី មិនមានប្រមាទ ។

៣-លោកថា ស្រីឆាប់ កាន់សុចរិតខ្ជាប់ ទស្សាស៍សង្វាត ធ្វើការសន្សំ តឿនខ្ចីឲ្យឃ្នាត ឲ្យខ្ចីឲ្យហាត មិនមានស្ទួមដៃ,

៤- លោកថា ស្រីទ្រាន់ សុចរិតអង់អាច បេះតធ្យាស្រ័យ ញាតិត្រឿនទៅមក តបតែងសែវៃ ទោះជនជាខៃ ក៏តបតាមពិត ។

៥- លោកថា ស្រីស្អាត សុចរិតគ្មានឃ្លាត មែនមានតំណិត បេះរៀបការការ ភ្នាក់ងារស្រីពិត រណ្តាប់ផ្តាំបង្គត់ ប្តីប្រាប់រៀលា,

៦- លោកថា ស្រីស្មោះ កាន់សុចរិតខ្ពោះ ចាំចិត្តស្នេហា តែនឹងអង្គប្តី ឥតបរភេ ស្មុគ្រស្មោះស្មើជា និត្យនេះរៀបរៀង ។

៧- លោកថា ស្រីស្លូត សុចរិតហូត អបអត់ឥតស្ទើង តាមពាក្យប្តីផ្តាំ បង្រៀនចាំទុកខ្មៀង ពោលពាក្យមិនយឿន មិនឃ្នាតសត្យា ។

៨ លោកថា ស្រីស្មើ សុចរិតសរសើ អាចរងជាន់ ទម្ងន់ចិត្តប្តី ទោះបីខ្ញុក្តា ក្សត្រក្រមែចម្តា អាចទទួលច្រាណ ។

សុចរិតច្រាំបី ជាមង្គលស្រី ប្រសើរក្រមាន អ្នកមានផ្ទះល្អ ឲ្យដល់នេះចាន ស្រីណាអាចធ្យាន ចិត្តចាំរៀនយក, ពាំរក្ងុំប៉ាច់ ហៅស្រីមហាគាប់ លោកយ៉កម្រ ស្រីកាន់សុចរិត ប្រព្រឹត្តល្អិតល្អ ស្រីណាថា

ក្រ ធ្វើតាមពុំបាន ។ លោកជាស្រីខោះ ចិត្តអាក្រក់សោះ ស្អប់ដំបូន្មាន ផ្សាដោយសារចិត្ត ទុច្ចរិត សន្តាន បង្កើត ឆន្ទាគតិ, អាសវៈ, មានោ, ភ្លើដូច្រើនកល ក្រដិនចេះដល់ លែបខាងតុតាំ ថើចិត្តចង់ស្រាប់ ចង់ស្តាប់ហាក់ជា ងាយដាយសោះសា ចេះឯងឥតឯង ។ ឯក្រនឹងបួសប្អូ តិចខេយល់ក្រ កម្រៃក្រៃលែង ក្រៃគ្រោះមិនចង់ ប្រុងអត្តិត្ថស្នែង ក្រដោយចិត្តល្ងង់ ចំណងឹតណ្ហា , អំពើសុចរិត អធ្យាស្រ័យចិត្ត សំអាតទស្សាហ៍ ស្មើស្មោះសូតត្រង់ ឆ្ពត់ឆ្ពង់ក្រឹត្យា ប្រាំបីនេះណា សុចរិតប្រាកដ ។ ឯសុចរិតស្រី ឆ្ពត់ឆ្ពង់ស្វាមី លោកឲ្យអបអត់ ខន្តិអឿន ចិត្តខ្ជិន ចេះគេនថែបបង ឥតតែប្តីពត់ ម្តេចៗតាមបាន, មិនមានប្រកែក មិនមានដដែក ថាធ្វើមិនបាន គោះអឿនអន់អត់ សង្កិតចិត្តប្រាណ តាមចិត្តប្តីឆ្ងាន ម្តេចៗមិនថា ។ ប្បាប់នេះតួស្រី នៅនាលោកិយ ឆ្ពង់ចិត្តទស្សាហ៍ កាន់តែសុចរិត ជាក្រឹត្យថ្លៃថ្លា ឲ្យខ្ជាប់ជាក់ជា ចរិតសព្វថ្ងៃ , កាន់បានដូច្នោះ ខ្ញីឥតក្តើរឈ្មោះ ប្រសើរពេកក្រៃ ខ្ញីឥតបានសាន្តសុខ ចៀសខ្ពុំគួចង្រៃ ដល់បរលោកថ្ងៃ សោយសុខសួគ៌សិទ្ធ ។ សំដែងសេចក្តី ពី មង្គលស្ត្រី ប្រសើពេកពិត គ្រប់គាំងប្រាំបីក្រឹត្យស្រីសុចរិត ចែងចប់គាសិត តាមព្រះបាលី, គម្ពីរនិកាយ សំដែងអធិប្បាយ មង្គលស្ត្រី នេះនឹងតែងឯ សំដែងអំពី អសិតិនិ- បាតជាតក ។

ส่วนสัตว์ กุณฑลธนมหา มีมารดาอันกิร-
ติยังมีชีวิตอยู่ ๕ ปี, ก็พระสัพพัญญูพระ
อัครชินเจ้า ทรงพระมหากรุณาโปรดประทาน
ซึ่งเทศนาโอวาทสั่งสอนสตรีทั้งหลาย ดุจดังมารดา
ผู้ให้กำเนิดโดยชอบแล้ว ๆ พระอัครชินเจ้าผู้
ทรงพระกรุณาโปรดปรานแก่สตรีทั้งหลาย
ดังนี้แล้วก็เสด็จกลับคืนสู่พระนครสาวัตถี
ตามเดิม. ฝ่ายนางวิสาขามหาอุบาสิกา ก็
ตั้งอยู่ในโอวาทานุศาสนีของพระบรมศาสดา
ประพฤติปฏิบัติตามโดยเคารพ ๆ

ครั้นต่อมาภายหลัง นางวิสาขาก็ได้
ทำการมงคลอาวาหวิวาหะ ให้แก่บุตรชายของ
ตนชื่อว่า ปุณณวัฒนกุมาร ๆ ครั้นได้ทำการ
มงคลอาวาหวิวาหะแล้ว นางวิสาขาก็ได้ตั้ง
ปุณณวัฒนกุมารไว้ในตำแหน่งเศรษฐี ๆ ครั้น
ต่อมาภายหลัง นางวิสาขาก็ได้ทำการมงคล
อาวาหวิวาหะ ให้แก่บุตรชายของตนชื่อว่า
ปุณณวัฒนกุมาร ๆ ครั้นได้ทำการมงคล
อาวาหวิวาหะแล้ว นางวิสาขาก็ได้ตั้งปุณณ-
วัฒนกุมารไว้ในตำแหน่งเศรษฐี ๆ ครั้นต่อมา
ภายหลัง นางวิสาขาก็ได้ทำการมงคลอาวาห-
วิวาหะ ให้แก่บุตรชายของตนชื่อว่า ปุณณ-
วัฒนกุมาร ๆ ครั้นได้ทำการมงคลอาวาห-
วิวาหะแล้ว นางวิสาขาก็ได้ตั้งปุณณวัฒน-
ก

២- ស្រីមាយាឥតស្មែ ចូលដេកប្រើនប្រែ ទុនឱ្យស្វាម៉ ហាក់ដំនហាត់ណាយ ចង់ងាយរកខ្នី មោះប្តេះចក្តី ចង់រមែសក្តាណ,

៣- ស្រីមាយាលាយឆៃ ប្តីលក់ល្ងចបើក ក្តាលបលេញបាន ទៅរកគេឯង ប្រពៃឡើងស៊ើបសាន ហើយវិលមកផ្ទាន ដេកក្តៅត្រដើយ ។

៤- ស្រីមាយាឥតល្អិតឆ្ងល់ ប្តីតនិច្ចគាត់ ប្តីពាល់ខ្លួនហើយ គេឱនគេចវេះ បម្រះគោះតើយ ឆ្កើហាត់ឆ្កៀវហើយ មិនមានចំណង់, ។

៥- ស្រីមាយាអប្រិយ ប្តីមួរវៀរី ប្រកែកការណ៍ ដង្កើមជំកូច ហាក់ដូចមិនចង់ ព្រោះអាក់រឿនគ្នី មោះចង់ស្នេហា ។

៦- ស្រីមាយាក្រសេះ ប្តីនឹងមួរសុំ ណាប្រាថ្នាលាភ ឈឺក្បាលឈឺគោះ តែគោះឯង ឯងស៊ប់ចិត្តវា ឯងដែរខេ,

៧- ស្រីមាយាគោលើ ចូលដេកទំលើប្តី ឆ្កេងជាជល់ខែ ហើយស្រែកចង់ក្បែន ថាមិនទំនេរ ជល់ប្តីរាយវេរ នាំឱ្យមានមោះ ។

៨- ស្រីមាយាកប្បុខ៏ង ដឹងណាប្តីនឹង រួមរ័ក្សស្នាញស្ទុះ ជាស់គេឯងឡៅ រកក្តើងចន្ទុះ ព្រោះទឹងពុំខោះ ចង់ចាកស្វាមី,

៩- ស្រីមាយាមម្រើ ប្តីពុំដែលស្មើ ធ្វើមុខរវើរ ស្ងៀណស្រស់ក្ងៀណក្រៀម ក្ងៀណស្រួមក្ងៀណស្តី ព្រោះធុញគ្រាន់ប្តី តូចចិត្តគំនិត ។

១០- ស្រីមាយាខ្វិចខ្វន់ ចំណីប្តីចង់ ពុំឲ្យតាមចិត្ត ចង់
មោះឲ្យនេះ បង្ហើរចេញតែត ព្រោះជំនាញចិត្ត តែតបែកចេញក្រៅ,

១១- ស្រីមាយាលាយអាស ចង់ឲ្យប្តីក្រុស ចេញតែលំនៅ
ទីដ៏បានចើកលេង គ្នាឯងឯកក្រៅ ប្តីមានបើកៅ អាឯងតទ្វឹក ។

១២- ស្រីមាយាលឿចលែន ប្តីកៅទ្វាយលេង តាល់
ល្ងាចតាល់ព្រឹក សើចលេងតាមចិត្ត គ្មានតែតគ្មានទឹក គ្មានក្តុកក្តួក
អាណិតស្រឡាញ់,

១៣- ស្រីមាយាមានោមានះ ប្តីមកដល់ផ្ទះ ជាទុក្ខគ្នាន់ក្នាញ់
កញ្ជ្រៀវកញ្ជ្រែវ ក្រមូរកន្ទាញ់ ឃ្លីតចិត្តសស្រាញ់ សស្រួលកៅផ្សឹង(១) ។

១៤- ស្រីមាយាលែបខាយ ឃើញមុខសហាយ ធ្វើយំ
ឲ្យដឹង អង្គុយសូតស្លៀម សញ្ជប់សោតសឹង ធ្វើប្រាប់ដំណឹង
តិចខ្លួនទុក្ខទាល់,

១៥- ស្រីមាយាលាយអាស ឃើញប្រុសមិនខ្មាស ធ្វើ
រិះរកកល សាកសួរសុំថ្នាំ ផ្តែផ្តាំភ្លាមៗទាល់ មោះចង់ជួបយល់
មុខមិត្តក្តីក្រៅ ។

១៦- ស្រីមាយាសស្រាញ់ ឃើញមុខសំឡាញ់ ដែលចង

១- សម័យនិពន្ធប្លាប់នេះ ប្រើពាក្យនេះថា " ផ្សឹង " បានជាមានសម្ផស្សពុងខ្លួន តៅ
ឃ្លាមុខថា ជឹង-សឹង-ដំណឹង ។ តែសម័យបច្ចុប្បន្ន ប្រើពាក្យនេះថា " ផ្សេង " ។

ចិត្តទៅ មើលៗហើយសើច ធ្វើគ័ចស្ងៀមទៅ បន្ទិចមើលទៅ ឃ្យប្រុសស្នេហា,

១៧- ស្រីមាយាតែកក្តិត(១) ឃើញប្រុសត្រូវចិត្ត ក្រឹមត្រូចចិត្តា ដាក់ក្អែកមមុយ កន្ទុយនត្រា លួចមើលរេញញឹមធ្វើភ្លើយ។

១៨- ស្រីមាយាក្តិចក្តាក់ ឃើញប្រុសសំឡក់ ភាន់នេះនោះហើយ លើកឡើងចើចថែ លួចមែរមើលដើយ ថើបខ្យែតធ្វើតើយ ញញឹមខោលចេញ,

១៩- ស្រីមាយាតំតៗ ឃើញប្រុសត្រូវចិត្ត ធ្វើជាម្នាម្នេញ ជិនឆ្នន់ត្រគោះ គឺមានតែតេញ ចិត្តចង់លេញ សេតសុខស្នេហា ។

២០- ស្រីមាយាវេះវៃ ឃើញប្រុសមានតេ ខៅផងប្រែខ្នាធ្វើជាត្រងើយ កន្ទើយសោះសា តែស្វាត់មើលភ្ញា ស្រដីចប្រាក,

២១- ស្រីមាយាចេះត្តិត(២) ឃើញប្រុសធ្វើស្ងួច ខ្ទិយស្ងួរសាក ខៅផ្ទះខៅវាល ស្រើបស្រាលសើចក្អាក ខើបបន្ទិចពាក្យ ខៅប្រុសលេញ ។

២២- ស្រីមាយាមែនមួន ឃើញប្រុសតំពួន កំរក្រេក

១-២ សម័យបាត់ពន្ធប្បាច់នេះប្រើពាក្យនេះថា "ក្តិត" ជានដាមានសង្ឃស្សជុំដង្ហិនទើបឮខុទ្ធ ថាស្ងួច ។ តែសម័យបច្ចុប្បន្នប្រើជា "ក្តាត់" ។

ចេញ គាប់ម្រាមដាំដប់ ពត់សព្វដៃមិញ ដូរតែនឿនស្រឡាញ់
នឹងប្រុសអាត្មា,

២៣-ស្រីមាយា ។ ល្បែង យើញប្រុសធ្វើក្មេង ឲកដើងព័ន្ធ
គ្នា ទៅតឆ្កែដើ ធ្វើស្តីម្នាក់វា លួចឈ្មៀងខេត្រា សំឡក់ធ្វើហ្លួយ ។

២៤-ស្រីមាយាតិរិយា យើញប្រុសធ្វើជា ប្រហោង
ព្រងើយ ខនគូសដីលេង តែឯងកន្តើយ លួចសំឡក់ហើយ ញញឹម
ខនបុះ,

២៥-ស្រីមាយាលង្វិចលែ្បង យើញប្រុសធ្វើឯង លេងខេះ
លេងខោះ លេងលាយអំពើ លេងធ្វើម៉ែះម៉ាំះ ឲ្យប្រុសកាន់កោះ
ត្រេកត្រអូរហ្លួយ ។

២៦-ស្រីមាយាឆ្នាំឆតិត យើញប្រុសដៃក្តិត សំពត់អាវសៃ
ស្ងួមបង្កែះផ្អៀង មើលមៀងចាំប្រៃ សំឡក់រៀលរៃ ឈរនៅព្រងើយ,

២៧-ស្រីមាយាអំពើ យើញប្រុសប្រែធ្លី មិតពត់ខ្លួនដើយ
មុខមៀងក្រឡេក ចុងក្បែកវើយ។ អង្គុយព្រងើយ ហាក់មិនស្នេហា ។

២៨-ស្រីមាយាយល់ប្រុស ធ្វើអ្វីឲ្យជ្រុះ ដជុះរុះរ៉ា មៀង
មើលយល់ជាក់ ប្រែកក្តែធ្វើជា រើសរួចហើយវា មើលទៀតញញឹម,

២៩-ស្រីមាយាឆ្នើងឆ្ងិត យើញប្រុសស្អាតស្អិត លាបប្រេង

ប៉ប្រឹម ដាត់មុខណាំខ្លួន ក្រមួនមាត់ទឹម ស្បែកសំពត់ត្រឹម ដណ្តាប់ពាតប្លឹ។

៣០- ស្រីមាយាឥតស្រាន្ត យើញប្រុសហើយចាន សរ. តើចំណី ក្តីចក្តីណា ហៅគ្នាមកឆ័ ផ្តោះឆ្ងងសំដី ញញឹមបញ្ចើ,

៣១ - ស្រីមាយាស្រើបស្រែសំយើញប្រុសសម្រស់ សម្រួលគំតើ ដេកដើរឈរអង្គ - គុយគងនឹតក្តើ អំតើបញ្ចើ បញ្ចូលស្នេហា ។

៣២- ស្រីមាយាលាយបើក ប្រុសចាត់ដើរល្បើត ឆ្លើតឆ្លៀត លលា ស្បែណេះចង្កៀណយំ ស្បែណពុំចរចា ដាំតរក្រាញ្ញា ចង់សេតកាមគុណ ,

៣៣- ស្រីមាយាត្រេសត្រើតត្បៀ កំណាញ់ឥតគិត មិនចង់ធ្វើបុណ្យ មិនធ្វើទានសីល ត្រែះខ្លៃលសីចស៊ីន ស្ងួចាយដាំចង្កូន ប្រុសអស់ព្រាណ ។

៣៤- ស្រីមាយាលាមក ចេះតែគុហក រៀចចង់ផ្តែងជាន កំភរកំភូត រកស្តូតត្រង់គ្មាន វិលវេះមិនមាន ខប់ខល់សំដី,

៣៥- ស្រីមាយាញ៉ែកញ៉ែក យើញប្រុសបញ្ចុក សរតើចំណី ក្នេងស៊ីឯងសើច គេចកើចសុំខ្ចី ឲ្យប្រុសភ្ញាប្រើយ ដឹងប្លុកខ្លួនឯង ។

៣៦- ស្រីមាយាកន្ទេង យើញប្រុសចុងក្នេង តនេបប្រែខ្សែង ក្នេងធ្វើម្តេចគាប់ ធ្វើត្រាប់ជាលែង ឲ្យប្រុសយល់វែង ចាប់ចិត្តស្រាលស្រើប.

(នៅមានត)

រឿងសត្វសិង្ហ

របស់ឃ្មុំពេញវ័យ ឥន្ទ លោក ប៊ី-ប៊ី បកប្រែពីសាស្ត្រាស្ទឹករ៉ាត

កាព្យពាក្យ ៣

*អហំអញខ្ញុំសូមវន្ទី លើតកវគេញ្ចលីឧទគតិវាទ ដូចតលគោសុម
ឋមុជាតិ ក្រាបក្រោមវរបាទយុគលំ ។ នៃព្រះអរហំស្រីសម្មា ជាមគុដ
លោកជាទីតាំង ព្រះអង្គជាសុខនិទ្ទុក្ខ ជាគ្រូអស់ទាំងឥន្ទ្រាព្រហ្ម ។
ខេវតាគន្ធព្វគ្រប់គ្រុងា ព្យាដរនាគាមរយក្ខយែម មនុស្សសត្វសុរសិទ្ធគត
ត្តូចធំ មូលមកបង្គំគ្រាបប្រួញប្រាណ ។ ព្រះមង្គលទ្ធានសព្វហ្មឥសត្ត ទាំ
កាត់ទ្ធរវដ្តសង្សារសាន្ត ផុតពីកងទុក្ខសុខសម្រាន្ត ជាត់ដល់ត្រើយត្រាណ
សិវាលយ ។ ព្រះចមនាគាចរិយវន្ទ្យ ខ្ញើសត្រង់ករុណាថ្លើងថ្លាថ្លៃ ប្រពាន
ព្រះធម៌បិដកត្រ័យ ទុកជាវិន័យសាមញ្ញសត្វ ។ ខ្ញុំថ្វាយបង្គំព្រះដម្ពោ
សេដ្ឋោវរោគាចបំបាត់ គំលេសសង្សារឲ្យសូន្យថ្លាត់ ដោយព្រះបរមត្ត
អាវុធថ្លា ។ ជាអរិយទ្រព្យគាប់បរិសុទ្ធ សម្រាប់កុលបុត្រកុងសាសនា
ខន្ធេញសូត្ររៀនប្រៀនប្រាជ្ញា ជាផ្លូវយោគ្រោះទៅនិព្វាន ។ បញ្ញត្តិថាត់
ថាកុំប្រមាទ ស្តាប់ពុទ្ធតាំងដំបូន្មាន ឲ្យរក្សាសីលបំពេញទាន ទុកទៅ
ជាយានប្រសើរជា ។ ឲ្យខំបំបាត់គាត់លោភោ គោសោមោហាកុំឆ្គាំ
ចង់បានមិនត្រូវផ្លូវធម្ម៌ រៀសអស់ជន្មបានអបាយ ។ គួរកែត្រង់ត្រាប់ច្បាប់

ប្រពៃ តាមព្រះនិយាយលោកអតិប្រាយ ធ្វើបុណ្យជាក់ថ្កាត្រចំណាំថ្កាយ
ចំណាយជាស្បៀងលៀងអាត្មា ។ ខ្ញុំថ្វាយបង្គំព្រះសង្ឃសម ប្រសើរ
ឧត្តមទ្រង់សិក្ខា ជាតិជាកុលបុត្រពុទ្ធសាសនា ទ្រង់ព្រះមេត្តាសាសនា
ថ្មី ។ ដែលលោកបណ្ដែតដល់បដិវេធ យើញហេតុសង្ខារជាបច្ច័យ ហើយ
កាត់រលាងកងកម្មក្ខ័យ សុខស្ប័យរួចចរកកគតណ្ហា ។ តាលព្រះអង្គទ្រង់
ជិតនិព្វាន ឈ្វេងញាណហាកំពុងសាសនា ឲ្យត្រប់ត្រាំតាន់ព្រះវស្សា
ជាពុទ្ធធម្មតាប្រពៃណី ។ សម្ដេចសព្វញ្ញាមុនីនាថ ជាន់ពុកព្រះថ្កាលលើតិរ
ពុកព្រះពុទ្ធរូបស្ដេចមុនី ព្រះមហាពោធិបដិតត្រើយ ។ ព្រោះជ្បិតសម្ដេច
ព្រះសាស្ដា ត្រាបថាសាសនាឯក្រោយក្រៃ ទន់សាបសូន្យទៅទើបទ្រង់ក្នុ
ពុកបូជានេយ្យតាំងថ្កាំស្ថាន ។ ឲ្យអស់សព្វសត្វផងនានា ត្រាន់ជាទីពឹង
បម្រុងប្រាណ នមស្ការបូជាខ្នើតធួបបាន ផលបុណ្យក្សេមក្សាន្តនិព្វាន ។

អហំអញ្ញេខ្ញុំសូមចារចង លើកលង្ឃរឿងវែងហាក ពាក្យសៀម
ប្រែមកជាភាសា ខេមកតីកម្ពុជាជាតិ ។ ពោះបើលើសលោះពុសពាក្យពិត
ពុំជិតពុំជួនស្ងួនហ្មាហ្មត សូមជួយជ្រើតចែងដោយខ្នើហ្មត សម្រាបជួន
ញាតិអ្នកចង់ដឹង ។ និពន្ធបក្សាជាប្រថម គួរសមទីធ្លាប់ស័ព្ទដំណឹង
ដំណើរនេះខ្ញុំទំប្រែច្រឹង សុទ្ធសឹងមានមកពីចាស៎ ព្រះពុទ្ធព្រះអង្គទ្រង់ចន្ទែ
បន្ទាយច្រាយប្រែកែសេចក្ដី ច្រោសអស់អរហន្តតិកុនី ដើម្បីឲ្យបានលុះ
មគ្គផល ។ ខ្ញុំហ្នឹងកក្ដីអក្សរតន់ រិះតិតកែកុនតាមយោបល់ យកបុណ្យ

សូមបានសុខសួស្តីសល់ សូមដល់រួចចាកទុក្ខភ័យផង ។ ព្រះពុទ្ធសកពជ
ព្រះសាសនា អតិក្កន្តាហួសកន្លង ពីរពាន់ប្លែនឆ្នាំសៃសិបសង់ រំលង
ទៅហើយដោយគណនា ។ ហេមន្តរដូវជាប់តើតខែ មិគសិរសៀលថ្ងៃ
អង្គារ ខ្ញុំកុរឯកសឹកដោយវេលា សុរិយាជ្រៀលសៀលថ្ងៃ ។ តែង
ក្តងសេខពីរទើបុយ៉ូ ទៅឃ្លាំងត្រីសូលប្រសើរថ្ងៃ ចតុម្មុខភ្នំពេញជក្រុង
ក្រែ រិះគិតកែខៃតាមប្រាជ្ញា ។

ខិតានដំណាលព្រះមុនី សត្តេជ្ញមោលីចមរលោកា ចាប់ជាតិជា
សត្វសកុណា នៅព្រៃហេមវាព្រឹក្សាសន្ត ។ កាលព្រះអង្គគង់ក្នុងដេតពន
សុគន្ធកុដីកែវសុភោន ជាទីសុខោរហោស្ថាន សម្រេចសម្រាន្តកិច្ចស្មោះ
សរ ។ សម័យមួយនោះអស់អាយុ ច្រើនព្រៃអន្តមកកុះករ គង់ធម្ម-
សភាថ្ងៃជវរ សឹងតែត្រេកអរសើរថា ។ ឧព្រះចមមកុដធុតព្រៃកព
ព្រះគុណលើសលុបឥតឧបមា ជាត្រៃវន្តព្រហ្មមនុស្សទេវតា ទ្រង់ព្រះមេត្តា
ករុណាសត្វ ។ សន្សំសេពសាងធ្វើម៉ៃថ្ងៃ ជួនអសង្ខ្យៃយ្យវែនយូរក្តាត់
បំពេញពិព្យាយាមខើបកាត់ ចំនួនអាយុស្ថានឥតប្រៀយ ។ ដើម្បីគាណិត
តិតស្រោចស្រង់ សត្វសត្វកាត់បង់សង្សារ ឲ្យសូន្យបាតទុក្ខបានសុខា
គឺមហានតរនិព្វានពិត ។ កាលនោះសម្តេចព្រះជិនស្រី ជ្រាបអាថ
សេចក្តីដោយញាណពិត ទើបយាងព្រះបាទស្តេចវិចិត្រ តាមពុទ្ធនិម្មិត
រៀងមកដល់ ។ ធម្មសភាសុវណ្ណ ឡើងគង់ក្រឡាព្រះគំនាល់ ទើបទ្រង់

ដម្រេរដោយយោបល់ ត្រាស់សួរកិច្ចកលដល់សាវតារ ។ អាវុសោហៃ
អស់តិកុធដ៏ ស្តីអ្វីដ៏តដ៏លើសាលា មិនទំប្រតិបត្តិហាត់សិក្ខា ទៃយ
សិក្ខាអាថ៌ចាលី ។ ទើបព្រះមោគ្គល្លានក្រាបទូលស្នង ជាអស់តិកុធដ
កើតស្រដី សរសើរត្រឹមតែព្រះជាម៉ែ អម្ចាស់សរសើលើសលោកា ។
សម្តេចសត្ថាព្រះពុទ្ធគង្គី ចាន់ត្រង់សណ្តាប់ដោយបញ្ញា ទើបបើកព្រះ
ឧស្តង្ហ្រាសតបថា ហៃបាមោគ្គល្លានមានបារមី ។ អ្នកនាំព្រះសង្ឃមក
សរសើរ ដំណើរពីអង្គអញដ៏ស្រី ជាមានអានុភាពលើសកពត្រីយ មោះ
មិនតែឥឡូវនេះណា ។ ពីកាលកតញ្ញូនំឈ្មោកប្បវាំង កំបាំងជាត់ស្ងាត់
អតីតា យូរណាស់កាលនោះតញ្ញូតថា- តតតើតជាមហាបុរសវ័ន
មួយមានមហិទ្ធិឫទ្ធិក្លាហាន នៅជែនឆានស្ងាត់ជនបទ ជាបុត្រប្រសើរ
ថ្លៃក្រាកដ ប្រកបហ្មត់ចត់ព្រះកាយា ។ ហើយមានសម្លាញ់អញជិតដាក់
មួយពាន់មួយនាក់ក្បែរស្មេហា តែពោធរង្សីទ្រង់ចេស្តា មានព្រះច្រុងជា
លើសអ្នកផង ។ អ្នកលាមាតាបិតាចរ ស្ងែងរៀនសិល្បសរដូចបំណង
ចង់ចេះជាធំមិត្រពិតជាប្រាជ្ញ ថ្ងៃក្រៃក្រែកទ្ធឹងឆ្លួសវាទា ។ សម្តេចជិនវង្ស
តង្សពុទ្ធរ័ត្ន នាំហេតុតាមបទព្រះគាថា មកជាសណ្តាប់ច្រាប់សាវិកា
ឲ្យជាហេតុហើយទ្រង់ឈឹងឈប់ ។

ត្រានោះជំនុំព្រះអរហន្ត ក្រាបទូលនិមន្តព្រះបមកត ថាសូមសន្តោស
ច្រាសច្រាវ្ន ខឹងបានដ៏ត្រប់សោះសង្ឃ័យ ។

ការស្តាបនាអាគារសិក្សា ចាប់តាំងពីថ្ងាក់ក្តួចរហូតដល់ថ្ងាក់ទី ៦ ទំនើប
សព្វថ្ងៃនេះ មានសន្ទុះលឿនណាស់ទៅហើយ ដោយសេចក្តីប្រឹងប្រែង
របស់ព្រះសង្ឃទាំងពុទ្ធបរិស័ទ ។ ការកសាងទាំងនេះឈ្មោះថាជាការគាប់
ប្រសើរណាស់ ប៉ុន្តែ ដោយបំណងជាតិយើងខ្ញុំនេះក្រៃឃ្លា ព្រមទាំងពាក្យនឹក
រកបុគ្គលិកសម្រាប់បង្រៀនតាមថ្នាក់នោះផង សូមព្រះសង្ឃនិងពុទ្ធបរិស័ទ
បង្អន់ការស្តាបនានោះសិន ។ ជាពិសេស សូមព្រះគុណត្រង់អគ្គមេត្តា
ជួយតឿលណាំពួកពុទ្ធបរិស័ទឲ្យទំប្រឹងប្រែងបរបាកសិក្សាឲ្យបានពេញ
ទំហឹងឡើង ដើម្បីឲ្យមានផលិតផលបរិបូណ៌ ឃុំគៀងគំទៅប្រទេសក្រៅ
តាលបើយើងសម្បូណ៌ផលិតផលចេញទៅប្រទេសក្រៅហើយ
យើងនឹងសម្បូណ៌ ហើយយើងអាចនឹងពង្រីកកិច្ចសិក្សាបានដោយងាយ
ជាច្រើនជ ។ល។

លុះចប់ព្រះសង្ឃថានេះហើយ ព្រះសង្ឃទាំងឡាយ ដែលមាន
សម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន បានសូធ្យាយពុទ្ធជ័យ
មង្គលប្រសិទ្ធិស័ព្ទសាធុការពរថ្វាយ ចំពោះសម្តេចព្រះបិតាឯកពាជ្យជាតិ
ជាទីបូជនីយ៍ចម្បងមហាសន្និបាត នៅពេលព្រឹកនោះ ។ បន្ទាប់ពីនោះមក
សម្តេចទ្រង់ថ្វាយបង្គំលាព្រះសង្ឃ យាងត្រឡប់ទៅព្រះពជដំណាក់វិញ ។

ម៉ោង ១០-៣០ ប្រគេនកត្តកតិ្តព្រះបរមនាមនៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ដល់ព្រះសង្ឃចំពោះមុខទេសរដ្ឋមន្ត្រីទទួលបន្ទុកទាំងក្រសួងធម្មការ ព្រមទាំងមន្ត្រីក្រសួងធម្មការ ឧបាសកឧបាសិកា នៅបរិវេណឈាបនដ្ឋានវត្តឧណ្ណាលោម ។

របៀបវារៈនៃការប្រជុំព្រះសង្ឃ

របៀបវារៈនៃការប្រជុំព្រះសង្ឃ ដែលធ្វើនៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក្រោមអធិបតីភាពនៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ នៅថ្ងៃទី ២៥ មេសា ឆ្នាំ ១៩៥៩ មានសេចក្តីដូចតទៅនេះ :

ម៉ោង ១៤ សម្តេចព្រះសង្ឃនាយកនឹងព្រះសង្ឃគាំនង្សាយទទួលមកដល់។

ម៉ោង ១៤-១០ ការបើកកិច្ចប្រជុំ ដោយសម្តេចព្រះសង្ឃនាយក។

ម៉ោង ១៤ ៣០ សន្និសីទ អំពីព្រះពុទ្ធសាសនាដែលមានការចាក់ឥន្ធនធ្វើកិច្ចសិក្សា ក្នុងប្រទេស ដោយព្រះគោដិវង្ស ។

ម៉ោង ១៥-៣០ សន្និសីទ អំពីការត្រួតត្រាពួកៗ នៃសាលាពុទ្ធិក-បឋមសិក្សា ដោយលោក យឹម-វ៉ែនទីប្រឹក្សាបច្ចេកទេស ។

ម៉ោង ១៥-៣០ ការប្រគេនកេសដ្ឋៈដល់ព្រះសង្ឃ ។

ម៉ោង ១៦-៤០ សន្និសីទ អំពីឧត្តមសិក្សា ដោយលោក អៀង-គុនសាគី អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យ ។

X XX

(ពីមក)

ព្រះវហា ប៉ាង-ខាត់ រៀបរៀង

អប្ប បុព្វបទ សំគោ..។ - **គ** ទៅត្រង់ ។ - **ឋ** ឬ - **ស** តម្រង់ទៅ។ - **ជ្រ** ដើមពណ៌ត ។ - **ឃ** ទៅណត ។ - **វ** អញ្ជើញ ។ - **វ** សំពះ ។

អប្បិច្ឆ គុ. ដែលមិនដាច់ចិត្ត, ដាប់រំភើក, ដែលខ្ចៅល្ង ។ **អប្បិច្ឆមិ**, **អប្បិច្ឆតា**, ភាពដែលរំភើក, ភាពដាប់ចិត្ត ។

អប្បិរិកា **អប្បិរី** ស្ត្រី. ក្រក, កង់ ។

អប្បែទ្យ គុ. ដែលមិនគប្បីកាត់ចេញបាន ។

អប្បុព្ធិ គុ. ដែលមិនប្បុត, ដែលមិនពេញប្រើក, ម៉ាំម្ខួន, ងឹតថោ ដែលមិនស្ទាប់។ ប៉ុ. ព្រះឥន្ទ្រ, ព្រះឥន្ទ្រ; ឈ្មោះទេពតាផ្ទៀង ។ ។ **អប្បុតាយុស** ប៉ុ. ឈ្មោះអ្នកចម្បាំង ។

អប្បិ មើលពាក្យ **អត្ថ** ។ - **អតិ** : **អតិតិ-តេ**, (ខាងវេទ) កិរិយាតំ ។

អប្បិ ប៉ុ ពពែ ។ **អជា** ស្ត្រី. ពពែញី ។ - **គរ** ប៉ុ. ពស់ថ្លាង់ ។ - **ម័ណ** ឬ **ម័ណ្ឌ** ប៉ុ. ឈ្មោះយុធិដ្ឋិរ; ឈ្មោះឆ្នូតពណ្តូរ; ឈ្មោះដំនផ្ទៀង ។ ទៀត ។ - **ប** ប៉ុ. អ្នកគង្វាលពពែ ។ - **ឋាល** ប៉ុ. អ្នកគង្វាលពពែ ។ - **មុខី** ស្ត្រី. ឈ្មោះរាក្សសី ។ **អជា-គល-ស្តន** ប៉ុ. ពួកនៅកនៃពពែញី ។ - **អជាវិ** ប៉ុ. ពហុ ពពែឬចៀម ។ **អជា - វិក** ឧប៉ុ., **អជាវិកា** ស្ត្រី. ពហុ. ប្រែទូចគ្នាទំនងអជាវិ ។ **អវិដកបទ**, ប៉ុ. តាមនៃព្រះពាសា ។

(តៅមានត)

ភ្នំពេជសុទិយា

ទស្សនាវដ្ដី ផ្សាយចំណុំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣១ លេខ ២ ខែកុម្ភៈ

ព.ស. ២៥០១ គ.ស. ១៩៥៧

ភ្នំពេញ



អក្សរសាស្ត្រ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បណ្ណៃរឿង	ទំព័រ
– ពុទ្ធសាសនធុរកថា របស់ព្រះមហា ព្រហ្ម-មារិន្ទ		១២១
– រឿងវិន្ទុរកៈ របស់ព្រះមហា ឌៀក-អន់ (ពពប់)		១៣១
– សុរពលាភក ឬ ចិត្ត ជំពូងតីសាស្ត្រាស្ងឹកវិត		១៤៩
ផ្នែកអក្សរសាស្ត្រ		
– ប្បាប់ស្រីព្រះភគតិតន្ទេយត្រះបាទអគ្គនួង លោកចាវ-ភិល តិត្តិត្ស (ពពប់)		១៦៤
– រឿងបព្វសិទ្ធិ របស់ ហ្ន៎ត្តិអក្សរ ពន់ លោក ប៊ូ-ប៊ូ ជំពូងតីសាស្ត្រាស្ងឹកវិត		១៩០
– ពិធីបុណ្យកំសាន្តស្រុក លោក ស្រ៊ី-អ៊ូ រៀបរៀង		២០៧
– សុភាសិតជាតិស៊ីនីងលីបង់ (តមក) លោក ទ័យ-ប៊ុក ប្រែរៀបរៀង		២១១
– រឿងសាមកុក (តមក) ឧកញ៉ា ខូ-ពន ប្រែ		២២៧
ផ្នែកកំណត់ទិដ្ឋវត្តិការណ៍		
– សន្ទិសីទនៃលោកម៉ាតូសាចាំ លោក ទ័យ-ប៊ុក រៀបរៀង		២២៩
– វិចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង		២៣៤

មួយឆ្នាំមាន ១២ លេខ តំលៃជាវ ២៣០០

KAMBUJASURIYA

Revue religieuse et litteraire
éditée par l'Institut Bouddhique

sommaire

Partie Religieuse :

-Buddhasàsanadhurakatha par Preah Moha PROHM-MARIN . 121
-Histoire de Vidudabha par vén. DŒUK-AMARA . . . 131
-Surabajataka recopie du manuscrit en feuille de latanier par M. THANG-VONG. 149

Partie littéraire :

-Chbap Srey Preah Bat Ang Duong revu et corrigé par M. CHAP-PIN. 169
-Histoire de Sabbasiddhi de Phakdei Aksar TAN revue et corrigée par M. BOU-PO 190
-Cérémonie pour le bonheur du village par M. SREY-OU 207
-Proverbes syriens et libanais traduits par M. RAY-BUC . . 211
-Histoire de Samkok (suite) traduite par M. NOU-KAN . . 217

Notes et Chroniques :

-Conférence de Marcus-Bach traduite par M. RAY-BUC . . . 229
-Dictionnaire Sanskrit-Khmer (suite) par vén. PANG KHAT . . 232

Prix d'abonnement annuel (comprenant 12 numéros): 230,00 .

ផ្នែកភាសាសង្ខេប

ពុទ្ធសាសនសុភាសិត

របស់ព្រះមហាប្រជ្ញ-មារិន្ទ ទទួលតាមវិទ្យុផ្សាយពីថ្ងៃទី ២៦-៥-៥៨

ឥមោ តស្ស កតញ្ញូនោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះគតញ្ញូម្ចាស់ អរហំសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដែរ ។

ថ្ងៃនេះ ជាថ្ងៃទុតិយ ដែលអស់លោក-អ្នកជាពុទ្ធបរិស័ទ គាំងឡាយបានសមាគមគ្នាប្រជុំស្តាប់ធម្មទេសនាផ្សាយតាមវិទ្យុទន្លេសាបសំពួរប្រទេសកម្ពុជា ។ ពេលនេះ អាត្មាភាពសូមសំដែងអំពីសុភាសិតសង្ខេប តាមសមគួរដល់កាលវេលាដូចតទៅនេះ :

ពាក្យថា ពុទ្ធសាសនសុភាសិត ប្រែជាសេចក្តីថា សំដែងដឹងពីការផ្សាយដែលត្រូវធ្វើ ត្រូវទទួលកាន់យក តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺជាតិចួដែលពុទ្ធបរិស័ទត្រូវរៀន ត្រូវធ្វើក្នុងព្រះពុទ្ធសាសនា តាមអត្ថស្រាយរបស់ទី ៣ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា ។

ពុទ្ធសាសនានោះ មានន័យដ៏ធំ

១- គន្ថធុរៈ ធុរៈខាងបរិយត្តិធម៌,

២- វិបស្សនាធុរៈ ធុរៈខាងវិបស្សនា ។

សេចក្តីអធិប្បាយ :

១- គន្ថធុរៈ ធុរៈខាងការសិក្សាអត្ថរសាស្ត្រ ឬព្រះត្រៃបិដក ជាខាងការបំពេញកិច្ចសិក្សា ព្រះបរិយត្តិធម៌ គឺការរៀនសូត្រខន្ធកៈ ជាលើ ព្រះពុទ្ធដីកា អដ្ឋកថា ដែលមានកថាបិដកទាំងមូល និងការសិក្សាវិជ្ជាផ្សេងៗ ទៀត ដែលពុទ្ធសាសនិកជនត្រូវរៀនជាន ពោះបីរៀនចេះនិកាយ ១ ក្តី និកាយ ២ ក្តី ឬចេះចប់គាំងអស់ក្តី ហើយសំដែងប្រាប់គេបង្រៀនគេកើត ដើម្បីជួយទប្ទម្ភព្រះពុទ្ធសាសនា ឲ្យរុងរឿងបរិបូរណ៍ជាន ហៅថា គន្ថធុរៈ ។

ពិស្តារ: តំព្រះបរិយត្តិធម៌នេះ ជាស្ពាន ជាច្បាប់ ឬថាជាទ្វាត ជាបន្ទាត់ដួយគម្រង់សេចក្តីប្រតិបត្តិ ឲ្យត្រឹមត្រង់តាមធម៌វិន័យ មិនឲ្យឃ្លៀងឃ្លាតចាកពុទ្ធប្បញ្ញត្តិនិងពុទ្ធានុញ្ញាត ដែលជាច្បាបដើម្បីទុកជាមគ្គុទ្ទេសក៍ឲ្យដល់នូវសេចក្តីសុខចំរើនជាន ។ ដូច្នេះ កុលបុត្រដែលមានសទ្ធាជ្រះថ្លាក្នុងសាសនារបស់ព្រះអង្គ ត្រូវតែខំប្រឹងរៀនសិក្សាព្រះបរិយត្តិធម៌នេះជាដំបូង ព្រោះធុរៈនេះជាបុព្វកិច្ចនៃសេចក្តីប្រតិបត្តិ ។ ព្រោះហេតុនោះ កុលបុត្រដែលមានវ័យទៅក្មេង ។ ត្រូវខំប្រឹងខ្នះខ្នែងរៀនសូត្រទន្ទេញឲ្យ

ជាខេះចាំ ព្រះបរិយត្តិធម៌ឲ្យតាំងជាប់ ព្រោះបរិយត្តិធម៌ជាមាគ៌ា ឬជាដែនទីសម្រាប់បង្ហិលបង្ហាញ នូវសេចក្តីសុខ-ចំរើន ក្នុងលោកនេះនឹងលោកខាងមុខ ។

ឯការសិក្សាគន្ថធុរៈ គឺបរិយត្តិធម៌នោះ ជាធុរៈធំធ្ងន់ណាស់ ប៉ុន្តែមានប្រយោជន៍ដល់ជាតិសាសនាកំដុលាយណាស់ ។ ការសិក្សានេះ មិនចំពោះតែភេទមួយៗ ជាដាច់ខាតទេ ទោះបីភេទបព្វជិតក្តី ភេទគ្រហស្ថក្តី ក៏សិក្សាបានដូចគ្នាទាំងអស់ ។ ប៉ុន្តែភេទគ្រហស្ថ ជាភេទដែលមានកិច្ចវល់ច្រើន មិនអាចនឹងសិក្សាបំពេញគន្ថធុរៈ ឲ្យពេញលេញគ្រប់គ្រាន់ ជាខេះ ដោយហេតុថា គ្រហស្ថមានការណីយកិច្ចគ្រប់សង្កត់ច្រើន ។ ចំណែកខាងភេទបព្វជិតវិញ បានតែក្នុងភេទនេះ គួរតែខំសិក្សារៀនសូត្រឲ្យពេញលេញ មិនត្រូវឆ្អែតប្រហែសទេ ប៉ុន្តែបច្ច័យទីសេនាសនៈសម្រាប់ជ្រកកោនអាស្រ័យនៅ ក្រមនុស្សខ្វះខុតបំរុង ក្រអាហារកោជនក្រគ្មានរឿយ ខោះកំរៀនសូត្រមិនគ្រប់ តុះតែប្រកបដោយសប្បាយ ទាំងបួនយ៉ាងនេះ ទើបញុំាងកិច្ចសិក្សានោះ ឲ្យប្រព្រឹត្តទៅបាន ។ សប្បាយទាំង៤ យ៉ាងនោះគឺ

១- ការបានទីសេនាសនៈ មានកុដិសាលាជាដើម ជាទីរៀនសូត្រគ្រប់គ្រានមិនលំបាក ហៅថា "សេនាសនសប្បាយ" ។

២- ការមានទាយកៈ-សិក្ខាបច្ច័យាន ទើបមានតិក្ខុសាមណេរផង

ត្តាជាកល្យាណមិត្ត ជាគួរប្រឹក្សាច្រើនរូប មិនខាសខែងខ្វែងគំនិតគ្នា ឬសម្បុរដោយត្រូវអាចារ្យបង្ហាត់បង្ហាញត្រឹមត្រូវ តាមរបៀបពុទ្ធសាសនាហៅថា "បុគ្គលសប្បាយ" ។

ក្ស - ការបានបរិស្ថានត្រូវ មិនខ្វះខាត ហៅថា "ឥហាសប្បាយ"។

ឩ - ការមានធម៌វិន័យ គម្ពីរដីកាអដ្ឋកថាវណ្ណនា ចាស់ឬសម្រាប់ សម្រាប់រៀន ប្រព្រឹត្តប្រតិបត្តិតាមធម៌វិន័យ ហៅថា "ធម្មសប្បាយ" ។

សប្បាយទាំង ៤ ប្រការនេះ ជាគុណជាតិសាធជួយទប្ទិដ្ឋការសិក្សាគន្ថធុរៈឲ្យបានពេញបរិបូណ៌ ។

ដំណើរនេះ សាធុជនអ្នកមានសទ្ធា ដែលបានឆ្លើសប្បាយទាំង ៤ យ៉ាង មានសេខាសនសប្បាយជាដើម ឈ្មោះថា បានបំពេញបុញ្ញកិរិយាវត្ថុធម៌ ឈ្មោះថា ផ្តួចផ្តើមបំរើឬផ្តួយដំណាលតំកូនចៅរបស់ពុកមាត់គោរពតឹព្រះពុទ្ធសាសនាឲ្យបានថ្កុំថ្កើង ចីរកាលតៅដោយពិតផង ។ ដែលត្រូវអាស្រ័យសប្បាយទាំង ៤ យ៉ាងនេះ តុំមែនតែក្នុងផ្នែកធម៌ទេ សូម្បីផ្នែកលោកក៏ត្រូវអាស្រ័យសប្បាយទាំង ៤ យ៉ាងនេះដែរ ទើបប្រព្រឹត្តតៅបាន ។ ដូចជាការរៀបចំប្រទេស ឲ្យមានផ្លូវសំបែងត្រឹមត្រូវ ប្រដាប់សំពាប់ប្រើប្រាស់សំលៀកបំពាក់ ឲ្យមានតាហារបរិភោគ យានជំនិះតៅមក ឬបង្កើតឲ្យមានសាលាសម្រាប់សិក្សារៀនសូត្រចំណេះវិជ្ជាផ្សេង ។ ឲ្យសមតៅតាមសម័យនិងឋមយ៉ាងនេះ ហៅថា តាក់តែងរៀបចំក្នុងផ្នែកលោក ដើម្បីឲ្យ

ប្រទេសៈយើងទៅតាន់ការត្រូវធម៌ជាន់ ការបង្កើតឲ្យមានសាលាសម្រាប់រៀនធម៌ ខំនាំបំរុងអ្នកក្រុងដ្ឋ អ្នកសិក្សាខាងសាសនា ដើម្បីសេចក្តីស្ងប់តាយវាយចិត្ត ដោយឲ្យតាក់តែងធម៌អាចិតម្ចិរដ៏តាស្ងួនបាប់ ផ្សាយចេញទូទៅក្នុងសាគលលោក ប្រដៅប្រដាផនឲ្យដឹងចាបបុណ្យគុណទោស ទុសត្រូវ ល្អអាក្រក់ ឲ្យលះបង់កន: ទោសៈ មោហៈ មិនឲ្យមានការបៀតបៀនគ្នាទីឆគ្នាដាដើមយ៉ាងនេះ ហៅថា តាក់តែងធម៌វិធម៌ ក្នុងប្រទេសមួយ ។ កន់លោកនេះ លុះតែមានធ្វើលោកធំឆធ្វើធម៌ស្មើគ្នាទើបប្រទេសនោះឡើងទៅតាន់ការស្រាតាន់ដ៏រុងរឿងការពាន បើមានតែធ្វើលោកតែមួយចំណែក មិនមានធ្វើធម៌សោះទេ នោះលោកនឹងក្តៅនេះជាភ្លើង ដោយហេតុមនុស្សមានពាលៈ ទោសៈ មោហៈខ្លាំងឡើង ។ ប្រណាំងប្រដែងគ្នាហួសហេតុពេក ឥតមានគិតអាណិតអាសូរដល់គ្នាទៅគ្នា ឥតគិតដល់បុណ្យបាបឡើយ បើមានតែធ្វើធម៌តែមួយចំណែក មិនមានធ្វើលោកសោះទេ នោះលោកនឹងក្លាយទៅជាព្រៃ ដោយហេតុមនុស្សមិនយកចិត្តទុកដាក់នឹងរៀបចំស្រុកទេស ។

ការទំនាក់ក្សាទៅឲ្យរៀនសូត្រ ធ្វើប្រតិបត្តិសាស្ត្រឲ្យដឹង ក្នុងប្រទេសរបស់ខ្លួនឲ្យបានហ្មត់ចត់ ឈ្មោះថា បានបំពេញធ្វើលោកធំ ។ ការទំនាក់ក្សាទៅឲ្យរៀនសូត្រ ធ្វើតាន់ដ៏តាស្ងួនបាប់ របស់ព្រះសម្មាសម្ពុទ្ធដើម្បីនឹងកំចាត់បង់ធ្វើសេចក្តីសង្ស័យ ឬ បាបអកុសលទាំងពួង

ឈ្មោះថា ឋានបំពេញគុណក្នុងវេនមិ ។ បើមនុស្សមិនទំនៀងក្បាលរឿងសូត្រ
ក្តីលោកនេះ គោះខានប្រវត្តិសាស្ត្រ ឬក្តីមិសាស្ត្រក្តី បរមពុទ្ធាភាវក្តី
ជាតិធម៌សាសនាធម៌សាបសូន្យជាមិនខាន ។ ពុទ្ធសាសនាដែលអាចនឹង
តាំងនៅឋាន ដោយអាស្រ័យបរិយត្តិជាឫសគល់ ដូចមានឋាលីថា
បរិយត្តិ ពុទ្ធសាសនស្ស មូលំ បរិយត្តិជាឫសគល់ពុទ្ធសាសនា ។

យាវ តិដ្ឋន្តិ សុត្តន្តា វិនយោ យាវ ទិបជ្ជតិ
តាវ ឯត្ថេវ អាលោកំ សុរិយេ ឧគ្គេ យថា ។

ព្រះសូត្រទាំងឡាយបានតាំងជាបណា ព្រះវិន័យនៅរុងរឿងដូចជា
ណា, សត្វលោកក៏អាចនៅយើញពន្លឺបានដូចគ្នានោះ ដូចជាព្រះអាទិត្យ
ដែលរះខ្ពស់ត្រដែតឡើងដូច្នោះឯង ។

សុត្តន្តេសុ អសន្តេសុ បម្មុដ្ឋេ វិនយម្ហិ ច
តាទោ វិកប្បតិ លោកេ សុរិយេ អព្ភុដ្ឋិតេ យថា ។

កាលបើព្រះសូត្រទាំងឡាយមិនមាន ទាំងព្រះវិន័យក៏គិតភ្លេចភ្លាំង
អស់ទៅហើយដែរ ដ៏ងងឹតអញ្ជឹងការ ក៏នឹងកើតមានដល់សត្វលោក ដូច
ជាព្រះអាទិត្យ ដែលអស្តង្គតបាត់ពន្លឺដូច្នោះឯង ។

សុត្តន្តេ វត្តតិ សន្តេ បដិបត្តិ ហោតិ វត្តតិ
បដិបត្តិយំ ឋិតោ ធីរោ យោគក្ខេមា ន ធំសតិ ។

កាលបើគិគ្គនៅរក្សាព្រះសូត្របាននៅឡើយ សេចក្តីប្រតិបត្តិ ក៏

ឈ្មោះថាជាគុណជាតិ ដែលតិក្ខនៅវក្ខាចាន់ដែរ ឆ័ត្រដែនអ្នកបិតនៅតែងតែ
សេចក្តីប្រតិបត្តិ រមែងមិនខ្ចាត់ឃ្លាតចាកធម៌ ជាដែនក្សេមចាកយោគៈ
ខ្លួយ ។

ព្រោះហេតុនោះ តុន្តមាមកជន ដែលមានបំណងនឹងបំពេញ
វិបស្សនាធុរៈ គួរចំឃកចិត្តទុកជាក់បំពេញតន្តធុរៈជាមុនសិន ។

២ - វិបស្សនាធុរៈ ធុរៈខាងវិបស្សនា ឬធុរៈខាងការពិចារ-
ណាឲ្យឃើញច្បាស់ នូវដំណើរនៃសង្ខារធម៌តាមការពិត ។ ចាន់ដែរ
ការបំពេញកិច្ចសិក្សាសមថកម្មដ្ឋាននឹងវិបស្សនាកម្មដ្ឋាន ជាវិធីហាត់ចិត្ត
ដំរេចិត្តឲ្យបរិសុទ្ធផូរផង់ ដែលជាតុណារសជាទ្វីមសារនៃព្រះពុទ្ធសាសនា ។

ពុទ្ធបរិស័ទទាំងឡាយដែលមានវ័យចាស់គ្រាំគ្រាហើយ ឥណ្ឌិចំបំពេញ
តន្តធុរៈមិនកើតព្រោះកម្លាំងកាយនឹងកម្លាំងសតិបញ្ញាខន់ខ្សោយ មិនគ្រប់
គ្រាន់បរិបូណ៌ បរិស័ទពួកនេះ ត្រូវបំពេញខាងវិបស្សនាធុរៈ ទើប
សមគួរ ព្រោះខ្លួនមានវ័យចាស់ជ្រុលហើយ ។ វិបស្សនាធុរៈមិនមែនជា
ធុរៈធ្ងន់ទេ ជាធុរៈដ៏ធូរស្រាល មិនមានកម្មវិធីសិក្សាយូរន្លង់ដូចសិក្សាក្នុង
ផ្លូវតន្តធុរៈទេ ។ ដូច្នេះធុរៈនេះ បរិស័ទគួរខំបំពេញឲ្យគ្រប់ៗគ្នា ព្រោះ
កាលដើមចិត្តនឿយណាយធុញទ្រាន់ នឹងការគិតឈឺចាស់ស្ទាប់ហើយ
ក៏បះបង់ពួកគណៈ ចូលកេងកែតន្ទែនដ៏ស្ងាត់ មិនមានតណ្ហាគោធជាយកិច្ច
ផ្សេងៗ ហើយតាំងចិត្តឲ្យស្ងប់ស្ងាត់ ពិចារណាឲ្យឃើញពិត នូវការកើត

នឹងការសូន្យទៅនៃសង្ខារ ។ កាលបើតាំងចិត្តដាច់ហើយ តែងបានសម្រេចធម៌ជាន់ខ្ពស់ណាមួយមិនខាន ។

វិបស្សនាធុរៈ ជាធុរៈដែលពុទ្ធបរិស័ទ ត្រូវធ្វើខាងក្រោយអំពីគន្ថធុរៈ មានគន្ថធុរៈ គឺបរិយត្តិធម៌ជាមគ្គនាយក អ្នកបង្ហាញផ្លូវ មានគន្ថធុរៈជាដែនដី សម្រាប់ដំរង់ពន្យល់អំពីវិធីហាត់ចិត្តឲ្យដឹងថា ការពត់ដម្រង់ចិត្តបែបនេះ ប្រដៅចិត្តបែបនេះ ចិត្តដែលជាបដិភាគនឹងអារម្មណ៍បែបនេះ ផ្ទើចិត្តនឹងរួចចាកអារម្មណ៍បែបនេះ បើមិនដឹងវិធីទាំងអស់នេះទេ មិនងាយនឹងផ្ទើចិត្តនោះ ឲ្យជាចិត្តស្អាតបរិសុទ្ធចាកកិលេសសូត្រត្រង់ទៅបានឡើយ ។

ព្រោះហេតុនោះ ឋានជាអដ្ឋកថាចារ្យ អធិប្បាយពន្យល់ជាសេចក្តីឧបមាថា ហ្វូងគោដែលមានសុទ្ធតែគោឈ្មោលទាំងអស់ គាលបើមិនមានមេគោ ជាសត្វក្បាលំណែបវណ្ណៈនៅក្នុងហ្វូងគោឈ្មោះផងទេ វណ្ណៈបវណ្ណីឬពួជគោនោះឯង មុខជានឹងដាច់សូន្យរៀយៗឆ្ងាំណាមិញ, សាសនានេះក៏ដូច្នោះដែរ គឺថាបើមានតែក្នុងប្រើនរូបដល់រយតាន់ក៏ដោយ បើសុទ្ធតែជាអ្នកច្រាវ្ច ខ្ជិលរិបស្សនាកម្មដ្ឋានធុតង្គគ្រប់មួល ទៅអាស្រ័យក្នុងព្រៃមិនមានតែក្នុងអ្នកទ្រទ្រង់ បរិយត្តិជាពួជទេ ឬក៏បរិយត្តិអន្តរធានទៅ ដោយហេតុតែផុតពួជលោកអ្នកទ្រទ្រង់បរិយត្តិធម៌ ការចាក់ធ្លុះ ការត្រាស់ដឹងនូវ

អរិយមគ្គអរិយផល ក៏ពុំមានដែរ ព្រោះពុំមានបរិយត្តិជាច្បាប់សម្រាប់បង្ក្អុលបង្ហាញ ឥឡូវលំបិតូវប្រតិបត្តិឲ្យត្រឹមត្រង់ទៅបាន ។ មួយទៀត លោកប្រៀបថា អក្សរដែលគេទ្វាត់ដាប់ទៅលើផ្ទាំងថ្ម ដើម្បីជាគ្រឿងសំគាល់ឲ្យដឹងនូវទី ដែលមានឆ្នាំងកំណប់ទ្រព្យ ដែលគេកប់ទុកជាបណា, អក្សរទាំងនោះ ទៅមិនបានល្អបរលាយបាត់បង់ទេ មនុស្សទៅចេះមើលអក្សរនោះបានដឹងបានៗ ឆ្នាំងកំណប់ទ្រព្យនោះ ឈ្មោះថាមិនបានវិនាសបាត់បង់ទៅទៅឡើយ ។ សេចក្តីនេះ យ៉ាងណាមិញ ឯសាសនានេះក៏យ៉ាងនោះដែរ គឺបរិយត្តិ ទៅមានតិកុសាមណេរទ្រទ្រង់សិក្សារៀនសូត្រទៅឡើយ ឬមិនបានអន្តរធានទៅដោយហេតុណាមួយទេ សាសនារបស់ព្រះសម្មាសម្ពុទ្ធ ក៏មិនបានអន្តរធានសាបសូន្យទៅដែរ ។

ព្រះពុទ្ធសាសនា មានន័យតែតិប្រការប៉ុណ្ណោះ ពួកពុទ្ធបរិស័ទគួរតែប្រតិបត្តិឲ្យបានគ្រប់ ។ គឺ ឲ្យសមហេតុជាអ្នកកាន់ព្រះពុទ្ធសាសនា ។

សំដៅធំអំពី ន័យព្រះពុទ្ធសាសនា ក៏ល្មមសមគួរដល់កាលវេលាតែប៉ុណ្ណោះ ។ សូមជូនពរចំពោះដល់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ ឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលគ្រប់ៗ គ្នា ។

ឥច្ចេវមត្ថុ ន ឥមិនាត្ថា ភយេនត្ថុ ន ឥមិនាភយា
សោតេនត្ថុ ន ឥមិនាសុខេន យោគ្គំ សទ្ធេមិ ន្ទ្រាណិនោ ។

សត្វសត្វទាំងឡាយ ដែលដល់ហើយនូវខ្ញុំគ្នា សូមឲ្យបាត់ទុក្ខទៅ

ដែលដល់ហើយខ្លួនភ័យ សូមឲ្យបាត់ភ័យទៅ ដែលដល់ហើយខ្លួនសោក សូមឲ្យបាត់សោកទៅ ។

រតនត្តយតេជេន តេរេម្ហាជេរដ្ឋភសិនោ
ភ្លឺឡឺ ភ្លឺឡឺ បបេញ្ញាត្តិ សន្តិកេរក្ខ នាញាជា ។

ដោយតេជៈនៃព្រះរតនត្រៃ សូមឲ្យប្រជាជនក្នុងឆ័កម្ពុជរដ្ឋគ្រប់ដំណក់មួល ដល់នូវការលួតលាស់ចំរើន ទំនឹងសន្តិភាព កុំបីឃ្លាតក្បាយទៅជាបាកវះដទៃឡើយ ។

ធម្មទេសនា បច្ចុតៃប៉ុណ្ណេះ ឯវំ ។

សាសនានៃអង្គព្រះសម្ពុទ្ធ ថ្លៃប្រសើរសុទ្ធគួរគ្រងគ្រាប់
ដោយមានធុរៈពីរនេះស្រាប់ ពុកជាស្ងួនច្បាប់ឲ្យសព្វសត្វ ។
គឺគន្ថធុរៈការសូត្រវៀន អស់ពាំងរបៀនផ្លូវប្រតិបត្តិ
ដើម្បីបេះដឹងហើយលះកាត់ បំផ្លាត់ក្តីល្ងង់ខ្វៀសាមាខ្យ ។
វិបស្សនាធុរៈផ្លូវត្រូវជា ឲ្យឃើញអនិច្ចាកង់សន្តាន
នៃសត្វខ្លួនទៅគ្រប់ភូមិឋាន ឲ្យបានទិញាន់ផុតជាតិសោធិ ។

រឿងវិទ្ធុរភ:

ព្រះមហា ខៀក-អម៉ែ រៀបរៀង

(តចប់)

ស្តេះរឿងនេះ ត្រឹមណេះសិន, និយាយតំព្រះអគ្គមហាសេនាបតីពន្ធុល, ក្រោយពីបាន១ឡើងគាន់ជំណែងនេះ ទ្រង់បានរៀបអាពាហ៍-ពិពាហ៍ជាមួយនឹងធីតាម្ចាស់ឈ្មោះ មល្លិកា ត្រូវជាព្រះពាជបុត្រីនៃក្សត្រាធ្លុ-មល្លៈខៅក្រុងកុសិនារ ។ ព្រះនាងអគ្គមហេសី តាំងពីបាន៤ខែមកនេះ ដែរជាមួយស្វាមីមក មិនទាន់មានបុត្រមួយរស់នៅ ក្រោយមក ព្រះអគ្គមហាសេនាបតីពន្ធុល តុំសត្វព្រះទ័យនឹងព្រះនាងមល្លិកា ក៏បណ្តេញព្រះនាង១ឲ្យត្រឡប់ខៅគាន់មាតុភូមិវិញ ។ ព្រះនាងនៅគាត្មោះអាល័យព្រះស្វាមីណាស់ដែរ តែតុំដឹងធ្វើដូចម្តេច បើតេលែងលះ១ទៅហើយ ប៉ុន្តែ ព្រះនាងបានគិតថា បាំខៅជួបព្រះបរមគ្រូជាម្ចាស់សិន សឹមធ្វើដំណើរខៅស្រុក, ក៏ចូលខៅគាលព្រះសោស្តា ព្រះនាងបានតិតទូលហេតុមូលគ្រប់ ដល់ព្រះអង្គ ។ ខើបព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ចូរនាងវិលខៅលំនៅព្រះស្វាមីនាងវិញសិន១ខៅ ។ បានតាប៉ុណ្ណោះ ព្រះនាងមានសេចក្តីត្រេកអរណាស់ ព្រោះស្រមៃនឹងបំណងរបស់ខ្លួន ខើបត្រឡប់ខៅគ្រាងវិញ ។ ព្រះអគ្គមហាសេនាបតីក្រឡេកឃើញភរិយាដើរមកវិញជួបន្តោះ ក៏សួរថា ហេតុអ្វីបានជានាងត្រឡប់មកវិញ ? ។ ព្រះនាងទូលថា ព្រោះតុំជាម្ចាស់ឲ្យតុំម្ចាស់មក។

ព្រះអង្គម្ចាស់សេនាបតីឮដូច្នោះ មិនហ៊ានបណ្តេញព្រះនាងតទៅទៀត ព្រោះខ្លាចយើញថា "ព្រះពុទ្ធច្បាស់ជាទ្រង់យើញហេតុវែងឆ្ងាយហើយ ឬមានជាហ៊ានឲ្យនាងនេះវិលមកវិញ", ទើបឃលព្រមឲ្យព្រះនាងនៅរួមតទៅទៀត ។ កន្លងមកមិនយូរខែ ព្រះនាងមានគភ៌ធំសោយវត្តុប្លែក ។ ។ ថ្ងៃមួយ ទឹកចង់ទៅស្រង់ទឹកក្នុងស្រះបោក្ខរណី មង្គលឯក្រុងសាវត្ថី ដែលរាជត្រកូលទុកសម្រាប់ប្រើក្នុងការអត់សេចក្តីមួយកាល ។ ព្រះអង្គម្ចាស់សេនាបតី ទ្រង់មានមំណារណាស់ ទើបរៀបចំរនេះបរជូនព្រះនាង ហើយឲ្យនាងដាក់ឆ្នាំរដែលមានកំលាំងខ្លាំងក្លាអាចបាញ់តែម្តងស្លាប់សត្រូវពាប់ពាន់នាក់ ។ ព្រះអង្គម្ចាស់សេនាបតី ឲ្យនាងចូលតាមទ្វារព្រះអង្គម្ចាស់មហាលិ ដែលត្រូវជាមិត្រសម្លាញ់ទីឆ្នាំកាលទៅសិក្សាឯមហាវិទ្យាល័យនាក្រុងតក្កសិលា ។ ព្រះអង្គម្ចាស់មហាលិគ្រាន់តែឮសូរសេន្ធឹករនេះ ក៏ស្គាល់ឮនថា ប្រាកដជារនេះពន្លឺសំឡាញ់អញហើយ ថ្ងៃនេះមុខជាមានកើតកឃន្ធកឃដល់ពួកលិច្ឆវីមិនខាន (១)។ និយាយពីស្រះបោក្ខរណី, គេមានចាត់មនុស្សមានអាវុធទាំងឆ្នាំងបន្តិចឲ្យទៅចាំរក្សាទាំងខាងក្នុងទាំងខាងក្រៅបង ផ្នែកខាងលើមានតាសសំណាញ់លួសពន្លុំវិញ សូម្បីសត្វបក្សី ក៏ហើរទម្លាយចូលទៅមិនរួចដែរ ។ លុះព្រះអង្គម្ចាស់សេនាបតីឥន្ទលបររនេះមកដល់ ក៏ចុះទៅរង់ពួកអ្នកយាម

---

១ - ពួកលិច្ឆវីនេះ គឺសុទ្ធតែជាជាតិក្សត្រ ។

ទាំងអស់នោះមួយរំពាត់ផ្តៀមម្ចាត់ ។ រត់បើកទៅអស់ ហើយតាត់សំណាញ់ លួសនាំព្រះនាងចូលទៅក្រសាលទឹកតាមសប្បាយ រួចហើយទ្បើងថយមកតាមផ្លូវចាស់ដែលចូលទៅពីលើកមុន ។ ចំណែកពួកអ្នកយាមស្រុះគ្រោយពីបានត្រូវមួយរំពាត់ម្ចាត់យ៉ាងដំណាំ គំរាត់ទៅប្រាប់ពួកលិច្ឆវី ទឹកភ្លៅក្រហាយនឹងអំពើយោរយៅ របស់សេនាបតីតន្ទុលខ្វាំងណាស់ គិតនាំគ្នាខឹមរទេះដេញតាមចាប់យកមកជួនាគោស ។ តែព្រះអង្គម្ចាស់មហោលិបានឱយាយឃាត់ថា «អ្នកវាល់គ្នាកុំដេញតាមវាធ្វើអ្វី ក្រែងវាសម្លាប់បានវិញនាំអសារបង់ទេ» ។ ពួកលិច្ឆវី មិនព្រមស្តាប់ពាក្យមហាលិ អ្នកខ្វះធ្វើយតបថា "យើងចាប់អាកំណាចនោះឲ្យបាន លោកចាំមើលចុះ» ។ ដោយទ្រង់យល់ឃើញថា មិនអាចនឹងឃាត់ពួកគាំងនោះបាន ព្រះអង្គម្ចាស់មហាលិបានផ្តាំទៅពួកនេះ ដោយសេចក្តីអាណិតអាសូរថា នែអ្នកគាំងឡួយ ! ចាំស្តាប់ខ្ញុំសិន បើអ្នកលិច្ឆវីគ្នាមុខក្រាស់ចេះមិនព្រមតាមពាក្យសំដីខ្ញុំទេ ក្រែទៅតាមតាប់ចិត្តរបស់ខ្លួនចុះ តែខ្ញុំសុំផ្តាំថា បើអ្នកគាំងឡួយឃើញកន់រទេះលិច្ឆវីកុំដាច់ដីត្រឹមខ្លួត ទោះត្រូវបួលគ្នាជួយគ្រោយមកវិញកុំខាន បើមិនព្រមជួយ ចូរអ្នកគាំងឡួយចាំស្តាប់សូរ បេក្តីសន្ធឹកដួងវិញ្ញាណខ្លះទៅខាងមុខ គប្បីជួយគ្រោយឲ្យឆាប់ ប៉ុន្តែតែមិនជួយទេ ចូរអ្នកគាំងឡួយតំរិះមើលចន្លោះទទេរវែង ។ ខ្លួនមុខជានឹងឃើញប្រយោជន៍ក្នុងមិនខាន ហើយត្រូវនាំគ្នាវិលមកឆ្ពុះវិញកុំបាច់តាមតទៅទៀត ដ៏ការ

ឥតប្រយោជន៍ទេ ។ លុះចប់សេចក្តីរំលឹកនៃព្រះអង្គម្ចាស់មហាសិកាលណា ក្តួតលិច្ឆវីបែរត្រឡប់ទៅរកសំពួសវិញ ដោយ ! ប៉ាបទ រួចបរបំផាញរាស្ត្រទេះដេញតាមសេនាបតីពន្ធុល ។ ពួកនេះគេប៉ើយញែលចហេតុខ្លះ ។ ល្មមឲ្យសំគាល់ឃាន់ដូចភាក្សមហាសិកាបានផ្តន្ទាំនោះ កំពង់តែមិនត្រមង់ឃើមកក្រោយវិញ ទេរតែនាំគ្នាបំភ្លោលរាស្ត្រទេះរៀន ។ ខ្លួន ។ ព្រះនាងមល្លិកាក្រឡេកយើញរាស្ត្រទេះខ្ចាប់ពីក្រោយ ហាក់ដូចជាមានហេតុគេចថ្លែកពីដម្ពតាខើបកែះក្រាប់ស្វាមីថា "ម្ចាស់ចង! រាស្ត្រទេះពួកណា ដេញតាមក្រោយយើងច្រើនម្ល៉ះ តើគេប្រាថ្នាធ្វើអ្វីដល់យើង ?" ។ ព្រះអង្គម្ចាស់សេនាបតីឆ្លើយថា "អូនកុំព្រួយ ទេះគឺរាស្ត្រទេះពួកលិច្ឆវី, កាលណារាស្ត្រទេះពួកវាត់ផ្លូវត្រង់គ្នា ប្អូនានក្រាប់មកបង" ។ លុះរាស្ត្រទេះព្រះអង្គម្ចាស់ដកឃ្លាទៅមុខបានបន្តិច ព្រះនាងបែរទៅក្រោយ ស្រាប់តែយើញរាស្ត្រទេះពួកបច្ចាមិត្រលឿនត្រចាញ់ត្រង់ផ្លូវគ្នាតែមួយ កំពែងក្រាប់ស្វាមីម្តងទៀត ។ ទើបសេនាបតីពន្ធុលហុចខ្សែបរទៅឲ្យព្រះនាងក្រាប់ថា ប្អូរអូនកាន់ឲ្យជាប់ ។ តាំងលើកដួងឡើងសំដែងអាការហាក់ដូចជាបង់ជ្រាញ់ ។ ពួកលិច្ឆវីរើយើញកន់រាស្ត្រទេះលិចទៅកន្លងដើ តែនៅច្រឹងដេញតាមតទៅទៀត ។ ព្រះអង្គម្ចាស់សេនាបតី យឺតបន្ទោរធ្លាញ់ខ្លាប់ ឮសូរធាំង! ដូចគ្រាប់អសនី ព្រួញហើរស្ទុះទៅមុតដួងរាស្ត្រទេះ ចាំង ៥០០ ព្រមទាំងអ្នកដឹងទៅនោះផង ។ ឯពួកលិច្ឆវីតុំពាន់ដើងថា ខ្លួនត្រូវគ្រោះអាសន្នទៅឡើយ ប្រើតែដេញតាមស្រែក

សន្ធាប់ពីគ្រាយថា "ខែ! តាចោរសាមាខ្យ ឈប់សិន។" ។ សេនាបតី
ពន្លកឹបញ្ឈប់វេះ រួសកប្រាប់ទៅវិញថា "ម្ចាលពួកខ្មោច! អ្នក
វាល់គ្នានេះសុទ្ធតែជាខ្មោចទេតើ យើងឥតត្រូវការច្បាំងជណ្តើមយកឈ្នះ
ចាញ់នឹងពួកខ្មោចទៀតទេ" ។ ពួកលិច្ឆវីតបត្រមគ្នាទៅវិញថា "យើ!
មនុស្សប្រហែលពួកយើងនេះ មិនងាយនឹងស្លាប់ផ្តាសទេ" ។ ទើប
ព្រះឥន្ទ្រាម្ចាស់ពន្លកប្រាប់ថា "បើអ្នកពាល់គ្នា មិនដឿយើងទេ ចូរស្រាយ
គ្រឿងគ្រោះ (ប្រដាប់ការពារប្រាណក្នុងចំបាំង) អ្នកនេះគ្រាយគេបង្ក្រាប
លេមើយ" ។ ពួកលិច្ឆវីក៏ធ្វើតាម ។ លុះស្រាយគ្រឿង ចូរសេនាដួលបះ
ដើងស្លាប់មួយរំពេចខោះគ្នាម ។ ទើបសេនាបតីពន្លកប្រាប់ភរទៅទៀត
ថា អ្នកឯងត្រាប់គ្នានេះ ឥឡូវនឹងបានទៅនៅស្រុកខ្មោចវិញបុសេនានេះ
ហេតុនេះ ដល់ត្រូវប្រាប់ទៅគួរវិញ តប្បីកុំកម្រើកកំនត់ហើយផ្តែផ្តាំប្រពន្ធកូន
ឲ្យស្រេច សឹមស្រាយគ្រឿងគ្រោះតំទ្វេ ។ ម្ចាលនេះពួកលិច្ឆវីក៏តាម
លែងហ៊ានដេញតទៅទៀត, លុះបានទៅដល់ឆ្នេរ គ្រាយដែលជុនធ្វើតាមបង្គាប់ព្រះឥន្ទ្រាម្ចាស់សេនាបតីប្រកាសណា តំដល់ទ្វារមណ្ឌលត្រប់ៗគ្នា ។ ចំណែកព្រះឥន្ទ្រាម្ចាស់សេនាបតី បានគាំងរយាត្រូវប្រាប់ទៅ
កាន់ក្រុងសាវត្ថីវិញដោយសុវត្ថិភាព ។ លុះឥតត្រប់ខែ ព្រះនាងមល្លិកា
ប្រសូត្របុត្រមួយឆ្នូ ប្រុប ១៦ ដង ត្រូវជា ៣២ នាក់ ។ កុមារទាំង
នោះធំឡើងកាលណា មានសភាពជាអ្នកក្លាហានណាស់ ឥតុកម្លាយ

ចុះឲ្យសិក្សាសិល្បសាស្ត្រគ្រប់ ៦ គ្នា, ដល់រៀងចេះចប់ ត្រូវចុះកូនខាហានខ្នាត់ ១ ពាន់ ១ ជាបរិវារ ។

សម័យថ្ងៃមួយ ទៅទីឆ្ងាសាលាវិនិច្ឆ័យ ពួកអាណាប្រជាទុកស្ត្រកើតខ្លួនតាមនស្ស្តេតក្រហាយទឹងនឹងចៅក្រមពុទ្ធិតែ ដែលកាត់ក្តីដោយអយុត្តិធម៌ស៊ីសំណូកសូកប៉ាន់ ឥតអាណិតអាសូរដល់ពស្ត្រគួចតាចក្រៃក្រ លុះក្រេឡកឃើញសេនាបតីតន្លៃយ៉ាងមកពីចម្ងាយ គំស្រែកយ៉ាងគគឹរពងហើយរៀបពាំទូរៀនហោតុរៀនពាល់ខ្លួន ឲ្យព្រះអគ្គមហាសេនាបតីឃាន ផ្ទាប ។ ឯដូច្នោះ, ព្រះអគ្គមហាមន្ត្រី គំឡើងទៅកាត់ឲ្យបណ្តាពស្ត្រ ត្រឹមត្រូវតាមគន្លងច្បាប់ តីកាត់ឲ្យឈ្នះឲ្យចាញ់តាមដំណើរក្តី ។ ខណៈនោះ សំឡេងខ្លះដៃហៅកញ្ជ្រៀវថ្ងៃឃពារសត្តសាធុការ គំលាន់ព្រះឡើងយ៉ាងគ្រហឹមអឺងអាប់ សំដែងនូវទំនងចិត្តស្មោះសរចំពោះព្រះអគ្គមហាសេ ។ ជំណឹងនេះ ជ្រាបដល់ត្រមេហាក្សត្រ ទ្រង់មានព្រះពជ្ឈទ័យសោមនស្សពន់ពេក ទើបប្រគល់ដំណែងចៅក្រមដល់ព្រះអគ្គមហាសេនាបតី ។ ចាប់តាំងពីនោះមក គេស្គាល់តែអំពើសុចរិតយុត្តិធម៌ទៅក្នុងសាលាវិនិច្ឆ័យ ដោយហេតុលោកចៅក្រមថ្មី កាត់ក្តីតាមគតិច្បាប់មិនលំអៀងដោយហេតុណាមួយ ។ ថ្លែងពីពួកអតីតចៅក្រម ក្រោយដែលខ្លួនចុះចាញ់ពីដំណែងនេះហើយ កំសាបសូន្យបាត់លាភ មិនសំបូរបាយសប្បាយស៊ីដូចមុនទៀត គំរកឧបាយកលនឹងសម្លាប់ព្រះមហាក្សត្រ ទូលមូលបង្កាច់ថា សេនាបតីតន្លៃបង់

ជរណ្តើមពងមស្ងួត ។ ព្រះពាជាដឿសំដីអគុសលរបស់ពួកល្មោភបុណ្យ
ស័ក្តិតាំងនេះ ទ្រង់មិនបានតិចារណារកហេតុផលឲ្យវែងឆ្ងាយតទៅទៀត
ហើយមិនអាចនឹងទប់ព្រះទ័យបំពោះសេចក្តីក្រោធបាន តំរែងបាយរំលំ
សេនាបតីពន្លស់ដោយវិធីម្យ៉ាង គឺទ្រង់ឆ្ងល់យល់ថា បើឲ្យគេសម្លាប់ពន្លស
នៅទីនេះ មុខជាត្រូវគេរិះគន់តិះដៀលមន្ត្រីជាមិនខាន ព្រោះហេតុអ្វី ?
ព្រោះថាគ្មានកងកូតានដ៏ជាក់លាក់ ដើម្បីនឹងយកមកបង្ហាញឲ្យបណ្តាជន
ទូទៅដឿបានផងសោះ ទើបទ្រង់ប្រើទៅយកសេ ធ្វើឲ្យគេតបះបោរ
នៅជាយដែន រួចត្រាស់ហៅព្រះអគ្គមហាសេនាបតីពន្លសមកប្រាប់ថា
"ឥឡូវនេះ នៅព្រំប្រទល់ដែន មានការបះបោរសម្រេចណាស់ សុំឲ្យ
លោកនាំបុត្រតាំងអស់ ទៅបង្ក្រាបពួកខ្មាំងតាំងនោះ ឲ្យបានពាបគាបវិញ"
រួចព្រះហស្តទ្រង់ចាត់តំណែងតាមសេសមួយក្រុម ដែលមានសេចក្តីអង់អាច
ក្នុងការបំភេញនូវព្រះរាជបំណង ហើយប្រាប់ថា "ចូរអ្នកតាំងឡាយ
តាត់ក្បាលសេនាបតីពន្លស ខ្លះបុត្ររបស់ក៏តាំង ៣២ នាក់ឲ្យអស់" ។
ចំណែកពួកទូម លុះបានឮថា សេនាបតីពន្លសមកដល់ទល់ដែន
ហើយ ក៏តក់ខ្លាចខ្លាយអស់ ។ ព្រះអគ្គមហាសេនាបតីពន្លសបានរៀបចំតំបន់នោះ
សាន្តស្រាណាហើយ ក៏តាំរៅពាំលសិលចូលមកតាន់ព្រះពាជាទៀត ។
តែអគុសលមកដល់ពាក់កណ្តាលផ្លូវ ស្រាប់តែចំពន្លក់របស់ស្តេចស្លាប់
ជាញាក់សម្លាប់ពាលតាំងនឹងពួកតាំងក្មួយអស់ ។

ថ្ងៃនោះ នាងមល្លិកាកំពុងធ្វើបុណ្យ ទំមន្តព្រះអគ្គសាវ័កទាំងពីរអង្គ ព្រមទាំងព្រះសង្ឃឯទៀត ៥០០ អង្គ ឲ្យនាង់នៅក្នុងគេហដ្ឋានរបស់នាង ស្រាប់តែមានគេទាំដំណឹងមកក្រាប់ ព្រមទាំងសំបុត្រមួយឆន្ទៈថា « ឪម្ចាស់ នឹងបុត្ររបស់នាង ត្រូវក្រុមចោរសម្ងាត់របស់ហ្លួងសម្លាប់ចោលអស់ទៅហើយ » ។ ឯព្រះនាងមល្លិកា សូម្បីបានឮពត៌មានដ៏អាស្រូវដូច្នោះ ក៏គ្មានតក់ស្លុតបន្តិចបន្តួច ហើយគ្មានឲ្យនរណាម្នាក់ ដឹងរឿងនេះទៀតផង ព្រះនាងជាក់សំបុត្រនោះទៅក្នុងហោប៉ៅ ហើយប្រឹងចំរើនសង្ឃយ៉ាងស្ងប់ស្ងៀម ។ ពេលនោះស្រីចំរើកំពុងលើកបាយបង្ហិនមកប្រគេនលោក ស្រាប់តែធ្លាក់បានសម្លមួយបែកខ្ចាយទៅមុខព្រះសង្ឃ ។ ព្រះសារីបុត្ត ឃើញមានថេរដីកាទៅកាន់នាងមល្លិកាថា « សុំក្បាមកុំតិតគួរអ្វីនឹងស្ត្រីសាវតើក្នុងលោកនេះ តែដឹងតែពុកផុយបែកធ្លាក់ទៅក្បាថាធម្មតាដូច្នេះឯង » ។ ទើបព្រះនាងលូកយកសំបុត្រពីហោប៉ៅមកអានប្រគេនព្រះថេរៈស្តាប់ រួចព្រះនាងពិតភ្លុដីកាបន្ទូលថា តោះបើខ្ញុំព្រះករុណាដឹងដំណើរនេះហើយ ក៏គ្មានតូចតោមទុក្ខ តិតគួរដូចម្តេចទៅទៀតទេ ប៉ើហេតុធំដល់ម្ចាស់ ខ្ញុំព្រះករុណាមិនតិតសោះ តើខ្ញុំព្រះករុណាតិតធ្វើអ្វីសព្វបើពីរឿងបានមួយបែកនោះ ។ ទើបព្រះថេរៈមានពុទ្ធដីកាជាបទព្រះគាថាដូចតទៅនេះ ៖

អនិមិត្តមនញ្ញាតំ មច្ចានំ ឥធ ជីវិតំ

ភាសាខ្មែរ បារាំង តាំង ឧក្រិដ្ឋ សំយុត្តិ

«មែនហើយញោម ជីវិតសត្វសត្វក្នុងពិភពលោកនេះ គ្មានអ្នកណាមួយកំណត់ដឹងទេ ហើយការស់នៅនោះសោតទៀត ក៏មិនបានយឺនយូរប៉ុន្មានដែរ តាំងជាការលំបាកដាច់ចំផុត ព្រោះច្រឡំបល់ទៅដោយសេចក្តីទុក្ខគ្រប់បែបយ៉ាង» រួចហើយ ក៏ចំរើនពរសាព្រះនាងត្រឡប់ទៅកាន់ភពវិញ។ តមកព្រះនាងមល្លិកា ជានហៅកូនប្រុសស្រីតាំង ៣២ រូប មកប្រាប់ហើយទូន្មានថា «ប្តីនាងតាំងអស់គ្នា គ្មានកំហុសអ្វីបន្តិចបន្តួចទេ ប៉ុន្តែ ពេលនេះត្រូវទទួលផលនៃកម្មពីអតីតជាតិមក ហេតុនេះ ចូរនាងតាំងរាល់គ្នាកុំសោកស្រណោះអាលោះអាល័យធ្វើអ្វី ហើយកុំធ្វើខ្លួនសេចក្តីថ្នាំងថ្នាក់ចិត្តចំពោះព្រះមហាក្សត្រដែនដីយើងឲ្យសោះ» អ្នកយកការឲ្យស្តេច លុះបានឮភាសាដ៏ផ្អែមល្ហែមប្រកបដោយសុខចិត្តដូច្នោះ ក៏នាំយកទៅក្រាបទូលព្រះរាជា ព្រមទាំងថ្វាយឲ្យព្រះអង្គបានជ្រាប អំពីសេចក្តីទូលនឹងបុត្រារបស់លោក ដែលគ្មានទោសកំហុសអ្វីសោះ។ លុះទ្រង់ព្រះសណ្តាប់សេចក្តីឲ្យការណ៍ពីចារីប្រុសនោះចប់, ព្រះទៅបសេនទិព្រះមានព្រះទ័យនឹងសង្វេគ ហើយគើតវិប្បដិសារីជាខាងក្រោយ ទើបយាងទៅកាន់លំនៅ ព្រះនាងមល្លិកាផ្តាំផ្ញើព្រះអង្គ ហើយសុំឲ្យនាងនឹងកូនប្រុសអត់ទោសឲ្យព្រះអង្គ រួចទ្រង់ព្រះពរជាពរដល់ស្ត្រីតាំងនោះ។ ព្រះនាងមល្លិកាទូលថា «ពរដែលទ្រង់ព្រះពរជាពរជ្រាលមកនេះ ខ្ញុំម្ចាស់

សូមទទួលយកដោយស្វាមីភក្តិ, ប៉ុន្តែ ខ្ញុំម្ចាស់គឺតបំណងចង់ថ្វាយកអ្វី
ទេ គ្រាន់តែសូមទ្រង់ព្រះពជានុញ្ញាតឲ្យដល់ខ្ញុំម្ចាស់ ទីឆ្កែកូនប្រសាំងឆ
៣២ រូប ចានរំលេចសាងដីតែពាក់ថ្នាំជាមួយនឹងមាតាបិតាវិញបុំណ្ណោះ សូម
ទ្រង់ព្រះមេត្តាប្រោស" ។ ព្រះមហាក្សត្រចានព្រះពជានុញ្ញាតឲ្យទាន
តាមសុំ ។ ថ្ងៃក្រោយ ទ្រង់ចានតែងតាំងក្នុងឋានៈសេនាបតីធនុបេ
ឈ្មោះ ទីឃការយ៉ន ឲ្យកាន់តំណែងនេះវិញ ។ លោកសេនាបតី
ទីឃការយ៉ន ក្រោយតិចានឡើងកាន់ដំណែងនេះគាលណា រមែងនឹក
ឃើញខ្លួនអនុស្សាវរីយ៍ដ៏អាក្រក់ របស់ព្រះមហាក្សត្រជាម្ចាស់ចិត្ត ហើយ
ចានចង់ចិត្តពុកចានឆ្នើសឆឹតវិញឲ្យចាន ។ រីឯព្រះរាជវង្សនៃដ៏ ចាប់តាំងពី
ចានជ្រាបច្បាស់ នូវសេចក្តីគំនួចឡើរបស់ព្រះអង្គមក ទ្រង់ពុំដែលចានតែ
រាយក្នុងព្រះទ័យដូចពេលមុន ។ ទេ បេះតែមានសេចក្តីភ្លៀក្រហាយស្តាយ
ក្រោយមិនចាត់សោះ ។

សម័យមួយនោះ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ឃាងទៅគាន់និគមមួយ
ឈ្មោះ មេទឡុប ដែលជាកម្មសិទ្ធិរបស់ពួកសាក្យៈ ។ ឯព្រះចានបរសេនទិ
ទ្រង់ក៏ឃាងចេញទៅសំចតរហ៍ពាលក្បែរទីនោះដែរ ព្រះអង្គចានឆ្លៀត
ឱកាសចូលទៅថ្វាយបង្គំព្រះបរមសាស្តា ហើយផ្ញើត្រឿងពជកកុធភណ្ឌ
(ប្រដាប់សម្រាប់ពជ) ទុកនៅនឹងលោកសេនាបតី ទីឃការយ៉ន ។
លោកសេនាបតីនេះ ចានឱ្យសាសល្អ ដោយខ្លួនប៉ង់ទុកមកយូរហើយ កំតាំង

បំពាក់គ្រឿងសម្រាប់កាជ្យទៅសេនាបតីវិដូឌកៈ ឲ្យធ្វើជាស្តេច ហើយខុកសេរមួយ ទឹងស្តេចបំរើម្នាក់ឲ្យស្តេចបសេនទិ កំនាំគ្នាវិលទៅកាន់ក្រុងសាវត្ថីវិញ ។ ព្រះបាបសេនទិ ទ្រង់កំពុងតែសន្ទនាស្និទ្ធស្នាលជាមួយនឹងព្រះពុទ្ធជាម្ចាស់ លុះទេញមកវិញ ស្រាប់តែឃាត់រហ័ពលអស់ លុះទ្រង់ជ្រាបនូវអំពើនៃសេនាបតីខាងក្រោយនោះគាល ក៏គាំងព្រះទ័យថា នឹងចាប់វិដូឌកៈ ឲ្យបានវិញ ។ ទើបស្តេចយាងត្មោះទៅកាន់ទន្លេរកផ្លែឈើជាមួយបាវស្រីហើយនឹងសេរមួយនោះ ដើម្បីទៅបបួលព្រះមហាកស្សបត្ថេរដែលត្រូវជាព្រះគោតមេយ្យ (ក្មួយ) របស់ព្រះអង្គស្រាប់ ដេញតាមចាប់ពួកកស្សក៏ពន្យាំងនោះ ។ តែអនិច្ចា! កន្លងព្រះពុទ្ធដំណើរដើរទេញ តោរទៅដោយសេចក្តីខ្ជិលច្រអូសមួយពាន់ជំពូកនោះ ព្រះអាទិត្យបានបបួលកាន់ទឹកសព្វគ្រឹតបាត់តម្លើស្មើអស់ទៅហើយ, នៅត្រង់គេហដ្ឋាន គេនាំគ្នាបូមទឹកស្រាលក់ស្អាប់ស្អាល់, តាំងពីវានៃព្រះពុទ្ធជាទីគ្រប់ចិត្តអស់ ។ ទ្រង់ទតឃើញដូច្នោះ ព្រះបាតុំដ៏ជាបួលតាមប្រកណា ទើបយាងទៅប្រថាប់ក្នុងសាលាមួយ ហើយទ្រង់ត្រាស់ទៅថានោះ ។ គួរឲ្យតាស្ងួរដល់ព្រះអង្គពេកណាស់ នាពេលកត្រដ៏ងងប់ងងុយនោះ ដោយហេតុទ្រង់ខ្ជឿយព្រះកាយពលត្រូវកំដៅព្រះអាទិត្យកាលយាងមកតាមផ្លូវ បណ្តាលឲ្យព្រះបាទកើតព្រះពេគខ្យល់គ ឥតនរណាម្នាក់ជាន់ដឹងជាន់ឆ្ងល់សោះ ក៏សោយទីវង្គតទៅកាន់ស្ថានាយតាមយថាកម្ម ។ លុះដល់ពេលភ្លឺស្វាង នាង

តាស៊ីក្បាក់ឡើងដឹងថា ព្រះពុទ្ធជាម្ចាស់ទ្រង់សោយព្រះទិវង្គតដូច្នោះ ក៏គក់ទ្រូងយំខ្លាំងរៀបរាប់ថា "ឱ! ព្រះនាថខ្ញុំនេះបានជាម្ចាស់នៃខ្ញុំអើយ! មិនគួរឡើយព្រះអង្គមកសោយទិវង្គតឆាប់ព្រោះដន្លាយ ឯកោអនាថាយ៉ាងនេះដូច្នេះសោះ"។ ។ ពួកអ្នកស្រុក បានឮដូច្នោះ ក៏ចូលទៅគ្រាបទូលព្រះមហាក្សត្រជាម្ចាស់ផែនដី ។ ឯព្រះចក្រី ទ្រង់មានព្រះទ័យសន្តោសប្រោសប្រាណ បានយកសពព្រះមាតុលោ (ឪពុកមា) ទៅធ្វើបុណ្យយ៉ាងអស្ចារ្យ ដើម្បីជាការលើកដំកើងនូវព្រះគុណយសរបស់ទ្រង់ ។

តទៅនេះ ខ្ញុំនឹងត្រឡប់មកនិយាយពីសេនាបតីវិញ, លុះយកពាក្យអំពីឱតាបានតាលណា តាំងរំលឹកនូវរឿងរាស់របស់ខ្លួន ដែលពួកសាក្យៈបានធ្វើឲ្យបាក់មុខតាំងពីមុន, ទើបនាំពលទាហានមួយកងធំដែលមានព្រះអង្គជាមេអគ្គបញ្ជាការផ្ទាល់ ចេញពីក្រុងសាវត្ថីឆ្ពោះទៅក្រុងកបិលវត្ថុ ដើម្បីសងសឹកនូវពួកសាក្យៈ ។ ថ្ងៃនោះ វេលាថៃកមជ្ឈិមសម័យ (ជិតភ្លឺ) សម្តេចព្រះជិនស្រីជាម្ចាស់នៃយើង ទ្រង់ប្រមើលមើលឧបនិស្ស័យនៃសត្វលោកក្នុងវិត្រកភព ឃើញនូវសេចក្តីវិនាសរបស់ពួកញាតិព្រះអង្គ ទើបទ្រង់ព្រះចិន្តាថា ខ្ញុំឯងនៅទៀតជួយសង្គ្រោះឲ្យរួចផុតអំពីសេចក្តីអន្តរាយ រួចទ្រង់ប្រជាប់ចាត្រចីវរ ចេញទៅបិណ្ឌបាតត្រង់ច្រកល្ហក ហើយយាងត្រឡប់មកគង់អាកមវិញ ។ ពេលរសៀលព្រះអង្គឃើញហោរាគាត់អាកាសវេហាស៍ ឆ្ពោះទៅកបិលព័ស្តុបុរី ទៅពុះ

ប្រជាប់ក្បាលគល់ឈើមួយដើមដែលមានមូលរដាច់ៗ ជិតដំរែនឹងទ័ពព្រះចៅ
វិឌូឌុកៈ ។ ព្រះពាជាក្រឡេកឃើញព្រះបរមសាស្តា កំពុងលេងធ្លើតារវែកចួ
រួចត្រាស់សួរថា « បពិត្រព្រះអង្គ ! តើស្តេចយាងមកប្រជាប់ក្រោមមូលឈើ
រដាច់ៗ ដូច្នេះ ទំនងជាមានការអ្វីឬ ? សូមស្តេចយាងទៅប្រជាប់ក្រោម
មូលត្រើងឯណោះវិញទើបត្រជាក់ស្រួល » ។ ព្រះសម្ពុទ្ធទ្រង់តបទៅវិញថា
« មិនអីទេមហាពាជ ! មូលភូតភ្លាត (របស់តថាគត) ទើបត្រជាក់ជាង » ។
ព្រះបាទវិឌូឌុកៈ ឮដូច្នោះ ក៏ខ្ញាល់យល់ថា ត្រាស់បន្ទោបង្អាស់ជាយាងមកការ
ពារព្រះញាតិព្រះអង្គហើយៈមើលទៅ ទើបថ្វាយបង្គំព្រះបរមគ្រូហើយនាំ
កងទ័ពវិលទៅគាន់ក្រុងសាវត្ថីវិញ ។ ចំណែកព្រះសម្ពុទ្ធក៏ទ្រង់យាងត្រឡប់
ទៅវត្តវេឡុវនវិញដែរ ។ ព្រះបាទវិឌូឌុកៈ ទ្រង់បានប្រព្រឹត្តអំពើបែបនេះ
អស់វារៈ ៣ លើក ប៉ុន្តែទេសកាលក្តី មកជួបតែទឹងព្រះពុទ្ធជាម្ចាស់
ជាហេតុធ្វើឲ្យគោលបំណងរបស់ទ្រង់មិនបានសម្រេច ។ ព្រះចៅនៅតែចង
ពៀរវែងចំពោះពួកសាក្យៈមិនគាន់ឈប់ទេ, លុះដល់លើកទី ៤ ព្រះសម្ពុ
ទ្ធទ្រង់ប្រមើលមើលឃើញថា មិនអាចនឹងជួយស្រោចស្រង់ព្រះញាតិរបស់
ព្រះអង្គឲ្យរួចផុតអំពីកណ្តាប់ដៃស្តេចនេះបានទេ ព្រោះពួកសាក្យៈបានធ្វើ
អំពើកម្មពីជាតិមុនធ្ងន់ណាស់ គឺបង់ថ្នាំពិសចំពុលត្រីក្នុងស្ទឹងស្ទាប់រាប់មិន
អស់ ហេតុនេះ បានជាព្រះអង្គមិនយាងទៅទៀត ។ ឯព្រះចៅវិឌូឌុកៈ
បានបញ្ជាកងទ័ពយ៉ាងធំ ចេញទៅដួចលើកមុនទៀត ។

ថ្លែងព័ត៌ព្រះញាតិវង្សនៃព្រះបរមសាស្តា, ពួកនេះ សុទ្ធតែជាអ្នក
រៀបចាកអំពើថ្នាំណាតិឃាត ទោះបីបញ្ជាស្តាប់រស់ចោទមកចំខ្លួន ក៏ស៊ូ
លះបង់ជីវិតឥតស្តាយ មិនហ៊ានបៀតបៀនសត្រូវវិញទេ ។ ពួកនេះ
ចាន់ប្រដុំពិភាក្សាគ្នាថា " ឥឡូវនេះ ពួកកងទ័ពរស្តេចវិទូឌកៈ ចាន់លើក
មកបំផ្លាញទីធីតយុទ្ធជាមួយយើងហើយ, ឯពួកយើង ក៏សុទ្ធតែរៀនចេះថ្នាក
ខាងយុទ្ធសាស្ត្រដូចគ្នាដែរ តែពួកយើងមិនត្រូវតទល់ទាំងសត្រូវបែរ
យើងឲ្យអន្តរាយដល់ជីវិតទេ, ក្នុងករណីនេះ គួរយើងគ្រាន់តែធ្វើសមយុទ្ធ
សំដែងនូវឥទ្ធិពលរបស់យើង ដើម្បីជាការគម្រាមកំញែញដល់បច្ចាមិត្រ
ឲ្យខ្លាចហ៊ានចេញមកវិញតែប៉ុណ្ណោះ " ។ ក្រោយដែលចាន់អនុម័ត
នូវយោបល់នេះហើយ ពួកសាក្យៈតាំងរៀបចំគ្រឿងយុទ្ធោបករណ៍ដើរ
ក្បួនទៅកាន់ទីសមរភូមិ ។ ខណៈនោះ គូសត្រូវចាន់ប្រយុទ្ធគ្នាយ៉ាង
សាហាវ ។ បេះរបស់ពួកសាក្យៈហើរច្រវាត់ប្រពាត់គ្នាសំដៅទៅពួក
បច្ចាមិត្រ តាមបន្ទោរខែលខ្លះ បន្ទះក្តារខ្លះ តាមបន្ទោរគុម្ពត្រចៀក
ទីឯសខ្លះភ្លៀកខ្លះ ។ ព្រះចាន់វិទូឌកៈ ទតឃើញដូច្នោះ ក៏ស្រែកឆ្លួច
ឆ្លើយទៅពួកសាក្យៈថា " នែពួកសាក្យៈ ! ក្រែងពួកអ្នកឯងគិតខ្លួនថា
មិនសម្លាប់ជីវិតមនុស្សសត្វទេឬ ? ឥឡូវនេះ ម្តេចក៏ហ៊ានញុំាងកូន
ចាហានទាំងឡាយរបស់យើងឲ្យវិនាសដូច្នេះ ? " ។ លំដាប់នោះ មាន
ចាហានម្នាក់ទូលថា " សូមទ្រង់ព្រះមេត្តាប្រោស សេនាចាហានរបស់

ព្រះអង្គសូម្បីតែម្នាក់ក៏គ្មានស្ទាប់ដែរ បើទ្រង់នៅសង្ឃឹម សូមចាត់ឲ្យ
ភប់មើល ។ ។ ទើបព្រះបាទ ត្រាស់បញ្ជាឲ្យកប់ពលបរិស័ទព្រះអង្គតាម
ពាក្យគាហានោះ ប៉ុន្តែឥតបាត់មនុស្សម្នាក់សោះ ។ តមកទ្រង់ជកខ័ត
ថយតិចនោះបន្តិច រួចមានព្រះពុទ្ធសាសនិកៅគាន់ក្រមុំយុទ្ធការថា ៖ នែ
កងគាហានយើង ! ចូរអ្នកទាំងឡាយសម្លាប់ពួកខ្មាំងដែលនៅឯយថា វាថា
ជាតិសាក្យៈបោលឲ្យអស់ តែត្រូវទុកជីវិតលោកតាមហានាមនឹងមនុស្ស
ដែលគ្រាបកែវគាត់ ។ ។ ឯពួកសាក្យៈគ្រាយដែលពួកខ្មាំងបានឡោម
ព័ទ្ធគ្រប់ទិស បាប់បានទាំងខ្លួនទៀត ឥតមានបញ្ញាអ្វីដោះស្រាយឲ្យរួច
ជីវិតសោះឡើយ ព្រោះពួកខ្លួនជាអ្នកវៀរចាកអំពើបញ្ចរភេ ប៉ុន្តែ អ្នកខ្លះ
មានបញ្ញាខឹកយើញគាន់ ក៏ខ្លួនទាំងពុងស្មៅ ខ្លះទាំងពុងបបោស លុះទាំង
បាប់បានសួរបម្រើយ ក៏ឆ្លើយថា មិនមែនសាក្យៈទេ គឺស្មៅ ខ្លះថា គឺ
បបោស ។ អាស្រ័យហេតុនេះ ជនណាដែលបានឆ្លើយដូចគេលមក
នេះ ជនទោះត្រូវចំខ្លួនជុតតិសេចក្តីស្លាប់ ទាំងព្រះអង្គម្ចាស់មហានាម
ហើយទាំងពួកជនដែលនៅក្បែរទ្រង់ ក៏ត្រូវចំខ្លួនដែរ ។ ត្រង់ពាក្យ
សូម្បីតែគេនៅស្ទៅដោះនេះឡើយ ត្រូវបានពួកបច្ចាមិត្តស្តាប់ដឹងឥតមាន
ត្រាប្រណី ។ ដំណាក់ឈាមនៃជនអ្នកឈរគ្រោះទាំងឡាយ ហូរជាស្ទឹង
ដុះចិតក្នុងស្ទឹងស្ទឹង ។ ព្រោះបាវខ្លួនតែតាត់តែនៃជនតាំងមោះឥតញ្ញាត្តិ យក
ឈាមលាងក្តារដែលព្រះអង្គគង់ តាលនៅមិនទាន់បានរះសាយពន្លឺនៅ

ឡើយ ។ សាក្យៈវង្ស ស្ដេចសោយសុខឡតាំងពីគេលនោះមក ។ លុះ
ការគាប់សម្ងាប់គ្នាយ៉ាងឃោរឃៅចប់ហើយ ព្រះចៅវិទូឌុក: ទ្រង់ប្ដូរឲ្យ
ឲ្យចាប់មហានាមមកផ្ដាញ់ផ្ដាលចំពោះមុខមហាជនទៀត ដោយបន្ទិចឲ្យ
សោយក្រយាជាមួយនឹងព្រះអង្គ ។ គេលនោះព្រះអង្គម្ចាស់មហានាមបាន
រំពឹងគិតថា គេនៅតែធ្វើបាបព្រះអង្គយ៉ាងណា ក៏ទ្រង់មិនព្រមសោយ
អាហារឬមជាមួយនឹងកូនចៅបាវព្រាវរបស់ព្រះអង្គដែរ ។ ដល់គេលគេ
លើកក្រយាមកបំរុងឲ្យសោយ ព្រះអង្គបានមានបន្ទូលដោះសាថា « ម៉ៃ
ចៅសំឡាញ់ ! តាកំពុងមានខ្លួនសៅហ្មងដោយញើសក្អែល ហេតុ
នេះ សូមចៅចេីកនុកាស ឲ្យតាចុះទៅលុបលាងកាយក្នុងស្រះនោះជាន
បន្ដិចសិន » ។ ព្រះពជបាទវិទូឌុក: ទ្រង់មានព្រះបន្ទូលតបទៅវិញថា
« ប្រពៃហើយព្រះអយ្យកោ សូមធ្វើតាមសព្វព្រះទ័យចុះ » ។ លុះបានចុះ
ទៅដល់ទឹក ព្រះអង្គម្ចាស់មហានាម ទ្រង់ពិចារណាមួយលើកទៀតថា
“ ដកបណា ចេីអញប្រកែកមិនព្រមបរិភោគទេ ដកបនោះ ជីវិតអញ
នឹងស្ងាប់ក្នុងកណ្ដាប់ដៃវិទូឌុកមិនខាន, ណ្ហើយចុះ សូវស្ងាប់ដោយសារ
ស្នាដៃខ្លួនឯងដ៏ប្រសើរជាង » រួចតាំងបួងសក់របស់ព្រះអង្គ ហើយសឹក
មេដើងទៅក្នុងទឹកផង មុជទៅក្នុងទឹកបំរុងឲ្យស្ងាប់ម្ចាក់ឯង ។ ថ្ងៃដ៏ឥតគ-
ណនា, ថ្ងៃនោះចេះតែស្ដៅពេលកាលអន្ទះសា ពុំដឹងមានហេតុកេីតអ្វី លុះ
តិចារណាឃេីញមហានាមកំពុងវង្វក់ក្នុងទ្រង់ដូច្នោះ ក៏ម៉ឺម្ចាស្រួតមកយ៉ាង

ប្រញាប់ នាំយកទៅទុកក្នុងពិតពន្ធាគអស់ ១២ ឆ្នាំ ។ ឯព្រះបាទវិរូ-ឧភៈ ទ្រង់ទឹតពិផលចំពោះដំណើរមហានាមតន់ពេក ទើបបង្គាប់ឲ្យព្រះពាដបរិពារបស់ព្រះអង្គចុះទៅកវៃកម៉ើលអស់ចិត្ត លុះពុំដឹងថាទៅគ្រាបសម្ងំនៅឋានណា តំនាំពលសេនាបរបស់ទ្រង់ចេញដំណើរតែទៅមុខទៀត ។ ព្រះមង្គលបានមកសំចតពលនៅប្រុបស្ទឹងមួយឈ្មោះអចិរវតី, គាប់ជួនភ្លេខោះយប់ជ្រៅបន្តិចទៅហើយ ពួកសេនាគហានរបស់ព្រះមង្គលក៏នាំគ្នាកកន្ទេងដម្រេតប្រាណរៀង ។ ២ ជួ ក្នុកខ្លះដេកលើផ្កឧព្យាឃ្លក្នុងស្ទឹង ខ្លះទៀតដេកនៅលើមាត់ច្រាំង ។ លុះដេកបានមួយស្របក់ ស្រាប់តែស្រមោចក្រហម (ស្រមោចយួន) វាវៃទៅចាំតាំងអ្នកដេកខាងលើតាំងអ្នកដេកខាងក្រោម ជាហេតុធ្វើឲ្យពួកគាំង៖ នេះនៅមិនសុខមិនសាប់, តែជាគ្រោះអក្រក់ អ្នកដែលដេកលើផ្កឧព្យាឃ្លក្នុងស្ទឹង ឃានគ្នាមកដេកលើមាត់ច្រាំង ឯអ្នកដេកលើមាត់ច្រាំង បែរជាចុះទៅដេកលើផ្កឧព្យាឃ្លវិញ ។ ខណៈនោះ មហាមេឃបានបង្អុរភ្លៀងយ៉ាងធំអស្ចារ្យ ភ្លាក់ព្រឺលដុំ ។ ក្លាយទៅជាទឹកជំនន់ជន់លិចខ្លាច់ នាំយកព្រះបាទវិរូឧភៈ ព្រមទាំងបរិស័ទរបស់ព្រះអង្គ ទៅចោលក្នុងមហាសមុទ្រ បានជាចំណីសត្វមច្ឆាអស់គ្មានសល់ ។

តតិរឿងបានសេចក្តីដូចតទៅនេះ :

— ការខ្លះបដិសណ្ឋារៈ ឬការមិនទ្វាស្សក្នុងបដិសណ្ឋារៈ ជាហេតុនាំ

ឲ្យមានសេចក្តីវិនាស ដូចយ៉ាង កាលព្រះពជកុមារវិទូរកៈ យាងទៅ
ក្រសាលនតរកបិលព័ស្តុ ពួកសាក្យៈមិនធ្វាសក្នុងបដិសណ្ឋារៈ ថែម
ទាំងបានយកទឹកទៅលាងក្តារដែលព្រះពជកុមារគង់ ដើម្បីកុំឲ្យជាប់ចង្រៃ
អតមង្គល លុះព្រះពជកុមារជ្រាបរឿងនេះ ក៏ចង់អាឃាតទុក្ខរហូតដល់
បានសម្រេចតាមបំណងរបស់ទ្រង់ ។

ចប់ រឿងវិទូរកៈ

សុភាសិត

បៀសមនុស្សក្រោធទឹងមួយភ្លែតបាន
ហើយអាចរាប់អានយកជាមិត្ត
មនុស្សខ្លួចរឿបរៃលាក់គំនិត
គួរគិតបៀសវាងឲ្យរហ័ត ។

លោក ប៊ិង-វ៊ិង បង្ហាញចេញពីសារ្ថស្តីភាព

កាលព្រះសាស្តាគ្រង់ព្រះដំណើរ ទៅកាន់ក្រុងកោសម្ពី ដែលទៅដឹកក្រុងពរគ្រឹះ ហើយគ្រង់តាំងក្នុងឃោសិតារាម ជាចន្លោះនៃក្រុងកោសម្ពីនោះ ទ្រង់ប្រារព្ធនូវសេចក្តីសរសើរបញ្ញាចារមី របស់ព្រះអង្គចំពោះតិក្ខតាំងឡាយ ហើយសំដែងធម្មទេសនា មានបទថា ទុដ្ឋំ ឧស្សុដ្ឋិ មម បញ្ញំ ជុទ្ធដ្ឋិ ជូរេះជាដើម ។

ឯកាធិវាសម្តិ កិក្ក ឆម្ម្ចសកាយំ មានកាលសម័យថ្ងៃមួយ ពួកតិក្ខតាំងតាមតប្រជុំក្នុងធម្មសភា ពោលសរសើរថា អាវុសោ ម្ចាលលោកដ៏មានអាយុតាំងឡាយអើយ! អម្ចាស្តាំ សន្តា ព្រះសាស្តាទៃយើងតាំងឡាយ មហាបញ្ញោ ព្រះអង្គមានព្រះបញ្ញាប្រើន ៨វ-ឧបញ្ញោ ព្រះអង្គមានព្រះបញ្ញារហ័សរម្ងាំទ្ងាស តិក្ខណាបញ្ញោ ព្រះអង្គមានព្រះបញ្ញាខ្មោះមុតនិងត្មៃ និតបញ្ញោ ព្រះអង្គមានព្រះបញ្ញាមិនខ្វើសគាក់ បរបញ្ញាធម្មទ្ធនោ ព្រះអង្គភាចញ៉ាំញ៉ីនូវនាគ្យបរប្បវាទ ឥន្ទ្រិយបញ្ញោ ព្រះអង្គមានព្រះបញ្ញាជ្រាលជ្រៅ ភូរិបញ្ញោ ព្រះអង្គមានព្រះបញ្ញា ដូចជាផែនដី អាចទម្លុះទម្លាយចិត្តមនុស្សលោកឲ្យលះបង់ចំណង់ មានរាគៈជាដើមបាន ហើយឲ្យដំកល់ខ្លួនទៅក្នុងអរិយគុណ, ព្រះអង្គអាច-

ខ្ញុំនាងទៅតាមខ្លួនត្រហឹមយមយក្ស ដោយប្រការផ្សេងៗ ។ លុះសេដ្ឋីនាគ្នាដូច្នេះ រួចហើយ, ពួកភិក្ខុ កំតង់ទៅសៀមស្វាត់កន្លែងធម្មសភានុ៎ះ ។

ឯសម្តេចព្រះមានបុណ្យ ព្រះអង្គតង់ទៅក្នុងសុគន្ធកុដិ ទ្រង់ជ្រាបដោយព្រះទិព្វស្រោត្រថា "អស់ពួកភិក្ខុទៅប្រជុំគ្នាអំពីដំណើរតថាគត" ។ ទើបព្រះអង្គទ្រង់ស័ណាយាត្រា ទៅកាន់ធម្មសភាសាលា ឡើងគង់លើធម្មាសនៈ ហើយមានព្រះតម្រាស់សួរថា: ភាយនុត្ថ ភិក្ខវេ ឯតាភិក្ខុតាំងឡាយអើយ ! អ្នកមកប្រជុំគ្នាអំពីដំណើរអ្វី ? ។ អស់ពួកភិក្ខុក៏ក្រាបបង្គំទូល តាមដំណើរសេចក្តី ។ សម្តេចព្រះជិនស្រី មានព្រះតម្រាស់ថា តិត្ថវេ ឯតាភិក្ខុតាំងឡាយអើយ ! តថាគតពុំមែនមានប្រាជ្ញាតែក្នុងជាតិនេះទេ, តថាគតមានប្រាជ្ញាស្មោតតាំងពីដើមមក តែប្រាជ្ញាស្មោតនោះតិចទៅឡើយ ក្នុងពេលដែលតថាគតអន្លោលទៅមក ស្វែងរកពោធិញ្ញាណ ។ ព្រះសម្ពុទ្ធដ៏ទ្រង់ញាណ ទ្រង់មានព្រះពុទ្ធដីកាតែប៉ុណ្ណោះ កំតង់ស្ងៀមទៅ ។ ទើបពួកភិក្ខុក្រាបទូលអាពាធនាថា ភន្តេ បពិត្រព្រះអង្គដ៏ចំរើន ! សូមព្រះអង្គនាំមកនូវគតិតនិទាន ក្រាស់ទេសនាឲ្យយើងខ្ញុំបានស្តាប់តទៅ ។ ទើបព្រះអង្គទ្រង់នាំយកនូវអតីតជាតកក្រាស់ទេសនាថា :

អតីតេ តិត្ថវេ តាសិតរដ្ឋេ ឯតាភិក្ខុតាំងឡាយអើយ ! នាអតីតកាល កំពុងដែលតាស់ទៅហើយ មានព្រះមហាក្សត្រ ១ ព្រះអង្គ

ទ្រង់ព្រះនាម ព្រះបាទសោរ្យពង្ស សោយពង្សនៅសោរ្យនគរ ។ មាន
នគរមួយទៀតឈ្មោះ កាសិកដ្ឋ ជាចំណុះនគរព្រះបាទសោរ្យពង្ស ទ្រង់
មានព្រះពង្សបុត្រ ២ ព្រះអង្គគឺ ព្រះពង្សបុត្របឋមទ្រង់ព្រះនាម សុរពេកុមារ
ព្រះពង្សបុត្របន្ទាប់ព្រះនាម សោរពេកុមារ ។ ឯព្រះសុរពេកុមារ គឺតថាគត
នេះឯង លុះមានព្រះជន្មចំរើនឯ ព្រះវរពេជបិតាទ្រង់ព្រះពង្សានាវជា
មហាឧបពង្ស, ព្រះពង្សបុត្របន្ទាប់ ទ្រង់ព្រះពង្សានាវជាសេនាបតីធំ ។
អមរគាលៈ លុះបំណើរលន់ទៅ ព្រះសុរពេពង្ស ជាព្រះមហាឧប-
ពង្សខាង បានពិចារណាឱសរបស់តាមគុណ ៥ ទ្រង់ផ្សាយប្បាសន៍ខ្លួន
គុណព្រះផ្នួស ទើបទំលាយបង្ខំខ្លួនតាមគុណ ៥ ជាន ទ្រង់ពិចារណា
យ៉ូរទៅ ក៏កើតសង្វេគទឹកដល់ព្រះគាថាថា :

អដ្ឋិ ទានិ សំខារា ទុព្ពលា ឆវយញ្ជិនោ
ទុព្ភន្តិត្វា ឯកុណ្ឌន្តិ ភេទសំ ភិជ្ជសាទោ សរីរាតិ ។

មុខតួទ្បើសង្វេគ ! សង្ខារទាំងឡាយ ពុំទៀងទាត់សោះ, តែងជាន
ជារូប តាយទាំង រលត់ជាត់សូន្យទៅវិញ, បើម្ចាស់ខ្លួនសង្ខារខាងជាន
ទើបជាន សេចក្តីសុខ ។

តាលបើព្រះសុរពេទបពង្ស ទ្រង់សមាធានដូច្នេះហើយ ក៏ទ្រង់
ព្រះបន្ទូលថា បើដូច្នេះ តាភ្នាមញ្ញតែតែកេទុយទៀសបាតដ្ឋសំសារ
ទើបរំលងផុតពីសង្ខារទាំងខាងជាន ។ អញ្ញោ ច ឧម្មា ដែមទាំងឡាយ

ឯទៀត ពុំអាចនឹងរំលងពីសង្សារទុក្ខនេះបានឡើយ មានតែកុសលផ្នែសនេះឯង ទើបអាចរំលាងបង់ខ្សែសង្សារទុក្ខបាន ព្រោះអាងសង្សផ្នែសនេះច្រើនណាស់ ។ តស្មាហំ បព្វជិស្សាមិ ដូច្នេះ អាត្មាអញនឹងទៅបួស។ ព្រះសុរតទេបរាជ លុះទ្រង់ព្រះចំណាំដូច្នេះសព្វគ្រប់ហើយ ទ្រង់តម្កើងស្រីស្នំដែលអានុភាពល្អ ។ ទៅជាកើតសេចក្តីខ្ពើមរអើមពន់ប្រមាណ ដូចបុគ្គលឃើញលាមក ពុំនោះសោត ដូចបុគ្គលឃើញឃ្មុំណា, ទ្រង់តម្កើងទៅប្រគ្នីប្រាសាទ ដ៏ល្អរុងរឿងដូចទិព្វវិមាន គិរីជាទាវ ដូចបុគ្គលឃើញហានរក, ម្ល៉ោះហើយព្រះអង្គទ្រង់អនុវត្តន៍តាមខ្នែងកងព្រះរាជហឫទ័យ ទឹកចរិតតែទ្រង់ព្រះផ្នែស ។ ឯតទធិវាសំ សម័យថ្ងៃមួយ ព្រះអង្គទ្រង់ឡើងទៅគាល់សម្តេចព្រះបិតា ក្រាបបង្គំទូលថា បតិតាសម្តេចព្រះវរាជបិតាអម្ចាស់ដ៏មានគុណធ្ងន់ ខ្ញុំអម្ចាស់សូមទូលសួរប្រស្នា ១ សូមព្រះអង្គទ្រង់ត្រាស់វិសជ្ជនា ។ ព្រះវរាជបិតាទ្រង់ត្រាស់ថា បើកូនចង់សួរប្រស្នាណា ក៏ចូរកូនសួរចុះ ។ សម្តេចព្រះរាជបុត្រលើកតម្កើងប្រណម្យបង្គំទូលថា បតិតព្រះវរាជបិតា ក្នុងចក្រវាឡនេះ បើមានព្រះអាទិត្យពីរតើមានគុណ មានទោស ដូចម្តេច ? ។ ព្រះវរាជបិតាត្រាស់ថា ក្នុងចក្រវាឡ ១ មានព្រះទិត្យពីរ មនុស្សសត្វនឹងត្តៅក្រហាយ, តាំងតែឫងកំពាំង ទឹកក្នុងខ្នង បឹងបួរកំរើងស្ងួតហួតហែងអស់ មនុស្សនិងសត្វនឹងស្លាប់អស់ ។ តំ សុត្វា សោ សម្តេចព្រះរាជបុត្រ លុះទ្រង់

ព្រះសណ្តាប់ប្រស្នានោះហើយ ក៏ទូលសួរទៀតថា ម៉ែដំរីឈ្មោលពីរ នៅក្នុងកេងជាមួយគ្នា តើមានគុណ មានទោស ដូចម្តេច? ។

- ម៉ែដំរីឈ្មោលពីរ នៅក្នុងកេងជាមួយគ្នា បហារឆ្កិបិ រមែងដល់ចាក់ព្រៃចគ្នា យុទ្ធឆ្កិបិ តែងតតាំងគ្នា, ដំរីមួយនឹងស្លាប់ ដំរីមួយនឹងលំបាកវេទនាពិការទៅនឹងខ្លួន ។ ឯព្រះសុរេនបពង្ស បានស្តាប់ព្រះពង្សវង្សរហើយ ទូលថា សាធុៗ ទើបទូលសួរតទៅទៀតថា មហាកាឝ ឯណា ៤ក្តី ម៉ែស្រីមួយមានប្តីពីរ តើប្រុសនោះ នឹងមានគុណ មានទោសដូចម្តេច? ។

- តាក បិយបុត្តក ហៃកូនសំឡាញ់ដ៏ពុកអើយ! ស្រី១ មានប្តីពីរ ប្រុសទាំងពីរនឹងឯកម្មតៀរ ចាក់តាប់សម្លាប់គ្នាមានប្រការផ្សេង ។ ។ ព្រះពន្ធបុត្រទូលសួរតទៀតថា ឯកស្តី តាមេ ក្នុងស្រុកមួយ មានមេស្រុកពីរ, មេស្រុកនោះ នឹងមានគុណ មានទោសដូចម្តេច? ។ - ស្រុកមួយ មានមេស្រុកពីរ មេស្រុកនោះនឹងឈ្លោះទាស់ខែងគ្នា ព្រោះតែណាកម្មការៈភាំងពួងឆ្នើ ។ - ព្រះពន្ធបុត្រទ្រង់ព្រះសណ្តាប់ហើយ ឆ្លើយថា សាធុៗ ទើបទូលសួរតទៅទៀតថា ឯកស្តី តាលេ ទ្វេ សត្តា សត្តពីរគឺ ស្ពានឹងពស់នៅក្នុងរូងជាមួយគ្នា តើនឹងមានគុណ មានទោស ដូចម្តេច? តាក ហៃកូនសំឡាញ់! រឿង១មានសត្តពីរ គឺស្ពានឹងពស់, សត្តទាំងពីរនេះជាសត្រូ

ទីនឹង្គា កំនឹងទាំង្គានៃសេអង្គពយហោង ។ ព្រះសុរពទបពជ ទូលសួរ
ទៀតថា បើបុរសណាមួយ កំសត់ឥតទ្រព្យ ឥតយសស័ក្តិ ហើយ
មានប្រពន្ធពីរ ចំណែកទៅ តើមានហេតុដូចម្តេចខ្លះ ? ។ - បើបុរស
ណាមួយ ឥតទ្រព្យ ឥតយសស័ក្តិ ហើយមានប្រពន្ធពីរ, ឯនាងទាំងពីរ
នឹងឈ្លោះគរស់នៃង្គា មិនត្រែងចិត្តប្តី, ចំណែកប្តី បើទៅប្រពន្ធ ១
ប្រពន្ធមួយទៀតនឹងប្រចណ្ឌ ចានតែសេចក្តីលំបាកចិត្តជានិច្ច ។ សម្តេច
ព្រះពជបុត្រទូលសួរថា នគរមួយ មានស្តេចពីរព្រះអង្គសោយពជ្ជ តើ
មានប្រការដូចម្តេច ? ។ - នគរមួយ មានស្តេចពីរព្រះអង្គសោយពជ្ជ
ស្តេចនោះនឹងមានមានះកនឹងចិត្តថា ខ្ញុំអញក៏ជាស្តេចដូចគ្នា, ឯពួកព្រហ្ម
ពណក៏ស្រែដើបញ្ចើចបញ្ចើស្តេចរបស់ខ្លួន ម្ល៉ោះហើយ ក៏ច្បាំងចាក់កាប់
សម្លាប់គ្នាពុំនានឡើយ ។ ព្រះសុរតទបពជទូលថា បុរមនុស្សដែលច្បាំង
ចាក់កាប់សម្លាប់គ្នា តើនឹងទៅចាប់កំណើតក្នុងទីណា ? ។ - មនុស្សដែល
ច្បាំងចាក់កាប់សម្លាប់គ្នា លុះស្លាប់ទៅ នឹងចាប់កំណើតក្នុងឋានប្រេត
នរក ខលុំទុក្ខវេទនាណាស់ ។ ព្រះបរមោធិសត្វ លុះឮដាក់ដូច្នេះហើយ
ក៏រីឹតតែមានសេចក្តីតក់ស្លុត ជាងមុនទៅទៀត ទ្រង់តឹងណែនក្នុង
ព្រះទរ ក្រមថ្ងាយបង្គឹ.ហថា បពិត្រមាតាមោ ខ្ញុំព្រះអង្គនឹងចង់ចេញ
ទៅបួស ចំរើនមេត្តាភាវនា, សូមមានព្រះអង្គបើកឲ្យខ្ញុំព្រះអង្គហោង ។
ព្រះវរពជមាតាត្រាស់ថា តាត បិយបុត្តក ម្ចាលកូនស្ងួនសុភុតអើយ !

អ្នកខៅក្មេងណាស់ មិនគួរនឹងខៅបួសឡើយ ចូរអ្នកខៅសោយរាជសម្បត្តិ
ស្នងត្រងដួសព្រះបិតា អម្ចាំ ខ្ញុំ មហាស្វាគោ ព្រះបិតាចាស់
ណាស់ហើយ កាលបើបានបុត្រីបុត្រាកាលណា អង្វាតនេះ ឯក្រោយ
សឹមខៅបួស ។ ឯព្រះរាជបុត្រ បានស្តាប់ហើយទូលថា នេះ បពិត្រ
ព្រះសម្មតិទេព ព្រះអនុជមានរូបពណ៌ល្អប្រពៃ សូមកុំត្រូវចំណេរ
ខបរាជ ឯខ្ញុំព្រះអង្គនេះ នឹងគ្រាបថ្វាយបង្គំលាចេញខៅបួសនាព្រៃព្រះ
ហិមពាន្ត, កាលបើព្រះអង្គបានសំតាលណា សូមព្រះរាជទានរាជសម្បត្តិ
ដល់ព្រះអនុជស្នងព្រះវរៈរាជបំរាបុះ ។ ព្រះមហាក្សត្រទ្រង់តែតែបាម
ឃាត់ ។ ឯព្រះរាជបុត្រទ្រង់តែលាមលា ។ ព្រះរាជាក៏ទ្រង់អនុញ្ញាត
ហើយឆ្លាំថា កូនអើយ! បើឪពុកអស់ព្រះជន្មកាលណា ចូរចាំលើមក
សោយរាជសម្បត្តិស្នងបិតាណា៎កូន! ។ ព្រះបរមពោធិសត្វគ្រាបថ្វាំ
លា មកឯប្រាសាទវិតិ៍ តុំមានប្រាប់ដល់ខ្ញុំខណាឡើយ ទ្រង់ប៉ោះអស់
គ្រឿងប្រដាប់ចេញហើយ កៀសព្រះអង្គជាអ្នកកំសត់ ធ្វើក្រិត្យតុំឲ្យគេ
ស្គាល់ ចេញពីប្រាសាទសិរីខាខយាត្រាតាមមាគ៌ា ១ ថ្ងៃបានប្រមាណ
៧ យោជន៍ ទ្រង់ឃើញដំណាក់ទតមួយឈ្មោះសង្ក្រាមទត ស្តេចចូលទៅ
អស្រ័យលើសាលាមួយ, លុះព្រឹកឡើងទ្រង់ព្រះចំណាថា ជម្មតាអ្នកបួស
ទីដ៏ខៅក្នុងស្រុកទេសជួបច្បាំតួរទេ ទីដែកតថ្ងៃលំអាលំប្រើន ចំរើន
សមណធម៌ក៏តុំបាន គួរកៀសប្រាណចេញឲ្យផុតពីមនុស្សម្នាមហាជន,

លុះទ្រង់ព្រះចន្ទ្រាស្រេច ស្តេចទ្រង់យាងចេញពីព្រះទេវគរ ខ្ពោះទៅព្រៃហិមពាន្ត បានដល់ដើមជ្រៃមួយធំខោជិតផ្លូវ ស្តេចនឹកថា អាត្មាអញដើរមកក៏ច្រើនថ្ងៃហើយ ខឿយហត់ខ្លាំណាស់ គួរឈប់នៅទីនេះសិនចុះ ទ្រង់ព្រះចន្ទ្រាដូខ្នោះ ក៏ចូលទៅអាស្រ័យក្រោមដើមជ្រៃខោះ ។

ឯកោ បនេសោ មានស្រុកមួយខៅឆ្ងាយពីដើមជ្រៃខោះ ។ ឯកោ តជាកោ មានស្រះមួយខៅកែរដើមជ្រៃខោះដែរ ។ ក្នុងស្រះមានត្រីអណ្តើក អាស្រ័យខៅឥតតណា មានផ្កាឈូក កុមុទ ចត្បូលណីដេរជាសត្រប់ពណ៌ ។ មច្ឆយាដ្ឋកោ អ្នកទេសាខតាំងពីឆ្ងាយនាំគ្នាកាន់ឆ្នងីអង្រឹតសំណាញ់ . លុះទៅដល់ស្រះខោះហើយក៏ដំនុំគ្នាថា កោឡោ ហែគ្នាយើងរមួយ ! ស្រះខេះមានត្រីច្រើនណាស់ ប៉ុន្តែ យើងមកខេះក៏សឹងខឿយព្រួយលំបាកណាស់ គួរឈឺបសម្រាកនឹកគ្រាមួយយប់សិន លុះព្រឹកឡើងសឹមខេសាខ ។ គ្រាខោះ ពួកត្រីនឹងអាណ្តើក ដឹងថាកំយុតភ្លៀយនឹងមានមកដល់ខ្លួន ក៏ដំនុំគ្នាថា យើងពុំមានអ្នកណាមួយជាទីពឹង ឲ្យរស់តទៅជាវិតឡើយ តែតដូច្នោះហើយ កំយុះសោកស្តាយជីវិតគ្រប់ៗ គ្នា ក៏នាំគ្នាទៅកាន់សំណាក់អណ្តើកធំមួយ អង្គុយថា . កោមហាកច្ឆប បពិត្រអ្នកកច្ឆបៈ យើងទាំងឡាយសូមពឹងអ្នក ឲ្យបានរស់កខមានជីវិតតទៅ ដ្បិតពួកអ្នកទេសាខនាំគ្នាកាន់ឆ្នងីអង្រឹតសំណាញ់អញ្ចឹងនឹងចុះមកទេសាខនាព្រឹកខេះឯងពុំសេចឡើយ ។ មហាកច្ឆបោ

អណ្តើកនោះពោលថា "ហៃអ្នកទាំង ឮឬយអើយ! យើងក៏មានសេចក្តីគិតក័យណាស់ដែរ ទើបជួយអ្នកពស់គ្នាដូចម្តេចបាន" ។ ពួកត្រីថា "យើងយល់ថា អ្នកមានប្រាជ្ញាថ្លាជ្រៅជ្រះ អាចបូលទៅរកស្តេចនាគឲ្យជួយយើងគ្រប់គ្នា, ដ្បិតស្តេចនាគមានឫទ្ធិខ្លាំងមហិមា យើងពស់គ្នាទើបថ្វាយខ្លួនជាខ្ញុំបំរើ ថ្វាយទាំងត្រកួនតំពីងតួយសាកយ អម្បាលដែលមានទៅក្នុងស្រះ ជារង្វាន់ទាំងអស់ហោង" ។ អណ្តើកស្តាប់ហើយមានសេចក្តីពេញចិត្តក៏ចេញទៅស្រដីនឹងនាគពស់ទាំងពួម ខ្លួល, អណ្តើកដំរែមកប្រាប់ពួកត្រី ត្រេកអរឥតឧបមា ។ នាគពស់លូនចេញមកក្នុងស្រះនោះទាំងយប់ ។ ឯអ្នកនេសាទ លុះព្រឹកឡើង តឿនគ្នាយកនេសាទុបករណ៍ ប្រយោជន៍នឹងបុះទៅចាប់ត្រី ។ គ្រានោះ នាគពស់ដែលថ្ងៃមានខ្លួនខ្លោះធំ មានក្បាល ៧ បើកពពារហែលទៅក្នុងស្រះ ។ ឆ្លងឃាត់ក្តារ អ្នកនេសាទទាំងឡាយ មើលទៅឃើញនាគពស់លើកពពារទាំង ៧ ហែលមកដូច្នោះ ក៏និយាយគ្នាថា គោរន្ធា ហៃគ្នាយើងអើយ! មើលខ្មោចខឹក អ្នោះចោរយក៏គិតគំយរត់ទៅភ្លាន ហើយឃ្លាំចាំមើលពារប្រែនថ្ងៃ ទើបគិតគ្នាថា ឧតារក្លេសោ ឧ តាកោតិ គ្នាយើងអើយ! អាកន្ទុំទាំងនឹងច្រើនដូដល់ពួកយើងនី ហើយក៏នាំគ្នាដាក់មងដឹកអញ្ជើលមើល ។ ឯនាគពស់ដែលថ្ងៃឫទ្ធិហែលទៅមក រលេចឮតតស្លុតខាប់ស្ងាប់ទាំងត្រី ស្រដីតិះដៀលថា ឧ អម្ចាស់ ឋិតិសារលាំ

ឥតកោតិ នាគពរដនេះ គាត់ធ្វើមិនឲ្យយើងពីងពាក់ជាន, ឯអស់តួនាទៅ
ផ្ទៅសន្ធាន មានសេចក្តីខ្វល់ខ្វាសោកទៅពីងគាត់ ដើម្បីឲ្យរួចរស់ជីវិត ឥឡូវ
ទៅជាស្លាប់អស្សារឥតការ ។ នាគពរដ្ឋដូច្នោះ តូចចិត្តណាស់ រត់ទៅ
លំនៅវិញ ។ បុន ដំរេស មច្ឆយ៉ាដ ថ្ងៃក្រោយមក ពួកអ្នក
នេសាទគាន់មងំសំណាញ់ទៅឈរនៅមាត់ស្រះ ។ ឯពួកត្រីយើញពួកអ្នក
នេសាទមកដូច្នោះ ក៏គិតគ្នាថា គោន្ធា ហៃគ្នាយើងអើយ ! នាថ្ងៃ
ម្សិលមិញ នាគពរដគាត់មកជួយការពារសេចក្តីអន្តរាយ មានអ្នកខ្លះរអិល
មាត់ស្រដីនិន្ទាគាត់ ទើបគាត់តូចចិត្តរត់ទៅវិញ ។ ឥឡូវ យើងគិត
ធ្វើដូចម្តេច ទើបមានជីវិតរស់នៅ ។ ឆុំ មរិសច្ឆ ត្រីមួយឆ្លើយថា
ពួកយើងប្រាកដជាស្លាប់ពុំមាន ។ ឆុំ វិនសច្ឆិសច្ឆ ត្រីខ្លះឆ្លើយថា
ពួកយើងប្រាកដជាវិនាស ។ តេសុ ឯកោ បណ្ឌិតត្រីចាំងអស់
មានត្រីមួយស្រដីថា គោន្ធា ហៃគ្នាយើងអើយ ! នាគពរដសំដែង
ឫទ្ធិនិរ្មិតខ្លួនធំ មានក្បាល ៧ តែប៉ុណ្ណោះ ពួកអ្នកនេសាទវាំខ្លាចណាស់
ទៅហើយ ចំណង់បើពួកយើងមានគ្នាច្រើន យើងនឹងសំដែងឫទ្ធិចង់ក្បាល
ហ្នឹងសែនតេញចាំងក្នុងស្រះនេះ ពួកវាំនឹងខ្លាចយើងជាងខ្លាចនាគពរដ
ទៅទៀត ។ ត្រីចាំងឮយតិតដូច្នោះហើយ ក៏នាំគ្នាចង្អុតក្បាលចង់
ហ្នឹងសែនណែនចាំងស្រះ ។ តហ្វ មច្ឆា ឯអ្នកនេសាទចាំងឮយ
យើញហើយក្រុងគ្នាថា យើ ! ត្រីច្រើនណាស់រើយ ! មកយើងនឹងចុះទៅ

ចាប់ , ក៏នាំគ្នាកាន់អង្រឹតថ្នមអញ្ជើញទូន្មបុះទៅ ។ គ្រានោះ ព្រះបរមពោធិសត្វ ស្តេចមានព្រះទ័យអាណិតអាសូរ ដល់អណ្តើកនឹងត្រួតនឹងប្រមាណ មួយទៀត ត្រអេង្គមានព្រះទ័យអាណិតអាសូរ ដល់ពួកអ្នកខេសាទដែលធ្វើបាបមានសភាពដូច្នោះ នឹងឆ្ងាត់ទៅសោយទុក្ខកន្លងទៅ, លុះទ្រង់ព្រះចន្លាដូច្នោះហើយ ក៏ស្រដីទៅកាន់ព្រានខេសាទទាំងឡាយថា អង្គោ នែអ្នកទាំងឡាយ, ចូរអ្នកកុំសម្លាប់ត្រី នឹងអណ្តើកនេះឡើយ ដ្បិតត្រីនឹងអណ្តើកទាំងឡាយនេះ សឹងជាញាតិមិត្រនឹងយើង៏ បើអ្នកទាំងអស់ មិនស្តាប់យើង ចំតែសម្លាប់ លុះដល់ស្អាប់ទៅនឹងទៅធើទុក្ខវេទនាក្នុងនរកពុំខាន ។ ពួកអ្នកខេសាទមិនស្តាប់បង្គាប់ព្រះបរមពោធិសត្វ សោះបែរជាស្រដីថា ត្រីនឹងអណ្តើកដាញាតិរបស់អ្នកឯង៏ មិនមែនជាញាតិមិត្តរបស់យើងទេ ស្រដីដូច្នោះ ក៏នាំគ្នាចុះស្រែទៅក្នុងស្រះ ។ ព្រះបរមពោធិសត្វស្តេចវិលមកនិម្ដិត ព្រះអង្គទ្រង់គ្រឿនប្រដាប់ចាប់ព្រះទ័ន កាន់វិលទៅប្រថាប់នៅមាត់ស្រះ ស្រែកគ្រហឹមបន្ទឺសួរសេចក្តីទៅកាន់អ្នកខេសាទទាំងនោះ ។ ឯអ្នកខេសាទទាំងឡាយឮហើយ អើតមើលសឹងតក់ត្រយ តក្តមា ស្រដីប្រាប់គ្នាថា អាកន្ទ្រអ្នកតា ទើបនាំគ្នាតេ្រាសយកតែប្រាណរៀងខ្លួន ។ តតោ បច្ចាយ ចាប់ដើមតាំងពីថ្ងៃនោះមក ត្រីនឹងអណ្តើក បីតនៅជាសុខសប្បាយខ្លួលាយចិត្ត ឥតតក់ត្រយអំពីអ្នកឡើយ ។ ឯព្រះបរមពោធិសត្វ ស្តេចចេញចាកទីនោះ យាងទៅតាមផ្លូវដាច្រើន

ថ្លៃដល់សាលាមួយ មក្តងរៀលឆ្នោ ព្រះអង្គខឿយព្រួយតាមផ្លូវ ទ្រង់ចូលទៅសម្រាកព្រះកាយលើសាលានោះ ស្តេចទ្រង់រំពឹងគិតដល់អំពើដ៏ល្អ ដែលទ្រង់ជួយជីវិតត្រួនឆ្កែក ព្រមទាំងជួយដោះពួកអ្នកនេសាទឲ្យផុតអំពីអបាយភូមិ ។ ដូច្នោះហើយ ឃានជាមានប្រពៃណីមកដល់ឥឡូវនេះថា បើមានមនុស្សចុះទឹកដើរលុកលុយទៅមក ធ្វើទឹកឲ្យកករល្អក់, ត្រីភ័យផុសងើបឡើងស្រែ ទើបមនុស្សស្មូនតថា "ត្រីភ្ញាល" ។

ឥទ្ធា ឯតេ្តា ឃុរិសោ ឆឌ្ឌុ អាធាយ មច្ឆឆ្ឌេ កច្ឆន្តោ ឮដ៏កាលនោះ មានបុរសម្នាក់ គាន់ធ្នូដើរតាមផ្លូវបួលទៅកំដរព្រៃ ក្អែកវិតឃើញកុកមួយ ទើបបាញ់សម្លាប់ ហើយបាចដើងចន្ទឹងដង្កូនដើរទៅ ។ ឥទ្ធា កាលនោះ មានបុរសម្នាក់ទៀត ដើរមកជួបនឹងបុរសពូនកុក មានចិត្តលោភចង់បានកុក ក៏ស្រដីថា នែវើយ ! មេ្តចអាហ៊ានបាញ់កុកជាឪពុកអញស្លាប់ ។ បុរសពូនកុកឆ្លើយថា កុកនេះប្រាកដជាឪពុកឯងមែនឬ ? ។-អើឪពុកអញមែន ។ អ្នកពូនកុកស្រដីថា បើកុកនេះ ជាឪពុកឯង ។ ក៏មិនប្រដូចឪពុកឯង ... មេ្តចក៏ប្រើឲ្យទៅធ្វើត្រីជាម្តាយអញ់ ។ ខឹងទើបអញបាញ់សម្លាប់ ។ បុរសទាំងពីរឈ្លោះប្រកែកគ្នាទៅដល់មណ្ឌលសាលា ដែលព្រះបរមពោធិសត្វអាស្រ័យនៅ ទើបនាំសេចក្តីទៅគ្រាបទូលរឿង ។ ខ្លួន ។ ព្រះបរមពោធិសត្វទ្រង់ជ្រាបកាលណា ក៏ទ្រង់ព្រះបន្ទូលថា បុរសទាំងពីរនេះ វាគិតថា វាមានប្រាជ្ញាឈ្លាសវៃ ស្រដីចាទ

គ្នាដូច្នេះ. អ្នកលោកចង់ជាន់កុក ប្រសប់តែខាងក្រជាដាបច្ចុប្បន្ន មិនខាន់ ដឹងទោសកងឬលោក ដែលមានទោសលើខ្លួនពីរប្រការគឺ មុសាវាទ ១, បេសុញ្ញវាទ ១, ឯចម្ល័យមានទោសពីរប្រការដែរគឺ ជាណាតិជាត ១, មុសាវាទ ១, ដូច្នេះ គួរកេញ្ញាមូលបំផ្លាត់ទោស អ្នកតាំងពីរឡើងជាន, លុះទ្រង់ព្រះចិន្តាស្រេច ស្តេចត្រាស់សួរថា "នែអ្នកតាំងពីរ! អ្នកនឹងខ្លួលស្តាប់បង្គាប់តាមពាក្យយើងឬ?" ។ បុរសតាំងពីរខ្លួលថា យើងខ្ញុំនឹងខ្លួលតាមបង្គាប់ ប៉ុន្តែ សូមឱ្យលោកដំរេះសេចក្តី ដោយសុចរិតយុត្តធម៌ កុំលំអៀងម្ខាង ។ ។ ទើបព្រះបរមគោធិសត្វត្រាស់ថា អើបើដូច្នោះ យើងនាំគ្នាទៅឯមាត់ទឹក ។ បុរសតាំងពីរក៏ដើរតាមពោធិសត្វទៅ ។ ស្តេចទ្រង់ត្រាស់ទៅកាន់អ្នកដើមចោទថា គោ ចោទក. ម្ចាស់អ្នកចោទ! មានប្រតិវណីតបុរាណមកថា បើមានកូនប្រុសស្រីម៉ែនដែលឱ្យសកេទពីម្តាយឪពុកទេ បើខ្លួនអ្នកប្រាថនដូចកូនកុក ចូរហើរទៅលើអាកាស ។ អម៉ើ ឯអ្នកឆ្នើយ ប្រាថនដូចកូនត្រីមែន ចូរឯងមុជទៅក្នុងទឹក ជាបើអ្នកមិនមែនជាកូនត្រីពុំមុជទេឬយ, ឯម្ចាស់ទៀត បើខ្លួនមិនមែនជាកូនកុកពុំបានហើរទេឬយ ។ បុរសតាំងពីរស្តាប់ហើយ គាល ប្រាថ្នាពុំអាចហាមាត់ឆ្លើយប្រកែកឡើយ ។ ព្រះបរមគោធិសត្វទ្រង់មានព្រះបន្ទូលតទៅទៀតថា បើអ្នកចោទហើរទៅលើអាកាសបាន អ្នកឆ្លើយចូរទៅជាខ្ញុំចុះ, បើអ្នកឆ្លើយមុជទៅក្នុងទឹកបាន អ្នកចោទចូរទៅជាខ្ញុំ

បំរើ, បើហើរកើបាន មុជក៏បានស្មើគ្នា នោះយើងយល់ថា អ្នកតាំងពីប្រាកដជាកូនកុក កូនត្រមែន, បើហើរកើមិនបាន មុជក៏មិនបាន នោះអ្នកតាំងពីរ មិនមែនជាកូនកុក កូនត្រមែនទេ; ឯក្តីនេះ អ្នកប្រាជ្ញហៅថា ណោគោធិដ្ឋមោហា ភ្លាត់ឆ្នើនដូចគ្នា ទើបបន្ទឹងថាគេសដល់គ្នាយ៉ាងនេះ។ លំដាប់នោះ បុរសតាំងពីរ តិតតំយរៀសរៀគ្រាបទូលសួមគេសថា សួមព្រះអង្គប្រោសប្រណីមេត្តា ព្រោះយើងខ្ញុំកល់ត្នាជាមនុស្សធោតល្ងង់ខ្លៅ។ ព្រះបរមពោធិសត្វទ្រង់ឲ្យនុវាទថា ម្នោលភ្លោ ម្នែអ្នកតាំងពីរដ៏ចំរើន! ចូរកុំឈ្លោះប្រកែកគ្នាឡើយ យេ ច ភុសាភិធំ បើអ្នកណាមួយ ស្រដីមុសាវាទ ខៅតាំនឹងមនុស្សតាំងឡាយ តុំសរសើរឡើយ យេ ច. បិសុណំ បើអ្នកណាមួយ ស្រដីបៀតបៀនអ្នកដទៃ ទីនព្រាត់ប្រាសម្តាយឪពុកប្រពន្ធកូនចៅញាតិគ្រួច. ចាមតែសេចក្តីខ្ពុកសោក ពេតកំយចន្ត្រែទបញ្ញាផ្សេង។, មួយសោត បើបុគ្គលស្រដីមុសាវាទទីនិងមេសុញ្ញវាទាំងពីរនេះ លុះស្លាប់ទៅទីនទៅរដ្ឋិកុក្ក អង្គអច្ចាយភូមិតាំង ៤, យេ ឆាណាតិឆាតំ អ្នកណាមួយ ធ្វើឆ្កូណាតិឆាត រមែងមានអាយុខ្លី ទីនភ្លាក់ទៅរដ្ឋិកុក្កកូនរកពុំលែងឡើយ ហើយកុំលួចទ្រព្យគេ កុំប្រព្រឹត្តកាមេសុ មិច្ឆាចារ កុំនិយាយកុហក កុំសេពសុរាបន្ទាប់មក ព្រះបរមពោធិសត្វទ្រង់ឲ្យអ្នកតាំងពីរទទួលសីល ៥ ព្រះអង្គទ្រង់យល់ច្បាស់ចំពោះអំពើទុច្ចរិត ដែលបុរសតាំងពីរធ្វើឲ្យព្រះអង្គកើត

សេចក្តីសង្ស័យ ក្នុងព្រះទ័យ ក៏ត្រៃត្រៃទ្រង់ព្រះតម្រិះថា អហោ ពាលោ មនុស្សអន្ធពាល អ្នកប្រាជ្ញតែងតុះតិះដៀលណាស់ហ្ន៎! បើគិតការអ្វីៗ សឹងជាគំនិតអាក្រក់, បើស្រមៃអ្វីៗ ក៏ជាពុំញ៉ាំសិត សឹងជាកំណាចគាចសាហាវ, បើធ្វើអ្វីៗ ក៏សុទ្ធតែជាអំពើអាក្រក់ពាំងអស់, លុះទ្រង់ព្រះបិតាផ្លូវច្បាស់ហើយ ក៏ត្រាស់ដោយទាហរណ៍ថា ឧបមំ ឧបេច្ច មម បញ្ហំ បុច្ឆន្តិ អនន្តរកំ បព្ភូជ្ជាមក្កំ តរោតិ តុម្ហំ វាចន្តិ មនុស្សពាលទុព្ភយ ឃាទយេយ់ជាតិគំណើតអាក្រក់ ឥតប្រយោជន៍ មិនមែនជាប្រពៃណាមនុស្សឡើយ តែងនាំគ្នាមកសួរប្រស្នាចំពោះអាត្មាភាព ឯអ្នកឆ្លើយសោកមិនដែលធ្វើកម្មផ្សេងៗ គឺពុទ្ធតែពាលខ្លោះខ្លៅយ, ហើយត្រូវអន្តេវាសិកទ្រង់ទូន្មានតទៅមៀតថា អាសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា ឯតា ច ឧត្តមំ ឃនដ្ឋំ ឯតមត្ថំ-ពុទ្ធមង្គលំ គារមែនសេពគប់នឹងមនុស្សពាលក្តី ការគប់រកប្រាស្រ័យនឹងអ្នកប្រាជ្ញក្តី ការបូជាចំពោះបុគ្គល ដែលគួរបូជា គឺមានពិតាសមណព្រាហ្មណ៍ ជាដើមក្តី ពាំនឹងសំដែងនេះ អ្នកប្រាជ្ញបុរាណលោកពោលថាជាមង្គលដ៏ប្រសើរ ឥណ្ឌ ទុក្ខ ឥតាខនេ ជាដើមប៉ុណ្ណេះ ។

ឯណា បណ្ឌិតខ្លះសោ ការតទ្ធរំ ទៅហើយខោះ, មានបុរសបណ្ឌិតម្នាក់ ចិញ្ចឹមមនុស្សអន្ធពាលតិរោក ឯណា ឯកម្នាក់នោះ បើបុរសបណ្ឌិតទៅណា ។ តែងដើរតាមទៅផង ។ ឯណា កម្នាក់

ទៀតនៅដណ្តើមបាយ ។ លុះនៅយូរទៅ, ថ្ងៃមួយ បុរសបណ្តើតទៅដុតឥដ្ឋកំពង់ ។ បុរសអន្ធពាលក៏ដើរទៅតាមដែរ ។ ពេលនោះ មានខ្សែកំបុតត្បូងបក់មក ធាបក្តួចសំពត់បុរសបណ្តើតនោះ លិចក្តងឥដ្ឋបាត់ទៅ, បុរសបណ្តើតមុជទៅតាមសំពត់ ។ ឯបុរសអន្ធពាល លុះចាំមើលបុរសបណ្តើតយូរពេក ក៏រត់ទៅជំរាបតរៃយោរបស់បណ្តើតថា បពិត្រអ្នកស្រីជាម្ចាស់ ឥឡូវ ម្ចាស់ប្រុសមុជឥដ្ឋរកសំពត់ ឥដ្ឋក្តួចបាត់ទៅហើយ ។ ឯនាងនោះឮហើយតិតៗយញ៉ែរន្ធត់ យំរត់ទៅប្រាប់អ្នករក្សាទ្វារ។ ស្តាប់ដាក់ហើយ ក៏រត់រលេះរលាំងទៅ ពុំបានពាំងទ្វារឡើយ, នាងនោះក៏រត់ទៅប្រាប់អ្នករក្សាក្តួន។ឮហើយតិតថា បើអញនៅក្តួនម្ចាស់ទឹងគេក្រែងគេមិនរក្សាឲ្យ ក៏យកក្តួននោះទៅដាក់ក្នុងអណ្តូងគ្មានទឹក, នាងនោះក៏រត់ទៅប្រាប់បុរសដាំបាយ ។ តែយរត់ទៅពុំបានរមូត់ភ្លើងក្តងដើងក្រោន តាំងបីខាត់ខំរត់ទៅកំពង់ទឹកយំទូញដោយប្រកាសផ្សេង។ ។ បុរសបណ្តើតឃើញដូច្នោះ សួរថា មានហេតុដូចម្តេច បានជានាំគ្នាយំរត់មកដូច្នេះ ។ ប្រពន្ធប្រាប់ថា អើយំ ឫស្សបង្ហាគ្រោ បុរសដែលមកនឹងអ្នកឯង វារត់ទៅប្រាប់ថា ឥដ្ឋក្តួចអ្នកបាត់ទៅហើយ បានជាខ្ញុំបបួលគ្នារត់មក ។ ឯភ្លើងក្តងដើងក្រោនត្រូវខ្សែកំនេះពេងបាយ, កួនទៅក្នុងអណ្តូងក៏ក្តៅស្ងាប់, ចោរវាឃើញថា ឪរមិនពាំង កំចូលទៅយកទ្រព្យសម្បត្តិអស់រលីង ។ លុះបុរសបណ្តើតនឹងតរៃយោនាំគ្នាវិលមកផ្ទះ ឃើញភ្លើងកំពុងនេះ វិនាសទ្រព្យ ស្ងាប់កួន កំនាំគ្នាយំ

សោកស្តាយឥតឧបមា ។ តស្មា ពាលសេវនា ព្រោះហេតុនោះ
បើអ្នកណាមួយស្ម័គ្រសមាគមនឹងមនុស្សអន្ធពាល រមែងរំនាសខ្លួនក្នុង
ឥដ្ឋលោក នឹងបរលោកពុំខាននឡើយ ។ បើអ្នកណា ស្ម័គ្រសមាគមជាមួយ
បណ្ឌិត រមែងជាមង្គលដ៏ឧត្តម ក្នុងលោកនេះ នឹងលោកខាងមុខដែរ ។

ពាវណាសិយំ ដូចបានឮមកថា ក្នុងក្រុងពាវណាសី មានព្រះ
មហាក្សត្រមួយព្រះអង្គ ទ្រង់មានព្រះប្រាជ្ញាអស្ចារ្យឈ្លាស មានអគ្គមហេសី
ព្រះនាម "ខេមា" ជាធំលើសអស់ស្រីស្នំ ១ ហ្មឺន ៦ពាន់ ក្នុងជាន់ខាង ។
ឯនាងខេមាប្រព្រឹត្តក្បត់ ទៅកប់ប្រសព្វនឹងសេនាបតី ។ សម្តេចព្រះស្វាមី
ទ្រង់ជ្រាបជាក់ ស្តេចស្ម័គ្រព្រះទ័យនឹងទៅប្រទេសឯទៀត ទើបព្រះអង្គ
ឲ្យហៅបុរោហិតមកសួរថា យើងមានចិត្តចង់ទៅប្រទេសឯទៀត តើត្រូវ
យកនរណាទៅខ្លះ ដើម្បីចិញ្ចឹមដំរីតឲ្យបានស្រួល ? ។ ទើបបុរោហិត
បានដឹងសេចក្តីថា ស្តេចបានជ្រាបអំពីមហេសីប្រព្រឹត្តក្បត់ ទើបព្រះអង្គ
តំរិះចង់តន់ទៅ ដូច្នោះ បុរោហិតក្រាបទូលថា ម ហាភាគ បពិត្រក្សត្រៃ
ប្រសើរអើយ ! ជាបើព្រះអង្គនឹងទ្រង់ដំណើរចេញទៅ សូមព្រះអង្គយក
អាមាត្យ ៤នាក់ គឺ អាមាត្យមានកម្លាំង ១, អាមាត្យជាជាងឆ្លាត១, អាមាត្យ
ចេះពិចារណាសេចក្តី១, អាមាត្យជាធម្មបណ្ឌិត១, យថា សុខំ គច្ឆតិ
រមែងទៅបានសេចក្តីសុខស្រួល តាមព្រះពុទ្ធដំណើរដែលទ្រង់យាង
ទៅ ។ ព្រះមហាក្សត្រលុះជ្រាបដូច្នោះហើយ ទ្រង់យកអាមាត្យទាំង ៤ នាក់

ដូចតាក្សបុរេហិតក្រាបបង្គំទូល ស្តេចយាងទៅដាច្រើនថ្ងៃបានដល់ឧតរមួយ ជួនដាអស់ស្បៀងអាហារ ។ ស្រាប់តែ មានដូនចាស់ម្នាក់នៅភូមិមួយ គាន់ដឹងដំណើរចេញទៅកុះទេស ហើយឈរមើលអ្នកទាំងនោះ ។ ឯអាស្រមដែលមានតម្កាំងស្មុះទៅទទួលដំណឹងដ៏ជួនចាស់ ឮថាបានទេសដាច្រើន ។ ដូនចាស់មានសេចក្តីត្រេកអរផែកឧបមា ឋានឲ្យរង្គើដាថ្ងៃក្រុងដល់អាស្រមនោះ ។ អាស្រមទាំង ៤ នាក់ចែកគ្នាស្តាយ ដាំបាយ ថ្វាយព្រះមហាកស្សបៈមួយខ្លួន ។ ទើបស្តេចយាងត្រេចត្រាតទៅនោះដាច្រើនថ្ងៃ បានដល់ឧតរមួយ ។ នៅឧតរនោះ មានសេដ្ឋីម្នាក់ដ៏រកដាធំធេងធ្លាប់ប្រដាប់ឲ្យកូនស្រាប់តែចូលអាស្រមចេះគារដាធំរងធំ ។ អាស្រមនេះ ខ្លួលធ្លោះត្បឿងប្រដាប់បានថ្ងៃឈ្នួលច្រើន យកមកចែកគ្នា ។ បន្តាប់មក ព្រះមហាកស្សបៈត្រូវចាកចេញពីឧតរនេះ ដល់ទៅឧតរមួយទៀត ត្រង់ចូលទៅអាស្រ័យក្នុងសាលាមួយ ដាធំរួមសេនាបតីបានបាន ឮដំណាលនោះ មានបុរសម្នាក់ ដើរមកដល់ព្រៃកមួយធំធ្លាប់ ខឹកហួរខ្លាំង, ក៏ស្វែកសំឡេងក្រាក់ក្រាន់យ៉ាងណាមិនដឹង យកថាយសំណុំទឹងប្រាក់មួយចានតហាមណៈ មកដាក់ហើយដាលង្ហែងព្រៃក, លុះដាលដល់កណ្តាលព្រៃកអស់ដៃ-ដើងដាលពុំរួច ស្ទើរស្លាប់នៅកណ្តាលព្រៃក ត្រូវរស្រែកថា «ឱ! អ្នកណាហើយ អាចខ្លួលខ្ញុំបាន ខ្ញុំមានទ្រព្យ ២ ប្រការគឺ ថាយទឹងប្រាក់ បើលោកស្ម័គ្រយកទ្រព្យណា យើងនឹងឲ្យ » ។ គ្រានោះ មានបុរសម្នាក់

ឃើញហើយ សុះសោតហែលទៅទទួលទ្រព្យទាំងពីរ លុះមកដល់ត្រើយស្មើគ្នា កំតំណាងថា អើអ្នកថាទ្រព្យអ្វីដែលគាប់ចិត្តបងអ្នក អ្នកនឹងឲ្យមក, ឥឡូវបងអ្នកឲ្យមក ។ ម្ចាស់ទ្រព្យស្រដីថា អើសឹមខ្ញុំឲ្យទ្រព្យដែលគាប់ចិត្តខ្ញុំទៅអ្នក ពោលហើយក៏លើកសំណុំថ្មយឲ្យទៅ ។ បុរសអ្នកចម្លងប្រកែកថា ខ្ញុំទៅចម្លងអ្នកឯង ពុំគិតស្មាប់ ស្រាប់តែមកដល់ត្រើយ អ្នកឲ្យសំណុំថ្មយដល់ខ្ញុំ ។ ពុំយកទេ ត្រូវឲ្យប្រាក់១ពាន់តហាបណៈមកទើបខ្ញុំព្រម ។ ម្ចាស់ទ្រព្យថា ខ្ញុំមិនបានឱ្យយថា ឲ្យប្រាក់១ពាន់តហាបណៈទេ ខ្ញុំថាឲ្យទ្រព្យណាដែលគាប់ចិត្តខ្ញុំ ឯថ្មយសំណុំនេះគាប់ចិត្តខ្ញុំហើយ ។ អ្នកចម្លងឆ្លើយថា បើថ្មយសំណុំនេះគាប់ចិត្តអ្នកហើយ អ្នកឯងយកចុះ ។ ម្ល៉ោះហើយបុរសទាំងពីរនាក់បងប្អូនគ្នាទៅកាន់ពេធរិនីច្ចយ ។ តួក៧ក្រមកាត់សេចក្តីថា ឲ្យថ្មយសំណុំទៅអ្នកចម្លង ។ បុរសចម្លងពុំសុខចិត្ត ក៏នាំគ្នាទៅឯសេនាបតី ។ សេនាបតីពុំអាចកាត់សេចក្តីបាន ។ ស្មោ បញ្ច ផលេ និស្សា សេនាបតីនោះ យើញអ្នកទាំង ៥ អស្រ័យនៅលើសាលា ទើបគិតថា អ្នកទាំង ៥ នោះ មានរូបស័ក្តិសមល្អ ។ សមជាអ្នកប្រាជ្ញ ក៏ទៅនិយាយសួរនាថា អ្នកទាំងឡាយអាចកាត់សេចក្តីបានឬ? ។ ទើបវិចារអាមាត្យឆ្លើយថា យើងអាចពិចារណាបាន ។ ទើបសេនាបតីហៅបុរសទាំងពីរនាក់មកប្រគល់ឲ្យវិចារអាមាត្យ ។ ឯវិចារអាមាត្យដណ្តឹងសួរបុរសទាំងពីរនាក់ ក៏សួរទៅបុរសម្ចាស់ទ្រព្យ

ថា អ្នកស្រឡាញ់ពេញចិត្តសំណុំជាយនេះពិតមែនឬ?។ - ស្រឡាញ់មែន។ វិចារអាមាត្យថា បើដូច្នោះ ត្រូវដាក់ទ្រព្យពាំងពីរនេះ ចំកណ្តាលដំខុំសិនចុះ ។ ម្ចាស់ទ្រព្យក៏ដាក់ជាយនឹងក្រុងក់ ១ ពាន់តហាថណៈនៅចំកណ្តាលដំខុំ ។ វិចារអាមាត្យបង្គាប់ថា អ្នកឯងចាប់យកទ្រព្យនេះ ណាមួយតាមចិត្តចុះ ។ ម្ចាស់ទ្រព្យចាប់យកថង់ក្រុងក់ដើរទៅ ។ វិចារអាមាត្យហៅមកវិញសួរថា ទ្រព្យដែលអ្នកកាន់ដើរទៅនេះ តាប់ចិត្តអ្នកឬ? ។ - ជាទតាប់ចិត្តហើយ ។ ទើបវិចារអាមាត្យថា បើតាប់ចិត្តហើយ អ្នកឯងត្រូវឲ្យទ្រព្យនេះទៅអ្នកដែលតាត់ចិត្តវិញ ក្នុងទីកន្លែងខ្លាចស្ងាប់ ទៅចម្ងល់អ្នកឯងព្រោះគេតាប់ចិត្តដូចអ្នកឯងដែរ ។ ម្ចាស់ទ្រព្យឆាល់គំនិត យំសោកស្តាយទ្រព្យ ។ ឯបុរសអ្នកចម្ងល់បែងទ្រព្យនេះ ជាតិរចំណែកគឺ ១ ចំណែកជាន់ខ្លួន មួយចំណែកទៀត ឲ្យទៅវិចារអាមាត្យ ។ គ្រានោះ អស់ពួកនាហ្មឹនសព្វមុខមន្ត្រី នូវប្រជាពស្ត្រពាំងឡាយ សឹងឲ្យតរសើរសាធុការព្រមខ្លួរខ្លារពេញពាំងព្រះនគរហោង ។ ថ្ងៃមួយ សេនាបតីចូលទៅគាល់ស្តេចស្តេចត្រាស់សួរថា គោ សេនាបតិ ម្ចាលសេនាបតីដ៏ចំរើន ! ឯមង្គលហត្ថីអញនេះ តើមួនប៉ុន្មាន? ធ្វើម្តេចនឹងដឹងជាន? ចូរអ្នកចូលមើល ។ សេនាបតីទទួលព្រះពាក្យរួចហើយ វិលមកផ្ទះ ប្រឹក្សាជាមួយមន្ត្រីធំ-តូចអស់ពាក់ព័ន្ធបីថ្ងៃ តុំមានអ្នកណាមួយអាចចូលដឹងបានទេ,

(នៅមានត)

ចប្បាប់ស្រី

ព្រះរាជនិពន្ធព្រះបាទអង្គឌួង

លោក បាប-ពិន ពិនិត្យ

(តចប់)

៣៧- ស្រីមានយាណាស់ណា ឃើញប្រុសឆ្កើជា ពាក្ខន់លេងថើប ថើបឈ្លក់ថើបឈ្លី ថើបញីហើយដើប ឆ្កើប្រុសឲ្យស្រើប សម្រេចតណ្ហា ។

៣៨- ស្រីមាយាលេងស្នេង ខុនថ្ពាល់ស្តាំឆ្កេង ខ្លួនឯងនឹងឲ្យវា ថើបវិញតែនឹងកៀង រំលឹងខេត្រា មើលប្រុសរួសរ៉ា សើចហើយវេរវៃ,

៣៩- ស្រីមាយាដេញដែ ឃើញប្រុសប្រើក្ខេង ប័ទបបំពេ ស៊ើបខ្លែលប្រុសតប់ ក្រឡាប់ជាខេ ហុចឲ្យគោរគេ ហើយឆ្កើនាំត់ ។

៤០- ស្រីមាយាឥតខ្វាស ឃើញប្រុសហើយអាស រំសាយសំពត់ ស្ទើរលេចកំពើខ្លាស ហៅអាសឥតបន្ទ ឲ្យប្រុសកួចតត់ បន្ទំមួរវិសនា,

សំដែងមាយាស្រី ស្រែសំម អប្រិយ លើសឱ្កាតមាត្រា ឲ្យស្រីឆងជំងឺ ដំណឹងពុតវ៉ា ម៉ិកម៉ឹកណាស់ណា គ្មានការស្តែប្រាណ ។ ធម្មតាស្រីមាយា ក្តីអ្វីល្ងង់ គួរឆ្កើគួរឆ្ងាន មិនស្ងួតបងិបិត្ត តែងិតិត

បំណាន ខ្ញុចខ្ញុសនោះគ្មាន ព្រួយនឿយព្រួយស្តី, បើប្តីក្រុងថ្នា កលកិច្ច
ស្នេហា ថាឯងអៀនប្តី តុំព្រមតាមចិត្ត តំនិតស្វាមី ប្តីអាត់អន់ក្តី មិនព្រឺ
ដល់តិច ។ គួរអស់ស្រីជិន គួរចៀសគួរមិន ឲ្យភ្លាត់ភ្លាំងក្ងេច
គួរចោលឲ្យឆ្ងាត់ គួរកាត់គួរគេច គួរវៃគួរបេច កាន់សុចរិតខ្ជាប់,
ធំឯងបានឮឈ្មោះ ឮស្តីតីពេះ ខ្ញុំខ្វះស្ងួរស័ព្ទ បរលោកលោកិយ
ហៅស្រីមហាគាប់ លោកទុកជាច្បាប់ អស់ស្រីមានា ។ សោះតិត
ប្រមាទ ខើបចោលមារហោទ មានរោគ្រប់គ្នា សំដែងវែងឆ្ងាយ
គ្រប់សព្វ មាយា សែសិប គណនា តាមព្រះគាថ,

ឧសភិ ហិ - នេហិភ្ជិយោ បទុដ្ឋា វេ- ធិតញ្ញាបិ
ភរិសន្ថុតេ ស្រីបង្កិនឯ ហេតុដប់តត់កល, ៖

១- នេះនើមបង្កិន ហេតុតែបង់កិន ឲ្យប្តីតើតដល់ ពោល
ខុកូលំបាក តោកយ៉ាកអំពល់ ដោយចិត្តកំហល់ កំហឹងមោហា ។

២- ស្រីបង្កិនប្តី ក្រព្យធនការអ្វី ឆ្លងប្តីអាត្មា មិនយកទុកជាក់
ពិតត្តិរក្សា ចោលឲ្យចង់អា- សាសោះឥតត្រែយ,

៣- ស្រីបង្កិនប្តី ការងារឯស្រី គួរតែធ្វើហើយ ទ្វិលធ្វើការឯង
ដេកលេងកន្តើយ ពុំតិតធ្វើឡើយ ដើរលេងសប្បាយ ។

៤- ស្រីបង្កិនប្តី របស់អ្វី ។ ផងប្តីយកចាយ លេងបៀ
ផឹកស្រា ក្រព្យអន្តរាយ មានខ្ញុចខ្ញាត់ខ្ញាយ គ្មានបានចំណេញ,

៥- ស្រីបង្កិងប្តី តូតែបុលី ដៀតែដូរទិញ ម្ចាស់ទ្រព្យ
តាតែង បែរទឹងឲ្យវិញ ប្តីគៀងអង្គុមិញ រកសងឲ្យគេ ។

៦- ស្រីបង្កិងប្តី បាយវាយឥតម៉ែ ប្រមាណរែរេ បង់ដោយ
ចាត់ដោយ ខម្ងោយក្រសេះខ្ញុ តាលែតដែរទេ តឿនប្តីឲ្យក៏,(១)

៧- ស្រីបង្កិងប្តី ធ្វើងឆ្មែក្រស្តី បង់ធំបង់ល្អ តាអ៊ូខ្ជិលា មិនភ្ញា
មើលយក៏(២) ធ្វើតែតាក្រ ដែលធ្វើក្រហាន ។

៨- ស្រីបង្កិងប្តី ចិលខូចតាលី ដើរលួចប៉ុកពន គេចាន់ពេះបុះ
គេចឈ្មោះបំពាន ប្តីធំខ្លួនក្រាណា រកទ្រព្យឲ្យគេ,

៩- ស្រីបង្កិងប្តីបណ្តាលតិចអ្វី ច្រើនឈ្មោះដៀតគេ គ្មានស្មើប
អ្នកណា ធ្វេធ្លាវ៉ៃវៅ កើតក្តីមិនទេ ប្តីបង់តែទ្រព្យ ។

១០- ស្រីបង្កិងប្តី ជាយឥតឧប្រិយ ឥតសារឥតសំព្ធ ចោរ
អាសគ្មានស្តាប់ តែយល់ចុះជាប់ ទ្រព្យប្តីឃកឆ្ងាប់ ចិត្តសញាយរ,

សំដែង បង្កិង ដ៏ ហេតុស្រីមិន ចេះទុកទ្រព្យ ចោលខ្លាត់
ចោលខ្លាយ ចោលរកយនានា ចោលមិនគំនាំ មើលទុកឲ្យល្អ ។ ចុះទុក
តែពាស ពត់កយទៅផ្តាស គ្មានរៀបរើសរក៏(៣) ពេះយើញនេះមុខ មិន
ទុកមិនយក៏(៤) ដើរទៅដើរមក៏(៥) ជាន់លើមិនតិត, ជាតស្រីឥតប្រាស់ក្តណ៌

---

១ ២-៣-៤-៥- សម័យនិពន្ធប្លាប់នេះ ពាក្យ "រក, យក, មក" អានថា "ក, យ, ម" ជាន់ជាពាក្យតាត្រូវនេះដាក់ពាក្យ "រក៏, យក៏ មក៏" ឲ្យទទួលសម្លេងស្មើនឹងពាក្យ "ល្អ ក្រ" ។

ទឹងហ៊ានខាក់ មិនមានគំនិត ខូចវិហារ ឥតប៉ាងគិត រុះរយមិនស្ងួត
យកដៃទៅកាន់ ។ ជាន់តែដើរលេង ទឹងគេទឹងឯង ស្រដីខ្ជាន់
អួចចុះអួចឡើង ចរចើរស្ងួកាន់ មិនមានគ្នាន់ ខាតដោយខូចដោយ,
អំពើច្នេះហាង គួរអស់ស្រីផង ផ្ដង់ចិត្តកុំឲ្យ បង់ក្ដីសុចរិត ពិនិត្យកុំខ្លាយ
កុំមានខម្លោយ ទៅកាន់ខុចរិត ។ អត្ថាធិប្បាយ ទ្រង់ត្រាស់បរិយាយ
ពីស្រីគំនិត បង្ហិន ស្វាមី ដោយក្ដីខុចរិត អំពើ ដប់ ពិត ចែងចប់គាថា,

អដ្ឋារស- បាំ ហានេហិ ឥត្ថិយោ តា ខុកិច្ចត្ថ.
អរមានា ស្រីចើក កំរើយ ច្រាំបីដ ឥឡូវ ។ :

១- នេះ ដើមស្រីស្រាល ចើកចង់លេងកាល លេង
ត្រៃមិនស្កប់ ទៅលេងរឿយ។ គ្មានខ្មីឃុំឃាច ទៅថ្ងៃទៅយប់
ទៅយូរមហិមា,

២-ស្រីចើកចង់តែ ដើរទៅលេងស្រែ ចម្ការនានា លេង
ច្បារទន្លាន មិនមានរួញរា ច្រើនដងច្រើនគ្រា ព្រោះចើកឥតត្រើយ ។

៣- ស្រីចើកចិត្តផ្ដួក ចើកចង់លេងទួក អុំលេង
ល្អាក់ល្ហើយ បន្ទរសើចសាន មិនមានខ្មាសឡើយ លេងរឿយៗហើយ
ព្រោះចើកកន្ទួង,

៤- ស្រីចើកចោលប្ដី ចង់ទៅផ្ទួតធឹក ដួតម្ដុំ

ច្រើនជង ឆ្លូតថ្ងៃឆ្លូតយប់ ឥតឈប់ឈរហោង ឆ្លូតលោតលេងជង ឆ្លូតសើចក្អាកក្អាយ ។

៥- ស្រីចើតអន្លើត នៅញាតិអន្ត្រើត អង្គុយនិយាយ ថ្ងៃយប់ញាយ។ លេងកូយសប្បាយ សើចលេងក្អាកក្អាយ ដោយសារចិត្តចើត,

៦- ស្រីចើតតែតតិត ថ្ងៃយប់ជង់ជិត ដើរលេងអន្ត្រើត ផ្ទះឯងមិនទៅ ដើរទៅអំបុក ផ្ទះគេខ្លើក។ ផ្សាចិត្តចង់ក្បាន្ត ។

៧- ស្រីចើតនោះមិញ ចង់ដើរតតាមិញ គ្រឿងស្អាងខ្លួនប្រាណ ចើតទៅតែផ្សារ តាមរាខេតខាន ឆ្លៀតចើតមិនស្រាន្ត មិនស្រាលតណ្ហា,

៨- ស្រីចើតៗ ងាំ នៅឈរចំងាំ មាត់ទ្វារបេត នៅក្នុងរបង ផ្អៀងផ្អង់នេត្រា ច្រើនជង់ច្រើនត្រា ដោយចិត្តចើតស្មោះ ។

៩- ស្រីចើតប្រើនចង់ អង្គុយតតាត្រង់ បង្អួចបន្ទោះប្រហោងជញ្ជាំង ចៀតជុំងឹងកៀនគោះ រឿយៗណាស់នោះ ចើតពេញបន្ទុក,

១០-ស្រីចើតនោតត្រែ ក្អួញក្អែរឈឺដៃ អង្គុយមិនសុខញាយ។នោមដុះ ថាពោះក្តែរបុក នៅមិនប្រណុក ផ្សាចើតជាក់ស្តែង ។

១១- ស្រីចើតមិនថាត់ ព្រលប់យប់ស្ងាត់ អង្គុយ

ម្នាក់ឯង លើផ្ទះនៅដដែ ឥតចីខ្ចាចក្រែង ស្រែកស្រួលប្រពៃដែ សូរសំឡេងស្ទាន,

១២- ស្រីចើតជាតាស្នែង ចង់ឆៅមើលស្លែង ម្ចាស្រតាសតូហាន មើលរឿយៗពាន់ លើសលន់មិនមាន តារក្តីខ្ញាសប្រាណ ព្រោះចើតមោហា ។

១៣- ស្រីចើតស្រើបស្រាស់ ខ្ពស់ទៀងត្រង់ដាស់ ប្រុសស្ទើរស្ទុះស្ទា ក្រោចឡែតធ្លាក់ផ្តួល សូរសន្ធាបា រឿយ ។ ត្រប់គ្រាជ្រុតចើតសើរើ,

១៤- ស្រីចើតសស្រួញ ចង់ស្តាប់ធំឆ្ងួញ ទំនុកសំរតើ ពាក្យតេចន៍ពៅហារ តារងារគ្នេចធ្លើ ស្តាប់រឿយលេលើ ព្រោះចិត្តចើតស្រែ។

១៥- ស្រីចើតចោះចិត្ត ឆោចចង់ជាមិត្ត ស្រឡាញ់អាល័យ នឹងស្រីផ្កាមាស អង្គអាសចង្រៃ ទៅលេងយប់ថ្ងៃ ផ្សាចើតមិនក្សត្ត,

១៦- ស្រីចើតក្រែងឮសា ដើរលេងផ្តេសផ្តាស តាមដំណើយទីហាន ប្រពៃដែប្រឡូក ច្របូកប្រច្រាណ ប្រាំយមិនក្សត្ត ខេតប់តក់តេច ។

១៧-ស្រីចើតស្តាប់ស្តី ដំយាយតែតី ស្លែងប្រុសមិនគ្នេច សរសើរប្រកាន វាមកដំពាក្យតេចន៍ នឹងប្រុសមិនតិច នឹកទៅឯង,

១៨-ស្រីចើកមុខ៖ឆ្ងែ ដឹកស្រាស្រីឆ្ងែ គ្មានភ្ញាសគេឯង
ផឹករឿយ។ខោះ ផឹកឈ្លោះទឹងក្នេង ហានក្លាថ្លាថ្លែង តាមចិត្តចើកចង់ ។

សំដែង ចើក គ្រប់ប្រាំបីឈ្មាប់ លំក្ខណ៍ស្រីចើកអង្គុ តាន់
ខ្ចុចតែខ្លាប់ ក្រឹត្យច្បាប់លះបង់ តាមតែចិត្តចង់ ចំណងគំនិត, ធម្មតាស្រី
ចើកចិត្តអប្រិយ តាមក្តីខ្ចុចតែ ឃើញប្រុសស្រៀវស្អួច ព្រឺព្រួចក្នុងចិត្ត
ចង់តែស្នេហ៍ស្ងួច ព្រោះតណ្ហាខ្លាំ ។ ចើកនេះអប្រិយ គួរគេប្បីស្រី តាំង
ឡាយចង់ចាំ ថាចើកខ្នះដួ មោហ៍ម្ខួមទាំ ចើកនេះចើកកម្ម ចើក
ដួលខ្ចុចសោះ, គួរស្រីតាំងឡាយ ខោលះចើកចេញឲ្យាយ ពីចិត្តចើក
ស្មោះ កុំត្រាប់កុំត្រូវ កុំចងចិត្តចុះ កុំចេះចើកនោះ ចើកនេះ
ជួលក្រ ។ ចុះលើលោកថា នរស្រីណា ចៀសចើកចង្រៃ តាន់ឃើញសុចរិត
ប្រព្រឹត្តប្រពៃ លោកសោមនស្សា ក្រៃលែងស្រឡាំង, ទេសនាចំ-
ឡើយ ស្រីចើកតាំងឡាយ ជាងនំនង ប្រាំបីឈ្មាប់ ចែងចប់
ចើកហោង គ្នាមដោយគន្ធ៍ អាចិត្តគាថំ ។

វិសាយ បិ ហេតេហិ ន- ត្តិសាមិ ភាំ អមាហោ
អចិយោ ឃោន្តំ វិស្រីអាសនាំង ម្ភៃសេចក្តី, :

១-នេះ ដើមស្រីអាស ឯអាសគាចន្ទាស ប្រច័ណ្ឌតែប្តី ជា
ស្រីចាក់ចុច មិនខ្ចប់សំដី ផ្តួញផ្តាន់ស្ងាម តែសព្វភាសា ។

២- ស្រីអាសចចេស ចេះតែឈ្លោខឹស គ្មានយល់អ្នកណា
របស់ផងគេ ចង់តែច្រាច្មុំ មិនបានហើយភ្លក់ រកតែលង្វិច,

៣- ស្រីអាសអង្រិយ ចិត្តធំធឹងប្លឹង តុំខ្លួលតូច ប៉ើប្តីនិន្ទាពាក្យ
ប្រៃខ្លាកមាត់ច្បូច ប្រណ្តោះខ្ចូច - គ្មានស្រាកសំដី ។

៤- ស្រីអាសអាស្រូវ ចេះតែចែចូវ ដើរស្តីដើមប្តី ខឹងអ្នកខោះនេះ ហើយរ៉ាំមកស្តី ច្រាប់ញាតិប្រុសស្រី អង្រិយណាស់ណា,

៥- ស្រីអាសឆុះឆេះ ពាលពីថ្ងៃនេះ ទាំភ្លើងរួសរាំ ទៅឆួលអ្នកផង ឲ្យឆ្ងន់ខ្លាចផ្សា តែព្រោះអេកា្ខ តុំស្ងាត់សូរស័ព្ទ ។

៦- ស្រីអាសឥតស្រោង ប្តីឆ្កាំខ្ចោង មិនស្ងៀតចង់ស្តាប់ ចេះប្រសចប្រាស ប្រឡាសស្ទើរស្ទាប់ គ្មានស្តាប់ចង្កាប់ បណ្តាំប្តីឥត,

៣- ស្រីអាសឆ្មាឆ្រឹម ឃើញប្រុសទំនឹម តុំតុកទៅស្ងួត ឲ្យប្រុសបានដឹង ដំណឹងគំនិត ដែលវាតូចតិត ចង់ចាប់ស្នេហា ។

៨-ស្រីអាសតោតណាស់ឃើញប្រុសតន្ទាស់ តន្ទោងប្រស្នា ឲ្យប្រុសតិតតាម ភ្លើតកាមតណ្ហា ចាប់ចងស្នេហា ឱនវាស្ម័គ្រស្មោះ,

៩- ស្រីអាសតន្ទាញ់ ឃើញប្រុសកង្កាញ់ មៀងមើលដូច្នោះ ញែចញាក់ចំពោះ ពាត្រមត្រង់ឆ្ពោះ ឲ្យប្រុសគាន់គោះ តូចកើតមេត្រី។

១០- ស្រីអាសមិនស្មើរ ឃើញប្រុសវាដើរ មើលមិចក្អែកខ្មៅ ឲ្យប្រុសដឹងអាថិ ប្រកាសចេចក្តី ដួចចូលស្រែដី ពាក់ព័ន្ធចំណង់,

๑๑- ស្រីអាសៗតិចៗ ប្រុសគេពុំតិត ។ាន់ពាក្យនឹង ញាក់មុខ ញែញញែញ ជន្លេញឲ្យអត្ត ប្រុសប្រែចិត្តនឹង ឈ្លះឈ្លោយកក់ ។

๑๒- ស្រីអាសៗលន់ ប្រុសគេមិនគន់ មិនគិតប្រាថ្នា ។ាស្តោះ ខាតព្រាត អណ្តាតលៀនហា ឲ្យប្រុសខ្មាសរ៉ា ខំបង់ឲ្យបាន,

๑๓- ស្រីអាសច្រឡាម យើញប្រុសរត់តាម ប្រាថ្នាឈ្លោន ។ាន ធ្វើស្ងួនសើចសព្វ ខ្នះតប់តក់ព្រួន ឲ្យប្រុសព្រឺព្រាណ ព្រួចត្រឹសស្នេហ៍ស្ងួត ។

๑๔- ស្រីអាសចង្កៃ យើញប្រុសលូកដៃ តវ៉ែ្លលតោះខ្លី ឲ្យប្រុសមើលយល់ តិតដល់ផ្លែងនឹ ទឹកប្រែចិត្តបង់ បង់ពាក់ខែបាត់,

๑๕- ស្រីអាសៗគ្រែ យើញប្រុសរើសស្បែ ជណ្តើបាស្តើ ចែបចិតភ្លើ ត្រូវមិញ្ចាំខ្មៅត្រៅ ឲ្យប្រុសមើលរៅ ស្រឡាញ់តុំស្បើយ ។

๑๖- ស្រីអាសធាំងសព្វ យើញប្រុសជណ្តើ ប្រទុតប្រាធ្លើយ លេបរ៉ាប្រាលន់ ស្បែតនន់ធ្លើប្លើយ ឲ្យប្រុសយល់ហើយ ពាក់ចិត្តគាន់តិត,

๑๗- ស្រីអាសមុខងប់ យើញប្រុសឈរឈើប់ រំសាយសំពត់ ហើយស្បៃសំយ៉ែ ស្ទើរខ្លះខ្លាងម៉ត ឲ្យប្រុសខ្ចើត ចិត្តចង់រួមស ។

១៨-ស្រីអាសាត្រើម ឃើញប្រុសរើម សំពត់ស្រាយ
អស់ រលាស់រុះ។ ឲ្យប្រុសស្រែបស្រស់ ចង់ជួបរួមរស រួមក្ស
ប្រតិព័ទ្ធ,

១៩-ស្រីអាសពេញអាស ឃើញប្រុសឥតភ្នុស ស្រើយ។
លាត់។ ស្រើយភ្លៅខៅតិច រិះលេចអស់ភ្លាត់ ឲ្យប្រុសសាបមាត់
ចង់ជួបមិនលែង ។

២០-ស្រីអាសបណ្តាច់ បណ្តូលអាសផ្តាច់ ឯកអាសសំញែង
ឃើញប្រុសលូកដៃ ឯព្ធាសឯង ប្រលោមប្រឡែង ពតរសវើណី,

សំដែង ស្រីអាស គ្រប់ស្ទើគ្រប់ភ្នុស ម្តៃ សេចក្តី ឲ្យស្រើផង
ដឹង ដំណឹងឋុកស្រី ថាអាសអប្រិយ ដូចាតិសាមាខ្យ ។ អាសនេះពេញ
ពុត មុខរើងបំផុត មានោមានះឈ្មោនពាន ·ឯប្តីខ្លួនស្រាប់ សូតផ្តាប់ធ្វើ
គ្មាន ចិត្តចង់រួមប្រាណ ចំណង់ទើងប្តី, សំដែងស្រីអាស គួរអា-
ស្រូវគាស អស់ពាំងស្រុក អាសនេះដូចាតិ លើសខ្លាតអប្រិយ គួរតប្បី
ស្រី ចាំជាខំខង ។ ចាំហើយពិនិត្យ ក្រែងដួងជាចិត្ត ចូលចុះគន្លង
ជាអាសដូច្នេះ ចូរវេះចេញហោង កុំឲ្យសៅហ្មង អាស្រូវអាត្មា, កុំចេះ
អាសខុក យកជាអភិមុខ ជាលក្ខណា អាសអាក្រក់ក្រៃ ចង្រៃមហិមា
គួរស្រើជា។ ចៀសវាងកុំត្រាប់ ។ អាសនេះមោហ៍ចាំង មារម៉ខចិត្តខ្ជាំង
ឲ្យគេពុំគាប់ គេតិះដៀលលេង ជាល្បែងសាយសព្ទ មិនខុកជាច្បាប់

អស់កាលដ៏លង់ , - អំពើច្នេះហោង គួរអស់ស្រើផង ផ្ចង់ចិត្តឲ្យគង់ អំពើក្រមក្រឹត្យ សុចរិតខុកខ្ចក់ ចិត្តចាំបំរុង គ្រប់ខ្លួនជីវៃ ។ ចូរកុំប្រមាទ ចូរកុំបីឃ្លាត សុចរិតថ្លាថ្លៃ សំដែងស្រីអាស ឥតខ្វាសចង្រៃ ចប់គ្រប់ ម្ភៃ ហេតុតាមគាថ,

ទ្វាទសហិ ឋានេហិ ឥត្ថី សាមិកំ អវជានាតិ. តិណ្ណា ចិត្តំ ស្រីមាក់ងាយតាំង ដប់ពីរកំយោ ។ :

១- ស្រីមាក់ងាយប្តី ព្រោះជ្រុតស្វាមី ខ្វាត់ខ្វាយមហិមា គ្មានសម្បត្តិត្រូវ ប្រដាប់ប្រដា ខ្វាត់លើសអាត្មា អាត្មាអ្នកមាន,

២- ស្រីមាក់ងាយប្តី ព្រោះជ្រុតស្វាមី ពូជពង្សែន្ធាន ជាបគួចថយថោក គ្មានលោកចាប់អាន ឯខ្លួនមិញមាន ត្រកូលខ្ពស់ខ្ពង់ ។

៣- ស្រីមាក់ងាយប្តី ព្រោះជ្រុតស្វាមី អាក្រក់គគ្រើង គគ្រាគគ្រៃល ក្រងិលក្រវង់ ឯខ្លួនត្រចង់ ល្អស្អាតសោភា,

៤- ស្រីមាក់ងាយប្តី ព្រោះជ្រុតស្វាមី កើតពាធ៌ពេគា របេងរំងៃ ល្ហិតល្ហៃគ្រាំគ្រា ខ្លួនមាំមួនថា ធ្វើការឥតអាក់ ។

៥- ស្រីមាក់ងាយប្តី ព្រោះជ្រុតស្វាមី ចាស់ជាន់ឆ្នេញចាក់ ក្អែកសស៊ក់ស្លៅ មិនស្ងៀសមស័ក្តិ ខ្លួនឯងហួតថ្នាក់ ក្រមុំជាម្ចាង ។

៦- ស្រីមាក់ងាយប្តី ព្រោះជ្រុតស្វាមី ល្ងង់ខ្លៅកន្ធើង ឆោតឆៅមមឹង មុខរឹងរូសផង ចរចាសដួសផង ខ្លួនឈ្លាសវៃជាង ។

៧- ស្រីមាក់ងាយប្តី ព្រោះដៀតស្វាមី ចង់តែស្លឹតស្អាត ដើរលេងចង់ស្រី ស្រដីវាសវាង តឿនទៅប្រដាង ត្រឡប់ជាឈោះ,

៨ ស្រីមាក់ងាយប្តី ព្រោះដៀតស្វាមី តែងតែទៅឆ្ពោះ លេងបៀលេងបោ៉ៈ ធោ៎ កែវកោះ របស់អស់សោះ រំភូតមិនបាន ។

៩- ស្រីមាក់ងាយប្តី ព្រោះដៀតស្វាមី ធឹកស្រាមិនស្រួត មិនស្រាកស្រឹង ក្សំណើងក្សំណាក្សត្ត រំភូតប៉ុន្មាន មិនស្តាប់តាក្សេត,

១០- ស្រីមាក់ងាយប្តី ព្រោះដៀតស្វាមី ខ្ចេញខ្ចិលចោរ៉ៃ មិនចេះការងារ ធ្វើការអ្វីទេ ខ្ជូនដេរដាន់រត ប្តីមិនចេះប៉ុន ។

១១- ស្រីមាក់ងាយប្តី ព្រោះដៀតស្វាមី មិនចេះគិតគន់ មិនរកអម្រស់ របស់ប្រពន្ធ មកឲ្យប្រពន្ធ, ដោយគិតខ្នះខ្នែង,

១២- ស្រីមាក់ងាយប្តី ព្រោះដៀតស្វាមី ប្រឡូកប្រឡែង មួលមិចចុចចាក់ តាមថ្នាក់នៃល្បែង ឥតមានគោតក្រែង ដេរប្តីអាត្មា ។

ចាលីច្នេះហោង គួរអស់ស្រីផង កាន់តាមពុទ្ធដីកា ប្រុងប្រាណប្រយ័ត្ន ប្រុងផ្គត់ផ្គង់ឃ្យា ប្រុងចាំចិត្តា ប្រុងសុចរិតចុន, កុំហ៊ានប្រឈ្មោះ កុំហ៊ានចោកចោះ តំរោះតំពន ប្រទេចផ្តាសា បំពាបំពាន កុំហួសកុំហ៊ាន ឆ្លងមាត់ឲ្យប្តី ។ កុំកាន់ធុច្ចរិត កុំមាយាក្រៀក្រត្យ កុំបង្ខិចប្តី កុំនើតចិត្តផ្តាស កុំអាសអប្រិយ កុំមាក់ងាយប្តី ហៅក្តីផ្តាត់,

អំពើទាំងប្រាំ(១) គួរអស់ស្រីចាំ កុំបីប្រមាទ ឲ្យជាក់ក្នុងចិត្ត ប្រព្រឹត្តកុំ
ឃ្លាត យកប្រាំជាអង្គ ខ្ញុំនាងអាត្មា ។ ថាប្រាំអំពើ ខ្លួចមុសណាស់តើ
គ្មានល្អត្រង់ណា គួរតែកុំគ្រាប់ កុំជាប់តិរិយា កុំចងចិត្តា អំពើប្រាំនេះ,
បើដឹងជាក់ហើយ គួរលះលែងហើយ កុំបង់ឲ្យចេះ កុំគ្រាបឲ្យជាប់ ខ្មាប់
ប្រឡែះ ខោលចេញវាងវែះ ឲ្យអស់ពីប្រាណ ។ អំពើប្រាំនេះ ដ្បិតខេ
ម្ពុជនេះ ព្រោះខុសិតមាន ចោលតែខុសិត មួយឥតចេញបាន ទាំង
ប្រាំនេះគ្មាន សោះសូន្យជាមួយ, អំពើខុសិត ជាដើមគំនិត បង្កើតប្រាំ
ហោង ប្រាំបែកដល់ រយ ម៉ែនយ៉ែនន បែកប្រែនកន្លួន តណាខាពុំ
បាន ។ មានតែសុចរិត តាំងជាគំនិត ជាគ្រប់ប្រជាន ទើបគាចខុសិត
គំនិតប្រាំគ្មាន អ្វាមំនមាន គាចប្រាំនេះឡើយ, ចូរអស់ស្រីដង ចាំអត្ត
គន្ថដ ខ្ញុំនាងនេះហើយ កុំឲ្យភ្លាំងភ្លេច កុំគេចគោះតើយ ចូរគិតកុំស្បើយ
ត្រង់ក្តីសុចរិត ។ ព្រះធម៌ទេសនា អំពើលក្ខណា ស្រីជាខុសិត អំពើទាំង
ប្រាំ ឈ្មោះយ៉ាហោតុពិត អំពើបុចរិត ប្រាំបីប្រការ, ឈ្មោះគាំងខ្លួ
ត្រមោះយ៉ាប្រាំបី(២) លក្ខណៈតាមសាច្ចិ អត្ថព្រះបាលិ គម្ពីរធម៌ជារ
អដ្ឋកថាគាថារ្យ ចែងចប់បរិយាយ ។

១- អំពើទាំង ៥ គឺ ១ មាយា ២ បង្កើត ៣ ចើក ៤ អាស ៥ មាក់ងាយ, អំពើទាំង ៥ នេះ
កើតមកពីខុសិត លុះខុសិតបាន ទើបគ្មានអំពើទាំង ៥ ។

២ ស្រីសុចរិត ៨ ចំពូក, ស្រីមាយា ៤០ ចំពូក, ស្រីបង្កើតខ្លី ១០ ចំពូក ស្រីចើក ១៨
ចំពូក, ស្រីអាស ២០ ចំពូក, ស្រីមាក់ងាយក្តី ១២ ចំពូក ឆ្ងាំគ្នាត្រូវគ្នា ១០៨ ចំពូក ។

នេះនឹងតែងត ដំណើរដំណា ឲ្យប្រុសទាំងឡាយ ដឹងដល់ចិត្តស្រី តាមក្តីអធិប្បាយ អាចារ្យដែងចាយ ជាបទគាថា, តាមពុទ្ធដីកា ទ្រង់ត្រាស់ទេសនា ដើមព្រះគាថា: កាតមេមនិ- ន្តីហា ឥធ អន្ធាទ្ធ មាតុក្តាមា ។ ប្រែអត្ថដើមបទ ថាហៃអន្ធពួក! អស់ស្រី នានា សឹងមាន ចិន្តចាំ រឿងកុំចិត្តា ពាំនឹងឃើលា ត្រប់ស្រីដូច្នេះ

១ ឪត្រីតាសុះត្រង់ ចិត្តស្រីច្រើនចង់ ខ្លួញខ្លិលលោះលេះ តន់តិតកំណាញ់ គ្មាន់ខ្លាញ់នោះនេះ រសោះរសេះ ហួងហ្លួងយា ។

២- ឪត្រង់សុះយប់ ច្រើនចង់សេពសព្វ សារតើអ្វីជា សម្រើបសម្រួល ស្រស់ស្រួលនេត្រា ពុំនោះទឹកឈ្នា- នីសដល់អ្នកឆន,

៣- ឪយប់សុះព្រឹក ច្រើនតែតិតទឹក ស្រះណាះជាមួង ពុំនោះច្រើនតែ ចង់ស្នេហ៍ស្និទ្ធស្នង រួមសេពគន្ធង ចំណង់តណ្ហា ។

ដំណើរនៃ ចិត្ត ស្រីច្រើនប្រព្រឹត្ត តាមដោយ ទោសា ទាំង បី ប្រាកដ ដូចបទគាថា ឲ្យប្រុសទាន ដឹងចិត្តនៃស្រី, នេះនឹងពណ៌នា តាមព្រះគាថា អាថិអត្តសេចក្តី ព្រះពុទ្ធទេសនា មានទាឋាលី អង្គុត្តរនិ- កាយកបត្តៈ ។ ៖

ឥត្ថីភន្តំ បុរិសរូបំ មាសិតេន កណ្ហិតេនា- ភេឡ្លាកប្ប វនកច្ឆំ ជសេដ្ឋ ឥត្ថី, មួយសោតលោកថា ព្រះពុទ្ធ

ទេសនា ... ថា ប្រុស ន័ង ស្រី ... រមែងស្នេហា ... ចង់ជាមេត្រី ដោយក្តី ច្រាំបី ប្រការច្រើនដង់ ៖

១- មួយគឺចង់ចិត្ត ចង់ទឹងចង់ឥត ធ្វើជាស្រេតត់ ផ្តិតផ្តង់ឫកពាប សុភាពជាន់ខ្ពស់ ស្អិតស្អាងហ្មត់ចត់ ខ្ជួនច្រណាអាត្ម, ...

២- ចង់មួយទៀតទៀង ទឹងបែរមើលមៀង ប្រទះមុខគ្នា ញញែមញញឹម ប៉ប្រឹមតក្តែ ស្រស់ស្រួលសោភា សើចសម្តីចគោះ ។

៣- ចង់មួយទឹងក្តី ទំយោងស្រដី ទន់ទៀនស្មោះ សំឡបសំឡែត លំអូតចំពោះ ពាក្យពោលពីពេះ ពាយុពាប់សំដី.

៤ ចង់មួយទៀតទៀង ទឹងសួរច្រៀងច្រៀង ឧតភ័ន្តពាក្យ ពីៗ ពោះពាយចំនុក ជាគំនុកសេចក្តី ផ្តែមផ្តុកមេត្រី ផ្សព្វផ្សាយខយា ។

៥- ចង់មួយរឹងទៀត ដោយខ្លួនឯងស៊ប់ឆ្កៀត អារម្មណ៍ត្រាត្រៃ ត្រូវចិត្តចង់ជាខ្ល ពេញភ្នក(១)ខ្ជាថ្នា ជាន់ដូចចិន្តា ចំណងគំនិត,

៦- ចង់មួយឆោះឆឹង ប្រុងប្រាណប្រែប្រឹង មារយាទគន់គិត រឿបជាក់តាកតែង ចាត់ចែងត្រូវចិត្ត តិច្ចកលគំនិត ការងារជនជាន ។

៧- ចង់មួយឆោះមិញ ទឹងក្តីខ្លួញ ខ្ជួនឹងមិនស្រាន្ត មិនស្រេកចិត្តនឹក រត្ថុកមិនក្សាន្ត ជាគុំគួរប្រុះប្រុលណា យំសោកអាល័យ,

---

១- តាមសព្ទ (ពាក្យបុរាណ) បំណង : មានភ្នាន, ពេញភ្នាន, គឺមានបំណង, ពេញបំណង (មានប្រើតែតែក្នុងកាព្យឃ្លោងបុរាណ) ។

៨- ចង់មួយទៀតនោះ ទឹងក្តីស្ត្រីស្មោះ ផ្តេកផ្តិតមូលមៃ-
ត្រីត្រេកមនោរម្យ ផ្សាធ្យូប្លុំយ សម្ផស្សកំសម្ផ័យ ត្រូវតាមបំណង ។

ក្តីចង សង្សារ ច្រើនមី ប្រការ គ្រប់ប្រុសស្រីផង តែងតែ
ចង់ចាប់ ឲ្យខ្ជាប់ស្នេហ៍ស្នង ដូចឫទ្ធិចង ជាធម្មទេសនា,

មួយៈសាគត្រះពុទ្ធ ទេសនាចំហុត ថាវិភវិយោ មានច្រើនពីរ
ស្មោះ បួនខោះចិត្តជា បីខោះមហា ចិត្តទុចរិយជាយ :

១-ឯប្រពន្ធជា ឯក ឈ្មោះ ម៉ាតា ភរិយាដូចគ្នាយ ឈឺឆ្អាល
កូនខ្លួន រៃអង្គុនមិនណាយ មិនខឹកសាយ ចិត្តចាំអាណិត, កូនទុក្ខ
ទោសម្តេច ខ្លាត់ក្រច្រើនតិច ខឹងខុសខូចចិត្ត ក្រោត់ក្រាសយុវលង់
កូនចង់បៃតចិត្ត គន់ចាំចិត្តគិត ឈឺឆ្អាលេកូនាស្មោះ ។ ប្រពន្ធណាគាប់
ឈឺឆ្អាលប្តីខ្លាប់ ចិត្តចាំកាន់តោះ ដូចគ្នាយស្រឡាញ់ កូនពេញពីពោះ
ហៅប្រពន្ធនោះ ថ្លៃឥតធ្ងឹមដល់,

២-ប្រពន្ធជា ទី ឈ្មោះហៅ ធាសី ភរិយាដូចកល់ ខ្ញុំធឹងអម្ចាស់
ប្រើណាស់ខ្លាយខ្លល់ អាចអត់ខប់ល់ ខម្លីខបម្រើ ។ មិនមានខំនេរ
ខោះម្ខាសាយដេរ អត់ទុនសរពើ តាមតែបង្គាប់ ប្រញាប់ចង់ធ្វើ
ចិត្តពុំសើរើ ចៀសវាងក្រោធ, ប្រពន្ធណាអត់ ទុនអង្គអំណត់

ខ្ញុំចប្តីអាត្មា ដូចខ្ញុំនឹងម្ចាស់ ខ្ញុំចណាស់ឆាតា ប្រពន្ធនោះជា ប្រសើរសុខសួន ។

៣-ប្រពន្ធជាស្ត្រី ឈ្មោះកតិនី កាយោដូចប្អូន ស្រឡាញ់ចង់ពិត លំអិតលំអូន ខ្នួលដំបូន- មានមាត់ពាក្យចង់, ផ្តាច់ផ្តួលតែមួយ ទឹងចង់ជាគ្រួយ ចិត្តចាំបំណង ពាក់ពីប៉ុនប៉ង តែទឹងអង្គុយ ឥតមែនទៀង ។ ប្រពន្ធណាចូល ទឹងប្តីមួយមូល ចិត្តជាប់អាល័យ ដូចប្អូនទឹងចង ចាំបង់អស្រ័យ ប្រពន្ធនោះថ្ងៃ មធ្យមពេកពិត,

៤- ប្រពន្ធ ចិត្រា ឈ្មោះហៅ សខា កាយោដូចមិត្ត សំឡាញ់ ស្រឡាញ់ អស់អញ្ញាពេកពិត ស្មើខ្លួនស្មើចិត្ត ស្មគ្រស្មោះចិត្តា ។ បើមិត្តទៅឆ្ងាត់ ស្ងប់ស្ងួតមុខមាត់ ខុក្ខខនខហោ ឃើញមុខមកឆាន ចិត្តក្សត្តសោះសា ស្រស់ស្រួលកក្រា ទីខុក្ខសោកសៅ, ប្រពន្ធណាចិត្ត ស្រឡាញ់ប្តីពិត គ្មានកង់គ្មានក្រៅ ដូចមិត្តនឹងមិត្ត ចង់ចិត្តជាប់នៅ ប្រពន្ធនោះហៅ ឧត្តមក្រមាន ។

សំដែង កាយោ ពាំងប្អូន សឹងជា ក្រស្រើធ្វើបាន បើស្រើណាពិត ផ្តង់ចិត្តសន្ធាន ស្រឡាញ់ប្តីប្រាណ ដូចធម៌ទេសនា, លោកថាស្រីនោះ

ក្នុងក្តីពេះ· ខ្ញុំមានទាន បើអស់ដំណែង មានបិតសួគ៌ ចៀសចាក
ចតុក· ជាយជាបខ្ញុំគ្មន់ ។

៥- ប្រពន្ធពុំជា ឈ្មោះ វិនកា ភរិយាដូចនៃ សត្រូវចាំបង
ខោសផងសព្វថ្ងៃ ប្រពន្ធបង្រៃ ប្តីមានតែខ្ញុំ, បើប្តីខ្ញុំសាច់ក្តី ឯគ្មាន
អាណិត ខេះខឹងជាអ្នក ចាំបងខោសប្តី ស្រដីកំចកុក ឱ្យមាត់ឱ្យមុខ រ៉ៃ
ជាងក្អែរវ៉ែរ ។ សុខខ្ញុំសាំគាំ ជាមើលបំណាំ ខៅស្ងៀមត្រងើយ
ពុំដួងខ្ញុំគ្មន់ ដោះដៃតន្ទើយ ស្ងាប់ដាយរស់ដាយ គ្មានចិត្តមេត្រី,

៦- ខោរីកភរិយា ប្រពន្ធពុំជា លបលួចទ្រព្យប្តី គ្មានចិត្តគុណា
មេត្តាប្រណី រមស់ទ្រព្យអ្វី លក់ចាយអស់ធួន ។

៧- អយ្យាកភរិយា ប្រពន្ធពុំជា ដំកើនតែខ្ជិល ចេះតែប្រើប្តី
ឥតប៉ិមានសួន ធ្វើឫកណាំខ្ជិល ខុកប្តីដូចខ្ញុំ,

ប្រពន្ធទាំង៧បី ដាក់ខៅអាវិបី រនេចក្នុងដំណាំ តូចខ្លះក្លិនត្រាំ
ឃ្លុះខៅក្រៀមក្រំ ព្រោះចិត្តខ្ជិលច័ណ្ឌ ជាងប្តីអាត្មា ។ ឯប្រពន្ធបួន
មុខនោះគួរសួន ឃកជាភរិយា ទើរកើតរបស់ កើរ្តិយសសក្តា ថ្កើងឆ
ពួជពង្ស សេៈយសុខថេរប៉ិត, សំដែងចរិយាយ ភរិយាទាំង៤ឡាយ
ទ្រាំពីរ ចរិត ទាំង៧ទាំងជា ពណិនាពោលពិត ចែងចាំពាក្យ
តាមអត្ថគាថា ។

តតមេហិ បញ្ចកតិ- ឥមិ សាមិកា ភរិយា

ស- ដ្ឋហា សម្ភា ប្រែតាមអត្ថ- ធម្មាយថាល, ថាប្រុសឯណា
ទំនងមានភរិយា លោកឲ្យចេះក្តី ទាំង ប្រាំ ចំពោះ សង្រ្កោះចិត្តស្រី
ប្រពន្ធប្រក្រតី ដូចធម៌សំដែង ។ បើប្តីឯណា ពុំគាន់ភរិយា ទាំង
ប្រាំនេះឯង ហៅប្តីពុំជំនួ ដួលនរកក្រៃលែង ចេះតែកំហែង ចិត្តប្រពន្ធពិត,
បើប្តីគាន់ច្បាប់ ទាំងប្រាំនេះខ្លាប់ ហៅប្តីសុចរិត បំរុងភរិយា ដោយ
នាក្រមក្រឹត្យ ប្រសើរពេកពិត ឥតអ្វីធ្ងន់ឡើយ ។ អស់ប្រុសទាំងឡាយ
ចូរចាំអធិប្បាយ ច្បាប់នេះជាត្រើយ ទុកគ្រប់ប្រុសស្រាណ កុំមាន
ភាន្តិយ មានប្រពន្ធហើយ ជាសុខសម្រាន្ត, :

១- មួយកី ឲ្យប្តី ហៅប្រើស្រដី ទំនងប្រពន្ធមាន ពាក្យខន់ពីរោះ
ស្មើស្មោះដោយក្សន្តិ សរសើរពេលអាន តាមសំភាសា ។

២- មួយកី ប្រពន្ធ ឲ្យសន្តិធ្រាលដួនំ កុំដេរដ្តាសា ខាត់ធាក់
ដៀលដំ ដូចខ្ញុំអាត្មា កុំស្តីដើមថា ឲ្យឮសាយស័ព្ទ,

៣- មួយកី ចាខដន ប្រគល់ប្រពន្ធ ទុកជាក់រណ្តាប់ ទាំង
គ្រឿងអាហារ ជាការស្រួលផ្តាប់ រៀបចំសម្រាប់ ថែរក្សា ។

៤- មួយកី កុំជួង កុំចិតែបង់- តើតកូនហើយថា ប្រពន្ធសុខចិត្ត
ឲ្យតែតប្បាថ្នា រួសរកខ្ចីគ្បា សម្រាប់ឲ្យផង,

៥- មួយកី ឲ្យចាប់ ស្រឡាញ់ឲ្យខ្លាប់ កុំជិនណាយហោង
បើមានប្រពន្ធ ទៀតកុំប្តូនបង់ ស្រឡាញ់ស្នេហ៍ស្នង ឲ្យស្មើមុនឡើយ ។

សំដែងសេចក្តី គ្រប់ទ្រាំវិញ ចែងចប់ស្រេចហើយ ឲ្យអស់ប្រុសផង ចាំចងជារត្នែយ ផ្ងន់កុំកន្តើយ ចោលច្បាប់បុរាណ, បើប្រុសឯណា តុំផ្ងន់ចិត្តា ដូចជមិខ្ញុន្នាខ នៅនឹងភរិយា គ្មានជាសុខសាន្ត ហិនហោចធនធាន ខាស់ខែនលែងគ្នា ។ ឯស្ត្រីយចិត្ត ស្អប់ស្រីផងពិត មានប្តីច្រើនថ្នាំ អំពើពាំងទ្រាំ ខេះចាំចិត្តា គ្រប់ចិត្តភរិយា នៅនាលោកិយ, បើខ្លះអំពើ ណាមួយហើយតើ ប្រពន្ធថាប្តី ចិត្តពុំត្រូវត្រង់ តុំគន់មេត្រី ដូចចិត្តស្វាមី អាក់អន់តុំស្មោះ ។ លោកឲ្យប្រុសផង គន់គិតស្ងួនត្រង់ ផ្ងន់ចិត្តសង្រ្គោះ ប្រពន្ធឲ្យពិត ដោយក្រែ្យចាំនោះ ប្រពន្ធក៏ស្មោះ ចិត្តចួលមួលឯង, កុំគិតតែយក ប្រពន្ធជាខមក គ្រាន់ខុបប្រឡែង បង្កើតតែកូន សោះសូន្យធនធេង លោកឲ្យគិតត្រែង ដំនៀលនិន្ទា ។ ធម្មតាជាប្តី ជាន់ត្រព្យធន់អ្វី ប្តូយសសក្តា តែងនៅសុខសឹង ខ្លីពឹងផងគ្នា ព្រោះដ្បៀតភរិយា តាន់ក្តីសុចរិត, អំពើច្នេះហោង ឲ្យអស់ប្រុសផង ចងចាំក្នុងចិត្ត តាមធម្មិខ្ញុន្នាខ គ្រប់ច្រាំណប្រុសពិត ទុកជាក្រមក្រែ្យ ច្បាប់ច្បាស់តម៉ៅ ។

អង្គអញ្ជាចនា សេចក្តីកាព្យ តាមច្បាប់ទុកនៅ ក្នុងព្រះបាលី សេចក្តីជាលជ្រៅ ពុំហ៊ានសៅដៅ លើកលេងងាយងាយ. ទស្សាហ៍ទំប្រុង ប្រែរកើសក្នុង តម្លឹងនិកាយ អដ្ឋកថា ដីកាបរិយាយ ទំចាត់ទាំងឡាយ មកផ្សំស្រដី ។ ជាច្បាប់ទុកត ដំណឹងដំណា ដំណើរស្ត្រី

ឲ្យជាក់ច្បាស់ដ ដោយបទច្បាស់ គ្រាន់តែសំប្រុសស្រី រើសរៀនតែម្តង, ច្បាប់នេះប្រសើរ ដំណឹងដំណើរ ខំនឹងនេះក្តី ជាច្បាប់ច្បាស់ដ ដោយបទត្រឹមត្រូវ គួរយើងឥឡូវ ប្រតិបត្តិតក្តី ។ គួររៀនឲ្យស្ទាត់ ឲ្យចាំរត់មាត់ ជាក់ក្នុងចិត្តា គ្រាន់នឹងប្រតិប្រឿន បង្រៀនអាត្មា តាមដោយគាថា នេះឯងតទៅ,

ចែងចប់អតិច្រើយ ដោយអត្ថបរិយាយ សូរចេចថ្លៃសៅរ៍ ច្រាំបីកេចឯ នាខែមាឃមៅ ឆ្នាំរកាត្រូវ នព្វស័កស្រេចហោង ។

- ចប់ -

និគមរឿងនេះ

ច្បាប់ស្រីនេះឯង ល្អឥតខ្ចីនឹងថ្លែង ទ្រង់តែងតាមច្បាប់ ជាព្រះពុទ្ធដីកា ទេសនាច្រើសច្រាប់ ចុកជាព្រះច្បាប់ សម្រាប់ស្ត្រី,

ច្បាប់នេះដៀនជាក់ ពិតតែទ្រង់ជាក់ នាមថា "ច្បាប់ស្រី" ប៉ុន្តែមានច្បាប់ សម្រាប់ស្វាមី សង្រ្គោះស្ត្រី ជាកិយោជន ។

កិយោស្វាមី ណាបានឃ្លាតខ្លី គាន់ច្បាប់នេះហោង មុខជាខ្ជឹងបាន សុខសាន្តកន្ទុង ក្នុងគ្រួសារផង ឥតមានមោរមៃ,

ច្បាប់នេះល្អពិត ខ្ញុំខ្ញុំពេញចិត្ត ជាងច្បាប់ដទៃ ទើបខ្ញុំផ្ទៀងផ្ទាត់ ហ្មត់ចត់ប្រពៃ ហើយបានគិតលៃ ចោះពុម្ពផ្សាយឡើង ។

រឿងសព្វសិទ្ធិ

(ភាគ)

របស់ហ្មឺនភក្តីអក្សរ តន់ លោក ប៊ុ-ប៉ូ បម្លងពីសារស្រ្តស្ប៉ាញ

កាព្យពាក្យ ៣

សកុណីស្តីហើយទ្វើយឥតក្រែង ថាចិត្តអ្នកឯងនឹងចំបូសា ខ្ញុំដឹងជាក់ស្រេចកុំចាច់ថា អាងតែក្រាជាចេះតែវៃ ។ នាងរឹងរំជួលក្តួលឥតម្រួយ ហាក់ដូចអគ្គីឆេះទៃ ចាក់តែនឹងតឹងស្ទើរក្សៃយ តែងរសាកាម៉ៃយភ្ញីស្រាកស្រាន្ត ។ បក្សាជាប្តីស្តីហត្ថក្រាប់ ភ្ញុំបួលចិត្តស្តាប់ដឿស្មោះស្មោន រីឯគស្រណោះចោះចោកក្រាណ ទោនទៀនខ្លួញខ្លួញថា ។ តុកូន កំសត់មាសម្តាយអើយ ពីរនេះទៅហើយម្តាយឈឺផ្សា ឱនត្រាំតែតុកទៅដល់ណា សូវសូន្យដីពាតាមមាសថ្ងៃ ។ ជាហើយកាន់ស្នាបត្រាបង្ខិំប្រណាម្យទៅតាស្ងួតាលើយ តាំងខេតស្ងិតស្ងាន់ដាន់ព្រឹក្សាព្រៃ ទៅនៃតារីខបពូតា ។ សូមលោកជួយជាអស់សាក្សី ទោះបីខ្ញុំតើតជាតិកាលណា ខ្ញុំសូមតាំងចិត្តគិតសច្ចា ប្រាថ្នាកុំឲ្យទៅរួមកាយ ។ ឱនឯជាតិជាប្រុសត្រូវអគ្គីប្រាណ ហើយកុំឲ្យបានចែងមកប្រាយ មេត្រីស្តីស្តាប់សព្វបរិយាយ ឲ្យឆ្ងាយរឿងពាល់ដឿសឲ្យបាន ។ ទោះបីទៅតើតកពណា ។ ជាសត្វមនុស្សាសព្វត្រូវស្តាន ជាតិប្រុសកុំស្ទើត្រូវរួមប្រាណ កុំឲ្យពាប់អានស្តានមេត្រី ។

គ្រានោះសក្កណាបក្សាសត្វ សម្លាត់ចាំស្តាប់សព្ទបក្សី ឮនាងសច្ចា
ថាបា្លះខ្ញុំ ទើបស្តីឆ្លើយឆ្លងនឹងនាងវិញថា ។ សូមអស់ទិសទសៈសោ-
ឡសស្ងាន ស្ងំតក្នុងត្រើយត្រាណធកាមា ជួយជាសាក្សីខ្ញុំប្រាថ្នា តប
ស្នងវាចានាងបក្សី ។ ដ្បិតគេប្រាថ្នាអនាគត ឲ្យចៀសឲ្យផុតខ្ញុំជាប្តី
ជាតិប្រុសគេថាមិនមេត្រី មិនស្តីមិនស្តាប់សត្វវាចី ។ ថាខ្ញុំស្រឡាញ់
មិនពេញស្មើគ្រែ ទឹងនាងនេះជាក់ស្តែងដីវ៉ែ ពុំមានបែកបែរប្រែចិត្តពីរ
លៃលកកេញ្ចឹងខ្មៅតសោះ ។ ជាតិក្រោយសូមឲ្យបានរួមគ្នា ទឹងនាង
នេះជាក់ជាគួរស្មោះ ខ្ញុំស្តីឲ្យស្តាប់សព្ទស្រណោះ កុំឲ្យរដោះលុះទៅភាន ។

ឯនាងសក្កណីបានស្ងៀងស្តាប់ បក្សាសារសព្ទតាំងប្រណិធាន ចិត្ត
ក្តៅតិតក្តួលក្តួលរំពាន មិនមានទឹកស្តាយជលដីវ ។ ហើរចុះចូលស
ស្ងឹកក្នុងកងភ្នើង នេះខ្លីនលេត់ផុតកាយា បាបរណ្ហាលរើញជាក់
ឆ្អាក់ខ្លួមឆ្អា សុះផ្តោះចូលឆ្អាកងអគ្គី ។ ភ្នើងនោះក៏នេះដាផេះផេង
ជាយដាត់ឆាត់អង្គីជាធុលី សត្វនោះទាំគ្នាស្តាប់តាំងពីរ ព្រោះមានវេរ-
ខ៉ែវែង ។ កាលកន្លងមុនឡើយបក្សានោះ បានលុះបុញ្ញកាតាប់ជាតិជា
មនុស្សហើយជុតសត្វឲ្យមណា រៀងនោះតាមតែកល់ជាតិ ។ មោះ
មកឆ្ពុទ្ធានាលោកិយ បក្សាបក្សីតើតវិវ៉ា ជុតខ្លួនឯងវិញពុំឃ្លាតឃ្លា
ត្រប់ច្រាំរយជាតិទើបរដោះ ។ រួចពីវេរាទៀបាបបាន បានជាតិ
តិរច្ឆានមកកើតស្មោះ ជាមនុស្សមានរូបល្អស្រីបស្រស់ លើសអស់មហា

ជនចាំងប្រុសស្រី ។ ឯចាបឈ្មោលនោះមកតើតជា ឫត្រាកោណ្ឌញ្ញ
មហាសេដ្ឋី តរីយោឈ្មោះនាងរេមារី ពាសេសតិសំសមសោភា ។
នៅស្រុកបច្ចន្តគ្រាមក្នុងបុរី ពាពណាសីពាជនាក សេដ្ឋីប្រកបដោយ
ទ្រព្យា អនេកតណាមាពន់ប្រមាណ ។ លុះនាងរេមាមានគតិគ្រប់ ទស-
មាសតំរាប់ចំរើណិបាន ប្រសូតនូវសុជាប្រសូត្រឈ្មោះ សេដ្ឋីកំសាន្ត
សោមនស្សក្រៃ ។ ឯឈ្មោះថាចៅសព្វសិទ្ធិ មានឫទ្ធិមានរុះពកងឆ
ប្រពៃ ដូចទេពទេវីសួគ៌ាលីយ ចុះស្រុតមកភ្លាដែនលោកា ។ សង់
លុះព្រះមង្គលចំរើនធំ សត្តិសមត្ថភ្លោតជព្រះឫទ្ធាជ្ញា ព្រះដន្ធបានជប់ប្រាំ-
វស្សា បិតាមាតារំងើរចេតី ។ ហើយប៉ើសរកបានតំលៀងម្នាក់ ឲ្យនៅ
រួមក្បស្ន៌ត្រេមត្រី នៃបនិត្យនឹងគ្នាជាប្រក្រតី ឥតប៉ីមានទុក្ខជាសុខា ។
ឯចៅសព្វសិទ្ធិឫទ្ធិរង្ស៊ី មានស្រីសួស្តីត្រប់ប្រាំការ ប្រកបនូវលក្ខណ៌សម
សត្តា ឥន្ទ្រព្រះឫទ្ធាអគ្គាស្រ័យ ។ ហើយមានកុមារជាគូស្ន៌ត្រ
មួយពាន់មួយនាក់នៃបសព្វថ្ងៃ រួមក្បស្ន៌ត្រស្មោះស្មើដូចមួយ ស្រឡាញ់
គ្នាក្រៃឥតមានហ្មង ។ អ្នកមានឫទ្ធាភ្លាហានណាស់ ឆ្លៀវឆ្លាស
លើសអស់កុមារផង សម័យមួយនោះព្រះបាលិច្ឆត្រ គន់គិតប៉ុនប៉ងឯ
ឥន្ទ្រាគ្រា ។ ចរលីចាកទីនគរេត រកវិរៀនវេទវិជ្ជាការ សិល្ប
សាស្ត្រសៃយរកេតព្រះគាថា ឯតក្កសិលាមហាស្ថាន ។ ហើយនឹង
បបួលពួកកុមារ ដែលរួមចិត្តាស្ន៌ត្រស្មោះស្មាន ទៅជាស្រុករកំដរឫទ្ធា

តិតស្រេចបួលថ្ងាន់ស្នាន់សេដ្ឋី ។ ដល់ហើយក្រុញក្រាបទៀបបាទ ម៉ែតា
មាតាដោយមេត្រី ថាសូមអម្ចាស់ប្រោសប្រណី ឲ្យដូចសេចក្តីប្រាថ្នា
ខ្ញុំ ។ ដ្បិតចិត្តសព្វថ្ងៃមមែណាស់ បង់ចរស្វែងសូរលេនិគម ទើបតិត
ទៅរកលោកគ្រូធំ. ឯបុរីមម្តតក្តសិលា ។ រកវៀនច្រើនកេរត្រេរវែងផង
អាណិតកូនខ្ចីដ៏កុំខាំងខា បើរៀនចេះចប់សព្វកាលណា ទើលាអាចារ្យ
មកវិញ្ញ ។

ម៉ែតាមាតាបានស្តែងស្តាប់ បុត្រាសារសំពីសព្វសេចក្តី ខ្ញុំសូមលា
លោកបាតបុរី ប្រយោជន៍រដំម្បីរៀនវៃ្យ ។ សេដ្ឋីទាំងសងមិនអាចអត់
ឃាលមាត់ទើបមានវាចាថា កូនអើយឯកចង់ចរយោគ្រា យើងឥតទាំង
ទាយាត់បុត្រថ្ងៃ ។ ដ្បិតថាទំនៀមថាបុរស ត្រូវរកវៀនអស់សិល្ប
សាស្ត្រសៃយ ថាកូនប្រុងជាបព្រត្យច្រើនកែ ឲ្យបុត្រអាស្រ័យសៀង-
ជាំ ។ ស្រេចទើបចំរៀនពារប្រសិទ្ធ ឲ្យបានដូចចិត្តសម្រេច្ច ទោះទាំង
អរិកជតៃរ៉ា កុំបីយាយីបៀតតាធា ។

គ្រានោះចមតន្ធ្រវែងដ៏ស្រី អារនេសរសើគ្រាបវន្ទា ខ្ញុំលព្រះ
តវៃ្ចនា ស្រេចបរីយគ្រាបលាចុះចាកស្នាន ។ នាទាំងសៀងជា
ដេដ្ឋា ទៅហៅកុមារម៉ែគ្រប់ប្រាណ មួយពាក់មួយនាន់មកស្នេះស្នាន
ព្រមគ្នាស្រេចបានចរយោគ្រា ។ ដើរទាំងថ្ងៃយប់តុំណប់ណា បានដល់
នគរតក្កសិលា ដើរចូលទៅគាន់ព្រះអាចារ្យ ទើសាបានមោក្ខនាគ្រូងក្រែ ។

ខំគ្នាគេរៀតគ្រប់ចំពាំ ហាត់រៀនវិជ្ជាច្រើនក្រាស់ក្រៃ អាចរៀបច្រាប់ប្រៀនតែសត្វថ្លៃ ប្រដៅសិល្បៈសៃយចេះសព្វសាយ ។ ឯពោធិសត្វវត្ថុនរេត រៀនរេទិដ្ឋាមន្តគាំងឆ្ងាយ ចេះចប់គ្រប់បែបដោយលៃបខាយ ប្រុះប្រោយប្រាជ្ញាក្លាហៅហាន ។ គោះរូបខ្មោចស្ងាប់ប្រាដកតិត អ្នកជកដួងចិត្តចេញព័ប្រាណ នៃអ្នករៀងាក់រូបខោះបាន រួចរស់ឡើងថ្កាន មិនមានហ្មង ។ គោះបើអ្នកធឹងចង់ប្រាថ្នា ដកដួងចិត្តតាមចំណង់ ទៅងាក់ទៅអ្វីដទៃផង សឹងចេះសាសង់ទូងន្លើយបាន ។ ភ័លៀនកំរៀនបានចេះចប់ ។ ប្រសិទ្ធិប្រសប់ស្មោះដូចស្មាន កុមារដែលជាមិត្តគ្រប់ប្រាណ តុំបានចេះស័ល្យស្មើព្រះអង្គ ។ តន់តតួចចិត្តដូតទុនទៀ ឱដ៏ទៅរៀនទៅតុំសូវចង់ ទើបលាអាចរៀបចេញចាកបង់ ត្រាច់ត្រដំរំលេមកកេបុរី ។ ឯចៅសត្វសិទ្ធិប្តូរិទ្ធិ អម្បូរពូជឥស្សរជិនស្រីទៅខឹងជេដ្ឋាជាប្រក្រតី ឥតប៉ាមានពុក្ខជាសុខា លង់លុះរៀនចប់គ្រប់វេទមន្ត លេខយន្តប្តូរិហៅហានក្លា យូរជាអម្ងឹងច្រើនវស្សា ទើបលាអាចារ្យវិលចរប្តូន ។ មកកេបុរីនៃអាត្មា សិហនាទយោត្រាំងឪពុកប្រាណ លង់លុះអាទិត្យចំទស្សរថាន អ្នកឈប់សម្រាន្តកងអង្គា ។

រឿងនេះស្ទះសិនមិនខាន់ស្តី ថ្លែងឯសកុណីកាលមរណា ទៅយកកំណើតកើតជាតិជា បុត្រនៅនាពារាណសី ។ នាមព្រះព្រហ្មទត្តទត្តិយវង្ស ច្រើសច្រង៉ាំអានុភាពច្រាបផែនដី កុសុមាសោភាជាមហេសី

ជាធំលើសស្រីស្នំក្រមការ ។ ព្រះនាងទ្រង់តតិបរិបូណ៌ត្រប់ ដួបចូលគំរប់ទសមាសា នាងក៏ប្រសូតពាជធីតា ចាកទ្វារចេញពុំលង់ ។ ព្រះបាទព្រហ្មទត្តក្សត្រធិបតី កួចកើតបេតបុត្រនោមយង់ តាំងនាងកុសុមាវតីឲ្យ ទ្រើសទ្រង់ត្រិះត្រែកពេកកន្ធង ។ ឲ្យមានមេនំបំផៅបី ខ្លួរពាជបុត្រីស្រីខ្លួនល្អង នាងល្អអស់អគ្គទ្រង់ម៉ដ្ឋង មិនមានស្រីផងប្រឡងបាន ។ សម្តេចបិតុរង្គអង្គមាតុរេត ឲ្យនាមតាមតេទាតណុង្គប្រាណ ឈ្មោះនាងសុវណ្ណកេសរសោន្ត ស្មោះស្មានស្មើស្មុគ្រក្សប្រីតា ។ លុះនាងចំរើនព្រះជន្មត្រប់ បានច្រុំងណ្តាប់ព្រះវេស្សា រតនអស់អង្គទ្រង់រូបា ដួចទេពកញ្ញានាសូតិស្រី ។ ព្រះកត្រកុំកួងដង្ហើមបុប្ផាខ្ចី ដួចកលព្រះចន្ទចែងរស្មី ព្រះអង្គទ្រង់ដួចកន្ទីរ ឆវីលឿងខ្ចីសុីខ្ទមក្លាយ ។ ស្ពន់ដោះគួចដួចខន្ធាប់ មាសផ្តាប់ដាប់ធនីព្រះអង្គកាយ ក្រពុំដោះក្សីសមនោមធាយ ល្អចប់សព្វសាធកាយសពិន្ធ ។ ទាំងរូបទាំងឫកកិរិយំ មិនតួចមិនធំសមរួចពង ដំណើរវិលាសនីយាសនោយ ពាក់ដួចជានាងស្រីសុជាតា ។ ធម្មតាជាស្រីកងដ៏ជែន កពង្គែនតួរដ៏ក្នុំសុមេក ទីរៈជ្រីសរើសកេស្រីឯណា ធ្លៀងធ្លីមរួចកំពុំបាន ។ ដោយហេតុផលកម្មប្រចាំកាយ នៃនាងនោមធាយកែវកលាណ សព្វំតាំងចិត្តប្រតិស្ថាន ឲ្យបានសម្រេចដួចសព្វ ។ ព្រោះនាងក្រោធខឹងនឹងស្វាមី កាលជាបក្សីនឹងបក្សា ថាសូមកុំឲ្យចែងចរចា នឹងប្រុសណា ។ ជាច្រាកដ ។ លុះនាងចាប់

ជាតិខ្លែតចំហុត ចំពោះជាបុត្រស្ងួត្រព្រហ្មទត្ត ផលកម្មនោះចាំផ្តួយសង្កត់
នូវនោរ៉ត្តមិនឲ្យស្តី ។ ឆឹងប្រុសតាំងអស់គោះឆ្ងេចធំ ប្តូព្រះបរមពជក្រៃ
ជាព្រះបិតុរុងអគ្គនាងស្រី នាងសោតផតបីចែនចរចា ។ នោតែកូនប្តូនុ
ប្រាសាទនុ សម្ងាត់លាក់ខ្លួនតួនអាត្មា ជាមួយនឹងស្តីក្រមបរិវារ និរ-
ទុក្ខសុខជាក្សេមក្សាន្ត ។ ស្រដីតែនឹងស្តីងដ៏ត្តា ត្រប់ខែនទើងជាស្មោះ
ស្មាន ជាតិប្រុសពុំចេញឲ្យផ្លូបប្រាណា ប្រមាណប្រាំដណ្តប់វស្សា ។

កាលនោះព្រះបាទព្រហ្មទត្ត ឯកអគ្គបតិទ្រង់ក្សត្រិយ៍ ទ្រង់ជ្រាប
សេចក្តីបុត្រីថា នាងពុំចរចានឹងប្រុសប្រាណ ។ ខ្លួព្រះបតិត្រូវជាបិតុរុង
យល់យូរអង្គុនពន់ប្រមាណ ពាំងខ្លែងគាល់ហ្មែកិខាតខាន ក្សត្រិយ៍ក្សាន្ត
រំដិលត្រង់ណលក្រៃ ។ ទើបមានតម្រាស់ត្រាស់ហៅថា ហៃតែកុសុមាតូកិ-
សម័យ ឬនអើយហេតុអ្វីបុត្រីថ្លៃ ពុំដែលប្រស្រ័យនឹងអញ្ជេឡើយ ។
តាំងតែតូចរួចដល់ធំ ពាលតេញក្រមុំប៉ុណ្ណេះហើយ ឬមួយកូនយើង
ឆ្នើងដឹងអើយ ទើបធ្វើគោះតើយមិនធ្វើយទូច ។ ឬមួយមិនសុខទុក្ខ
ភេមនស្ស មានបើខុសចាស់ចិត្តសៅហ្មង ហេតុនេះសែនសល់ឆ្ងល់កន្ធឹង
ប្លូនាងឆៅលងលួងសួរសួល ។

កុសុមាថ្លាថ្លៃវិញ្ញល័ក្ខណ៍ ខ្ជូនអ្នកជាន់ស្តាប់សព្តូកូធរ ខ្ជួលទង្ហាវ
ជាព្រះពារ ទើបវាវៃគ្នាលីលាថ្លាន ។ ចរចួលខែនត្តបុត្រីថ្លល់ច្បើង ដល់
ខ្លើងតង់តែបនៃបណ្តើងក្រាន មានព្រះសារនីយ៍ស្តីស្មោះស្មាន ថាហៃ

កលប្រណាម្ចាំមមាតា ។ ដែលព្រះទេវបតិ៍ចិតាក្សត្រ ម្តេចកូនស្ងួនស្ងាត់
មិនបរបា តុំដែលឡើងគាល់តាល់ម្ល៉ះណា គួឲ្យស្រឡាំងក្រែងអំប្លាយ ។
ឬមានទោមនស្សតូចចិត្ត នឹងព្រះបពិត្រតិតដំនណាយ មិនចង់ស្តី
ស្តាប់សព្ទអតិប្រាយ ប្រាប់កូនប្រាប់ម្តាយកុំលាក់ឡើយ ។

សុវណ្ណសេរីភ្ញេកយ័ណាស់ ទូន្រាបសំពះមាតារហើយ ទូលថា
ព្រះមេមានគុណនើយ ដែលសង្រ្តែត្រាណត្រើយជាបិតា ។ ព្រះអង្គទ្រង់
គុណធ្ងន់អនេក អង់គ្សអតិរេកអស់បិន្តា បង្កើតបុត្រធានឡើងគាលណា
ប៉ាប់ប៉ាងស្ទើរថែលុះធំ ។ តុំដែលឡហ្នឹងគ្គនិចិត្តកូន ត្រូវខ្វយអត់ក្ខូនធំធ
ដូចគ្នំ ថាហើយអាត់អួលទូលតាំងយ៉ំ ៖លើកតរបង្គិព្រះដនីដ ។ សូម
ទ្រង់ករុណាអាណិតម្តង វិលទោទូលស្នងព្រះភូមិ ឋាកូនយល់មានពៀរ
វេរ តាំងពីតើតមកដល់ឥឡូវ ។ សូមរីអស់ប្រុសទុសចិត្តឡាយ ចេះ
តែជំនណាយណាស់មិនត្រូវ មិនត្រេកចង់ស្តាប់សព្ទសោះកូវ ទោះតាំង
អង្គចុះជាបិតា ។ ហៀបនឹកហើយហាមាត់ស្រដី ហាក់ដូចមានអ្វីភ្ញាស់
ទ្រូង ប្តូរយើញព្រះនេត្រក្រឡាត់តាលណា អៀនអន់ទ្រាំជាប្រាកដ ។ តឹកិម្ម
អកុសលដល់ម្ល៉ះតើ ព្រះមេមិនដឹកូនហ៊ានស្បថ ហេតុនេះកូនសូម
សន្តោសអត់ ទោសទ្រង់មំណត់ព្រះទ័យា ។

កុសុមាទេវីដនីនាថ ស្តាប់ហើយយាងយាត្រព្រះភូមា ទ្បើង
តាល់ចមពង្រឹងអង្គពជា ខើបនាងឥតណានាទូលស្វាម៉ ។ ជាកូនយើងឯ

ខោះគ្រោះកម្មពិត ស្តាប់តួរអាណិតតាមពាក្យស្តី ថាឈ្នះតែប្រុសក្នុង
លោកិយ កម្មអ្វីប្រចាំតាមមកកាត់ ។ មិនឲ្យចង់ចែងថ្វែងចរចា ខោះ
តាំងចិតាមហាក្សត្រ ដែលទ្រង់ព្រះគុណនេកស្តាត់ កំនាំឲ្យជាត់សត្ថ
វាទី ។ ខើបបានមិនហ៊ានឡើងគាល់ហ្អើ សម្ងំតួនទៅក្នុងព្រះគ្ភីមណី
សេចក្តីនេះសូមព្រះកូម៉ី ជ្រាបក្រោមធុលីល្អងបាទ ។

ព្រះបាទព្រហ្មទត្តក្សត្រត្រងចិតី ជ្រាបថាបុត្រីពុំមាយា ខំនងឹមានកម្ម
ពៀរវែក បានជាពុំស្តីទីធ៌ប្រុសច្រណា ។ បើគិតឲ្យត្រូវតាមច្បាប់ធម៌
កូនខែនេះពេញល្អក្រកបាន ច្រហែលជាចាំគួបុកណា ខើបកូនកល្យាណ
ថ្វែងអកិច្ចាយ ។ ស្តេចទ្រង់បង្គាប់សេនាមាត្យ ឲ្យធ្វើច្រាសាទស្អាត
ឆើតឆាយ ប្រទានបុត្រពៅនៅសប្បាយ ទំនឹងស្មំាងឡាយជាបរិវារ ។
ជាតិប្រុសនាងមិនឲ្យឃើញច្រណា ព្រោះនាងកល្យាណមិនច្រាថ្នូ ខើប
ទ្រង់ដំរិះត្រិះរិះថា ចំនៀមតម្រាពីបុកណា ។ កូនធំគោងតិតឲ្យមានគួ
ទុកយូរទៅយល់ជាពុំបាន មួយពាជរដ្ឋជាមហាស្តាន ទំនងសួនក្សត្រ
ក្សាន្តត្រងផែនដី ។ ច្រសិនខើឥតពីអញទៅ ដែលមានសល់នៅតែកូន
ស្រី ខ្មោះគួរអញផ្សងបុណ្យចាមើ ក្រែងដួនបុត្រីត្រូវចិន្តា ។ អញឲ្យ
រើសបត្រឧត្តមវង្ស ច្រាកដជាពង្សពូជក្សត្រា ឲ្យមកលួងលោមថ្នមចរ
ចា ទំនងកូនកល្យាកែវកល្យាណ ។ ខើមានបុព្វនិវាសា បានសាងទំនង
គ្នាពីបុកណា តងំនាងចរចាជាក់ស្មោះស្មាន ទំនងបានអកិសេកជាគូគ្រង ។

តិតភ្លាមទើបយាងព្រះបាទ លីលាឡើងគង់ក្នុងកេរដែន មន្ត្រីតាល់ត្រៀបរៀបរាប់ដើ ទូលតាមទំនងដំណើរមកា ។ បពិត្រសម្តេចព្រះភូមិន្ទ ខ្ញុំពិនតាលុបលោកា ចៅហ្វាយស្រុកត្រៀត្រប់ដំណា មកជាត្រប់ទៃត្រឥតហេតុអ្វី ។ អាណាប្រជាជនទាំងឡាយ សឹងសុខសប្បាយទាំងប្រុសស្រី ដោយសារព្រះគុណបុណ្យបារមី អម្ចាស់សិរីទ្រង់ទសពិធ ។

ស្ត្រីត្រកូលខ្ពង់បានស្តាប់សព្ទសេនា ត្រាវព្រះចន្ទាជួបទ្រង់តិត ដើម្បីមានតម្រាស់ត្រាស់ប្រតិដ្ឋ ជាអញ្ជើញនិត្យតែសព្វថ្ងៃ ។ ឯតអញពុំមានពាជបុត្រា តាតាវតារត្រង់ត្រង់ក្រៃ មានតែបុត្រីស្រីត្នៃថ្ងៃ នាងពុំប្រស្រ័យនឹងប្រុសប្រាណ ។ គស់ភ្លូតគាល់ក្តួតគាក់តែង ចាត់ចែងតែងស័ព្ទអស្ចារសោន ប្រាប់ស្តេចបរទេសនិវេសន៍ស្ថាន មួយរយដែលមានពាជបុត្រា ។ ពុំខាន់បានគួរស្រួតរាប់ .ហើយឆ្លាប់ប្រសប់ធ្វើពាជការ ទ្វៀតឆ្លាតសំដីរៀបច្រើរ៉ា ទ្រមកចរចារជាយទាយ ។ នឹងពាជដ៏តាកែវកល្យាណ ហើនាងស្មោះស្មោនបានអកប្រាយ ។ យើងឲ្យត្រាប់ត្រួនជាគូកាយនឹងនាងនោមតាយកែវកល្យាណ ។ ហើយឲ្យតាវជ្ញាអង្គឯងឯអាច ជាមហាទេពាជក្នុងពាជស្ថាន ត្រាស់ស្រេចទើបស្តេចចរចូលថ្ងាន ទីនេនសូរិកាន សម្រាន្តរម្យ ។

ត្រានេះអាល័ក្ខចៅក្នាក់ងារ តែងសព្ទសាពជាន់យម .ចែកចេញ

ទៅតាមតាមនិតម ប្រទេសតូចធំផងគាំងឡាយ ។ លុះសារទៅដល់
មណ្ឌលស្ពាន ស្តេចមួយរយបានដឹងសុះសាយ ត្រៃកងរស្មោះសរត្រៀម
អង្គាយ ទ្រលំភ្លាយចាត់ចែងតែងឫទ្រា ។ កូនស្តេចខ្លះមានប្រភព្ធមុន
ស្តាយស៊ុនក្រោះខ្លួនឥតវាសនា ខ្លះមានប្រពន្ធពុំពាក់ការ ជាវែ្ងងតែគ្មន់ថា
ជាគំនាប់ ។ សុទ្ធសឹងចាត់ចែងតែងរូបអង្គ យកប្រាក់ព័ថងំាយ
ឲ្យរៀប ទិញគ្រឿងតែងកាយឥតស្តាយសោះ ឲ្យពាងតែស្រស់ស្រលៀង
ចិត្តស្រី ។ ខ្លះគិតរកស្នេហ៍ពូកែឆុត ខ្លះកាមេមត់ជាន់ប្លែងខ្លី ខ្លះកំពឹក
មន្តស្រោចសុីសេី ខ្លះធ្វើយន្តត្រីនេតសង្ឃែ ។ ខ្លះរៀនគាថាមហាំសាយ
ខេពាំផ្លូវណាយឥតខ្វៃ តាំងស្មូហ៊ាវីរសេតទឹនស្នេហ៍ គួតអាត៌ពូកែតែ
ត្រៀបគ្នា ។ លុះរៀបរួចស្រេចស្តេចត្រៀបអង្គ យាត្រាត្រាច់ត្រង់តាមមាគា
ពជខ្លួតស្រួតនាំចូលតាក ដល់ព្រះពេទ្ធាកុំគ្នាស្រាប់ ។ រឿនភ្លូនចូល
ទូលស្តេចតុំលង់ ព្រះអង្គបានទ្រង់ព្រះសណ្តាប់ ទើបយាព្រះបាទ
ចេញប្រញាប់ ត្រាស់ប្រាប់បុត្រស្តេចតាំងនោះថា ។ ចូរទៅនៅថ្នែង
ចែងវាទ័ ទឹងនាងនារីពជធីតា បើនាងធ្វើយន្តទឹងសងវេរា នោះមាន
សញ្ញាជាមុនស្រេច ។ ទើបត្រាស់បង្គាប់អស់យោធា រៀបទ័ពខ្លួលអស់
កូនស្តេច ការម៉ូមានឯងតែងសម្រេច កុំបាច់ឲ្យអញប្រាប់ច្រើនដង ។
បុត្រស្តេចទឹងអស់ពជយោធា ក្រាបលាទាំគ្នាចេញត្រសង ហើយ
រៀបទ័ព្យទៅតាមកង ត្រូវទៅសាសងម្ខាង ។ ម្នាក់ ។ ហើយបាត់តន្ត្រី

ចានមួយវេន ឲ្យទៅត្រៀមកន្លែងព្រះដំណាក់ ចាំស្តាប់ព្រះនាងទាថវ
លក្ខណ៍ មានវាចាដាក់ទីឯអ្នកណា ។ ត្រូវតួតតន្ត្រីបទ្វីសព្ទ ឲ្យឮអឺង
អាប់កងគោណ នឹងចានជ្រោបដល់ព្រះចិត្ត ទើបការនោះស្រេចមិនចាប់
ខ្លួល ។ លង់លុះត្រលប់ឃប់សន្ធ្យា ភ្លាត់ឆ្ងាទៅបុត្រស្តេចសាមល
មួយអង្គលីលាឡើងទៅដល់ សាលប្រាង្គមណីមន្ទីរស្ថាន ។ កុមារគ
តិតគិតថាវត្ត មន្តឆ្ងំអានមមហាកំសាន្ត ទើបហៅថាយៃកែវកល្យាណ
សូមទោសក្រោសក្រាណាស្រណោចឆ ។ ដ្បិតបានឮនាមព្រះនាងស្នេ
ហនឹស្ទើនឹងហោះនឹងមៃលក្ខន្ធ មកវាគមាសមិត្រដោយចិត្តប៉ងឆ ឲ្យដូច
បំណងចងប្រាថ្នា ។ ស្លមប្អូនពិសីស្តីមួយមាត់ កុំឲ្យសូន្យស្ងាត់ជាត់ជា
ខា ដ្បិតព្រះបិតុរង្គីទ្រង់មេត្តា ឲ្យកែវកន្យាជាគូហ៊ោយ ។ នោមអើយ
នោមធើតស្លើតវាវ៉ល្អ កុំគិតរវើរបង្គង់ឡើយ កុំស្ងាត់កុំស្ងើរធ្លើប្លកនើយ
ពាក្យនុះគោះតើងមិនខ្លើយទន្ទឹង ។ កុមារចរចាយូរអស់ចិត្ត ព្រះនាងមិន
ស្បើតចេញសាសង៍ កុមារមានរេមញ្ចាញ់កន្ទួង ព្រះនាងខ្លួនល្អងមិន
រវៃ ។ កុមារឈឺចិត្តស្ងើក្តួតឈាម ដូចទៅចាំយាមទាងនឹងម្ចាស
ឯងុយងោកងឹកជាទុក្ខលំ ឲ្យតែអំពល់ឥតអំពើ ។ មាត់មានន្ទានាងវា
គុះ ងើចុះជ្រលជ្រកមកភ្លាក្តី ដល់ទៅដំណេកដេកមើ រវើរវាយនិ
យាយវែ ។

លុះដល់ថ្ងៃក្រោយជាបន្ទាប់ កុមារលំជាប់អួតគយរ ដោយចិត្ត

តម្រែតម្រែកសាខរ ទំនិះទៅលួងលាលោយទុយ ។ ភ្នាក់ងារនាងាំ
ខ្សែងលើច្រាំង ច្រូសាខស្អាតស្អាងនាងដើតនាយ ដល់ទ្វារទាងត្រៃ
ហៅតំឆ្ងាយ ថាមាសបងគាយបងមកហើយ ។ ខ្ញុំនបងជាប្តីស្រីស្រស់
ស្រាប់ បងស្តីចូរស្តាប់នាប់ឆ្លាសខ្លើយ កុំតែរវេរវាន់តង់តន្តើយ ធ្វើហាក់
រាហើយនៅសៀមស្ងាត់ ។ បើមិនស្រឡាញ់កំរាហ៊ី លែងតែប្អូនស្រី
ស្តីមួយមាត់ បងសោតជាតូចពន្យល់ក្រែងត្រូត្រែ យសសក្តិសម្បត្តិកំសម
គួរ ។ តាំងរូបតាំងនេមល្អមបេត៌ នាងយកជាប្តីយល់មិនដូរ កុំធ្វើ
ឫកឆ្មើងដំកើងតួ ឬនាងទៅមួរពីរឿងអ្វី ។ ខ្ញុំនបងល្អស្រេចជាច់លោភ
សមជាតស្តានាងប្អូនប្រុ ខ្ញុំនប្អូនល្អស្រេចជាច់លោភ៌ សមជាមហេ-
សីនៃរៀមរ៉ាស្ង ។ ប្អូនអើយប្អូនមាសមិត្រប្រសើរ កុំធ្វើដំណើរឡៃស្ងើរ
ស្ងាត់ យប់កាន់តែត្រៀវត្រែងត្រជាក់ រងាញ់ញាក់អស់អង្គច្រាណ ។
កុមារចរចាអស់ចំណេះ ធ្វើមុខស្រមែរដែរដើងក្រាន ព្រះនាងក៏ពុំធ្វើយ
សងឹសាន កល្បាណច្រូសង្ងំសង្ងិលក់ ។ កុមរឈឺចិត្តរឹតខ្នេញ
សំណាងអ្វីពេញជាតម្រក់ ថាភ្លើងសុះក្រោកទាំងឆ្ងាយឆ្ងក់ ពក្តក់ពក្តើរ
ចេញវៃ ។ លុះដល់ដំណាក់ជាដំណេក ច្រូសរដេកសន្ធឹកវិងសន្ធៃ
មមើមមាលតិតមមៃ រំពៃរំពឺងវិងទុក្ខា ។

ជួបចូលថ្ងៃជាតំរប់បី ដល់យប់រាត្រីត្រូវសៃញ ភ្នាក់ងារនាងាំជ
កុមារ មួយខៀតយាត្រាខ្សែងលើស្ថាន ។ ខែវត្តនាវ៉ាកដសៃដ្ឋ កុមារ

ពាសោចិត្តក្សត្រហាន កំហែងស្រែកហៅនាងកល្យាណ ថាហៃយើម៉ាន
សំឡាញ់ចង ។ អញ្ជើញចែរបើកព្រះសន្ទិយា ចេញមកម៉ែម្ចាកុំផ្សូវ
ផ្សង អ្នកចង្គាចរចាគ្នាបានម្តង ខ្លួនល្អងកុំស្លែងក្រែងចិត្តា ។ ក្មេរមែក
គួរកេស្ងាបារ ខ្លួលក្មេរថ្លែហើយស្តីថា ទើបត្រូវតម្រាប់ប្បាប់តម្រា
មិនដែលនារណាស្មើមម្រមឹង ។ ឫទ្ធជាកដបុត្រីក្សត្រប្រសើរ មិនគួរ
មកធ្វើមុខយ៉ាងហ្នឹង យ៉ាងនេះគួរឬមាសត្រលឹង ចូរនែរពឹងឲ្យត្រូវប្បាប់ ។
ធម្មតាកើតមកជាកូនស្រី បើគ្មានស្វាមីតាមសណ្តាប់ គេថាអប្រិយស្រី
ឥតសព្ទ ខុសទំនឹងតម្រាប្បាប់បុរាណ ។ មិនគួរកំណាញ់ពាក្យមួយម៉ាត
សន្ធឹសម្ងាត់មិនសងឥសាន មួយម៉ាត់តើកាត់ថ្លៃប៉ុន្មាន រៀមរ័ក្ស្មហាក់ហាន
ជួយតាមថា ។ ឬក្រែងស្តីខោះជ្រុះមាសប្រាក់ ឬមួយក្រែងធ្លាក់ផ្កាចម្ប៉ា
ចូរប្រាប់ចំពោះសោះសង្កា ឬមិនវាចាតែនឹងចង ។ បើប្រុងឯទៀត
ទ្វៀតធ្លងស្តី អីចឹងដឹងប្តីស្រីខ្លួនល្អង ឬមួយតបូងឹលូងកន្ទួង ខ្លែមមិន
សាសងសំពាងី ។ ឲ្យបងខ្ញុំញាដូចសូត្រធម៌ ពាល់តែស្អកតញ៉ាវ
តិរ្ថិយ តាំងពីត្រាលប់ឃប់យាមពីរ គួរឬនាមិនមេត្តា ។

ព្រះនាងស្តែងស្តាប់ឮសំដីប្លាស់ ខ្លាល់ណាស់ស្ទើរទ្រឹងដេរផ្តាសា
ពាល់ព្រោះសច្ចំតាំងសច្ចា នឹងហើយមាត់ហាថាពុំបាន ។ តិតហើយ
ប្រាសផ្ទុសម្ងំលក់ ក្មេរមក្បាច្ចនិទ្ទេក្ខសុខសម្រាន្ត លង់លុះដឹតរះព្រះ
សុរ្យាន កុមារវិលថ្លានមកស្ថានស្ងាត ។ ថ្ងៃក្រោយឲ្យនាំបុត្រក្សត្រ

ឡើងវេទមន្តរោមជួមចិត្ត តាមដោយបំណងប៉ុនប៉ងស្ងួត ខាងរោគ
មិនស្បើតមែងចរចា ។ ឬត្រូវគ្រែរហូតរលាកកាយ សឹងតែអត់-
ប្រាយដោយប្រាថ្នា សត្វយប់ខាងត្រែមអង្គុយគ្រា តុំដួចប្រាថ្នាលោរលែ
ភ្នាង ។

កាលនោះព្រះបាទព្រហ្មទត្ត ជ្រាបអត្ថជាបត្រស្បែត្រប៉ុន្មាន ស្រដី
លួងលោមមានឥតល្បាណ ខាងតែតាំងបានត្រេយភោគធន ។ ព្រះតូប
ព្រះរាយក្នុងគេមបាស្បែ តើបត្រាស់ប្រាប់ដល់មាន្តិធរ ថាអញតែងលួ
ងួលតែក្នុង ឥតានិទ្ទនល្ហដ៏ពជប្បុត្រ ។ កូនស្តេចតាំងនោះខាងក្នុងចិត្ត
តាមតិតមិនត្រូវមិនតប្បី មិនមែនជាតូចទេដឹងអ្នក ឬនជាកូនស្រីមិនស្តីថា ។
ម្នាលត្រួមន្តីរក្តុតាស ចូរចេញប្រតាសតាសញ្ញា ស៊ុំញែតាមឈ្មោះ
បិតរបស់ត្រា ប្រាប់សៅតាមាត្យមន្ត្រី ។ បើមានកូនប្រុសតំណែរស្អាត
មែនមានមារយាទឆ្លាតសេចក្តី ប្រកបមួយដៃចូកពស៌ ចែងចេះសំដីរៃ
អង្គប្បាយ ។ ឲ្យមានប្រាជ្ញាថ់សម្រាប់ខ្លួន ឲ្យសមស័ក្តិសួនឱដ៏អង្គកាយ
នាំមកបរបាអង្គប្បាយ ត្រែចាងនោមនាយត្រូវចិត្តា ។ បើនារត្នស្តុត្រ
ស្មោះមេរ នឹយាយតបតន់ដ៏អ្នកណា អ្នកនោះចំពោះមានឥសនា ឬាន
ដួចសញ្ញាថាខុកស្រាប់ ។ តែត្រូវសៅរកពួកប្រចាំ ឲ្យគេនាំទើបត្រូវ
ច្បាប់ អាមាត្យបន្តិចរំបង្គាប់ ត្រាបលាប្រញាប់ចេញប្រញាយ ។
មកដល់ពេធិក្តុមអាល័ក្ខ ថ្លែងប្រាប់ឲ្យតាត់តែនខ្លួលខ្លាយ អាល័ក្ខ

ទើបបោះត្រាចុតហ្មាយ ហើយតំបែតចាយសព្វទិសា ។

គ្រានោះអស់កូនមុខម៉ន្ត្រី ឃានដឹងសេចក្តីតាមសាច សឹងតែត្រេកអរឥតឧបមា តាក់តែងកាយាជាប្រញាប់ ។ ស្រាលជ្រើសរើសសឹងគ្រឿងយ៉ាងឯក ថ្លៃក ។ ដោយពណ៌ល្អចំណាប់ ខ្លះស្វែកខ្លួនខ្មៅអាវក្រចាប់ រ៉ែនពេជ្រប្រជាប់តាក់ម្រាមដៃ ។ ក្រវ៉ាត់ទិមខាត់ឈាយលួសមាស ជាំតូងពេជ្រតាសមានដំឡៃ សែ្មកដើងស្រោមដើងមុខខ្នើងខ្នែ តាត់សក់រ៉ៃស័យបៃបុឡឹងសុង ។ ខាឡៃតាសឹងមាសសុទ្ធតំងខ្សែសាមិសុីខ្សែជាជាន់ក្នុង តាក់មួកតៅសូត្រសំយុង មានតាំងជាតុងបម្រុងតាន់ ។ ខ្លះតែងកាយាយ៉ាងសុភាព សំពត់ទិមខាបច្នក់ដកចន្ទន៍ ជាយប៉ាក់ផ្កាភ្ញីមានជរខ្ចណ្ឌ មួកសត្វចាក់ព័ន្ធផ្កាដុំបី ។ តាក់អាវសាក្លាតស្អាតភ្នៅយង់ រលើបរលង់លេចរស្មី ក្រវ៉ាត់ផាហ៊ុីសន្ធនខ្ចី កន្ទុយចារចង្កឹមខ្ចូខ្លែងសែ្មកខោយ៉ាងចាក់ចិង តាត់សក់លុងក្បាំងតាក់រ៉ែនតា តាក់អាវបាបីនាខ្លីតា មាត់មិនសុីស្លាទុក្ខធ្មេញស ។ ខ្លះស្វែកសារុងស្រុងដល់តែង បង់តកខ្សែរងសូត្រសាច់ល្អ តាក់មួកតំលេចក្បាច់ភ្ញីវល្លិ មានកួងផ្កាញ៉ែរតាក់កងដៃ ។ តាត់សក់ហោតិលរលាយ៉ាងខ្លី លាបប្រេងតាណ៉ាអប់ម៉ាឡៃ តាក់សែ្មកដើងផ្ងាត់ក្រវ៉ាត់សែ្ម ឫកនោះវិស័យអ្នកលេងប្រាណអស់កូនយោធាសេនាមាត្យ តែងតួស្អាងស្អាតយ៉ាងកុំផាន មិនតិតក្រក្រាយដោយទឹកស្មាន បង់បានស្រីថ្លៃជាពន់តា ។ ប្រកួតគ្នាឯងតែងតែ

អគ្គ្រាណ បង់ភាតប៉ុន្មានគំមិនថា អ្នកខ្វះរៀនមន្តផ្សំវាសនា ខ្វះចាក់
តម្រាផ្សង់សំណាង ។ ខ្វះអ្នកជាអញ្ជើវេលានេះ បើតាមតម្រេះមើល
បែបយ៉ាង មានហោរាគេតាយទុកជាតាង ថាបានឡើងច្រាំង្គ្រាសាទ
ខ្ពស់ ។ ឥឡូវត្រូវទឹងស្តេចច្រើរក ឲ្យទៅលៃលកសួរតាគ្រោះ ទឹង
ព្រះធីតាជាតំមោះ មុខជាមានឈ្មោះមួងនេះហើយ ។ ខ្វះជាគ្មើន
ភក្តិម្នាក់ស្គាល់ភ្លា ឮពាក្យសន្ធឹងថាអ្នកអើយ ខ្ញុំរំតឹងអ្នកជាក់ជាត្រើយ
ចូរកុំភ្លេចឡើយណាអ្នកណា ។ អ្នកបានជាធំខ្ញុំស៊ីបុណ្យ ចូលទៅផ្គាប់ផ្គុន
ឆ្នើរជការ សូមបានច្រាក់ខែមានចេស្តា តាមដោយច្រាជ្ញាអាថ៌ភាព ។
អ្នកខ្វះនិយាយញ្ជក្តេងក្តាង ថាបើបានសាងតង់បានស៊ី សឹមយើងរាប់រក
អស់គ្នាគ្មី តាំងពីឲ្យត្រូវតាមថាថាង ។ លុះរៀបស្រេចស្រាប់តាប់ម្នី
ម្នា ទៅរកក្លាក់ជារជាចាងហ្វាង ឲ្យនាំគ្នារះទៅតាម្រាង្គ្រាសាទ
នៃនាងនាថមារ ។ ដល់ហើយថ្ងាថ្លែងចែងចរចា តាមតែច្រាជ្ញាអាថ
ភាព ថាដ្បិតសម្តេចព្រះភូមី ឲ្យយើងចរលើឡើងមកតាល់ ។ អញ្ជើញ
ព្រះនាងនាថពីសី មានព្រះសារទីយ៍កុំឲ្យាល់ កុំច្រើតែយកតិតគិតតិ
ដល់ យើងខ្ញុំសូមស្គាល់ព្រះភក្ត្រា ។ ចេះតែនិយាយតែម្នាក់ឯង ដូច
គេសាំដែងធម៌ទេសនា អស់ចិត្តអស់ចង់ផុតប្រយ៉ា មិនដូចចិត្តាយាត្រា
ភ្លាន ។

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

ពិធីបុណ្យកំសាន្តស្រុក

ស្រី-អ៊ូ រៀបរៀង

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ នៅពុទ្ធសាសនបណ្ឌិត្យ ដូចមានសេចក្តីតទៅនេះ ៖

តាមប្រពៃណីខ្មែរ តែងមានពិធីធ្វើបុណ្យកំសាន្តស្រុក នៅខែមាឃមួយដង នៅខែពិសាខមួយដង រៀងពស់ឆ្នាំ ។

ពិធីបុណ្យកំសាន្តស្រុកនៅខែមាឃ មានរបៀបដូចរៀបរាប់តទៅនេះ

នៅក្នុងរោមន្តដូវថ្ងៃ ១៥ កើតខែមាឃ រៀងពស់ឆ្នាំ ជារដូវហើយស្រូវអង្ករ អាចរៀសម្រាប់ត្បែនមួយ។ តែងដើរឃោសនា ប្រាប់អ្នកស្រុកដើរតែជាមួយគ្នា ឲ្យធ្វើរោងមួយយ៉ាងធំ នៅកណ្តាលស្រុក ដើម្បីរៀបចំធ្វើបុណ្យកំសាន្តស្រុកកូមិ ឲ្យបានសេចក្តីសុខសប្បាយគ្រប់គ្នា ។ គេធ្វើពន្លាក់នៅចំពោះមុខរោងធំ មានព្រះពុទ្ធរូបតែម្តង់ទ្វេដុំវិញ មានប្រាំមួយ ជាក់គ្រប់ជ្រុងពុទ្ធរូបតែ មានស្វាធម៌ដោតគ្រប់ជ្រុងពុទ្ធរូបតែ ជាយស៊ីធំមួយគូ ស្វាធម៌មួយគូ ទៀន ៥ ធូប ៥ លាជ ៥ ទឹកអប់មួយគូ ស្វាចារ បង្អែមចំអាប ក្រាលសំពត់សប្រវែង ២ ហត្ថ យកវណ្ណាប់តាំងអស់ទៅជាក់លើពន្លាក់ ៣ ថ្នាក់ ស្រុកខ្លះមានធ្វើពន្លាទេពតា ៨ ទិសផង ហើយពួនក្តុំឡាប់ ៩

នៅមុខពន្លស្រាប់ប្លូវទៅតា ហើយយកដើមចេកធ្វើជាអាសនៈ ២ ដាក់
ដាក់ខ្នែង ៥ គូប ៥ ជាយស័ ស្លាធម៌ ទឹកអប់ ជ័រ ផ្កាក្ងី សម្រាប់បូជា
ព្រះតុន្ទរូប ដល់ពេលល្ងាចមោង ៧ ទ័មន្តព្រះសង្ឃ ៤ អង្គ មក ចំរើន
ព្រះបរិត្ត គេរៀបឲ្យជាយក្រងតាលី នៅខាងត្បូងកេង ។

ឯរណ្តាប់ឲ្យជាយក្រងតាលីនោះគឺ គ្រួងវែងមួយវង់ ប្រៀងបទ
ជាយទុន មានតែមួយប្រវែងមួយហត្ថ ៤ ជ្រុង, បង្គែម ចំអាបដាក់ក្នុងពែ
ស្រូវអង្គរ គាត់ស្ងឹករណ្តៅឲ្យមួល។ ធ្វើជាជ្រក់ ៤ ជាន ដាក់លើអង្គរ បង្គែម
១ ជាស ចំអាប ២ ជាស ហិបស្លា តន្ទេល ខ្នើយ ហើយនាំគ្នាបួន
សួងអញ្ជើញស្តេចក្រងតាលីឲ្យមកយកក្រយាបូជា សូមពរឲ្យជានសេចក្តី
សុខសប្បាយ តំណអស់គ្នាតរៀងទៅ ។

ព្រឹកឡើងប្រជុំគ្នាធ្វើបង្ហិនពាប់ជាត្រ ទ័មន្តព្រះសង្ឃសូត្រធម៌ភហូ-
ទៅដាវធ្នង់ហើយស្រេច ។

ចប់ពិធីបុណ្យកំសាន្តស្រុកនៅខែមាឃ ។

ឯពិធីបុណ្យកំសាន្តស្រុកភូមិ នៅខែពិសាខនោះ មានរបៀបដូច-
រៀបរាប់តទៅនេះ ៖

ក្នុងតំបូរដូវ នៅថ្ងៃ១៥កើតខែពិសាខ រៀងពាល់ភ្នំ ជារដូវធ្លើម
ធ្វើស្រែ អាចារ្យសម្រាប់វត្តនីមួយ ។ តែងដើរយោសនាបប្លូលអ្នកស្រុក

ដើងវត្តជាមួយគ្នា ឲ្យប្រុងប្រៀបរៀបចំម្ហូបចំណី ទៅធ្វើបុណ្យឡើងអ្នកតា ដែលនៅក្នុងស្រុកភូមិរបស់ខ្លួននោះ សុំឲ្យអ្នកតាជួយចាំរឹងចំរើនឲ្យបានសេចក្តីសុខសប្បាយទាំងអស់គ្នា ទាំងក្មេងទាំងចាស់ ព្រមទាំងសត្វពាហនៈ ។

ឯរបៀបដែលត្រូវរៀបចំធ្វើបុណ្យឡើងអ្នកតានោះ មុនដំបូង គេទៅជួសជុល ជ្រោសសំអាតខ្ទមអ្នកតា ហើយរៀបចាយស៊ីធំមួយគូ ស្វាធមិធាងចេក៦ ខៀន ៥ ជួប ៥ ផ្លា ៥ ចំគមបំមួយគូ ហើយគ្រាលសំពត់ស ប្រវែង ២ ហត្ថ ជាត់ណ្តាប់ទាំងអស់ ក្នុងខ្ទមអ្នកតា ហើយមានធ្វើព្រះពេជវ័ត្តិព្ធតិទាងក្រៅខ្ទម មានស្វាធមិធាងចេក ៤ ប្រម ៤ ជាត់ចំណីបន្ថែម ចំអាបក្នងប្រមគ្រប់ប្រដាប់ទាំង៤ (បើអ្នកតានោះគ្មានខ្ទមទេ គេធ្វើពន ៣ ផ្ទាំក់ មានព្រះពេជវ័ត្តិព្ធតិទាងក្រៅដូចគ្នា) ហើយគេធ្វើពេនឬជាកំនៅប្រុបខ្ទមអ្នកតានោះ សម្រាប់ព្រះសង្ឃគង់ ទីធ្លាគេរៀវដែលមកប្រជុំ ។ ជល់ម៉ោង ៦ ល្ងាច គេទៅនិមន្តព្រះសង្ឃ ៤ អង្គ មកចំរើនព្រះបរិត្តព្រឹកឡើងជល់ម៉ោង ១០ ព្រះសង្ឃនិមន្តមកជល់ ទើបអាចារ្យទីឯអ្នកស្រុកជាច្រើនគ្នា រៀបរាប់ថ្វាយអ្នកតា រួចហើយបួងសួងសូមពរឲ្យអ្នកតានោះ ជួយទំនុកបំរុង ឲ្យមនុស្សក្មេង-ចាស់ទាំងអស់ ព្រមទាំងសត្វពាហនៈទីឯសត្វចិញ្ចឹមទាំងឡាយ បានសេចក្តីសុខសប្បាយ ហើយនិមន្ត

ព្រះសង្ឃសូត្រធម៌ជារន្ធរស្រេច ហើយគេធ្វើសង្ឃភមួយ ជាក់ថ្វាយ
សំឡ ស្រូវ អង្ករ លូ សណ្តែក ចាន ឆ្នាំង មានលុយកាក់ជាក់ក្នុង
សង្ឃភនោះផង រួចគេយកដើមចេកធ្វើជារូបមនុស្ស ខ្លះរូបសត្វពាហនៈ
សត្វចិញ្ចឹមគ្រប់មុខ នាំគ្នាសែនសង្ឃភចេញដូនៅក្រៅភូមិ ហើយបួង
សួងសុំឲ្យបានសេចក្តីសុខសប្បាយ ដល់មនុស្សសត្វគ្រប់គ្នា ។

ឯរបៀបធ្វើបុណ្យឡើងអ្នកតានេះ គ្មានរូបមនុស្សជាន់អារក្សដូនួស
អ្នកតានោះទេ គឺសំគាល់យកដុំថ្ម ដែលនៅកន្លែងមានោះជាប្រមាណ ។

ចប់តំណែបុណ្យកំសាន្តស្រុក តៅខែពិសាខត្រឹមប៉ុណ្ណេះ ។

ប្រពៃណីខ្មែរតាំបុរាណ សព្វស្រុកភូមិឋានផងនានា
ចង់បានក្តីសុខគាំងអស់គ្នា ធ្វើបុណ្យបូជាសូមសួស្តី ។
ប្រពៃណីនេះល្អថ្លៃថ្លា ស្របតាមសាសនាព្រះជិនស្រី
ដែលប្រដៅសត្វក្នុងលោកិយ ឲ្យខំឃ្លាតឃ្លីសាងសីលទាន ។
បុណ្យទានគាំងភួងដែលបានធ្វើ ចាត់ជាអំពើល្អដូចយាន
ដឹកនាំអ្នកធ្វើទៅឋានា ជាហានឥតមានខុសបៀតបៀន ។

សុភាសិតជាតិស្បែនជាតិលីបង់

(តមត)

លោក ភ័ឃ-ប៊ុត ដកស្រង់រៀបរៀង

១២២- កែកមើលឃើញចម្ការ តែដៃជាទូ ។

១២៣- តែអ្វីដែលអ្នកមិនចានគាន់ខ្លាប់នៅដៃ, តែនោះនាំឲ្យអស្ចារ្យជាងគេ ។

១២៤- បើជោគវាសនាជួយអ្នក, វានឹងយកគុណសម្បត្តិអ្នកជាច្រើនមកឲ្យអ្នក, បើជោគវាសនាមិនជួយអ្នក, វានឹងដកគុណសម្បត្តិរបស់អ្នកចេញ ។

១២៥- ព្រះអាទិទេពស្ថិតនៅជាមួយអ្នកខ្លាំងក្លាយ ដើម្បីនឹងឲ្យមេរៀនទៅអ្នកគាន់អំណាច ។

១២៦- ចូរអ្នកត្រាប់ទៅតាមមនុស្សសប្បាយ, អ្នកនឹងជួបប្រទះនូវសេចក្តីសប្បាយ ។

១២៧- គួរឲ្យអាណិតអាសូរមនុស្ស ដែលគោលការណ៍មួយម៉ាត់គ្មានអ្នកណាទីងស្តាប់ ។

១២៨- មានតែម្យ៉ាង ដែលមានសារាតំបាកជាងសេចក្តីស្លាប់នោះទៀត គឺសេចក្តីស្តាយនៃការដែលធ្វើខុសគ្នាឆ្ងាយ ។

១២៩- គ្មានអ្នកណាស្គាល់ដំណែវតុ ក្រៅតាមាស់តែនោះទេ ។

១៣០- អ្នកណាដែលធ្វើការរៀងតាមចំនើនចិត្តរបស់ខ្លួន នឹងដួបប្រទះនូវតែដែលខ្លួនស្អប់មិនខាន ។

១៣១- គេមិនអាចយកទឹកសន្សើម ទៅបំពេញស្រះដែលរីងទឹកបានទេ ។

១៣២- បុរសកើតខ្មួនឆ្នាំប្រពន្ធស្លាប់ ប្រហែលនឹងឈឺដែលយកកែងដៃប៉ះដញ្ជាំង ។

១៣៣- ស្ត្រីមិនមែនគ្រាន់តែជាក់ដៃលើពោះ ប្រសូតកូនទេ ។

១៣៤- គេអាចលាក់បំហ៊ាំងពោះធំបាន តែគេលាក់កូនទៅក្នុងពោះមិនបានទេ ។

១៣៥- កូនទៅតួច ខ្លួនាងប្រដៅវាថ្នុះ ដល់កូនវាធំ ខុសវាជាប្អូនទៅវិញ ។

១៣៦- មាតាំនៃជនរបួសនឹត្រាមិនលក់ទេ មាតានៃជនស្លាប់និត្រាលក់ស្រួល ។

១៣៧- គុណវិបត្តិនៃកូនក្មេង មកពីម៉ែតាមាតា ។

១៣៨- កូនអាក្រក់ នឹងធ្វើឲ្យគ្រួសារអាក្រក់ ។

១៣៩- បណ្តាកូនប្រុសស្រី ១០០ មានតែកូនប្រុសស្រីមួយទេដែលស្រឡាញ់មាតាក្មេក ។ បណ្តាមាតាក្មេក ១០០ មានតែមាតាក្មេកម្នាក់ទេ ដែលស្រឡាញ់កូនប្រុសស្រី ។

១៤០- សុរិយាឆៃវែកុម្ភៈ សម្រាប់កូនប្រុសារស្រី សុរិយាឆៃវែមីនា សម្រាប់កូនស្រី សុរិយាឆៃវែមេសា សម្រាប់ពេលចាស់ជរា ។

១៤១- ក្តៅឆ៍ឆ៍ឯស ស្តែតទៅជិតគ្នាមិនបាន ។

១៤២- អ្នកណាបោកគេ លើកមីប៊ី វិនាសខ្ទះវិញ ។

១៤៣- កុំលេងចំចាប់ទឹងកូនក្មេង បើវាក្តៅឯងឲ្យដួល វាទឹងចំមកឡុកឡឺយឲ្យឯង បើឯងធ្វើវាឲ្យដួល វាទឹងយំ ។

១៤៤- អ្នកបណ្តាយឲ្យគេចាលថ្នមួយលើខ្លួន អ្នកនោះនឹងត្រូវខ្ទួលថ្នមួយទៀតចំកញ្ចឹងក ។

១៤៥- តក់ៗ មានទឹកពេញពាង ។

១៤៦- ក្អួមជាក់ទឹកបានតែតាមចំណុះ ។

១៤៧- អ្នកដើរចង្កិចម្តងៗ ឆឹងទៅដល់ផាប់ បើអ្នកតក់ អ្នកនឹងដេកផ្ងូរមិនខាន ។

១៤៨- ដែកក្តៅឆឹងឆ្ងាំគ្នានេះប៉ុយ ។

១៤៩- អ្នកដែលដើរឈ្នះម្តងជំហាន ចេះតែឈ្នះហួតតាមផ្លូវដែលដើរទៅ ។

១៥០- តាលេតដើរតាមថ្នល់ល្អ គេមិនជំពប់ដើរឆ៍ទេ ។

១៥១- មិត្តភាពមិនមែនកេងបាន ក្តីគោលស៊ីឆ៍កនោះទេ ។

១៥២- អ្នកណាគ្មានភេអាវចាស់ ភោអាវថ្មីក៏គ្មានដែរ ។

១៥២- ចូរអ្នកកុំភ្លេច នូវសេចក្តីស្នេហាពីអតីតកាល សេចក្តីស្នេហាថ្មីមិនបានបិតនៅអស់កាលយូរទេ ។

១៥៣- អំពើពាល មនុស្សចាស់ គ្មានឧសថកែទេ ។

១៥៤- កន្ទែងឆ្កែតអាចដាក់បានមិត្ត ១.០០០នាក់ ។

១៥៥- បើអ្នកចង់រក្សាមិត្តភាពឲ្យបានជិតជៅអស់កាលយូរ ចូរអ្នកកុំខ្ចីប្រាក់ កុំឲ្យគេខ្ចីប្រាក់ ។

១៥៦- មិត្តដែលបំផ្លាញកោតខ្លាចអ្នក ខុសជាសត្រូវអ្នក ។

១៥៧- សូវចុះនេកខនឯង ប្រសើរជាងឲ្យស្មានសុគតៅអ្នកដទៃ។

១៥៨- ស្ត្រីបើខុសជាស្មៀតពាក់អាវរៀបវាំហមន្តីលការ ក៏កុំគាន់ខុកចិត្តថាជាតរំយោងឯងពិតប្រាកដ ។

១៥៩- ស្ត្រីនៅលីវបិតនៅមួយសតវត្សរ៍ ប្រសើរជាងនៅមេម៉ាយមួយថ្ងៃ ។

១៦០-អ្នកធ្ងុំខ្ចុយ មិនអាចជាំធុកចង្កាឯងបាន ។

១៦១-បញ្ចាមិត្ត ១ ពាន់ ស្តិតនៅទាន់ត្រៀ កុំឲ្យតែបញ្ចាមិត្តម្នាក់ស្តិតនៅកន្លែងគេហដ្ឋាន ។

១៦២-អ្នកណាមានសត្រូវតែម្នាក់ គ្មានពេលសម្រាកទេ ។

១៦៣-សត្រូវនៃជីតាអ្នក មិនដែលស្រឡាញ់អ្នកទេ សត្រូវមាតាបិតាអ្នក មានបំណងចង់ឲ្យតែអ្នកស្លាប់ ។

១៦៥- អ្នកណាដេរធ្មេចគាអ្នកដទៃ អ្នកនោះនឹងត្រូវគេដេរធ្មេចគាខ្លួនវិញណាមួយមិនខាន ។

១៦៦- កន្លះទឹងមិនដែលក្លាយទៅជាផ្លាជាមេរ៉ាទេ សត្រូវមិនដែលទៅជាមិត្តមានចិត្តស្មោះត្រង់ទេ ។

១៦៧- មនុស្សណាដែលឃ្លាតចេញឆ្ងាយពីអ្នកមួយថ្ងៃ ត្រូវអ្នកឃ្លាតចេញឆ្ងាយពីមនុស្សនោះមួយឆ្នាំ ។

១៦៨- គេឲ្យយើងចុះទៅដល់ពាក់កណ្តាលអណ្តូង គេកាត់ខ្សែពីលើ ។

១៦៩- កុំនឹងមិនដែលជួបប្រទះកុំឯទៀតទេ តែមនុស្សនឹងជួបប្រទះមនុស្សឯទៀត ក្នុងវិថីណាមួយមិនខាន ។

១៧០- មនុស្សខ្លាយពីនោក មានតម្លៃស្មើនឹងមនុស្សភ្លាំងម្នាក់ ។

១៧១- សាមគ្គីធ្វើឲ្យឈ្នះគាំងអស់ ។

* ១៧២- បើគេទះអ្នកមួយដៃ ត្រូវអ្នកទះគេវិញពីរដៃ ។

១៧៣- មនុស្សណាមើលអ្នកតែក្នុកមួយ ចូរអ្នកមើលមនុស្សនោះនឹងក្នុកពាក់ពីរ ។

១៧៤- បើអ្នកមិនបង់គោទៅឆ្ការ ត្រូវតែអ្នកគោរពម្ចាស់ឆ្ការទានមិនបាន ។

๑๗๕-ចូរអ្នកចរិកោតទ្វារកោដនាហារ ដែលអ្នកពេញចិត្ត តែចូរអ្នកស្វែកតាកឲ្យសមរម្យដូចអ្នកជាខ្មែ ។

๑๗๖-អ្នកសន្សំទ្រព្យ ប្រសើរជាងអ្នកកេទ្រព្យ ។

๑๗๗-សើចឥតហេតុ មកពីខ្លះការអប់រំ ។

๑๗๘-ចូរអ្នកសិក្សាទ្វារការអប់រំល្អ ជាមនុស្សគោរពកាច ។

๑๗๙-ទឹកមិនដែលហូរទៅតាន់អ្នកស្រែកទេ ។

๑๘๐-អ្នកដែលគ្មានគេអញ្ជើញ កុំមកដែរ ត្រូវតែអង្គុយស្រែកនេះ ។

๑๘๑-ចិត្តសប្បុរសគ្មានគោគទ្រព្យសម្ងាប់អ្នកសប្បុរសទេ មានទ្រព្យតែឥតមានចិត្តសប្បុរសប្រៀបដូចខាវជូន ។

๑๘๒-មិនដែលមានពួកស្នេមយាចក ស្រឡាញ់ពួកស្នេមយាចកទេ។

๑๘๓ ការមិនឲ្យទាន ប្រសើរជាងការធ្វើចាំទទួលទាន ។

๑๘๔-ចរិកោតហ៊ោយសរសើរ ប្រសើរជាងចរិកោតរួចទៅស្រែម។

๑๘๕-អ្នកធ្វើសេចក្តីល្អនឹងពួកអកតញ្ញូ ដូចគ្នានឹងអ្នកអុជទៀនបូជាអ្នកតា ។

๑๘๖-កាលណាដៃអ្នកលែងចាប់អាហារ យកមកជាក់មាត់ឆាន ដៃនោះឈ្មោះថា លែងស្តាប់បង្គាប់អ្នក ។

(នៅមានត)

កណ្ឌទី ៣៤

ឧកញ៉ាវិបុលវាឯសេនា ស្វ-កាន ប្រែរៀបរៀង

(តមក)

លុះចូលឆ្នាំនៅរៃមាយភាគខ្វិត ស៊ុនគួនក៏ដួចជុំប្រឹក្សាទីធីដ៏យើ , ខៀវដៀខ្លូវអស់នាយ ឥហានទាំងពួងថា យើងមិនលើកកងទ័ពទៅវាយ ហាច្បងទៅហ្វាយស្រុកគាំងហែម្ខនខ្លៅ ជាទីសឹកគ្នានឹងហាច្បង ដែលបានតគាំងប្លាំងនឹងស៊ុនតៀង ជាបិតាយើងរហូតមក ខណៈនោះ ព្រឹក្សាគាំងអស់ក៏យល់ម៉ិនព្រមត្រៀងគ្នា ខ្លះលើបងដែលទៅនៅឈរកក្អូតយ ប៉ាកណាំឡងដ៏រមកត្រាប់ស៊ុនគួនថា ឥឡូវ គាំឡងឥហានហាច្បងមក សុំចំណុះចុះចូលនៅធ្វើពជការជាមួយនឹងលោក ខ្ញុំបានឃុនេះស៊ើបដឹងច្បាស់ថា គាំឡងនេះនៅជាយខ្នង់ដំបន់លិមគាំង ព័ះដ៏មនោះគាំឡង

តប់ពួកគ្រឿនធ្វើចោរកម្ម ដើរពាតត្បាតធាត់ដណ្តើមប្លន់ ជាយយកទំនិញរបស់
ទ្រព្យអ្នកដំនួញកណ្តាលទន្លេ ឯពួកចោរគាំងនោះ ក៏យកពួនធ្នឹកណ្តើរ
ភាយចង់ក្លាប់ធំនិងខ្លួនរៀងគ្នា ហើយគាំទ្បើង ឲ្យយកព្រៃតាំងជាប់លាយ
ទៀមាស ដែលជាយជាន់ក្នុងទូកទំនិញស្រុកសែឈួនមកធ្វើជាស្ទាបក្តោង
ឯពួនឈ្នួលជង្គ្បៅ ឃើញទូកសំពាន់ដូច្នោះ ក៏គាត់ខ្លាចមិនអាចនឹងតស៊ូ
លុះយូរមក គាំទ្បើងក៏លះបង់សេចក្តីខ្ជិលតែងចេញ ទើបនាំពួកគ្រឿន
ទៅទាំងឹងទ្បើងប៉ៃវ៉ៃជាច្រើនខែ គាំទ្បើងឃើញថា ទ្បើងប៉ៃវ៉ៃជាមនុស្ស
មិនចេះគិតការអ្វីឲ្យត្រូវចិត្តសោះ ក៏តែងោះខ្លួនឆ្លងឈូងសមុទ្រចំណងមក
នៅនឹងលោក ទទួលជួបនឹងហង៊ិចកណ្តាលផ្លូវ ហង៊ិចក៏និយាយសួរនឹង
សួរសុខលោមយកគាំទ្បើងទៅនៅផង កាលគ្រាលោកលើកទ័ពទូកទៅច្បាំង
នឹងហង៊ិចនោះ ប៉ែហង៊ិចមិនមានគាំទ្បើងទៅទុកជាកំឡាំងទេ ហង៊ិចនឹង
បាត់ជ័យទ្បើងដ៏វិតគាលណោះទៅហើយ គ្រានេះ ហង៊ិចក៏មិនជាន់ឲ្យ
បំណាច់ផ្ងាន់ដល់គាំទ្បើង តាមគុណានុភាពដែលទ្បើងហត់ ថែមទាំង
សង្កត់សង្កិនលើកគោសនិន្នាថាជាចោរ ទើបគាំទ្បើងខ្ចាស់អៀនតូចចិត្ត
គិតតែងោះខ្លួនចេញពីហង៊ិច មកចូលនៅនឹងលោក ។

ឯសោហ៊ុយ ដែលជាគាហានហង៊ិច ឃើញគាំទ្បើងតូចចិត្តមិន
សប្បាយដូច្នោះ ក៏ចូលទៅនិយាយនឹងហង៊ិចថា សូមឲ្យលោកយកចិត្ត

គាំឡេង ពុតឲ្យទៅធ្វើការជានាយពាហាន ក្នុងស្រុកអៀនតួន ដែលឡើងចំណុះស្រុកគាំឆហែ តទៅហាងចកព្រម ។ សោហ៊ុយក៏ហៅគាំឡេងទៅស៊ុំសៀង ហើយប្រាប់ថា យើងជួយនិយាយស្នើសេចក្តីតាប់ប្រសើរឲ្យអ្នក ឥឡូវ ហាងចឲ្យអ្នកទៅធ្វើជានាយពាហាននៅស្រុកអៀនតួនដូចខ្លួនអ្នកគំជាជាតិពាហានស្រាប់ ចូរពិគ្រោះមើលឲ្យជាក់ក្នុងចិត្តចុះ មិនមែនជាថ្ងៃនេះ នឹងទៅរើចាំក៏ទេ លុះនឹងស្នៀមទៅអ្នកគំគាន់តែចាស់ជាគ្រប់ថ្ងៃ ដែលអ្នកនឹងទៅធ្វើជានាយពាហាននោះ ចូរប្រគិតតាំងខ្លួនឲ្យបានខ្ជាប់ចុះ ។

គាលគាំឡេងទៅនៅស្រុកអៀនតួន គឺបានកល់ការខឹបបួលមកប្រាប្តាខ្លួនទៅធ្វើការជាមួយនឹងលោក ឥឡូវ គាំឡេងតបមកហើយ តែត្រេកឆ្ងល់ថា លោកមានចិត្តព្យាបាទ គាលគ្រាលោកលើកទំពាទៅចាប់ហាងចកនោះ គាំឡេង គឺជួយការពារយកក្តីប្តាញ់ឡើងធោ ដល់ខ្លួនសេចក្តីស្លាប់ គាំឡេងគឺនាំហាងចកគេចពីកងចិណោមទំពារស្រាប់ ឥឡូវ ខ្ញុំបានប្រាប់គាំឡេងថាឯចិត្តលោកនោះគ្មានសេចក្តីព្យាបាទទេ ប្រការមួយទៀត ការដែលធ្វើសឹកសង្គ្រាមកងចំណោមទ័ពពាំងអស់គ្នា រមែងនឹងជួយការពារយកអាសាទាយទៅហ្មាយ ដើម្បីនឹងយកជ័យជំនះ សេចក្តីពាំងអម្បាលណោះ ខ្ញុំបានតំឡានខ្លួលពាក្យនឹងគាំឡេងមកហើយ សូមឲ្យលោកមានសេចក្តីករុណាឈ្លងយល់មកខ្ញុំបានចុះ កុំឲ្យបង់ពាក្យសំដី ។ ស៊ុនតួនបាន

នេះ យើងធ្វើត្រឹមថ្នាក់ណាជាន់ណា គឺបានត្រឹមថ្នាក់ខ្ពស់ជាន់ខាងដែរ តែថា សេចក្តីសុខចំពូកខ្លះ ឲ្យផលបានត្រឹមមួយគ្រា ។ មិនបីតវេរថាវិនាសឡើយ សេចក្តីសុខចំពូកខ្លះ បរិសុទ្ធស្អាត តាំរនៅអស់កាលដ៏យូរ មិនត្រឡប់តែតសេចក្តីត្រូវក្រហាយវិញ ។ សម្តេចព្រះពុទ្ធអង្គទ្រង់សំដែងថា សេចក្តីសុខណា មិនបរិសុទ្ធ តែងត្រឡប់បានទុក្ខវិញ សេចក្តីសុខនោះហៅថា សាមិសសុខ គឺសុខនៅប្រឡូកដោយគាមិសគ្រឿងជំនួបចិត្ត ។ សេចក្តីសុខឯណាដែលបរិសុទ្ធស្អាត មិនត្រឡប់បានទុក្ខវិញ សេចក្តីសុខនោះឯង ហៅថា និរាមិសសុខ ជាសុខប្រាសចាកគាមិសគ្រឿងជំនួបចិត្ត ដូចព្រះពុទ្ធាសិត ដែលបានមិញនុ្តកថាដើមថា ទ្វេមានិ ភិក្ខវេ សុខានិ ដូច្នេះជាដើម សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខមាន ២ ប្រការ តើប្រការនោះដូចម្តេច ? គឺសាមិសសុខ ១ និរាមិសសុខ ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខមាន ២ ប្រការដូច្នេះឯង ។

ពាក្យថា សុខ នេះ ជាមជ្ឈគតការដែលសប្បាយកាយ សប្បាយចិត្ត កើតឡើងព្រោះការស្រឡះចាកបាបកម្ម ដែលសម្ភុះសម្ភល ដូចកវិកាយជាទីតាំងសេចក្តីត្រូវក្រហាយ ឬជាទីតាំងនៃសេចក្តីត្រជាក់ដែលសុខដុន ឬភាពនៃកាយស្រែកឃ្លាន កើតសេចក្តីកេលពលរសាប់រសល់ ឬបានរំពោគគាំងនៃខ្លួនស្ពប់ស្ពល់ ក៏ជាសុខ

ជានមួយគ្រាមួយស្របក់ ឬក៏សេចក្តីល្មោភក្រាធរង្វើង មើតឡើង ធ្វើ
ចិត្តឲ្យក្តៅអន្ទះអន្ទែង កាលបើជានរម្ងាប់សេចក្តីល្មោភ-ក្រាធ-រង្វើងជាន
ហើយ ក៏ជាសុខដូច្នេះជាដើម តែសេចក្តីសុខត្រឹមថ្នាក់ណាជាន់ណា ក៏
ស្រេចហើយតែហេតុដែលខ្លួនជានបំពេញ ។ ម៉ើហេតុនោះ ជាចំណែក
រូប-ភ្ញែន-វេរ៉ៈ-ផៅដ្ឋុះ-ធម្មារម្មណ៍ក្តី ឬ សុខដែលកើតអំពីលាភ-យស-
សរសើរ កើតអំពីការងារដែលធ្វើដោយចំណង ប្រយោជន៍ដ៏គាប់ចិត្ត
ដូចប្រុាថ្នាផងចំណេញហើយបរិភោគនានរក្សាសិល ជាដើមក្តី តាំង
អម្បាលនេះជាសាមិសសុខ គឺ សេចក្តីសុខដែលអែបអរស្រើយអាមិសត្រឹង
ជន្ធចិត្ត ។ អ្នកដែលជានសាមិសសុខនោះ លោកប្រដៅឲ្យដឹងថា
ប្រហែលគ្នានឹងអេះរមាស់ ជានស្រួលក្នង់ វាលាអេះមួយគ្រាមួយខណៈ
ប៉ុណ្ណោះ ក្រៅពីនោះ លោកឲ្យពិចារណាប្រៀបធៀបនឹងអ្នកឆ័តទឹកស្រែវិល
ស័ងធ្វើឲ្យជាប់ចិត្ត ហើយសម្បាយក្នង់វេលានោះ តែតមក ខ្ញុំឆ័តឡើងជាខេស ឬ ប្រៀបដូចត្រីដែលឃើញខ្ទុយត្រង់ចុងសន្ធូច ក៏ត្រចាក់
យក ហើយនឹងគោនស្ទាប់ខ្លួន ដោយខ្ទុយនោះ ។ សេចក្តីសុខ ដែល
ជាហេតុឲ្យប្រខូសភ័យដល់ខ្លួន . មានការពុះពារតស៊ូក្រហាយចិត្តជាខាង
ក្រោយ ដូច្នេះ ហៅថា សាមិសសុខ គឺសុខដែលជាហេតុឲ្យពេញ
ចិត្ត តែខាងក្រោមកមានទុក្ខជាផល ។ ដូចមនុស្សប្រកបរកាគរបស់ដែល

ស្ងួនធឺងពេត បានសេចក្តីតាប់ចិត្តក្នុងពេលដែលបរិភោគ តែពេលត្រឡប់ជារឿងឡើងវិញដូច្នោះ ។

សេចក្តីសុខ ដែលតែបអាស្រ័យអាមិសជាគ្រឿងជំនួ ធ្វើឲ្យសត្វតាប់ចិត្តដូចនេះ ក្នុងអំណាចត្រឹមតែមានបញ្ញា ឧត្តមាបគេបង្កើនដម្លោះខ្លួនឲ្យបូតផុតចេញទៅបាន ព្រោះសេចក្តីសុខបែបនេះ ជាសេចក្តីសុខដែលក្លើឡតែតែត្តិត្តិត្តិ ពុំគួរនឹងក្នុងអំណាចនៃតំណែសតែម្យ៉ាង ។ ដូច្នេះ ក្នុងធម្មវិន័យព្រះពុទ្ធសាសនា លោកទើបប្រដៅឲ្យតិចណាឲ្យឃើញច្បាស់ថា សេចក្តីសុខក្នុងជាន់នេះមិនខ្លឹង មិនមាំមួនថាវិនាសប៉ុន្មានគ្រាន់តែអាស្រ័យមួយគ្រាមួយខណៈប៉ុណ្ណោះ ដូចមនុស្សដែលទៅកន្លែមហាសមុទ្រ គោនឹងអាស្រ័យសំពៅ លុះដល់គំនរឹងជាទីប្រាថ្នាបង់ចុះហើយ ក៏ឡើងទៅសាន់ព្រាំដី មិនអាចក្លែងអាល័យសំពៅនោះទៀត ។ បុគ្គលដែលមានបញ្ញាឃើញដែលពោគន្លឹះលាភ គោនឹងអាស្រ័យសេចក្តីសុខដែលជាចំណែកលោកត្រង់ឃាំងត្រង់ប្រគាប តែត្រូវមានបញ្ញាចេះពិចារណាឲ្យឃើញតាមការពិតថា ខ្លះគ្រាន់តែជាសាមិសសុខ ជាសុខអាស្រ័យមួយពេលមួយគ្រាប៉ុណ្ណោះ ធឺងជាសុខមានឧបាទានកើតឡើងហើយត្រូវរលត់ទៅវិញជាធម្មតា មិនបីតជាថាវិនាសទាំងមានសេចក្តីទុក្ខជាផល ។

ហេតុនេះ ពុទ្ធបរិស័ទទាំងឡាយ គប្បីជ្រាបដូច្នោះហើយ គួរស្ងួន

រកសេចក្តីសុខដែលប្រណីតល្អិតលើសឡើងទៅទៀត តាមសមត្ថភាព
ខ្លួន ទើសេចក្តីស្រាយមានបែបខ្លះ មិនគួរពេញចិត្តតែក្នុងសេចក្តីសុខ
ដែលនៅប្រឡាំដោយអាមិសគ្រឿងរឹតរួតចិត្ត ឲ្យជាប់នៅក្នុងអំណាចនៃ
កិលេសគ្រប់ពេលវេលាឡើយ គួរណាស់ហើយតែបំពេញនូវគុណជាតិ
ឲ្យជាកំលាំងខាងក្នុង ដើម្បីជាបច្ច័យឲ្យបានដួចប្រទះនឹងនូវអាមិសសុខ
ក្នុងកាលជាខ្លាំងបំផុត ។ ឯនូវអាមិសសុខខោះបានដល់សេចក្តីសុខ ដែល
ច្រាសចាកអាមិសគ្រឿងដន្ទដ្ឋចិត្ត ។ កំសេចក្តីសុខនេះទៀតសោត ទើង
តើតឡើងបាន កំព្រា អាស្រ័យហេតុនៃការប្រកប ។ ឯហេតុដែល
ឲ្យកើតនូវអាមិសសុខខោះ បានដល់វិវេកសេចក្តីស្ងប់ស្ងាត់ ៣ ប្រការគឺ
កាយវិវេកស្ងាត់កាយ បានដល់បុគ្គលដែលមានកាយស្ងប់ស្ងាត់ ត្រេកអរ
ក្នុងនេក្ខម្ម: លះបង់ចោលពួកគណៈ: ហើយប្រព្រឹត្តនៅតែម្នាក់ឯង ១
ចិត្តវិវេក ស្ងាត់ចិត្ត បានដល់បុគ្គលដែលមានចិត្តបរិសុទ្ធផូរផង់ លះ
បង់ចោលនូវកិលេស ដោយអំណាចសមាបត្តិ ៨ ជាអ្នកមានចិត្តថ្លា
ស្អាតជ្រះស្រឡះចាកគ្រឿងរាំងឆក ១, ឧបធិវិវេក បានដល់បុគ្គលដែល
មិនមានកិលេស មិនមានសង្ខារ គឺជាអ្នកបានធ្វើចិត្តឲ្យស្ងាត់ចាកកិលេស
ទាំងឡាយ ដោយប្រើបញ្ញាពិនិត្យ ពិចារណាឲ្យឃើញច្បាស់ ដឹង
ច្បាស់ក្នុងរឿងសង្ខារ ដកបាលតែចិត្តលែងចាប់ប្រកាន់មាំ ក្នុងសង្ខារ
ដោយអំណាចតណ្ហា-ទិដ្ឋាន ១ ។ សេចក្តីស្ងប់ស្ងាត់ទាំង៣ប្រការនេះ

សុទ្ធតែជាគ្រឿងបំពេញបំពួនបញ្ចេនឲ្យកើតសេចក្តីសុខដ៏ឧត្តមលើសលុបឡើងទៅទាំងអស់ ។ សេចក្តីសុខដែលកើតអំពីចិត្តវិវេក ទី៣បណ្តាវិវេកទាំង២ នេះ ចាត់ជានិរាមិសសុខ ជាសុខមិនប្រឡូកដោយអាមិសគ្រឿងជំពាក់ចិត្ត គឺជាសេចក្តីសុខថ្លាស្អាតបរិសុទ្ធ ទីឆ្នូនមិនប្រែប្រួល ។

និរាមិសសុខនេះឯង ជាសុខពិតប្រាកដ មិនមែនអាស្រ័យអាមិសគ្រឿងធ្វើចិត្តឲ្យរង្គើរង្គាន់ ជាប់ព័ន្ធកង្វល់កិលេស ជាសន្តិសុខ គឺសុខដែលកើតអំពីសេចក្តីស្ងប់ចិត្ត ដែលមានរៈ-មានអាការមាំភាំងជាសុខទាំង-ឡាយទាំងពួង សមដូចសុភាសិតថា: ឧត្តិ សន្តិបរំ សុខំ សេចក្តីសុខដទៃក្រៅពីសេចក្តីស្ងប់មិនមាន ។

ស្វាធ្យៅ បពិត្រសម្តេចទាំងឡាយ កាលបើបានជ្រាបសេចក្តីសុខទាំង២ប្រការ ព្រមទាំងហេតុបច្ច័យបច្ចស់លាស់ ដោយន័យដូច្នេះហើយ គួរព្យាយាមស្វែងរកសេចក្តីសុខទាំងពីរប្រការនោះ ឲ្យកើតមានឡើងក្នុងខ្លួន សូម្បីជាចំណែកសាមិសសុខ ក៏គួរស្វែងរកបំពេញឡើងទុកឲ្យបរិបូណ៌តែមិនត្រូវភ្លេចខ្លួនទេ ត្រូវមានបញ្ញាជាគ្រឿងពិចារណាឯង កុំបណ្តោយឲ្យចិត្តជាប់ជំពាក់ស្រេកឃឹងរង្គើន ត្រូវដឹងថា សាមិសសុខនេះមិនបិតថាវាវិវេកមាំមួនទេ ជាសុខដែលកើតឡើងមួយពេលមួយខណៈ តោងផ្លាស់ប្តូរប្រែប្រួលទៅវិញ តាមសភាវៈធម្មតា ដូចបុគ្គលដែលអេះអមាស់ជាដើម សុទ្ធតែមានសេចក្តីវិនាសប្រចាំនៅខាងមុខជានិច្ច ប្តូរដូចសេចក្តីសុខដែលកើត

អំពីមានទ្រព្យ ដែលជាទីប្រាថ្នារបស់ពុទ្ធជនគ្រប់គ្នា តែទ្រព្យនោះគឺពុំ
បានឲ្យកើតសេចក្តីសុខពិត ។ ទេ រៀបជាបានមកពីត្រកអរ តែគង់សេចក្តី
ទុក្ខនៅអមជានិច្ច ចាប់តាំងអំពីការប្រើប្រាស់ទុកជាគំថែរក្សាដើមទៅ ម្យ៉ាង
ប្រើខុសខន្ធនឹកវិនិតកើតជាទោស មានសេចក្តីតប់ប្រមល់ ក្តៅក្រហាយចិត្ត
ជាផល ។ ដូច្នេះ សាធុជនពុទ្ធបរិស័ទគំនិតល្អ គួរប្រញាប់ប្រញាល់យក
ប្រយោជន៍អំពីរបស់គំនិតអម្បាលនេះ ឲ្យសមតាមខ្នាត ដូចការខ្ញុំមេស
អ្នកជាទៃមកប្រើ ត្រូវប្រញាប់ប្រើឲ្យបានសំរេចប្រយោជន៍ សមតាមប្រាថ្នា
ហើយដូនត្រឡប់ទៅឲ្យគេវិញ ដោយមិនមានគាល់ឃ ។ ឬដូចជា
សត្វហង្ស ដែលចុះស៊ីចំណើកឯកក់ ឆ្អែតហើយក៏ហើរទៅ មិនធ្វើសេចក្តី
អាល័យជាប់នៅក្នុងទីនោះ; លំដាប់តមក គួរស្វែងរកនិពន្ធមិនសុខ ដែល
ជាសុខកើតអំពីការបដិបត្តិផ្លូវចិត្តខាងក្នុង ដោយបំពេញវិវេក គឺសេចក្តី
ស្ងាត់ឲ្យប្រការឲ្យបរិបូណ៌ លុះវិវេកគាំង ឲ្យប្រការកើតឡើងហើយ រមែង
ជាគ្រឿងកំចាត់ដុសហ៊ុសេចក្តីសៅហ្មងក្នុងចិត្ត ឲ្យអស់ទៅដោយ
អំណាចវិវេកនោះ ។ ដាំចិត្តដល់នូវសេចក្តីផូរផង់ សុខដែលជាផលក៏កើត
ឡើងជាកំពូលខាងក្នុង ឈ្មោះថា បានត្រេបធ្វើកន្ទួរវិសនៃនិពន្ធមិនសុខ
ជាសុខមិនប្រែប្រួល ពាក្យតថាគតនិយាយ សមដូចព្រះពុទ្ធភាសិតថា
ឯញ្ជ ឆំ បរមំ សុខំ "ព្រះនិញ្ជនជាសុខយ៉ាងក្រលែង" ដូច្នេះ

អត្ថាគាត សំដែងអំពីសុខថា ពណ៌នាអំពីសេចក្តីសុខ ២ ប្រការ គឺល្មមសមគួរដល់ពេលវេលាតែប៉ុណ្ណោះ ។

ដោយអំណាចនៃធម្មទាននេះ អត្ថាគាតសូមប្រមែប្រមុំសេចក្តីសិរីជាំធំគស់ថ្វាយចំពោះព្រះកុំណាដាមម្ចាស់ជីវិតជាំធំពីព្រះអង្គ ទើសម្តេចព្រះទេយ្យវាជ ព្រះបិតាឯតាជផ្សាតិ សូមព្រះអង្គស្តេតទៅកន្លែព្រះសិរីវាជសម្បត្តិ ជានប្រកបដោយបរមសុខសុភមង្គលសិរីសួស្តីគ្រប់ទីពាក្រាល កុំបីមានសឹកសត្រូវកៃយន្តពាយអ្វី មកបៀតបៀនត្រាះឡើជានឡើយ ហើយសូមព្រះអង្គទ្រង់ជានប្រកបដោយព្រះជន្មាយុយឺនយូរជាដរាយព្រះសិល្បៈ ដើម្បីទ្រង់ព្រះសណ្តែតកន្លែហាន:ជាព្រះអត្តមគ្គនុះទូសក់នៃប្រជាពលរដ្ឋតរៀនទៅ ។

ម្យាងទៀត សូមឱ្យភ្លុងបាំសំខាំងឡាយ ជានសម្រេចនូវឥដ្ឋមនុភាផលវិបុលសុខគ្រប់ប្រការ កុំបីឃ្លាតឡើយ ។

ទេនន្តយា នុភាវេន សតតលោកភ័សិនោ

ត្រៃ រិទ្ធី បវេច្ឆន្តុ សន្តិការញ្ច នាញ្ជា ។

ដោយអានុភាពនៃព្រះតន្ត្រីយ សូមឱ្យប្រជាពលរដ្ឋតាំងឡាយដែលអាស្រ័យទៅក្នុងលោកតាំងមូល ជានជល់នូវការលូតលាស់កែចំរើនទំនឹជានទូលំទូលាយ កុំបីហ្មាតក្លាយ ដោយបាតារៈដទៃឡើយ ។

× × ×

រឿងសត្វចាបនឹងដំរីស្ពៃ

លោក ប៊ូ-ប៊ូ រៀបរៀង

កាលពីព្រេងនាយ មានមេចាបមួយធ្វើសំបុកគ្រាបក្រែងកូនខ្ចីនៅដើងភ្នំមួយ ត្រង់ផ្លូវដំរីដើរកស៊ី ។ ថ្ងៃមួយ មានដំរីព្រៃមួយហ្វូង ដើរកស៊ីទៅដល់សំបុកមេចាប ។ ឃើញហ្វូងដំរីដើរត្រង់មកចំសំបុកខ្លួន តក់ស្លុតខ្លាំងណាស់ ក្រែងដំរីជាន់កូនស្លាប់ តែហើរយ៉ាងប្រញាប់ទៅគាំស្ងាបគោរពចំពោះមុខដំរីជាមេហ្វូងនិយាយអង្វរថា សូមលោកអាណិតមេត្តាកុំដើរជាន់កូនខ្ញុំ ព្រោះវានៅតូចណាស់មិនទាន់ដុះស្លាបហើរទៅណារួចទេ ។

ឯដំរីជាមេហ្វូងធ្វើឃើញថា អើ មិនអីទេ ! ឯងកុំតក់ស្លុតអី ចាំអញជួយការពារឲ្យកូនឯងបានរួចរស់ជីវិត ប្រាប់ហើយក៏ដើរទៅឈរត្រែនដើរព័ទ្ធសំបុកចាប ប្រាប់ដំរីឯទៀតជាបរិវារឲ្យនាំគ្នាចៀសសំបុកចាបហួសអស់ទៅ ។ កូនចាបក៏បានរួចពីសេចក្តីស្លាប់ ។ ដើមដំរីមេហ្វូងផ្តាំមេចាបថា នៅមានដំរីស្ពៃមួយទៀត ដើរមកខាងក្រោយតែម្នាក់ឯង អាស្ពៃនោះសាហាវណាស់ ហើរកុំមកជល់សំបុក ចូរឯងខំអង្វរគេ ឲ្យមែនទែន ក្រែងវាអាណិតអាសូរឯងខ្លះ ផ្លាស់រួចដើរហួសទៅ ។

មេចាបឃើញកូនខ្លួនរួចរស់ជីវិត ត្រេកអរណាស់ និយាយសរសើរចិត្តនឹងអរគុណដំរីមេហ្វូងយ៉ាងក្រៃលែង ។ មិនយូរប៉ុន្មាន ដំរីស្ពៃសាហាវនោះ ដើរមកជល់សំបុកមេចាប ។ ចួលទៅគាំស្ងាបគោរពអង្វរ

សុំដំរីតែកូនដូចលើកមុន ។ ដំរីស្តីស្រែកតំហកមេចាបថា "ម៉េចក៏ហាន ឯងមកធ្វើសំបុកពុកកូនត្រង់ទ្លុះអញដើរ អញជាន់សម្លាប់កូនហាងឯងឥឡូវ ហើយ មិនអាណិតទេ កុំថាតែខ្លួនដែលមួយពាប៉ុណ្ណោះ សូម្បីចាបពាន់ ម៉ឺនសែន ក៏អញជាន់ឈ្លីតែទឹងជើងធ្លុងមួយឲ្យល្អិតខ្លួចខ្ទីដែរ អញមិន ឆ្កប់ជាន់ទឹងជើងតាំងប្លុនទេ" ថាហើយសុះទៅជាន់ឈ្លីកូនចាបស្លាប់តូច ល្អិតល្អន្ថចាំងសំបុកទៀត រួចវាទោមជាក់ អណ្តែតឆ្ពើងឆ្ពែង ពាមកូនចាប ហូរទៅតាមទឹកទោមភ្នំ ជាអស្ចារ្យតណ្ហាយសប្បាយចិត្តដើរហ៊ុះទៅ ។

មេចាបឃើញដូច្នោះ គេចហើរទៅទំលើមែកឈើតែក្បែរនោះ យំសោក ក្តៅក្នុងក្តាឡាអាល័យស្តាយកូនខ្ចាំងពេកស់ ស្រែកដេរប្រទេចដំរីស្តីថា "នែអាពាលកំណាច! ពេលនេះ អាឯងសប្បាយចិត្តចុះ អាឯងអាងខ្លួន ថា អាងខ្លាំងក្លាមាំងាំងាងអញ អាធ្វើតាមអំពើពាលទៅចុះ មិនយូរប៉ុន្មានទេ តបើតែអាទឹងជើងកម្ចាំងអញជាចាបមិនខាន ។

មេចាបដេរប្រទេចដំរីរួច ហើរទៅរកតឹងតែកូតជាសម្លាញ់ និយាយ ប្រាប់ពីដំណើរដាច់សម្លាប់កូនឲ្យក្តៅស្តាប់ តាំងពីដើមដល់ចប់ ហើយអង្វរ ក្តែតឲ្យទៅចឹកបោរតែកដំរីស្តី ។ តែតអាណិតមេចាបណាស់ ទឹកភ្នែក ក្រហាយទឹងស្តីដំរីស្តីយ៉ាងខ្លាំង ទ្រើយថា "សម្លាញ់តូចអើយ ចាំខ្ញុំជួយឲ្យ បានដូចចិត្ត" ថាហើរទៅរកដំរីស្តី ឃើញវាកំពុងទៅទំលើក្បាលចឹក បោរតែកដំរីលាល់តែធ្លុះបែកប្រស្រីតាំងពីរហូរឈាមរហាម ហើយមេចាប

ទៅនិយាយពីដំរុយទៀត ។ រុយទទួលយកអាសាទៅពន្លឿជាក់ក្អែកដំរីកើតជាដង្កូវចុះមែនក្អែកឲ្យដំបៅតាល់តែខ្លាក់ទៅ ។ មេចាបទៅពឹងកង្កែបឲ្យជួយទៀត ។ កង្កែបទទួលជួយឡើងទៅស្រែកយំលើភ្នំកែ្សមាត់ជ្រោះជ្រៅ ។ ឯដំរីខ្លាក់ស្រែកទឹកណាស់ដើរសូរស្នែងរកទឹកផឹក ឮសូរកង្កែបយំ សំគាល់ថាជាត្រពាំងទឹក ក៏ដើរយ៉ាងលឿនដម្រន់ទៅដល់មាត់ជ្រោះអើលជើងមុខនឹងដុំថ្មរមៀលធ្លាក់ ក្នុងជ្រោះស្លាប់ត្រមោះទៅ ។

មេចាបឃើញដំរីស្លាប់ធ្លាក់ទៅក្នុងជ្រោះភ្នំស្លាប់ហើយ ទឹកត្រគងរណាសស្រែកផ្តាំផ្តាលដំរីថា "នែអាដំរីពាល កម្លាំងគាយ ប៉ើខ្លួនជាខ្លាំងយ៉ាងណា ក៏មិនអាចធ្វើការគ្រប់ចំពូក ឲ្យសម្រេចបានដែរ, កម្លាំងបញ្ញាទើបអាចសម្រេចកិច្ចការសព្វគ្រប់បាន សូម្បីក្អែងតូចក៏អាចបំលាយឲ្យក្បាលស្មើនឹងថ្លែផែនដីបានដែរ ,, ។ មេចាបថាចប់ហើយ ក៏ហើរចេញទៅ ។

និទានមេចាបសម្លាប់ដំរីស្តេចនេះ ដើម្បីបញ្ជាក់សេចក្តីឲ្យឃើញច្បាស់ថា ការសាមគ្គីរួបរួមគ្នា តែងធ្វើកិច្ចការដែលធំៗ ធ្ងន់ៗ ក្រៗ ឲ្យសម្រេចបានដូចជាមេចាប, ក្អែក, រុយ ទឹងកង្កែប តែបន្លួចរួបប៉ុណ្ណោះ រួមគ្នាជាកម្លាំងមួយ អាចសម្លាប់ដំរីសារបានដោយងាយ តាមកម្លាំងបញ្ញារបស់វា ។ អតីតនិទាននេះ ជារឿងខាងគតិលោក ។

ចំណែករឿងខាងគតិធម៌វិញ ក៏មានចែងទុកថា អ្នកជាញាតិសន្តានជាសឹកសត្រូវនៅក្នុងខ្លួនក្តី អ្នកធ្វើបុណ្យទានតាំងពីក្មួង មានកសាងឆ

វត្ត, វិហារ, គុដិ, សាលា ជាដើមក្តី តំណែងបានសម្រេចដោយសារកម្លាំងសាមគ្គីត្រមត្រៀងគ្នា ដូចមានសេចក្តីកំណត់ក្នុងវិហានីយសូត្រ នៃព្រះគម្ពីរអង្គុត្តរនិកាយសត្តកនិបាតថា :

សម័យតុទ្ធកាល វស្សការព្រាហ្មណ៍ជាមហាមាត្យនៃព្រះបាទអជាតសត្រូវក្រុងមគធ ចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ លើកតំណែងក្រុងក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ! ព្រះបាទអជាតសត្រូវមានព្រះរាជបំណងនឹងលើកតំណែងវជ្ជីក្សត្រដែនវជ្ជី ដោយនេះនៅឯតគ្នា ឲ្យខ្លួនខ្លីនៅក្នុងអំណាចរបស់ព្រះអង្គ ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍! ក្សត្រដែនវជ្ជីគេត្រមត្រៀងគ្នាប្រតិបត្តិតាមវិហានីយធម៌ ដោយមិនតាំងអ្នកប្រតិបត្តិតាមមិនឲ្យរីឯសសាបសូន្យ ឲ្យមានតែចម្រើនសុខចំរើនយ៉ាងលើសលុបណា គេទស្សាក់ប្រជុំប្រឹក្សាគ្នាតាំងតែដើមរៀងមក, គេស្រុះស្រួលសាមគ្គីជួយទ្រទ្រង់ការងារសាធារណប្រយោជន៍, គេគោរពតែក្រឹត្យវិស្សាចារ្យជម្លាតនៃព្រះបាទក្សត្រមុនៗ គេតាំងប្តូរបង្គាប់ប្រកាសរបស់គេយ៉ាងខ្ជិលច្រអូស, គេមិនហ៊ានធ្វើតាមអំពើចិត្តគេឡើយ; អាស្រ័យការប្រតិបត្តិតាមវិហានីយធម៌នេះហើយ ទើបបានដែនវជ្ជីមានសេចក្តីសុខចំរើនយ៉ាងក្រៃលែង មិនដែលមានសត្រូវណាគេប្រមាថតាមរាជសង្គ្រាមបានឡើយ គោរបីសត្រូវខាងក្រៅមានឥទ្ធិពលខ្លាំងក្លាយ៉ាងណាក៏ដោយ" ។

វិស្សុតាព្រាហ្មណ៍ស្តាប់ព្រះពុទ្ធដីកាចប់ហើយ មានចិត្តត្រេកអរណាស់ ក្រាបថ្វាយបង្គំលាព្រះទសពល ត្រឡប់ទៅក្រាបទូលព្រះបាទអជាតសត្រូវ សូមទ្រង់ជ្រាបអំពីអបរិហានីយធម៌ ទេសក្សត្រដែនវជ្ជីត្រប់ប្រការ ។

តាមនិយាយព្រះពុទ្ធដីកា ដែលទ្រង់ទេសនាអំពីអបរិហានីយធម៌នោះ បើយើងសង្កេតមើលស្ថានការក្នុងប្រទេសកម្ពុជា នាសម័យបច្ចុប្បន្ននេះ ឃើញថា សម្តេចព្រះបិតាឯករាជ្យជាតិ ជាព្រះអគ្គមគ្គុទ្ទេសក៍នៃប្រទេសកម្ពុជា ដែលទ្រង់ដឹកនាំប្រជាពលរដ្ឋឱ្យរួបរួមគ្នា ជាមហាសង្គមមួយក្នុងសង្គមជាតិ, ឱ្យពួតដៃគ្នាជួយធ្វើកិច្ចការ ជាសាធារណប្រយោជន៍ដល់ប្រទេសជាតិមាតុភូមិប្រើនប្រការ មានទ្រង់ដឹកនាំឱ្យប្រមូលគ្នាជួយលើកថ្ម, លើកខ្នងប៉ាត, ជីកស្រះ, ជីកអណ្តូងជាដើមនោះ ត្រូវតាមគន្លងអបរិហានីយធម៌នោះ ពិតប្រាកដ ។

អាស្រ័យព្រះទត្តមគតិនៃសម្តេចព្រះបិតាឯករាជ្យជាតិយ៉ាងនេះ ហើយបានជាពលរដ្ឋខ្មែរត្រប់ប្រភេទ ទាំងភាពជាន ទាំងស៊ីវិល វេញគ្នាជាសាមគ្គី ជាប់ស្និតណាស់ អាចធ្វើកិច្ចការអ្វីៗ គេះក្រៃពុំបានយ៉ាងណាក្តី ឱ្យបានសម្រេចទាំងអស់ ហើយថែមទាំងមានជ័យជម្នះឈ្នះមារសត្រូវត្រប់ទិសទីផងទៀត គេះបើសត្រូវណាប្រច្នាច្នៃនឹងបៀតបៀនប្រទេសខ្មែរ សត្រូវនោះគឺរលាយ ដូចអម្បិលត្រូវទឹក, ក្រមួនត្រូវថ្ងៃ ពុំមានឡើយ ។

x x x

សុរពជាតក

(តមក)

លោក ចិង-រិង បម្លងពីសាស្ត្រាស្នឹកវិត

ម៉ែ សង្ខំ សេចក្តីនេះពិតប្រាកដមែនឬ? ។ ឯចៅជាតិតមាណព ក្រាបបង្គំទូលថា បពិត្រមហាកដ! ចៅឃើញតាខ្ញុំព្រះបង្គំជាខ្ញុំទ្វីក្នែកបុរសនេះយកភៅ ខ្លួចព្រះបង្គំជាខ្ញុំនឹងសងវិញ តែសូមឲ្យព្រះអង្គប្រើបុរសនេះឆ្កៀលក្នែកម្ខាងដែលគង់នៅនេះ មកជាក់ចំពោះព្រះតក្កព្រះអង្គសិន ខ្លួចព្រះបង្គំជាខ្ញុំនឹងឆ្កៀលក្នែកខ្លួចព្រះបង្គំជាខ្ញុំ ២ សងវិញ ព្រោះចៅតាខ្លួចព្រះបង្គំជាខ្ញុំខ្ចីយកទៅវិញ ១ ទេ។ ព្រះពាជាទ្រង់ត្រាស់ថា កោ ចោ-ឧត្ត ហៃព្រាវស្តែងអ្នកចោទ! ក្នែកព្រះស្តែងម្ខាងដែលមាន មំសៈជ្រួតមានសាច់ខ្មៅក្តីគ្នត ចូរព្រះស្តែងរេឆ្កៀលឲ្យល្អ, ឯក្នែកដែលគង់នៅនោះ កំចូរព្រះស្តែងឆ្កៀលឲ្យស្អាតហើយយកចេញ ជៅតិតមាណតទឹងសងក្នែកភ្លាមឲ្យស្អាតដូចដើមវិញ ។ បុរសកន្ទៅដែលចោទ លុះឮព្រះបន្ទូលដូច្នោះហើតិតតិយតក្តៅ ក្រុតដង្កឹងទូលថា បពិត្រក្សត្រៃព្រះសើរអើយ! ខ្លួចព្រះបង្គំជាខ្ញុំពុំកាចឆ្កៀលក្នែកបានទេឡើយ ។ ទើបស្តេចត្រាស់ថា ឃើងឲ្យព្រះស្តែងឆ្កៀលក្នែក ព្រះស្តែងឆ្កៀលពុំបាន ចុះកាលព្រះស្តែងឆ្កៀលឲ្យទៅតិតខ្លួបណ្តើត ព្រះស្តែងកាចឆ្កៀលបានហ៊ឺ! ទើបបុរសនោះក្រាបបង្គំទូលថា៖ ហេតុតែខ្លួចព្រះបង្គំជាខ្ញុំល្ងង់ខ្លៅឥតប្រាជ្ញា ឥយាយពុំពិតៈឡើយ ។

ស្តេចស្តាប់ហើយទ្រង់ព្រះពិភាគនមហាមាមានព្រះបន្ទូលថា អរោ ធុដ្ឋ អន្ធ
ពាល ហៃព្រះស្តេចអន្ធភាលអញ្ជើញគ្នាណ៎ដូចតា ព្រះស្តេចជាអ្នកមានចិត្ត
ជាបគម្មក្រាសអំពីជាតិមុន ទើបកើតមកកំដាតិនេះមានភ្នែកខ្វាក់ ឥឡូវ
ព្រះស្តេច ធ្វើកម្មមានទម្ងន់យ៉ាងនេះទៀត តើព្រះស្តេចប្រថ្នាអ្វី ? ។ បុរស
នោះក្រាបបង្គំទូលថា ព្រោះតែខ្ញុំបានទ្រព្យគេណាព្រះអង្គ ។ ពេលស្តេច
ត្រាស់ពៅអាមាត្យតាំងឮយថា តោន្តោ ហៃអ្នកទាំងឮយដំចំរែន
បុរសនេះ វាខាងជាតិកមាណពជាអ្នកឥតទោស ៨ ទំ កុតោម្ចុំ ទោស
នេះ មានទម្ងន់ក្រៃលែង ចត្តុនាម បិយំ ភ្នែកជាទីស្រឡាញ់ពេញ
ចិត្តស្មើដំរីតែ ចូរអ្នកទាំងឮយតែងភ្នែកទាំងពីរលក់ជាថ្ងៃ ១ ពាន់ដំឡឹង
ហើយលក់បុរសនេះទុកគុណជាក្រយាពីទ័យហ្មង ១ ជា ២ រួចកត់ជក្រិត្យ
នេះទុក សត្រាប់ព្រះនរាតៅ ។ ព្រះមហាក្សត្រាធិរាជទ្រង់មានព្រះ
តម្រាស់ទៅដោតិកមាណតថា បុរសនេះមកពោលថា រីឯអ្នកប្រាជ្ញបិតា
ចៅឯងមកខ្ចីកូនជ្រូកស ១ យកទៅ តុំយកមកជូនគេឡើយ តើពិតមែនឬទេ ?
ដោតិកមាណពក្រាបបង្គំទូលថា បើបិតាខ្ញុំទូលព្រះបង្គំជាខ្ញុំខ្ចីកូនជ្រូកយកទៅ
សមបើ មានបន្ទាល់ខ្លះមែនទេឡើយ ។ បុរសនោះទូលថា ទូលព្រះបង្គំ
ជាខ្ញុំមានភរិយាជាបន្ទាល់ ។ ដោតិកមាណពទ្រង់ថាថា ប្រពន្ធជាបន្ទាល់
ប្តីក្តី ប្តីជាបន្ទាល់ប្រពន្ធក្តី តុំដែលមានពីបុរាណរៀងមក លោកតុំឲ្យយក
ជាបន្ទាល់ឡើយ ដ្បិតប្តីធំប្រពន្ធមានតំនិតតែមួយ ។ បុរសនោះ ស្តាប់

ហើយគាល់ក្រុងផ្ទៅស្រេច ។ ដោតិកមាណពត្រាបទូលបន្ទូលថា បពិត្រ
មហាពាជ! ដំណើរនេះ ទោះមានបន្ទាល់ក្តី គ្មានបន្ទាល់ក្តី មិនជាសំខាន់ទេ,
ប៉ុន្តែធម្មតាកូនស្ត្រីគ្រួ រមែងនឹងមានពាណិសម្បុរដូចមេបាវ សូមព្រះអង្គទ្រង់
ត្រាស់ដណ្តឹងបុរសនេះឲ្យស្ត្រីគ្រួគង ។ ទើបព្រះពោធិសត្វត្រាស់សួរទៅបុរសនោះ
ថា កូនស្ត្រីគ្រួស្តើងនោះ មេសឬ ឯាសេ ? ។ – បពិត្រព្រះជាម្ចាស់ថ្លៃប្រសើរ
អើយ! កូនស្ត្រីគ្រួនោះ ខ្ញុំសូមក្រាបទូលថា ខ្ញុំមិនមានឡើយ ។ – បើដូច្នោះ
ព្រះស្តេចនោះជាគ្រួសឬក៏ទេ ? ។ – ក្រាបទូល ។ ទើបស្តេចត្រាស់
ថា ម្នាលអ្នកតាំងឡាយ! បុរសនេះមិនមែនជាគ្រួទេ ខ្ញុំសូមជា គ្រួវិញ
ចង់បានស្ត្រីគ្រួតែ ទើបវាយកាន់ជាគ្រួសឬក៏ទេ, ម្នាលអ្នកតាំង
តាំងឡាយ! ត្រូវលក់បុរសនេះតាមតម្លៃកូនស្ត្រីគ្រួ ព្រោះធម្មតាកូនស្ត្រីគ្រួ
ស លោកខ្ញុំសូមថ្លៃ ដំរីភ្លៀងតាត់ថ្លៃមិនបាន ពុំដែលឲ្យតើតត្រូវទូល
ថាតាមឡើយ តែនឹងឲ្យតើតត្រូវទូលសូត្រាសដូចសូមឮ ចូរអ្នក
តាំងឡាយតាត់ជាថ្លៃ ទៃនឹងឡើង ហើយលក់ទូតុណ្ឌរួចហើយ ត្រូវតែត
ខ្ញុំជាពាជសូត្រាសម្រាប់ត្រួតតែ ។ ចាប់តាំងពីថ្ងៃដែលបុរសតាំង
៤ ទាក់ចាញ់មាណពទៅ ពុំមានអ្នកណាមកនោទប្តឹងសេចក្តីដូច្នេះទៀត
ឡើយ ។ រឯដោតិកៈ ណាតគឺជូតចំនិញបញ្ជាទៅជួញក្នុងស្រុកតហុលនគរនោះឯង ។

ឥតា បរេ ធសា ភាជាតោ កាលនោះ មានស្តេចបរទេសពាជាព្រះ

អង្គ សោយរាជ្យនៅនគរផ្សេងពីគ្នា, ថ្ងៃមួយ ចាន់ដំណឹងថា ព្រះរាជ
បុត្រីព្រះចៅពហុលនគរ ដ៏ទ្រង់ទូរ៉ូបនាមល្អប្រពៃ ដូចស្រីទេពអប្សរបវរ
កញ្ញា ក៏ត្រាំងឆ ៣ ព្រះអង្គចង់ចាន់ដូចគ្នាំ ទើបធ្វើជាប្រស្នាដោយព្រះ
ទំរង់កន ១ ព្រះអង្គបី ១ ប្រស្នា ឯកោ គឺស្លឹងព្រះទំរង់ ១ កើតនៅ
ទៀបឆ្នេរសមុទ្រ, ឯកោ ស្លឹងព្រះទំរង់ ១ កើតពីថ្ងៃមហាសមុទ្រ,
ឯកោ ស្លឹងព្រះទំរង់ ១ កើតនៅនាព្រៃព្រះហិមពាន្ត រីព្រះទំរង់ទីមួយ
គិតថ្លៃជាមាស ១ សែនដំឡឹង ១ ឯកោ ក៏ជា ឯស្តេចមួយព្រះ-
អង្គទៀត ធ្វើប្រស្នាដូចគ្នា តែថា ស្លឹងព្រះទំរង់ ១ កើតនៅក្នុងបុលបពិត
ស្លឹងព្រះទំរង់ ១ កើតនៅនាគពិភព, ស្លឹងព្រះទំរង់ ១ កើតនៅឆ្នូតព្រះធរ-
ណី, ស្លឹងព្រះទំរង់ទាំងបីនេះ មានតម្លៃ ១ សែនដំឡឹង ។ ឯកោ
ឯស្តេចមួយព្រះអង្គទៀត ធ្វើប្រស្នាដូចគ្នាគឺ ស្លឹងព្រះទំរង់ ១ កើតក្នុងកំ
ព្រះសុមេរ៍ ស្លឹងព្រះទំរង់ ១ កើតក្នុងកំសុវណ្ណគីរី, ស្លឹងព្រះទំរង់ ១ កើត
នៅកំទីរីនាឋបពិត; ព្រះទំរង់ទាំង ៣ នេះមានតម្លៃជាមាស ១ សែនដំឡឹង។
ស្តេចទាំង ៣ ព្រះអង្គនេះ កំដាត់ស្លឹងព្រះទំរង់កន ប្រគល់ឲ្យ ... ដោយ
ហើយតែងព្រះរាជសារមានសេចក្តីថា អម្ពោ ពហុលរាជ ! ម្នៃ
ព្រះបាទពហុលរាជដ៏ចំរើន ! ឥឡូវយើងឲ្យនាំប្រស្នាស្លឹងព្រះទំរង់ទាំង ៣
នេះ មកឲ្យស្តេចពិចារណាកំរេតើហ៊ានកំណើត បើស្តេចរកឃើញ យើង
នឹងបូជាសក្ការៈផ្សេង ។ បើស្តេចរកពុំឃើញ ត្រូវជូនព្រះរាជធីតាមកយើង

ចាំឆ័ ព្រះអង្គ ម៉ែសេចមិនព្រមដូនទេ ឃើងនឹងលើកវេហ៍ាសសកល
យោងាមតារាយព្រះនតះឲ្យខ្ញុចផាចុល ។ ព្រះពជសារចាំឆ័ ៣ ង
សេចក្តីដូច។ គ្នា រួចហើយព្រំរោងាទ្រង់ចាត់ពជខ្ញុតចាំឆ័ឲ្យនាំព្រះពជ
សារចូលទៅថ្វាយព្រះបាទពហុលពជ ។ ពជខ្ញុតចាំឆ័ឲ្យកចូលទៅឈរ
នៅខ្ញោឆ័ទ្វារ ហើយក្រាប់ឆ្នាំទ្វារឲ្យចូលទៅក្រាបខ្ញុលព្រះបាទពហុលពជ។
ស្តេចគ្រាបហើយ ទ្រង់ហៅពជខ្ញុតឲ្យចូលទៅ ។ ពួកពជខ្ញុតកចូលទៅ
ក្រាបថ្វាយបង្គំ ហើយអង្គុយកន្លែចាំដ៏សមគួរ ។ ព្រះចៅពហុលនគរ
ត្រាស់សួរថា តុតោ អាតតា ព្រះសែ្តឆ័ចាំឆ័បីអញ្ជើញមកពីនគរ
ណា ? ។ ពជខ្ញុតចាំឆ័ ៣ កំក្រាបខ្ញុលតាមដំណើរគ្រប់ខ្ញុន ។

តាស្មា. អាតតា អ្នកចាំឆ័ឲ្យមកមានហេតុដូចម្តេច ? ។ ពជខ្ញុត
ចាំឆ័ឲ្យកំក្រាបខ្ញុលតាមសេចក្តី រួចហើយថ្វាយព្រះពជសារត្រប់គ្នា ។
ស្តេចទតហើយត្រាស់ថា តតមំ តណោ ម្នាលត្រាស្តែឆ័ ឯព្រះពជ ហា
រឿនព្រះទំរាំនេះដូចម្តេច ? ។ ទើបពួកពជខ្ញុតថ្វាយប្រអប់ព្រះទំរាំត្រប់។
គ្នា ។ ព្រះពជាទ្រង់ចាត់ឲ្យសាំព្រះពជកេ ១ ជប់លៀងពួកពជខ្ញុតចាំឆ័
នោះស្រេចហើយ ទ្រង់ឲ្យហៅអស់ពួកមុខមន្ត្រីមកប្រជុំគ្នា ហើយត្រាស់
ថា តោណ្ណោ ម្នាលអ្នកវាំឆ័ឲ្យដ៏ចំរើន! អ្នកណាដឹងជាតិកំណើត
នៃកែវនេះដែរឬ ? ម៉ែដឹងច្រាសជ ឃើងនឹងបូជាគុណអ្នកនោះ ។ ពួក
គាត្យជំទុំគ្នាពិចារណា ហើយក្រាបខ្ញុលថា ន ជានាម ន ជានាម

យើងខ្ញុំតាំងខ្លួយតុំដឹង តុំស្គាល់ឡើយ ។ ស្តេចស្តាប់ហើយទ្រង់ព្រួយព្រះកដហឫទ័យ ត្រាស់ថៃ្ងអាមាត្យថាំវែងនែរកបុរសស្ត្រីណាមួយក្រែងដឹង ស្គាល់ លុះថ្ងាំវែងសព្វស្រុកគ្រាំលំនៅដះបន តែឥតមានអ្នកណាមួយដឹងឡើយ ។ ព្រះពន្ធាទ្រង់ព្រួយព្រះកដហឫទ័យក្រៃពេក ហើយត្រាស់ថា មយ្ហំ ឧកាំ រិណ សន្ថតិ ព្រះនគរអញនឹងវិនាសច្រាកដហោង ហើយចូលទៅដំទូកក្នុងប្រាសាទអស់ពីរ ៣ ថ្ងៃ លុះចូលថ្ងៃទី៤ ក៏គ្មានអ្នកណាមួយដឹងបាន ស្តេចទ្រង់ព្រះកន្សែនសោយសោកថា វិនាសហើយ។។ តទា បន ភគវតី សព្វញ្ញុតញាណេនាវជេង ព្រះកដធម៌តាឫង ទ្រង់ព្រះនាមជោតកទៅ មានច្រកភ្នំឈ្មោះវៃ លើសនាងតាំងអស់ លុះឃើញព្រះកដថ៌តាកើតទុក្ខដូច្នោះ ព្រះនាងទូលសួរថា ហេតុដូចម្តេច ក៏ព្រះបិតាទ្រង់ព្រះកន្សែនដល់ម្ល៉ះ ។ ព្រះមហាសត្វទ្រង់មានព្រះបន្ទូលប្រាប់ព្រះកដធម៌តាឫងរបស់ព្រះអង្គសព្វគ្រប់ប្រការ ។ ព្រះនាងក្រាបទូលព្រះបិតាថា សូមទ្រង់ព្រះមេត្តាប្រោស ចះជោតកមាណពកម្ល៉ះនោះ តើព្រះអង្គដណ្តឹងសួរហើយឬនៅ ? ។ ស្តេចស្តាប់ហើយឆ្លើយថា កន្ទេ ម្នាលនាងដ៏ចំរើន ! អស់នាហ្នឹងថាស់ខ្ញុំតតែមិនឃើញទៅហើយ ចំណង់បើចៅជោតកមាណពកម្ល៉ះទៀតក្តីនឹងចេះអ្វីឡើយ។ ព្រះនាងស្តាប់ហើយឆ្លើយថា ឥមេ ខត្តា ខុប្បញ្ញាជាតិកា ភុតោ្ត ជានិសន្ថន្តិ;ខុទាយវំ ជោតកមាណវំ នាម ឆាវិកំ

រួបបញ្ចូសមន្ទាតតំ បុច្ឆិសុ្ន ឥតិត្រៃព្រះបិតា! អស់ពួកនាហ្នឹង
មានអាយុវែងចាស់ទុំតិតមែន ធម្មា សឹងតែល្ងង់ខ្លៅឥតប្រាជ្ញអំពី
កំណើត ទើងដឹងដួចម្តេចបាន សូមព្រះអង្គត្រាស់សួរនាយសំពៅឈ្មោះ
ភោតិកមាណពអ្នកចេះទុកជាយដ៏ចំណាន ដែលប្រកបដោយប្រទីបញ្ញា
ចុះ ។ ស្តេចស្តាប់ហើយទ្រង់ព្រះចិន្តាថា ព្រោះពិចូរអ្នកប្រាជ្ញជាបិតា
ភោតិកមាណពនេះ បានសំដែងដោះសា សាតបធីតាបញ្ហា, ឥឡូ
យើងបានសុខសប្បាយម្ខងហើយ អយំ បន សុ្ន បុត្តោ ឯ៎ា
ភោតិកមាណពនេះជាកូនរបស់ព្រាហ្មណ៍ប្រាជ្ញប្រហែលជាចេះមុខវិជ្ជាស្ទាត់
ពុំខាន ទើបស្តេចបញ្ជូនព្រះពន្ធុនាថត្រាស់ឲ្យអាមាត្យទៅហៅ
ភោតិកមាណពឱ្យចូលមក ។ លុះភោតិកមាណពមកដល់ហើយ, ស្តេច
ត្រាស់សួរថា ណាវិកកៃមានាយសំពៅ! ឥទានិ តយោ កដ្ឋានោ
ឥទ្ធរនេះ មានបុព្វជាព្រះនេះ ឬទាំមុខវិជ្ជាឬ ទីប្រឹងកែព្រះទំនើងភាំ
ញមក បើដឹងហានកំណើតកែ ពាំរាល ផ្នែកនេះដាក់ ល្អ ប្រើមិ ដឹងតែទើង
លើកតាមមកវាយនឹងឲ្យខ្លួនឯង ដូច្នេះ ប៉ោចាំដឹងផាត់ចូរប៉ោចាំប្រាប់
យើងនាឥលូវនេះ ។ ជាណាមីតិ ទ្វេ្ធ ភោតិកមាណពក្រាប
ទូលថា ទូលព្រះបង្គំជាខ្ញុំស្គាល់ដាក់ប្រាកដ ប៉ុន្តែទូលព្រះបង្គំជាខ្ញុំបាន
រៀនសូត្រមក ។ ប៉ោចាំដឹង ចូរប៉ោចាំសំដែងមកហោង ។ ទើបភោតិក-
មាណពក្រាបទូលថា តោ ច មម សាត្តិ ទូលព្រះបង្គំជាខ្ញុំសំដែង

ឥឡូវនេះ ទឹងមានទេវាណាជាបន្ទាល់សាក្សីនៃទូលព្រះបង្គំជាខ្ញុំ តស្មា ព្រោះហេតុនោះ សូមព្រះអង្គប្រដាប់ពួកទេវតា, ផ្សឹងអស់ទេវតាសូមជួយជាបន្ទាល់សាក្សីនៃខ្ញុំ ។ ព្រះពុទ្ធជាម្ចាស់ត្រាស់បង្គាប់ ឲ្យប្រដាប់ត្រឿងពួកទេវតាទាំង ៨ ទិសថា គោន្តោ នេវសង្ឃាយោ បពិត្រអស់ពួកទេវតាដែលឋិតនៅក្នុងទិសទាំង ៨ សូមអញ្ជើញមកជាបន្ទាល់សាក្សីនៃខ្ញុំ ក្នុងខ្ញុំនឹងកប្រស្នាក្នុងកាលឥឡូវនេះ បើខុសសូមជួយដំរង់ បើគោលត្រូវត្រង់ សូមជួយឲ្យព្រះស័ព្ទសាធុការ ។ គោន្តោ បពិត្រទេវតាដ៏ចំរើន មួយរសោត ខ្ញុំសូមនមស្ការអោនឆ្ពាអញ្ជើញភុម្មទេវតា អាកាសទេវតា រុក្ខទេវតា វិមានទេវតា សូមស្តាប់ខ្ញុំ បើខ្ញុំធ្វើយត្រូវ សូមអ្នកសំដែងខ្ញុំឲ្យប្រាកដដល់អ្នកទាន់នេះ ។ លំដាប់នោះព្រះពុទ្ធជាម្ចាស់យកប្រអប់ព្រះធំដ៏មកុដតម្កល់នៅមុខដៅតិកមាណព ហើយត្រាស់ហៅពួកតាំង ៣ ទ្វារអស់មុខមន្ត្រីអាមាត្យពួកបុរោហិត ឲ្យមកអង្គុយជិតចាំស្តាប់លើប្រាសាទនោះ សោ ច ជោតិកមាណវោ ឯទេវតាដៅតិកមាណពនោះ កាលបើក្រឡេកមើលព្រះធំរង់ក្នុងប្រអប់នេះហើយ ក៏ស្គាល់ជាក់ ឯកំគណ្ឋិត្វា កំចាប់តែ ១ តិចិតមើលហើយទូលថា បពិត្រមហាភគវ! សម្មុទ្ទតីរេ ជាតំ តូរ្ណ ១នេះ កើតនៅច្រាំមហាសមុទ្រ, ឯំ សម្មុទ្ទមជ្ឈេ ជាតំ តូរ្ណ ១ នេះកើតនាកណ្តាលមហាសមុទ្រ,

៩ធំ ហាមវត្តបព្វតៃ តួង ១ នេះ តើតទៅវាគ្គុព្រះហឹមភាន្ត; តែវ
ទាំង ៣ នេះ មានតម្លៃជាមាស ៣ សែនដំឡឹង អចិច ប្រកាមួយ
ទៀត តែវដែលតើតទៅកណ្តាលផ្លែសម្បុរនោះ មានគុណប្រសើរ
លើសតែវទាំង ២ ។ ស្តេចជ្រាបហើយ ទ្រង់បើកប្រតម្រះទំរង់ ១ទៀត
ហុចទៅផ្ទាតកមាណពដោយពាក្យថា វិទាវេមិ ចូរអ្នកពិចារណាមើល
តួងនេះទៀត ។ សោ តំ បដិក្ខណ្តិត្វា ផ្ទាតកកមាណព ទទួល
អំពីព្រះហស្តព្រះពារ យកមកពិនិត្យមើលហើយទូលថា វីតួង ១ នេះ
តើតកន្លឹកវិបុលបពិត, តួង ១ នេះ តើតទៅនាពិតពខាត, តួង ១ នេះ
តើតទៅនាធ្លិតព្រះធរណី វីតួងទាំង ៣ នេះ តិតតម្លៃជាមាស ១ សែន
ដំឡឹង; មួយទៀត តួងដែលតើតនាធ្លិតព្រះធរណី មានគុណប្រសើរ
លើសតួងទាំង ២ ។ ពួកពាលទូតតូចហើយសួរថា ម្នាលទៅមាណព! ហេតុ
ដូចម្តេច ចានតួងតើតទៅនាធ្លិតព្រះធរណី មានគុណប្រសើរលើស
តួងទាំងពីរ ។ ផ្ទាតកមាណពឆ្លើយថា ម្នាលពាលទូត! តួងដែលតើតកន្លឹ
កំវិបុលបពិតនេះ ជាបេះសំប្រើប្រាស់សំពាក់ស្តេចបក្រែតត្រៃធិពង មាន
សិរីសួស្តី ជាបេះសំពាក់បំប៉ាក់ទេពកូពាសួគ៌។ , តួងដែលតើតទៅពិតត
ខាតនោះ ជាគ្រឿងធ្មេមណ្ឌ មានសិរីសួស្តីបំពាក់មនុស្សលោក ប៉ើតុំដឹង
ក្បាទឹងតើតទោសខ្លួនទុក្ខទប្រព្យទៃផ្សេង ។, រីតួងតើតនាធ្លិតព្រះធរណី
មានគុណប្រសើរលើសតួងទាំងពីរ ព្រោះជាបេះតើតពីថ្មមិលាក្បាយ

ព័ទ្ធជាប់យ៉ាងត្រជាក់បំផុត មួយសោតទៀតលើតខោះមានជំរៅក្រៃលែង
ខោះទំលៀងក្តី ខ្សល់ក្តី ភ្លៀងក្តី ពុំអាចបំរះពាល់ដូចខ្យល់, ប្រសិន
បើ ខរណៈមួយជាន់កែវដែលតើតនាឆ្នូតព្រះឆរណីខោះ សឹងតើត
លាតសក្តារះខ្ចីសុខសួស្តី ព្រោះឥតគណនា ដើមខ្ញុំហ៊ានពោលថា
កែវនេះមានគុណប្រសើរលើសកែវតាំងពីរ តំ សុត្វា សាធូ ឧទាហ
អស់ពួកវិទេហ លុះដឹងដឹតមាណពដោះស្រាយអាថប្រស្នាត្រឹមត្រូវ
ដូច្នោះ តំទ្យតវេស័ព្ទសាធុការ ជាច្រើនសាចន្ទ្រមាណក្តីផ្កាងពូ ត្រមតាំង
សំដែងខ្លួន ឲ្យប្រាកដដល់ភ្នែកអ្នកគន្ធរ ។ មហាជនោ ច ឯពួក
មហាជនឃើញហ៊ាហ តំបន្ទូលសរសើរសព្ទសាធុការកងំពង ។ ចំណែក
ខាងព្រះរាជាទ្រង់ត្រាស់ថា ម្នាលភដ្ទខូត! ពាក្យរបស់មាណពនេះ ត្រឹម
ត្រូវហើយឬ? ។ ភដ្ទខូតតាំងនោះក្រាបបង្គំទូលថា បពិត្រសុំត្រូវថ្លៃប្រ
សើរណើយ! រីពាក្យដោតិតមាណពដោះសាខោះ ត្រូវតិតប្រាកដហើយ ។
ព្រះរាជាមានព្រះរាជហឫទ័យសោមនស្ស ឥតទបមា ព្រះហត្ថាទ្រង់ចាប់
ប្រអប់ព្រះខ័ងហុចទៅដោតិតមាណព ដោយព្រះរាជឫទ្ធាថា ចូរចាំរះរក
ទីកើតត្បូងព្រះខ័ងនេះទៀត ។ ចាំដោតិតមាណព ទទួលយកព្រះខ័
រង់តាំង ៣ មកហើយក្រាបទូលថា បពិត្រមហារាជ! រីត្បូងព្រះខ័រង់ ១
នេះ កើតនាដើនភ្នំព្រះសុមេរុរាជ, ព្រះខ័រង ១ នេះ កើតកងភ្នំសុវណ្ណ
បពិត, ព្រះខ័រង់ ១ នេះកើតនៅនាគិរីនាថបពិត ត្បូងព្រះខ័រង់តាំង ៣ នេះ

គិតតម្លៃជាមាស ១ សែនដំឡឹង មួយសោត តែថ្នឹងដែលកើតនាតិរីនាថបព្តិត
នោះ មានគុណប្រសើរលើសតែវាំងឆ្ងាយពីរ ៧ តួណោះ ពាដទូតស្តាប់ហើយ
សួរថា តួដ៏ព្រះពុទ្ធដែលកើតនៅនាតិរីនាថបព្តិត មានគុណប្រសើរលើស
នោះ តើមានប្រការដូចម្តេច? ។ ដោតិកមាណពឆ្លើយថា អម្ពោ រាជ-
ទូត ម្នាលពាដទូតដ៏ចំរើន! តែថ្នឹងដែលកើតនាដើមគុំព្រះសុមេរុពាដនោះ
សឹងប្រដាប់ពិចិត្រដោយតែវ ៦ ប្រការ, តែថ្នឹងដែលកើតនៅគន្ធគុំសុវណ្ណ-
បព្តិតនោះ សឹងប្រដាប់ដោយមាសជុំវិញរឿង ជាវិមានសម្រាប់ប្រតិស្ថាន
នៃទេវតាទាំងឡាយ តែជាទីសំពះបាន់ឆាត់មិនបាន, ឯថ្នឹងដែលកើតនៅ
នាតិរីនាថបព្តិតនោះ ជាតែប្រសើរក្រៃលែង ហើយជាវត្ថុសំពះឱ្យកើត
លាភសក្ការៈទឹងសំពះបាន់ឆាត់បាន តែតែមានបព្ជាប់ពុកណាលោកសំដែង
ពុតមកជាច្រើន ។ ពាដទូតឮហើយសួរថា ម្នាលនាយសំពៅ! ពុកណាជម
ខ្មោះតើដូចម្តេច? ដោតិកមាណពឆ្លើយថា ម្នាលភ្ញៀ មិ ឯកោ មាណ-
កោ ឯហាកដទូតទាំងឡាយតើយ! តួដ៏ភាលមុនឡើយ មានមាណពម្នាក់
ឈ្មោះដោតិកមាណព ទៅកន្លែងត្រូវពាដគ្រឹះដាមួយខាតបិតា ។ ឯតាស្មឹ
សមយេ តួដ៏ទ្វៃមួយ ដោតិកមាណពនោះ តំណាងនូវបញ្ជាតកដូរលំណា
ឃាត្រាះពៅកាន់ព្រៃ ប្រយោជន៍ដើម្បីនឹងបរបាញ់សត្វ តំណាងថ្នឹងតស់ ៧ ថ្ងៃ
ខឹងតែដូរវិលមកផ្ទះពុំបានឡើយ ទៅរួចហើយដោតិកមាណពត្រាប់ឆ្លើតដ៏
ព្រៃស្ងាត់ ពៅតាមគោនវិហារដ៏ក្តៅតែម្នាក់ឯង ដើរពៅដល់តំណាងដ៏ពុតបព្តិត ។

អថខោ ត្រានោះ មានខ្លាធំមួយ សន្ធេន តដៅន្តោ ត្រហឹមគំ
រាមដ៏មានសំឡេងខ្លាំងខ្លារ មុខគួរឲ្យខ្លាចមហិមា ស្ទុះលោតមកប្រុងនឹងនាំ
ហែកស៊ី តែពុំអាចចាប់ជាតិតមាណពបានឡើយ ស្មោ តំ និស្ទា
បលាយិត្វា មាណពនោះ លុះឃើញខ្លាលោតមកដូច្នោះ ក៏តត
កំយាស្ទុះជុំ ស្មាតើ ស្ទុះតំឡើងភ្នំ ហើយអង្គុយនៅស្ងៀម ។ ឯខ្លា
ក៏ដេកចាំនាបន្ទោះភ្នំខោះឯង ។ ជាតិតមាណពអង្គុយសំកុកមិនហ៊ានចុះ
ពីភ្នំនោះឡើយ ។ អថខោ ភូតកណា តស្ស សន្តិ សុត្វា
លំដាប់នោះ អស់ពួកទេវតាលុះឮសំឡេងខ្លាយំ របស់ជាតិតមាណព
នោះក៏មានសេចក្តីអាណិតអាសូរ ក៏ធ្វើខ្លានោះឲ្យតេជាឡើ; ឯកន្ទេ
ទេវ ទេវតាអង្គខ្លះនាំយកអាហារពិតមកឲ្យបរិភោគ ឯកន្ទេ នានា
ផលាផលំ ទេវតាអង្គខ្លះ នាំយកផលាផលមកឲ្យ, ឯកន្ទេ និញ្ជា-
សនំ ទេវតាអង្គខ្លះ នាំយកភួកខ្លាឲ្យមកឲ្យ ។ ឯកន្ទេ វក្ខន្តិ
ទេវតាអង្គខ្លះ ចកវក្តិព្យាឋ្ឋល, លុះព្រឹកឡើងទេវតាទាំងនោះ នាំយក
ជាតិតមាណពមកដាក់នៅកន្លែងសួនទន្យាននគរផង្គ្រែះ ឲ្យដេកលើថ្ម
មង្គលសិលាហើយឲ្យកែវខ្ចប្រការ ទើបឆ្លាំថា ម៉ៃហៅជាតិតមាណព!
បើអ្នកណាសួរថា អ្នកមកពីណា ? ចូរឆ្លើយថា ទេវតានាំមក
អស់ពួកទេវតាលុះឆ្លាំហើយក៏អន្តរធានបាត់ទៅ ។ តទាបន ឯកា

តាលមតាសិ គ្រាន់តែឮឯណ ព្រះមហាសុត្រក្រុងពជគ្រឹះទ្រង់ចំរើនគ្គត ។
ពួកអាមាត្យពជបុរោហិតដ៏ទុំគ្នាថា ម្នៃអ្នកនាងតាំងឡាយអើយ ព្រះមហា
សុត្រនៃយើងតាំងឡាយ ទ្រង់ព្រះពជសុវណ្ណគតទៅហើយ ឥឡូវ ព្រះពជ
បុត្រានៃព្រះអង្គក៏គ្មាន ទើងបានសុត្រកន្លងណាសោយពជ្ជតទៅទៀត,ធម្មតា
ព្រះខត្តដែលពុំមានសុត្រសោយពជ្ជ រមែងវិនាសអន្តរាយពុំខាន ដូច្នោះ
គួរយើងកងជ្ជាខផ្សេង បុស្សរថលែងទៅស្វែងរកអ្នកមានបុណ្យ ទើងបាន
ជាម្ចាស់ជំរៅនៃយើងតាំងឡាយ តែតគ្នាស្រេចហើយ កំលែងបុស្សរថនោះ
ទៅ ។ បុស្សរថក៏ប្រទក្សិណព្រះខត្តរហើយ ឈរមុខរត្តោះទៅតាន់ទ្វារខ្នង
លុះចូលទៅដល់ហើយ ធ្វើប្រទក្សិណថ្មសិលា ហើយឈប់ទៅក្បែរបាត
ដើងនៃដោតិកមាណពនោះ ។ អស់ពួកបុរោហិតទើងអាមាត្យតាំងឡាយ
ឃើញដូច្នោះហើយ ស្រែកប្រាប់គ្នាថា ម្នៃអស់អ្នកតាំងឡាយអើយ
ឥឡូវនេះ មានបុរសម្នាក់ដេកលើត្រែមនោសិលានេះ ចូរអ្នកតាំងឡាយ
ប្រគំដង្វាជន្ត្រីឡើង ឲ្យត្រមគ្នាតែម្តង, បើបុរសនេះឥតបុណ្យ ឥតវាសនា
គាលបើឮសូរសព្ទសំឡេងដង្វាជន្ត្រីតងំរពង តើទើងតើយង្ហើលរត់ទៅ, បើ
មានបុណ្យនិងវាសនាច គោះឮសូរសព្ទដង្វាជន្ត្រីប៉ុន្មានក្តី ពុំអាចតគ្គើយង្ហើយ
អស់ម៉ោងជាច្រើនតាំងនោះ តើប្រគំនូវដង្វាជន្ត្រី ដ៏មានសព្ទសូរខ្ទរខ្ទារគ្រហឹង
អឺងកង សោ អត្ថោ ។ អដ្ឋាសិ ឯខាងដោតិកមាណពនោះ
តើពុំអាចតគ្គើយភ្ញាក់ផ្អើលឡើយ សើងបិតនៅស្ងៀមដដែល ។ ទើប

បុរេហិតចូលទៅដិត ហើយលើកតម្រាមអង្គុះដៃប្រាប្ញាថា បពិត្រ
អ្នកមានបុណ្យ យើងខ្ញុំជាមនុស្សមកពីឆ្ងាយ សូមអញ្ជើញទៅសុំយកដីសម្បត្តិបិតាទៅ
ព្រះនគរដោយសុខសួស្តីហោង ។ ឯចៅដៃតកមាណពក្រាកឡើងអង្គុយ
តាំងសមាធិលើអាសនៈ ។ បុរេហិតសួរថា តុណ្ហោ អាគតោសិ
បពិត្រអ្នកដ៏មានបុណ្យ ព្រះអង្គស្តេចយោនីមកពីប្រទេសណា ? ។ ចៅតិក
មាណពថា យើងនេះ គឺពួកទេវតាទាំមកជាក់នៅសួនច្បារនេះ ។
គ្រានោះ ពួកអាមាត្យរាជបុរោហិត ក្រាបទូលអញ្ជើញចៅតិកមាណព
ឲ្យឡើងគង់លើបុស្សរថ ដង្ហែនាំចូលទៅគាន់ព្រះនគរអតិសេកជាមួយ
ព្រះរាជធីតាទ្រង់ព្រះនាម ដេតិយកដាទេវី ជាឯកអគ្គមហេសី ។
ឯចៅដៃតកមាណពកំឡើងព្រះទោមជា ព្រះហរិជាតិកជ, ចាប់ដើម
តាំងពីនោះមក ព្រះអង្គតែងមានព្រះរាជហឫទ័យសង្រ្គោះដល់អ្នកនគរ
ដោយសង្គហធម៌ ៤ យ៉ាង ទ្រង់រក្សាសច្ចធម៌ និងរាជបុរោហិត តាម
ប្រពៃណីធម៌តាំងពីបុរាណ, មិនត្រឹមតែប៉ុណ្ណោះ ព្រះអង្គទ្រង់រក្សាទូទៅនូវទសពិធ
រាជធម៌ (ធម៌សំរាប់ស្តេច១០ យ៉ាង) ទៀត ហើយស្តេចនឹកដល់គុណ
ទេវតានៅក្នុងដីនោះជាពិត ស្តេចបង្គាប់បង្គាប់មហាជនឲ្យទៅតាំងស្រុកនៅ
ទៀបដើមក្នុងដីនោះជាពិត ឲ្យឈ្មោះថា មហាគ្រាម ហើយឲ្យធ្វើទម្លាប
បូជាដល់ទេវតាទាំងឆ្ងាយៗដល់ឆ្នាំ តុំដែលមានឡើយ ។ ឯក្នុងនោះ ក៏
មានឈ្មោះថា ដីនោះជាពិត តាំងពីពេលនោះមក ។ ដែរវាជាទុតៈ ហេតុ

មានបុរាណធម្មតាដូច្នេះ ទើបយើងហ៊ានពោលថា តែវែលតើតក្នុងក្តីរបៀតបៀន ជាតែវាមានគុណប្រសើរលើសតែវាំងឆ័ត្រនោះឯង ។ កាលដែលដោតតមាណព សំដែងនូវគុណនៃត្បូងនោះចប់ហើយ, ទៅតាវែលក្សាស្ងួតច្រត្រនាំគ្នា ច្រាយពាយនូវតេនបុជ្ជាគឺក្តីក្រាក់ក្តីមាស ហើយឲ្យពរសព្វសាធុការផ្សេង ។ ចំណែកខាងមហាជនគាំងឡាយ គឺអាមាត្យពលបុរោហិត សឹងឲ្យស័ព្ទសាធុការកងរំពង ។ ឯពលខ្លួនគាំង ៣ យតនូវព្រះទំរង់គាំងអស់ថ្ងាយដល់ព្រះបាទតហុលពល ថ្វាយបង្គំលាទៅឯកន្ទ័ពអាត្មារៀង។ ខ្លួនាំសេចក្តីទៅក្រាបទូលៈស្តេចបេសន់ខ្លួន តាមដំណើរវាក្យត្រែគាំង ៣ នតរលុះជ្រាបហើយ កំចាត់ពលខ្លួនឲ្យនាំមាស ១អង្គ ១ពាន់ដំឡឹង ទៅជូនដោតតមាណពនោះ ហើយលើកទ័ពវិលទៅកាន់ព្រះនគរវិញ ។ ថ្លែងពីព្រះបាទតហុលពល ស្តេចទ្រង់ព្រះចិន្តាថា ព្រះតាំងអ្នកច្រៀងជាបិតានៃដោតតមាណពនេះ មានគុណបការៈលើតាត្មាអញអនេកអនន្តណាស់ តាត់ចាន់ដោះស្រាយនូវសេតបតីតប្បញ្ញា ហាក់ដូចជាតាត់លើកពលសម្បត្តិឲ្យអាត្មាអញ, តួនាលនោះ ម៉ែកុំតែចាន់តាំងអ្នកច្រៀងនោះ ត្រូវនតតើនឹងវិនាសអន្តរាយ, ចំណែកខាងទៅដោតតមាណពនេះ ក៏មានច្រាំងាយាសរៃ ដូចត្រូវតាំងអ្នកច្រៀងដែលជាឪពុកដែរ ចាន់ដោះស្រាយនូវម៉ែខ្លួនប្រសាទ្រូតតើសតាក់ម៉ែកុំតែចាន់តាត់នតរអាត្មាអញ មុខជាវិនាសឥតសង្ស័យទេឬយ ហើយថែតាត់បេញ្ជាតិ

ព្រះនគរនេះទៅ ខានសឹកសត្រូវមកដណ្តើមសួរប្រស្នាដូច្នេះទៀត គោ
វិសជ្ជេសុត្តំ អ្នកណាឆ្លើយមិនដោះស្រាយបាន, យថា សោ
ឯតរម្ហា ដូច្នោះ ដើម្បីកុំឲ្យគាត់ចេញពីព្រះនគរនេះបាន គួរអាត្មា
អញយកព្រះរាជធីតា ឲ្យថាកឃាតាត់ចុះ, លុះទ្រង់ព្រះចិន្តាស្រេច ស្តេច
យកព្រះរាជធីតា មកប្រដាប់រៀបមង្គលការ ជាមួយ ជាតិតមាណព ។
អបរភាគៃ តមកពេលក្រោយ ព្រះរាជាទ្រង់លើកអស់សម្បត្តិចាំផ្តួច
មកប្រគល់ឲ្យព្រះរាជធីតានៃព្រះអង្គ លុះទ្រង់ចាស់ដឹកនាំពេតាមកទៀត
បៀនព្រះតាយកំសោយព្រះទ័យគ្គីតគំពីមនុស្សលោកនេះបានទៅកើតឯហ្នឹង
សួតខេវិលោកនាយហោង ។ លំដាប់នោះ អាមាត្យរាជបុរោហិតកំណាច់
លើកសពសំស្ការព្រះមហាក្សត្រយស់ខ្លួនរួចស្រេច ជំនុំគ្នាអតិសេកជាតិ-
តមាណព ឲ្យសោយរាជសម្បត្តិ ថ្វាយព្រះនាមថា ព្រះបាទជាតិតរាជ ។
តតោ បដ្ឋាយ ចាប់ដើមអំពីថ្ងៃនោះមក ព្រះបាទជាតិតរាជ តែង
រក្សាទុកឧបោសថសីល ក្នុងថ្ងៃ៨កើត ៨ រោច១៤កើត១៤រោច ស្តេចទ្រង់ប្រជុំ
អស់មហាជនពាំនាំគ្នាយ ហ៊ោយទេសនាពួន្នាន ដោយព្រះរាជឋង្ការថា
គោ ភៃអ្នកពាំឡុយដំចំរើន យាវតា ដែលមកប្រជុំគ្នាមានប៉ុន្នាន ។ ក្តី
ឯសប្បុមេន ចូរប្រុងស្តាប់សំឡេងក្តីពីរោណព្រងនាយ យេ ច
ជាតា បុរសបុគ្គលណាមួយ សម្លាប់សត្វបំបាត់ជីវិតអ្នកដទៃ លួច
ប្លន់ឆបោកអ្នកដទៃក្តី ប្រព្រឹត្តល្មោនពានទៅលើប្រពន្ធបុត្តីអ្នកដទៃក្តី

និយាយពាក្យកុហកអ្នកដទៃក្តី ធ្វើកន្ទូរចំកស្រីរើ គឺសុភនីរម៉ៃយក្តី
ឬគួរនោះ លុះស្លាប់ពីមនុស្សលោកនេះទៅ រមែងទៅសោយទុក្ខវេទនា
ក្នុងនរកពុំខាន ។ យេ ច សីលាទិ វត្តន្តិ បើអ្នកណាមួយមានចិត្ត
តាត់តម្កាស្ងួត រក្សាសីលឲ្យបានខ្ជាប់ខ្ជួន លុះអស់អាយុពីមនុស្សនេះទៅ
រមែងទៅកើតក្នុងឋានសួគ៌ ទេវៈលោកនាយទោត , ដូច្នេះ អ្នកទាំងឡាយ
ចូរបបួលគ្នាធ្វើការកុសល ទានា ឯកាវេច ចូរវៀរខាតបាប
ទុច្ចរិតាទិ បដិបាទ ចូរលះលែងនូវអំពើទុច្ចរិត ។ ឥតិ ភគា
ពុទ្ធទិត្យា ព្រះបរមគ្រូត្រាស់ឆ្លើយតបនូវពាក្យអស់មនុស្សម្នា មហាជនទាំងពួង
យ៉ាងនេះ ឯទ្ធនព្រះអង្គសោតទ្រង់ប្រព្រឹត្តនូវទសតិធម្មជាធម៌ ពុំមានព្រះរោគ-
ហាបូច័យកាយមាយឡើយ ព្រះអង្គទ្រង់សម្រាន្តមហាជនដោយសន្តិហវត្ត
ប្រកាស, ព្រះកិត្តិនាមបស់ព្រះអង្គនឹងតែងប្រកដរហូតកប្បសតសហស្សលោក ។
ឯស្តេចសាមលោកដ្ឋានទាំងខ្លួន លុះច្យុតពីមានជន្មខ្លី តែងមានចិត្តត្រេកអរ
សាទរ ខ្ចាយនូវគំណាចត្រប់ ។ អដ្ឋ សីលានិ ព្រឿងសេក្ខារៈឲ្យដឹង មក
ថ្វាយ ។ តតោ បដ្ឋាយ ចាប់ពីមុតាំងនឹងថ្ងៃដែលព្រះបាទរដាតិក-
រាជ សោយរាជសម្បត្តិមក សុភិក្ខំ ស្រូវអង្កើលសូវណែកតំបន់ក
អន្តរាយោ សេចក្តីអន្តរាយដោយរោគុណាមួយក៏ពុំមាន ប្រជាកស្ត្រ
តាំងឡាយសឹងនៅជាសុខសប្បាយត្រប់ ។ គ្នា ។

ឥតិ ស្តុរតោ តោនិ សន្តោ ព្រះបរមគ្រូពោធិសត្វទ្រង់ព្រះ

នាមសុរព តាលបើនាំមកនូវទេភហរណ៍ ដូច្នេះហើយ ស្តេចទ្រង់ទេសនា
តទៅថា អសេវនា ច ពាលានំ បណ្ឌិតានញ្ច ច សេវនា
ការមិនសេពគប់នឹងមនុស្សពាល ១ ការសេពគប់នឹងបណ្ឌិត ១ ទាំង៣ប្រការ
នេះជាមង្គលឧត្តម, អ្នកប្រាជ្ញទាំងឡាយមានព្រះសម្ពុទ្ធជាដើម តែងសរ-
សើរយ៉ាងក្រៃលែង, អង្គកយោ រីសេចក្តីមន្ទពាយទាំងពួង តុំមានឡើយ
ដូចព្រះបាទពហុលរាជ ក៏មានស្តេចស្រីសមាគមនឹងពួកអ្នកប្រាជ្ញនូវជោគកា-
ណាត សឹងបានសុខសួស្តី និរាសទុក្ខភ័យ ។ ព្រោះហេតុនោះ បុគ្គល
គ្រប់រូប គួរតែស្តេចស្រីសមាគម ជាមួយនឹងបណ្ឌិតតុំពាន ។ យា ឯវ័
បណ្ឌិតា ឥត្ថី ស្ត្រីណាមួយ ជាបណ្ឌិតប្រតិភាល គួរបុគ្គលស្តេចស្រី
សមាគម ដូចស្រីម្នាក់ឯស្រីស្នំរបស់ព្រះមហាសត្វត្រាធិរាជ ដែលមានព្រះ
រាជហឫទ័យសហិចសាហាវ ។ រីនាងនោះមានបុណ្យមានប្រាជ្ញច្រើន,
ឈ្មោះ សុសលា ជាស្ត្រីឈ្លាស ចេះនិយាយសំដីពីរោះ ចេះខ្ជាន់ព្រះមហា-
សត្វត្រោះបាន ដោយឥតសេរចស់នាង ។ ព្រះសាស្តាត្រាស់ដូច្នេះហើយ
ទ្រង់នាំមកនូវអតីតនិទានពីព្រេងនាយមកសំដែងថា អតីតេ ឯកស្មិំ
ឧភវេ ក្នុងកាលដែលកន្លងទៅហើយ មានព្រះមហាសត្វត្រាធិរាជមួយ
ព្រះអង្គ ទ្រង់ព្រះនាម ចន្ទភាជ សោយរាជសម្បត្តិនៅនគរមួយមាននាម
ពុំប្រាកដ ព្រះអង្គមានព្រះរាជហឫទ័យកាចសាហាវមហិមា តោច-
វសតោ . លុះដោយសេចក្តីក្រោធ តែងសម្លាប់អស់ស្រីស្នំមេនំ

ពេលនឹកឃើញ ថ្ងៃពុំដែលភាន់ភ្លេយ ។ ឯស្រីស្នំដែលចូលចំរើនដោយគាម
គុណ បើគាប់ព្រះពុទ្ធហឫទ័យក៏ច្រើនពួកខ្លួន បើមិនគាប់ព្រះពុទ្ធហឫទ័យ
ទេ តែងសម្លាប់ចោលចេញ ។ ព្រះអង្គតែងតាំងស្រីស្នំដែលនេះជួន
កាល ១ ជួនកាល ២-៣-៤ ។ បពិត្រមើយ ! ឰដ៏កាលនោះ មានស្រី
ស្នំម្នាក់ មានក្រុងជាឈ្មោះវៃយល់សេចក្តីគាប់ខុស លុះមកដល់វិនេរបស់
នាងក៏គិតថា តើ តេរាមិ ន្តអញ! តើតបំរើដូចម្តេច ? តើ តេរាមិ
ស្រដីដូចម្តេច? ចិន្តយិ សុភាមិ តើតដូចម្តេច? តើ ជីវិតំ អញ្ញទិវ
តេរាជីវិតដូចម្តេច, បើដូច្នេះ គួរតែញុំាងវិជ្ជាមកនិយាយថ្វាយ
ទើបល្អ លុះដល់ពេលល្ងាចក៏ចូលទៅគាល់ បន្ទាប់មក ដល់ឃាមតី ក៏
ក្រាបទូលថា បពិត្រព្រះតេជគ្គដ៏មានគុណក្លួន ខ្ញុំម្ចាស់បានស្គាប់និពន្ធមួយ
តុម្ចាតំ តំ តេរាសុភាមិ ខ្ញុំម្ចាស់និងនាំវៀរនោះមកថ្វាយព្រះអង្គ
រីនិពន្ធនេះ ជាសុភាសិតកថា សម្រាប់ក្លួនព្រះមហាក្សត្រតំពីបុរាណ
រៀងមក, ហើយព្រះមហាក្សត្រទាំងនោះតែងប្រតិបត្តិតាម ទ្រង់រក្សាអស់
អាណាប្រជាទុកស្រួលតាំងឡើយតាមតទ្ធនធម៌, តិត្តិសព្ទរបស់ព្រះអង្គល្ប
ល្បាញក្រៃលែង យោ ហិ អត្តនោ ភតិតោ បើអ្នកណាមួយ
ជាអ្នកមានចិត្តស្មូតត្រង់ចំពោះព្រះមហាក្សត្រក្លួន ចេះដឹងគួរសម ពុំមាន
ចិត្តក្រុស្តមិត្រ, អ្នកនោះគួរចិញ្ចឹមឲ្យជារាជអាមាត្យ ដូចជាព្រះបាទ
រាមាទិត្តពង, មួយសោត ព្រះមហាក្សត្រណាចិញ្ចឹមក្លួនរាជអាមាត្យ

មានចិត្តរឿបរៃអកតញ្ញូ កំនិនិះតែសេចក្តីក្តៅក្រហាយដល់អណាប្រជានុ-
ករស្ត្រ ដូចព្រះបាទវេស្សភ្ជ . ម្យ៉ាងទៀត ព្រះមហាក្សត្រណាដែលំ
អគ្គមហេសី ត្រូវដំកល់ស្រីឱ្យឯានដូចនាងកណ្ហាណី , បើស្រីឯណាមាន
ចិត្តថោកទាបរូសជ្ឈប្បសា ដូចនាងកដសីហ៍ ឬអានឯយក្ខិនី ពុំគួរដំកល់
ជាមហេសីឡើយ ។ សោ ចន្តោ រាជា . រីព្រះចៅចន្ទកដទ្រង់
ព្រះសណ្តាប់ដូច្នោះហើយ សួរថា នែនាងបរិសទ្ធនាងកណ្ហាណីនោះ តើ
មានប្រការដូចម្តេច ? ។ នាងបុញ្ញវ៉ាក្រាបទូលថា :

អតីតេ ឯកោ រាជា កុងកាលដែលកន្លងទៅហើយ
មានព្រះមហាក្សត្រមួយព្រះអង្គទ្រង់ព្រះនាម វេទ្ធមាដិតកដ ពុំមានព្រះ
កដវុត្តាឡើយ មានតែព្រះកដបុត្រីមួយ ព្រះអង្គ ដ៏មានរូបឆោមលោម
ពណ៌ សម្បុរស្អិតស្អំ ប្រកបដោយបញ្ញាឥតកណ្ហាណីហាក់ដូចស្រីទេព
អប្សរបរិភក្តិ នាស្គន់ត្រៃត្រឹមស្មែតិ ខាងលើលាយត្រាយឆាយដូច
កដហង្សមាស, ថ្ងៃមួយ នាងចូលទៅគាល់ព្រះវរកដបិតាឥតឆ្ងល់ទៅកន្លងដំ
សមគួរ ។ ព្រះមហាក្សត្រាធិកដទ្រង់ទតឃើញព្រះកដធីតាដ៏មានសិរីសួស្តី
ប្រសើរដូច្នោះ ព្រះអង្គទ្រង់ត្រួយព្រះកដហឫទ័យថា រីព្រះកដធីតាអញ
នេះ គួរនឹងឱ្យមានស្វាមីហើយ លុះទ្រង់ព្រះចិន្តាដូច្នោះ ក៏មានព្រះកដ
ឧទ្ទាន់ថា ម្នែកលណ្ហាណីជាសំឡាញ់បិតា ! បិតាគួរស្នងស្វែងរកស្វាមីឱ្យ
កូនហើយ ។ ព្រះនាង លុះឮព្រះកដបិតាមានព្រះបន្ទូលដូច្នោះ ទ្រង់

ព្រះចិន្តាថា រីព្រះពជកុមារកុដ៏ជម្ពូទ្វីបនេះ ទីរែកព្រះពជកុមារណាមាន
ប្រុងជាដូចអាត្មាអញនេះពុំមានទេសោះ, ឯបុរសអន្ធពាលអប្បឥតប្រុងជាឥត
បុណ្យរាស្មា នោះមានតរគោក, បើដូច្នោះ អាត្មាអញកុំនិយាយស្តីនឹង
បុរសដទៃ ទើបជាការល្អ, ចាប់ដើមតាំងពីថ្ងៃនោះមក ព្រះនាងឥតចរចា
នឹងបុរសណាមួយទេ ព្រមទាំងមិនរមិលមើលបុរសទៀតផង ។ ព្រះមហា-
ក្សត្រាធិពជទ្រង់ចង្អាប់ពជអាមាត្យ ឲ្យចាព្រះពជសារប្រុងដល់ស្តេច
កុដ៏ជម្ពូទ្វីបថា ភោ ន្តោ ភៃអស់ស្តេចកុដ៏ជម្ពូទ្វីបដ៏ចំរើន ! បើអ្នក
ណាមានព្រះពជបុត្រា ឲ្យរៀបតាក់តែងគ្រឿងប្រដាប់ ដូចទៅតា ហើយ
ជូនព្រះពជកុមារនោះមក ឲ្យលួងលោមព្រះពជធីតានៃយើង តាលបើពជ-
ធីតានៃយើងត្រេកអរស្រេចជាមួយ យើងនឹងអភិសេកព្រះពជកុមារនោះ
ឲ្យសោយពជសម្បត្តិតាំងយើងហោង លុះតែងព្រះពជសារស្រេចស្តេច
ឲ្យចុះត្រាហើយ ប្រើពជទូតឲ្យទាំងព្រះពជសារចេញទៅកាន់នគរផ្សេងៗ
ក្រាបទូលស្តេចភាំងនោះតាមព្រះពជសារ ។ អស់ស្តេចកុដ៏ជម្ពូទ្វីបលុះឮព្រះ
ពជសារដូច្នោះ ក៏រៀបប្រដាប់ប្រដាតាក់តែងព្រះពជបុត្រាយ៉ាងខ្លួនទីនៃ ។
មានសេនាពលដូចទៅតា ហើយឲ្យចតុរង្គិនីសេនាហែហម ចោមរោមជា
យសម្ភារៈ លើកចេញមកតាមផ្លូវ លុះដល់ព្រះនគរហើយ ក៏បញ្ឈប់កង
ទ័ពនៅខាងក្រៅ ឯព្រះពជកុមារតាំងនោះ ក៏ទ្រង់គ្រឿងប្រដាប់ចូលមក
តាល់ព្រះបាទវេទូមាដើតពជ ជាបិតានៃព្រះនាងតិសប្បាណី ។ ព្រះមហា

ក្សត្រានីកដ្ឋានព្រះបន្ទូលថា កោន្តេយ្យ ម្នាលអស់ព្រះពួកកុមារទាំងឡាយ ដ៏ចំរើន ! យោ មម ឥទំ អសប្ផាសុំ ព្រះរាជកុមារណាមួយ កាលដើរតាមនៃយើងនឹងត្រឡប់ស្ងួមត្រកត់ក្តី ឲ្យសើៗញាក់ ឬស្រដីដាក់ម្ហូបក្តី យើងនឹងនិមន្តសេកព្រះរាជធីតានៃយើង ជាមួយព្រះរាជកុមារនោះ ហើយឲ្យសោយរាជសម្បត្តិស្មើនឹងយើងហាស ។ ឯព្រះរាជកុមារទាំងឡាយ ថ្វាយបង្គំហើយ ក៏ឡើងទៅគាល់មហាក្សាសាទនៃព្រះនាងកល្យាណី ចូលទៅស្រដីលួងលោមដោយគុណទាំងឡាយរៀនកាលសន្តឹង ។ ព្រះនាងឥតមានព្រះរាជសារទើយ សូម្បីមួយម៉ាត់សោះ ។ ព្រះរាជកុមារខ្លះទ្រឹង្សាយោមបាន ១ យាម អង្គខ្លះបាន ២ យាម អង្គខ្លះបាន៣ យាម អង្គខ្លះទៀតបាន ៤ យាម ព្រះនាងពុំស្រដីដងឡើយ ។ លំដាប់មក ព្រះរាជកុមារអង្គខ្លះ ក៏តាំងព្យាយាមលួងលោមតទៅទៀត អង្គខ្លះបាន ១០ ថ្ងៃ អង្គខ្លះបាន ១ ខែ អង្គខ្លះបាន ៣ ខែ ។ ព្រះរាជធីតាឥតញញឹម ឬបរទាមាមួយដងឡើយ ។ ព្រះរាជកុមារទាំងនោះ ទាល់ចំណេះពាល់ៗព្រះអង្គ; នាំគ្នាចូលទៅគាល់ព្រះបាទវេទ្ធមារជិតរាជ ក្រាបថ្វាយបង្គំលាទៅកាន់ទីតរៀងៗខ្លួន ។ រីឯកុមារនេះ ពុំបាត់ស្ងាត់ឡើយ ឮខ្ជួទៅក្នុងសាលដម្ពូទ្វីប ។

ឮដំណាលនោះ មានព្រះមហាក្សត្រមួយព្រះអង្គ សោយរាជ្យនៅអញ្ជនេតរ មានព្រះរាជបុត្រាព្រះនាមវេទ្ធកុមារ ទ្រង់រៀនសិល្បសាស្ត្រ ១៨

ប្រការនេះហ្នាត់បរិបូណ៌ ។ ព្រោះពាជកុមារ ចាន់ឮថា ព្រះនាងកល្យាណី ដ៏ជាព្រះពាជធីតានៃព្រះចាន់ទេវិចមារជិតពាជ មានរូបឆោមលោមពណ៌ដ៏ល្អ ឥតខ្ចោះត្រង់ណា ពុំចាន់ចរចានឯបុរសណាមួយ លុះចាន់ឮដូច្នោះ ក៏ត្រង់ព្រះចិត្តាថា ឯកោ មន្តោ រមន្តុអាគមមួយ ឈ្មោះចិត្តខ្ចូរមន្ត គឺមន្តស្រូបគាញ ឬជកចិត្ត, អញមិនគាន់ចាន់រៀនទៅឡើយ ឯសោ ហិ មន្តោ រមន្តុនោះឯង អាចបែងចិត្តចាន់ជា ២ រំចិត្តនោះអាចយកទៅដាក់កន្លែងណាក៏ប្តូរដ៏រចស់អ្វី ។ កំអាចស្រដីចាន់ តោ ឯតំ ជានាតិ រីនរ-ណាហ្ន៎ ! ចេះមន្តុនេះ លុះទ្រង់តិចារណាដូច្នោះ ហើយ ក៏ចាន់ដឹងច្បាស់ក្នុងព្រះពាជហឫទ័យថា មានតែព្រះមហាឥសីនៅក្នុងព្រៃព្រះហិមពាន្ត ទើបចេះ, ក្រៅពីនេះ គ្មានឧរណាចេះឡើយ, ចើដូច្នេះ គួរអញទៅកព្រះមហាឥសីអង្វរសូមរៀន លុះរៀនចេះហើយ សឹមអញទៅតនាងកល្យាណីឯក្រោយ, នាងកល្យាណីនឹងលុះទៅក្នុងអំណាចអញហោង ។ ព្រោះពាជកុមារ លុះទ្រង់តិចារណាស្រេចហើយ ព្រឹកឡើងចូលទៅគាល់ព្រះវរពាជបិតា មាតា ក្រាបទូលសូមលាទៅរៀនមិល្ប្សាស្ត្រនេះ ដោយឧកកូនតាមតួម្នាក់ទៅជាមួយផង ហិ ភវន្តំ តត្ថ ដើរទៅតាន់ព្រៃហិមពាន្ត ហើយចូលទៅតាន់សំណាក់តាបសឫស៊ី ថ្វាយបង្គំសូមកាស្រ័យនៅ ឯតាយា ទ្វិ ហិ កុមារាទីនីប្រតិបត្តិតាបសឫស៊ី ៦ ថ្ងៃ ២ ថ្ងៃ ទើបអង្វរសូមរៀនមន្តុនោះថា តន្តេ មមំ អនុតមេន្តុ បពិត្រព្រះភាបសដ៏

មានគុណធ្ងន់ សូមអម្ចាស់កន្លះគ្រាក្រាបប្រណីដល់ខ្ញុំ ។ ខ្ញុំសូមរៀនចិត្តមន្ត សូមអម្ចាស់ប្រដៅមន្តខ្លះ ដាស់យើងខ្ញុំកាំងពាន់នេះហាន ។ តាបសក្រាបថ្វាយថា ម្នាលកុមារ ! មែនន្តនោះ គួរបេតែម្ចាស់ឯង ទើបជាការល្អ ។ ព្រះពោធិកុមារឥតប្លែសូមរៀនកាំងពាន់ អស់វារៈ ៣ ដង ។ តាបសតាំត្រមាឡើយ ។ ទើបព្រះពោធិកុមារអង្វរថា បពិត្រតាបស ! កុមារនេះ ជាបំណាច់ឆ្អឹងដ៏ខ្ញុំគម្ចាស់ ជាអ្នកធ្វាប់លេងលែ្បងជាមួយគ្នាតាំងពីនៅជាកុមារតូច។, ហេតុដូច្នោះ សូមអម្ចាស់ប្រដៅយើងខ្ញុំកាំងពាន់នេះឲ្យគាន ។ ឯតាបសបានឮពាក្យដូច្នោះហើយ ក៏ប្រដៅចិត្តមន្តដល់កុមារទាំងពីរ ។ ព្រះពោធិកុមារលុះរៀនចប់សព្វគ្រប់ហើយ ទើបនមស្ការក្រាបថ្វាយបង្គំលាមកនេះ ចួលទៅក្រាបថ្វាយបង្គំសម្តេចព្រះវរពោធិតាមាតា ហើយទូលលាទៅឯនគរនៃក្រុងវេច្ចមារជិតពាន ។ ត្រះបិតាព្រះមាតាក៏ត្រមតនុញ្ញាត ឲ្យព្រះពោធិកុមារតាមសេចក្តីសុំ ហើយប្រដាប់ចតុរង្គិសេនាយោធាជាច្រើន ។ ឯព្រះពោធិកុមារក៏ប្រដាប់គ្រឿងបញ្ចកកុធភ័ណ្ឌ ឡើងគង់លើពាជរថដ៏ប្រសើរ បរចេញពីព្រះនគរតាមលំដាប់មាគ៌ា លុះដល់នគរព្រះចាវេច្ចមារជិតពាន ស្តេចដាក់កងទ័ពនៅខាងក្រៅ ទើបប្រើពាន្តចូលទៅក្រាបទូលថា ខ្ញុំតម្ចាស់ឈ្មោះទៅវេច្ចកុមារ ជាព្រះពោធិបុត្រចូលមកថ្វាយបង្គំចង់ឃ្លានព្រះពោធិតា។

(នៅមានត)

អក្សរសាស្ត្រខ្មែរក្រោយសម័យអង្គរ

លោក ស៊ីង-ហ៊ាន រៀបរៀង

ក្រោយពីសម័យអង្គរវ៉ាត់រឿង ទាន់សិល្បៈល្បីល្បាញក្នុងសាកល-លោក, ប្រទេសខ្មែរយើងបានជួបប្រទះនឹងសង្គ្រាមជាញឹកញាប់ ដោយមានចម្បាំងពាំនាំដល់ នឹងប្រទេសជិតខាងផង ចាំនឹងដណ្តើមពាជផ្ទាក្នុងស្រុកផង ។ កន្លែងកើតសង្គ្រាមដូច្នេះ ប្រជាពលរដ្ឋយើង ត្រូវតែគេចវេះ រត់ទីតែ រត់សឹក ឬត្រូវកណ្តាក្លើជាគាហាន ។

ទាន់សិល្បៈដែលធ្លាប់ល្បីល្បាញមក ក៏ពុំឃើញមានសតម្ភភាពក្លឹងធ្ងុំធ្ងុយ ។ បុព្វណាវត្ថុទាំង ៗ នៅសម័យអង្គរបានលុបរលាយបាត់បង់អស់រលីង នឹងបានតបចោលនៅកន្លែងព្រៃដាំចំណីក្តៅតិ ហើយពុំបានមានខរណានឹកឃើញផងសោះ ។ ទាន់សាសនា ប្រជាពលរដ្ឋខ្មែរយើងនៅប្រកាន់ជឿព្រះពុទ្ធសាសនាយ៉ាងមុតមាំ ។

ចំណែកទាន់អក្សរសាស្ត្រវិញ តរឹងជាញឹក ។ ក្នុងសម័យលង្វែកនឹងតុត្តុង ច្រើនតែជនស្រុងរឿងព័ត្តព្ធសាសនាមានរឿងរសជាតិ ដែលនិទានពីកំណើតព្រះពុទ្ធ១០ជាតិ កាលនៅជាព្រះពោធិសត្វជាដើម, ក្រៅពីនេះ តរឹងជាញឹកជាតិយើង ជាទីតំតុបតែងឡើងនូវសាស្ត្រាល្បែង

នឹងសាស្ត្រាចារ្យបង្រៀនជាច្រើនរឿងច្រើនប្រភេទ មានច្បាប់ក្រម, ភ្នែក្តាល, កូនចៅ, ក្រមខែតិជាដើម នឹងរឿងទ្រង់ដែលនិយាយត ។ ត្រាមក មានរឿងតាឡៅ, តាខ្វាក់អាទិន, សុភាទន្សាយ, ធនញ្ជ័យ ចណ្តិតជាដើម ។ តែរឿងទាំងអស់នោះ ពុំឃើញមានដាក់ឈ្មោះ តរៀងទេ នឹងកាលបរិច្ឆេទនៃការសរសេររៀបរៀង នៅអ្នកណាឆ្នាំណាឡើយ ។

ចំពោះព្រឹត្តិការណ៍នៃនាមតរៀងទុក, កាលបរិច្ឆេទ, រដ្ឋការនឹងប្រកាសអក្សរសាស្ត្រ នៅលើសាស្ត្រាចារ្យ សាស្ត្រាសៀម នឹងរឿងព្រេងទាំងអស់នោះ ដោយពុំមានគោលហ៊ានដាក់ហាក់ដូច្នេះ, យើងជាអ្នកស្រាវជ្រាវអក្សរសាស្ត្រមួយរូប សូមធ្វើឲ្យតំនៃការស្រាវជ្រាវអក្សរសាស្ត្រទាំងអស់នោះ ចំពោះអស់លោក-អ្នកអក្សរសាស្ត្រទាំងឡាយ សុំឲ្យជួយស្រាវជ្រាវកែឬសតម្រង់អក្សរសាស្ត្រនោះ ឲ្យមានគោលហ៊ានដាក់លាក់ឡើង ជូនដល់រួមជាតិយើង, ដើម្បីនឹងលំអ ឬសម្រង់នៃសាស្ត្រាចារ្យរឿងទាំងអស់នោះ ឲ្យមានលក្ខណៈគ្រប់គ្រាន់ ទៅជាមតិកអក្សរសាស្ត្រ សម្រាប់សិក្សាកូនខ្មែរ ក្នុងព្រះពុទ្ធសាសនាចក្រតទៅ ។

មុននឹងពិនិត្យមើលអក្សរសាស្ត្រខ្មែរយើងសម័យនោះ ដែលមានអត្ថរសជ្ជះម្តង យើងសូមធ្វើអត្ថាធិប្បាយនំពីរបៀបការសិក្សានៅសម័យនោះបន្តិច ដូចតទៅនេះ ៖

ក) នៅសម័យនោះរបៀបការសិក្សា, កូនខ្មែរយើងគេទុកប្រុស
អាយុ ៨ ឬ ១០ ឆ្នាំបានចូលទៅនៅវត្ត, នៅបំរើលោកគ្រូ ដាំទឹក ដងទឹក
ពុះទេស តាមលោកគ្រូទៅសូត្រមន្ត ទៅឆាន់ ទៅទេសនា ។ ការរៀនសូត្រ
ពុំសូវមានពេលមោឡឺមត់ចត់ទេ , ក្មេងនៅជាមួយលោកគ្រូតាំងអស់នោះ
ក្មេងណាដែលយកចិត្តទុកដាក់ជាងគេ ក៏ជាប់ចានចេះមើលជាប់ ចេះ
សរសេរទៅបានខ្លះ ។ គេសង្កេតមើលក្មេងដែលចេះរឿងចាំមាត់ហូរ
ហែ តែមើលគម្ពីរ ឬសរសេរផងមិនសូវគ្រាន់ទេ ។

ដល់អាយុ១៥-១៦ឆ្នាំ ក្មេងនោះក៏បានប្រែភេទចូលទៅបួសជា
សាមណេរ បាន ៥-៦ ឆ្នាំ ក៏បានបួសជាភិក្ខុភាព ឬមួយក៏ឪពុកមករៀប
ចំផ្ទះសម្បែងប្រពន្ធកូនវិញ ។ បណ្តាតាំងនោះ មានខ្លះមកប្រកបការ
ធ្វើស្រែ ខ្លះទៀតក៏បានទៅជាប់ផ្នែកបុណ្យសក្តិ បានធ្វើស្មៀនស្មេរមន្ត្រី
ជាច្រើន អ្នកដែលមានវាសនាសូត្រក៏បានចេះដឹងច្រើនច្រៀវដៃ ដោយខ្លះ
បានទៅរៀនទៅប្រទេសថៃ ។

ខ) ត្រង់ការរៀនសូត្រនៅសម័យនោះ, វត្តលោកសង្ឃជាសាលារៀន
ដោយលោកសង្ឃធ្វើជាគ្រូបង្រៀន ។ លោកសង្ឃជាអ្នកចេះដឹងជាង
គេក្នុងដំបន់ស្រែចម្ការ លោកប្រៀនទេសនាផ្សាយព្រះពុទ្ធសាសនាពីរឿង
ធម៌អាថ៌ ដែលសំដែងពីហានិភ័យនៃការធ្វើបាបនិងផលនៃការធ្វើបុណ្យ ។
ក្រៅពីនេះ លោកបានផ្សាយបង្រៀនជាដំបូង នូវសាស្ត្រាបញ្ជាក្រមៈ,

ក្ដើកាល, ពាក្យចាស់, សាស្ត្រាលៀង: ហង្សយន្ត, ស័ង្ខសិល្បជ័យ, មរណមាត, ជំនាន់ឆ្នាំ, លក្ខណវន្តាដើម ។

គ) កម្មវិធីសិក្សាកូនខ្មែរនៅសម័យនោះ ច្រើនជួបប្រទះស្ទើរតែគ្រប់គ្នា នូវការរៀនសូត្រវិជ្ជាផ្សេងៗដូចតទៅនេះ៖

១- រៀនមន្តអគមអូមអាមស្នេហ៍ នឹងរបៀនផ្សេងៗដូចរៀនធ្វើគ្រូ ហ្មាំធំពិសពស់ ពិសខ្លួយ ពិសត្រីកណ្តានជាដើម ដែលជាការពុំសមហេតុសមផល ចំពោះយើងក្នុងសម័យនេះ ។

២- រៀនក្លីហោរាយកាត់សប្តី ជាហេតុឲ្យមានពាក្យខ្មែរបុរាណនៅយ្រាប់ថា "កូតនៅហោរ ចោរនៅជាង" ។

៣- រៀនភ្លេងស្គរស្គឹងណាស់, មានចំនួនតិចដែលបានរៀនក្បាច់ចិន ហើយច្រើនទៅទេញាមេលេងជាភាសាចិនផង ។ គេរៀនតែលេងបួតគុណសង្ខ័ចតិចៗជាការចប់, ចំណាយពុំសូវឮរៀនផងឡើយ ។

៤- ខាងអក្សរសាស្ត្រវិញ គេរៀនច្បាប់ក្រម, ក្ដើកាល, កូនចៅច្បាប់ប្រុស, ច្បាប់ស្រី, សាស្ត្រាលៀង: លៀកជុច, ហង្សយន្ត, ស័ង្ខសិល្បជ័យ; គម្ពីរវេស: អកិធម្មត្ថាំបួនបរិច្ឆេទ, អកិធម្មត្ថាំតីរគម្ពីរ, មហាជាតក, មហោសថជាតក់ជាដើម ។ គេរៀនមើលជាច់ ដើរទៅយាយប្រុ.ប់គ្នាបានជាការចប់ ។ គេពុំសូវរៀនពិចារណាលើច្បាប់ទាំងអស់នោះ ឲ្យឈ្លៅយើញច្បាស់លាស់នូវហេតុនឹងផលឡើយ ។

ការសិក្សាអក្សរសាស្ត្រខ្មែរសម័យលង្វែកនឹងតួន មានរបៀប
ដូចបានពណ៌នាមកខាងលើនេះ តែបើពិចារណាយកអត្ថន័យរបស់
នៃអក្សរសាស្ត្រទាំងអស់នោះទៅយើញថា ភាពណាជាតិយើង
ជំនាន់នោះ បានខិតខំទ្រឹស្តីនិពន្ធឡើង ដើម្បីបំពេញតម្រូវការនឹងកែ
អង្គុតនៃប្រជាពលរដ្ឋខ្លួនឯង ឬដើម្បីធ្វើជាតតិជល់អ្នកមានជីវភាពរស់នៅ
តាមចំណោមណាមួយ នឹងដើម្បីធ្វើជាគោលច្បាប់ដម្បូន្មានខាងសីលធម៌
នឹងវិជ្ជាដ៏វែ: សម្រាប់ជាញ្ញាបតិសម្បជញ្ញៈនៃបណ្ដាជនឱ្យក្រាស់ក្រមតិតខុស
ជាក់ខ្លួនឯងតាមគោលនៃសម្ភាចិដ្ឋ ។ អក្សរសាស្ត្រទាំងនេះក៏មាន
មហិទ្ធិឫទ្ធិខ្លាំងណាស់ ចូលផ្សែតផ្សាយជ្រួតជ្រាបតាសតេញលើដែលប្រទេស
សូម្បីតែមាមញ្ញជនទៅទីកៀនកោះចុងចាត់មាត់ញាក ក៏បានទទួលរស
ជាតិអក្សរសាស្ត្រនេះដែរ ។

ហេតុនេះ បានជាគ្រាកដរង្គាតិជាលខ្មែរ ដោយចង់ឱ្យប្រទេសខ្មែរ
អាចរក្សាទុកបានយូរតែន្តែនតត ព្រមទាំងចង់ឱ្យតម្រិកប្រយោជន៍សំខាន់ ។
ដែលកើត ឡើងពីអក្សរសាស្ត្រពុកណានឹងទំនើប បានបង្កើតឱ្យមានពុទ្ធិក
វិទ្យាល័យត្រសុកម្រិត (សាលាជាលិ ៨ ខ្ពស់) នឹងក្រុមពុទ្ធសាសន-
បណ្ឌិត្យឡើង , ដែលហាទាំងពីរនេះមានទាំងបង្ហាត់បង្រៀនឱ្យដឹងនឹងដឹកនាំ
បណ្ដាជនជាតិខ្មែរទាំងគ្រហស្ថទាំងបព្វជិតឱ្យដើរទៅតាមវប្បធម៌ដ៏ប្រសើរ
ផ្នែកខាងសាសនានឹងអក្សរសាស្ត្របានចំរើនឡើងតាមលំដាប់ ឱ្យយើង

បានរយើញលទ្ធផលដាក់ស្តែងដូចសព្វថ្ងៃនេះ ។

ទៅក្រុមពុទ្ធសាសនបណ្ឌិត្យ មិនមែនត្រឹមតែមានន័យថាព្រះពុទ្ធសាសនាដោយការរៀបរៀងតែងនិងរៀបចំចោះពុម្ពផ្សាយ ទូរសៀវភៅផ្សាយលោកផងដែរមិនឡើយ ច្រើនមុខប៉ុណ្ណោះទេ ថែមទាំងបានបង្កើតឲ្យមានបណ្ណាល័យមួយរក្សាទុកនូវគ្រប់គ្រងអក្សរសាស្ត្រ គឺគម្ពីរជាសាស្ត្រាវាន ក្រាំង សៀវភៅស្លឹកខ្ចាត តម្រាប់តម្រាផ្សេង។ រយៈបុពណ៌ទាំងនេះជាច្រើន ។ ឯក្បួនច្បាប់អក្សរសាស្ត្រទាំងអស់ ដែលបានមកដាក់ទុកក្នុងបណ្ណាល័យនេះ គឺបានមកដោយសារសង្ឃរបស់ពួកពុទ្ធបរិស័ទ្ធនេះ បានមកដោយក្រុមពុទ្ធសាសនបណ្ឌិត្យចាត់ភ្នាក់ងារឲ្យទៅកត់ត្រាស្រាវជ្រាវប្រមែប្រមូលរកអំពីវត្តអាពាធ ភូមិ-ស្រុក តួច ធំនិគម ជនបទនានាក្នុងព្រះពុទ្ធអាណាចក្រទាំងមូលនេះ ។ ដូច្នេះយើងឃើញថាបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ជាឃ្លាំងមួយសំបូរបំផុតនូវឯកសារអក្សរសាស្ត្រខ្មែរបុរាណ សម័យលង្វែកទីក្រុង ទីរក្សាទុកនូវសៀវភៅស្លឹកខ្ចាតអក្សរសាស្ត្រទំនើបជាភាសាបរទេសទីភាសាខ្មែរជាច្រើន ។

សព្វថ្ងៃបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ដែលបរិបូណ៌ដោយឯកសារអក្សរសាស្ត្រច្រើនយ៉ាងដូច្នេះ បានក្លាយទៅជាបណ្ណាល័យប្រកបអក្សរសាស្ត្រ ជាឃ្លាំងវិជ្ជាជា វិជ្ជាហាន សម្រាប់ប្រជាពលរដ្ឋទីកន្លែងឆ្ងាយ

ចាំងផ្នែកគ្រហស្ថចាំងផ្នែកបព្វជិត តែងចេញចូលសិក្សា សាកសួរតាក្រោះរ៉ារកក្បួនច្បាប់កន្លងមុខ្លីរនេះជាហូរហែកល់ថ្ងៃធ្វើការ ។

ជាទីអាសោរ, យើងបានធ្វើអត្ថាធិប្បាយវែកញែកអំពីរបៀបការសិក្សាកិច្ចការជាស្នាដៃអ្នកជំនាន់មុន នឹងពណ៌នាអំពីមតិកអក្សរសាស្ត្រការជំនាញជំនាន់នោះ ដែលមានឯកសារដំកល់ទុកនៅក្នុងបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ជូនជនរួមជាតិស្គាប់អម្បាញ់មិញនេះ ដោយមានចំណាងចង់ណែនាំអ្នកមានគំនិតចាំងច្បាយ ឲ្យចូលចិត្តស្រឡាញ់អក្សរសាស្ត្រជាតិ ដែលជាកេរ្តិ៍ដំណែលនៃបុព្វបុរសរបស់យើង ព្រមទាំងចង់ឲ្យដឹងនូវដំណើរអក្សរសាស្ត្រពីដើមមកទុកជាគោលសម្រាប់កសាងអក្សរសាស្ត្រថ្មីឲ្យបានចំរើន ហើយឲ្យមានការប្រែកៗផង, នាំឲ្យយើងចេះប្រើការរិះគន់ដើម្បីប្រយោជន៍ជប់ខ្នងយើង គឺដៀសវាងការភ្លាត់ភ្លាំង ហើយកត់សំគាល់នូវសេចក្តីល្អត្រូវទុកជាឧត្តមាហរណ៍បង្រៀនតទៅអនាគត ។

-ចប់

× + ×

រឿងសព្វសិទ្ធិ

(តមក)

របស់ហ្មឺនពត្តីអក្សរភត់ លោកប៊ូ-ប៊ូ ប៉ិឡងតីណាស្ត្រាស្ទឹកវត

រីឯកូនស្រីនៃចោរនោះ លន់លុះបានឮពាក្យបញ្ជា អាពុកឲ្យរៀបគោជនា ខ្ជួលមិត្រភ្ងាច្រាំមួយតុ ។ ឲ្យបាននាប់ខ្ញុំបីយូរ នាងនឹកគិតគូរនឹងដាក់ ពិតាល់ធ្លល់ណាស់សែនវិតក្ក ម្តេចអកអាពុកពាលរៀបវេរ ។ ក្មៀវនៅឯ ណាមិនយល់ដាក់ ឃើញតែតីរោតមិនគាត់ខេ នឹងសួរឲ្យស្តែងត្រែង គាត់ដេរ នាងគិតគ្នាន់គ្នេរភ្ញាក់ក្នុងចិត្ត ។ ទើបតែងតាំងគិតសូដណ្តាំ រួច ហើយចិញ្ច្រាំបុកប្រហិត សម្ងប្រហើរឆ្ងាញ់ឈ្ងុយឆ្ងៃត ជាយសោតសឹង ស្រិតអង្គរស ។ ស្រេចដោះដួសដាក់គ្រប់តុតាំង សំរិតសំរាំងសម្រេចល្អ ច្រាំមួយស្លាកលើកឡើងបន្ទ តាំងជាយសម្ងប់បូណាបាន ។ គ្រានោះ នាយចោរដោះបិតា ស្រាប់តាញ ជាយចាប់ដាក់ពាន គ្រប់តាំងច្រាំមួយ ដោយប្រមាណ យល់មនុស្សមានច្រាណប៉ុណ្ណេះឯង ។ ហើយហៅ ចៅនោះមកកោត្តា ដោយក្តីស្នេហាទើបចាចែង ថាម្នាក់ដែលណាក៏ខ្ញុំ ឃើញស្តែង ឆ្លាក់មកកុំក្រែងគិតលែងថ្វី ។ បុរសនោះស្តាប់ស័ព្ទអកច្រាំយ ពីតាល់ធ្លល់ឆ្ងាយក្រែតតប៉ ក្នុងនេះម្តេចដឹងដល់ដើមក្តី ឬឃើញខេរ៉ុំទើប យល់ការណ៍ ។ គិតហើយហាមាត់ឆ្លាក់ច្រាំ មកតាំងគៀនអន់ឲ្យ កោត្តា ទើបចោរសួរទៀតទៅនាងថា ម្នាក់នោះតាលណានឹងឆ្លាក់មក

នាងនោះលុះឮគេថាដូច្នោះ ខញ់ចាស់អេះអុះខើបចាញ់ក សហាយតំ
មាត់ជាក់ដិតស្តួត ទឹងកែអ្នកឯណាដឹងថាអ្វី ។ មហាចោរហាហៅកូនក្រមុំ
មកជុំចំពោះរំពេចឡើ លោមថាម្នាលនាងកូនពិសី ចុះប្តីឯងម្នាក់
លាក់ឯណា ។ មិនហៅគ្នាមកបរិភោគផង ឲ្យតែគ្នាបានម្តងដូចប្រុាថ្នា
កូននោះលុះបានឮដំណា អៀនណាស់តែថាចាស់គំនិត ។ អម្បាលគេ
លាក់ខុកក្នុងមាត់ ម្តេចគាត់គង់ដឹងដំណឹងពិត បើអញទំលាក់គង់មិនដឹត
នាងតិតដូច្នោះអស់ប្រាជ្ញា ។ ខើបចាញ់សហាយចេញពីផ្ទះ សក់ដែលៗ
បន្ទះឥតសង្កា ចាស់ត្រង់ចាំងប្រាំមួយកាយា នាំគ្នាភោគ្គាចាំងក្រៃមក្រៃ ។ ឯនាយចោរនោះគិតសញ្ជឹង រំពឹងឆ្ងល់ដូចគេដំ ថាតុអញអើយ
ឥតគេសម ប្រឹងរំចិញ្ចឹមកូនស្តើរស្តាប់ ។ ត្រង់រូបត្រង់ប្រាណចាំងអស់
គ្នា បងឲ្យបានជាត្រូវនឹងឱប្បាប់ មិនគួរវៀរប្រៃកែក្រឡាប់ មកធ្វើបង្អាប់មុខ
ចាស់បាន ។ ឯអ្នកសម្លាញ់ពេញដួងគ្នា ស្រឡាញ់ភក្តីយោលើសខ្លួន
ប្រាណ បៀមខុកក្នុងម្នាត់គិតប្រមាណ ទឹកស្មានថាស្មោះចំពោះល្អ ។
តែគេមិនត្រូវនឹងនឹកឆ្ងៀត បៀមសហាយវៀតជាតិវេត ខ្ញុំទើបសម្លាញ់នេះ
ពេញក្រ ត្រូវទើបសៅដាមខ្ញុស្រួចថ្ម ។ ថាតូនាងខើបផ្តាំកូនស្រីនោះ នៃ
នាងនៅចុះកុំប្តី ឲ្យសុខសម្រាន្តក្បាន្តចិត្តស្រី កុំបីភ័យគិតគិតបិតា ។
ថាហើយនាយចោរលោលបគេច ទៅមួយរំពេចដល់បព្វតា ឡើងលើកំ
ពូលស្រែចការណា លោតចុះដីវាគឺក្បីណាស្រួយ ។ បុរសសម្លាញ់យើញ

ចោរស្លាប់ លោខឹកខឹងនាប់ត្បាវដើងដៃ ចាមេនមិញពេញចង្រៃ រាប្រែ
កែខៃហួសប្រាជ្ញា ។ បៀមក្នុងឆីមាត់ចេញក្សត់ឃាន ឱ្យប្រាណអង្គអញ
ពេញអសារ រស់នៅអាសាច័ន្ទស់ខ្មោចថា ស្លាប់តាមចោរប្រសើរគាប់ ។
ថាហើយដើរដល់កំពូលភ្នំ លោតចំក្នុងជ្រោះជាប្រញាប់ ធ្លាក់ខ្លួនផ្តិល
ផ្តាច់ដាវតាប់ បុរសនោះស្លាប់តាមចោរ ។

ឯកូនក្រមុំនៃនាយចោរ ភ័យស្ងោលោស្ទឹងរំពឹងថា អញនេះខ្លួន
ក្រែក្រមាត្រា ឥតតែបិតាមរណាជន្ម ។ ព្រោះអញទុច្ចរិតប្រព្រឹត្តខ្ពស់
យកម្រុសមកលាក់ធ្វើជាស្នេហ៍ ឯបុរសនោះព្រោះប្រពន្ធ ចិត្តចោរពុំដឹង
ទើមគាត់ស្លាប់ ។ ខ្លួនអញគិតទៅត្រូវកុំរស់ ដាមនុស្សមានឈ្មោះឥត
សារសព្ទ័ គិតភ្លាំងនាងឡើងលើកំពូលប់ លោតធ្លាក់ស្លាប់ធាប់តាមចិត្តា ។
ឯកវិយាចោរចិត្តមិត្តទ្រុស្ត ឃើញប៉ាត់នោះក្រៃយដីវ៉ា ភ័យកិតក្នុងចិត្ត
គិតឋប់ថា ប្តីអញមរណាព្រោះខ្លួនអញ ។ ស្រឡាញ់អញណាស់លើស
ខ្លួនគាត់ គាត់បៀមក្នុងឆីមាត់ព្រោះស្រឡាញ់ អញនេះចិត្តដូម្ចាស្លាញ់
រស់នៅឋង់ចាញ់ពេញអប្រិយ ។ ព្រោះខ្លួនបានជាធ្វើមិនត្រូវ គិតទៅគួរ
ស្លាប់តាមស្លាមី ចង់រស់ថ្លីទៀតចង្រៃតជី ថាហើយឃ្លាតខ្លួចេញមីមា ។
ទៅឡើងលើកំពូលភ្នំ លោតចុះស្លាប់ភ្លាមតាមវៀត ឯចៅសហាយពីរ
អង្គា ឃើញហើយគិតថាដោយតម្រិះ ។ ខ្លួនយើងប្រព្រឹត្តគិតកាមេ
ឥតែតេខឹងស្លាប់ដូច្នេ បងអើយអាក្រក់ពីដល់ម្ល៉ះ មិនចេះអាណិតចិត្ត

គេផង ។ ទំនៅធ្វើអ្វីអប្រិយឈ្មោះ ខឹងរស់ជាមនុស្សក៏សៅហ្មង ថា
ហើយនាំគ្នាដើរត្រសង ប៉ុនប៉ងធ្លុះផ្តាច់ដន្ទដីវ ។ លុះដល់លើកុំពូល
ខ្ពស់ លោតចុះកន្លងជ្រោះពីរកាយ កំណែកំណួយប្រលំយសូន្យសង្ខារ នៅ
ដើមបព្វតាំច្រាំមួយច្រាណ ។ ដំណឹងដឹងដល់ទៅដូនចាស់ ជាតំបូស
តាតតែតិតរំខាន ថាអញជាហេតុច្រាប់ដើមឯង ទើបបានជាគេសហាយ
គ្នា ។ មិនតែប៉ុណ្ណោះកើតហេតុត ជើងរឿងអន្ធកានធំតរំយោ នៃចៅ
បុរសថែមមួយគ្រា ឥឡូវមរណាក្សយតាំងអស់ ។ នេះគឺដើមហេតុពី
អញឯង សំដែងសំដីតាលមុនស្មោះ ខ្លួនអញសៅទៅមិនគួរសោះ គួរ
ស្តាប់ទៅចុះសៅធ្វើអ្វី ។ ថាហើយដូនចាស់តាត់ប្រញាប់ អត់ដង្ហើមស្លាប់
រំពេចទ្លី ដំណើររឿងនេះធួលសេចក្តី បវរិតានព្រះស្រីជួយគិតការ ។
អ្នកតាំងច្រាំតាំដែលស្លាប់នោះ ជាបេតមុំចំពោះបាននរណា ដូនចិត្តកន
តានទើបធ្វើយថា ត្រូវបានកុមារចៅសហាយ ។ ដែលទៅលបលួចកូន
មហាចោរ ព្រោះវាមេហេតិតទុជាយ នាំហេតុតាលតែគេតាំងឡាយ
អន្តរាយស្លាប់អស់តាំព្រោះវា ។

កាលនោះក្សត្រីស្រីប្រុស សុវណ្ណគេសរពៅពុងវា នាងគិតរំពឹង
កន្ធឹយ យល់ជាតានថាទុសសេចក្តី ។ នាងទប់ពុំបានមានវាចា
តបថាចៅចៅតានព្រះស្រី ម្តេចឡើយគ្រានេះចៅចេះស្តី ស្តីហើយ
ហេតុអ្វីកំទុសផង ។ បើបានជាថាឲ្យត្រូវ ដោយអ្នកសុចរិតពិត

ជាមួយនឹង ម្តេចគាត់ក្រឡាសចាស់គោនឹងឯ គាត់នោះឯងហោងជាហេតុដើម ។ ប្រាប់គេទៅគាចនឹងកូនចៅ ចិត្តគាត់មោហាមិនគិតស្មើមិនទេគាល់តែកូនគេដើម គេចឹងញ៉ាំរថ្មើមនាំគ្នាស្លាប់ ។ ផលកម្មផ្ទាប់ពៀរតំនើរនោះ ត្រូវបានគាត់ស្មោះនេះតាមច្បាប់ ជាក់ច្បាស់ច្នេះឯងមិនភ្លេចប្រាប់ ថាថ្នូរចោលម៉ាំពួនៃសត្វា ។

គ្រានោះពួកគ្រូដ៏តែងចាំស្តាប់ ក៏រុះរួនឮសំឡេងនាងចរចា ធ្វើយតបសេចក្តីបិបញ្ជា សឹងសោមនស្សពន់ប្រមាណ ។ ប្រគំតន្ត្រីបន្ទំសព្ទ អឺងអាប់កងពិនឹងប្រាសាទសាន ជ្រាបដល់ព្រះកាណិមហាស្តេចក្សត្តន្ត ទ្រង់ព្រះសណ្តាប់ប្រាណសោមនស្សា ។ ថ្ងៃនឹងពីក្នាត់ងាជានាយក្រុម នានាំសត្វសិទ្ធីទ្ធីក្ខា ចិតចូលទៅទៅជិតធីតា ដល់ជិតសន្ទិយាជាជាន់ក្នុង ។ ទើបទៅសព្វសិទ្ធិបុទ្ធីក្រៃ ដកយកដួងចៃបុទ្ធីរុង ពីតានព្រះស្រេចញាំពុលង់ទៅជាក់កងវង់ព្រះសន្ទិយោ ។ គ្រាន់ជាទុក្ខាយសួរប្រស្រ័យ ថាតើហ៊ានមានប្រាជ្ញា ចូរនាំនិតានមកឧបមា ឲ្យយើងស្តាប់ពាក្យសោះឯងដេក ។ ដ្បិតអីយូរយល់ដល់យាមបួន កម្មផ្តួនវង់ផ្តុកមួយវិរេក ស្រវេះស្រវោចលន្ទោចពេក គ្រាន់ទឹងតំរេកចិត្តខ្លះក៏ ។ គ្រានោះកំឯនឮសំឡេងឆ្លើយថាម្ចាស់ខ្ញុំអើយខ្ញុំនេះណា មិនអាចចេះពាក្យបញ្ញា ព្រោះគ្រាន់តែជាកំឯនថ្មង ។ សម្រាប់តេជាំនឹកំឯងប៉ុណ្ណោះ រឿងក៏មិនចេះមិនចូលចិត្ត បើម្ចាស់ចេះពាក្យកាសិត អាណិតនិយាយឲ្យស្តាប់ផង ។

កាលនោះក្សត្រីស្រីល្អឯក ឮពាក្យចំឡែកដល់ប្លន់ ឆ កាំងនន្តេបវាចេះសាសង ខ្លួនល្អដឹងតែតិតកង្វា ។ ជ្រាលាន់ឮគ្មានពាក្យព្រះស្រីស្តីបដិសេហើយគួរអស្ចារ្យ ឥឡូវកាំងនន្តមានច្រើនជា ឆ្នើងថាដូចម្តេចទៅខ្លៃតអេះ ។ ឯចៅសព្វសិទ្ធិប្លន់មាន រើសកេងិទាន់តាមតម្រិះ កាំងនន្តបូរចាំស្តាប់រឿងនេះ យើងិចេះតាមចាស់លោកអកច្រាយ ។ ថាកាលនោះមានស្រីប្លន់ម្នាក់ ប្រកបន្តូវលំក្ខណ៍ត័ក្រនោមធាយ សុទ្ធសឹងក្រមុំសមអង្គកាយ ស្នេមកពីឆ្ងាយសែងរកប្តី ។

ជួនមានកម្ម៉ោះចាំងប្លន់នាក់ សុទ្ធតែចិត្តស្នេគ្រងឆ្នាំចានស្រី ជួបគ្នាវេលានោះឯងឆ្នី តតបសំដីដោយស្នេហា ។ ប្រុសមួយសួរថាផ្ទះនាងឯង ខ្ញុំស្នេនកន្លែងនៅត្រង់ណា នាងមួយទើបប្រាប់ជាប្រស្នាចង្អុលហត្ថាត្រង់ដើងឆ្ងាញ ។

ប្រុសមួយសួរស្រីមួយទៀតថា ត្រង់ណានាងប្រាប់កុំអម្នេញ នាងនោះចាប់សត់ខ្លួបម្តុខវិញ ថាផ្ទះខ្ញុំមិញនៅត្រង់ណឹង ។

ប្រុសម្នាក់សួរស្រីមួយទៀតលង ថាផ្ទះស្រីឈ្នះត្រង់ណាដឹង នាងនោះសម្លក់ផ្តើមុខស្ងឹង លើកដៃទៅដើងឆ្ពិនឆ្ងីងផ្ទះខ្ញុំ ។

ប្រុសក្រោយសួរស្រីក្រោយទៀតថា ផ្ទះនាងត្រង់ណា ។ មាសមុំបងសួរដាក់ស្តេសុខុម បូរកុំបង្វែងក្លែងក្លាយថា ។ នាងនោះឮនស្តាប់ប្រាប់មកវិញ ថាផ្ទះខ្ញុំមិញនៅត្រង់ផ្សារ ទ្រហឹងនោះឯងផ្ទះខ្ញុំណា បើអ្នក

ត្រូវតារៀវគបុះ ។ បុរសស្ត្រីច្រាំបីច្រាណ លុះបានស្តាប់សាកពាក្យ
សាយសុះ, ដំនឹងសព្វគ្រប់គ្នាវេលានោះ ស្រេចវិលវិនឆ្ពោះដល់ទីហាន ។
ឯប្រុសតាំងប្តូនជួនពាប់ចិត្ត ចង់ស្និទ្ធគិតស្នេហ៍តែគ្រប់ច្រាណ នាំគ្នា
គោក្តាចុះយឺតបាន ស្រេចហើយសូវ្យធានកំជួនយប់ ។ ទើបចរបុះបេញ
ពីគ្រឹហា ស្រុតរូតគ្នានឈរឈឺនឹងយប់ គ្រាចរកប្រើនសាស្តុរសព្វ
គ្រប់ តាំងពីព្រលប់លុះយប់ជ្រៅ ។ មិនដឹងកន្លែងនៅត្រង់ណា លោ
លាន់មាត់ថាទុស្រីៗ ចង្អុលច្រាប់បងថានាងនៅ ដើរឆ្ពេញឥឡូវនៅ
ត្រង់ណា ។ បងស្តុះបងស្តែងរកព្រលឹង ម្ល៉ោះហើយសមទឹងក្រៃជីវ
ឯនាងមួយដែលយកហត្ថ មកខ្ចប់កក្តោនោះកំឆ្លៀ ។ មិនដឹងរើនឹងតាត់
ដូចម្តេច ខំគ្រាចតែដើរស្តើរជាច់ឡៃ គំនិតដែលគិតកំពុំដល់ ពុំដឹង
កិច្ចកលអាថិប្រស្នា ។ នាងមួយថាផ្ទះនៅត្រង់ដៃ រតែតែសង្ឃឹយខ្ញីច្រាជ្ញា
នាងមួយថាផ្ទះនៅត្រង់ផ្សារ ច្រហឹងនោះណារតែត្រ ។ ទុច្រូង
យើងអើយវិនរំខាន យ៉ាងមេះអស់បាននាងរូបល្អ បបួលគ្នាដើរស្តើរខេះក
ច្រហាំងមាត់ហត់ហៀបស្ងាប់ ។ មិនដឹងបើនៅរកត្រង់ណា ខ្លះថា
អង្កាលដែលគេច្រាប់ ប្រឹងគិតណាស់ដែរតែវត្តស័ព្ទ ច្រាជ្ញាវាគាប់
ខ្ញុំតាឆ្លើយតបទៅគួនអ៊ូ , ខ្ញុំហ៊ុយថា អ្នកចាំង ២ មិនដឹងឬថាអ្នកមានតម្រិះប្រាជ្ញាខ្លោះ ព្រោះបើនឹងដេកអង្គុយច្បាំងក្បែរទៅក៏ល្អ មិនបានឃើញកិច្ចការឯណាក្តី ក៏អាចនឹងតតាំងជំនះដល់សឹកសត្រូវបានបាន ឬខ្លួនយើងតាំង ២ កុំសារឥតខ្លឹមទុនបើខ្ជើយ ត្រូវអ្វីបានឮដូច្នោះហើយ ក៏និយាយនឹងខ្ញុំហ៊ុយថា បើយើងរំលងខ្ញុំតតាំងនេះ ក៏នឹងតាស់ដួងជីយើង ត្រូវធ្វើតាមពាក្យខ្ញុំរបងៈទៅចុះ បើមិនសមប្រកបដូចតំនិតប្រាជ្ញាដែលបានតាក់តែងនេះទេ ក៏ទៅមុខសឹមបន្ទោសតាមចិត្តយើងចុះ គួនអ៊ូ , ខ្ញុំហ៊ុយក៏លាទៅតាំទ័ពលំទៅប្រជុំខ្លួន ។

ពុនមេធីគំនិយាយទំនងខ្លាចថា រំលាត្រីកខេះ កងចំណែកហ្វូងពុន
ទឹងលើកមកដល់ហើយ សូមឲ្យលោកលើកគាហានយើងទៅតាំងនៅជា
កងដំណួយដូច្នេះទៅដើម្បីកុំអ៊ូសាន់ចុះ ពុំបាច់ទីដីតុក, ប៉ះហាន ទំនុំគុ-
មានទៅរក្សាស្រុក ហើយទំនងតែងតុឲ្យស៊ុនទៀនទំនងយ៉ាងលើកចេញ
ទៅខ្លួលលោកកណ្តាលនេះ ឲ្យគាហានស៊ុលៀងលេងសប្បាយចិត្ត
ខ្លាតិត្តពុនមេធីជាដូច្នោះគឺលើកចំណែកចេញទេ តែថាទៅមិនអស់សង្ឃឹម
ទំនងនេះទេចុះជាប្រាកដ ។

ឯកងចំណែកហ្វូងពុនលើកមកដល់ជាលក្ខណៈហើយ គំបាត់ចែង
ពួកគាហានទាំងពួងលើកមកជាលំដាប់គ្នា ឲ្យពួកស្បៀងលើកតាមមក
ជាក្រោយ ខ្លួលពួកត្រួលបន្ទើបដល់រាំលក្ខណៈ ត្រឡែកទៅមុខ
ឃើញធំធ្លុលីហុយទ្រលោមដូចផ្សែងទៅលើអាកាស ទើបឲ្យឈប់កង
ចំណែកាប់ការហើយឲ្យអ៊ុតមឃុំរក្សាគាហាន ឯហ្វូងពុនកំបរសេះស្រួត
ចេញទៅមុខ ត្រឡែកឃើញកងចំណែកដូច្នេះលើកមក ហ្វូងពុនគំ
អស់សំណើច គាហានទាំងពួងនិយាយថា ហេតុម្តេចបានជាលោកសើច ?
ហ្វូងពុនឆ្លើយថា យើងគិតដល់ពាក្យឈើស៊ុបានជាអត់សំណើចពុំបាន
ព្រោះឈើស៊ុអួតសរសើរតម្រង់ប្រាប់ជាពុនមេធី នៅចំពោះមុខមហាជនដ
យើងគឺបានឮដែរក្នុងថ្ងៃនោះ ថាបើដូចនិយាយស្គាល់ហួតទៅក្នុងគ
ការខ្លាំងក្រាមណែនបើ ឥឡូវយើងឃើញហ្វូងពុនមេធីរៀបរៀបកងចំណែ

លើកមកប្រហែលនឹងគាត ដែលលួងគ្មានប្រាជ្ញាសោះ ពុំនោះមើលទៅដេញហ្លួងអម្រឹតឲ្យតែចូលទៅក្នុងមាត់ខ្លា ពាក្យដែលយើងបានតាលខុតនឹងមហាឧបាសថា នឹងបាច់យកខ្លួនឲ្លៅពីខុងបេងឲ្យបាននោះ ឃើញនឹងសមប្រកបបេះយើងគ្រានេះជាប្រាកដហើយ ។ ហៃហ្ន៊ីខុនក៏បរពលស្រែតលើកចូលទៅ ។

ឯដួង្គឹងយើញដូច្នោះ ក៏បរសេះសូរចេញមកមុខតាហានចាំងពួងហៃហ្ន៊ីខុនក៏ស្រែកដេរថា ឯងនេះគោតលួងគ្មានប្រាជ្ញាសោះ មកនៅជាតាហានឲ្លៅតិ បិដូចជាខ្មោចជាប់សង្កែន ស្មែរកស៊ីតែត្រឹងសំណែនដែលគេសែនស្ទើរអត់ស្ទើរឃ្លាន ដួង្គឹងឮដូច្នោះ ក៏ខឹងណាស់ បរសេះចូលប្រយុទ្ធគ្នានឹងហៃហ្ន៊ីខុនបានប្រហែល ៩ ភ្លេង ក៏ធ្វើជាតាញសេះថយត្រឡេយ នាំតាហានចាំងពួងរត់ថយទៅ ហៃហ្ន៊ីខុនបានចំណាប់ក៏ដេញប្រដាច់ចូលទៅ បន្ទាយផ្លូវប្រហែល ៩០០ ស៊ិន (២០ គ៊ី) ហាន់លោកបរសេះទៅស្លាក់តាមុខហៃហ្ន៊ីខុនហើយឃាត់ថា សូមឲ្យលោកឆ្លើមង្គឹងឈប់ទៅវិនេះសិនចុះ ព្រោះដួង្គឹងនោះមានថ្លៃដាំងពួងតែណាស់ តប៉ុន្តែនឹងលោកមិនខាន់ខ្លឹយហាត់ប៉ុន្មាន ញាក់សេះរត់ចេញដូច្នេះជាការខ្លែកតែណាស់ មុខដាំងក្រឡេងបាយបង្ខំបាហានខុកចាំវាមកខ្លួបប្រសប់យកដំយំនឹងលោកទេដឹង ហៃហ្ន៊ីខុនឆ្លើយថា គោះបើដាំងដួង្គឹងនឹងធ្លើតលបង្ខិបាហានខុកប៉ុន្មានអន្លើក្តី យើងក៏មិនត្រូវញ៉ាញ៉ីតខ្លាច ហៃហ្ន៊ីខុនក៏

បរសេះនាំគាហានស្រូតតាមទៅ ចម្ងាយផ្លូវប្រហែល ៥០ សិនទៀត (២ គ.)។

ខ្ញុំតាយើញហៃហ៊ុនលើកគាហានជាប់តាមមកដល់តំនឹងគាន់ដូច្នឹង ដូច្នោះ កំឲ្យអុជផាវជាសញ្ញាឡើង ហើយកំលើកទ័ពដំឡូងចូលទៅជួយបំពេញគាហានផ្លូវឡើងទៀត ខណៈនោះហៃហ៊ុនយើញកងទ័ពរបស់ខ្លួនលើកទ័ពដំឡូងមកដូច្នោះកំអស់សំណើច ហើយប្រាប់ហាន់ហោថា ខុនហេងរៀបរាបៀបកងទ័ពបង្កប់ទុកដូច្នេះ អ្នកយើញហើយឬ? មុខត្មុះឲ្យខ្លាចណាស់ណា ពេលនេះយើងត្រូវស្រូតលើកទៅជាន់សង្កត់ស្រុកចិនអៀឲ្យបាន បើមិនបានយើងកំមិនសូមត្រឡប់ទៅឲ្យមហាបពរយើញមុខឡើយ ហើយហៃហ៊ុនក៏បរពលស្រូតតុំតំណាយចូលទៅទៀត ខ្ញុំតាំនឹងដូច្នឹងកំមិនបានតស៊ូ ធ្វើផារត់ថយត្រឡប់ទៅក្រោយវិញ ប្រហែលចូលក្នុងយាម ៣ ជាយ តើតព្យុះខ្យល់ធំនឹតមេឃដូចជានឹងធ្លាក់ភ្លៀង។

ឯអ៊ុតិមនឹងលីខៀន ដែលឃុំទាំស្បៀងលើកតាមហៃហ៊ុនមកជាក្រោយនោះ លីខៀនកំប្រឹក្សាគ្នាថា ឥឡូវកងទ័ពទាយយើង លើកកន្ទុងហួសចូលទៅក្នុងដែនស្រុកស៊ុនអៀរហើយ ពេលនេះកំយល់ឆឹតន្ទុះនឹងដើរទៅកំលំបាកមិនស្រួលសោះ សុទ្ធតែលុយភ្លក់លុយលាប់ដូច្នេះបើសឹកសត្រូវលបមកជុតក្តៀងឲ្យនេះពីក្រោយយើងឯ ខឹងមិនខាំគ្នាស្លាប់តាំងអស់ទេឬ? អ៊ុតិមធ្វើឥតបទៅលីខៀនវិញថា អ្នកនិយាយនេះត្រូវណាស់

បើដូច្នោះ អ្នកចូរនាំអ្នកលែសែងស្បៀងឲ្យឈប់នៅទីនេះសិន ខ្ញុំ
ទើងស្រួតទៅតាមឃាត់ហែហ្ហិខ្ញុំកុំឲ្យចូលទៅ លើខឿនយល់ឃើញត្រូវ
តំឃាត់តាហានដែលលែកសែងទាំងអស់គ្នាឲ្យឈប់ឋង្គំ ម៉ុងមកបំបរសេះ
ស្រួតទៅទាន់ហែហ្ហិខ្ញុំហើយឃាត់ថា លោកលើកពលតាហានលែង
ដែនចូលមកក្នុងស្រុកសុំនេះធ្វើហើយដូច្នេះ តៅមៃនេះជាយប់គ្រាត្រូវស្ងាត់
ទីរកក្លូវដើរពុំឃើញ លុំបាកណាស់ ក្រែកង្កាងមានកុំ ម្ចាងមានព្រៃស្តុក
ប្រសិនបើមានសឹកសត្រូវនៅតួនបង្គីប់ឯបដុតភ្លើង យើងកំទើងថ្លង់ការ
មិនខាន សូមឲ្យលោកបញ្ឈប់ទ័ពនៅទីនេះសិន ។

ហែហ្ហិខ្ញុំបានឮដូច្នោះ កំរ៉ាយស្តាប់តើទឹករលើកឃើញត្រូវ
ទើបឲ្យឈប់ទ័ពនៅទីនោះ ខណៈនោះរុក្ខាហានទើងតួនបេង ដែល
លើកតាហានម្ភាក់ ៥០០ ចង្កាប់ទៅសង្កាត់ឆ្លងនោះ កំអុជក្លើងនេះឡើង
ត្រមត្រា ឯតួនអ្នកដែលលើកតាហានទៅបង្គីប់នៅពីក្រោយ ឃើញតួន
ភ្លើងពីទិសទាំង ៤ ដូច្នោះ ត្រែកំភ្លាំងខ្សល់ត្បុះខ្ទាំង កំស្រែកហៅ
លើកតាហានចេញមកវុកបំពានចូលទៅ តាហានហែហ្ហិខ្ញុំកំតក់ស្តុត
ទាំងគរគ្នា តៅជាក់បែកជាន់គ្នាស្ទាប់ជាច្រើបល់ ខ្លះតៅចេញពីភ្លើង
មិនមាន កំនេះពេលស្ងាប់ ពាប់តែស្ងាប់ក្នុងភ្លើងនោះច្រើនណាស់ ដួលឡើង
ឃើញជាន់ចំណាប់ កំដេញតាហានត្រឡប់ចូលមកវិញ ហែហ្ហិខ្ញុំ
ថ្លង់ការទើងមកតស៊ូវិញកំមិនខាន់ ទើបរបសេះស្ទុះពារចំលាយថយ

ទៅ ឯលុយខ្មៀនដែលនាំស្បៀងជាតដែរគ្រាយក្រោយក្រែងឃើញគួនអ្វីវាយ
ខ្ជប់មកពីក្រោយក៏បានតស៊ូជាយូរណាស់ ប៉ះទាំងមិនបានតបវាសះ
ថយវាត់ទៅ ។

ហៃហ្លើអានធីដីហានហ្នេ ដែលទៅក្នុងដែនដីខ្ទុះក៏ញាក់សេះរៀល
ត្រឡប់មកក្រោយ ប្រាថ្នាធីដួយការពារស្បៀងឲ្យផុតពីភ្លើង ខ្ជួល
ឃើញខ្មៀរហ៊ុយយកគួនចាក់ហៃហ្លើអានញាក់ដីះសេះស្ទាប់ ហាន់ហៃ
យល់ថាធីដីតខ្លាំពុំបាន ក៏ញាក់សេះវ៉ះវាត់ចេញទៅ ឯពលគាហាន
ខាងខ្មៀរដែលនៅសល់ពីស្ទាប់ចាក់តាប់សម្លាប់គាហានហៃហ្លើខ្ទុន ក្នុងពេល
យប់នោះឈាមហូរបែកតពុះពេញតាំងព្រៃដីវាល ខ្មោចគឹស្ទាប់ដួចរាត
ក្រាលគារលើគ្នា បីដូចគំនរក្បាលមុស លុះព្រឹកឡើងស្មានដែរហៃហ្លើខ្ទុនបាន
គាហានដែលនៅសល់ពីស្ទាប់បែកទៅនោះ ក៏នាំគ្នាលើកត្រឡប់ទៅ
ស្រុកហ្លើគោវិញ ឯគួនអ៊ូ, ខ្មៀរហ៊ុយ, ជួឡុង លុះមានជ័យដ៏ខ្លះ
ហៃហ្លើខ្ទុនដូច្នោះ ក៏នាំគ្នាគោតសរសើរតម្រេះប្រាជ្ញាខុងជឺរបងថា ចេះ
រិះគិតប្រាកដពិតមែនហើយ ។

ឯខុងជឺរបងលុះព្រឹកព្រាងស្មានព្រះសុរិយា គឺតែងខ្ចងយ៉ាងសុភាព
ឡើងជិះរទេះគួចមាច ១ ហើយនាំគាហានឲ្យរែកសែងតុតាំង ទីរត្រឿង
អាហារចេញមកតាមឡៅពី លុះឡៅពី, គួនអ៊ូ, ខ្មៀរហ៊ុយ, ជួឡុង,
លើកទ័ពត្រឡប់មកផ្លូវធីដីខុងជេងកណ្តាលឆ្ងាយ ក៏មានសេចក្តីត្រេកអរ

សាខរណាស់ ទាំងគាំងអស់ចូលទៅតំនាប់ខុនបេង។ កំឡុងរៀបចំណែ
អាហារឲ្យបណ្តាពួកជាហានខោះបរិភោគគាំងអស់គ្នាជាទីសប្បាយ រួចក៏
លើកត្រឡប់ចូលទៅក្នុងស្រុកសុំនអៀវិញ ។

សាមកុកខ្សែ ៣៦

តាំងតីទៅតីខុនបេងប្រឹក្សាគ្នា ហើយបែហាហ្គីខុនទៅដល់ចូនួ ។
លើកទោស គិតលើកទ័ពមកវាយទៅតីពីខែត ទៅបៀរស្ទាប់
ចូនួលើកទ័ព ទៅវាយស្រុកសុំនអៀ ទៅតីតេះចេញទៅស្រុក
សុងយ៉ុង ។

ខុនបេងក៏និយាយនឹងទៅតីថា លោកមានដំណើរបែហាហ្គីខុនគ្រា
នេះ លោកកុំគាលត្រេកតរសេប្បាយឡើយ ព្រោះខ្ញុំជ្រេលាំ ចូនួ
នឹងលើកទ័ពមកខែត តបកំហឹងនឹងសងសឹកលោកវិញជាក្រែកដ ទៅតី
ក៏សួរថាបើដូច្នោះ លោកនឹងត្រូវគិតប្រការម្តេច ទាំងខែត
ខុនបេងថា
ដែលខ្ញុំរិះគិតតស៊ូនឹងចូនួនោះ កំលាំងនឹងកែខ្លាចាន ទេ
តែមកឃើញ
ថាស្រុកសុំនអៀនេះតូចចង្អៀតណាស់ នឹងគិតការពារចាន ជាយក្រ
តឡប់ទៅបៀតើឈឺជួនណាស់ទៅហើយ ដើមឡើយគំចាន តនុញ្ញាតនុក
ចានឹងឲ្យស្រុកតេងជាវិមកលោក គ្រានេះបានខ្លាចខ្មោចស្លួចហើយ បើប្រ

ប្រសិនជាលោកធំឯងលើកទៅស្រុកកេនដ៏វគ្រានេះ គោះបើចូរធ្វើឯងលើក
កងទ័ពតាមកយ៉ាងណា ក៏ធំដ៏ជាន់រៃគិតការផ្ទាស់ប្តូរតស៊ូច្បាំងជាន់យ៉ាងមាំ
គ្រោះស្រុកកេនដ៏វនោះធំខ្លាយស្រួលណាស់ ។

ឡៅតឹតបថា លោកមានប្រសាសន៍នោះត្រូវហើយ តែថាឡៅ
បើវាមានឧបការធំដ៏ខ្ញុំមកតាំដើមជាច្រើន បើធំឯងលើកទៅគ្រានេះ ក៏ដូចទៅ
ដណ្តើមយកស្រុកគេទៅ ខុងបេងតបថា ដែលខ្ញុំពាយមកនេះ មិនមែន
ឲ្យលោកទៅធ្វើអាក្រក់ដល់ឡៅបើវានោះទេ គ្រោះស្រុកកេនដ៏វមុខជា
ធំដ៏ឆ្ងាយមកលោកជាប្រាជក គោះបីលោកមិនលើកទៅតាមខ្ញុំពាយ ឃ្លាទៅ
ក៏ធំដ៏មានអន្តរាយ ការណ៍ណាមានហេតុឡើង លោកត្រូវធំដ៏ជ្រាបតាមការ
ដែលខ្ញុំថ្លែងដំណឹង ឡៅតឹតថាគោះបីតែយអន្តរាយមកដល់ខ្លួនយើងដោយ
ប្រការម្តេចៗក្តី យើងក៏ស៊ូតែស្ងាប់តាមកម្មផល ដែលធំដ៏ទៅមិលគុណគេ
នោះ មិនត្រូវសោះឡើយ ខុងបេងតបថាដែលលោកមិនគេញ៉ាំគ្នាធំដ៏ធ្វើ
តាមខ្ញុំបាទ ក៏តាមតែអធ្យាស្រ័យលោកចុះ សឹមខ្ញុំបាទធំឯងគិតប្រែប្រួល
ទៅវិញ ។

ឯលៃហ៊ូខុងលុះលើកតាលទៅដល់ក្រុងហ៊ូតោ ក៏ចង្ខ្លួនឯងចូលទៅ
ដល់ចូរដោយគំនាប់ថា ឥឡូវគោសខ្ញុំបាទដល់ខ្លួកសេចក្តីវិនាសដ៏វិត
ហើយគ្រោះខ្ញុំបាទមានសេចក្តីប្រមាទមិនជាន់ដឹងតួទាយខុងបេង ទើប
ខាតបង់តាលរហ៍ច្រើនគាំដម្ងើរ ការណ៍ខ្ញុំបាទធំដ៏លើកចូលទៅនោះក៏ជាន

សញ្ញាមុកថា ចៃម៉ាមិនបានខ្វះនៅឡើត, ខុងបេងមកជូនលោកខេ ខ្លឹងឲ្យលោកកាត់ក្បាលខ្ញុំបានដំនួស ខ្លួនខ្ញុំបានកំយើញថាខុសមែនហើយ តាមតែលោកខ្លឹងធ្វើចុះ ។

ចូរឲ្យយើញហៃហ៊ីខ្លួនធ្វើចោសខ្លួនឯងដូច្នេះ កំន័តគួរឲ្យមានចិត្តអាណិតណាស់ទើមឲ្យស្រាយចំណងដែលចងនោះចេញហើយថា ដែលអ្នកខៅធ្វើសង្គ្រាមឲ្យថ្លស់តារដល់សឹកសត្រូវដូច្នេះចោសអ្នកក៏ដល់ថ្នាក់ស្លាប់ តែថាខ្លួនអ្នកមានគុណតាប់ឆ្នាប់ធ្វើការសង្គ្រាមមកពីមុនជាច្រើន ចោសនេះយើងត្រូវលើកឲ្យរួចមុងខៅចុះព្រោះធម្មតាជាតិពាហានធ្វើការសឹកសង្គ្រាមកំរមែងមានចាញ់មានឈ្នះដាវគ្នាដូច្នេះ ហៃហ៊ីខ្លួនឮដូច្នេះកំសោមនស្សរីករាយខ្លួនគំនាប់ហើយថា ខ្ញុំបានលើកទ័ពខៅគ្រានេះអ៊ុតមនីងលើគ្នាកំបានរំភុកជាស់តឿនស្មារតីដែរ តែថាខ្ញុំបានជាមនុស្សអប្រិយរឹងរូសប្រទូស្តយកតែតាមអំពើចិត្តឯងឯ ទើបថ្លស់តារដូច្នេះ ព្រោះមើលងាយប្រមាទ ។

ចូរឮដូច្នេះ កំឲ្យបំណាច់ផ្តើមដល់ម៉ុតមនីងលើគ្នាជាច្រើនហើយថាសព្វថ្ងៃនេះ យើងអានេះសមក្តីបរិតក្តណាស់ ព្រោះឡៅតីនីងស៊ុនគួន ២ នាក់នេះមានតំណាំលើសលុប ក្នុងតីនេះយើងគ្មានត្រួយជាម្ចាស់នេះឥឡូវនេះការសឹកសង្គ្រាមកំបានធ្វើជាប់ដៃខ្លួនមកហើយ ទីនតីតំបាត់ឡៅតីនីងស៊ុនគួនចេញឲ្យបាន ទើបដែនដីនីងបានរាបបាជាសុខតរៀ. ត្រា

ខេត្តចូលកំឡុងគ្រប្រមូលតាហានបាន ៥០ ម៉ឺន តាំងឡើងពោធិ៍ចិនធំ ពោធិ៍ឆ្លើតតែ ១០ ម៉ឺនចេញទៅជាកងទ័ព ឡេវៀរលៀវ, ខេត្តទាបលើកតែ១០ម៉ឺនចេញទៅជាកងទ័ព ២. ឡៃហាប៉ាំងនិងហែហ៊ីរៀនលើកតែ ១០ ម៉ឺនចេញទៅជាកងទ័ព ៣, ឡេអ៊ីតមានលើខ្នើនលើកតែ ១០ ម៉ឺនចេញទៅជាកងទ័ព ៤, ឡេខាងលើកតែ ៣ ភាគចេញទៅជាទ័ពស្រួចសម្រាប់ស៊ើបស្ទង់ស្ទាប់ការ ឯចូនោះលើកតែ៦ម៉ឺនជាទ័ពហ្លួង ។

រីណាគាលចូលកំពុងកេណ្ឌកងទ័ពនិងលើកទៅ គ្រានោះព្រះលៀហៀនតេរោយភជសម្បត្តិបាន ១៣ ឆ្នាំ ជារដូវខែស្រាពណ៌ទាងនិងខ្មែតបានចូលក្បែរស្តេចនិងឡេលើកកងទ័ពចេញទៅ ខណៈនុងយ៉ាងចូលមកដំណាលថា ដែលរាជានិងលើកកងទ័ពទៅកំចាត់ឡៅតីគ្រានេះ ខ្មៅតីកំពុងតូចគ្រានេះ ពួកវង្សព្រះចៅហៀនតេជាការមិនគួរសោះឡើយ ឯស៊ុនគួនខ្មែតស្គាតកីបានតាំងភូមិហានមានតាហានតលរហ៍ជាមាំមួន ហើយមានស្រុកចំណុះសម្រាប់ឯក ៦ មណ្ឌល ពលយោធាក៏ច្រើន ឯក្តីនិងទោះនោះក៏ឆ្លាយជាច់ស្រយាល ដែលមហាទិពភជមិនលើកទៅគ្រានេះ ខ្លាចមិនបានកលការដាតុកាសល្អនិនខ្លួចតុរហ៍ឥលជាច្រើន សូមឡើលោកត្រិះរិះគិតមើលតាមគួរសិនចុះ ។

ចូតូបានឮដូច្នោះក៏ឆ្លើយតបថា ដែលអ្នកមកឃាត់យើង មិនឡើលើកទៅកំចាត់ឡៅតីនិងស៊ុនគួនទោះមិនត្រូវសោះ ព្រោះមនុស្សតាំង ២

នេះជាអត្តភាពអាត្រក់ណាស់ ថាហើយក៏ចាំណាញខ្លួនយ៉ាងចេញថា អ្នក
ឯងកុំមកចរចាដូច្នោះតទៅទៀត បើមិនស្តាប់យើងនឹងកាត់ក្បាលចេញ
ខ្លួនយ៉ាងយើញចុងខ្លឹងដូច្នោះ ក៏ក្រោកចេញទៅឆ្ងាយហើយដក
ដង្ហើមធំថា មហាឧបាសនេះជាមនុស្សមិនតាំងនៅក្នុងសត្យសុចរិតសោះ
បើខ្លួនតែទៅធ្វើការប្រកួតស្តូអ្នកដែលត្រង់ល្អក៏គង់នឹងវិនាសទៅឯង ។

ខណៈនោះខ្លួនស៊ីដែលជាទេសហរិត្តាទីឯខ្លួនយ៉ាងនោះ បានឮ
ខ្លួនយ៉ាងនិយាយដូច្នោះ ក៏យកសេចក្តីនោះទៅក្រាបបង្គំទូលថា ខ្លួនយ៉ាង
នេះជាមនុស្សមិនល្អសោះ លបនិយាយដើមពីលោកអាត្រក់ផ្សេង ។
ហើយតាលត្រយ៉ាងនេះមិលងាយប្រមាថលោកនោះ ក៏ព្រោះខ្លួនយ៉ាង
ញុះញង់ឲ្យនិយាយ បង្កូតដូច្នោះ ក៏ចូលចិត្តដឿមានសេចក្តីខឹងក្តៅ
ណាស់ ទើបប្រើឲ្យទាហានទៅចាប់ខ្លួនខ្លួនយ៉ាងប្រហារជីវិត មនុស្ស
ស្មើខ្លួនបស់ខ្លួនយ៉ាងយើញដូច្នោះ ក៏តេះទៅក្រាបដល់បុត្រខ្លួនយ៉ាងទាំង ៤
នាក់ថា ឥឡូវមហាឧបាសចាប់យកបិតាអ្នកទៅសម្លាប់ហើយ ហេតុ
ដូចម្តេចអ្នកនៅលេងប្លាស្តាត្រឹមយូច្នោះ មិនខ្វាយស្លាប់ទេឬ បានជាមិន
គិតរត់ចេញ ។ បុត្រខ្លួនយ៉ាងទាំង ៤ នាក់ឆ្លើយតបថា ដែលអ្នកអាណិត
ខ្លាំដំណឹងមកឲ្យយើងដឹងដូច្នោះ ជាគុណគាប់បបស់អ្នកជាខ្លាំងណាស់
តែជាធម្មតាសត្វប៉ុន្តែទាំង ៤ ពួក
ដែលសំពាលពង់មកនៅក្នុងសំបុកហើយ
ក៏

(មានត)

គណៈប្រតិភូខ្មែរទៅសាសនា
ទៅរួមក្នុងពិធីបុណ្យ ព. ស. ២៥០១ នៅប្រទេសជប៉ុន
តាមដំណឹងដែលបានជូនពីថ្ងៃមុន

កាលពីខែមេសាមុននេះ ព្រះពុទ្ធសាសនិកជាលក្ខណៈបានចាត់គណៈប្រតិភូ ១ ឱ្យទៅរួមក្នុងពិធីបុណ្យ ព. ស. ២៥០១ នៅប្រទេសជប៉ុន, គណៈប្រតិភូនេះ បានត្រឡប់មកវិញហើយ ក្រោយដែលបានធ្វើបុណ្យនោះរួចស្រេច ។

មុនទីនឹងចេញដំណើរត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ, លោក រស្មី ន· ចឹម ប្រធានគណៈប្រតិភូខ្មែរ បានធ្វើសេចក្តីថ្លែងការណ៍មួយ ជូនដល់ស្ថានឯកអគ្គរាជទូតខ្មែរ សុំឱ្យចុះផ្សាយតាមសារព័ត៌មាននានានៅក្រុងតូក្យូ មានសេចក្តីដូចតទៅនេះ ៖

យើងជាគណៈប្រតិភូខ្មែរ ដែលព្រះពុទ្ធសាសនិកជាលយើងបានចាត់មក ដើម្បីជាតំណាងប្រទេសខ្មែរ ក្នុងពិធីបុណ្យ "ពុទ្ធជយន្តិ" នៅប្រទេសជប៉ុន យើងមានសេចក្តីសោមនស្សរីករាយជាអំបំផុត ដោយបានមកចូលរួមប្រជុំក្នុងពិធីបុណ្យពុទ្ធសាសនាដ៏ឧត្តមឆ្ងាយនេះ ដែលចាប់ផ្តើមនៅក្រុងតូក្យូពីថ្ងៃទី ២៧ ទៅដល់ទីនឹងថ្ងៃទី ៣១ ខែមីនា ១៩៥៨ ហើយ

នៅទីក្រុងនានា ក្នុងប្រទេសជប៉ុនពីថ្ងៃទី ១ ទៅលើនឹងថ្ងៃទី ៩ ខែមេសា ១៩៥៤ ។

ការដែលបានតំណាងប្រតិភូ ឲ្យនាំនូវការប្រុស្រាយជាតាតរកាត របស់ព្រះមហាក្សត្រយើងទាំងពីរព្រះអង្គ, របស់ព្រះរាជរដ្ឋាភិបាល នឹងរបស់ប្រជាពលរដ្ឋខ្មែរ ព្រមទាំងសេចក្តីគោរពដ៏ជ្រាលជ្រៅរបស់ពុទ្ធ-សាសនិកជនខ្មែរ មកកាន់ពិធីបុណ្យឆ្លងឆ្នាំមហោឡារកនេះ, គេអាចសំគាល់ថា ប្រទេសកម្ពុជាបានឈរលើឫសនូវតម្លៃយ៉ាងខ្ពស់បំផុតនៃមហាសន្និបាតរំលឹកដល់ ព.ស.២៥០០ ហើយគេអាចសំគាល់ទៀតថា ប្រទេសកម្ពុជាទាំងមូលបានចូលរួមរួម ដោយស្មោះចំពោះទាំងចិត្តទាំងកាយជាមួយនឹងអ្នកដែលប្រតិបត្តិតាមពុទ្ធឧប៉ាទាំងអស្សាលមាននោះ ។

ម្យ៉ាងទៀត ដោយសារការអញ្ជើញពីតំណាងកម្មការបុណ្យទាំងនោះ, គេអាចឧកពេលនេះ ជាឱកាសមួយយ៉ាងថ្លៃថ្លាបំផុត ហុចមកដល់យើងរាល់គ្នាជាតំណាងប្រទេសនានាបែកខាងអាស៊ី ឲ្យយើងបានមកជួបជុំគ្នានៅក្នុងប្រទេសជប៉ុន មិនត្រឹមតែធ្វើសក្ការៈបូជានឹងស្តាប់ជាមួយជនជាតិជប៉ុន នូវពុទ្ធឧប៉ាទដែលព្រះបរមគ្រូបានប្រទានប្រដៅឧកមកចំនួន ២៥០០ឆ្នាំហើយប៉ុណ្ណោះទេ គឺថែមទាំងជាឱកាសមួយនាំឲ្យយើងរឹតចំណងមិត្តភាពនឹងសហការខាងសាសនា ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋរៀងៗប្រទេសនានារបស់យើងរាល់គ្នាទៀតផង ។

ពិធីបុណ្យ « តុន្នដយន្តិ » នៅប្រទេសជប៉ុន ដែលបានតាក់តែងឡើងយ៉ាងសម្ផើមនោះ, គួរនឹងជាព្រឹត្តិការណ៍មួយយ៉ាងធំនៅក្នុងប្រវត្តិសាស្ត្ររបស់តុន្ទិកតិកតាលោក ។

យើងជាតណាៈប្រតិកូខ្មែរ ជាន់នៅជួបប្រទះគ្រប់របៀបតិធីដែលគេបានរៀបចំធ្វើនៅទីក្រុងតូក្យូ ទឹងទីក្រុងនាគក្នុងប្រទេសជប៉ុន ដូចជាទីក្រុងតូក្យូ, ណាហ្គ៉ា, អូសាកា, ណាគោយ៉ា ទឹងទីសឺកាហ៊ូ ដោយគម្ងាងប្រើខញ្ចីកញ្ចាប់ចំផុត ។

យើងបានសំគាល់យើញថា ធម្មព្រះពុទ្ធនៅប្រទេសជប៉ុន គេបានថែរក្សាយ៉ាងខ្ជាប់ខ្ជួន ឲ្យទោរសរវែក តាមប្រពៃណីប្រទេសរបស់គេ ។

យើងមានសេចក្តីពេញចិត្ត ទឹងមានសេចក្តីគោរសរសើរ ដ៏ជ្រាលជ្រៅបំផុត ចំពោះតិធីផ្សេង: ដែលគេបានតុបតែងធ្វើពិធីអម្ពាលមាន ។

គ្រប់ទីគ្រប់កន្លែង ដែលយើងជាតណាៈប្រតិកូខាងបានៈទៅកាន់ពិធីប៉ុន្មានៗនោះ, យើងបានទទួលទទួបដិសន្ថារកិច្ចយ៉ាងជិតស្និទ្ធជាចំបំផុត អំពីតណាៈភម្ចាធិការបុណ្យ, អំពីព្រះសង្ឃនឹងគ្រហស្ថ, អំពីសាធារណជនជាតិជប៉ុន ដែលជាមិត្រយើង, ក្រៅពីនេះមានបដិសន្ថារកិច្ចយ៉ាងធំៗទៀត ដែលវិវេនៅទីក្រុងតូក្យូ បានរៀបចំជាកិត្តិយសដល់យើងកល់ខ្លា ។

យើងសូមថ្វែងនូវកតញ្ញូតាធម៌ដ៏ក្រាលក្រៅ ចំពោះការអញ្ជើញ
ជាមិត្តភាពទាំងអម្បាលម៉ានទោះ ហើយនឹងអំណរគុណយ៉ាងក្រៃលែង
ចំពោះបដិសន្ថារកិច្ច ដែលគេបានធ្វើចំពោះយើងគ្រប់ពីរនៃនេះ, យើង
សូមសំដែងនូវគោរពភាពចំពោះជនទាំងអស់ ដែលមានឥទ្ធិសំណាងបាន
ទៅប្រជុំក្នុងឱកាសពុទ្ធជយន្តីនេះ ។

ទៅមិត្តអ្នកស្នេហ, យើងសូមប្រសិទ្ធិពរសេចក្តីសុភមង្គលយ៉ាងស្មោះ
ស្ម័គ្រ ដើម្បីសេចក្តីសុខចំរើនដល់ប្រជារាស្ត្រទៅ, ដើម្បីមហិទ្ធិឫទ្ធិដល់
បហាប្រទេសជាប៉ុន ទីន ដើម្បីសន្តិភាពដល់ពិភពលោក !

ធ្វើនៅក្រុងតូក្យូ, នៅថ្ងៃទី ៨ មេសា ១៩៥៨

ហត្ថលេខា : ឃៀន-ចឺម

ប្រធានគណៈប្រតិភូថ្វៃនៃពិធីពុទ្ធជយន្តីប្រទេសជប៉ុន

———លទ្ធផលនៃការរួមប្រជុំ

ការរួមប្រជុំអ្នកតំណាង
ប្រទេសបែកខាងពុទ្ធសាសនា
ដើម្បីស្រុកជប៉ុនពេលនេះណា
ឃើញថាចម្រើនសន្តិធម៌ !

ចាប-តិន

(តទៅ)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អជិតិប គុ. ដែលមិនលោភ ។

អជិតិ គុ. ដែលមិនឈ្នះ, ដែលឋាប៉ុ; ប៉ុ. ព្រះឥន្ទ្រ។ - ភ្ជ្ជតា ស្ត្រី. ភាពនៃទាសៈគឺម្ចាស់មិនតឹងរុំង, ភាពនៃទាសៈគឺម្ចាស់បណ្តែតបណ្តោយឲ្យ ។ អជិតាត្ម គុ. ដែលមានអាត្មាចាប់ហើយ ។ អជិតេន្ទ្រិយ គុ. ដែលមានឥន្ទ្រីយ៍ចាប់ហើយ។

អជិន នបុ. ស្បែក (ទ្រឹតខ្មៅ); ស្បែក, ស្បែកសត្វទ្រឹត; ហិបស្បែក ។ អជិនាវតិន គុ. ដែលរុះស្បែកពាក់ស្បែក ។ - រត្ន នបុ. ទៃព្លែកវិសេស ។ - វាសស គុ. ដែលស្បែកពាក់ស្បែក ។

អជិរ នបុ. អណ្តូង, ឡា (មុខគេបាផ្ទាន, ស្រះទៀន; សមរភូមិ ។ - វតី ស្ត្រី. ដៃទទេគ្មា ។

អជិហ្ម គុ. ដែលមិនកោង, ត្រង់ ។ - គ គុ. ដែលទៅត្រង់; ប៉ុ. ព្រឹ; ព្រួញ; សរ ។ - ចារិន គុ. ដែលប្រព្រឹត្តត្រង់រឹង។ - គ គុ. ដែលមិនមានពុតអាក្រក់នឹងមិនលាក់ពុត, ដែលមិនមានពុតឆ្មុត ។

អជិហ្ម គុ. ដែលមិនមានអណ្តាត ។

អជីគតិ ប៉ុ. តាមឫសី ។

(នៅមានត)

ភគ្គិយសុត្តន្ត

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ៥ ខែឧសភា

ព.ស. ២៥០២ គ.ស. ១៩៥៩

ក្នុង ៣ ក្បាល



ភ្នំពេញសន្ទេសារ

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	– វេរុបសមកថា របស់ព្រះគ្រូញាណមុនី ឡេង-ភម	៤៨១
	– ពេលកាលធម៌ របស់ព្រះមហា មាស-សុមន៍	៤៨៤
	– សុវេជាតក (តមក) លោក ជឹង-រឹង បម្លែងពីសាស្ត្រស្លឹកឥតឹ . . .	៤០៩
ផ្នែកអក្សរសាស្ត្រ		
	– រឿងសព្វសិទ្ធិ (តមក) របស់ហ្មឺនភក្តីអក្សរ តន់ លោក ប៊ូ-ប៊ូ ចំឡងពីសាស្ត្រស្លឹកឥតឹ	៤២១
	– រឿងហង្សយន្ត (តមក) លោក អឹម-ភន បម្លែងពីសាស្ត្រស្លឹកឥតឹ	៤៤៧
	– អំពីល្មោនស្បែក អ្នកស្រី ពេជ្រ-សល់ រៀបរៀង	៤៥៧
	– ការកាងវៃនៃបឋក ភិក្ខុ ម៉ែន-រៀម រៀបរៀង	៤៦៣
	– រឿងសាមកុក (តមក) ឧកញ៉ា ឆ្ង-ភន ប្រែ	៤៦៩
ផ្នែកកំណាត់ទីប្រវត្តិការណ៍		
	– ពិធីប្រពៃណីព្រហ្មទាន់ដោះសមណទិស្សឥត រៀបរៀង . .	៤៧៤
	– បុណ្យនមស្ការ ព្រះសាស្ត្រទុនចេតិយ លោក ចាប-ពិន រៀបរៀង	៤៨៣
	– វិចនានុក្រមសព្ទខ្មែរ-ខ្មែរ (តមក) ព្រះមហា ជាំង-ទាត់ រៀបរៀង	៦០០

មួយឆ្នាំមាន ១២ លេខ តម្លៃ ដង ២៣:០០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

sommaire

Partie religieuse :

-Verupasamakatha par Preah kru Nhean Muni LENG-REAM. . 481
-Lokapaladhamma par Preah Moha MEAS-SUM 494
-Surabajataka (suite) recueilli du manuscrit sur feuilles de latanier par M. THANG-VONG 509

Partie littéraire :

-Histoire de Sabbasiddhi (suite) par Phakdei Aksar TAN revue et corrigée par M. BOU-PO 521
-Histoire de Hang-Yon recueillie du manuscrit sur feuilles de latanier par M. IM-PHON 547
-Le Théâtre d'Ombre par Mme PICH-SAL 557
-La Ruse du Loup par le bonze MEN-REAM 563
-Histoire de Sam Kok (suite) par l'Oknha NOU-KAN . . . 569

Notes et Chroniques :

-Distribution des Prix aux lauréats religieux par M. RAY-BUC. 574
-Cérémonie "Namaskar Preah Sakyamunichedey célébrée à Phnom-Penh" par M.CHAP-PIN. 587
-Dictionnaire Sanskrit-Khmer (suite) par vén. PANG-KHAT . . 600

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

រៀបរៀបសមកហ៊ា

(ពោលអំពីការអ្វាប់ពៀរ)

របស់ព្រះគ្រូញាណមុនី ខ្មែង-រាម

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥ ហ៊ា វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោតិ ។

ពោលនេះ អាត្មាភាពនឹងសម្តែងធម្មកថា ដែលមានក្នុងន័យធម្មបទគាថាត្រង់ឃើញមកពីគន្លងនៃបុព្វភាគ ពណ៌នាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាដើម្បីជាគុណប្រតិបត្តិអប់រំនិស្ស័យសន្តាន បណ្តុះសទ្ធាឲ្យកើតសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ជាស់តឿនចិត្តឲ្យលះបង់អកុសលធម៌ គឺសេចក្តីលោភ ក្រោធ វង្វិន រុកគួនបៀតបៀន ឲ្យបំពេញកុសលធម៌ គឺសេចក្តីមិនលោភ-ក្រោធ-វង្វិន មិនគំនុំគុំគួនបៀតបៀនដាដើម តាំងចិត្តប្រតិបត្តិល្អតាមពាក្យប្រដៅរបស់ ព្រះសាស្តា ដើម្បីសម្រេចគុណប្រយោជន៍ ទីដ៏សេចក្តីសុខចំរើន ដល់អ្នកគោរពប់អាននៃព្រះពុទ្ធសាសនាឲ្យល្មមសមគួរដល់តំណែងជាកុលបុត្រ កុលធីតាក្នុងវង្សព្រះពុទ្ធសាសនា ។

ក្នុងលោកនេះ មានវត្ថុដែលជាបដិបក្ខនឹងគ្នាពីរយ៉ាងគឺ: មិត្រនឹងសត្រូវ, មិត្រជាចំណែកមួយ ដួយខំទុកបម្រុងជួនឆ្នើម ឲ្យកើតសេចក្តីសុខ សត្រូវជាចំណែកមួយទាំងការបំផ្លិចបំផ្លាញ ធ្វើសេចក្តីវិនាសឲ្យកើតទុក្ខគ្រោះថ្នាក់ក្រហាយលំបាកចិត្តឈឺផ្សា ។ មិត្រប្រៀបដូចអ្នកប្រាថ្នាល្អ គឺអ្នកដែលមានមេត្រីចិត្តប្រាថ្នាសេចក្តីសុខចំរើនឲ្យមនុស្សជាមិត្រ, សត្រូវប្រៀបដូចអ្នកប្រាថ្នាសេចក្តីវិនាស គឺសឹកសត្រូវតែតបំផ្លិចបំផ្លាញធ្វើឲ្យមនុស្សជាមិត្រហ៊ានបៀចឲ្យឥន្ត្រាយ ។ មនុស្សយើងត្រូវប្រាថ្នាត្រូវការមិត្រ មិនត្រូវការសត្រូវ តែមិត្រឬសត្រូវ មិនមែនមានមកឯងឯ ។ រមែងតែកើតមានព្រោះយើងធ្វើឲ្យកើតឡើង ។ មេត្តាចិត្តជាហេតុឲ្យកើតមិត្រចោសចិត្ត ជាហេតុឲ្យមានសត្រូវ បុគ្គលអ្នកមានមេត្តានៅកណ្តាលចិត្តតែងប្រាថ្នាល្អដល់អ្នកដទៃ ដោយពាក្យមេត្រីចិត្តថា សត្វេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ សត្តូតាំងឡាយតាំងពួង ចូរជាអ្នកមិនមានពៀរ មិនបៀតបៀនគ្នា មិនមានសេចក្តីទុក្ខ ចូរជាអ្នកមានសេចក្តីសុខរក្សាខ្លួនចុះ ។

អ្នកមានមេត្តាចិត្តដូច្នេះ រមែងមិនឃើញមនុស្សដទៃ ដែលជាសត្រូវដល់ខ្លួន រមែងឃើញមនុស្សឬសត្វដទៃសុទ្ធតែជាមិត្រ គឺសម្លាញ់តែតរាស់ឈឺស្លាប់ជាមួយនឹងខ្លួនតាំងអស់ ។ ការធ្វើទិយាយតិត របស់បុគ្គលអ្នកមានមេត្តាចិត្តនោះ រមែងគ្រាសចាកពោស ប្រព្រឹត្តទៅដើម្បី

មិនបៀតបៀនប្រទូសព្យ៉ាយអ្នកដទៃ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ខ្លឹង
សេចក្តីសុខដោយចំណែកមួយ ព្រោះអ្នកធ្វើមានចិត្តក្រោសចាកអយ៉ាត
ព្យាបាទវិហិង្សា កាលមានចិត្តមេត្តាប្រាថ្នាល្អ និយាយនឹងធ្វើតែការណា
ដែលជាប្រយោជន៍ដល់អ្នកដទៃ អ្នកណាខឹងគ្រោធស្អប់ហិនតាំងខ្លួនជា
សត្រូវចាំប្រទូសព្យ៉ាយ មានតែមនុស្សស្រឡាញ់ប្រាថ្នាល្អដំនួសវិញ ព្រោះ
មនុស្សយើងមានចិត្តប្រាថ្នាល្អ ធ្វើល្អច្រើនជាងនឹងគិតធ្វើប្រទូសព្យ៉ាយ កាល
ខ្លាំងធ្វើល្អ ខ្លាំងខ្មៅគំកេតសេចក្តីស្រឡាញ់ធ្វើតបខ្លះ មេត្តាជាគុណធម៌
ប្រសើរ ជាអាវុធពិសេសសម្រាប់ការពារសត្រូវ មិនឲ្យធ្វើអន្តរាយដល់អ្នក
ដែលមានមេត្តាបាន នឹងជាហេតុឲ្យកើតមិត្រក្នុងទីតាំងតួង ។ សម្តេច
ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សរសើរមេត្តាថា មានគុណានិសង្ស
ច្រើនដល់ភេ ១១ ប្រការ មានបទថា សុខំ សុបតិ ជាដើម ប្រែថា
"អ្នកចំរើនមេត្តានេះ ដេកក៏ស្រួល ភ្ញាក់ឡើងក៏ស្រួល មិនឃើញសុបិន
អាក្រក់ ឯនជាទីស្រឡាញ់របស់មនុស្សនឹងអមនុស្សទាំងឡាយ តួក
ទៅតាមែងរក្សា ភ្លើងឬថ្នាំពិសឬកំសស្ត្រាមិនញាំញីធ្វើអន្តរាយបាន ចិត្ត
របស់អ្នកចំរើនមេត្តារមែងតាំងទៅលឿនជាសមាធិយ៉ាងឆាប់រហ័ស មាន
ព័ណ៌សម្បុរនៃមុខមាត់ដ៏ផូរផង់ មិនវង្វេងស្មារតីក្នុងវេលាធ្វើមរណកាល
កាលបើមិនបានសម្រេចព្រះអរហត្ត ដែលជាធម៌ខ្ពង់ខ្ពស់ រមែង
ជាអ្នកចូរដល់ព្រហ្មលោកដូច្នេះ" ។ ព្រោះហេតុនោះ បុគ្គលអ្នកប្រាថ្នា

ដើម្បីឧទ្ទិសឧទ្ទេសពីសត្រូវ ទើបប្រាថ្នាជាអ្នកមានមិត្រដ៏ពិសេសហាមឃាត់ដោយមនុស្សស្រឡាញ់ប្រាថ្នាល្អហើយ តម្រិះរបស់មេត្តាឲ្យជាគុណធម៌ប្រចាំចិត្តរបស់ខ្លួននៅជានិច្ចកាល, ចំរើនមេត្តាខាះ ជាដល់គាត់ដល់ខ្លួនដៀបនឹងមនុស្សសត្វដទៃថា "យើងស្រឡាញ់សុខ ស្អប់ទុក្ខយ៉ាងណា មនុស្សសត្វដទៃ ក៏ស្រឡាញ់សុខ ស្អប់ទុក្ខដូច្នោះដែរ" ។

ដូច្នេះ យើងមិនបៀតបៀនប្រទូសរ៉ាយមនុស្សសត្វដទៃ ឲ្យបានសេចក្តីក្តៅក្រហាយលំបាកព្រោះយើងជាហេតុ ទើតបញ្ជាយតែសេចក្តីល្អទៅដល់មនុស្សនឹងសត្វទាំងអស់នោះថា "មនុស្សនឹងសត្វទាំងពួងសុទ្ធតែប្រាថ្នាសុខដូចគ្នា ចូរជាអ្នកបានសេចក្តីសុខសមតាមសេចក្តីប្រាថ្នារបស់ខ្លួនចុះ កុំមានពៀរនឹងគ្នា កុំបៀតបៀនគ្នា កុំមានសេចក្តីទុក្ខកាយលំបាកចិត្តឡើយ ចូរជាអ្នកមានសុខគ្រប់គ្រងរក្សាខ្លួនដូច្នេះ" ។ ការផ្សាយមេត្តាតាមទំនៀមដូចពោលមកនេះ ជាត់ជាមិនមានពៀរ មិនមានតំឃដល់មនុស្សនឹងសត្វទាំងពួងឡើយ ដោយចិត្តមេត្តារបស់ខ្លួន ឈ្មោះថាធ្វើសមភាពភាពជាអ្នកស្មើមុខគ្នាដល់មនុស្សនឹងសត្វទាំងពួងឡើយ ចំណែកការតបៀតបៀនប៉ុនប៉ងឲ្យគេបានទទួលសេចក្តីទុក្ខលំបាក ឈ្មោះថាធ្វើភាពមិនឲ្យស្មើមុខគ្នា ព្រោះហេតុនោះ ការផ្សាយមេត្តាចិត្តគិតប្រាថ្នាល្អដល់គ្នានឹងគ្នាទើបឈ្មោះថា ឲ្យសមភាពដល់គ្នានឹងគ្នាដោយទំនងចិត្ត ព្រោះមនុស្សយើងត្រូវកើតចាស់ឈឺស្លាប់ដូចគ្នា បើបានសេចក្តីសុខ

មិនចង់ជាន់ទុក្ខ កាលយើងបង្អាន់ចិត្តគិតឲ្យគេបានផុតពីទុក្ខហើយ ឈ្មោះ
ថា យើងឲ្យអភ័យ ឲ្យសមភាពដល់គេ ឲ្យសិរីភាព សូមសុខដូច ។ គ្នា ។

ម្យ៉ាងទៀត ការផ្សាយមេត្តានេះ លោកប្រដៅឲ្យផ្សាយទៅក្នុង
មនុស្សដែលខ្លួនស្រឡាញ់ពប់អានជាមុន គាំងពីមាតាបិតា ស្វាមី ភរិយា
បុត្រធីតា ទីឯលោកដែលជាទីគោរព ដូចខ្ញុំបង្ហាញអាចារ្យជាដើម
រួចសឹមផ្សាយដល់មនុស្សដែលខ្លួនគាំងជាកណ្តាល ។ ទីបំផុតទើបផ្សាយ
ដល់មនុស្សដែលយើងស្អប់ ដើម្បីឲ្យចិត្តស្ងាត់ជាំនាញក្នុងការចំរើនមេត្តា
ការផ្សាយមេត្តាដល់មនុស្សដែលខ្លួនស្រឡាញ់នោះ មិនជាការអស្ចារ្យទេ
អ្នកណា ក៏អាចធ្វើបាន ប្រៀបដូចអុំទូកបណ្តាយទឹក ។ ចំណែកការ
ផ្សាយមេត្តាដល់មនុស្សដែលខ្លួនស្អប់ លោកប្រៀបដូចអុំទូកច្រាស់ទឹក
កម្រនឹងសម្រេចជាមិនតាមច្រកថ្នា ត្រូវប្រើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា
ទើបចំរើនមេត្តានេះបានផលល្អ ។

បើបច្ចុប្បន្ន ការផ្សាយមេត្តាក្នុងមនុស្សដែលខ្លួនស្អប់នោះ មនុស្ស
សាមញ្ញធ្វើបានដោយក្រ តែលោកអ្នកប្រាជ្ញធ្វើបានដោយងាយ ព្រោះ
មានឧបាយប្រសើរដែលធ្វើឲ្យបាត់សេចក្តីស្អប់ គឺធ្វើចិត្តឲ្យត្រូវផ្លូវ បាន
ដល់លើកសេចក្តីល្អរបស់គេឡើង ទឹកពិចារណាតាមដែលយើងលើក
មកបាន ការប្រព្រឹត្តផ្លូវកាយក៏ដោយ វាចាក៏ដោយ ចិត្តក៏ដោយ ដូច
មនុស្សច្រើនខិយាយជំទាស់ត្រចៀកអ្នកដទៃ តែមិនមែនមនុស្សគ្រប់ដល់

ទៅធ្វើមន្តយ៉ា មនុស្សប្រើនដោយសេចក្តីក្រោធតែមិនធ្លាប់តែ ។ មនុស្ស
តាច តែមានចិត្តអើពើដួយអន្តរាយដល់អ្នកដទៃ តាំងនេះ ជា
គួយ៉ាង គប្បីនឹកសេចក្តីល្អដែលមាននៅក្នុងខ្លួនរបស់គេ ដួនតាលឹក
រម្លាប់សេចក្តីស្អប់ឲ្យស្រាលបានខ្លះ ប្តូរ ។ ទៅអាចដាច់តែម្តងក៏មាន ។
បើនឹកសេចក្តីល្អរបស់គេមិនបើញ្ញា គប្បីញុំាងឯកុណាចិត្ត គឺសេចក្តី
អាណិតអាសូរឲ្យគេតែ មនុស្សគោកយ៉ាកខ្វត់ទ្រព្យ មិនមានកម្លាំងជា
គ្រឿងទំនុក ម្រុងជំរិត ខឹងពងគាយឲ្យសុខ មិនមានឧបាសអន្តរាយ
មនុស្សដទៃដោយកម្លាំងទ្រព្យ ជាអ្នកគួរជាងខ្លួលសេចក្តីកុណារបស់
មនុស្សដែលមានទ្រព្យយ៉ាងណា មនុស្សមិនមានគុណធម៌សេចក្តីល្អជា
គ្រឿងបម្រុងចិត្តឲ្យជាសុខ មិនមានឧបាសនឹងដឹកនាំខ្លួនអ្នកដទៃក្នុង
សេចក្តីល្អ មិនតែប៉ុណ្ណោះត្រឡប់បៀតបៀនមនុស្សឲ្យបានខ្លួលសេចក្តី
ក្តៅក្រហាយឡើង ។ រមែងជាអ្នកសមគួរបានខ្លួលសេចក្តីកុណារបស់
មនុស្សអ្នកប្រព្រឹត្តធម៌ មានសតិសម្បជញ្ញៈគឺដូច្នោះ ការដែលស្អប់
មនុស្សដូច្នេះគឺរកប្រយោជន៍ដល់ខ្លួនមិនមាន ការដែលនឹកយ៉ាងនេះអាច
ញុំាងឯកុណាឲ្យតើតឡើងបាន បើបង្អោនចិត្តទឹកទៅដោយមិនប្រុងសម្រួល
ដោយឧបាយយ៉ាងនេះ គប្បីនឹកដល់ភាពនៃសត្វមានកម្មជារបស់ខ្លួន អ្នក
ណាធ្វើល្អ ឬធ្វើអាក្រក់ អ្នកនោះ នឹងទ្រាំកដោយកម្មរបស់ខ្លួនឯង
គប្បីតាំងចិត្តជាឧបេក្ខា សូម្បីយ៉ាងនេះ ក៏ទៅមិនសម្រេច កុំប្រាថ្នា

ដល់អ្នកនោះឲ្យសោះ បើគេស្អប់ខ្លួន ក៏គប្បីកេនកាសសម្តែងសេចក្តីពិតនេះសេចក្តីល្អដោយកាយវាចាចិត្ត ឬក៏ជួយអនុគ្រោះដើម្បីចង់មេត្រីភាពកាលប្រព្រឹត្តប្រតិបត្តិដោយមេត្តាចិត្តដូច្នេះ ក៏នឹងនៅជាសុខស្រួល មិនខ្វាចដល់ពៀរនឹងភ័យដែលនឹងមានមកអំពីគេណា ។ ឈ្មោះថានៅដោយមិនមានភ័យ មិនមានពៀរនឹងអ្នកដទៃ មានសេចក្តីស្ងប់ម្ចាស់ មិនឈ្មោះប្រកែកវៃនឹងអ្នកណា នៅទីណាក៏នៅបាន មិនត្អូកត្រហាយចិត្ត តែតក់ស្លុតដល់បត្រូវដែលនឹងមកបៀតបៀន ព្រោះជាអ្នកមានមិត្រជាទីស្រឡាញ់នៅជុំវិញ មានតែសេចក្តីកក់ក្តៅចិត្ត លែងខ្នែត់ស្ងើបពីជុំវិញ មានតែគេជួយការពារសុខ ខ្ពុងឲ្យវៀតផង ។

ចំណែកគោសចិត្ត ដែលជាហេតុឲ្យកើតសត្រូវនោះ អធិប្បាយថា គោសចិត្តបានដល់ចិត្តប្រទូសព៌ាយ មនុស្សអ្នកមានចិត្តប្រទូសព៌ាយរមែងដឹងខ្លួនថា មានសត្រូវជុំវិញ ព្រោះខ្លួនប្រទូសព៌ាយអ្នកណា តែងចំទ្វេចបំផ្លាញបៀតបៀនធ្វើសេចក្តីអន្តរាយដល់អ្នកណា ក៏រមែងឃើញអ្នកនោះ ។ ជាសត្រូវចំបង់ខ្លួន, នេះបញ្ជាក់ឲ្យឃើញថា សត្រូវកើតឡើង ព្រោះការតែបង់ខ្លួន កាលបើលុះក្នុងអំណាចនៃសេចក្តីក្រោធជាបហេតុធ្វើប្រទូសព៌ាយគេ ឬនិយាយរកអក្រក់ព៌ាគេ ឲ្យបានខូចសេចក្តីលំបាកឈឺចាប់ត្អូកត្រហល់ត្រហាយ តើជាហេតុឲ្យគេក្រោធធ្វើអន្តរាយតបដល់ខ្លួនវិញខ្លះ, ត្រង់នេះ សត្រូវកើតឡើងព្រោះការធ្វើបង់

ខ្លួន បុគ្គលអ្នកមានសត្រូវជុំវិញ រមែងតក់ស្លុតព្រឺសើបរន្ធត់ដេកដើរឈរ
អង្គុយតំមិនប្រក្រតី ព្រោះខ្លួនជាអ្នកមានពៀរ មានតំយជុំវិញ បើអាច
ឆ្លើបាន ខំរិតាឃាមបៀតបៀនចងកម្មចងពៀរថ្មីប្រហារអ្នកដែលឃើញ
ថាជាសត្រូវរបស់ខ្លួនប៉ុន្មាន ៗ នាក់នោះរកទីបំផុតមិនមាន ម៉្លេចនឹងចាំបាន
ច្រើនតាតែមានច្រើន ព្រោះការធ្វើដូច្នេះជាការកៀរឲ្យឃើតវែងមិន
មានពេលស្រោកស្រាន្ត ការចេរពៀរមិនស្ងប់រម្ងាបដរាបណា ទុក្ខតំយ
សេចក្តីក្តៅក្រហាយចិត្ត រមែងមិនស្ងប់រម្ងាប់ដរាបនោះ ។

ព្រោះហេតុនោះ ព្រះបរមសាស្តាចារ្យ ការសង្រឹងពន្យល់ដូរដុះ
ដាលនៃពៀរ និងផ្លូវដែលស្ងប់រម្ងាប់នៃពៀរ ឲ្យឃើញច្បាស់ប្រចក្ស
ហើយឲ្យចំពះដឹងក្នុងផ្លូវដែលស្ងប់រម្ងាប់នៃពៀរ ទើបត្រាស់ព្រះពុទ្ធគា-
ថាតដាស់តឿនចិត្តយ៉ាងនេះថា :

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។

ជនពួកណា ចងសេចក្តីក្រោធទុកក្នុងចិត្តថា គេបានដេរយើង
គេបានធ្វើប្រទូសរ៉ាយយើង គេបានផ្តាញ់យើង គេបានលួចទ្រព្យ
យើងដូច្នេះ ពៀរបស់ជនពួកនោះ រមែងមិនស្ងប់រម្ងាប់បាន ។

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

ជនពួកណា មិនចង់សេចក្តីក្រោធកុំកក្នុងចិត្តថា គេបានជេរយើង គេបានធ្វើប្រទូសរ៉ាយយើង គេបានផ្តាញ់យើង គេបានលួចទ្រព្យរបស់យើងដូច្នេះ ពៀរបស់ជនពួកនោះ រមែងស្ងប់រម្ងាប់បាន ។

គេសង្កេតឃើញដែលកើតពីសេចក្តីប្រាថ្នាអាក្រក់ដល់គ្នាហៅថាពៀរ ពៀរនេះ រមែងមិនស្ងប់រម្ងាប់បានដោយពៀរ ម្នាងធ្វើសេចក្តីអាក្រក់ដល់គេមុន ម្នាងទៀតធ្វើសេចក្តីអាក្រក់នោះតបមកវិញ ដោយប្រាថ្នាឲ្យជាការសងសឹកដល់គ្នា ចង់បានឲ្យតែឈ្នះដៃរៀនៗខ្លួន ការធ្វើអាក្រក់ដល់គ្នាក៏វរឹតតែមានកម្ទាំងខ្លាំងច្រើនឡើង ព្រោះធ្វើអាក្រក់ដល់គ្នាខឹងគ្នាច្រើនដងបណា ចិត្តគំនិតក៏វរឹតតែមានក្រក់ពេញពោរពៅដោយអយោគត្បាចារិហិង្សាដងបនោះ ប្រៀបដូចបុគ្គលប្រាថ្នាខឹងលាងវិដែលមិនស្អាតឲ្យស្អាត តែបើយកទឹកស្មោកគ្រោកទៅលាង ក៏នាំឲ្យប្រឡាក់ស្មោកគ្រោកវរឹតតែខ្លាំងឡើង ឬប្រៀបដូចបុគ្គលប្រាថ្នាខឹងលត់ភ្លើង ហើយយកកំញាវភ្លើង មានចំបើងឬនុះជាដើមទៅថែមក្នុងភ្លើងនោះទៀត ភ្លើងរមែងមិនលត់ ត្រឡប់ជាឆេះកាន់តែខ្លាំងឡើង, ឧទាហរណ៍ណា ការធ្វើសេចក្តីអាក្រក់តបគ្នា ធ្វើការសងសឹកដល់គ្នាក៏ដូច្នោះដែរ រមែងជាការកាត់ឲ្យឃើតវែងតទៅមិនមានទីបំផុត ត្រូវតាមពុទ្ធភាសិតដែលបានលើកមកអាងនុ៎ះក្នុងដើមថា :

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

ប្រែថា ក្នុងកាលណា ។ កំដោយ ពៀរទាំងឡាយរមែងមិនស្ងប់ម្ចាស់ដោយពៀរទេ តែថាពៀរទាំងឡាយ រមែងស្ងប់រម្ងាប់បានដោយឧភាពជាអ្នកមិនមានពៀរ ធម៌នេះ ជាធម៌មានយូរមកហើយ ។

ការបង្កពៀរ គឺបន្ទឹងពៀរទៅវិញទៅមកដូច្នេះ ផលទីបំផុតក៏រមែងដល់នូវការតន្តិះដាន់ទាំងអស់គ្នា ខានេះ គប្បីយើញតួយ៉ាងគឺកុម្ភអ្នកនៅស្រុកកោសម្ពីក: អាស្រ័យហេតុអាងលេសបន្តិចបន្តួចធ្លើសេចក្តីអន្តរាយរវាងគ្នា មិនព្រមចុះចាញ់គ្នា សូម្បីព្រះបរមសាស្តាទ្រង់ហាមប្រាមពន្យល់ណែនាំ ក៏មិនត្រមដឿស្តាប់ធ្វើតាម ព្រះមគ្គឹកទ្រង់រអាព្រះទ័យ ទើបស្តេចគេចចេញចាកទីនោះ ទៅប្រថាប់នៅឱព្រៃកុំតវ័នតែមួយព្រះអង្គឯង តិក្ខុទាំងអស់នោះ មិនមានអ្នកណាជាតិតិងបាន កំទួលសេចក្តីទុក្ខលំបាកជាច្រើន ចំណេរតមកខាងក្រោយ ក៏ត្រឡប់បានជានរសះស្ម័យនឹងគ្នាវិញ ព្រះបរមសាស្តាបានត្រាស់ប្រដៅឱ្យយើញទោសនៃសេចក្តីច្បាស់ក្រក់ យកឈ្នះគ្នាដោយទោសចិត្តដូចព្រះតថាគតថា:

បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ

យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

ប្រែថា ពួកជនដទៃមិនដឹងថា ពួកយើងទាំងឡាយសុំបាត់កង់ពួកបស់

យើងនេះឯង ក្នុងពួកដែលកពៀគ្នានេះ ពួកណាដឹងថា សេចក្តីប្រកួត
ប្រកាន់គ្នា រមែងស្ងប់រម្ងាប់បាន ព្រោះដូនពួកនោះ ។

អធិប្បាយថា ក្នុងបណ្តាពួកជនដែលឋិតនៅខែងរវាងគ្នា ពោល
អាក្រក់ ទើងធ្វើអាក្រក់ដល់គ្នានោះ គ្រប់ៗខ្លួនក៏រមែងមិនដឹងថា យើងនាំ
គ្នាធ្វើសេចក្តីលំបាកក្នុងពួកក្រុមជាមួយគ្នា តែលោកអ្នកដែលមានប្រាជ្ញា
ញាណច្បាស់ងងៃវៃក្រៅពីពួកដែលបង្កពៀរធ្វើសឹកសត្រូវទើងគ្នានោះ រមែង
ដឹងបានដោយល្អថា សេចក្តីប្រាថ្នាអាក្រក់ដល់គ្នាទើងគ្នាទើងស្ងប់រម្ងាប់
បាន ព្រោះលោកអ្នកដែលប្រកបដោយប្រាជ្ញាញាណភិនភម្ភាលនេះ
ឯង ។ អវេរេន ច សម្មន្តិ តែថាពៀរ រមែងស្ងប់រម្ងាប់ដោយ
ភាពជាអ្នកមិនមានពៀរ គឺម្ខាងកពៀរ តែម្ខាងទៀតមិនបង្កពៀរតប ពៀរ
ក៏ទើរស្ងប់បាន មិនដុះដាលតទៅទៀត គប្បីយោគយល់ដោយកោដកៈ
ធ្វើសេចក្តីប្រទូសក៏ឃើញទើមឃមាណភ តែមឃមាណត មិនបង្កពៀរតប
ត្រឡប់ជាមានមេត្តាចិត្តផ្សាយសេចក្តីល្អតបវិញ ទើងពាក្យដែលប្រទូសក៏ឃ
សុមង្គលសេដ្ឋ តែសេដ្ឋមិនប្រកាន់ពោស ត្រឡប់ជាទុំសចំណែកកុសល
ដែលកើតអំពីការកសាងព្រះសុគន្ធកុដីថ្វាយព្រះពុទ្ធជាម្ចាស់ ឲ្យដល់ពោរ
អ្នកធ្វើសេចក្តីប្រទូសក៏ឃ ទើងរឿងព្រះសារីបុត្តដែលត្រូវព្រាហ្មណ៍ម្នាក់ប្រ-
ហារ ហើយលោកមិនប្រហារតបត្រឡប់មានមេត្តាតបវិញ ព្រាហ្មណ៍នោះ

ក៏ត្រូវប់មានចិត្តដ្រះថា យ៉ាងនេះហៅថា ពៀរវែងស្មប់រម្ងាប់បានដោយ
ភាពជាអ្នកមិនមានពៀរ ។

ការប្រតិបត្តិកន្លងព្រះពុទ្ធសាសនានេះ និយមថា អ្នកដែលធ្វើស្រេចក្តី
ល្អតបណ្ដោះថា ជាអ្នកឈ្នះ អ្នកដែលធ្វើស្រេចក្តីអាក្រក់ណ្ដោះថា ជាអ្នក
ចាញ់ ព្រោះមនុស្សដែលធ្វើល្អ រមែងមានប្រៀបជាជាងប ព្រោះមិនបាន
ធ្វើស្រេចក្តីអន្តរាយឲ្យកើតឡើងដល់អ្នកណា ទើងគួរបានទទួលស្រេចក្តីសរ-
សើរថាជាអ្នកមានគុណធម៌កន្លងចិត្ត មានទន្លេទើងសោច្ចៈជាដើម ទើបរក្សា
ស្រេចក្តីល្អទុកបាន មិនធ្វើអាក្រក់ សូម្បីក្នុងខណៈដែលត្រូវធ្វើស្រេចក្តី
អាក្រក់ការស្មប់រម្ងាប់ពៀរបាន ដោយភាពជាអ្នកមិនមានពៀរនេះ ជាធម៌
បរមបុរាណមានមកឃ្លាយណាស់ហើយ ។

បណ្ដិតទាំងឡាយ ក្នុងបុរាណសម័យ បានទិយមគោរពរាប់អាន
ប្រតិបត្តិធម៌នេះតទៅមក ដរាបដល់សព្វថ្ងៃនេះ ព្រោះហេតុនោះ ព្រះ
មហាមុនីជាម្ចាស់ទើបត្រាស់ថា ឯស ធម្មោ សនន្តនោ ការ
ស្មប់រម្ងាប់ពៀរដោយភាពជាអ្នកមិនមានពៀរនេះ ជាធម៌បាស់, ជាធម៌មាន
ឃ្លាយណាស់មកហើយ ។

ព្រោះហេតុនោះ បុគ្គលអ្នកត្រូវការមិត្រ គប្បីកម្ចាត់រមែងចិត្តឲ្យបាន
បរិបូណ៌កន្លងខ្លួន ទើងការពារលើកស្រេចក្តីល្អឲ្យបានរឿយ ។ អ្នកមិនត្រូវការ

សត្រូវ គប្បីហាមឃ្លាមគោសចិត្ត តំសេចក្តីក្រវល់ក្រោធអយោតព្យាបាទ
វិហឹសាឲ្យអស់ទៅ បើប្រាថ្នាជាអ្នកមិនមានពៀរ មិនមានភ័យកុងនិ
ច្ចំតាំងពួងចូរត្បាយាមបដិបត្តិធម៌ពិត ។ កុំឲ្យឃ្លៀងឃ្លាតអំពីភាក្យប្រៀន
ប្រដៅរបស់ព្រះសាស្តាថា ៖

« កុងកាលណា ។ កំដោយ តៀរតាំងខ្លាយ រមែងមិនស្ងប់រម្ងាប់
បានដោយពៀរ តែថា តៀរតាំងខ្លាយ រមែងស្ងប់រម្ងាប់ឃ្លានដោយការ
ជាអ្នកមិនមានពៀរ ការស្ងប់រម្ងាប់ពៀរដោយការមិនចងតៀរនេះ ជា
ធម៌ចាស់ " ។

សាធុកៈ បពិត្រលោកអ្នកសប្បុរសតាំងខ្លាយ កាលបើប្រាថ្នា
សេចក្តីសុខចំរើន នឹងប្រាថ្នាធ្វើខ្លួនឲ្យផុតពីសត្រូវ នឹងប្រាថ្នាឲ្យជាអ្នកមាន
មិត្រភ័ក្តិជុំវិញ ហៃបាមគៅមកដោយមនុស្សស្រឡាញ់ប្រាថ្នាល្អហើយ
គប្បីចំរើនមេត្តាឲ្យជាគុណធម៌ប្រចាំចិត្តរបស់ខ្លួន នៅដឹតជាមជាប់ជានិច្ច
និរន្តរ៍ ។

អាត្មាភាព សំដែងរៀបរាប់សមកថា ពណ៌នាអំពីធម៌ចូលគៅស្ងប់
រម្ងាប់ពៀរ ដូចបរិយាយដោយសង្ខេបខ្លី ។ ខាងលើនេះ កំលុមសមគួរ
ដល់ពេលវេលា សន្មតថាចប់ត្រឹមប៉ុណ្ណេះ ។

លោកជ្ជាលធម៌

របស់ព្រះមហាមាស-ស៊ុមង

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការ បំពោះព្រះភគវន្តមុខីអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ

(ព្រមទាំងព្រះធម៌ ទំនឹព្រះអរិយសង្ឃ ដោយសេចក្តីគោរព)

វេលានេះ អាត្មាភាពសូមសំដែងអំពី លោកជ្ជាលធម៌ ដើម្បីសេចក្តីសារជូចតទៅនេះ

ពាក្យថា "លោកជ្ជាលធម៌" ប្រែថា "ធម៌ក្បាលោក" ឬហៅថា "ទេវធម៌"

ដូចមានភាសិទ្ធកនិកាយធម្មបទថា

ហិរិ ឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា

សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ ។

សប្បុរសទាំងឡាយ អ្នកមានចិត្តស្លប់រម្ងាប់ បរិបូណ៌ដោយហិរិនឹងឱត្តប្បៈ ជាអ្នកមានចិត្តជ្រះថ្លាទៅក្នុងធម៌ស អ្នកប្រាជ្ញពោលថា ជាបុគ្គលមានទេវធម៌ក្នុងលោក ។

ក្នុងទីឃនិកាយត្រង់សង្គីតិសូត្រនៃពួកធម៌ឯក មានបាលីថា

អហិរិកេកំ អនោត្តប្បំ ។ ហិរិំ ឱត្តប្បំ ។

សេចក្តីមិនខ្មាសបាប ១ សេចក្តីមិនក្តៅនឹងបាប ឬមិនខ្លាចបាប ១ ។

សេចក្តីខ្ញុសឆ្គង ១ សេចក្តីក្តៅនឹងឆ្គង ១ ។

ចាំរ៉ៃ ខុទ្ទកប្ប: ក្នុងអាគតដ្ឋានផ្សេង ។ ហៅថា "ទេវធម្ម" ខ្លះ, ហៅថា "អរិយទ្រព្យ" ខ្លះ, ហៅថា "លោកុត្តរធម្ម" ខ្លះ ។

សូមអធិប្បាយអំពីពាក្យថា "លោក" ជាមានដើម

"លោក" នេះ ជាទដល់សត្វ:ដែលកើតមានច្រើនហើយមិនតាំងនៅដោយច្រើនឆាត់ តែងតែបែរឈឺមមុខទៅរកសេចក្តីវិនាសឆាត់បង់សូន្យ:ទៅវិញ ក្នុងពេលណាមួយ ហៅថា "លោក" ។ លោកមានច្រើន តែបើបំព្រួញឲ្យខ្លីចុះមក មានត្រឹមតែ ៣ យ៉ាងគឺ សង្ខារលោក ១, សត្តលោក ១, អាសលោក ១ ។

សេចក្តីអធិប្បាយ

រូបធម្ម នឹងអរូបធម្មតាំងឡាយដែលកើតមានច្រើន ដូចជាពួកសត្វតាំងអស់ដែលមានអត្តភាពតាំងនៅជាទដោយសារអាហារក្តី នាមនឹងរូបក្តីវេទនាញ៉ាំង មានសុខវេទនាជាដើមក្តី អាហារ ៤ យ៉ាង មានកវឡិង្ការាហារជាដើមក្តី អាយតន:ខាងក្នុង ៦ យ៉ាង មានចក្ខាយតន:ជាដើមក្តី វិញ្ញាណដ្ឋិតិ ៧ យ៉ាង មានខានត្តកាយ នានត្តសញ្ញីគឺ (ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាកំផ្សេងគ្នា) ជាដើមក្តី លោកធម៌ ៨ យ៉ាង មានលាភ:នឹងអលាភ:ជាដើមក្តី សត្តាវាស: ៩ យ៉ាង មានវិញ្ញាណដ្ឋិតជាដើមក្តី អាយតន: ១២ មានចក្ខាយតន:នឹងរូបាយតន:ជាដើមក្តី ធាតុ ១៨ យ៉ាង

មានបុគ្គលជាតុជាដើមក្តី ប៉ុណ្ណេះជាដើម ហៅថា "សង្ខារលោក" ប្រែថា លោកគឺសង្ខារ ដែលជាភ្នាក់ងារខាងឯការតាក់តែងឲ្យចំរើនឲ្យវិនាស ។

ពួកមនុស្ស តាំងប្រុស តាំងស្រី ខ្លះមានបុណ្យ ឬឥតបុណ្យ, មានកិលេស ឬឥតកិលេស, មានប្រាជ្ញា ឬឥតប្រាជ្ញា, ល្អ ឬអាក្រក់ក្តី : ពួកអមនុស្ស គឺទេវតា, មារព្រហ្ម, យក្ស ទាំងនុ៎ះជាដើមក្តី តែងអាស្រ័យនៅក្នុងលោកតាំងបី ។ ប្រភេទសត្វតាំងអស់នេះ រួមមកតែពាក្យមួយហៅថា "សត្តលោក" ប្រែថា លោកគឺពួកសត្ត ។

លោកតាំងមូលដូចគាថាសម្រាប់រងទ្រូងតទាំងគ្នា គឺឲ្យសំទ្រទឹកទាំងទ្រដាំងទ្រឥតឈប់ឈរសង្ខារ គឺសង្ខារដែលមានវិញ្ញាណមានមនុស្សជាដើម ទាំងអនុច្ចាឈរសង្ខារ គឺសង្ខារដែលឥតវិញ្ញាណ មានរុក្ខជាតិ, តំណជាតិ ទាំងភ្នំថ្ម ជាដើម ឬសំដៅយកឧកាស ដែលព្រះអាទិត្យទាំងព្រះចន្ទដើរបំភ្លឺលោកអស់ទាំងត្រឹមណា ទំត្រឹមនោះហៅថា "ឧកាសលោក" ប្រែថា លោក គឺឧកាស (ដែលមិនមែនជាមនុស្សសត្វ) ។

ឯពាក្យថា លោកនេះ ទេមរជនយើងច្រើនទំយកមកចំអកថាជាពាក្យថ្លែថ្លា, ពាក្យគួរសម សម្រាប់ប្រើហៅមនុស្សអ្នកមានបុណ្យយសស័ក្តិអំណាច ឬហៅព្រះសង្ឃខ្លះ តែបើតាមតិតវិញ ពាក្យថា លោកនេះ ជាពាក្យសាធារណៈ អាចហៅបានគ្រប់សព្វសត្វទាំងសង្ខារ

ទាំងអស់ ។ អ្នកប្រាជ្ញខាងធម្មសាស្ត្រទាំងឡាយ មានព្រះពុទ្ធជាដើម តែងប្រមូលយកសង្ខារទាំងមានវិញ្ញាណទាំងឥតវិញ្ញាណ ហៅថា "លោក" ព្រោះយល់ថា លោកនេះ ដែលកើតឡើងជាមួយនឹងហើយ មិនដែលតាំងនៅខ្ជាប់ខ្ជួនទេ រមែងចំរើនក្នុងខាងដើម ប្រែប្រួលក្នុងកណ្តាល ហើយត្រូវបាត់បង់ទៅវិញទៅទីបំផុត ។

ន័យមួយទៀត ពាក្យដែលយើងនិយមប្រើហៅឈ្មោះ សត្វ ទាំងសង្ខារ សត្វថ្លង់នេះ ដូចពាក្យថា មនុស្ស សត្វ ប្រុស ស្រី ឈើ ក្តឹម ជាដើម សុទ្ធតែជាពាក្យលោកវោហារទាំងអស់ គឺជាសំដីនិយាយ ហៅដោយការសន្មតិទៅតាមកេរ លក្ខណៈ អាការៈ សំនាំរបស់សត្វ ទាំងសង្ខារ ដែលផ្សំផ្គុំគ្នាប៉ុណ្ណោះ មិនមែនជាសំដីពិតទៅតាមផ្លូវបរមត្ថសាស្ត្រទេ, បើហៅតាមផ្លូវបរមត្ថសាស្ត្រវិញ ទើបជាពាក្យពិត ។

ឧទាហរណ៍ដូចជា មនុស្សម្នាក់ ដែលយើងយកមកឲ្យឈរនៅក្នុងទីចំពោះមុខ ហើយពិចារណាវែកវាពាក្យដែលគេហៅថា "មនុស្ស" នោះ កំមុខជាធាតុកំពុងយើញឡើយ គឺយើញតែជាតុដី ជាតុទឹក ជាតុភ្លើង ជាតុខ្យល់ទាំងអស់ ។ បើដូច្នេះ តើពាក្យថា មនុស្សប្រុសស្រីនេះនៅត្រង់ណា ? ឯសង្ខារទាំងពួងក៏ដូច្នោះដែរ ,

ម្យ៉ាងវិញទៀត ដូចពាក្យដែលយើងគ្នាប់ហៅថា ផ្ទះថា សាលា បើពិចារណាវែកវាកៅកំយើញតែសសរ ផ្ទោង ផ្ទាំង បង្អួច ដែរណោះ ។ល។

មានឈ្មោះដោយវិសេសៗគ្នាទាំងអស់, បើដូច្នេះ ពាក្យថា ឆ្នះថាសាលានោះ លុះតែគ្រប់សម្ភារៈ, ហេតុនោះ ពាក្យថា មនុស្សប្រុសស្រីថាឆ្នះសាលាប៉ុណ្ណោះដាដើម សុទ្ធតែហៅដោយសន្ទុតតាមលោកវោហារ មិនមែនជាពាក្យពិតតាមធម្មវិបរមត្ថសាស្ត្រឡើយ ។

វត្ថុធាតុ ដែលមានឈ្មោះគេហៅដោយពាក្យ ជាលោកវោហារក្តី ដោយពាក្យជាបរមត្ថក្តី រួមមកហៅថា លោកៗដូចគ្នាទាំងអស់ ។

បណ្តាលោកទាំងនោះ កន្លះនេះ សំដៅយកសត្វលោក គឺមនុស្សៗ មនុស្សនេះឯង តែងមានសេចក្តីវិនាសអន្តរាយទៅដោយប្រការផ្សេងៗ ឯធម៌ដែលគ្រប់គ្រងរក្សាមនុស្សឲ្យបានសេចក្តីសុខ ចំរើន នឹងសន្តិភាព ហៅថា "លោកបាលធម៌ ។ លោកបាលធម៌នេះ មាន ២ យ៉ាងគឺ: ហិរិ ១ ឱត្តប្ប: ១ ។

ហិរិ ប្រែថា "សេចក្តីខ្មាសបាប" គឺ (ធម្មជាតិ) ខ្មាសប្តូចខ្លឹម អំពើទុច្ចរិត មានកាយទុច្ចរិតជាដើម ។

ឱត្តប្ប: ប្រែថា "សេចក្តីខ្លាចបាប" គឺ (ធម្មជាត) តក់ស្លុតប្តូចខ្លាចអំពើទុច្ចរិតមានកាយទុច្ចរិតជាដើម ។

សេចក្តីអធិប្បាយ

១-ហិរិ សេចក្តីខ្មាសបាប ជាអង្គគុណសម្បត្តិ (មានហេតុទាំង

កន្លងផុតសម្លាប់ខ្លួន) ជាន់សេចក្តីថា មានិ កើតឡើងព្រោះពិចារណាហេតុ ៤ យ៉ាងនេះ គឺ :

១-ជាតឹ បច្ចវេក្ខិត្វា ព្រោះពិចារណាជាតិ;

២-វយំ បច្ចវេក្ខិត្វា ព្រោះពិចារណាវ័យ;

៣-សូរភាវំ បច្ចវេក្ខិត្វា ព្រោះពិចារណាសូរភាព;

៤-ពាហុសច្ចំ បច្ចវេក្ខិត្វា ព្រោះពិចារណាពាហុសច្ចៈ ។

ពាក្យថា "ព្រោះពិចារណាជាតិ" ជាន់សេចក្តីថា ជាតិមានន័យ ៤ យ៉ាងនេះ គឺ ជាតិខ្ពង់ខ្ពស់ ១ ជាតិថោកទាប ១ ។

បុគ្គលអ្នកមានជាតិខ្ពង់ខ្ពស់ កាលបើដួបប្រទះនឹងអំពើបាប មានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបាន ក៏ពិចារណាថា អាត្មាអញមានជាតិខ្ពង់ខ្ពស់ ដោយមហាកុសល ដែលខ្លួនបានធ្លាប់អំពីអតីតមកពិតៗ បើប្រសិនជាខ្លួនប្រព្រឹត្តធ្វើនូវអំពើបាបនេះ មុខជាទឹងបានទៅជាតិដ៏ថោកទាប ក្នុងកាលអនាគតជាពុំខាន លុះពិចារណាដូច្នេះហើយ ក៏ញ៉ាំងចិត្តសេចក្តីខ្មាសបាបឲ្យកើតឡើង ហើយធ្វើអំពើបាបមានបាណាតិបាតជាដើម ។

ចំណែកបុគ្គលមានជាតិដ៏ថោកទាបវិញ កាលបើដួបប្រទះនឹងបាបកម្ម មានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបានហើយពិចារណាថា អាត្មាអញដែលមានជាតិដ៏ថោកទាបយ៉ាងនេះ ក៏ព្រោះតែបានធ្វើនូវអំពើ

អាក្រក់មានឋាណាតិឋាតជាដើម អំពីអតីតជាតិដោយពិត ប្រសិនបើអាត្មាអញធ្វើនូវអំពើដ៏លាមកនេះ ទៅអនាគតជាតិ អាត្មាអញមុខជាទឹងមានជាតិថោកទាបជាងនេះទៀតមិនខាន លុះពិចារណាដូច្នេះហើយ ក៏ញុំាងហិរិសេចក្តីខ្មាសឋាបឲ្យកើតឡើង មិនធ្វើនូវបាបកម្មមានឋាណាតិឋាតជាដើម ។

ហិរិ កើតឡើង ព្រោះពិចារណាជាតិដូច្នេះ ឈ្មោះថា "ព្រោះពិចារណាជាតិ" ។

ពាក្យថា "ព្រោះពិចារណាវ័យ" សេចក្តីថា វ័យមាន ៣ យ៉ាងគឺ បឋមវ័យ ១ មជ្ឈិមវ័យ ១ បច្ឆិមវ័យ ១ ។

វ័យគឺដំណាក់ ឬ រយៈកាលនៃអាយុដែលនៅក្នុងហៅថា បឋមវ័យ, ដំណាក់កណ្តាល ហៅថា មជ្ឈិមវ័យ, ដំណាក់ដែលចាស់ ហៅថា បច្ឆិមវ័យ។

បុគ្គលដែលស្ថិតនៅក្នុងបឋមវ័យ, កាលដួបប្រទះនឹងឋាបកម្ម មានឋាណាតិឋាតជាដើម ដែលខ្លួនល្មមធ្វើបានហើយពិចារណាថា អំពើដ៏លាមកនេះ អាត្មាអញមិនគួរធ្វើទេ លុះពិចារណាដូច្នេះហើយ ក៏ញុំាងហិរិសេចក្តីខ្មាសឋាបឲ្យកើតឡើង មិនធ្វើនូវឋាបកម្ម មានឋាណាតិឋាតជាដើម ។

បុគ្គលតាំងនៅក្នុងមជ្ឈិមវ័យ, កាលដួបប្រទះនូវឋាបកម្មមានឋាណាតិ-ឋាតជាដើម ដែលខ្លួនល្មមធ្វើបាន ហើយពិចារណាថា អំពើអាក្រក់នេះ

អាត្មាអញជាមនុស្សធំ ដ៏ឥតគុណ-ទោស-ខុស-ត្រូវ-ល្អ-អាក្រក់-បុណ្យបាប សត្វត្រូវប៉ះហើយ មិនគួរបើធ្វើទេ លុះតិចារណាដូច្នេះហើយ កំញ៉ាំងហិរិសេចក្តីខ្មាសបាបឲ្យកើតឡើងមិនធ្វើនូវបាបកម្មមានបាណាតិបាតជាដើម។

បុគ្គលដែលតាំងនៅក្នុងបច្ចុប្បន្នវ័យ, កាលដួចប្រទះនូវអំពើអាក្រក់ដែលខ្លួនល្មមធ្វើបាន កំតិចារណាថា អាត្មាអញនេះ ជាមនុស្សចាស់ទ្រេមទ្រេមយ៉ាងនេះ មិនគួរធ្វើនូវអំពើដ៏លាមកទេ លុះតិចារណាដូច្នេះហើយ កំញ៉ាំងហិរិសេចក្តីខ្មាសបាបឲ្យកើតឡើង មិនធ្វើនូវបាបកម្មមានបាណាតិបាតជាដើម ។

ហិរិ កើតឡើងព្រោះបុគ្គលតិចារណាវ័យ ៣ យ៉ាង ដូច្នេះឈ្មោះថា "ព្រោះតិចារណាវ័យ" ។

ពាក្យថា "ព្រោះតិចារណាសូរភាព" សេចក្តីថា ភាពនៃបុគ្គលអ្នកមានកម្លាំងក្លៀវក្លាអង់អាច ហៅថា សូរភាព ។ បុគ្គលអ្នកមានសូរភាពនេះត្រូវាស្តួត បព្វជិតក្តី កាលដួចប្រទះនឹងបាបកម្ម មានបាណាតិបាតជាដើម ដែលខ្លួនល្មមធ្វើបាន ហើយតិចារណាថា អំពើអាក្រក់នេះ អាត្មាអញជាមនុស្សក្លៀវក្លាក្នុងទីប្រជុំ មិនគួរធ្វើទេ លុះតិចារណាដូច្នេះហើយ កំញ៉ាំងហិរិ សេចក្តីខ្មាសបាបឲ្យកើតឡើង មិនធ្វើនូវបាបកម្មដូច្នេះឈ្មោះថា "ព្រោះតិចារណាសូរភាព" ។

ពាក្យថា «ព្រោះតិចារណាពាហុសច្ចៈ» សេចក្តីថា ភាពនៃបុគ្គល

អ្នកចេះដឹងច្រើន, អ្នកស្ទាត់ជំនាញច្រើន ឈ្មោះថាពាហុសច្ចៈ ។ បុគ្គលអ្នកមានពាហុសច្ចៈ កាលបើជួបប្រទះនឹងបាបកម្មដែលខ្លួនលាមធ្លើបានហើយតិចារណាថា អំពើដ៏លាមកនេះ អាត្មាអញជាអ្នកចេះដឹងច្រើន, ជាអ្នកស្ទាត់ជំនាញច្រើន មិនគួរធ្លើទេ ល្មុះតិចារណាដូច្នេះហើយ គំរាំងហ៊ារសេចក្តីខ្មាសបាបឲ្យកើតមានឡើង ដូច្នេះឈ្មោះថា "ព្រោះតិចារណាពាហុសច្ចៈ" ។

ហ៊ិរិ សេចក្តីខ្មាសបាបជាអង្គនៃសមុដ្ឋាន (មានហេតុខាងក្នុងជាសមុដ្ឋាន) ព្រោះតិចារណាហេតុ ៤ យ៉ាង ដោយប្រការដូច្នេះ ។

ហ៊ិរិ ឈ្មោះថា ជិគុច្ឆនលក្ខណៈ (មានការខ្ពើមបាបជាលក្ខណៈ) ឬជា សប្បតិស្សវលក្ខណៈ (មានការដឹងស្តាប់ជាលក្ខណៈ) ដោយប្រការដូច្នេះ ។

ហ៊ិរិ ជាអករណរសៈ (មានការមិនធ្លើបាបជាកិច្ច)

ហ៊ិរិ ជាសង្កោចនបច្ចុបដ្ឋាន មានការរួញរអែកនឹងការធ្លើបាបមានបាណាតិបាតជាដើមជាផល ។

ហ៊ិរិ ជាអត្តគារវបច្ចាន (មានការគោរពខ្លួន) គឺប្រាថ្នាឲ្យកខ្លួនជាធំហើយមិនធ្លើខ្លួវបាបតាំងឡាយជាហេតុ ។

๒ ចិត្តប្ប៉ា សេចក្តីខ្លាចបាប ជាពហិទ្ធាសមុដ្ឋាន (មានហេតុខាងក្រៅជាសមុដ្ឋាន), សេចក្តីថា បុគ្គលកាលជួបប្រទះនឹងបាបកម្មដែល

ខ្លួនល្មមធ្វើបាន ហើយតិតក្រែងរអែងហេតុខាងក្រៅថា បើអ្នកនឹងធ្វើនូវបាបកម្ម អ្នកមុខជានឹងជួលនូវសេចក្តីតិះដៀល ក្នុងចំណោមបរិសទ្យទាំងពួងជាពុំខាន ហើយពិចារណាថា: អ្នកចេះដឹងទាំងឡាយនឹងតិះដៀលអ្នក ដូចជាបុគ្គលមានអនាម័យរមែងស្អប់ខ្ពើមនូវតម្រងទុំស្អាតស្អាតគ្រាតដូច្នោះ អ្នកឯងត្រូវលោក អ្នកមានសីលទាំងឡាយចៀសចាំងហើយនឹងធ្វើដូចម្តេចកើត ? លុះពិចារណាដូច្នេះហើយ ក៏មិនហ៊ានធ្វើបាបកម្ម មានឫទ្ធាណាតិបាតជាដើម ។

ចិត្តបរិ: ជាលោកធិបតេយ្យ (មានលោកជាធំ) សេចក្តីថា កុលបុត្រខ្លះ ក្នុងលោកនេះ ប្រារព្ធយកលោកជាអធិបតី គឺយកអ្នកដទៃឲ្យជាធំថា លោកសន្និវាសនេះ ធំណាស់, សមណព្រាហ្មណ៍ទាំងឡាយអ្នកមានឫទ្ធិ មានចក្ខុទិព្វ ដឹងចិត្តរបស់អ្នកដទៃ តែងមានខៅក្នុងលោកសន្និវាសដ៏ធំនេះឯង ។ ពួកលោកទាំងនោះមើលឆ្ងាយក៏បាន, ជិតក៏បាន, ដឹងចិត្តដោយចិត្តបាន ។ បើពួកលោកដឹងឥឡូវហើយ មុខជានិយាយនឹងគ្នាលោក យ៉ាងនេះថា: "នែលោក ដ៏ចំរើនទាំងឡាយ ! លោកចូរមើលកុលបុត្រនេះ ចេញចាកផ្ទះមកបួសដោយសទ្ធា ហើយនៅតែប្រឡាក់ប្រឡូសដោយអកុសលដ៏លាមកទាំងឡាយទៀត" ។ ពួកទេវតាអ្នកមានឫទ្ធិ មានចក្ខុទិព្វ ដឹងចិត្តរបស់អ្នកដទៃតែងមានខៅក្រាកដក្នុងលោក ពួកទេវតាទាំងនោះមើលឆ្ងាយក៏បាន, ជិតក៏បាន, ដឹងចិត្ត

ដោយចិត្តក៏ជ្រាន , បើពួកលោកដឹងអញ្ជើហើយ មុខជាទៅយោងនឹងគ្នា លោកយ៉ាងនេះថា: « នែលោកដ៏ចំរើនទាំងឡាយ ! លោកចូរមើលកុលបុត្រនេះចេញចាកផ្ទះមកបួសដោយសទ្ធា ហើយនៅតែប្របួតប្របល់ដោយមកុសលដ៏លាមកទាំងឡាយទៀត " ។ លុះពិចារណាដូច្នេះហើយ ក៏លះអកុសលចេញ ហើយចំរើនខ្លួនកុសលឲ្យកើតឡើង លះកម្មខ្មៅចេញ ញុំាងកម្មមិនមានទោសឲ្យចំរើនឡើង យ៉ាងនេះឈ្មោះថារក្សាខ្លួនឲ្យបរិសុទ្ធ ។

ចិត្តបឋ: ឈ្មោះថា ជាលោតាធិបតេយ្យ (មានលោកជាធំ) ដោយប្រការដូច្នេះឯង ។

ចិត្តបឋ: ឈ្មោះថា កយសតាវិសល្លិតៈ (តាំងនៅដោយសតាពតីសេចក្តីតក់ស្លុតក៏ឃុតឃងក្នុងអច្ចាយ) ហើយមិនហ៊ានធ្វើច្បាប ព្រោះខ្លាចអច្ចាយនោះ ដូចជាបុគ្គលអ្នកមានទ្រព្យដាំមិនហ៊ានចាប់ដុំដែកក្តៅ ដែលភ្លើងកំពុងឆេះរន្ធាលច្រាលឡើង ព្រោះខ្លាចរលាកដូច្នោះ ។

ចិត្តបឋ: តាំងនៅដោយសតាពតីសេចក្តីខ្លាចច្បាប ដោយប្រការដូច្នេះ ។

ចិត្តបឋ: ជាទុក្ខាសលក្ខណៈ (មានសេចក្តីតក់ស្លុត) ចំពោះអំពើទុច្ចរិតជាលក្ខណៈ ឬជា វិរុទ្ធកុកកុច្ចវិលក្ខណៈ (មានការខ្លាចទោសនឹងឃើញភ័យជាលក្ខណៈ) មាន ៤ យ៉ាងគឺ:

១-អត្តានុវាទភយ ខ្លាចខ្លួនឯង តិះដៀលខ្លួនឯងបាន,

២-បរានុវាទភយ ខ្លាចបុគ្គលដទៃ តិះដៀលខ្លួនឯងបាន,

៣-ទណ្ឌភយ ខ្លាចព្រះរាជអាជ្ញា,

៤-ទុគ្គតិភយ ខ្លាចកំណើតទុគ្គតិ ។

ទុតិយប្ប: ឈ្មោះថា ទុច្ចរិតលក្ខណ: (មានការតក់ស្លុតខ្លាចជាលក្ខណៈ) ឬជា វិប្បដិសារលក្ខណ: (មានការខ្លាចទោសប្តឹងយើញកំយ) ក្នុងហេតុទាំង៤ យ៉ាង មិនហ៊ានធ្វើជាលក្ខណៈដោយប្រការដូច្នេះ ។

ទុតិយប្ប: ជាអករណរស: មានការមិនធ្វើជាកិច្ច ។

ទុតិយប្ប: ជាសង្កោចនប្បច្ចុបដ្ឋាន មានអាការរអែងក្រែងរអែងក្នុងការធ្វើជាដរាប ។

ទុតិយប្ប: ជាបតាវៀបច្ចុដ្ឋាន (មានការគោរពកោតក្រែងបុគ្គលដទៃ) ហើយមិនហ៊ានធ្វើជាហេតុ ។

ហិរិនិទ្ទេស ទុតិយប្ប: ពាំងតាំនេះ ជាធម្មិគ្រប់គ្រងរក្សាបុគ្គលអ្នកប្រព្រឹត្តសង្ឃឹមខ្លួនធម៌ ឲ្យជាទទួលនូវសេចក្តីសុខ-ចំរើន មិនឲ្យមានសេចក្តីទុក្ខ វិនាស អន្តរាយ ។ ជាធម្មិមានគុណប្រាកដក្នុងការវៀរចាកបាបរបស់បុគ្គលអ្នកប្រព្រឹត្តធម៌សាំងពីរប្រការនេះ ទើបបានឈ្មោះថា ជាអ្នកមានអំពើល្អ ទើបឈ្មោះថា ជាមនុស្សធម៌ ជាអំពើឲ្យអស់ភ័យដល់ដាំតែ,

ទ្រព្យសម្បត្តិ, ទ័ក្ខិណេយ្យបុគ្គលជាអ្នកដាំពូជ ឈ្មោះថា ជាអ្នកនាំមកនូវសេចក្តីសុខចំរើន ដល់អ្នកដាំពូជផង ដល់ពួកជនដែលបរិភោគផង តាំងពីមានជីវិតរស់នៅ លុះស្លាប់ទៅរមែងមិនទៅកាន់ទុគ្គតីឡើយ ។

ហេតុនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សរសើរអំពីអានិសង្សនៃបុគ្គលអ្នកប្រព្រឹត្តធម៌ ដូចមានក្នុងគម្ពីរធម្មបទ ទុកនិកាយ ត្រង់ឃមកវគ្គថា :

ឆម្មោ ហាវេ វក្កតំ ឆម្មចារឺ
ឆម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ឆម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ឆម្មចារ ។

ធម៌ហ្នឹងឯង រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលសន្សំហើយ រមែងនាំមកនូវសេចក្តីសុខ កាលបើបុគ្គលសន្សំធម៌ដោយប្រពៃហើយ រមែងបានផលនូវអានិសង្សយ៉ែបនេះមិនខាន, បុគ្គលអ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតីឡើយ ។

ធម៌តំណពីរប្រការគឺ: ហិរិនិងឱត្តប្បៈនេះ រមែងឃុំគ្រងរក្សាលោក (ត័ព្ភកសត្ត) អ្នកប្រព្រឹត្ត ឲ្យជាគណៈជាក្រុម នៅជាសុខសប្បាយ ដូចជាមាតាបិតារក្សាបុត្តធីតាឲ្យបានសេចក្តីសុខ រឿរមិនឲ្យបៀតបៀនគ្នានឹងគ្នាដូច្នោះ ។

មែនពិត មនុស្សក្នុងលោកនេះ ដែលហ៊ានប្រព្រឹត្តឈ្លានពាន

មានការគាប់សម្លាប់គ្នា លួចប្លន់ធន់ជណ្តើមទ្រព្យសម្បត្តិទីតន្ទៃនិងនិងគ្នា ដើម្បីគ្នាទើនគ្នាឲ្យវិនាសអន្តរាយដោយប្រការផ្សេង ។ ជាច្រើនបែបច្រើនយ៉ាងនោះ កំព្រោះតែគ្មានធម៌ពីរប្រការនេះ សំរាប់គ្រប់គ្រងថែរក្សា ។ ដូច្នេះ បើជនទាំងឡាយក្នុងលោកសន្និវាស មានធម៌ពីរប្រការនេះ គ្រប់គ្រងរក្សាហើយ មុខជាមិនមានការបៀតបៀនគ្នាឡើយ ។ អាស្រ័យការមិនបៀតបៀនគ្នានេះ សេចក្តីសុខ ក៏ទើរតើតមានឡើងជាប្រាកដ សមទើរព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា អព្យាបជ្ឈំ សុខំ លោកេ ការមិនបៀតបៀនគ្នា ជាសុខ ក្នុងលោក ។

អ្នកប្រាជ្ញទាំងឡាយតែងឃើញធម៌ឯក គឺ អហិរិកៈ ទើរអនោត្តប្បៈ ជាជា (អំពើដ៏លាមក) ទើបមានធម៌សគឺ ហិរិទើរត្តប្បៈ ស្អប់ខ្ពើមអំពើទាំងនេះ ដូចជាគេខ្ពើមខ្លាចពស់អសិពិសដែលពេនត្រាំក្នុងលាមក ។

ម្យ៉ាងទៀតទៅទៀត លោកទាំងឡាយមានមាតា-ម្តាយមើន-ម្តាយធំ ទើរតាយាបេះអាចារ្យជាដើម ចើធម៌ទាំងពីរនេះ មិនរក្សាទ្វារលោកទេ លោកទាំងឡាយនោះ ក៏មិនប្រាកដថាជាអ្វី ក្នុងលោកនេះដែរ គឺមុខជាទើរដល់ទ្វារសម្លេង ដូចសត្វតិរច្ឆានជាពុំខាន ។

សមដូចព្រះគាថាថា:

ទ្វេមេ កិត្តវោ សុក្កា ឆម្មា លោកំ ចាលេន្តិ ។ តតមេ ទ្វេ ។ ហិរិ ច ឱត្តប្បំ ច ។ ឥមេ ខោ កិត្តវោ ទ្វេ សុក្កា ឆម្មា លោកំ ន ចាលេយ្យុំ ន យិទ បញ្ញា.

យេ ๘ មាតាតំ ๗ មាតុច្ឆាតំ ๗ មាតុលានីតំ ๗ អាចរិយភរិយាតំ ๗ ភគ្គំ ធាវតំ ๗ សម្ភេទំ លោកោ អភមិស្សរ យថា អនេឞ្ឆកោ ភុញ្ជេ ដសូភកោ សោណសិគាលោ ។

" ម្នាលភិក្ខុទាំងឡាយ ធម៌សទាំង៧ប្រការនេះ តែងរក្សាទូរលោក ។ ធម៌សទាំង៧ប្រការនេះ តើដូចម្តេច ? ធម៌សទាំង៧ប្រការនោះគឺ: ហិរិ ឧត្តប្ប: ១ ។ ម្នាលភិក្ខុទាំងឡាយ (បើ) ធម៌សទាំង៧ប្រការនេះមិនរក្សាទូរលោកទេ, លោកនឹងមានភាពមិនប្រក្រតី ម្តាយមិនប្រក្រតី ឪពុកមិនប្រក្រតី ភរិយារបស់អាចារ្យក្តី ប្រពន្ធរបស់គ្រូក្តី ក៏មិនប្រាកដក្នុងលោកដែរ មុខជាដល់នូវសម្ភេទ (ការច្របូកច្របល់) ដូចជាសត្វតិរច្ឆានគឺ ក្អែក, ចចក, មាន់, ឆ្កែ, ឆ្កែនឹងជាតជាដើម ដុំខាន » ។

ធម៌សពីរយ៉ាងគឺ ហិរិ នឹង ឧត្តប្ប: នេះជាឫសគល់នៃកុសលធម៌ទាំងពួង ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ មានកាមាវចរភូមិជាដើម ជាធម៌ឃុំគ្រងរក្សាលោកឲ្យបានសន្តិភាព មិនឲ្យប្រព្រឹត្តទុច្ចរិតមានការកាប់សម្លាប់គ្នាជាដើម ទើបឈ្មោះថា " លោកបាលធម៌ " ដូច្នេះ ។

ក្នុងទេវធម្មជាតកថា: សាធុជនទាំងឡាយអ្នកប្រកបដោយហិរិនឹងឧត្តប្ប: អ្នកដឹកនាំនៅមាំក្នុងធម៌ស អ្នកសួរនាំអ្នក អ្នកថ្លាថ្នូទាំងឡាយ មានព្រះតេជៈជាដើម ហៅថា " អ្នកទ្រទ្រង់នូវទេវធម្មិកក្នុងលោក " ។

ព័ណ៌នា អំពីលោកបាលធម៌ ចប់តែប៉ុណ្ណេះ ឯង ។

សុរពជាតក

(តទៅ)

លោក ជង-រីង បកប្រែពីសាស្ត្រាស្ងឹកវិត

ជ្រាថ្នាក់អ្វី ។ កំនើនថ្វាយតាមសត្តព្រះពជហឫទ័យ ។ ពជខ្លួតទទួលព្រះពជសារនាំចូលទៅដល់ភ្នំព្រះពជកំនត ហើយជ្រាប់ដល់អាមាត្យទ្រាំសេចក្តីនេះទៅគ្រាបទូលដល់ព្រះបរមក្សត្រាធិពជ ។ លុះទ្រង់ជ្រាបហើយព្រះមហាក្សត្រ កំទ្រង់ឲ្យពជខ្លួតនោះចូលទៅគ្រាបបង្គំគាល់ ហើយត្រាប់សួរថា តត្ថតោ អាគតោតិ ម្នាលពជខ្លួត! អ្នកមកពីប្រទេសណា ? ។ ពជខ្លួតក្រាបបង្គំទូលថា បតិត្រព្រះសម្មតិទេព! ខ្ញុំព្រះបង្គំមកពីខ្ពង់ឈ្មោះដូច្នេះ ។ តកស្មា អាគតោតិ ស្តេចមានព្រះពជទន្លាត្រាស់សួរថា ចៅមកតើមានជ្រាថ្នាក់អ្វី ? ។ ពជខ្លួតក្រាបទូលតាមដំណើរហើយថ្វាយព្រះពជសារចំពោះព្រះមហាក្សត្រ ។ ស្តេចឲ្យអាមាត្យម្នាក់មើលក្រាបសេចក្តីសព្វគ្រប់ហើយ មានព្រះបន្ទូលថា គោ ពជខ្លួត ម្នាលពជខ្លួតដ៏ចំរើន! យោ ច រកុមារណា ចេះប្រលោមលួងលោមព្រះពជបិតានៃយើងឲ្យសោមនស្សក្តី ឲ្យចេញជាមួយក្តី យើងទទឹងអកិ-សេកជាមគ្គមហេសីនៃព្រះពជកុមារនោះ ព្រមទាំងឲ្យសោយពជសម្បត្តិជាក្សត្រប្រសើរស្មើនៃយើងហោង, ម៉ែពជខ្លួត ! ចូរចៅនាំពាក្យនៃយើងទៅទូលព្រះពជកុមារជាម្ចាស់ចៅហោង។ ពជខ្លួតទទួលព្រះពជទន្លាត្រេច

ហើយ, ត្រឡប់មកគ្រាបទូលព្រះពរជកុមារវិញ ។ ឯព្រះពរជកុមារគេត្រង់ត្រឿងប្រដាប់លីលាយាត្រាចូលទៅតាល់ព្រះបាទវេឡុមារជិតពរជ អង្គុយទៅក្នុងទីដ៏សមគួរ ។ ក្រុណាទោះ ព្រះបាទវេឡុមារជិតពរជ ស្តេចឧតរទៅឃើលព្រះពរជកុមារ មានព្រះតម្រិះយល់ប្រកៃ ទ្រង់ពិចារណាថា អហោ ន! ព្រះពរជកុមារនេះ គួរពិតពិលរមិលមើល ប្រកបដោយលក្ខណាសួស្តី មានឧកាសដ៏រុងរឿង ដូចជាទេវបុត្តឬតិរមានទេវលោកនាយ ស្តេចទ្រង់ព្រះពិន្តាដូច្នោះហើយ មានព្រះបន្ទូលទៅតាមអជ្ឈាស្រ័យ ហើយត្រាស់ប្រើឲ្យទៅថ្លាន់នាព្រះបាសាទព្រះពរជធីតា ។ ព្រះពរជកុមារកើបគ្គិលចូលទៅកាន់ប្រាសាទព្រះពរជធីតា ទ្រង់ព្រះដម្រិះថា អាត្មាអញស្រដីនឹងរបស់អ្វីជាមុនិ៍ លុះឧតរទៅឃើលចំញៀនព្រះខំរង់ ដែលព្រះពរជធីតាកំពុងទ្រង់ កំពុងមន្តបែងចិត្តជាក់ក្នុងចំញៀនត្រះខំរង់ ជាស់តាមាំបញ្ចូលទៅ ទើបព្រះពរជកុមារហៅចំញៀនព្រះខំរង់ថា ម្នាលចំញៀន! ។ ចំញៀនព្រះខំរង់ កំឆ្លើយថា តើ សាមិ បពិត្រអ្នកជាម្ចាស់! ហៅខ្ញុំម្ចាស់មានហេតុអ្វី? ។ ព្រះពរជកុមារត្រាស់ថា ម្នាលចំញៀន! យើងប្រាថ្នាចង់ស្រដីនឹងព្រះនាងកល្យាណី តែព្រះនាងកល្យាណីពុំស្រដីនឹងយើង ទើបយើងស្រដីនឹងឯង តើឯងស្រដីនឹងយើងឬទេ? ។ - បពិត្រព្រះពរជកុមារ! បើអម្ចាស់ត្រាស់នឹងខ្ញុំ។ ស្រដីហោង ។ - ម្នើដូច្នោះយើងនឹងដណ្តើងសួរទៅ។ - តើ ឬចុះសិ ព្រះអង្គដណ្តើងអ្វី? ។ - អើម្នើដូច្នោះ ទៅចាំស្តាប់

យើង ។ ខ្ញុំនិងនាងរឿងមួយ ចូរគាំងចិត្តស្តាប់ តតទ្បាយល់ ត្រាប់តែប៉ុណ្ណោះ កំនាំនិងនាងពីព្រេងនាយមកត្រាស់ថា:

កុងបុរី មានឧទានព័ុកណាមកថា មានមាណព ៤ នាក់ទៅរៀនសិល្បសាស្ត្រនៅឧត្តរតក្កសិលា, មាណពម្នាក់រៀនដប់ដឹងមនុស្សឲ្យរស់, មាណពម្នាក់រៀនខាងពោរពាយ, មាណពម្នាក់រៀនខាងសិល្បធ្នូ, មាណពម្នាក់ទៀតរៀនខាងវិជ្ជាមុជទឹក; មាណពទាំង ៤ នាក់លុះរៀនចប់សព្វគ្រប់ហើយ គំណាងាវ្យទិសាថា មាក្នុលែមកស្រុក ដើរតាមមាគ៌ាក្នុងវាលស្ងាប គំនាំគ្នាចូលទៅអស្រ័យនៅក្រោមដើមឈើធំ ១ ទៀបឆ្នេរមហាខ្ទី, ឯកោះ មាណាភៅ មាណពម្នាក់ដែលចេះហោរ ច្រាប់ទៅមាណពទាំង ៣ ថា អន្លោ ម្នាលគ្នាយើងអើយ ; បន្តិចទៀតនឹងមានសត្វឥន្ទ្រីតាំព្រះពជធីតាម្នាក់មកត្រង់យើងឥឡូវហើយ, ឯមាណពចេះសិល្បធ្នូស្រដីថា បើដូច្នោះ, ខ្ញុំនឹងបាញ់សត្វឥន្ទ្រីនោះ ។ មាណពទាំងនោះនិយាយគ្នា មិនទាន់ចប់ផង, ស្រាប់តែនោះ សត្វឥន្ទ្រីតាំយកព្រះពជធីតាហើរស្ទុះមកតាមអាកាសមែន ។ មាណពចេះសិល្បធ្នូបាញ់សំរុងទៅសត្វឥន្ទ្រី កំឡាក់ព្រះពជធីតាមកក្នុងមហាខ្ទី រលត់ព្រះជន្មលិចបាត់ទៅ ។ មាណពចេះមន្តមុជទឹក ក៏លោតចុះមុជតាវែក លុះឃើញហើយថ្មមនុបម៌ត្រកងយកឡើងមក ។ មាណពចេះមន្តដប់ ក៏យកមន្តដប់ដឹងព្រះពជធីតាឲ្យរស់ក្រោកឡើងអង្គុយទៅហោង ។ មាណពទាំង ៤ នាក់

គន់មើលទៅព្រះពោធិសត្វនោះ មានរូបស្រស់ចំត្រង់ ដូចគល់ទៅតា ក៏
មានចិត្តប្រតិព័ទ្ធស្រឡាញ់ត្រង់គ្នា, វេស្សកុមារោ តំ អនាសំ ឃុច្ឆិ
ទើបព្រះចៅវេស្សកុមារ សួរទៅចិញ្ចៀនព្រះខ័នដ៏ថា តោ លភតិ
វិទ្ធិ តើមាណពណា គួរបានព្រះពោធិសត្វនោះជាប្រតន្ធ? ។ ចិញ្ចៀន
ឆ្លើយថា បពិត្រព្រះពោធិកុមារ! នាងនោះគួរបានជាកំរៀវនៃមាណពអ្នក
ច្រោះឱ្យរស់នោះហាន ។ ព្រះពោធិកុមារត្រាស់ថា ម្នាលចិញ្ចៀន! អ្នក
ស្រដីនេះពុំគួរឡើយ។ ថ្លែងពីព្រះនាងកល្យាណី ទ្រង់ព្រះសណ្តាប់ចិញ្ចៀន
ព្រះខ័នដូច្នោះ ទ្រង់ពាស់ព្រះទ័យ ហើយជាប់ចិញ្ចៀនថ្លែងថា ម្នាល
ចិញ្ចៀន! ប្រសែងស្រដីដូច្នេះ ពុំត្រឹមត្រូវឡើយ យោ អាកាស-
ធញ្ញំ រាមាណពដែលចេះមើលនក្សត្រឫក្សឰដ៏អាកាស គួរជាតំកុកជា
បិតា, មាណពចេះសិល្បៈធ្នូ គួរជាតំកុកជាបង, មាណពដែលច្រោះឱ្យរស់
ដំរែត គួរជាតំកុកជាម្តាយ, ឯមាណពចេះសិល្បៈមុជទឹក គួរបានជាស្វាមី
នៃនាងនោះ ព្រោះបានឧបត្រូវសោបច័ច្ចមប៉ះពាល់សព្វសព៌ាង្គកាយនៃ
នាង ។ ត្រេកពោធិសត្វទ្រង់មានព្រះពោធិសវិទ្យាតែប៉ុណ្ណោះ ក៏ទ្រង់ ស្ងៀម
ស្ងាត់ទៅវិញ ។ ឯមហាជនទាំងឡាយឮសព្ទសម្តីនៃព្រះនាងកល្យា-
ណីចរចា ក៏នាំគ្នាប្រតំនូវដូរៀបដន្ត្រីឮកងរំពងពេញទាំងព្រះបរមពោធិ ។
ទើបព្រះពោធិកុមារ យកចិត្តចេញពីចិញ្ចៀនព្រះខ័នទៅដាក់នឹងផ្តិលមាស

ហើយគ្រាស់ខឹងផ្តិលថា ម្នាលផ្តិលមាស ! ឯយើងត្រូវចរចានឹងចៅតៅ
ទៀត ។ ផ្តិលមាសទូលថា បពិត្រព្រះពជបុត្រ ! ព្រះអង្គចង់សួរអ្វី
សូមសួរចុះ ។ ព្រះពជកុមារក៏នាំមក នូវនិទានដូចតទៅនេះ :

ក្នុងកាលដែលកន្លងទៅហើយ មានមាណព ៤ នាក់ចេញទៅរៀន
សិល្បសាស្ត្រនៅឥតតែក្តីសោក លុះរៀនត្រឡប់មកស្រុកវិញជល់នាក់
កណ្តាលផ្លូវជួនជាជល់រៀលល្ងាច នាំគ្នាដេកនៅក្នុងព្រៃ ។ មានខ្លា
មួយយ៉ាងធំដើរចូលមកប្រុងនាំមាណពទាំងនោះស៊ី ។ មាណពទាំង ៤
ឃើញខ្លាដូច្នោះ ពុំហ៊ានដេកឡើយ នាំគ្នាដុតភ្លើងឡើងអង្គុយ ។
ឯតោ ឃាណាភៅ មាណពម្នាក់ដែលចេះសិល្បៈខាងខ្លាក់ កំយក
ខ្លឹមចន្ទន៍មកខ្លាក់ជារូបស្រីមួយយ៉ាងល្អឯក, មាណពដែលរៀនសិល្បៈ
ខាងជាស់ កំជាស់បង្កើតអស់អាការៈតួច-ធំគ្រប់ សក់ ភេម ក្រចក ត្រម
ទាំងអវយវៈដទៃទៀតនៃស្រីនោះ, មាណព ចេះសិល្បៈប្រោះដំរីតមនុស្ស
ឲ្យរស់ កំជប់ធ្វើជីវិតស្រីនោះឲ្យរស់ឡើង, ឯមាណពម្នាក់ទៀតកំពុយមន្ត
ឧស្ម័តជាសំលៀកបំពាក់ សំពប់ជាគ្រឿងប្រើប្រាស់នៃស្ត្រីនោះ ។ ទើប
ព្រះវេជ្ជកុមារសួរផ្តិលមាសថា ម្នាលផ្តិលមាស ! ឥឡូវ បុរសទាំង ៤
នាក់ឃើញរូបនាងនោះល្អដូចទេវតា ចង់បានជាគ្រប់ៗគ្នាទើ តើគួរបាន
ទៅបុរសណា ? ។ ផ្តិលមាសទូលថា បពិត្រព្រះពជកុមារ ! នាង
នោះគួរបានទៅបុរសដែលឲ្យជីវិតនោះហាន ។ ព្រះពជង្គតា ទ្រង់ព្រ

ផ្តិលមាសទូលដូច្នោះ កំពស់តួនព្រះពជហឫទ័យ ស្តីបន្ទោសផ្តិលមាស ថា ម្នាលប្រស្នែង! ហេតុអ្វីក៏ប្រស្នែងទូលព្រះពជកុមារដោយសេចក្តីវង្វែងវង្វាន់ដូច្នេះ! គួរបុរសដែលចាំងឈើធ្វើរូបនោះជាបិតា, បុរសអ្នកធ្វើត្រចៀក ច្រមុះ មុខ មាត់ គួរជានជាបង. បុរសអ្នកប្រុះឲ្យរស់ គួរជានជាម្ចាយ, បុរសអ្នកឲ្យគ្រឿងស្បែកពាក់នឹងគ្រឿងតែងច្រាណ គួរជានជាស្វាមីនាងនោះហោង; ព្រះនាងទ្រង់មានព្រះពជសន្ទនីយ៍តែប៉ុណ្ណោះគឺគង់ស្ងៀមទៅវិញ ។ ឯមហាជនទាំងគ្នាប្រគំដូរឫជន្ត្រីឡើង ឮសូរទ្រហឹងអឺងអាប់ ។ ឯព្រះពជកុមារក៏ដកចិត្តចេញពីផ្តិលមាស ឃុតទៅជាក់តួនឱ្ចីយហើយហៅថា ពិន្ធោមាន ម្នាលឱ្ចីយ! យើងត្រូវដណ្តឹងប្រស្នានឹងទៅ ចូរចាំធ្វើយហោង ។ ឱ្ចីយធ្វើយថា បើព្រះអង្គចង់ដណ្តឹងប្រស្នាអ្វី សូមទ្រង់ដណ្តឹងចុះ ។ ទើបព្រះវេជ្ជកុមារនាំមកនូវនិទានថា:

កុងកាលដែលកន្លងទៅហើយ មានបុរសម្នាក់ជានធ្វើកម្មដ៏ធ្ងន់ ។ ព្រះមហាក្សត្រ ទ្រង់បញ្ជាឲ្យគេជោតឆ្កាងបុរសនោះទាំងរស់ ទៅក្បែរទ្វារព្រះនគរ ។ បុរសនោះរងនូវសេចក្តីទុក្ខដ៏ខ្លាំងក្លា ។ ក្បែរនោះមានស្ត្រី៤នាក់ ដើរមកឃើញបុរសនោះមានរូបល្អ ក៏មានចិត្តប្រតិព័ទ្ធស្រឡាញ់ត្រេកត្រអាល ។ ស្រីម្នាក់យកមាស ១.០០០ ដុំឡើង ទៅថ្វាយព្រះមហាក្សត្រ សូមដោះដីវិតនៃបុរសនោះ. ស្រីម្នាក់ទៀតយក ពីក ខំ ចំណី,

ស្រីម្នាក់ឲ្យនុសថគឺថ្នាំ លាប ផឹក, ស្រីម្នាក់ទៀត បំរើទឹកក្តៅ ទឹកត្រជាក់ ស្ពឹ លាងខ្លះ លាងដំរេចៅ រក្សាថែទាំពេលយប់ថ្ងៃ ត្រមាំងឲ្យកន្ទេលខ្ញុំយ ទឹងដូសលាងសំលៀកបំពាក់របស់បុរសនោះ ម្នាលខ្ញុំយ! ស្រីណាជាន់ជាកំយានៃបុរសនោះ? ។ ខ្ញុំយខ្ញុលថា បពិត្រព្រះពជកុមារ! រីស្ត្រីដែលយកមាសមៅដោះជីវិត ត្រូវជាន់ជាកំយោហោង ។ ឯព្រះនាងកល្យាណីស្តាប់ហើយ តុំត្រូវព្រះពជហប្តំយខ្លាំយ ហើយមានព្រះពជូសរនៃយ៍ថា: ម្នាលខ្ញុំយ! ប្រស្នែងស្រដីនោះពុំគួរទេ, ប្រស្នែងមៅទឹងយើងតុំចេះដឹងអ្វីសោះ ប្រស្នែងស្តាប់ហើង។ ទឹងប្រាប់: រីនាងដែលដោះជីវិតបុរសនោះ គួរជាន់ជាបិតា ព្រោះបិតាតែងឧបត្ថម្ភគ្រួសារ, យា ទ កោ ជនា ហារំ រីនាងដែលឲ្យអាហារបរិភោគគួរជាន់ជាមាតា, រីនាងដែលស្ងួរស្ងែងរកនុសថមកឲ្យបុរសនោះលាបផឹកគួរជាន់ជាបង, រីនាងដែលប្រតិបត្តិដោយទឹកក្តៅទឹកត្រជាក់ ចោសតួកកន្ទេលខ្ញុំយ គួរជាន់ជាកំយាបុរសនោះ ។ ព្រះនាងកល្យាណីស្រដីតែប៉ុណ្ណោះក៏ស្ងៀមទៅ ។ អស់មហាជនក៏ប្រគំក្តេងឆ្លងទៀត ។ ក្នុណោះព្រះពជកុមារក៏ដកចិត្តចេញពីខ្ញុំយ យកមៅជាក់ក្នុងព្រះភួសារបស់ព្រះនាងហើយត្រាស់ដណ្តឹងថា ម្នាលព្រះភួសា! ចូរស្តាប់ខ្លួនិទានដូចតមៅ:

ក្នុងកាលដែលកន្ទងមៅហើយ មានស្រី ៤ នាក់ នាំគ្នាស្ងួរស្ងែងរកប្តីដើម្បីឲ្យជានគាប់ចិត្ត ជានមៅជួបនឹងបុរស ៤ នាក់ កំពុងស្ងួរស្ងែងរក

ប្រគន្ធដែរ កំសន្ធនាគ្នាទៅវិញទៅមក ។ បុរសម្នាក់ដណ្តើនសួរស្រីថា
កុតរាស្មឹ វែសសិ តន្ទេ ម្នាលប្អូន! ប្អូននៅភូមិណា? ។ សា តីវិ
បរាមសិត្វា ស្រីនោះបកដៃអង្អែលតហើយឆ្លើយថា ផ្ទះខ្ញុំនៅត្រង់
នោះ។ ឯណោ ឯតំ បុច្ឆិ បុរសម្នាក់ទៀត សួរស្រីម្នាក់ទៀតថា ផ្ទះ
នាងនៅត្រង់ណា? ។ ស្រីនោះយកដៃស្ទាបសិរសា ហើយថា ផ្ទះខ្ញុំនៅ
ត្រង់នេះ ។ បុរសម្នាក់ទៀតសួរទៅស្រីមួយទៀតថា ផ្ទះនាងនៅត្រង់
ណា? ។ ស្រីនោះបកដៃស្ទាបថ្ពាល់ ហើយថា ផ្ទះខ្ញុំនៅត្រង់នោះ ។
បុរសទី៤ សួរទៅស្រីម្នាក់ទៀតថា ផ្ទះនាងនៅត្រង់ណា? ។ ស្រី
នោះយកដៃស្ទាបដោះហើយថា ផ្ទះខ្ញុំនៅត្រង់នោះ ។ ស្រីទាំង៤នាក់
លុះប្រាប់ដូច្នេះហើយ កំលាបុរសទាំង៤នាក់ទៅ ។ ឯបុរសទាំង៤
ដំខុំតិចាវណាគ្នាអំពីប្រស្នារបស់ស្រីទាំង ៤ នាក់ សួរគ្នាទៅវិញទៅមក
អញ្ជាក្តៅចិត្តខ្លាចផ្សា ខ្ទីឯខ្លោចអាខ្លាចត្រែ ។ អញ្ជាត្រូវតែបំផ្លាញ ខ្លា
ឲ្យសាញអស់តាំត្រៃ សំឡាប់ឲ្យក្បែណាស្ងួយ ឲ្យស្គាល់ដៃពពស់ហ៍ ។
ដូច្នេះហ្នឹងចចក បើខ្លាមកត្រូវយាត្រា ទៅច្រាប់អញ្ជាធាប់ក៏ ដោយវាចា
ដ៏ស្ងប់ស្ងាត់ ។

ចចកស្តីរួចស្រេច វាគេចមុខច្បើមឆ្ងាត ច្រាប់ខ្លាតាំវិបត្តិ ឲ្យខ្លាខ្លាត់
ដោយថៃមថា ។ ខ្ញុំគិតខ្លាចលោកស្តាប់ ខ្ញុំមិនច្រាប់ហេស្សការណ៍ ដែល

លោកចរយោគ្រា ឲ្យស៊ីហាដ៏ធ្ងន់ខ្លះ ។ ដូច្នេះដរាបណា ពួកស៊ីហានៅឯឆ្នេរ - ស្ងួនោះត្រូវលោកវេ កុំខំនេរវត់ឲ្យឆាប់ ។ ទើបរួចជីវិតបាន បើមិនភ្លាន់មុខតែស្លាប់ ដូច្នេះសូមប្រញាប់ ដោយឲ្យបាត់កុំបង្អង់ ! ។

ខ្ញុំតែយខ្លាំងណាស់ ឆ្លើយហ៊ានមិនពាល់ តួយតើយខ្លួនមាលដ៏ ដោយក្តីល្ងង់មិនជ្រាបការណ៍ ។ សូមតួយជួយមានដ៏ ឲ្យបានធួនមរណា សូមកុំប្រាប់ស៊ីហា មាសុំលាតួយសិនហើយ ! ។ លាតួមខ្លាយតែតួក លឿនត្រដែតឥតយឺតឡើយ ដោយសារតែយឥតស្បើយ មិនត្រឡើយវាគេចបាត់ ។

ចចកសែនរីកយ មុខតក្រាយក្រែងខ្លាខ្លាត់ ដោយក្រែងវាតំបាត់ ផ្តួតវិបត្តិដ៏វិតវាំង ។ លេចមុខឯពានរ មួយមតឈរឆ្លើយកេ ចចកឃើញបងស្លា ត្រែះរែះថាបងស្លានេះ ។ វាមានឆ្នាញ់មុតស្ទ្ច ត្រូវអញ្ជើញដោយចំណេះ បំភាន់ដោយចរិតនេះ ឲ្យសាត្រែរហែកដំរី ។ តិតហើយវាញញឹម មុខប៉ប្រឹមចេញសំដី តួយអើយចុះហេតុអី ស្បើមវាហ៊ានមុខក្រៀមម្ល៉ះ ? ។ មានពានឃើញយូរហើយ នែតួយអើយចូលមកណោះ តួយឯងចេះតែវេះ មាឯនេះចេះតែទឹក ! ។ ម៉េចទៅគ្រូសារយើង មានឹកឡើងសែនរញ្ជួយ សុខទុក្ខពេលល្ងាចព្រឹក រឿងបាយទឹកយ៉ាងណាទៅ ? ។ មាម៉ើលទៅមុខតួយ ចែបដូចព្រួយចិត្តម្ល៉ៅ ឃ្លានបាយប្តូ

ខឹកចៅ ? កុំសោកស្ដៅហ្នឹងដ៏ខ្លះ ។ ជារបស់នៃកេសរ លោកប្រើមាមក៏ចាំទិ រក្សាដោយសម្ដី ក្មួយឯងស៊ីមួយនែ្លតចុះ ! ។ កុំភ័យកុំបារម្ភក្មួយឯងនឹងឲ្យតេញគោះ នែ្លតលើយសឹមលែងគ្នោះ ទៅគោះភ្ញៀកដេកសប្បាយ ។ ចំណែកឯខ្លួនមា ចាំគោរពតើចម្ងាយ ម៉ែលេចយើញរូបកាយ ស៊ីហាដាយមកមាច្រាប់ ។

ពានរឮដូច្នោះ ភ័យញ័រគោះធ្វើយប្រញាប់ អៃយ៉ា ! ស៊ីហើយស្ងាប់ ឃ្វាងដឹតជាប់តឹងដៃ ។ លោកតូសូមមេត្តា កុំវាឲ្យក្មួយប្រដាក្ខុដោយសារតែ តែពីរឿងដែលស៊ីលន់ ។ ព្រោះគាសិតគោលថាក្ដីសុខជាខគន់វាំ ព្រោះមានជីវិតគន់- ទ្រន់លន់យូរពប់រយឆ្នាំ ។ ដូចជានាងសីតា ជួបតស្ដាគូប្រចាំ ព្រោះនាងរស់យូរឆ្នាំ តាមចំណាំអាយុវែង ។ ហេតុនេះខ្ញុំមិនអាច ធ្វើល្អាល្អាចឥតតិតក្រែង ដឹកនាំខ្លួនប្រាណឯង ឲ្យតម្កែងកដស៊ីហ៍ឡើយ ។

បបតបង្គំស្ងា ដោយវាចាថាក្មួយអើយ ! មានៅដឹតបង្កើយ កុំព្រួយឡើយមាគាគោរ ។ គាលណាពដស៊ីហ៍មក មាលែលកឲ្យគាន់គារ ប្រាប់ក្មួយឲ្យយាត្រា ផុតមរណាដោយសុខសាន្ត ។ ហេតុនេះក្មួយកុំភ័យ មិនក្ស័យទេកុំខកខាន បរិភោគឲ្យស្កប់ប្រាណ ទើបយើងមានកំឡាំងដើរ ។

ចចកបង្ខំខ្លាំង ស្ទាក់ស្ទាំងគ្រោះគ្នាល្ខី ស្មានថាគេអើតើ មក
លើខ្លួនដោយពិត ។ ។ ក៏ឆ្លើមហែកខំណាយ សែ្បកឲ្យខ្លាយបានដូច
ចិត្ត ប្រាវខ្លួនតចូលជិត ដោយប្រុងគិតស៊ីឲ្យឆ្អែត ។ ចចកឃើញដូច
ចិត្ត សាច់ប្រណីតក្រហមត្នែត ក៏មិនបានបណ្តែត - បណ្តោយឲ្យស្ទា
ស៊ុះទេ ។ ទើបស្រែកបំភ័យថា នែកូយស្ទាចូរៃះរេ ផ្ទាយៅកុំខំ
នេរ ព្រោះម្ចាស់គេមកវិញហើយ ។ ផ្ទាយៅឲ្យប្រញាប់ រត់
ឆាប់ៗ កុំព្រងើយ តែយឺតធុងខ្លួនហើយ ទុកយអើយតិចលោស្ទាប់ ។

សន្តានចិត្តបងស្ទា យើងរាល់គ្នាដឹងឮស្រាប់ គាត់នេះកំយុទ្ធ
ឆាប់ សត្វអកំព្លាគេចោកប្រើ ។ ឮថាពរសិរ៍មក ស្ទុះលាន់ត្រក(*)
លឿនដូចហើរ ផ្ទាយចាត់ឥតលាក្លៀ ធ្លើដំណើរចាត់ៅអំយ ។

(*) ពាក្យត្រឹមត្រូវ គឺ ព្រោក វិញទេ ។

ចប់

x x x

ភណ្ឌទី ៣៦

ឧកញ៉ាវិបុលរាជសេនា ង្វួ-ភិន ប្រែជាបារាំង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
គឺដំបៅខុបាយកលបំណាន
ទាំងមានសន្ធានស្នេហាជាតិ ។

ដើមសំបុកនោះធ្លុះធ្លាយអន្តរាយទៅវេលាណា ពន្លឺនោះក៏ត្រូវធ្លាក់បែកទៅ
វេលានោះ មិនគាចនឹងតាំងនៅបានឡើយ ដូចបិតាយើងដែលដល់ទូវសេចក្តី
ស្លាប់ ដោយសារគោសគ្រានេះ ខ្លួនយើងជាបុត្រនឹងរស់នៅឲ្យធុតទៅ
បាន ថាដូច្នោះ មិនគាន់ដុតមាត់ ខ្លួលគាហានបួនឆ្លួចូលមកព័ទ្ធជុំ
វិញផ្ទះ ចូលចាប់យកបុត្រនឹងកិយោទ្ធយ៉ាងទាំងអស់គ្នា ទៅដួនបួនឆ្លួ ។
ក៏ឲ្យយកទៅប្រហារជីវិតអស់គ្នានសល់ ហើយឲ្យយកសពទ្ធយ៉ាងទៅ
ដោតជាលខ្លូវផ្លូវចំបែក មិនឲ្យមនុស្សភ្ញាំងពួងយកជាតួយ៉ាងតទៅទៀត ។

ខណៈឈើស៊ុប ដែលជាសំឡាញ់គ្នានឹងទ្ធយ៉ង ដឹងថាបួនឆ្លួឲ្យ
យកសពទ្ធយ៉ងទៅដាក់លដូច្នោះ ក៏ដើរទៅមើល ឃើញសពហើយ ក៏

ឧបទ្ធញ្ញយំអាណិត មានមនុស្សយើញ ក៏ទៅប្រាប់ចូទ្ធ។ ចំណាស់បង្គាប់ឪពុកឲ្យទៅចាប់យកខ្ទះឈើសុំបទៅសម្ងាប់ចេញទៀត ។ ស៊ុនហុកកំនិយាយនឹងចូទ្ធថា ដែលលោកនឹងឲ្យយកខ្ទះឈើសុំបទៅសម្ងាប់ទៀតនោះមិនគួរទេ ព្រោះឈើសុំបនេះជាមនុស្សស្រឡាញ់រាប់អានគ្នានឹងខ្ញុំយ៉ាងកំមែន តែថានឹងចុងដើមឃើញចិត្តជាមួយផងនឹងខ្ញុំយ៉ាងកំខ្លាចដើមកំបានឱយាយរំឭកខ្ញុំយ៉ាងថា ខ្ទះខ្ញុំយ៉ាងជាមនុស្សអាក្រក់កាចសាហាវគ្មានអធ្យាស្រ័យសោះ បើប្រព្រឹត្តដូច្នេះយូរទៅ នឹងមានភ័យដល់ខ្ទះ ឈើសុំបនិយាយដូច្នោះ ខ្ញុំបានកំបានឮនឹងត្រចៀក ដែលមកឧញ្ញយំអាឲ្យអាល័យខ្ញុំយ៉ាងនោះ ព្រោះគិតថាជាមិត្តភ័ក្តិនឹងគ្នា ។ ចូទ្ធបានស្តាប់ពាក្យសាយកំហឹង ទើបឲ្យឈើសុំបយកសពខ្ញុំយ៉ាងទៅបញ្ចុះតាមត្រូវការ លុះចូទ្ធសម្ងាប់ខ្ញុំយ៉ាងចេញដូច្នោះហើយ កំបាត់ឲ្យស៊ុនហុកទៅរក្សាស្រុកហ៊ូគោ ហើយចេញក៏ពល ៥០ ម៉ឺន ទៅវាយស្រុកស៊ុនអៀ ។ ខ្ញុំលឲ្លៅចៀវចៅហ្វាយស្រុកគេនឹងដីវាឈឺចួនថ្ងៃមម្តងទៀត កំឲ្យហៅឲ្លៅពីចូលទៅប្រាប្តាន់ឯផ្តន្ទាំផ្ញើការពេជការពាក់ព័ន្ធ ។ ឲ្លៅពី, គួនអ៊ូ, ខៀវហ៊ុយ កំនាំគ្នាទៅកៃឲ្លៅចៀវឯស្រុកគេនឹងដីវ ។

ឲ្លៅចៀវឃើញមុខឲ្លៅពីត្រេកអរណាស់ កំនិយាយថា ខ្ញុំយើងសព្វថ្ងៃនេះ ដូចដើមឈើស្បែរច្រាំងកប់ថ្ងៃខែតែនឹងរលំចុះ ដែលយើងឲ្យហៅអ្នកមកនេះ ប្រាប្តាន់ឯផ្ញើស្រុកគេនឹងដីវឲ្យប្អូន ព្រោះកូនបងតាំង

៦ មានដម្រែប្រាជ្ញាខ្លះ ឯណាស់ ប្រសិនបើ បងអស់បុណ្យក៏សនា
ហើយ កូនខ្មោះនឹងរក្សាស្រុកទេសបានដោយក្រវៃក្រពកណាស់ ខ្លួន
ប្អូនជាចាស់ មានដម្រែប្រាជ្ញា ចូរជួយរក្សាស្រុកទេស កុំឲ្យអន្តរាយ
បានទៅអ្នកដទៃឡើយ ។

ឯឡៅតាបានស្តាប់ពាក្យនាងហើយយំសោកាធ្វើយថា ខ្លួនខ្ញុំបាទសព្វ
ថ្ងៃនេះ មានសេចក្តីសុខតែត្រង់នឹងលោក ដោយផ្លូវកតញ្ញូមិនបានប្រាថ្នា
ការអ្វីសោះ ទោះបីលោកអស់បុណ្យទៅហើយក្តី ខ្ញុំបាទនឹងជួយចិញ្ចឹម
បំរុងកូនលោកតាំង ៦ តទៅ ។ កាលឡៅប៉ើរៀនិយាយផ្តែផ្តាំគ្នានឹងឡៅតា
មិនទាន់ផុតមាត់ មានបំរើសេះម្នាក់ចូលមកជំរាបថា កងម័តចូតូលើកមក
ដល់ហើយ។ឡៅតាក៏លាទាំគួនអ្ញ,ទៀវហ៊ុយត្រឡប់ទៅស្រុកស៊ុនអៀវិញ។

ឯឡៅប៉ើរៀបានឮដំណឹងសឹកសង្រ្គាមមកដល់ដូច្នោះ ក៏រឹតតែតក់
ស្លុតខ្លាំងទ្វើងទៀត ជម្ងឺខ្មោះក៏កាន់តែធ្ងន់ចុះ កាលឡៅប៉ើរៀបរាជ្ញ
ផ្តាំឡៅតាខ្មោះ ទាំងឈ្លូហ៊ូយិនជាកូរយោឡៅប៉ើរៀលឮស្តាប់ដំណឹងអស់
ក៏ខឹកខឹងខ្លាំងណាស់ថា ឡៅប៉ើរៀស្រឡាញ់រាប់អានឡៅតាច្រើន ទីឯ
លើកស្រុកទេសប្រគល់ឲ្យឡៅតា មិនមានសេចក្តីអាណិតដល់បុត្រប្រុសស្រី
ខ្លួន ទើបឲ្យឈ្លូម៉ីនឹងទៀអ៊ុនតាំង ៦ នាក់ជាទីពុកចិត្ត ឲ្យនៅរក្សា
ខ្នាងនេះ កំដាប់ត្រួតត្រាមិនឲ្យនរណាចូក ឬមកចូល-ចេញបាន ។

ឯឡៅតង់ជាបុត្រឡៅប៉ើរៀ ដែលទៅឈរស្រុកតាំងវៀហនោះ លុះ

ឮថាបិតាឈឺធ្ងន់ក៏ស្រួតត្រដៃសួរ លុះឡើងទៅដល់ខាត់ភ្នំ ឈួម៉ៃ,ខៀវ អ៊ុន ឃាត់ហាមមិនឲ្យឡៅតីចូលទៅជួប ជាខ្លួនអ្នកនេះបិតាប្រើឲ្យទៅឈរយាមស្រុកកាំងហែ ហើយមិនបានហៅឲ្យមកទេ ដែលអ្នកមកពាលខឹកខ្លែងដូច្នេះ ប្រសិនបើស៊ុនតួនដឹង ទឹងលើកទ័ពមកដាយយកស្រុកកាំងហែនោះជាអសារឥតការ មួយទៀតបិតាអ្នកឈឺធ្ងន់ បើអ្នកនឹងចូលទៅឥឡូវនេះ ក៏ឃើញថាបិតាអ្នកនឹងទឹងថាលះបង់ចោលខ្លួន ពេតនោះក៏នឹងជាស្ងែនឡើងទៀតលើសកំឡាំង គង់នឹងដល់សេចក្តីស្លាប់ ដូចជាអ្នកមកធ្វើឲ្យបិតាអ្នកអស់ជីវិតឆាប់ទៅទៀត ។ ឡៅតីបានស្តាប់ដូច្នោះ ក៏អង្គុយយំសោកអាណិតបិតាណាស់ ទៅតែតាត្រៀវភ្នំ ទឹងចូលទៅសួរពុំបានហើយក៏ឡើងសេះត្រឡប់ទៅស្រុកកាំងហែវិញ ។

ឯឡៅប៉ៃវិគាន់តែឈឺងាប់ គាំងចិត្តគិតដល់ឡៅតីជាបុត្រឫងមិនឃើញចូលមក លុះដល់ខែតន្រួច ៣ កើត ពេតកំរើកខ្ទាំងស្រែកបានតែពាក្យ១ មាត់ គឺដាច់ខ្យល់ស្លាប់ ខាងឈួហ៊ូយ៉ងឃើញថាឡៅប៉ៃវិមរណភាពហើយ ក៏ឲ្យឈួម៉ៃខៀវអ៊ុនចូលទៅសរសេរសំបុត្រ ដាបណ្តាំឡៅប៉ៃវិទុក ១ ច្បាប់ សេចក្តីថា បើប្រសិន យើងអស់បុណ្យវាសនាតាលណា ត្រូវឲ្យឡៅចងខួលក្បាលខែត្រស្រុកកេងជីវិតទៅចុះ ខាងឈួហ៊ូយ៉ងក៏ឲ្យហៅខាម៉ឺនមុខមន្ត្រីចូលមកប្រជុំប្រឹក្សាគ្នា ហើយយកសំបុត្រនោះចេញមកបង្ហាញមន្ត្រីពាំងអស់មើល រួចក៏តាំងឡៅចងឡើង

ជាចៅហ្វាយស្រុកកេរ៍ដីវាំងនួសបិតា ហើយទើបចាត់ចែងតែងការសេព
ខ្លៅបៀវតាមប្រពៃណី ។

ខណៈខ្លៅចន្ធអាយុបាន ១៤ ឆ្នាំ មានដម្រេះប្រាប់ថ្វៀរឆ្នាត
ណាស់និយាយនឹងមន្ត្រីចុងភៅគាំងឆ្ងល់ថា បិតាខ្ញុំមរណភាពទៅហើយ
ខ្លៅតើជាមាខ្ញុំ នឹងខ្លៅគឺជាបងក៏នៅមានជីវិតរស់នៅឡើយ ដែលអ្នក
ពាល់គ្នាមកតាំងខ្ញុំជាធំនោះមិនគួរទេ បើប្រសិនខ្លៅតើ នឹងខ្លៅតែដឹងនឹង
មានសេចក្តីតូចចិត្ត លើកកងទ័ពមកធ្វើអន្តរាយយើង អ្នកទាំងពួងនឹង
រៃគិតប្រការម្តេច ? ។ លំគុយដែលជានាម៉ឺនមានឥស្សរជុំជាលក្ខ្វើយថា
ដែលលោកមានប្រសាសន៍នេះគួរណាស់ ត្រូវតាមទំនៀមទម្លាប់ព្រាប់
ប្រពៃណីតបូពណមក ហើយឲ្យអញ្ជើញខ្លៅតើមកជួយរៃគិតការពារក្សាស្រុក
ទេស នឹងបានជួយគ្នាការពារស៊ុនគួនឥតបួងតែ ។

ឈ្លើមបានឮដូច្នោះ ក៏ស្រែកតំហកឲ្យលំគុយថា ខ្លៅបៀវជិតស្លាប់
បានសរសេរសំបុត្របណ្តាំជាសំគាល់ទុកថា យើងពាល់គ្នាសុទ្ធតែជាមន្ត្រី
ធំ ត្រូវជួយគ្នារៃគិតទំនុកបំរុងស្រុកទេសបុំណ្ណោះមិនបានឬ ? ចាំឲ្យមាន
សំបុត្រទៅអញ្ជើញខ្លៅតើខ្លៅតើមកប្រយោជន៍អ្វី ? អ្នកទាំង ២ នោះមាន
ដំរេះប្រាប់ជាយ៉ាងណាទៅ ? ។ លំគុយឮដូច្នោះក៏ទាល់គំនិតស្រែកដេរឈ្លើម
ថា ឯងជាមនុស្សមិនមានអធ្យាស្រ័យអ្វីសោះ មិនធ្វើតាមទំនៀមទម្លាប់

(នៅមានត)

ពិធីប្រគេនព្រះឆ្នាំទានបំពោះសមណនិស្សិត

លោក ភ័ឃ-ប៊ុក រៀបរៀង

កាលពីថ្ងៃសៅរ៍ទី ១៦ ខែឯកថ្ងៃអាទិត្យទី ១៧ ឧសភា ១៩៥៩ សមាគមមិត្តពុទ្ធិកវិទ្យាល័យ បានធ្វើពិធីបុណ្យព្រហ្មទានមួយ ចំពោះសមណនិស្សិតចំនួន ៤០ រូប ដែលបានចូលសិក្សាខៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ តាំងពីថ្ងៃទី ៨ ឧសភា ខេវយ៉ាពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត ។

ថ្ងៃសៅរ៍ទី ១៦ ឧសភា ១៩៥៩ ពេលម៉ោង ៧-៣០នាទី ពួកពុទ្ធមាមកជន តាំងបព្វជិត តាំងគ្រហស្ថ បានខំមន្ត-អុញ្ជើញមកជួបជុំនៅយ៉ាពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត ខាងបព្វជិតមានសមណនិស្សិតពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជតាំង ៤០ រូប ខាងគ្រហស្ថមានលោក ភ័ឃ-ល្មុត ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ លោក ភ័ឃ ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ និងឥស្សរជនឯទៀតជាច្រើន ។

ពេលម៉ោង ៨ យប់ បានខំមន្តសមណនិស្សិតចាំង ៤០ រូប ចម្រើនព្រះបរិត្ត លំដាប់តមកព្រះមហា ចាំង-ខាត់បានសំដែងធម៌ទេសនា លុះចប់ធម៌ទេសនាហើយ បានថ្វាយកុសលកាសី ដែលកើតអំពីព្រហ្មទានទឹងធម្មទានចំពោះព្រះមហាក្សត្រតាំងពីព្រះអង្គ ទឹងសម្តេចព្រះចបយុវរាជ

សូមព្រះអង្គប្រកបដោយសិរីសួស្តីជ័យមង្គលគ្រប់ចំពូក ព្រមទាំងពពួក
តុន្ទបរិស័ទជាម្ចាស់ព្រហ្មទាន ។

ថ្ងៃអាទិត្យទី ១៧ ឧសភា ១៩៥៩ ពេលម៉ោង ៣ រសៀល សម្តេច
ព្រះពជកនិដ្ឋាស្មីសោភ័ណ ស្តេចយាងមកជាព្រះអធិបតីនៃពិធីបុណ្យនេះ។
ទាំងបព្វជិត មានសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក គណៈធម្មយុត្ត
ព្រះពោធិវង្ស ហួត-តាត អគ្គាធិការពុទ្ធិកសំក្សា ព្រះពជាគណៈហានាទុ
ក្រម ទំនឹសមណនិស្សិតចាំង ៤០ រូប ។ ទាំងគ្រហស្ថ មានសហជីវនៃ
ដួច-ហៃល ប្រធានវដ្ឋសកា សហជីវនៃធ្មឹម ដុង រដ្ឋលេខាធិការក្រសួង
ឃោសនាការនឹងទេសចរណ៍ សហជីវនៃ ម៉ុច-វ៉ែន អនុរដ្ឋលេខាធិការ
ក្រសួងមហាផ្ទៃ លោក អៀង-គុណ សាត៍ អគ្គលេខាធិការពុទ្ធិកវិទ្យាល័យ
ព្រះសុពម្រឹត លោក ក៉ាយ-ល្ងុត ប្រធានពុទ្ធិកសមាគមកម្ពុជវដ្ឋ លោក
ក៉ាយ-ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យនឹងឥស្សរជនឯទៀតជាច្រើន។

ម៉ោង ៤ លោក ក៉ាយ-ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ បាន
ថ្លែងសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ ៖

សូមក្រាបបង្គំទូលសម្តេចព្រះពជកនិដ្ឋាស្មីសោភ័ណ

សូមទ្រង់ជ្រាបក្រាមលួងគួលព្រះបាទ ។

សូមនមស្ការ ចំពោះសម្តេចព្រះសង្ឃនាយក ព្រះថេរានុត្តរៈទាំង
ឡាយ សូមទ្រង់ សូមជំពាបឯកទត្តម លោកអ្នកទាំងឡាយ ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទ តាជ័នាមសមាគមមិត្តពុទ្ធិកវិទ្យាល័យ សូមថ្វែងនូវគតញ្ញូតាធម៌ដ៏ថ្លៅលើសថ្លៅ ចំពោះសម្តេចដែលទ្រង់ស្តេចយាងមកជាព្រះអធិបតី ក្នុងទុតាសបុណ្យព្រហ្មចាននេះ ទុកជាព្រះរាជកិត្តិយសដ៏ប្រសើរចំពោះសមាគមមិត្តពុទ្ធិកវិទ្យាល័យ ។

សូមថ្វែងនូវអំណរដ៏ក្រៃលែង ចំពោះសម្តេចព្រះសង្ឃនាយកគាំង ពីគណៈ ព្រះថេរានុត្តរៈ ទ្រង់ ឯកទត្តម លោកអ្នកគាំងឡាយ ដែលបានធ្វើតេលទុតាសដ៏ប្រសើរ ទំមន្ត ស្តេចយាង អញ្ជើញមកកាន់ពិធីបុណ្យនេះ ដើម្បីលើកទឹកព្រះហឫទ័យនៃសមណនិស្សិត ๔๕ រូប ដែលបានចូលទៅបន្តវិជ្ជាជាន់ខ្ពស់ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ តាំងពីថ្ងៃទី ๘ ខែសីហា ។

ពិធីបុណ្យនេះ ជាតំណាងនៃការអបអរសាទរ ចំពោះសមណនិស្សិតគាំងឡាយ ដែលបានសិក្សានូវពុទ្ធិកឧបមសិក្សាអស់រយៈពេល ๓ ឆ្នាំ បានព្យាយាមចូលមកសិក្សានៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត បំពេញនូវមជ្ឈមសិក្សាខាងព្រះពុទ្ធសាសនា អស់រយៈពេល ๔ ឆ្នាំ, ឥឡូវនេះបានឱមន្តចូលមកសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដើម្បីនឹងបំពេញនូវទុតិយសិក្សាខាងព្រះពុទ្ធសាសនាតទៅទៀត ។

ព្រោះហេតុដូច្នេះ ព្រហ្មចានដែលស្ថិតនៅចំពោះព្រះភក្ត្រ ព្រះតេជៈព្រះគុណ ទ្រង់ ឯកទត្តម លោកអ្នកគាំងឡាយ ទុកជាគ្រឿងជំនួយ

សម្រាប់ជួយញុំាងព្រះទ័យសមណនិស្សិត ឲ្យមានវីរិយភាព ជំរុំជួយ
នឹងពេលភាពខ្វាំងក្លាឡើងតាមលំដាប់ ។

ព្រហ្មចារីនេះ ដែលតើតឡើងដោយបរិសាទសង្គ្រាមនៃពុទ្ធមាមកជន
ទាំងឡាយ ទាំងប្រុស - ស្ត្រី សម្រាប់យកមកបូជាចំពោះសមណនិស្សិត
នេះ ជានិមិត្តរូបដែលគ្មានបំណងអ្វីក្រៅពីអង្គព្រះទ័យក្រុមសមណនិស្សិត
សូមឲ្យនិមន្តបន្តវង្សាព្រះពុទ្ធសាសនាតៗថ្ងាក់ទត្តមវង្សា ដោយប្រឹងប្រែង
តទៅទៀត ព្រោះថាវង្សាព្រះពុទ្ធសាសនាមានពុទ្ធិកបឋមសិក្សា ពុទ្ធិក-
មជ្ឈមសិក្សា នឹងពុទ្ធិកទត្តមសិក្សា ជាវង្សាប្រសើរបំផុត សម្រាប់ប-
នាព្រះតេជ-គុណជាសមណនិស្សិតទាំងឡាយឲ្យទៅជាបណ្ឌិត វិញ្ញូ-
ជន ដែលជាមេដាំដ៏យ៉ាងដំនាញខាងការកសាងព្រះពុទ្ធសាសនាឲ្យមាន
វឌ្ឍនភាពតទៅអនាគត បើព្រះពុទ្ធសាសនាចម្រើន ប្រទេសជាតិក៏ចម្រើន
តាមលំដាប់ឡើងដែរ ។ ព្រោះហេតុដូច្នេះ ពុទ្ធបរិស័ទទាំងឡាយអាចពុក
ព្រះតេជ-គុណសមណនិស្សិតទាំងឡាយ ជាវរជនៃព្រះពុទ្ធសាសនា
សម្រាប់ញុំាងពុទ្ធចក្រឲ្យវិលទៅមាន់វឌ្ឍនភាពនឹងសន្តិភាព ។ វរជនៃព្រះ
ពុទ្ធសាសនាជាអ្នកជួយទ្រទ្រង់ពុទ្ធចក្រ ដូចជាវរជនៃជាតិជាអ្នកជួយ
ជ្រោមជ្រែងខាងអាណាចក្រដែរ ។ ពុទ្ធចក្រនឹងអាណាចក្រត្រូវប្រែស្រ័យ
គ្នាទៅវិញទៅមក ទើបតួរនេះគឺប្រទេសកម្ពុជាអាចប្រព្រឹត្តទៅបានស្រួល។

សមាគមមិត្តពុទ្ធិកវិទ្យាល័យ មិនមែនទើបតែទំនើងធ្វើបុណ្យព្រហ្មាទានក្នុងថ្ងៃនេះទេ គឺបានធ្វើមកតាំងពីឆ្នាំ ១៩៥០ រៀងពីបដពីបមក អាក់ខានធ្វើក្នុងឆ្នាំ ១៩៥៧-៥៨ ដោយសមាគមជាប់មានកិច្ចវល់ផ្សេង ។ មិនអាចធ្វើតទុកាសទំនើងធ្វើបាន ។ ថ្ងៃនេះ ជាឱកាសក្នុងសម័យដ៏មានជោគជ័យសិរីមង្គលសួស្តី ព្រោះសមាគមបានចាត់ចែងធ្វើការកុសលគឺ មានចែកប្រគេនទៀវព្រហ្មាទានដល់ព្រះតេជគុណ ៣ អង្គ ជាសមណានិសិ្សតពុទ្ធិកកល្យាណកិច្ចមួយដ៏វិសេសវិសាល ក្នុងព្រះពុទ្ធសាសនា ។

លំដាប់តទៅនេះទៀត ខ្ញុំលុះព្រះបន្ទូលជាខ្ញុំ - ខ្ញុំព្រះករុណា - ខ្ញុំបាទ សូមានព្រះបរមវិរោគាសប្រស្រ័យរំលឹក ចំពោះព្រះសង្ឃជាសមណានិសិ្សតដូចតទៅនេះ :

ព្រះតេជ-គុណជាសមណានិសិ្សតទាំងឡាយ សូមព្រះអង្គជ្រាបថា : ពុទ្ធិកបឋមសិក្សា ពុទ្ធិកមជ្ឈមសិក្សា និងពុទ្ធិកឧត្តមសិក្សាជាខ្ទឹស្តិនៃពុទ្ធសាសនា ត្រូវយកខ្ទឹស្តិនេះទៅអនុវត្តន៍ថែមទៀត ។ ព្រោះការចេះដឹងជាការប្រសើរមែនពិតហើយ ប៉ុន្តែបើមិនប្រតិបត្តិតាមការចេះដឹង ក៏មិនបានផលល្អដែរ ដូចពុទ្ធភាសិត ១ អន្ទើតង់ធម្មបទ២ពុទ្ធនិកាយ ពោលថា:

ពហុម្បិ ចេ សហិតំ ភាសមានោ ន តក្ករោ ហោតិ នរោ បមត្តោ ជាដើម ប្រែថា : ពុកជាចេះដឹងច្រើនយ៉ាំងណា តែមិនប្រតិបត្តិ

ឲ្យបានល្មមតាមចំណេះ ជាការមិនមានផលប្រយោជន៍ប្រសើរប៉ុន្មានដែរ។

ម្យ៉ាងទៀត កន្លងពេលនេះ ប្រទេសយើងបានឯកភាពជ្រើសតាំងលក្ខណៈបើមានរាជសមណៈចំនួនជាច្រើនអង្គ ដើម្បីប្រស្រាយពាក់ព័ន្ធនឹងប្រទេសនានា ដែលកាន់ព្រះពុទ្ធសាសនាជាការប្រសើរបំផុត ។ សមាគមមានរាជសេចក្តីសង្ឃឹមចុងចិត្ត លើព្រះរតនត្រៃគុណសមណនិស្សិតពុទ្ធិកមហាវិទ្យាល័យនេះថា : ខិតខំបានជាបណ្ឌិតសម្រាប់ជួយដោះស្រាយនូវបញ្ហាដ៏ស្មុគស្មាញក្នុងព្រះពុទ្ធសាសនា ។

កន្លងអាសនៈនេះ សមាគម សូមប្រមូលកល្យាណកុសលដែលកើតមកពីបុណ្យព្រហ្មចារីនេះថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតនឹងសម្តេចព្រះមហាក្សត្រិយានី សូមអតិថាលរក្សាព្រះចក្រិតាំងពីព្រះអង្គ ទ្រង់គង់ជាសុខក្នុងសិរីភោជសម្បត្តិ អស់កាលមួយរយព្រះវស្សា ប្រកាសចាកព្រះពោគាពត្រមប្រការ ប្រកបដោយនូវជោគជ័យសិរីសួស្តីគ្រប់ទិវាពត្រីក្រមតាំងព្រះពជវង្សានុវង្សកុំបីឃ្លាត សូមថ្វាយសម្តេចព្រះឧបយុវពជជាព្រះបិតាឯកាធ្យជាតិ សូមព្រះអង្គជាសរសៀវភៅព្រះពោគាពឲ្យបានធាប់រួសរាន់តាន់ចិត្ត សូមថ្វាយសម្តេចព្រះពជកនិដ្ឋាស្ទើសោភ័ណ សូមឲ្យទ្រង់ប្រកបដោយសុខមាលភាព ខិតខំព្រះមង្គលត្រប់ប្រការ សូមប្រគេនដួន ចំពោះព្រះថេរានុត្ថេរៈតាំងពីឥសិសង្ឃរាជនិងពុទ្ធមាមកជនជាអ្នកស្រាវជ្រាវព្រហ្មចារីឲ្យបានប្រកបដោយអាយុ វណ្ណ សុខ ពល បដិភាណ

សមគួរតាមសេចក្តីប្រាថ្នា ។ សូមឱ្យប្រទេសកម្ពុជា ប្រាសចាក
អសន្តិសុខគ្រប់ប្រការ សូមឱ្យបានប្រកបដោយវឌ្ឍនភាព សម្បូណ៌ភាព
សន្តិភាព តាំងពីសម័យបច្ចុប្បន្នរហូតដល់អនាគត ជាតិយៅភាពតទៅ។

លុះជាប់តមក ព្រះពោធិវង្ស៍ អគ្គាធិការ នៃភ្នំពេញសិក្សា បានថ្លែង
ន្ទសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ ៖

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃនាយក ព្រះថេរានុត្តរៈគាំងឡាយ
សូមថ្វាយព្រះពរសម្តេចព្រះភោជកនិដ្ឋាវស្ថិសោភ័ណ
សូមចំរើនពរ ឯកទគ្គម នឹងអស់លោក

ខ្ញុំព្រះករុណា អាត្មាភាព មានបំតិសោមនស្សដ៏ក្រៃលែង ចំពោះ
សម្តេច ទ្រង់ ឯកទគ្គម នឹងអស់លោកទាំងឡាយ ដែលបានស្តេចមក
និមន្តមក អញ្ជើញមក ជាព្រះអធិបតីភាព នឹងជាកិត្តិយស ក្នុងឧកាស
ពិធីប្រគេនព្រហ្មាទានដល់សមណនិស្សិតទាំងឡាយក្នុងវេលានេះ ។

អម្បាញ់មិញនេះ លោកប្រធាននៃសមាគម បានថ្លែងសេចក្តីរៀប
រាប់អំពីការផ្តើមធ្វើព្រហ្មាទាន ថ្វាយប្រគេនជូនសង្ឃគ្រប់ហើយ ។ អាត្មា
ភាព អ្នកការនាំគាប់ផ្លាល់ក្នុងពុទ្ធិកសិក្សានេះ មានអំណរណាស់ ចំពោះ
កុសលាណកម្ម ដែលសមាគមមិត្តពុទ្ធិកវិទ្យាល័យបានផ្តើមធ្វើ ព្រោះអំពើ
នេះនឹងអាចប្រព្រឹត្តទៅ :

១ – ដើម្បីជាកិត្តិយស ចំពោះពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពុទ

ដោយមហាវិទ្យាល័យនេះ បានបង្កើតឡើង ៥ ឆ្នាំហើយ តុំបានបើកថ្នាក់បាលីសន្តិសុខឲ្យសិក្សាទៅឡើយ ទើបតែនឹងបើកថ្នាក់ ឲ្យមានការសិក្សាពីថ្ងៃទី ៨ ឧសភា ១៩៥៨ នេះ គិតទៅទើបនឹងបានត្រឹម ៨ ថ្ងៃប៉ុណ្ណោះ ។ ការសិក្សាក្នុងពេលដ៏ខ្លីត្រឹម ៨ ថ្ងៃប៉ុណ្ណោះ បានទាំងឲ្យសមាគមនីករលឹកយើញ ហើយបានចាត់ការបំពេញកល្យាណកម្ម គឺព្រហ្មចារីនប្រគេនដល់សមណនិស្សិតភ្លាម ។ អាត្មាមានអំណរដោយមានសង្ឃឹមថា ប្រសិនបើការសិក្សាក្នុងតុំនៃមហាវិទ្យាល័យនេះ ប្រព្រឹត្តទៅដោយសុខស្រួលរៀងទៅក្នុងអនាគត ប្រាកដជានឹងមានសមាគមឯទៀតក្រៅពីសមាគមនិត្តតុំនៃវិទ្យាល័យ ឬនឹងមានក្រុមពុទ្ធបាមកជនឯទៀត មានចិត្តជ្រះថ្លាជួយផ្គត់ ឬជួយបំពេញតំណាងឯណោះ ដើម្បីឲ្យពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មានដំណើរដឿនលឿនទៅមុខ ទៅជួបនឹងវឌ្ឍនភាពយ៉ាងខ្លួលខ្លាយ សមតាមគោលបំណងរបស់មហាវិទ្យាល័យតុំមាន ។

២- ដើម្បីនឹងបានញ៉ាំងសមណនិស្សិត ឲ្យមានកំឡាំងព្យាយាមខំសិក្សាត ទៅក្នុងអនាគត ដោយហេតុថា សមណនិស្សិតទាំងឡាយតង់មានសេចក្តីតែកយចំពោះទឹកចិត្តជ្រះថ្លា ការអបអរសាទរ នៃពុទ្ធបាមកជនទាំងឡាយ ។

រឯព្រហ្មចារីមួយៗ មិនមែនជាវត្តអាចញ៉ាំងជីវភាពនៃសមណនិស្សិត ១ រូប ឲ្យសម្រេចដល់អវសានបានតំពិតមែន ប៉ុន្តែសមណនិស្សិតគប្បី

តែដំណឹងដល់ទឹកចិត្តដ៏ជ្រះថ្លាខៃពុទ្ធមាមកជន ដែលខំបាត់បែងធ្វើឲ្យកើតជាព្រហ្មចាន់ឡើង ។ ទឹកចិត្តដ៏ជ្រះថ្លានេះជាសម្មដ្ឋាន នាំឲ្យដុះដាលកុសលធម៌ឯទៀត១ ចំពោះព្រះពុទ្ធសាសនា ។ សមណខ័ស្ត្រតាំងឡាយដែលសម្បូណ៌ដោយការសិក្សា ខឹងអាចជំគល់ទុកទ្ធូរសេចក្តីជ្រះថ្លារបស់ពុទ្ធមាមកជនក្នុងគ្រាមួយ១ ឲ្យបិតនៅដល់កល្បាវសាន ។

លំដាប់តទ័ាះ អាត្មាភាព សូមព្រះពុទ្ធចាន់ទេសាសបន្តិច ដើម្បីប្រស្រ័យចំពោះសមណខ័ស្ត្រតាំងឡាយ ដែលនៅក្នុងទីចំពោះមុខនេះ ។

អស់លោកតាំងឡាយ !

ការសិក្សាថ្នាក់ក្នុងពុទ្ធិកមហាវិទ្យាល័យ ដែលលោកតាំងឡាយទើបនឹងបានចាប់ឆ្នើមឡើងតទ័ាថ្ងៃទី៨ ខសការោះ ឥឡូវនេះបាន ៨ ថ្ងៃហើយ សូមលោកតាំងឡាយ ខំប្រឹងបំពេញកិច្ចសិក្សាក្នុងពុទ្ធិកៈ ថ្នាក់នេះ ឲ្យដល់ទីបំផុត ។ ឯកិច្ចសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យនោះមានប៉ែនៈ ផ្នែកទី១ ហៅថាវិសេសិក្សាត្រូវសិក្សាកំណត់ ៣ ឆ្នាំ ត្រូវប្រឡងចេញម្តង លោកអង្គណាមានវិជ្ជានឹងសមត្ថភាពគ្រប់គ្រាន់ខឹងអាចទទួលសញ្ញាបត្រវិសេសិក្សាបាន ។ ផ្នែកទី ២ ហៅថា ខត្តមសិក្សាជាន់ដំបូង សមណខ័ស្ត្រដែលបានទទួលសញ្ញាបត្រវិសេសិក្សារួចហើយ ត្រូវបន្តការសិក្សាទៀតកំណត់កាលសិក្សា ៤ ឆ្នាំ ត្រូវប្រឡងចេញម្តងទៀត ។ លោកណាមានវិជ្ជានឹងសមត្ថភាពគ្រប់គ្រាន់ ខឹងអាចទទួលសញ្ញាបត្រជាន់ដំបូងបាន ហៅ

ថាពុទ្ធិតបរិញ្ញា ត្រូវនឹងឋានាសាថាកំណត់ថា (Licence Bouddhique) ផ្នែកទី៣ ហៅថា ទុតិយសិក្សាជាន់ចំបូង សមណនិស្សិតក្រោយដែលបានទទួលសញ្ញាបត្រទុតិយសិក្សាជាន់ដំបូងហើយ ចេះនៅមានព្យាយាម នឹងអាចបំពេញកិច្ចសិក្សា ៣ ឆ្នាំតទៅទៀតបាន ក្រោយការសិក្សា ៣ ឆ្នាំ នឹងត្រូវប្រឡងមួយទៀត ដោយតិចតែងអត្ថបទឆ្លើយជាសៀវភៅផ្សេង ។ ។ បើលោកណាមានសមត្ថភាពគ្រប់គ្រាន់ នឹងអាចទទួលសញ្ញាបត្រទុតិយសិក្សាជាន់ចំបូង ។ សញ្ញាបត្រនេះ នឹងអាចប្រសិទ្ធឲ្យសមណនិស្សិតដែលបានទទួលនោះមានឋានៈជាមហាបណ្ឌិត ត្រូវនឹងឋានាសាថាកំណត់ថា (Doctorat Bouddhique) ។ កាលវេលាដែលត្រូវសិក្សាក្នុងពុទ្ធិតមហាវិទ្យាល័យនេះរួមគឺឯអស់កំណត់ ១០ ឆ្នាំ បើគិតរួមពេលវេលាដែលសិក្សាក្នុងពុទ្ធិតបឋមសិក្សា ៣ ឆ្នាំ ក្នុងពុទ្ធិតមជ្ឈមសិក្សា ៤ ឆ្នាំផងត្រូវជា ១៧ឆ្នាំគត់ ។ អស់លោកគាំងឲ្យដែលបានសិក្សារួចមក ៧ ឆ្នាំហើយ ឥឡូវចូលមកសិក្សាក្នុងពុទ្ធិតមហាវិទ្យាល័យតទៅទៀត ចើគេបើមានទុបសគ្គដោយសេចក្តីលំបាកយ៉ាងណា ក៏ត្រូវទំប្រឹងឲ្យបានចប់ក្នុងផ្នែកសិក្សាទីមួយ ។ ព្រោះតាសិក្សាខាងព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជាយើងនេះ តាំងពីបូពណាមក ក៏ពុំមានចារឹកទុកក្នុងប្រវត្តិសាស្ត្រថា មានមហាវិទ្យាល័យដូចជាក្នុងសម័យនេះឡើយ ។ សម័យនេះប្រទេសកម្ពុជាបានបិតនៅក្នុងហានៈជាប្រទេសឯករាជ្យ ព្រះករុណាជាអម្ចាស់ជីវិត ក៏ទ្រង់ជាអគ្គពុទ្ធសា-

សន្ទូបត្តម្ភក៍ អាស្រ័យគុណសម្បត្តិនេះ ទើបព្រះពុទ្ធសាសនាបានឡើងហាន៎ះទៅជាសាសនារបស់រដ្ឋ ។ ពាន់ពេលវេលាដ៏ប្រសើរដូច្នេះ គួរអស់លោកតាំងចិត្តប្រកបដោយសេចក្តីព្យាយាមក្នុងហាន កុំរួញរាឡើយ ត្រូវខំសិក្សារៀនសូត្រឲ្យពេញសមត្ថភាពគ្រប់គ្នា ។ ក្នុងពេលកំពុងសិក្សាសូមអស់លោកកុំបណ្តោយចិត្តឲ្យជឹកជាប់នឹងអារម្មណ៍ភាំងព្យាយ ដែលនាំឲ្យការសិក្សាថយក្រោយ ត្រូវបណ្តុះចិត្តឲ្យស្រឡាញ់ការសិក្សាតែម្យ៉ាង ការសិក្សាបែបនេះ នឹងនាំអស់លោកឲ្យបានខួលជោគជ័យយ៉ាងប្រសើរ ឲ្យបានខួលនូវលទ្ធផលល្អ គឺការចេះដឹងពេញលេញ ។ ការចេះដឹងពេញលេញនោះ នឹងអាចនាំយកនូវសុភមង្គលមកប្រគេនលោក ក្នុងអនាគតសមតាមក្រុងថ្មីបាន ។

ម្យ៉ាងទៀត ក្នុងសកលលោកសព្វថ្ងៃនេះ ប្រទេសជាតិព្យាយដែលមានព្រះពុទ្ធសាសនាដូចប្រទេសយើងដែរ គេកំពុងតែមានការខ្វល់ខ្វាយបណ្តុះបណ្តាលព្រះសង្ឃ អបរំព្រះសង្ឃ ឲ្យមានការចេះដឹងច្រើនឡើង ទាំងផ្នែកសាសនា ទាំងផ្នែកលោក ដើម្បីឲ្យព្រះសង្ឃទាំងឡាយមានសមត្ថភាពបរិបូណ៌ អាចបំពេញភារៈយ៉ាងកិច្ចជាមុខងារបស់ខ្លួន គួរដល់ការគោរពបូជានៃពុទ្ធសាសនិកជនទូទៅផង អាចជួយផ្សាយពន្រីកព្រះពុទ្ធសាសនាឲ្យរុងរឿងឡើងក្នុងលោកផង ។

ឯប្រទេសកម្ពុជាយើង ក៏ដូចគ្នានឹងប្រទេសឯទៀតដែរ ពុទ្ធសាស-

ខ្ញុំកជនតាំងឡាយ ដែលយកចិត្តទុកដាក់គោរពព្រះពុទ្ធសាសនាតែងមានសង្ឃឹមលើអស់លោកជាទិស្សតែថ្មីនៃពុទ្ធិកមហាវិទ្យាល័យ ជាទីដ៏មានការភ្ញីស្មារងប្រើន ដោយមានកាំរះចេះដឹងប្រើន ហើយនឹងអាចរក្សាអនាគតនៃព្រះពុទ្ធសាសនាឲ្យបានឲ្យបានគង់វង្ស ព្រមទាំងអាចជួយផ្សាយពង្រីកព្រះពុទ្ធសាសនា ឲ្យកែកូលាយឡើងពុំខាន ។

ទីបំផុតនេះ អាត្មាភាព សូមរំលឹកគុណព្រះរតនត្រ័យ សូមសំបូងសម្រួងអស់ពួកទេវតា ដែលស្រឡាញ់ព្រះពុទ្ធសាសនា សូមឲ្យជួយអភិបាលរក្សាព្រះមហាក្សត្រ សម្តេចព្រះនរោត្តមសីហនុ ជាប្រមុខរដ្ឋាភិបាលព្រះពរវង្សពុទ្ធិវង្ស រដ្ឋាភិបាល នាយឧត្តមមុខមន្ត្រីគ្រប់ហាន់ នគរប្រជាពលរដ្ឋ ព្រមទាំងពុទ្ធសាសនិកជនតាំងឡាយ ឲ្យបានជួបប្រទះតែនឹងសេចក្តីសុខក្សេមក្សាន្តនឹងសុភមង្គលគ្រប់យ៉ាង ជានិច្ចនិរន្តរ៍ កុំបីឃ្លាត ។

ម៉ោង ៤.៣០ នាទី លោកជា.ខន់ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត បានសូត្រព្រហ្មទេយ្យតាមលំដាប់ព្រហ្មទាន ចាំងពីលេខ ១ រហូតដល់លេខ ៤៥ ។ សម្តេចព្រះពរវង្សទិដ្ឋាវិស្ទ្ធោ សោភ័ណ ទ្រង់បានថ្វាយព្រះព្រហ្មទានទី ១ របស់ព្រះអង្គ ចំពោះសមណនិស្សិតព្រះនាមហ៊ុន-ម៉ន វត្តសាកវ័ន ដែលបានប្រឡងសញ្ញាបត្រពុទ្ធិកមជ្ឈមសិក្សាជាប់លេខ ១ ។

លំដាប់តមក លោកជួប.ហែល ប្រធានវដ្ដសតា កំចាន់ប្រគេនព្រហ្មទានលេខ ២ រួចលោកទឹម-ដុង វដ្ដលេខាធិការក្រសួងឃោសនាការ លោក ស៊ុប-វ៉ែន អនុវដ្ដលេខាធិការក្រសួងមហាផ្ទៃ ខឹងឥស្សរជន កំចាន់ប្រគេនព្រហ្មទានទី ៣ ៤ តាមលំដាប់ហូរហែ រហូតដល់ព្រហ្មទានទី ៤០ ។ រួចហើយ សមណានិស្សិតចាំង ៤០ រូបក៏ចាន់សូត្រដងខ្លោ ។

ពិធីធ្វើព្រហ្មទាននេះ ចាប់បញ្ចប់នៅម៉ោង ៦ ល្ងាច ក្រោយដែលសម្តេចព្រះរាជគណឯដ្ឋាវស្មីសោភ័ណ ទ្រង់ស្តេចយាងវិលត្រឡប់ទៅគាន់ព្រះដំណាក់វិញ ។



ព្រហ្មទានសំរាប់លើកទឹកចិត្ត សមណានិស្សិតគ្រប់រូប
ឲ្យខំបន្តការសិក្សា នៅក្នុងមហាវិទ្យាល័យ ។
ព្រះសីហនុរាជខុតម ដែលបានរៀបចំតាមសម័យ
ផ្លូវលោកផ្លូវធម៌ប្រសើរថ្លៃ អប់រំនិស្ស័យជាបណ្ដិត ។

បុណ្យនមស្ការព្រះសក្យមុនីពេតិយ

ជាប - ពិន រៀបរៀង

ថ្ងៃពេញបូណ៌មី ខែពិសាខ ជាថ្ងៃដែលព្រះបន្ទូពេញវ័ន ផ្សាយ
រស្មីភ្លឺត្រចះ មេឃខៀវស្រឡះ ដេរដាសដោយតារាកករ ជាមហិរ្ឋ គួរ
ឲ្យកើតសោមនស្សបេតនាជ្រះថ្លាជាអនេក ។ ថ្ងៃនេះ ជាមហាតិលក្ខតិ-
កាល ដែលពពួកតុទ្ធបរិស័ទទៅទ្វីបអាស៊ីកាតអាគ្នេយ៍ ស្ទើរតែគាំងអស់
ទឹងនៅតំរង់ខ្លះៗ នៃទ្វីបតឺរ៉ុប ទ្វីបអាមេរិក មានសេចក្តីជ្រះថ្លានាំគ្នាកាន់
គ្រឿងសក្ការបូជា មានទៀនធូបទឹងផ្កាឈើជាដើម ដើរត្រសងទៅកាន់វត្ត
អាពមថ្កុះស្តូប ព្រះបេតិយ ឬគ្រែះស្ថានពុទ្ធិកសមាគម ដែលមានដំកល់
ព្រះពុទ្ធរូប ដើម្បីធ្វើពិសាខបូជា រំលឹកដល់ថ្ងៃដែលព្រះសក្យមុនីគោតម
បរមសម្មាសម្ពុទ្ធដ៏បរមគ្រូទ្រង់ប្រសូត ទ្រង់ជាន់ត្រាស់ដឹង ទ្រង់
រំលត់ទុក្ខចូលកាន់ព្រះនិព្វាន ។

ត្រប់តែវត្តអាពម នៅប្រទេសកម្ពុជា តុទ្ធបរិស័ទជានរៀបគ្រឿង
សក្ការៈធ្វើពិសាខបូជា នាថ្ងៃពេញបូណ៌មីខែពិសាខ ជាម ហាឡាភ
អធិកអធ័មរៀងរាល់ឆ្នាំ ។

ក្នុង ព.ស. ២៤៩៩ គ.ស.១៩៥៦ ប្រទេសកម្ពុជាជានសាជ្ញាព្រះ
បេតិយ ១ នៅមុខស្ថានីយរថភ្លើងស្ទឹងឃាន ក្រុងភ្នំពេញ ជាទីប្រតិ-
ស្ថានព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្ពុទ្ធ ដែលសម្តេចព្រះនរោត្តម

សីហនុ ទ្រង់ជាន់មកពីប្រទេសសិរីលង្កា ពេលការបានធ្វើបុណ្យទ្វន់ព្រះចេតិយនោះ ជាមហាឧត្តរិកហៅថា "បុណ្យព-ស-២៥០០" រួចហើយ ។

ក្រោយពីបុណ្យ ព.ស. ២៥០០ មក មានព្រះរាជក្រឹត្យលេខ ៧៣ ន.ស. ចុះថ្ងៃទី ២៤-១-៥៨ ទ្រង់ព្រះរាជតំណាក់ទុកបុណ្យនមស្ការព្រះសក្យមុនីចេតិយនោះ ជាបុណ្យទ្វេការ បុណ្យជាតិ ត្រូវធ្វើនៅថ្ងៃ ១៥ កើត ខែពិសាខ រៀងរាល់ឆ្នាំតទៅ ។

ចំពោះបុណ្យនមស្ការព្រះសក្យមុនីចេតិយ នៅ ព.ស. ២៥០២ គ.ស. ១៩៥៩ នេះ មានកម្មវិធីដូចតទៅ ៖

ថ្ងៃទី ១

ថ្ងៃ១៥កើត ខែពិសាខ ព.ស.២៥០២ (២២-៥-៥៩)

ពេលរសៀលម៉ោង ១៧ ៣០ ជួបជុំព្រះសង្ឃ ព្រះរាជវង្សានុវង្ស ប្រធានសភាទាំង២ នាយករដ្ឋមន្ត្រី សមាជិកពេជ្ឈកិច្ច សមាជិកសភាទាំង២ មន្ត្រីគ្រប់តំណែង ទាំងពាហន ទាំងស៊ីវិល ព្រមទាំងឧបាសក ឧបាសិកា និមន្ត ស្តេចយាង អញ្ជើញដល់ រង់ចាំគោរពព្រះ-រាជតំណាងស្តេចយាងដល់ ដោយមានក្រមឧត្តមប្រឹក្សានៃព្រះរាជា ទីព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមលំដាប់ ។

ពាហនក្រុមរក្សាព្រះអង្គ ក្រុមខេមរភូមិន្ទ ក្រុមរក្ខទេវតាអង្គរសេនា តូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ធ្វើតាមវិធីតាមទម្លាប់ ។

សម្តេចក្រុមព្រះ ព្រះរាជតំណាង ស្តេចឡើងគង់លើព្រះពន្លា ។

- ពិធីបង្ហូតទឹកដាក់ ខាំសាសនា ដោយសិស្សប្រុសម្នាក់ស្រីម្នាក់ ។
- ចម្រៀងបទខនភាព ដោយសិស្សប្រុសស្រីច្រើននាក់ ដូចតទៅនេះ

ចម្រៀងបទខនភាព

សូមពួកទេពតាវត្សមហាក្សត្រយើង
ឲ្យបានខុនរឿងដោយជ័យមង្គលស្រីសួស្តី
យើងខ្ញុំព្រះអង្គសូមជ្រក ក្រាមមួបព្រះបាទមី
នៃព្រះទេវបតីវង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរបុរាណថ្កើងថ្កាន ។

ប្រាសាទសិលាតាំងនៅកណ្តាលព្រៃ
គួរឲ្យស្រមៃទឹកដល់យសសក្តិមហានគរ
ជាតិខ្មែរជួបថ្មគងំរងំនៅល្អីងឮបឹងដំហរ
យើងសង្ឃឹមតាកែវព្រះសំណាងរបស់កម្ពុជា
មហាវង្សកើតមានយូរអង្វែងហើយ ។

គ្រប់វត្តអារាមតែសូរស័ព្ទធម៌
សូត្រដោយអំណាចទឹកដល់គុណពុទ្ធសាសនា
ខ្ញុំយើងជាអ្នកជឿជាក់ស្មោះស័ក្តិតាមបែបដូនតា
គង់តែខេត្តផ្គត់ផ្គង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរជាមហានគរ ។

បន្ទាប់ពីនោះ ថ្វាយបង្គំសរភញ្ញ ដោយសម្តីប្រុសស្រីច្រើនឆាក់ :

ធម្មកថាសរភញ្ញ

ខេត្តរាជបុរី

សូមថ្វាយបង្គំ	ខ្ញុំសូមប្រណម្យ
ព្រះពោះត្រង់	ព្រះពុទ្ធជាម្ចាស់
ដ៏ព្រះមានព្រះភាគ	លោកទ្រង់ត្រាស់
ដ៏ឆ្ងាយឆ្ងាយ	ធម្មទាំងឆ្ងាយ
ឥតមានសេសសល់	សោះឡើយ ។
យើងខ្ញុំវត្ថា	ដល់ព្រះសង្ឃ ·
ដែលទ្រង់ចូល	និព្វានទៅហើយ
ពុទ្ធសាសនាឲ្យ	សព្វថ្ងៃនេះឡើយ
ភ្លឺឆ្អែតត្រាណ	គ្រាន់ឆុតពីពុទ្ធា
ដោយសារសាមគ្គីព្រះអង្គ ។	
យើងខ្ញុំព្រះគុណា	តាំងអស់ពាល់ឆ្នាំ
សូមលើកហត្ថបង្គំ	ព្រោះត្រង់
ដល់គុណខ្ពង់ខ្ពស់នៃព្រះអង្គ	ដែលទ្រង់ព្រះបរិនិព្វានទៅ
ពុទ្ធសាសនាឲ្យជាកេរ្តិ៍ ។	

-ព្រះសង្ឃ គ្រហស្ថ ក្រោកឈរបែរព្រះភ័ក្ត្រមុខ គោរពព្រះ

សក្យមុនីចេតិយ ខេរវេលដែលថ្វាយបង្គំរួចហើយ ។

- សុន្ទរកថាសំដែងសេចក្តីគោរពចំពោះព្រះសក្យមុនីចេតិយ ដោយលោកអ្នកឧកញ៉ាពិភក្តិសាសនៈ រដ្ឋលេខាធិការក្រសួងធម្មការ (អ៊ឹង-ហុនសាង) ថ្វាយកឋិនទានក្នុងនាមនៃព្រះពុទ្ធជាតិបាល ។

សុន្ទរកថា

សូមទ្រង់ព្រះមេត្តាប្រោស ,

សូមក្រាបបង្គំទូលសម្តេចក្រុមព្រះជាព្រះពុទ្ធតំណាង នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រិយានី

សូមទ្រង់ជ្រាបក្រាមល្អឯងទូលបង្គំព្រះបាទ ។

កឋិនទានក្នុងនាមនៃព្រះពុទ្ធជាតិបាល ទូលបង្គំជាខ្ញុំ សូមព្រះពុទ្ធគុណទទួលនូវគំណរយ៉ាងជ្រាលជ្រៅ ចំពោះព្រះករុណាថ្លៃវិសេស ដែលទ្រង់សព្វព្រះហឫទ័យ ស្តេចយាងមកជាព្រះពុទ្ធធិបតីក្នុងពិធីបុណ្យទមស្ថានព្រះបរមសារីរិកធាតុ ដែលប្រតិស្ឋានក្នុងព្រះសក្យមុនីចេតិយ នាថ្ងៃនេះ ក្នុងព្រះហានៈជាព្រះពុទ្ធតំណាង នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងគាំងពីព្រះអង្គ ។

សូមទ្រង់ព្រះមេត្តាប្រោស ,

ព្រះបរមសារីរិកធាតុ ដែលជំកល់ក្នុងព្រះសក្យមុនីចេតិយនេះ គឺជា
ព្រះបរមអដ្ឋិធាតុនៃព្រះសក្យមុនីគោតមបរមសម្ពុទ្ធ ដែលសម្តេចព្រះឧប-
យុវរាជទ្រង់បានទទួលផ្ញើលព្រះអង្គនៅប្រទេសស៊ីរីលង្កា ហើយទ្រង់បាន
ដង្ហែចូលមកប្រទេសកម្ពុជា មុនដំបូងជំកល់ទុកក្នុងព្រះបរមកដ៏ឯក ។

លុះដល់កន្លែងកាសបុណ្យ ពុទ្ធសករាជ ២៥០០ សម្តេចទ្រង់ព្រះមេត្តា
ប្រោសឲ្យមានពិធីដង្ហែព្រះបរមសារីរិកធាតុ មកប្រតិស្ឋានដំកល់ទុកក្នុង
ព្រះសក្យមុនីចេតិយនេះ នៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៥៧ ដើម្បី
ជាទីគោរពនមស្ការបូជា នៃពុទ្ធសាសនិកជនទូទៅ ។ លំដាប់តមក
ព្រះតេជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះមេត្តាប្រោសព្រាយព្រះហស្ត-
លេខាលើព្រះរាជក្រឹត្យលេខ ៧៣-ន.ស ចុះថ្ងៃទី ២៤ មករា ១៩៥៨
កំណត់ឲ្យធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយនេះ នៅថ្ងៃ ១៥ កើត ខែឆ
ថ្ងៃ ១ រោច ខែពិសាខរៀងរាល់ឆ្នាំតទៅ ហើយត្រូវទុកពិធីបុណ្យនេះជា
ពិធីបុណ្យជាតិ ដោយការចាត់ចែងរៀបចំក្រោមព្រះរាជាធិបតីភាព នៃ
ព្រះតេជាអម្ចាស់ជីវិតលើត្បូង ខ្ញុំសម្តេចព្រះមហាក្សត្រិយានី ។

ដោយអាស្រ័យការអនុវត្តន៍ ប្រកបដោយសេចក្តីគោរពតាមព្រះរាជ
ក្រឹត្យខាងលើនេះ ក្រសួងធម្មការបានរួបរួមជាមួយក្រសួងរដ្ឋមន្ត្រីនាយ
ទីការក្រុង ព្រមទាំងសមាគមព្រះពុទ្ធសាសនា ដោយមានការទប់ទល់ពី
ព្រះបរមរាជវាំងផង បានចាត់ចែងធ្វើពិធីបុណ្យនមស្ការព្រះសក្យមុនី

ចេតិយ កាលពីកន្លងទៅ ១៩៥៨ ម្ដងហើយដែរ ដែលខ្ញុំបានមក ។ តែឆ្នាំនេះ ជាលើកទីពីរ ។

សូមព្រះមេត្តាប្រោស,

ខ្ញុំសូមក្រាបទូលថ្វាយបង្គំ សូមព្រះរាជអាកាស ថ្វាយនូវការគោរពដ៏ខ្ពង់ខ្ពស់ចំពោះព្រះបរមសារីរិកធាតុនៃព្រះអរហំ សម្មាសម្ពុទ្ធ ដ៏ប្រសើរបំផុត ដែលមានព្រះគុណដ៏ធំធ្ងន់ឧត្តុង្គឧត្តម ។ ខ្ញុំសូមក្រាបទូលព្រះអង្គ ដែលមានសេចក្ដីដូចតទៅនេះ ៖

បពិត្រព្រះសក្យមុនីសម្ពុទ្ធបរមគ្រូ,

ថ្ងៃនេះ ជាថ្ងៃ ១៥ កើត ខែពិសាខ ជាថ្ងៃដែលពុទ្ធបរិស័ទទាំងឡាយ តែងព្រមព្រៀងយកជាព្រឹត្តិការណ៍ជាអស្ចារ្យ របស់ព្រះអង្គឥតដែលភ្លេចសោះឡើយ ។ ថ្ងៃនេះ, ពួកពុទ្ធបរិស័ទបានកំណត់ទុកថាជាថ្ងៃសុភមង្គលដ៏ប្រសើរ ។

បពិត្រព្រះភគវន្តមុនី,

ព្រះអង្គទ្រង់បរិនិព្វានទៅ ២៥០២ ឆ្នាំហើយ ប៉ុន្តែព្រះពុទ្ធសាសនាជារបស់ព្រះអង្គ ដែលព្រះសង្ឃតាមប្រទេសបានរួបរួមគ្នាកែទុកមក បានបិតទៅដោយពេញលេញ ឥតខានសោះឡើយ សូមនៅតែបន្តិចបន្តួចឡើយ ចំពោះព្រះគុណរបស់ព្រះអង្គ ដែលមានច្រើនជាអនេកអនន្តនោះ គឺជិតជាប់នៅជានិច្ចកាលក្នុងចិត្តនៃពុទ្ធបរិស័ទទូទៅ ។

សាសនធម៌របស់ព្រះអង្គ, កាលក្រោយដែលព្រះអង្គបរិនិព្វានទៅ,

ដ្ឋានមកប្រតិស្ឋាននៅប្រទេសកម្ពុជា អស់រយៈកាលជាង ២០០០ ឆ្នាំ
ហើយ ។ ដោយអាស្រ័យសទ្ធាជ្រះថ្លា ខំឯការគោរពប្រតិបត្តិអាននៃព្រះ
មហាកឋិនត្រៃទ្បែរតាំងឡាយ តាំងពីបុរាណកាលរហូតដល់ព្រះគុណជា
អម្ចាស់ជីវិតលើត្បូងសព្វថ្ងៃនេះ ព្រមទាំងប្រជាជាតិទ្បែរតាំងឡាយ, ទាំង
ឧបាសិកាបស់ព្រះអង្គ អាចមានចិរកាល ខំឯវឌ្ឍនភាពនូវរឿងជាដរាប
រៀងមក ។

បពិត្រព្រះបរមគ្រូ,

ថ្ងៃនេះ ជាថ្ងៃប្រកបដោយសិរីសួស្តីជ័យមង្គលដ៏ប្រសើរ, ព្រះពរ
គុណានៃព្រះគុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាឋិយោ
ព្រះសង្ឃពុទ្ធសាសនិក ព្រះពេជ.ឆ្ញាន្ទវង្ស ។ តួមក្រុមប្រឹក្សាព្រះពុទ្ធ
សភាទាំងពីរ គណៈរដ្ឋមន្ត្រី មន្ត្រីត្រចំហាន: តាំងពីហាន-ស៊ីវិល ខំឯ
ប្រជាពលរដ្ឋទាំងឡាយ ជានស្តេចមក អញ្ជើញមកដួបជុំគ្នាខំនេះប្រារព្ធធ្វើ
តាមទំនៀមប្រពៃណីបូជាចំពោះព្រះអង្គ ដែលប្រកបដោយព្រះមហាករុណាគុណ
ដ៏ធ្ងន់ធ្ងរយ ។

ក្នុងអវសានេះ ក្រសួងធម្មការ សូមរំលឹកចំពោះគុណព្រះរតន-
ត្រ័យ គឺ ព្រះគុណរបស់ព្រះអង្គ ខំឯព្រះធម៌ព្រមទាំងព្រះសង្ឃ សូមដួយ
អភិបាលរក្សាព្រះករុណាជាម្ចាស់ជីវិតលើត្បូងទាំងពីរព្រះអង្គ សម្តេចព្រះ
បិតាឯកពជ្ឈជាតិ ខំឯព្រះពេជវង្ស្ឆាន្ទវង្ស ព្រមទាំងប្រជាពលរដ្ឋទ្បែរទូទៅ

ឲ្យបានសេចក្តីសុខប្រកបដោយសេចក្តីចំរើនរុងរឿងជាកំយ៉ាកាពតទៅ ។

សូមព្រះករុណាជាម្ចាស់ដ៏វិតគាំងនឹងព្រះអង្គ ទ្រង់មានព្រះជន្មាយុជាឯរយៅស្រួ ដើម្បីជាម្លប់ដ៏ត្រជាក់ដល់ប្រជាពលរដ្ឋទូទៅ ។

សូមសម្តេចព្រះទេបយុវរាជ ទ្រង់បានទទួលព្រះសុខភាពដ៏បរិបូណ៌ឡើងវិញយ៉ាងឆាប់រហ័ស ដើម្បីទ្រង់បំពេញព្រះពលិកម្មត្រប់បៃបត្រប់យ៉ាង ជូនជាតិ-សាសនា - ព្រះមហាក្សត្រិយ៍ ។

សូមពិភពលោកទាំងមូល បានប្រកបដោយសន្តិភាព ប្រាសចាកសឹកសង្គ្រាមកុំបីឃ្លៀងឃ្លាតឡើយ ។

ជយោ ព្រះពុទ្ធសាសនា !

ជយោ កម្ពុជរដ្ឋ !

បន្ទាប់ពីនេះ ពិធីទម្លាយផ្ទាត់ក្បាក ដោយលោក ចាប.ពិន នៅពុទ្ធសាសនបណ្ឌិត្យ ជាអ្នកនាំដូចតទៅនេះ :

សូមទ្រង់ព្រះមេត្តាប្រោស,

សូមព្រះពរជាន់ក្រាបបង្គំទូលសម្តេចក្រុមព្រះ ជាព្រះពរតំណាងព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទីឯសម្តេចព្រះមហាក្សត្រិយានី

សូមទ្រង់ជ្រាបក្រាមល្អដូចទូលព្រះបង្គំ ។

វេលានេះ ទូលព្រះបង្គំជាខ្ញុំ ជាអ្នកនាំពុទ្ធបរិស័ទនមស្ការព្រះសង្ឃមុនីចេតិយ សូមសម្តេចជាអម្ចាស់ទ្រង់ព្រះមេត្តាប្រោសទទួល ព្រមទាំង

ពុទ្ធបរិស័ទ៤ តាំងអស់ខ្លួនតាមតាំងជាលីតាំងសម្រាយ ១ សង្ក្តាត់ម្តង ៗ ដូចតទៅនេះ ៖

ពាក្យនមស្ការព្រះបរមសារីរិកធាតុ

មាយាវសព្ភនិ សម្ភុន្នោ ភគវា យោ តថាគតោ
សុមស័ត្តាយុកកាលេ បរិនិព្វាយិ សោ មុនិ
តស្ស សារីរិកា ធាតុ អម្ហាកំ ច៦បុរេ ឋិតា
៨ជាតគោ ច សោ សត្តា នរមានោវ តំដ្ឋតិ
សក្កោរេហាតិបូជេម តំ ធម្មសព្ភម សារទំ
សាធុ នោ ភគវា ធាថោ សព្វញ្ញ សន្តិវាយ៤ោ
៨មេ ធលិទ្ធសក្ការេ អនុគម្ភាយ កស្សាតុ
ឥឃរត្តំ ហិតាយេវ សុខាយម្ហាក សព្វទា ។

"ព្រះតថាគត ភគវន្តមុនី ទ្ធង្គណា ទ្រង់ប្រាន្តាស់ហើយ (បរិនិព្វាន) អស់កាល ៤៥ ឆ្នាំ, ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនី ទ្រង់បរិនិព្វានហើយ ក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ ឆ្នាំគត់ ; (ឥឡូវ) ព្រះបរមសារីរិកធាតុនៃព្រះអង្គមកប្រតិស្ឋាន ក្នុងទីចំពោះមុខនៃយើងខ្ញុំព្រះអង្គ ហាក់ដូចជាព្រះបរមសាស្តាអង្គនោះ ទ្រង់គង់ព្រះធរមាននៅឡើយ ស្មើចយ៉ាងមកគង់ក្នុងទីនេះ យើងខ្ញុំ, សូមបូជាចំពោះព្រះអង្គ ដោយគ្រឿងសក្ការៈទាំងឡាយ សូមនមស្ការព្រះអង្គ ដោយ

គោរព, សូមព្រះកតវេទ្ធីមុនី សព្វញ្ញុពុទ្ធ ចរមលោកនាថ ដែល
តែងតែប្រោសប្រទានសន្តិសុខ ដល់សត្វលោក ទ្រង់ព្រះមេត្តាប្រោស
ទទួលនូវគ្រឿងសក្ការៈតាំងពីឆ្ងាយ របស់យើងខ្ញុំព្រះអង្គ ដែលជាសក្ការៈ
បូជារបស់អ្នកកំសត់ទុគ៌តនេះ ដើម្បីអនុគ្រោះយើងខ្ញុំព្រះអង្គឲ្យបានហិត-
ប្រយោជន៍និងសេចក្តីសុខ សព្វកាលវេលាយូរអង្វែងរៀងទៅហោង! " ។

បន្ទាប់ពីនេះ ពិធីហែប្រទក្សិណព្រះសក្យមុនីចេតិយ ឬជាផ្លាកម្រង
ដោយសម្តេចក្រុមព្រះ ជាព្រះពជតំណាង ព្រមទាំងវេជន ដោយមាន
លោក ចាប - តិន ជាអាចារ្យនាំព្រះពជដំណើរ ។

ព្រះសង្ឃ - មន្ត្រី - ពុទ្ធបរិស័ទចេញពីវិថីតាមកឈរគោរពព្រះសក្យ-
មុនីចេតិយ តាមទីកន្លែងដែលគណៈកម្មការរៀបចំ ប្រគេន-ជូនក្នុង
ពេលនោះ ។

-សម្តេចក្រុមព្រះជាព្រះពជដំណាងស្តេចយាងឡើងកាន់ព្រះតម្ហាវិញ ។

-ព្រះសង្ឃត្រឡប់មកគង់លើវេទិកាដែរ ។

-ចំរើនពុទ្ធជ័យមង្គលគាថា ដោយព្រះសង្ឃ ២០០ អង្គ ។

-សម្តេចក្រុមព្រះជាព្រះពជតំណាងស្តេចយាងត្រឡប់ ។

បន្ទាប់ពីនេះទៅ បើកទុកាសឲ្យពុទ្ធបរិស័ទត្រប់ប្រភេទ ចូលធ្វើ
សក្ការៈបូជា រហូតដល់ម៉ោង ២០-៣០ ។

ម៉ោង ២១,០០ ចំពោះព្រះសង្ឃមុនីចេតិយ ដាក់ចង្កៀបញ្ចប់បុណ្យ ថ្ងៃទី ១ ។

ថ្ងៃទី ២

ថ្ងៃ១កើត ខែពិសាខ ឆ ស ២៥០២ (២៣-៥-៥៩)

ពេលព្រឹកម៉ោង ៨-៣០ ជួបជុំព្រះសង្ឃ ព្រះពុទ្ធសាសនិកជន ប្រជាពលរដ្ឋ សាតាំង ២ នាយករដ្ឋមន្ត្រី សមាជិករដ្ឋាភិបាល សមាជិកសភាតាំង ២ មន្ត្រីត្រួតត្រាំណាង តាំងពាហន តាំងស៊ីវិល ត្រមតាំង ទាហាន ទាហាន និមន្ត ស្តេចយាង-អញ្ជើញដល់ រង់ចាំគោរពសម្តេចក្រុមព្រះជាព្រះពុទ្ធតំណាង ។

ម៉ោង ៨-៤៥ សម្តេចក្រុមព្រះជាព្រះពុទ្ធតំណាងស្តេចយាងដល់ ។

- ទត្តមក្រុមប្រឹក្សាខែត្រពារ ទីឆ្ងាយមកគោរពថ្វាយព្រះអង្គតាមហែ។

- ពាហនក្រុមក្សត្រព្រះអង្គ ក្រុមទេមរភូមិន្ទ ក្រុមក្មេងឆ្លងរាស្ត្រនាគូច រក្សាព្រះអង្គ ក្រុមតន្ត្រីព្រះពុទ្ធត្រៃ ធ្វើតារាកិច្ចតាមមគ្គាប់ ។

- សម្តេចក្រុមព្រះជាព្រះពុទ្ធតំណាងស្តេចយាងតង់លើព្រះពន្ធ ។

- ពិធីសម៉ាខនស៊ីល ដោយលោក ចាប-តិន ជាអាចារ្យអាពធនា ។

ម៉ោង ៩-១០ ព្រះពុទ្ធពិធីជាក់ថ្កាត្រព្រះសង្ឃ ៨០ អង្គ ។

- សម្តេចក្រុមព្រះដាព្រះពជតំណាង ស្តេចឡើងគង់លើព្រះពន្ធា ។
- ព្រះសង្ឃទទួលចង្ហាន់ហើយ និមន្តត្រឡប់មកគង់លើវេទិកាវិញ ។
- ស្វាធ្យាយធម៌ ដោយព្រះសង្ឃ ។
- ពិធីដាក់ទង់ជាតិ ទង់សាសនា ។
- ចំរៀងបទខនគរពជ
- ថ្វាយបទសរសើរគុណ

ដោយសិស្សប្រុស-ស្រីដូចពីល្ងាចថ្ងៃពេញបូណ៌មី

ព្រះសង្ឃគ្រហស្ថ ក្រោកឈរបែរព្រះភ័ក្ត្រមុខគោរពព្រះសក្យមុនី ចេតិយ ។

ម៉ោង ១០-០០ សម្តេចក្រុមព្រះដាព្រះពជតំណាង ទ្រង់ស្តេចយាងត្រឡប់ ។

ចប់ពិធីបុណ្យគម្ពីរព្រះសក្យមុនីចេតិយប៉ុណ្ណោះ ។

(តមក)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អជីណ៌ា នបុ. ការមិនរលាយអាហារ ។

អជីយ៌តា ស្ត្រី. ភាវនៃកិរិយាបំផ្លាញមិនបាន, ភាវនៃកិរិយាមិនផិត ។

អជីវ គុ. ដែលឥតជីវិត ។

អជីវិឝ នបុ. កិរិយាមិនរស់, សេចក្តីស្លាប់ ។

អជីវិត នបុ. កិរិយាមិនមានជីវិត ។

អជុគុប្ស គុ. ដែលមិនស្អប់ខ្ពើម ។ *អជុគុប្សិត* គុ. ដែលមិនគួរស្អប់ខ្ពើម, ដែលឥតរៃខ្លះ ។

អជ្ជេយ្យ គុ. អធេយ្យ, ដែលមិនគប្បីចាញ់ ។

អជ្ញ គុ. ដែលមិនដឹង (សត្វ, ជាពាក្យផ្សេងៗ): ល្ងង់ខ្លៅ, សំពីក, ភ្លើ ។ – *តា* ស្ត្រី. ភាវនៃកិរិយាមិនដឹង, ភាវនៃបុគ្គលល្ងង់ខ្លៅ ។

អជ្ញាត គុ. ដែលមិនដឹង, ដែលមិនបេះ ។ – *ភូត* គុ. ដែលបរិភោគដោយមិនដឹងខ្លួន ឬ ដោយមិនមានសម្បជញ្ញៈ ។ – *លិប្សូម* ឬ – *លិប្សាម* ក្រ. វិ. ដោយកិរិយាបង់ជាតមិនបញ្ហាក់ ។

អជ្ញាតិ ប៉ុ. ការមិនមែនជាសាច់ញាតិ ។

(នៅមានត)

ភគ្គិយសុត្តន្ត

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ៦ ខែមិថុនា

ព. ស. ២៥០២ គ. ស. ១៩៥៩

ភ្នំពេញ



ភ្នំពេញសន្ធ្យា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មក្ខ្លឹវឿន	ទំព័រ
- មលធម្មកថា របស់ព្រះមហា ឌួច-សុមេធ	. . . . .	៦០៥
- ពេតចិត្ត លោក ស៊ុម-ហ៊ាន រៀបរៀង	. . . . .	៦១៧
- សុរេងាគត (តមក) លោក ថង-រឹង ចម្លងពីសាស្ត្រាស្លឹករឹត	. . .	៦២៣
ផ្នែកអក្សរសាស្ត្រ		
- រឿងសព្វសិទ្ធិ (ភាគ៥) របស់ហ្មឺនភក្តីអក្សរ ភន់ លោក ប៊ូ-ប៊ី ចំឡងពីសាស្ត្រាស្លឹករឹត		៦៣៥
- រឿងប្រពៃដើមនុស្សដោយភ័យខ្លួនរាយរាំភន់ លោក ស៊ុម-ហ៊ាន រៀបរៀង	.	៦៤២
- រឿងហង្សយ៉ន (តមក) លោក អឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត		៦៤៧
- រឿងព្រឿងគំណាត លោក ប្រ៊ី-អ៊ូ រៀបរៀង		៦៦៩
- រឿងសាមកុក (តមក) ឧកញ៉ា ឆួ-ភន ប្រែ		៦៧០
ផ្នែកគំណត់ទំនឹកប្រវត្តិការណ៍		
- ពិធីបើកការសិក្សានៅក្នុងទីក្រមហាវិទ្យាល័យព្រះសីហនុរាជ និងពិធីសម្ពោធព្រឹះស្ថាន ព្រះសីហនុ លោក ថង-រឹង រៀបរៀង		៦៧៩
- វិចារានុក្រមអក្សរសិល្ប៍ខ្មែរ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង. . . .		៦៦១

ចូលឆ្នាំទាន ១៤ លៀកែរ៉ា ពិព្រឹទ្ធាវី ២៣០០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

sommaire

Partie religieuse :

—Mahādhammakatha par Préah Moha LACH SOMEDH . . . 605
—Les souffrances psychologiques par M. SIN HEAN 617
—Surabajataka (suite) relevé du manuscrit sur feuilles de latanier par M. THANG-VONG 623

Partie littéraire :

—Histoire de Sabbasiddhi (suite et fin) par Phakdei Aksar TAN revue et corrigée par M. BOU-PO 635
—La Correction par cent coups de rotin par M. SIN-HEAN . 642
—Histoire de Hang-Yon (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON 647
—Les Objets symboliques selon les traditions khmères par M. SREY-OU 665
—Histoire de Sam Kok (suite) par l'Oknha NOU-KAN . . . 670

Notes et Chroniques :

—Cérémonie d'Ouverture de l'Université Bouddhique Préah Sihanouk Raj par M. THANG VONG 689
—Dictionnaire Sanskrit-Khmer (suite) par vén. PANG-KHAT . 716

Prix d'abonnement annuel (comprenant 12 numéros): 230,00 .

ផ្នែកសាសនា

មង្គលធម្មកថា

ព្រះមហា ឌួច-សុមេធ វត្តឧណ្ណាលោម រៀបរៀង

ឯកោ ៣ បទ

មហាការុណិកំ តុទ្ទិំ ធម្មញ្ច វិមលំ វរំ

វន្ទេ អរិយសង្ឃញ្ច ទក្ខិណេយ្យំ ឯវន្តំ ។

សូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធ ព្រមទាំងប្រកបដោយមហាករុណាគុណផង ព្រមទាំងព្រះធម៌ដែលប្រាសចាកមន្ទិលដ៏ប្រសើរផង ព្រមទាំងព្រះអរិយសង្ឃជាទក្ខិណេយ្យបុគ្គល មិនមានពាលាទិក្កិលេសក្នុងសន្តានផង (ដោយសេចក្តីគោរព) ។

ឥឡូវនេះ សូមសំដែងអំពីមង្គលធម៌៨យ៉ាង ដែលមានពុទ្ធភាសិតក្នុងគម្ពីរធម្មបទខុទ្ទកនិកាយត្រង់មង្គលវគ្គ ដូចមានមាតិកាបៀបរៀងក្នុងទំនេះគឺ:

១- អសេវនាច មាលា ច បណ្ឌិតានំ មង្គលំ ការមិនសេពគប់នឹងមនុស្សពាល ជាមង្គល ។

២- អនុដ្ឋានញ្ច មាលា ឃរេ ផ្ទះតាំងខ្លួន មានការមិនជួសជុល មិនថែទាំជាមង្គល ។

៣- មលំ វណ្ណស្ស តោសជ្ជំ សេចក្តីខ្ជិល ជាមង្គលរបស់សម្បុរ ។

๔- បមានោ វត្ថុតោ មលំ សេចក្តីធ្វេសប្រហែស ជាមន្ទិលរបស់បុគ្គលអ្នករក្សា (ទ្រព្យ) ។

๕- មលិត្ថិយា ទុច្ចរិតំ ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី ។

๖- មច្ឆេរំ ទទតោ មលំ សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ។

๗- មលានិ ចាបកានិ ធម្មា អស្មិំ លោកេ បរម្ហិ ច ចាបធម៌ទាំងឡាយ ជាមន្ទិលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

๘-តតោ មលា មលតរំ អវិជ្ជា បរមំ មលំ អវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ជាងមន្ទិលទាំងនោះទៅទៀត ។

ត្រង់មាតិកាខ ១ ថា «មន្ទិទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល", អធិប្បាយថា: បណ្តាមន្ទិ តិវិជ្ជាទាំងអស់ក្នុងលោកនេះ គេហៅវិជ្ជាខាងផ្លូវលោក ដូចជាអក្សរសាស្ត្រនិងវិជ្ជាហត្ថកម្ម ការជាងឈើ ជាងដែកជាដើមក្តី ឬវិជ្ជាខាងផ្លូវធម៌ ដូចជាធម្មវិន័យ បរិយត្តិសាសនា ជាដើមក្តី សូម្បីវិជ្ជាណាមួយ បុគ្គលមិនបានសិក្សារៀនសូត្រសោះ ឬបានសិក្សារៀនសូត្រ ៗ ចេះចាំស្ទាត់ជ្រុតជុះហើយដែរ ប៉ុន្តែខ្ជិលប្រឹងមិនយកចិត្តទុកដាក់ព្យាយាមរំលឹកបន្តែមទៀតទេ ឬ មិនបានយកចំណេះដែលខ្លួនរៀនចេះដឹងហើយនោះ មកប្រកបប្រើការទេ ឃ្លេចឆ្ងល់ភ្លាំងឲ្យ

ក្នុងភេទជាមនុស្សតិរច្ឆានវិជ្ជា ឈ្មោះថាបានសេចក្តីសុខ សេចក្តីចំរើនយ៉ាងប្រសើរ ព្រោះវិជ្ជា អាចឲ្យសម្រេចប្រយោជន៍ច្រើនយ៉ាងយោងខ្លួនឲ្យបានឃ្លាតចាកកំសត់ទុគ៌តជាដើម ទាំងបំភ្លឺនិងឲ្យឃើញត្រូវយល់ល្អផង ជាសម្បត្តិមួយយ៉ាងស្រាលអាស្រ័យនៅនឹងខ្លួនបាន លោកទុកថាជាកំណប់ទ្រព្យមួយដ៏សំខាន់ ហៅថា គន្ថសមធិ "កំណប់ទ្រព្យស្មើដោយអង្គកាយ", សូម្បីភេទាន់ទំហំនណា ។ មិនចាំបាច់រែកវែង - លី - តុន - វេច - ខ្លប់ ប្តូរទ្រព្យនឹងការខ្មុកជាក់ឡើយ ចោរលួចយកក៏មិនបាន ជាវិជ្ជាឲ្យសុខកាតនឹងវិឡនកាត ទាំងបច្ចុប្បន្នជាតិនេះនឹងបរលោក; សេចក្តីនេះ សមដូចសុភាសិតក្នុងគម្ពីរលោកនីតិថា.

សិប្បសមំ ធនំ នត្ថិ សិប្បំ លោកេ ឥត្ថិយា
តេន លោកេ សិប្បំ មិត្តំ បរលោកេ សុខាវហំ ។

មានទ្រព្យមិនស្មើមានវិជ្ជា វិជ្ជាចោរលួចយកមិនបាន
វិជ្ជាខ្មុកជាមិត្រសន្ទាន ក្សាន្តក្នុងឥតលោកយោគបរលោក ។

វិជ្ជាជារបស់ថ្លៃថ្នូរយ៉ាងសំខាន់ អាចឲ្យប្រយោជន៍នឹងសេចក្តីសុខគ្រប់ប្រការ ដល់ខ្លួនប្រាណយ៉ាងនេះ បានជាត្រូវខំរៀន មិនត្រូវ

ដំអក់ទំនន់ទំលាក់ក្រាញដោយអាន្តរាយផ្សេងៗ ក្រៅពីការរៀន ព្រោះ
ក្រុងជាអាប់ស្មារតីខ្លាំងណាស់ ។

ម្យ៉ាងទៀត សូម្បីអ្នកមានទ្រព្យសម្បត្តិច្រើនស្រាប់ហើយក៏មិនត្រូវ
គិតថា គាំងរៀនវិជ្ជាក្រុងជាទំនឹងកទ្រព្យ ចុះបើមានទ្រព្យហើយ ចាំចប់
រៀនធ្វើអ្វីទៀត ! គំនិតយ៉ាងនេះក៏មិនត្រូវដែរ ព្រោះថាទ្រព្យដែលទំនងនៅ
ជាន ប្តូនឯកតែចំរើនឡើងជាន អាស្រ័យដោយមានវិជ្ជា វិជ្ជាទុកដូច
ជាដើមឥនសម្រាប់ទ្រ ប្តូទុកដូចជាសាសម្រាប់ចាក់ទុកជាក់ទ្រព្យសម្បត្តិ
ដែលកេជានមក ឯមនុស្សត្រូវចំណេះទើឯកក្សាទ្រព្យក៏មិនគង់ ទំនឹងកទ្រព្យ
សម្បត្តិក៏ជានដោយកម្រនេកណាស់ ទ្រព្យសម្បត្តិរបស់មនុស្សដែលឥត
ចំណេះ ដូចគ្នាទំនឹងរបស់ដែលនៅលើដៃមនុស្សវិកលចរិត សូម្បីគេបោក
ក្រុងស់មុខក្រោយក៏មិនដឹង ។ អ្នកឥតចំណេះ ទុកដូចជាចំណី ប្តូយាន
ដំនិះរបស់អ្នកមានចំណេះក្រុងជា មនុស្សល្ងីល្ងើបើទុកជាមានរូបសមរម្យ
ល្អ ក៏ឃើញល្អតែក្នុងវេលាមិនជានហាមាត់និយាយ បើហាមាត់ឡើង
និយាយវេលាណា ក៏ជាត់ល្អ អស់រលាជាតិ អស់ថ្លៃថ្លាវេលានោះ ។

ធម្មតាមនុស្ស ទោះបីមានក្រុងជាស្មារតីអន់អាប់ខ្លាំងយ៉ាងណាក៏ដោយ ឲ្យតែមានព្យាយាមរំប្រឹងរៀន តង់ចេះខ្លះមិនខាន, សម
ដូចសុភាសិតក្នុងគម្ពីរលោកនីតិថា:

អប្បកំ ជាតិមញ្ញេយ្យ ចិត្តេ ឯដ្ឋាបយេ សុតំ

វម្មិកក្ខុទកតិណ្ឌំ ចិរេន បរិប្ផរតិ ។

សេចក្តីថា: បុគ្គលកុំមើលងាយថា ព្រុយផ្សារបស់ខ្លួនតិចតួចស្តួច ស្តើងឡើយ គប្បីញុំាងចិត្ត តំណាស្តាប់នឹងការរៀនឱ្យបានទៅជាទុកជាសន្ធានចិត្ត ឃុំរក្សានឹងនេញជាប្រយោជន៍ដោយវិស្តារពុំខាន ប្រៀបដូចជាក្អមដែលគេយកទៅដាក់លើដំបូក រហោរភ្លៀងបង្អុរបុះមក ចួលក្នុងក្អមម្តងមួយដំណក់ ។ ឃុំរក្សាក្អមទោរងឹង តំនឹងនឹងនេញដោយដំណក់ទឹកភ្លៀងមិនខាន តំណាក់ដោយដែរ ។

មួយទៀត វិស្តារណាមួយដែលតិចតោសតោចបើតិចតួច តួចតាច ថយថោក យ៉ាងណាក៏ដោយ. បើមានតុកាសល្មមគ្រៀតរៀនបាន តំតួរតែរៀនឱ្យបាន ព្រោះសូត្រតែមានប្រយោជន៍ភាំរឹតអស់ ។ មានសុភាសិត កន្លងមកក្នុងគម្ពីរលោកនីតិប្រដៅទុកជាៈ

ខុទ្ទោតិ ជាតិមញ្ញេយ្យ វិជ្ជំ ច សិប្បមត្ត ច

ឯតាំបិ បរិយោធាតំ ជីវិតកប្បការណំ ។

សេចក្តីថាៈ បុគ្គលកុំតប្អូរមើលងាយមន្តសិល្បសាស្ត្រវិជ្ជា ដោយគិតថា វិស្តារតួចតាច ជន្តិចវន្តិច រៀនទៅក្រែងមិនសម្រេចប្រយោជន៍ សូម្បីវិស្តារតែមួយ បើឃុំរក្សារៀនបានចាំស្ទាត់ច្បាស់ហើយ តំនឹងនឹងសម្រេចផលប្រយោជន៍ តួនិតារចំញឹមជីវិតមិនខាន ។

វិជ្ជា គឺសេចក្តីចេះដឹងគ្រប់យ៉ាង ដែលហុចប្រយោជន៍ធំធឹងសេចក្តីសុខមកឲ្យនោះសោត ក៏ត្រូវតែខ្មីឃ្មាត់ដោយការប្រឹងហាត់ ប្រឹងរៀនជាមុនសិនដែរ ទើបបានចេះ បើមិនខំរៀនក៏មិនចេះ, សមដូចបុពណាគាសិតប្រដៅថា: «ចេះមកពីរៀន មានមកពីរក, មិនរកមិនមាន មិនរៀនមិនចេះ» ។

បណ្តាវិជ្ជាខាងផ្លូវលោកក្តី ខាងផ្លូវធម៌ក្តី វិជ្ជាណាមួយ អ្នករៀនៗមិនប្រាកដ ចាប់នេះបន្តិច ចាប់នោះបន្តិច ច្បាស់ៗ ត្រង់ណេះមួយចុប ត្រង់ណោះមួយចុប មិនប្រាកដដោយមុខវិជ្ជាណាមួយសោះ ពុំនោះសោតរៀនចេះដឹងស្ទាត់ប្រាកដហើយ ប៉ុន្តែមិនបានព្យាយាមរំលឹកបន្តែមទៀតទេ ឬមិនយកវិជ្ជានោះមកប្រើការទេ មុខតែនឹងភ្លេចជាមន្ទិល ជាទោសគឺក្លេចបាត់ប្រើការមិនកើត ។ ព្រោះហេតុនោះ បានជាព្រះបរមលោកនាថ ទ្រង់សំដែងថា «អសជ្ឈាយមលា មន្តា មន្តានំ ឯឡាយ មានការមិនស្វាធ្យាយជាមន្ទិល» ។

ត្រង់មាតិកាទី ២ ថា «ផ្ទះគាំងឡាយ មានការមិនជូសជុល មិនថែទាំជាមន្ទិលេ», អធិប្បាយថា: គេហដ្ឋានជាលំនៅ ដែលយើងនៅអាស្រ័យជាប្រក្រតីមិនអើពើថែទាំ បណ្តោយឲ្យស្មោកគ្រោកដោយតក់ក្រាំ ខាងក្រោមផ្ទះ ឬជួលសំរាមសំរេចតក់ក្រាសតេញក្នុងផ្ទះខាងក្រៅផ្ទះ ទឹងសម្បុកពីងពាង រែងភ្លើងរុំខ្សែព័ទ្ធតាលើពីក្រោមស្រុកគស្រកាកក្នុងផ្ទះ

ឬផ្ទះនោះលេចបាក់បែកធ្លាយធ្លុះខ្រេតខ្រោត មិនជួសជុលមិនសំអាត
ទេ ជាហេតុនាំឲ្យទៅជាមន្ទិលសៅហ្មង គឺបណ្តាលឲ្យកើតអន្តរាយ ឬ
រោគផ្សេងៗ ដល់មនុស្សអ្នកនៅក្នុងផ្ទះមិនខាន ។ ចំណែកខាងបព្វជិត
ក៏តប្បីប្រព្រឹត្តតាមន័យនេះដូចគ្នាដែរ ។ ព្រោះហេតុនោះ បានជាព្រះ
លោកុត្តមាចារ្យ ត្រាស់សំដែងថា "អនុដ្ឋានមលា ឃរា ផ្ទះ
ទាំងឡាយមានការមិនចេះចាំ មិនជួសជុល ជាមន្ទិល" ។

ត្រង់មាតិកាខ័ញ្ញ ថា "សេចក្តីខ្ជិលជាមន្ទិលរបស់សម្បុរ", អធិប្បាយ
ថា បុគ្គលជាគ្រហស្ថក្តី បព្វជិតក្តី ប្រកបដោយសេចក្តីខ្ជិលច្រអូស ការ
មើលឆ្ងាយប្រឡាក់ប្រឡូសដោយមន្ទិល គឺធ្មេញក្អែល ឬបែកញើស
ហូរចេញមកតាមអួតក្នុងអាក្រត់ហើយ មិនបានលាងជំរះដោយទឹក ឱសថ
គ្រឿងលុបលាងទេ ជាហេតុនាំឲ្យទៅជាមន្ទិលសៅហ្មង គឺមានសម្បុរ
កាយតាក្រក់ បណ្តាលទៅជារោគផ្សេងៗ មានប្លុសបមកមរមាស់ជា
ដើម ពុំនោះសោត សំពត់ឬចីវរជាគ្រឿងសម្រាប់ស្លៀកពាក់ ប្រឡាក់
ភ្ញើសក្អែលតាប់អួ មិនស្អាតបាត់លាងហាល ធ្វើឲ្យស្អុតជាដើម
ជាហេតុនាំឲ្យទៅជាមន្ទិលសៅហ្មង គឺមានឥណិសម្បុរអន់តាប់តាក្រក់
ធ្លុំក្នុងអាសោចដល់អ្នកជាដៃ ធាប់ចាស់ ធាប់រំហែក, ខេះជាដោសមកតែ

អំពីសេចក្តីឱ្យលះក្រអូសនឹងឯង ។ ព្រោះហេតុនោះ ឃានជាព្រះមានព្រះភាគ
សំដែងថា "ឥលំ វណ្ណាសុ ឧត្តាសង្ខំ សេចក្តីឱ្យលះជាមន្ទិលរបស់សម្បុរ" ។

ត្រង់មាតិកាទី ៤ ថា "សេចក្តីក្រេវក្រោធជាមន្ទិលរបស់បុគ្គលអ្នករក្សា (ទ្រព្យ)", អធិប្បាយថា បុគ្គលអ្នករក្សាទ្រព្យសម្បត្តិមានវិញ្ញាណមានតោ, ក្របី, សេះជាដើម, ទ្រព្យឥតវិញ្ញាណ មានសំលៀកបំពាក់ជាដើម ជាអ្នកប្រកបដោយសេចក្តីក្រេវក្រោធ រមែងតែជេរប្រមាថ តែដើរលេងមិនចៃដំប្រុងប្រយ័ត្ន បណ្តាយឲ្យគោ, ក្របីទាំងនោះរត់ចាត់ចៅ ឬអន្តរាយដោយប្រឹតសាហាវពាប់ធ្លុះចំណី ឧដ្ឋានរបស់ជាដើម ប៉ើមិនដូច្នោះទេ គោក្របីនោះឯងចូលទៅស៊ីដំណាំរបស់គេ។ កំចាប់យកទៅពួនផ្តល់តិចយកធ្វើជាសំណងសងទ្រព្យធនធាន ឬខ្លួនឯងដល់នូវតិចយកទៅមកវិញ តាំងនោះសោត ត្រូវគេដេរប្រទេចផ្តាសាផ្សេង។ ក៏មាន ។

ម្យ៉ាងទៀត ទ្រព្យសម្បត្តិសម្រាប់ប្រើប្រាស់ក្នុងផ្ទះគឺគ្រឿងទុបភោគ ឧដ្ឋានគ្រឿងបរិភោគ មិនចេះរៀបចំទុកដាក់ឲ្យមានសណ្តាប់ធ្នាប់ បណ្តាយឲ្យពាក់ព័ន្ធរាត់រាយទៅដោយហេតុផ្សេង ។ ទ្រព្យទាំងនោះ ក៏ឧដ្ឋានដល់នូវសេចក្តីវិនាសអន្តរាយ មានចោរលួចជាដើម ទាំងនេះក៏ជាហេ

មកតែអំពីមនុស្ស តើសេចក្តីធ្វេសប្រហែស ឥតគំនិតហ្នឹងឯង ។ បើចំណែកខាងបព្វជិតវិញ តើមានការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន មិនគ្រប់គ្រងរក្សាសង្រួមខ្លួនឲ្យជាដើម បើកនុងសាសនាព្រះសម្មាសម្ពុទ្ធ តើគំរើសមានពាន:ជាដើម ចូលមកញាំញីគ្រប់សង្កត់បង្ខិលចិត្តនៃបព្វជិតនោះ ឲ្យហ៊ានប្រព្រឹត្តធ្វើនូវអំពើអាក្រក់ផ្សេងៗ មានតុកាបត្តិជាដើម ដែលជាអំពើមិនសមគួរដល់សមណៈគេទេ ។ ព្រោះហេតុនោះ បានជាព្រះអរហំសម្មាសម្ពុទ្ធទ្រង់សំដែងថា " បមាទោ រក្ខតោ មលំ សេចក្តីធ្វេសប្រហែស ជាមន្ទិលរបស់បុគ្គលអ្នករក្សាទ្រព្យ " ។

ត្រង់មាតិកាទី ៥ ថា " ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី " , មធិប្បាយថា ស្ត្រីណាដែលប្រព្រឹត្តក្បត់ចិត្តស្វាមីរបស់ខ្លួន តើជាខ្លួនមានគួរស្រឡាស្វាមីគោរពសួរណៈចូលចាប់ហាយ មិនស្អប់ស្អើលៗ មានចិត្តរំលោភទៅលើបុរសដទៃទៀត, ការប្រព្រឹត្តនុះប្រៀណាយ៉ាងនេះ ឈ្មោះថាជាមន្ទិលសាមកអាក្រក់បំផុតរបស់ស្ត្រីនោះ ។ ចំណែកខាងបុរសជាស្វាមីគេតវិញវិញ ក៏សេចក្តីស្តាយក្រៃយក្តៅក្រហាយ ទៅជារកឿងទាស់ខែងនឹងគ្នា បណ្តេញស្ត្រីជាតំណាងនោះ ឲ្យចេញចាកត្រកូលរបស់ខ្លួន ស្ត្រីនោះឯង ក៏ទៅជាមនុស្សគ្មានថាឥតវិតីធ្លាស់ខ្លួនសេចក្តីទុក្ខលំបាក

ត្រង់ឃាត ។ ព្រោះហេតុនោះ ឃាននាសម្តេចព្រះអនាវរណញ្ញាណ ទ្រង់ត្រាស់ថា "មលិត្ថិយា ទុច្ចរិតំ ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី" ។

ត្រង់មាតិកា ខ ๖ ថា "រសចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ", អធិប្បាយថា បុគ្គលមានចាគចិត្តបំពុងនឹងលះតែម្តងឲ្យទៅជាទាន តែដោយអំណាចមច្ឆេរចិត្ត គឺចិត្តកំណាញ់កើតឡើងកាំងស្ងាត់ដណ្តើរចាគ-ចិត្ត មិនឲ្យលះបង់ទៅកើត គួយ៉ាងដូចជាបុគ្គលអ្នកធ្វើស្រែប្តូរធ្វើដំនួញជាដើម រាល់កំពុងធ្វើមានគំនិតតិចថា រមៀស្រែប្តូរដំនួញដែលមានភ្នាក់ងារនេះ ការណាផលប្រយោជន៍ច្រើនសម្រេចហើយ នឹងបង្ហាតទ្រព្យធ្លាក់ជាមានក្នុងកាលនោះមិនខាន ។ លុះរាល់ផលប្រយោជន៍ច្រើនសម្រេចហើយ ស្រាប់តែមច្ឆេរចិត្ត គឺចិត្តកំណាញ់កើតឡើងកាំងគំនិតដែរទៅជាគិតថា បុរេមេញ្ចំណាយទ្រព្យនោះ ធ្លើជាមានអស់ទៅ ខ្ញុំនឹងក្តីប្រពន្ធកូនរបស់នឹងក្តី ទើងបានអ្វីចិញ្ចឹមជីវិត នឹងបានអ្វីប្រើប្រាស់ក្នុងគ្រួសារ ទើងបានអ្វីទុកការពារទៅមុខ ។ កាលបើមច្ឆេរចិត្តដ៏មានកម្លាំងកើតឡើង គ្របសង្កត់ចាគចិត្តមិនឲ្យងើបរួចឡើងដកបណា បុគ្គលនោះឯងឈ្មោះថាឃ្លាងមានបានទ្រព្យអំណាយផល ដែលកើតអំពីការបរិច្ចាគ

ទានជាកបនោះ ។ ព្រោះហេតុនោះ ទ្រង់ជាព្រះលោកុត្តមាចារ្យត្រាស់ ថា "មច្ចេរំ ឧទតោ មលំ សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឲ្យ ។

ត្រង់មាតិកាទី៧ ថា "ចាបជមិ ជាមន្ទិលក្នុងលោកនេះផង នឹងលោកខាងមុខផង", អធិប្បាយថា ចាបជមិជាធម៌ដ៏លាមកបែកខាងអកុសលដែលបុគ្គលប្រព្រឹត្តអាក្រក់ដោយកាយ, វាចា, ចិត្ត ពាប់បាលក្នុងអកុសលកម្មបថភាគ ១០ ឬក្នុងទុបក្កិលេសភាគ ១៦ មានអភិជ្ឈាវិសមលោភៈ ជាដើម ហៅថាចាបជមិ ។ ធម្មតាអំពើអាក្រក់ដែលបុគ្គលធ្លាប់ហើយ កុំថាឡើយជាប់ទៅអំពើនឹង ។ សូម្បីតែអំពើតូច ។ ក៏មិនកំចាំងចាត់ស្ងាត់ដែរ បើទុកដាក់កំចាំងចាត់ក្នុងលោកនេះ ទៅលោកខាងមុខតែម្យ៉ាងជាក់ស្តែងដោយខ្លួនឯងមិនខាន ជួនកាលក៏ឃើញជាក់ស្តែងក្នុងលោកនេះ លុះទៅកាន់លោកខាងមុខ ក៏ឃើញជាក់ស្តែងទៀត ។ ព្រោះហេតុនោះ ទានជាព្រះសយម្ភូញាណទ្រង់សំដែងថា "មលា វេ ចាបតោ ឧប្បា អស្មឹ លោកេ បរម្ហិ ច ចាបជមិ ពាលិយា ជាមន្ទិលក្នុងលោកនេះផង ក្នុងលោកខាងមុខផង" ។

ត្រង់មាតិកាទី ៨ ថា "អវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ជាងមន្ទិលទាំងនោះទៅទៀត", អធិប្បាយថា សេចក្តីមិនចេះមិនដឹងល្ងីតល្ងង់រវើរវាយមិនយល់តាមតថភាពនឹងឯង ហៅថា អវិជ្ជា ។ អវិជ្ជានេះ ជាដើមឥតិ ដើម

ចម ធ្វើមនុស្ស-សត្វឲ្យលង់ វង្វេងក័ន្តគំនិត មិនយល់សេចក្តីពិតតាមគតិលោក ទឹងគតិធម៌ ។ បើនិយាយដល់ថ្នាក់ជាន់ខ្ពស់ គឺមិនដឹងនូវហេតុ ៨ យ៉ាង មានមិនដឹងថា នេះជាគ្លួទុក្ខ, នេះជាហេតុនាំឲ្យកើតទុក្ខ, នេះជាទុបាយនាំឲ្យរលត់ទុក្ខ, នេះជាបដិបទា ដំណើរនាំឲ្យដល់នូវសេចក្តីរលត់ទុក្ខជាដើម ។ ព្រោះហេតុនោះ ទ្រង់ជាព្រះបរមសាស្តាទ្រង់ត្រាស់សំដែងថា «តតោ មណា មលតរំ អវិជ្ជា បរមំ មលំ អវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ជាធម៌មន្ទិលដូចជាន់ពោលមកហើយនោះឯង ។

ដំណើរនេះ គួរអស់លោកជាពុទ្ធបរិស័ទ ខាំងឲ្យយល់ច្បាស់នូវធម៌ជាមន្ទិលឲ្យបានដុតស្រឡះអំពីខ្លួនចេញ ដូចជាន់សំដែងមកហើយនេះ គង់នឹងបានជួបប្រសព្វ ឬតិចតួចប្រទេះ នូវសុខភាពនឹងវិញ្ញានភាពគ្រប់ប្រការ ក្នុងបច្ចុប្បន្នជាតិនឹងអនាគតជាតិ ជាលំដាប់តទៅភ្លាមៗ ។

បញ្ចប់ធម្មទេសនា ដោយសង្ខេបត្រឹមប៉ុណ្ណេះឯង ។

រោគចិត្ត

លោក ស៊ុន - ហ៊ាន រៀបរៀង

សភាពដែលធ្វើចិត្ត ឲ្យសៅហ្មង ឲ្យកកស្អុត ឲ្យក្តៅក្រហាយ ឲ្យអន្ទះអន្ទែងជាដើម ហៅថា រោគចិត្ត ។

ពាក្យថា "រោគចិត្ត" នេះ គង់មានជនខ្លះសួរថ្លែងត្រៀបក្បាតុំមានព្រោះមនុស្សភាគច្រើនតែងយល់ថា អ្នកដែលកើតរោគចិត្ត គឺមនុស្សមានសតិវិបល្លាស ឬមនុស្សឆ្កួតដែលទៅកន្លងខ្លួនពេទ្យព្យាបាលរោគចិត្តនោះតែបើពិចារណាតាមគោលនៃព្រះពុទ្ធសាសនា មនុស្សដែលមានរោគចិត្តតុំមែនសំដៅយកមនុស្សមានសតិវិបល្លាសនោះទេ គឺសំដៅយកបុថុជ្ជនអ្នកមានកិលេសតណ្ហា,ឯអ្នកដែលគ្មានរោគចិត្ត មានតែព្រះអរហន្តដែលលះកិលេសអស់ហើយប៉ុណ្ណោះ ។ ធម្មជាតដ៏ពិតប្រាកដរបស់ជួងចិត្តនោះបរិសុទ្ធស្អាតណាស់ ថើតុំមានរោគអ្វីមករៀតរៀនទេ , តែដែលធ្វើឲ្យជួងចិត្តគ្រាយថាតសភាពដើមនោះ ខាងគាសាបាលីហៅថា «ឧបក្កិលេស" គ្រឿងសៅហ្មងចិត្ត ឬគ្រឿងធ្វើចិត្តឲ្យមានតំណើរស្រអាប់តុំមានពីរ ។

រោគចិត្ត មានលក្ខណៈប្រហែលគ្នានឹងរោគផ្លូវកាយ, រាងកាយរបស់មនុស្ស បើចេះរក្សាតាមច្បាប់អនាម័យ, ឧស្សាហ៍បញ្ចេញកម្ចាំង, ចេះបរិភោគអាហារ ដែលជាប្រយោជន៍ដល់រាងកាយ ឥរិយាខ្លួនមានផ្នាំព្យាបាលរោគ, អ្នកដែលចេះរក្សារាងកាយដូច្នេះ ការឈឺចាប់តុំមានឱកាស

នឹងចូលមកបៀតបៀនបាន, ឯកោតចិត្តក៏មានលក្ខណៈដូចគ្នា បើចេះរំដើរក្បាចិត្តរបស់ខ្លួន ចិត្តក៏មិនអាចមានកោតៅបាន តែការក្បាចាលកោតចិត្តលំបាកជាងការក្បាចាលកោតផ្សែងកាយ ព្រោះកោតផ្សែងកាយគេឲ្យអាចនឹងពិនិត្យៅឃើញសម្គាល់កោត ហើយក្បាចាលឲ្យសះជាបានដោយងាយឯកោតចិត្តជាកោត ដែលគេឲ្យពិនិត្យៅឃើញបានដោយកម្រណាស់, មនុស្សខ្លះសូម្បីតែតោតចិត្ត ក៏មិនដឹងថាខ្លួនកើតមានកោតចិត្តផង ។ កោតដែលនឹងចូលមកបៀតបៀនចិត្តមានច្រើនណាស់នឹងប្រមាណមិនបាន តែកាលបើរួបរួមគោលចំរោះតែកោតចិត្តប្រភេទធំៗ មាន ៣ យ៉ាងគឺ :

១- រោគស្រេឡាញ់,

២- រោគស្អប់,

៣- រោគវិង្វែង.

រោគស្រឡាញ់បានដល់កាត: ដែលសោសឡំដោយកិលេសតណ្ហា មានពិសក្តៅក្រហាយណាស់, ព្រោះសម្តីទ្រង់ត្រាស់ថាជាភ្លើងមួយយ៉ាង ដែលដុតកំដៅចិត្តឲ្យក្តៅក្រហាយត្រាល់ត្រាំងជានិច្ច, សេចក្តីស្រឡាញ់ ទើបថាជារោគចិត្តមួយដែរ ។ បុគ្គលដែលមានរោគស្រឡាញ់ សង្កេតឃើញនូវអាការដែលសំដែងចេញមកផ្សែងកាយ ដូចស្រីក្រមុំ ហ៊ឺហាខ្លះឆ្ងាយទ្រព្យសម្បត្តិកុងការតែងខ្លួនជ្រុលណា មិនស្គាល់ប្រមាណខ្លួន ទោះបីខ្លួនមាន

ហានៈក្រខ្វក់ កំមិនចាននឹកដល់ដែរ សុំឲ្យតែចាននៃតែងខ្លួនយ៉ាងហ្មឺងហ្មឺ ប៉ុណ្ណោះគាំហើយគ្នា ។ ប្រុសតម្កោះសំដែងខ្លួនជាអ្នកចំណូលខាងស្រីតាលបើចាននជួបប្រទះតែរនេះ កំព្យាយាមសំដែងអាការ ប្តូនិយាយលួងលោម ជាអ្នកចំណូលហួសហេតុ ។ ឪពុកម្តាយដែលស្រឡាញ់កូនខ្លាំងតែងបើកអំណាចតាមចិត្តកូនគ្រប់យ៉ាង ធ្វើឲ្យកូនមានឱនិស្ស័យជាអ្នកទំនើសជាអ្នកខ្ជះខ្ជាយហ្មឺងហ្មឺ, អាការទាំងនេះឯង ជាអាការបេះសំពេកស្រឡាញ់ដែលសំដែងចេញមកឲ្យប្រាកដខាងក្រៅ ។

ពេកស្អប់ ជាពេកចិត្តមួយបែប ដែលបង្កើនសេចក្តីក្តៅក្រហាយ, មនុស្សដែលកើតពេកស្អប់ តែងឆ្គើតឃើញចាននដល់មនុស្សដែលខឹងរាល់ ចិត្តច្រើនមានមុខប្រមឹងពាល់តែលវាលា និយាយចាចចញពីមិនតែពេះដល់ត្រចៀក ។ មនុស្សខ្លះកើតពេកស្អប់ខ្លាំងឡើង ចាននៅជាយកប់សម្លាប់គ្នាក៏មាន ។

ពេកវង្វេង ជាពេកចិត្តមួយបែបទៀត, អាការបេះមនុស្សដែលកើតពេកវង្វេង គឺការភ្លេចមុខ ភ្លេចក្រោយ ច្រើនដឹងយាយផ្តេសផ្តាសគ្មានសារប្រយោជន៍, ពាំងនេះឯងជាអាការបេះពេកវង្វេង ។

ពេកចិត្ត ៣ បែប គឺ ពេកស្រឡាញ់, ពេកស្អប់ខឹង ពេកវង្វេងនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានឧបមា ៣ បែប ទុកសម្រាប់ពាក្យពោលពេកចិត្ត គឺ ប្រទានឧបមាកម្មដ្ឋាន សម្រាប់ពាក្យពោលពេកស្រឡាញ់, ប្រទានមេត្តា

ព្រហ្មវិហារ សម្រាប់ព្យាបាលភេតស្អប់ ទើនប្រពន្ធអានាបាណស្សតិ សម្រាប់ព្យាបាលភេតវង្វើន ។

ដែលព្រះសម្ពុទ្ធទ្រង់ប្រពន្ធអសុភកម្មដ្ឋាន ទុកឲ្យភ្លក្ខភេតស្រឡាញ់នោះ ព្រោះទ្រង់ឃើញថា ភេតស្រឡាញ់ត្រូវព្យាបាលដោយទុសថដែលជាសត្រូវនឹងគ្នា ។ អសុភកម្មដ្ឋានជាកម្មដ្ឋានមួយបពួកក្នុងកម្មដ្ឋាន ៤០ ប្រែថា « ការពិចារណាឃើញថាមិនស្អាតគួរខ្ពើមឆ្អើម » ។ មនុស្សដែលកើតភេតស្រឡាញ់ គួរចំរើនកម្មដ្ឋានបពួកថា មិនស្អាតនេះ គឺកុំឲ្យសម្លឹងមើលទៅឃើញសុទ្ធតែល្អគាំងអស់ខ្លាំងពេក ដូចស្រីក្រមុំចូលទៅកន្លែងកម្សាន្ត កុំឲ្យសម្លឹងមើលរបស់ឆ្អែនៗ ក្នុងកន្លែងកម្សាន្ត សុទ្ធតែល្អគាំងអស់នោះ, គួរនឹកថារបស់គាំងនេះ « មិនល្អ , មិនស្អាត » ទូរធ្លាក់ដើម្បីបន្ថយខ្លួនសេចក្តីស្រឡាញ់ ទើនសេចក្តីជ្រុលជ្រាលចិត្តបាន ឲ្យស្រាលស្តើងតិចទៅ តែបើចេះតែនឹកថា អាវ - សំពត់នេះល្អ, កំប្រុងនេះល្អ ក្រមួបនេះល្អ ទើនធ្វើឲ្យភេតស្រឡាញ់កំរើកកាន់តែខ្លាំងឡើង ក្នុងចំណុតគឺត្រូវចេះវាយប្រហារគាស ចំញ្ញូវបរស់គាំងនោះយ៉ាងខ្លះឆ្លាយ ហួសការចាំបាច់ ។ ក្នុងកម្មវិធីដែលបានឃើញស្រីក្រមុំ ក៏កុំឲ្យសម្លឹងមើលដោយកំណត់ក្នុងចិត្តថា នាងនោះល្អស្អាតជ្រុលហួសពេក ទើនធ្វើឲ្យចិត្តកំរើកស្រឡាញ់ នាំឲ្យរោតចិត្តចំពោះការសិក្សារៀនសូត្រ អាចឲ្យប្រឡងធ្លាក់ក្នុងវេលាតំណាចំនាំមួន ។ ពុំខាន ។ ឧទាហរណ៍ដែលពោល

មកភាវនាលើនេះ នាំឲ្យខ្ញុំយល់ឃើញថា អសុភកម្មដ្ឋានជាកម្មដ្ឋានដែលណែនាំសាធុជនគ្រប់ប្រភេទឲ្យមានសេចក្តីព្យាយាម ឥតគិតនឹកពិចារណាមើលចំពោះតែផ្នែក ។ ថា មិនស្អាតមិនល្អ ដើម្បីជាគ្រឿងកែកេតស្រឡាញ់ដោយពិតប្រាកដ ។ សូមសាធុជនគ្រប់ហាទៈ ដែលមានកេតស្រឡាញ់ បីតនៅក្នុងសន្តាន គួរនាំគ្នាយកទៅពិសោធមើល ។

កេតស្អប់ ព្រោះមិត្តខ្ពើមប្រតាន ព្រហ្មវិហារ គឺមេត្តា, ករុណា, មុទិតា, ឧបេក្ខា ដើម្បីជាគ្រឿងកែកេតស្អប់ ព្រោះកេតស្អប់ជាវេតដ៏ក្តៅ ។ ឯព្រហ្មវិហារជាធម៌ត្រជាក់ ល្មមនឹងរំលត់កេតស្អប់បាន ។ មនុស្សដែលកើតកេតស្អប់ មានអាការក្រោធខឹងឆាប់ ចិត្តប្រែនោះ បើជាខមេត្តាធម៌ មកគប្រមណ្តុះបណ្តាលខ្លួនសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ, បណ្តុះករុណាធម៌ គាលឃើញអ្នកដទៃបានខ្វល់ខ្វាយនូវសេចក្តីទុក្ខ, បណ្តុះមុទិតាធម៌ មិនឥច្ឆា ឫស្យា សំដែងសេចក្តីត្រេកអរអែកយ គាលឃើញអ្នកដទៃបានល្អ បានចំរើន ឧបេក្ខាធម៌ គឺជាកន្ទុយជាគណ្តាលមិនលំអៀងចូលទៅខាងណា ។ ព្រហ្មវិហារទាំង ៤ យ៉ាងនេះ មនុស្សដែលមានកេតស្អប់បីតនៅក្នុងសន្តាន គួរនាំគ្នាយកទៅពិសោធមើល ។

កេតវង្វិន ព្រោះរង្គិនខ្ពើមប្រតាន អានាបាណស្សតិ ជាគ្រឿងកែកេតវង្វិន ព្រោះមនុស្សដែលកើតកេតវង្វិន ច្រើនមានចិត្តពយមាយ

មិនស្ងប់រម្ងាប់ គួរតែអប់រំចិត្តឲ្យមានសមាធិជាធម៌សមគួរសម្រាប់តែកេត
វង្វើងបាន ពុំមានអ្វីស្មើនឹងអានាបាណស្សតិ ការកំណត់ដង្ហើមចេញចូល
នេះឡើយ ។ កម្មដ្ឋាននេះ មនុស្សដែលកើតកេតវង្វេង អាចនឹងនាំ
យកទៅអប់រំចិត្តបានច្រើនពេលវេលា ដូចវេលាអាស្រ័យដំណេក មាន
ចិត្តពយមាយអណ្តែតអណ្តូងទៅក្នុងរឿងច្រើនយ៉ាង កំចូរណែនាំចិត្តឲ្យ
មកកំណត់នូវអានាបាណស្សតិ គឺដង្ហើមចេញចូលនេះ ដូចគាលដង្ហើម
ចេញចូលខ្វី គំឲ្យដឹងថា ដង្ហើមចេញចូលខ្វី, ដង្ហើមចេញចូលវែង គំ
ឲ្យដឹងថា ដង្ហើមចេញចូលវែង ។ ការចំណាត់ដង្ហើមចេញចូលនឹងអាចធ្វើ
ចិត្តឲ្យស្ងប់រម្ងាប់ដោយពិត អាចអាស្រ័យដំណេកលក់បានដោយស្រួល
មិនចាំបាច់ញ៉ាំដេកលក់យកមកសោយ តាំងអស់ប្រាក់កាសឡើយ ។

ការព្យាបាលកេតចិត្ត គឺកេតស្រឡាញ់, កេតស្អប់ ទើងកេតវង្វើង
ដោយឧទ្ទេសបី ៣ មុខនេះ គឺព្យាបាលកេតស្រឡាញ់ ដោយកម្មដ្ឋាន
ឈ្មោះអសុភ, ព្យាបាលកេតស្អប់ដោយកម្មដ្ឋានឈ្មោះព្រហ្មវិហារ ទើង
ព្យាបាលកេតវង្វើង ដោយកម្មដ្ឋានឈ្មោះអានាបាណស្សតិ ដូចពោល
មកដោយសង្ខេបនេះ ជាវិធីមួយយ៉ាងដែលព្យាបាលកេតចិត្តល្អណាស់
ពុំសូវមានវេបៀបច្រើនប៉ុន្មានឡើយ ។ ឯការសំខាន់ជិតនៅត្រង់ពុទ្ធមា-
មកជនដែលមានសេចក្តីគោរពចំពោះព្រះពុទ្ធសាសនា ហើយនាំយកវិធី
នេះទៅប្រតិបត្តិតាមប៉ុណ្ណោះ ។

សុរពជាតក

(តមក)

លោក ជិត-វិន ចម្លងពីសៀវភៅស្លឹករឹត

ព្រះនគរហើយ ចូលទៅក្នុងប្រាសាទមាស ។ ព្រះនាងកល្យាណី
យើញទុសចរិត ក៏ខឹងសង្វែយ ហើយប្រើឲពិនិត្យឫកពា កំពុងមាន
សីហនាទដូចព្រះមហាក្សត្រ្តី តាំងពាក្យសំដីក៏ញ៉ើតញ៉ើម ទ្រង់
មន្ទិលពីដលក្នុងព្រះពេជហឫទ័យណាស់ ហៅអាមាត្យម្នាក់មកត្រាស់សួរ
ថា ម្នាលអាមាត្យ ! រីសេនាបតីមកជាមួយដែរឬ ? ។ អាមាត្យក្រាប
ទូលថា អើយ បពិត្រព្រះនាងជាម្ចាស់ ! រីឬសេនាបតីនោះ ដេក
ដួលនៅកណ្តាលព្រៃ ដំណើរនេះ ទូលព្រះបង្គំពុំដឹងឡើយ ។ ព្រះ
នាងស្តាប់ហើយ ទ្រង់ព្រះចិន្តាថា " នេះសមព្រះមហាក្សត្រ្តដកចិត្តចេញ
ពីព្រះរូប ទៅចូលក្នុងបក្សី ឬម្រឹគស្ងាប់ណាមួយ, ឯសេនាបតីនេះ ដក
ដួងចិត្តចេញ . ចូលក្នុងព្រះរូបស្វាមីនៃអញ ហើយនាំយោងចូលមក
ព្រះនគរវិញ ចោលព្រះមហាក្សត្រឲ្យទៅក្នុងព្រៃពុំសែងឡើយ , ឧ!
សេនាបតីនេះហើយ ជាមនុស្សអកតញ្ញូណាស់តែ"; ចាប់តាំងពីពេល
នោះមក ព្រះនាងពុំទៅគាល់សេនាបតីនោះឡើយ ទោះបីសេនាបតីមក
គាន់សំណាក់ព្រះនាង ក៏ព្រះនាងពុំរាទូល ពុំស្រដីសោះ ។

រឿងនេះសូមស្ទែងទុកសិន, យើងនឹងនិទានពីព្រះមហាក្សត្រវិញ ។

កាលស្តេចចូលក្នុងរូបម្រឹគនោះ ឃានត្រាច់ទៅក្នុងលង្វែកព្រៃតាំងពីព្រឹក រហូតថ្ងៃត្រង់ ទៀរឃលំបាកក្នុងកាយជាខ្លាំង ទើបដើរទៅទៀតឃើញ ស្រះមួយចុះផឹក ហើយក្រឡេកមើលទៅ ឃលៅសេកសោមបណ្ដើតមួយ ស្លាប់ថ្មី ។ ក៏ពេលនោះ ព្រះនាងក៏ចេញអំពីម្រឹគ ចូលក្នុងសេកសោមបណ្ដើត ហើចហើរមកតាមអាកាសចូលដល់ប្រាសាទព្រះនាងកស្សាណ៏ ។ ព្រះនាង ឃលៅសេកសោមបណ្ដើតហើយ ស្គាល់ជាក់ថាជាស្វាមីព្រះនាង ក៏ពិនិត្យ ពិចារណាតវិញាបថ ឃលៅឮសំថាជាព្រះមហាសត្វត្រូចូលក្នុងសេកសោម បណ្ដើតពិតប្រាកដ ។ ក្នុងណោះ សេកសោមបណ្ដើត ពោលជាភាសា មនុស្សថា "បុគ្គលមិនគួរជឿហេតុព័យ៉ាងគឺ: សឹកសត្រូវមានចិត្តល្អ ១, ស្រីមានចិត្តត្រង់ ឬ ការយាមិនចេះក្បត់ស្វាមី ១ ", បុគ្គលមិនគួរសេពគប់ មនុស្សពីរពួកនេះឡើយ ។ ព្រះនាងទ្រង់ព្រះសណ្ដាប់ហើយ មានព្រះ សារីទៅកាន់សេកសោមបណ្ដើតថា កឹ កត ដេសិ បពិត្រសេក សោមបណ្ដើត! ហេតុអ្វីក៏អ្នកស្រដីដូច្នោះ? ស្ត្រីឯទៀតក៏អ្នកមិនស្រដីឆ្គង អាធិសា ស្រីដូចខ្ញុំម្ចាស់ តើមានចិត្តក្បត់ដូចម្ដេច? ខ្ញុំម្ចាស់ស្គាល់ ជាក់ជាព្រះអង្គហើយ បើកុំតែដួងចិត្តព្រះអង្គនៅក្នុងសេកសោមបណ្ដើត ខ្ញុំម្ចាស់ពុំស្រដីកេឡើយ, បពិត្រសេកសោមបណ្ដើត! អញ្ជើញស្តេច គង់លើបល្ល័ង្កឥន្ទ ជាប្រកបនឹងទៅនូវកម្រាសដ៏វិចិត្រ សូមស្តេចប្រថាប់ នៅហោង ។ សេកសោមបណ្ដើត ក៏ឡើងគង់លើបល្ល័ង្កឥន្ទ ។ ព្រះ

នាងកល្យាណី ឃាត់យកលាជសាយដោយទឹកឃ្មុំ ដាក់ក្នុងផ្តិលមាសថ្វាយ
សោយរួចហើយ ទ្រង់ព្រះចិន្តាថា តួរអញគិតទុកាយកលយកព្រះរូបព្រះ
ស្វាមីនៃអញឲ្យឃើញវិញ ព្រះនាងជណ្តើងសួរថា បពិត្រសេកសោម
បណ្ឌិត! ព្រះអង្គយាងមកពីណា ? ។ សេកសោមបណ្ឌិតទូលថា
យើងមកពីព្រៃ ។ តើព្រះអង្គចេញពីប្រទេសណាទៅ ? ។ ម្នាល
នាងទេវី ! យើងចេញពីក្រុងសាវត្ថី-ពីនគរនេះទៅប្រាំគាត់ព្រៃ ឃើញ
ម្រឹគមួយស្ងាប់ថ្មី ។ យើងមានចិត្តចង់គ្រាប់លេងក្នុងលង្វែកព្រៃ ខ្លែរពាយ
មន្តបន្ទុយចិត្តចូលក្នុងរូបម្រឹគនោះ គ្រាប់ចូលទៅក្នុងព្រៃតែម្នាក់ឯង លុះ
ខ្មៀយហត់ខ្លាំង រំលងមកកកសេនារយោជនកំពុងឃើញឡើយ ឃើញតែរូប
សេនាបតី គំដឹងថា សេនាបតីជាមនុស្សក្បត់, យើងដើរទៅជល់
ស្រះមួយ បានឃើញរូបសេកសោមបណ្ឌិតមួយស្ងាប់ថ្មី។ គិតចិត្តចេញ
ពីរូបម្រឹគ ចូលក្នុងរូបសេកសោមបណ្ឌិត ហើយហើរមកកកព្រះនាង
នេះហាន៎ កន្ទេ វិបស្សកោ ម្នាលព្រះនាងដ៏ចំរើន! តើព្រះនាងឃើញ
ស្វាមីរបស់ព្រះនាង មានឥរិយាបថផ្សេងពីដើមឬទេដែរឬទ្រង់ ? ។ ព្រះ
នាងក្រាបទូលថា បពិត្រព្រះអង្គ! ខ្ញុំម្ចាស់សង្កេតឥរិយាបថ ឃើញខុស
ពីឥរិយាបថរបស់ព្រះអង្គ ទើបខ្ញុំម្ចាស់មិនស្គាល់, ព្រោះខ្ញុំម្ចាស់យល់ថា
ព្រះអង្គទ្រង់ដកដួងចិត្តចូលក្នុងរូបម្រឹគ ឬម្រឹគណាមួយ ។ យ៉ាសេនាបតី
ដកដួងចិត្តចូលក្នុងព្រះរូបរបស់ព្រះអង្គ, ខ្ញុំម្ចាស់ទំនឹងសូន្យរកតែចិត្តព្រះ

អង្គឱ្យឃើញ ដូចនាងសិរីសោភា កាលដែលប្តីរបស់នាងស្លាប់ នាង
ខំស្វែងរកតាល់តែឃើញ ។ សេកសោមបណ្ឌិតសួរថា ម្នាលព្រះ
នាងកល្យាណី កាលដែលនាងសិរីសោភា ស្វែងរកចិត្តស្វាមីរបស់ព្រះ
នាង តើស្វែងរកដូចម្តេច ? ។ ព្រះនាងកល្យាណី នាំនិទានមកថ្វាយ
មានសេចក្តីដូចតទៅនេះ ៖

ក្នុងកាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រាធិរាជមួយព្រះ
អង្គ ទ្រង់ព្រះនាមព្រះបាទសាមន្តរាជ ស្រោយរាជសម្បត្តិនៅនគរមួយ
មានឈ្មោះពុំប្រាកដ មានព្រះអគ្គមហេសីព្រះនាមសិរីសោភា ព្រះអង្គ
នៅវ័យក្មេង តុំតាន់ចាស់នៅឡើយ , ថ្ងៃមួយ ទ្រង់មានព្រះរោគមក
បៀតបៀនព្រះកាយ ក៏ស្រោយព្រះទិវង្គតទៅ ។ ព្រះនាងសិរីសោភា
អញ្ជើញព្រះសពព្រះស្វាមី ជាក់ក្នុងហិបមាសបិទយ៉ាងជិតល្អ ទ្រង់
ផ្តាំអស់សេនាមាត្យថា យើងទៅកប់តែព្រះស្វាមីយើងឱ្យបានវិញ អ្នក
ទាំងឡាយ កុំថ្វាយព្រះភ្លើងព្រះសពព្រះស្វាមីយើងឡើយ ផ្តាំស្រេចព្រះ
នាងចុះពីប្រាសាទសង្វាតសាកសួរ ពួកសមណព្រាហ្មណ៍ ទូវអ្នកប្រាជ្ញ
ពាលបណ្ឌិត អំពីមន្តនិងឱសថសម្រាប់ធ្វើជីវិតមនុស្សឱ្យរស់ ។ ពួកសមណ-
ព្រាហ្មណ៍ ទូវអ្នកប្រាជ្ញទាំងឡាយ តុំបានចេះឡើយ ។ ព្រះនាងត្រាច់
ទៅទៀតដកបដល់នគរមួយ ។ នៅនគរនោះ មានព្រះមហាក្សត្រមួយ
ព្រះអង្គ ស្តេចមានព្រះសុពណ៌ចាតុក៌តែវមួយ ។ រីព្រះសុពណ៌ចាតុក៌តែវ

នោះ តាលបើស្តេចមានព្រះពរជាហេតុដ៏ឃ ចង់ទៅនគរណា ។ ក្តី ខ្ញុំ
ប្រាប់ព្រះសុតណិជាទុក់នោះ ហោះតាមអាកាសវេហាស៍ ចានដល់ទៅ
នគរនោះមួយរំពេច អង្គ យោ តាលំ តត្ថ បើអ្នកណាមួយស្លាប់
ហើយក៏ដោយ ត្រូវពួកញាតិវង្សគាំងឡាយ អញ្ជើញព្រះសុតណិជាទុក
នោះយកទៅស្រង់ទឹក ហើយយកទឹកនោះទៅផ្ចុង-ប៉ងឹកបុគ្គលស្លាប់នោះ,
របុគ្គលស្លាប់ ក៏មានជីវិតរស់ត្រាកខ្លឹង ឥតមានភេតាអ្វីមកបៀតបៀន
ទៅខ្លួន ។ សា ច តំ ឯតំ បត្វា ព្រះនាងសិរីសោភា ខ្ញុំ
យាងទៅដល់នគរនោះ ចូលទៅក្នុងឧទ្យាន អាស្រ័យនៅទីដ៏ជួនចាស់
ម្នាក់ជាអ្នកត្រង់ផ្កាថ្វាយព្រះមហាសត្វត្រ ។ រីជួនចាស់នោះ សោត ឥតកូន
ទៅឡើយ លុះឃើញព្រះនាងសិរីសោភាហើយ មានចិត្តស្រឡាញ់ដូច
ព្រះនាងមកចិញ្ចឹមជាកូនធម្មិ ។ ឯព្រះនាងសិរីសោភា តែងចេះផ្គាយ
មកដោតត្រង់ជួនជួនចាស់ ។ ជួនចាស់ទាំងត្រង់មាលានោះ ទៅថ្វាយ
ព្រះមហាសត្វត្រាធិភ ។ ស្តេចទតព្រះនេត្រឃើញ កម្រងមាលាល្អ
ចម្រុងចម្រុងនឹងសព្វដង កំដល្អឹងសួរថា ម្ចៃជួនចាស់ ! ផ្កានេះ
នារណាត្រង់ ? ។ ជួនចាស់ក្រាបទូលថា កូនខ្ញុំម្ចាស់ឈ្មោះសិរីសោភា
ត្រង់ថ្វាយ ។ ទើបស្តេចត្រាស់សួរថា ក្មេ តោ លភសិ ជួន
ចានមកពីណា ? ពីដើមយើងតុំដែលឮថា មានកូន ។ ជួនចាស់
ក្រាបទូលថា នេវ បតិត្រព្រះសម្មតិទេព ! រីនាងនេះ ឥតបិតាមាតា

ជាអ្នកខ្ចាត់ខ្ចាយមកអំពីនគរដទៃ ខ្ញុំម្ចាស់មានសេចក្តីអាណិតណាស់ ក៏យកមកចិញ្ចឹមដាក់ទុកជាមិ ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ដូនចាស់ដូច្នោះហើយ ត្រាស់សួរថា នាងនោះជាស្រីដូចម្តេច ? ។ ដូនចាស់ក្រាបទូលថា នាងនោះមិនមែនជាស្រីខ្ចីទ្លាក់ កើតក្នុងត្រកូលពាណិជ្ជទេ ប្រាកដជាកើតក្នុងត្រកូលក្សត្រហោង, ព្រោះនាងនេះ មានរូបល្អប្រពៃ ។ តំ សុត្វា ព្រះមហាក្សត្រគិតថា ទ្រង់ព្រះសណ្តាប់ហើយ មានព្រះពុទ្ធហឫទ័យសោមនស្សយ៉ាងក្រៃលែង ទើបត្រាស់ប្រើយាយអក៍(១) តាំងឲ្យ ដែលស្គាល់លក្ខណៈស្ត្រី ឲ្យទៅពិនិត្យមើល ថាមើចក្នុងស្ថីនោះ តាស្រីចរំបូណ៌ដោយលក្ខណៈ ៦៤ ប្រការ ឬឲ្យខានទោះឡើងដំរេីយានមាសដ៏ឧត្តម ឲ្យសមនឹងសក្តានុភាពរបស់នាងហោង ។ យាយអក៍តាំងឲ្យ ក្រាបបង្គំលាទៅកាន់ទីឲ្យាន ឃើញព្រះនាងសិរីសោភាមានលំអគ្រប់លក្ខណៈតាំង ៦៤ ហើយអញ្ជើញព្រះនាងឡើងលើយានមាស ។ ព្រះនាងពុំមកឡើយ ។ ព្រះមហាក្សត្រទ្រង់ឲ្យទៅអញ្ជើញអស់វារៈ ពីរ បីដង ក៏ព្រះនាងមិនព្រមមក ។ ក្រុណោះ ព្រះមហាក្សត្រទ្រង់យាងទៅអញ្ជើញដោយព្រះអង្គឯង ទើបព្រះនាងឡើងគង់លើយានមាស ចូលទៅក្នុងប្រាសាទមាស ។ លុះចូលទៅ

(១) អក៍=អ្នកមិនធ្វើការអ្វី ។ សំដៅយកស្រីដែលមានអាយុច្រើន ហើយចេះនឹងព្រះរាជពិធីតាំងពីងងាងយាយ,ចាស់,ទុំ ព្រមទាំងជាអ្នកតាំក្សត្រីឬចៅចមក្នុងព្រះបរមរាជវាំងទៅមកដោយកិច្ចណាមួយម្តងៗប៉ុណ្ណោះ ។

ដល់ស្រុកសាខមាសហើយ, ព្រះខាន់ស៊ីរីសាតាមើលមើលសត្វត្រប់ភ្លៅ
ឃើញព្រះបុតណាំបាខុត់តែ រុំព្យួរនៅខាងលើ ទើបទូលសួរព្រះមហា-
ក្សត្រថា អ្នព្យួរនៅខាងលើ ? ។ ស្តេចត្រាស់ថា ព្រះសុតណាំបាខុត់
តែ ។ បពិត្រក្សត្រថ្លៃប្រសើរណាស់ ! ហេតុអ្វីក៏ព្រះអង្គឃាតព្រះសុតណាំ-
បាខុត់ទៅព្យួរនៅខាងលើវិញ ? ។ - កាលនោះ ម្ចាស់ខាន់ជំទាវនែ ! ព្រះសុ-
តណាំបាខុត់នេះ មានគុណប្រៀនណាស់ បើមនុស្សស្លាប់ហើយ យក
ព្រះសុតណាំបាខុត់នេះទៅដាក់ក្នុងឆ្អឹងមាស រួចយកភ្នែកទោះទៅស្រោច
មនុស្សស្លាប់ ទើបមានជីវិតរស់ឡើងវិញ, មួយសោត បើចង់ទៅលេង
ឯណាក្តី ត្រូវយកព្រះសុតណាំបាខុត់នោះមកប្រដាប់ អាចហោះទៅតាម
អាកាសដោយលឿន ហេតុនេះ ទើបយើងឲ្យព្យួរនៅខ្ពស់ ។ ព្រះខាន់
ស៊ីរីយ មានព្រះពុទ្ធហឫទ័យសោមនស្សជាងពីរកន្លែង ទ្រង់ព្រះចម្រើនថា
ម្ចាស់យកព្រះសុតណាំបាខុត់នេះរត់ទៅ ហើយព្រះទោសទូលដោយទុច្ចរិយភាព
ថា បពិត្រក្សត្រថ្លៃប្រសើរណាស់ ! ក្រែងតែថា "មង្គល", ឯខ្ញុំម្ចាស់ថា
"អតមង្គល" វិញ, ក្រោយយកភ្នែកទៅតម្កល់ទុកក្នុងឆ្អឹងខ្ពស់ ទើបម្ចាស់
យកមកដាក់ក្នុងទីតាមដែលសមគួរ ។ ស្តេចស្តាប់ហើយ ក៏យកព្រះ
សុតណាំបាខុត់មកដាក់ក្នុងទីតាម ។ លំដាប់នោះ ព្រះខាន់ស៊ីរីសេតា ក្រាប
ទូលទៀតថា បពិត្រក្សត្រថ្លៃប្រសើរណាស់ ! ព្រះអង្គនិមន្តយកខ្ញុំម្ចាស់មកពុំ
មានតែនឹងបណ្តាការក្នុងការចាត់ដាំដូនតាសោះនោះសោះ គឺព្រះអង្គនិមន្តខ្ញុំ
ម្ចាស់មកដោយតំណាង ដាក់អតមង្គល ចើព្រះអង្គព្រះកដាងបណ្តាការ

ដល់ដូនចាស់នោះហើយ ជាមង្គលសួស្តីល្អណាស់ ។ ស្តេចត្រាស់ថា ម្នាលនាង ! រីដូនចាស់នេះ, ជាទាសីរបស់យើងឬតើ ។ បពិត្រព្រះអង្គដ៏ចំរើន ! ដូនចាស់នោះ ជាទាសីរបស់ព្រះអង្គកំពុងមែនហើយ ប៉ុន្តែ គួរព្រះអង្គព្រះរាជទានបណ្ណាការផ្សេង ។ ទើបត្រូវតាមប្រពៃណីធម៌ពីបុរាណ ។ ស្តេចស្តាប់ហើយ ទ្រង់ត្រាស់ប្រើយាយអគ្គមហេសីឲ្យតាក់តែងគ្រឿងបណ្ណាការ ព្រះរាជទានដល់ដូនចាស់នោះ ។ លុះពេលរសៀលល្ងាច ព្រះនាងយល់អាការរបស់ព្រះរាជា ចង់ប្រមាថមកលើរូបព្រះនាង.។ យកព្រះសុពណ៌ិជាខ្ទុក់មកទ្រង់ ហោះឡើងលើអាកាសវៀតាន់ព្រះនគរវិញ ហើយចូលទៅក្នុងប្រាង្គប្រាសាទ យកទឹកជាក់ក្នុងដំឡូងមាសមួយយ៉ាងធំ មកស្រង់ព្រះសុពណ៌ិជាខ្ទុក់ រួចលើកសពព្រះរាជ-ស្វាមីព្រះនាង មកជាក់ក្នុងដំឡូងមាសនោះ ។ រីព្រះកាយព្រះស្វាមីរបស់ព្រះនាង ក៏មានសម្បុរល្អបរិសុទ្ធដូចមាសជម្ពូនទ ; មានជីវិតរស់ឡើងវិញហោង ។

ព្រះនាងកល្យាណី លុះនាំអតីតនិទានមកទូលព្រះស្វាមីដូច្នេះរួចហើយ ក៏ទូលថា « បពិត្រសេកសោមជម្ពិត ! រីព្រះនាងសិរីសោភា មានចិត្តសុចរិតពិតត្រង់នឹងព្រះស្វាមី មានសេចក្តីឫទ្ធិយ៉ាងធំរកជីវិតឲ្យព្រះស្វាមីបានដូចម្តេចមិញ, រីឯខ្ញុំម្ចាស់ក៏នឹងធ្វើសេចក្តីឫទ្ធិយ៉ាងដូចព្រះនាងនោះហោង , ថ្ងៃនេះ . ខ្ញុំម្ចាស់បានជួបនឹងជីវិតព្រះស្វាមីរួបហើយ នឹង

អញ្ជើញព្រះអង្គចូលក្នុងព្រះបូបព្រះអង្គវិញឲ្យបាន" , ព្រះនាងទូលដូច្នោះ
ហើយ ក៏ទ្រង់គ្រឿងប្រដាប់ល្អប្រពៃ យាងចូលទៅគាល់សេនាបតី ។
រីសេនាបតី លុះឃើញព្រះនាងចូលមកគាល់ហើយ មានចិត្តត្រេកអរ
ឥតឧបមា គិតថា ថ្ងៃនេះព្រះនាងកល្យាណីមកគាល់អញហើយតើ ។
ទើបព្រះនាងក្រាបទូលថា បពិត្រព្រះពជកុមារ ! ខ្ញុំម្ចាស់ប្រាថ្នាចង់ឃើញ
ឫទ្ធិវេស្ការបស់ព្រះអង្គ, សូមព្រះអង្គសំដែងឲ្យខ្ញុំម្ចាស់ បានឃើញផង
ហោង ។ សេនាបតីទទួលពាក្យរបស់ព្រះនាងហើយ ក៏ប្រើពួកអាមាត្យ
ឲ្យទៅកេសតូស្វាប់ ។ អាមាត្យទាំងឡាយស្តុះយ៉ាងប្រញាប់ រកបានតែពៃ
មួយទើបនឹងស្វាប់ថ្មី ។ នាំមកថ្វាយ ។ សេនាបតីកាយមន្តដកចិត្តចូល
ក្នុងរូបពៃ។ ក៏ក្រោកឡើងស្តុះហោះទៅ ។ ឯសេកសោមបណ្ឌិតកាយ
មន្តដកចិត្តចូលក្នុងព្រះបូបព្រះអង្គវិញ ត្រាស់ប្រើឲ្យអាមាត្យទាញពៃនោះ
សម្លាប់ ។ ពួកអាមាត្យទទួលព្រះពជនុដ្ឋារហើយ នាំគ្នាបញ្ចាំពៃនោះ
សម្លាប់កាលនោះហោង ។ ចាប់តាំងពីថ្ងៃនោះមក ព្រះបាទវៃច្ចកុមារ
និងព្រះនាងកល្យាណី សោយរាជ្យជាបរមសុខតាមទស្សពិធរាជធម៌ តែង
ទូន្មានប្រៀនប្រដៅអ្នករាជនគរផង តាមព្រះពជបវរណីអំពីបុរាណរៀងមក។

រីនាងបណ្ឌិតទារី លុះនាំមកនូវទេពាវរណ៍ដូច្នេះរួចហើយ ក្រាបទូល
ថា បពិត្រព្រះអង្គដ៏ទ្រង់ខ្ជាប់ខ្ជួនព្រះគុណជួន ! យោ ច ភជា រីព្រះ
មហាកស្សត្រណាមួយ បានក្សេបវរណីធម៌ ហើយសូមរក្សាឲ្យមានចិត្ត

ខៀងត្រង់ មានប្រាជ្ញាដូចនាងកណ្ឌាណ៍ ទំនងសិរីសោភា គួរដំកល់ជាមហេសីបាន, មួយទៀត បើបានឧត្តមភរិយាដូចនាងលើនេះ ជាមហេសីហើយ គួរព្រះមង្គលបុរសមានប្រាជ្ញាខៀងត្រង់ដំកល់ជាអាមាត្យ កុំអាលដំកល់បុគ្គលដូចយ៉ាងសេនាបតីនោះទៀតឡើយ; នាងបានទាំនៀងតទល់ថ្វាយតាំងពីបឋមយាម ជាបឋមល់មជ្ឈិមយាមកន្លងទៅ ។ ទើបព្រះបាទកន្ធកជាស្តាស់ស្តាប់ថា ព្រះចាខវិច្ឆមារជាតកជ ស្តេចដំកល់បុរសខៀងត្រង់កតញ្ញូ ជាអ្នកដំនឹគុណអម្ចាស់ខ្លួន ឲ្យជាសេនាបតី នោះតើដូចម្តេច ? ។ នាងបណ្ឌិតនារី ក៏ទាំនៀងមកថ្វាយទៀតថា ៖

បុត្តេបិ មហារាជ ជនិត្តមហារាជ ! ក្នុងកាលមុនឡើយ ព្រះចាខវិច្ឆមារជានោះ សោយរាជសម្បត្តិនៅនគរពារាណសី ស្តេចតើតក្នុងត្រកូលមហាសម្មតវង្ស ចាប់តាំងពីស្តេចប្រសូតចេញចាកព្រះគភ៌នៃព្រះវរាជមាតាមក ឯកន្ធសុខ ជិតោ ស្តេចមានតែសេចក្តីសុខ ពុំដែលស្គាល់សេចក្តីទុក្ខឡើយ, ហេតុនោះ ទើបព្រះមហាសត្វត្រែងតោលរឿយ ។ ដូច្នេះថា: តតិ ទុក្ខំ តតោ វេទនា តតោ បរិទ្ធា មោ រីសេចក្តីទុក្ខដូចម្តេច ? វេទនាដូចម្តេច ? សេចក្តីស្តាប់ក្រហាយដូចម្តេច ? យើងពុំដែលដឹង-ស្គាល់ឡើយ" ។ ត្រានោះ មានអាមាត្យម្នាក់តតបថា អញនឹងធ្វើឲ្យព្រះមហាសត្វ ស្គាល់សេចក្តីទុក្ខវេទនាក្រហល់ក្រហាយព្រះកាយម្តង តតស្រេចតំហៅនាយព្រានម្នាក់មកបង្គាប់ឲ្យចាប់

ម្រឹតត្រៃមួយ យកគ្រឿងសេះចងប្រដាប់ម្រឹតនោះ ហើយចូលទៅគាល់ព្រះពង្សាឲ្យថា បពិត្រព្រះសម្មតិទេព! បើស្តេចចង់ស្គាល់សេចក្តីទុក្ខវេទនាក្រហល់ក្រហាយបំផុតព្រះគាយ សូមស្តេចឡើងគង់លើម្រឹតនេះហោង ។ សេះម្តេចត្រមហាក្សត្រគង់ពាស ត្រង់ឡើងគង់លើខ្នងម្រឹតព្រះហស្តាម់ខ្សែបន្ទូរខ្លាប់ ។ ឯម្រឹតនោះ ស្ទុះលាតផ្លោះតាមគម្ពាំង, ព្រះពង្សាទាំងបីព្រះអង្គត្រូវតាមប៉ុន្មានទាន្តី តំបន់ព្រៃពុំដេរដាលគ្រាយឡើយ រំងឹតតែស្ទុះផ្លោះលោតទៅមុខពាំនយប់ភាំងថ្ងៃ ទាំងព្រះមហាក្សត្រជាបដល់មួយ ទើបម្រឹតនោះអស់កម្លាំងទន់ភាំងខ្លួន ទើបលោតទៅទៀតពុំបាន ឈរនៅស្ងៀម ។ ព្រះមហាក្សត្រ ទ្រង់ខ្ញីរលំបាកព្រះគាយពាស ដោយត្រូវខ្សែទឹងតំរង់ថ្ងៃ អត់ភាំងព្រះក្រយោះស្ងួយ សោយទុក្ខវេទនាដ៏ខ្លាំងក្លាលើខ្នងម្រឹតនោះ លុះជ្រាបថា ម្រឹតត្រៃលែងលោតទៅទៀតហើយ ទ្រង់ចុះពីខ្នងម្រឹតចូលទៅគាស្រ័យនឹងស្រុកមួយ ។

នៅស្រុកនោះ មានស្រីក្លាមាសម្នាក់ ប្រកបដោយរូបឆោមលោមពីណាដ៏ប្រពៃ គួបុរសជនពីនឹងតួរមួរសេដោយគាមគុណ, តែថា នាងនោះយកឈ្នួលជាទ្រព្យ ។ ពាន់ដំឡឹង លុះឃើញព្រះមហាក្សត្រគង់ខ្ចីទេយ៉ាងមកដល់ នាងគិតថា បុរសនេះ មិនមែនជាអ្នកតំណតទូតិតឡើយ ទើបនាងថ្វាយខាទនីយភោជនីយាហារ ។ ព្រះពង្សា ជានរួមសំពាធនឹង

នាងនោះដោយព្រះពរជាហេតុដែលកាលយាងមកក្រៃលែង លុះត្រឹកឡើងស្តេចប្រុងនឹងលាយាត្រាទៅទៀត ។ នាងនោះ គិតថា ប្រសិនមកអញមិនសុំតាមគុណនឹងយើង ត្រូវឲ្យទ្រព្យ ១ ពាន់ដំឡឹងមកយើង ទើបយើងឲ្យប្រសិនទៅ ។ ម្ខាងទៀត កាលអាមាត្យរៀបចំដំណើរព្រះមហាក្សត្រនោះ បានវេចមាស ១ ពាន់ដំឡឹងមកផង ។ ព្រះមហាក្សត្របានឲ្យថ្ងៃឈប់ដាក់មាស ហើយនៅរួមរស់ក្សេនីនាងនោះ ពាល់តែអស់ទ្រព្យនោះហោង, តមក ពុំមានទ្រព្យឲ្យឡើយ ។ រីស្រីផ្កាមាសកំយកព្រះមហាក្សត្រជាខ្ចុំបំរើ គឺឲ្យធ្វើកិច្ចការទាំងឡាយ មានដងទឹកចំសស្រូវជាដើម ។ តតោ បដ្ឋាយ ចាប់ដើមតាំងពីថ្ងៃនោះមក, ព្រះពុទ្ធាគ្មាលខ្លួរសេចក្តីទុក្ខវេទនា ន ក្កេន ភុញ្ជតិ សោយក៏ជាទុក្ខ, ន ក្កេន និសីទតិ ប្រថាប់ក៏ជាទុក្ខ ន ក្កេន សយតិ ផ្ទំក៏ជាទុក្ខ; ព្រះអង្គទ្រង់ព្រួយព្រះពរជាហេតុណាស់ លាន់ព្រះឧទានថា ឧ ! អត្ថាអញ ស្គាល់សេចក្តីទុក្ខហើយតើ ! ។

ទើសស្រដីអំពីអាមាត្យ ដែលឲ្យដំណើរព្រះមហាក្សត្រវិញ, កាលបើព្រះពរជាទៅបានប៉ុន្មានថ្ងៃហើយ ទើបគិតថា យន្នូនាហំ ពលាធិ អនុពន្ធិស្សាមិ គួរអាត្មាអញ ទៅតាមព្រះមហាក្សត្រឲ្យត្រឡប់វិញហោង, ឥទានិ កុហិំ គច្ឆតិ ឥឡូវ ស្តេចយោងទៅឯណា ?

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

រឿងសព្វសិទ្ធិ

(តជប់)

របស់ឪ្ញុកភាត្តីអក្សរតន់ លោក ប៊ូ - ប៊ួ ចំរួងពីសាស្ត្រាស្ងឹករឹត

តែថាជាការណ៍ត្រាស់បង្គាប់ ត្រូវធ្វើតាមច្បាប់កុំប្រណី ត្រូវបន្តអយ្យកា-
ស្ថានទីបី ត្រូវកាត់សិរសីពុះទាវ តិតស្រេចបង្គាប់ពួកតេជឃាត ថាឯងធ្វូ
ឃ្លាតតិតតាមការ ចាប់សត្វតពែធ្វើគោសា តាមព្រះអាជ្ញាជាប្រញាប់ ។
តេជឃាតឮហើយស្រែកហៅគ្នា ព័ទ្ធចោមចាប់ជាន់ស្រែកស្រាប់ តពែ
បំរះដួលផ្ងារផ្កាប់ តិតថាអញស្លាប់ត្រានេះម្តង ។ ហើយប្រឹងសម្លឹងមើល
សត្វស្ងាន ក្រែងមានសត្វស្ងាបនឹងតិតប៉ង ដកចិត្តៈខ្លាចូលរួបទៀតផង
តាមដោយបំណងឱ្យកន់រួស ។ រកមើលពុំមានសត្វក្តីណាក្បែរ ទើង
តែសង្ឃឹមភ័យញ័រគោះ រំពឹងតិតថាទុកម្នាក្រោះ ព័ត្រោះខ្លួនឯងវង្វើង
ខ្លាំង ។ ប្រែចិត្តពុំជិនពន់ប្រមាណ ហៅហ៊ានចូលរួបតេហើយតាំង
លើកខ្លួនជាតាងអាងបំប៉ាំង ប្រណាំងវ៉ាសនាឱ្យតេក្បែរ ។ ពេលនេះ
ធលកម្មប្រចាំកេរ ទិដ្ឋធម្មវេរបណ្តាយដៃ ផ្តល់ផ្តាច់កាច់កំនមិនសំចៃ
ម៉ុំរទឹងប្រល័យជន្មដីវ ។ អស់ពួកតេជឃាតឃ្លាតចាប់ចង ខ្លាប់ខ្លួន

ដាំមួងគ្មានមេត្តា លុះដល់ទៅទ័ព្វទោសា ឥតគ្រាប្រហារគាត់ស៊ីរសី ។
ហើយតុះដើមទ្រូនរូនយកថ្ម ម្ខខគួរឲ្យស្បែរខ្លាចពេកក្រៃ តែលឿន
ខុនិនកំសត្បិណាស្ងួយ ធ្លាក់ទៅនឹងតំយនរកស្រី ។ ដោយកម្មគតកាត់
អតតភា ញ្ចូ រនឹទុក្ខជាយូរលន់និត្យនោ ស៊ីតែឈោមខ្លុះខោះរឿងទៅ
ព្រោះចំណូយរយរយៅក្រៅជម្ងា ។ ឯជនកំឡឹងក្នុងក្រុងក្រៃ សុទ្ធសឹងន
សង្ឃ័យតែពាល់គ្នា ពុំដឹងដើមដល់កំលោភជា ទ្រង់ព្រះក្រោធាតំហេតុម្តៃ ។
នានីនាថសុវណ្ណាគេសរថ្លៃ យល់ព្រះភូវនេយ្យចមក្រើ ចូលរួបអគ្គីច្រាណ
ជាន់ទាញ្ចី ក្សត្រីត្រូតអរឥតទប់មា ។ ព្រះលៀសពួសិង្គីខ្លីហាន នឹង
នាងតលាណទ្រនឹរជាំ ខ្លួវព្រះបមាប្រុតគ្គិចភា ស្មេរមក្សាខ្លួសុខាតាំង
ព័ទ្រាណ ។ សុកន្ធីនាងសំក្រមកំណាន់ ប៉ែតម៉ឺនសែនពាន់ពេញព្រះ
ស្ថាន គាស់ហ្លាំរើមហាស្សក្រែក្សាខ្លួ ពុំដែលឧតខានមួយម៉ា ។
នាម៉ឺនចតុង្គគង្គិនិកាយ ស្មេរមក្សាខ្លួសប្បាយនឹពេគ តាំងស្រុកតូបធំ
ខំគមា កុងព្រះភាពអាណាចក្រ ។ បង្កើតរក្ខាខ្លួនរជារជាកដាំ តាម
ដូវខ្លាំពុំដែលអាក់ សារពើដំណាំដាំរជាកជាក់ ជាខលអន័ន្តរនេក
ក្រៃ ។ ពុំមានឃ្លានអត់កំសត់ក្រ តាំងស្រុវអគ្គីតែជួរថ្លៃ ចោរក្នុយតែស្ងប់
តាំងយប់ថ្ងៃ អាស្រ័យរកស៊ីតាមសំម្ភា ។ ឯអគ្គីពួជតាំរួច្រះទ្រង់ទ្រី
ប្រែតបន្ទុះតិធំដាច់ប្រកាន់ ស្តេចតាំងយមួយនាំសួយសារ មកថ្វាយ

ព្រះមហាក្សត្រថ្កើងថ្កល់ ។ ថ្ងៃនិតព្រះចំាទព្រហ្មទត្ត ។ សោយរាជសម្បត្តិ
សុខសែនសល់ ប្រជួនប្រជុំបព្រះឥន្ទដល់ ទេសពលទ្រង់ព្រះដកពាជ ប៉
ប្រឈួនព្រះពេគរឹតតែខ្លាំង ជាហេតុអន់ចិត្តពុំយូរឡើងឃ្លាត រំលងជីវិត
ជន្មទ្វន្ទធាតុ ប្រែជាតិ:ទៅកើតត្រៃត្រឹង្សា ។ គ្រានោះកុសុមាជាមហេសី
ទូរាជបុត្រស្រីបវរ៉ា មន្ត្រីសេនីយទូរសេនា សឹងសោយសោកាសព្វអីន
កន ។ ដោយក្តីសង្ស័យក្រៃពេកពិត រលឹកនឹកគិតក្សត្រច្បាស់ឲ្យឆ
ហើយក្រោមច្រាប់អស់ពស្ត្រាសជន៍ កាន់ទុក្ខពាល់ធូនបុណ្យព្រះសព។
ព្រះតង្ឋរោធីទីទេវពន ទ្រើសទ្រង់ដំណាចលើសដែនតព ចេញត្រួត
បគ្គាប់ប្រាប់ប្រាឲ្យ ត្រាស់សព្វពួកក្រុមខាងមេការ ។ ឲ្យសង់ព្រះមេរុ
មាសមណ្ឌប ទីតាំងត្រាំសពធ្វើបញ្ចា ក្សត្រាប់រំលេចរចនា មានកូនឯ
បុប្ផាចនកាយរៀង ។ កេងជួរជុំវិញគេញប្រគំត ជាំងចិទ្ធាប់ឡៃក្បែរ
រៀង រេបប្រុងប្រៀបរៀបឥតល្អៀង យប់អុជចង្កៀងភ្លឺត្រាយ ។
ហើយចាត់ឲ្យមានលែ្បងមហាស្រេត លេងតាំងថ្ងៃយប់ដោយឡែកលាយ
ត្រើងហែសឹងរូបសត្វសម្ងាយ ប្រើសត្រាយសង្ឃគោគមហិង្សា ។ លុះ
រៀបរួចគ្រប់នាំសពចេញ មន្ត្រីភាសពេញហែត្រៀបត្រា សុទ្ធសឹងតែឥ
តាមយសសក្តា តឹកតឹងគោលដោយជាមី ។ ហែដល់លើកជាក់លើ
មណ្ឌប ដម្កើងព្រះសពក្សត្រជិបតី ទិមន្តព្រះសង្ឃតាំងបួរី ថ្វាយទានប្រ-
ក្រតីពលវេលា ។ បន្សុំគូលទេសនាតាំងថ្ងៃយប់ លុះជួបត់រប់សត្តមិវ៉ា ទ្រង់

ឲ្យប្រដុំក្រមមុខដារ រួសរៀបបូជាព្រះសពស្រេច ។ លើសព្រះអដ្ឋិដាក់កោដ្ឋ
មាស រួចវិលាសមាសល្អដាច់ សឹងវែកចម្ងាក់ខ្នាក់ក្សរក្សាច់ ហើយស្រេច
ឲ្យសាធព្រះចេតិយ ។ រួចទើបដង្ហែព្រះធាតុទៅ បញ្ចុះទីតៃទៅចេតិយថ្ម
ស្រេចការពុំលង់អង្គចក្រី នាំអគ្គមហេសីស្រីស្រឡាង ។ ចូលកាន់មន្ទីរ
ខែនមណ្ឌល តុំមានអំពល់ទុក្ខភ័យា ទើបតស់ចតុរង្គអង្គីយោធា ដំនុំ
ព្រមគ្នាតាំងផែនដី ។ អញ្ជើញពិធីឲ្យអង្គមហាក្សត្រ ឲ្យគ្រងសម្បត្តិក្នុងឆ
ប្ជរ៍ ទ្រង់លើកព្រះនាងនាថក្សត្រី ជាអគ្គមហេសីសិរីស្ស ។ ព្រះអង្គ
ស្តេចបានស្ថានពិភព ជាមេលើសលប់ចប់ត្រៃច័ក្រ ព្រះកិត្តិយសខ្ចស់
អន័ត្ស អតិរេកឯកអគ្គឧត្តមំ ។ ប្រកបព្រះទ័យអភ័យទោស សន្តោស
អំណត់អត់សង្កំ សច្ចាដោយចិត្តទ្រង់គំតតាំង · ប្រោសសត្វសង្កើយ្យ
ដៃលទាំងខាន ។ ទ្រង់សីលសទ្ធាគុណខ្ជាប់ ជាយព្រះពជទ្រង់ឥត
ប្រមាណ បំពេញកុសលផលបុណ្យបាន បរិបូណ៌ក្សេមក្សាខ្ពក្នុងភាព ។
គ្រប់ទីប្រទេសទិវេសន៍ស្ថាន ពុំហ៊ានប្រឡងព្រះពជា ចរចូលមូលមកថ្វាយ
វន្ទា តឹងព្រះសម្ភារពោធិវង្ស ។ ព្រះអង្គគ្រប់គ្រងពជសម្បត្តិ សម្បូណ៌
ពេកក្តាត់ជាយូរលង់ នៃបខំងមហេសីស្រីរោមយង់ ទ្រើសទ្រង់ព្រះជន្ម
ប្រជួបបាន ។ មួយរយមៃព្រះវស្សា ទើបមហាក្សត្រាថ្កូវថ្កើងថ្កាន
ទ្រង់ព្រះអាយាធរៀតអង្គប្រាណ ក្សត្រក្សាន្តសោយព្រះវិលាល័យ ។ ៧

កើតក្នុងហានតុសិតា មានមហាប្រាសាទខ្ពស់ត្រៃឈ ប្រាំដណ្តប់យោជន៍
យល់ប្រពៃ និកើយនិខុក្ខសែនសុខា ។ ចុះចាកឋុតស្រុតចុះមក យោន
យកកំណើតជាមនុស្សា ជួនចក្រពត្តិរាជ្យក្សត្រា ជួនជាសេនាបតីផង ។
រីលកើតវិលស្ងាប់ពាប់ឃួរក្រៃ ច្រើនអសង្ខ្យឃ្យរពេកកន្ទង់ តាមដោយផល
កម្មដែលចាំបង់ បំណាន់នៃវដ្តសង្សា ។ កំណើតអនិច្ចតាំងពុំខ្វៀ ជួន
ល្អៀងមិនល្អដោយយថា - កម្មកើតអំពីឥតណ្ហា ជួនណាកើតជាមនុស្ស
ក្រៃក្រ ។ ជួនកាលកើតជាសត្វម្រឹគា ជួនណាកើតជាសត្វបក្សី ជា
ព្រហ្មខេវតាទាតកពក្រៃ តែពង្សជិនស្រីប្រលំយខ្លាប់ ។ ប្រឹនទំសន្សំ
សាងសិលាទាន តុំដែលឱ្យលតាមដោយទំហាប់ យោនយកកំណើតកើត
គួរតាប់ មិនត្រូវអត់ឮប្រាំបីស្ថាន ។ ព្រះអង្គបំពេញទសបារមី បរិបូណ៌
ឥតមីខ្វះខាតខាន បតុកសង្ឃឹយកំរៃបាន សែនកប្បអាសាខំផុតជាតិ ។
ស្តេចលះសម្បត្តិតុសិតា មកចាប់ជាតិជាព្រះសិទ្ធាថ៌ ចេញទ្រង់បព្វជិតពុំ
គិតញាតិ ទំហ្មាតសង្វាតសាងចរិយា ។ បានត្រាស់ចំហុតជាពុទ្ធអង្គ
ហើយទ្រង់សំដែងធម៌ទេសនា ប្រោសសត្វច្រើនលន់អនន្តា ជាក់ដល់
ថ្នល់មហានិព្វានពិត ។ ទើបព្រះសាស្តាចរិយវង្ស ស្តេចទ្រង់និទានរឿង
សត្វសិទ្ធិ ដោយបទគាថាជាអតីត សេក្ខណាជាតិដែតវិត្ថារ ។ លុះដួល

គំរប់ចប់ត្រប់ត្រាន់ តាមជាន់ជាតកដោយប្រការ ទ្រង់រៀសប្រមូលរួមជាតា
ន៉ាមកនេសនាជាបរិយាយ ។ តទ្បើអើយ! តិលៀងចោរទ្រុះក្បត់ កើតជា
ទេវតាគាត់អន្តរាយ ព្រះឆណើស្រូបតាំងរូបកាយ ឆ្លុះឆ្ងាយឆ្ងាត់ដល់មហា
អវិចី ។ ព្រះបាទព្រហ្មទត្តមហាក្សត្រា ចេរវិលវិនិជាតហេតុ អនាថ-
បិណ្ឌិកមហាសេដ្ឋី ទបង្អាកដំនស្រីសម្ពុទ្ធ ។ កុសុមានាងនាថពុំឃ្លាត
ឃ្លៀង ជាក់ជឿនដួចដួនចាប់ជាតិជា នាមនាងពលីកាសមសោភា កប
ដោយអតិញ្ញាសម្ភាថត្តិ ។ គោណ្ឌញ្ញសេដ្ឋីជាបិតា នៃព្រះកុមារចេរវិល
ឫទ្ធិ ជាព្រះសុទ្ធោទនមហាក្សត្រ បានលុះអរហត្តគាត់សង្ខារ ។ ទេម
តរីយានៃគោណ្ឌញ្ញ ចេរវិលវិនិរិញ្ចោយយថា- កម្មបានមកជាពុទ្ធមាតា
នាមនាងមហាមាយាថ្លៃ ។ សុរណ្ណគេសរបរមិត្រ យោនយកជាតិជាត
ជាកន្សែ សាពើជ្រលើសលុបតាំងតពីត្រៃ នាមនៃព្រះនាងនាថពិម្ពា ។
ព្រះមហាសត្វសិទ្ធត្ថិទ្ធិឆ្លើ តីអង្គអញ្ជាត្រាស់ប្បាសនម្ម ប្រាសសត្វសុស
សត្វភូមិតពការ ជាក់ដល់ថ្នល់នាមហានិព្វាន ។

សាធុនរៈជាតិតាំងឡាយ ចូរស្តាប់បរិយាយរឿងនិទាន សកុណា
ជាតកពុកខូន្ថាន ត្រប់ប្រាណសម្បុរសតាំងប្រុសស្រី ។ ត្រាន់ម៉ើល
ត្រាន់ស្តាប់ត្រាប់ត្រងរង៉ែ ខំនងខំនើបខើបតែងថ្ម វ៉ែក្រងដួនពុំចំសមសេចក្តី

សំចៃអត់ទោសទ្រង្គាសមេត្តា ។ ត្បិតខ្ញុំល្មើកភាក្យពិចក្ខណាស់ ខុសខ្វះ
ត្រូវខ្វះតាមតែថា បន្ទែបន្ទាយល្បាយពៅហារ តែងតាមប្រជ្ញាអធ្យាស្រ័យ ។
ហើយច្រើនតែភាក្យស្ទើងឃ្ងើងឃ្ងាត សម្ផប្បលាប៉ាងប៉ាងចាក្រៃ ក្រែងជ្ជនជាប់ទោសជាបច្ច័យ ខិសរ័យកំសាអនាគត ។ សូមទានស្មាលវៃ-
ភកម្ម កុំឲ្យចងចាំឲ្យរួចផុត មគ្គផលឯណាជាសុខសុទ្ធ សូមបានចំហុតដល់
អញ្ញខ្ញុំ ។ បើអ្នកណាស្តាប់ចាប់ចូលចិត្ត តាមរឿងសព្វសិទ្ធិជាសុខុម
បើឃើញខាតខុសលោះដោយដុំ សូមសុំជួយថែមតែមកាថា ។ បើតែមានតែឲ្យជាឆន្ទនេះ ប្រសិនមិនចេះកុំចង់ថា រឿងនេះចែងចប់សព្វប្រការ
ឥតខ្វះខាតនិដ្ឋិតំ ។

រឿងសព្វសិទ្ធិ ចប់ប៉ុណ្ណោះ ។

រឿងប្រជៀមឆុស្សដោយវិយមួយរយរំពាត់

លោក ស៊ុខ-ហ៊ាន រៀបរៀង

កាលពីព្រេងនាយ មានព្រះពុទ្ធ ១ ព្រះអង្គ ។ សោយភក្ត្រក្នុងខេត្តមួយ ។ ព្រះពុទ្ធអង្គនោះ ទ្រង់សោយព្រះស្ងោចតែមួយបែប គឺព្រះស្ងោយ ដែលនាយពាសេសគេធ្វើតាមត្រប៉ុណ្ណោះ ។

ខណៈនោះ មហាមេឃមិនបង្អុរភ្លៀងអស់កាលដ៏ឃ្លាតអែង, ស្ងួតខន្ធមិនបួតាំងឡាយ ក្នុងព្រះពុទ្ធអាណាចក្រ គំនាគតាំងរើងស្លុតអស់ជាច្រើនកន្លែង ។ នាយពាសេសលំបាកនឹងរកត្រីបានមកធ្វើព្រះស្ងោយពន់ពេក ។ ព្រះពុទ្ធទ្រង់ព្រះពុទ្ធបញ្ជាឲ្យផ្សាយព្រះពុទ្ធសាវ ទៅគ្រប់ទីតំបន់ក្នុងព្រះពុទ្ធអាណាចក្រថា " បើអ្នកណារកត្រីមកថ្វាយយើងបាន យើងនឹងឲ្យរង្វាន់ជាទីគាប់ចិត្តដល់អ្នកនោះពុំខាន" ។

លុះដាច់នោះ មានកសិករម្នាក់បានឃើញព្រះពុទ្ធសាវផ្សាយទៅគ្រប់ទីតំបន់ដូច្នោះ មានចិត្តស្វាមីភក្តិចំពោះព្រះពុទ្ធជាខ្លាំង បានខំដើរកត្រីក្នុងទីផ្សេង។ ពាល់តែបាន, លុះបានហើយ ក៏យកត្រីនោះទៅថ្វាយព្រះពុទ្ធដោយខ្លួនឯង ; ទៅដល់ព្រះពុទ្ធកំផែ , គាហាទឆ្មាំទ្វារក៏ហាមឃាត់មិនឲ្យចូលសោះ, កសិកររនោះ ក៏អង្វរករដោយពាក្យទន់ផ្អែមល្អែមផ្សេង។ ថា "សុំលោកមេត្តាជល់ខ្ញុំ ឲ្យខ្ញុំចូលទៅក្នុងព្រះពុទ្ធកំផែ នាំត្រីនេះ

ទៅថ្វាយព្រះពរដោយខ្លួនឯង" ។ គាហាទន្ធំគ្នាគោលថា មិនបាច់អ្នក
ចូលទៅខ្លួនឯងទេ សុំឲ្យគ្រឿងនេះមកខ្ញុំ។ យកទៅថ្វាយព្រះពរឲ្យ មិន
បាត់ទៅណាទេ អ្នកកុំព្រួយបារម្ភអី ! ។ តាបសក៏ពុំព្រមប្រគល់គ្រឿងនោះ
ឲ្យទៅគាហាទន្ធំគ្នានោះ ចេះតែទទូចអង្វរករ ដោយសំដីដ៏ផ្អែមល្ហែម
ផ្សេង ។ ទីបំផុតគាល់តែគាហាទន្ធំគ្នាគោលថា "បើអ្នកត្រូវការចូល ទៅ
ក្នុងព្រះពុទ្ធកំណ យកគ្រឿងទៅថ្វាយ ព្រះពរដោយខ្លួនឯង មិនអីទេ យើង
ទឹងអនុញ្ញាតឲ្យអ្នកចូលទៅបាន តែបើព្រះពរទ្រង់សព្វព្រះទ័យ
ប្រទានរង្វាន់អ្វីដល់ចិត្តដល់អ្នក ត្រូវអ្នកបែងចែករង្វាន់នោះឲ្យយើង
ពាក់កណ្តាល" ។ តាបសបានឮដូច្នោះ ទើបតបថា "មិនអីទេ តាលបើខ្ញុំ
ចូលទៅក្នុងកំណហើយ បានរង្វាន់អ្វីគឺព្រះពរ សឹមខ្ញុំបែងចែករង្វាន់
នោះឲ្យអ្នកពាក់កណ្តាលតុំពានទេ" ។ គាហាទន្ធំគ្នាបានស្តាប់ដូច្នោះ
ហើយ ក៏មានសេចក្តីត្រេកអរជាពន្លឹក ទើបអនុញ្ញាតឲ្យតាបសនោះចូល
ទៅ, អំពើរបៀបនេះ បង្ហាញឲ្យឃើញថា គាហាទន្ធំគ្នាជាអ្នកមិន
សុចរិតឃុត្តិធម៌ ស្មោះត្រង់ចំពោះមុខងារបស់ខ្លួន ដាបតិត ។

តាបសនោះ លុះដើរចូលទៅបាន២-៣ជំហានក៏ត្រឡប់មកសួរគាហាន
ន្ធំគ្នាវិញថា លោកនាយ! លោកឈ្មោះអ្វី? គាហាទន្ធំគ្នានោះក្រាប់
ថា ខ្ញុំឈ្មោះអាយ័ក្សគ្រាត់ក្អែកមាន" ។ តាបសគោលថា "បានជាខ្ញុំសួរ
នាំឈ្មោះលោកនាយឲ្យដាក់ណាត់ដូច្នេះ ត្រែងលោលោកនាយផ្ទាល់ទៅ

យោម កាលបើខ្ញុំចេញពីក្នុងវាំងមកវិញ បានឮគ្នាន់អ្នកអំពីព្រះរាជា ហើយ
បែងចែកឮគ្នាន់នោះឲ្យទៅខុសឈ្មោះលោកនាយ ដូចដែលបានសន្យា
គ្នា" ។ លុះកសិករនោះចូលទៅដល់ ក៏ថ្វាយបង្គំព្រះរាជា ហើយថ្វាយ
ត្រីនោះ ។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យចំពោះកសិកររនោះ ដែលមាន
ចិត្តស្មោះត្រង់ចំពោះព្រះអង្គយ៉ាងនេះ ហើយទ្រង់មានព្រះរាជឧទ្ទាន
ថា «អើកសិករ! បើអ្នកត្រូវការចង់បានរបស់អ្វីពីយើង ក៏ចូរប្រាប់មកចុះ
បើយើងអាចឲ្យបាន យើងនឹងឲ្យ"។ កសិករក្រាបបង្គំទូលថា "ព្រះករុណា
ថ្លៃវិសេស បើព្រះអង្គទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានឮគ្នាន់ហើយ សូម
ទ្រង់ព្រះមេត្តាប្រោស ឲ្យយកទូលព្រះបង្គំជាខ្ញុំឲ្យបាល់តែគ្រប់១០០រំពាត់
ជាឮគ្នាន់ចុះ, ទូលព្រះបង្គំជាខ្ញុំ ពុំប្រាថ្នារបស់អ្វីដែលព្រះអង្គមិនអាចព្រះ
រាជទានបាននោះទេ" ។ ព្រះរាជាមិនទ្រង់ជ្រាបបំណងរបស់គេ ក៏ទ្រង់
លំបាកក្នុងព្រះរាជហឫទ័យជាខ្លាំង ទើបត្រាស់តបថា "នែបុរសកសិករ!
អ្នកចូរឈប់និយាយពីរឿងវាយដោយរំពាត់ទៅ បើអ្នកត្រូវការដោយមាស
ប្រាក់តែវាងឯណា ក៏ចូរប្រាប់មកចុះ យើងនឹងរកឲ្យបានគ្រប់យ៉ាង" ។
កសិករក្រាបទូលថា "បពិត្រព្រះសម្មតិទេព! បើទ្រង់ព្រះមេត្តាប្រោស ញ៉ាំង
សេចក្តីប្រាថ្នារបស់កសិកឲ្យគេញ៉ាំងបរិបូណ៌ ក៏សូមទ្រង់ព្រះរាជទានឮគ្នាន់
ដល់ទូលព្រះបង្គំជាខ្ញុំ ដោយការវាយឲ្យបាល់តែគ្រប់ ១០០ រំពាត់ចុះ, បើ
មិនដូច្នោះទេ ទូលព្រះបង្គំជាខ្ញុំ នឹងថ្វាយបង្គំលា សូមស្ងួតថ្ងូរមានចំពោះ

ព្រះអង្គចុះ" ។ កាលព្រះពុទ្ធមិនទ្រង់ឃើញផ្លូវដទៃ ដើម្បីញុំាងសេចក្តី
ជ្រួលជ្រាបរបស់កសិករឲ្យពេញបាន ទើបត្រាស់បង្គាប់ឲ្យនាយតម្រួតចាត់ការ
ជាក់ព្រះពុទ្ធអាជ្ញា ។ លុះតម្រួតរាយបាន ៥០ រំពាត់ ដោយថ្នមៗ ព្រោះជា
មនុស្សគ្មានទោសកំហុស តែរាយបន្ត្រមតែកន្ត្រុំប៉ុណ្ណោះ , កសិកររកំស្រែក
ជ្រួលថា "ឈប់បង្អត់រាយត្រឹមប៉ុណ្ណោះសិនចុះលោក! ព្រោះខាហានឆ្មាំទ្វារ
ម្នាក់ ឈ្មោះអាយ័ស្សខ្វាក់ក្អែកម្ខាង ជាអ្នកត្រូវបានខូចចំណែកនៃរង្វាន់
ដោយការរាយនេះដែរ ដ្បិតអ្វីបានចុះសន្យាទីឆ្ងាយគេពុកថា រង្វាន់ឯណា
ដែលខ្ញុំបានអំពីព្រះពុទ្ធ ត្រូវបែងចែកគាក់កណ្តាល ឲ្យដល់ខាហានឆ្មាំ
ទ្វារនោះ បើមិនដូច្នោះទេ ខ្ញុំទីឆ្ងាយមិនបានចូលគាស់ នាំត្រឹមកថ្វាយព្រះពុទ្ធ
ឡើយ , ។ ហេតុនេះ សូមមេត្តាចែករង្វាន់ គឺការរាយ៥០រំពាត់ខាងក្រោយ
នេះ ដល់ខាហានឆ្មាំទ្វារនោះ ដើម្បីកុំឲ្យខូចសច្ចៈរបស់ខ្ញុំដែលបានប្តេជ្ញា
ទីឆ្ងាយគេហើយ" ។

ដោយកេរអង្វរនៃកសិកនោះ , ខាហានឆ្មាំទ្វារឈ្មោះអា
យ័ស្សខ្វាក់ក្អែកម្ខាង ក៏ត្រូវគេនាំខ្លួនយកមកកន្លែងចំពោះព្រះភក្ត្រព្រះពុទ្ធ
ហើយរាយខ្លួន ៥០ រំពាត់ យ៉ាងធូរៗ ។

ព្រោះសេចក្តីឈ្លាសវៃនៃកសិកនោះ, ព្រះពុទ្ធទីឆ្ងាយមន្ត្រីទាំងឡាយ
មានសេចក្តីស្ញើចសរសើរក្នុងចិត្តជាងខ្លាំង ក៏តាំងចិត្តមិនសេចក្តីពប់អាន
ចំពោះកសិកនោះ យ៉ាងសន្ធឹក ។

រឿងនេះ គឺជាបទរៀនមួយបែប ដែលកសិករប្រៀនកូនខ្លួន ដើម្បីប្រដៅមនុស្សលោកខ្លះៗ ឲ្យមានចិត្តប្រកបដោយសុចរិតយុត្តិធម៌ ក្នុងមុខការរបស់ខ្លួនត្រង់ៗគ្នា ។

វិធីនេះជាគន្លងផ្លូវនៃយុត្តិធម៌ មិនមែនជាវិធីធ្វើឲ្យគោសចំរើនខ្លាំងដោយការធ្វើអាក្រក់តបនឹងអាក្រក់ទេ , គឺជាវិធីតបតនឹងសេចក្តីអាក្រក់ដោយសេចក្តីល្អ ដើម្បីវែកញែកការសេចក្តីសុចរិតយុត្តិធម៌ សម្រាប់មនុស្សលោកតៗ ។

សេចក្តីនេះ សមដូចព្រះគាថាក្នុងធម្មបទខុទ្ទកនិកាយថា :

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

បុគ្គលគប្បីឈ្នះបុគ្គលក្រោធ ដោយការអត់មិនក្រោធតប, គប្បីឈ្នះបុគ្គលអសប្បុរស ដោយសេចក្តីសប្បុរស, គប្បីឈ្នះបុគ្គលកំណាញ់ដោយការឲ្យ, គប្បីឈ្នះបុគ្គលលេះលោះ ដោយពោលពាក្យពៀងត្រង់ ។

រឿងបាដ្ឋយន្ត

(តមក)

លោក អ៊ឹម-ពន ជម្នួងពីសាស្ត្រាស្ទឹងត្រែ

បទ កាកគតិ

កាលនោះបុរោហិត អ្នកប្រាជ្ញព្រាហ្មណ៍ព្រឹទ្ធ ប្រដៅសិស្សផង
អង្គុយរៀនពាល់ រៀនធម៌អ័ដ្ឋកង ច្រើនវិក្រកន្ទុង ជុំជាប្រក្រតី ។
ព្រាហ្មណ៍យល់ព្រះអង្គ ប្រសើរកិម-ន្តិលគាថ៌ពិសី រវៃនោមរវៃក្ខណ៍
រវៃកត្តែសោតិ ព្រាហ្មណ៍ប្រាជ្ញបេតិ តើតកូចស្រឡាញ់ ។ តេជៈសម្ភារ
សម្តេចភូឋាល សាងពីមុនមិញ ព្រាហ្មណ៍យល់ហើយគិត ក្នុងចិត្តឯងវិញ
កន្ធក់កន្ធេញ សោកសរសើរថា ។ រីអ្នកនេះនៃ រូបល្អប្រពៃ ដើរមក
ពីណា មិនគឺកូនពាស្ត្រ ចាំងផ្កាសង្ខិដ្ឋា សមកូនក្សត្រា ពីបរទេសឆ្ងាយ ។
សមមកនេះណា រកៀនសាស្ត្រា ធម៌ជដ្ឋចាំងឡាយ អញហៅមកសួរ
ខ្លួនខ្លះឱយ ប្រកាសមួយ ឲ្យអស់សេចក្តី ។ ទើបព្រាហ្មណ៍
ប្រាជ្ញហៅ ថារើយនៃចៅ កំឡោះតិសី អាពុកយល់ចៅ ល្អេញស្តៅ
ប្រឹមប្រិយ អញ្ជើញអ្នកលី.លាមកឯអាយ ។ អាពុកនឹងដ-ណ្តើងអ្នក
ប្រសត់ន បន្ទិចព័ត៌កាយ ក្បាលោះព្រះអង្គ ដ៏ទ្រង់ធំមធាយ ឮព្រាហ្មណ៍
ប្រាជ្ញប្រាយ ហៅដូច្នោះណា ។ ទើបអ្នកខត់ចៅ យល់សឹងសិស្សចៅ
រៀនធម៌សាស្ត្រា ស្តែងស្តេចគិតក្នុង កំឡុងចំយា ទ្រង់ព្រះចិន្តា ត្រេកអរ

គេកម្រៃ ។ អញមកនេះម្តង ចាន់ដូចចំណង់ ពុំក្រឡើយនៃ អញនឹង
សំណាក់ ពីងពាក់អាស្រ័យ យកព្រាហ្មណ៍នេះនៃ ជាអាពុកធម៌ ។
ហើយអញនឹងរៀន ឲ្យអស់រៀបរៀន សិល្បសាស្ត្រគាថិ ចំណេះអ្វីៗ កុំ
ប៉ះទើសទាស់ ដូចអញតែតាស់ ប៉ុនប៉ង់ច្រើនថ្នាំ ។ ទ្រង់ចំណាស្រេច នោះ
ទើបស្តែងស្តេច យាងយាសយាត្រា ចរចូលទៅផ្ទាន ត្រើះស្ថានព្រាហ្មណ៍
ណា ព្រាហ្មណ៍សោតចរចា សាកសួរព្រះអង្គ ។ ថាហៃអ្នកមាស ឯក
ឯនយាងយាស មកពីកំឡែង ដំមន់ហាខណា យាត្រាត្រាច់ត្រង់ នេះអ្នក
ចោទចង់ ប្រការតស្អូ ។ ចូរអ្នកប្រុសច្រាប់ ឲ្យអាពុកស្តាប់ ដឹងដើម
សេចក្តី មាសមកនេះណា ច្រាំថ្នាំពាក្យស្តូ ចូរអ្នកស្រដី កុំលាក់លៀម
ឡើយ ។ មួយសោតនាមករ កូនស្ងួនចរិយ ឈ្មោះអ្វីកូនអើយ រីស្រុក
ទេសតន់ ដំបន់ត្រាណត្រើយ នៅឯណាឡើយ នាមហៅស្រុកអ្វី ? ។
មួយទីសោតណា ឯងមាតា បិតាដាតិ បងប្អឹតនៃបា សួនភ្ងាពិសី នាម
ហៅឈ្មោះអ្វី ? ណាអ្នកកូនអើយ ។ ក្បាំណោះព្រះអង្គ អម្បាពួជពាឡ
ក្សត្រាត្រាណត្រើយ ស្តេចស្តាប់ព្រាហ្មណ៍សួរ ខន្ធលមកហើយ ទើបព្រះ
អង្គឆ្លើយ សារសង្ឃស្រៃ ។ ថាខ្ញុំនេះណា ជាកូនក្សត្រ ធ្លាជដៀស្តដ័យ
ជាចៅហ្វាំ ដែនដ៏កតវត្រ ឥស្សរឯនឮ ត្រាច់ត្រង់ភាព ។ ខ្ញុំឈ្មោះសុវណ្ណ
កុមារសោភ័ណ ត្រាច់ចរយាត្រា មកតាំងម្ល៉ះហោង ប៉ុនប៉ង់ច្រើនថ្នាំ រៀន
សិល្បសាស្ត្រា អស់អាថិធម៌ផង ។ ក្បាំណោះព្រាហ្មណ៍ស្តាប់ ព្រះ

អគ្គវ្ថែនក្រាប់ បទដើមទំនង ដំណើរក្សត្រា ក្រាថ្នាប់ទំនប់ឆ្នាំ រកវៀនធម៌ផង សព្វព្រះហឫទ័យ ។ ព្រាហ្មណ៍ថាខ្ញុំសូម អ្នកមានទត្តម ជាកូនធម៌ថ្ងៃ ទីឆ្នាប្រដៅសិល្ប ធម៌វិសេសសេយ្យ តាមតែព្រះទ័យ អ្នកនឹងក្រាថ្នា ។ កាលនោះព្រះថៅ សែនស្តេចអ្នកនៅ ទីឆ្នាព្រាហ្មណ៍ហោក ព្រាហ្មណ៍ប្រដៅធម៌ សព្វសិល្បសាស្ត្រា សម្តេចពាជា រៀនអស់ធម៌ផង ។ ហេតុព្រះក្រាថ្នា ទ័ព្វវិសេសក្រា- ក់ដកបកទ្វឆ្នា ស្តេចរៀនសេធម៌ សិល្បសាស្ត្រាផង ចាន់ដូចបំណាង ចប់បិដកត្រៃ ។ ព្រាហ្មណ៍សរសើរថា កូនស្ងួនតុំកា មានក្រាថ្នាវៃ អ្នករៀនអស់ធម៌ សព្វសិល្បសាស្ត្រសេយ្យ តែរំពេចនៃ ចប់សាស្ត្រាគម (១) ។ អាពុកទឆ្នាបង ចំណេះទ្ងួនឯង ឲ្យមានទត្តម តាឯតួអាពុក សេតសុទ្ធតែម្យ ជាអ្នកក្រាជ្ញធំ លើសលែងលោកា ។ អាពុកទឆ្នាយក ជាបុត្រតាទ្ងួក កូនស្ងួនតុំកា ទៅថ្វាយព្រះភ្ងា ទនោឋជេដ្ឋា រឯចិត្តជា តិតម្តេចកូនអើយ ។ ព្រះអគ្គីស្តេចស្តាប់ ពាក្យតាកេះតាប់ ព្រាហ្មណ៍ក្រាប់ថ្នោះហើយ ក្សត្រិណាក្សត្រត្រកូល ចង្ងូលទ្ងាស់ឆ្នើយ អ្នកអាពុកអើយ ខ្ញុំទឆ្នាអ្វី ។ ក្សត្រិណានោះព្រាហ្មណ៍យក ព្រះអគ្គីតាទ្ងួក សាតិជ្ជដ៏ទស្រើ ទៅថ្វាយព្រះភ្ងា

---

១ សាស្ត្រ ន. (សំ.ឧ) គម្ពីរ, ប្បាប់, ក្បួន, តម្រា, អាគម ។ ន. (សំ.ឧ.) ការរៀ-សូត្រ, ការចេះដឹង; ផ្សំសាស្ត្រាទឆ្នាងអាគម ជាសាស្ត្រាគម ចប់សាស្ត្រាគម តឺចប់ការរៀនសូត្រតាមគម្ពីរ ក្បួនប្បាប់ ។

ខនាថខនបតិ ជាបៅបូរី ខតរបញ្ញាល់ ។ ព្រាហ្មណ៍ខនសិរសី ក្រួញ
ក្រាបវន្ទីយ បង្គំទូលថា ខ្ញុំថ្វាយកូនប្រុស ស្រេចស្រស់សោភា ជា
ខ្ញុំកវុណា តាងខ្ញុំឯងហោង ។ កវ្ឈណានោះក្សត្រា ស្តេចបន្ទូលថា
ព្រាហ្មណ៍នេះជាម្ចាស់ ព្រាហ្មណ៍យកបុត្រា តុំរ៉ាសួនគ្រប់ មកថ្វាយជាស្នង
តួព្រាហ្មណ៍ច្រាជ្រាយ ។ កូនព្រាហ្មណ៍តើញាំង ចេះបង់ទូទាំង សិល្ប
សាស្ត្រសព្វសាយ ធម៌អាចិក្ខនច្បាប់ តម្រាប់តាំងឡាយ ដូចព្រាហ្មណ៍
ច្រាជ្រាយ ឬទេព្រាហ្មណ៍ព្រឹទ្ធ ។ ទើបព្រាហ្មណ៍ទូលថា បពិត្រ
ព្រះមហា-ក្សត្រថ្លៃព្រះរ៉ាំខ្ញុំ កូនខ្ញុំនេះណា ច្រាជ្រាចាំពិត តោះខ្ញុំឯងតិត
ផ្ទឹមជនិពុំបាន ។ ស្តេចស្តាប់ព្រាហ្មណ៍ទូល ព្រះបាទឥសូរ ក្សត្រ
ថ្លៃថ្លើងក្លាន ត្រាស់ថាអញអរ សាទរស្មោះស្មាន អរជ្រួតព្រាហ្មណ៍មាន
កូនប្រុសច្រាជ្រាយ ។ ទ្រង់ព្រះចិន្តា ក្នុងព្រះទ័យា ថាតុអញស្តាយ
កូនព្រាហ្មណ៍នេះណា សោភាខោមនាយ លែងប្រុសតាំងឡាយ
លោកិយនេះណា ។ ដ្បិតតែយសក្តួច ពុំស្មើពុំដួច នាងនាថធីតា
បុត្រីសំឡាញ់ កូនអញនេះណា ទើងផ្សំផងគ្នា ពុំបានឡើយហោង ។
សម្តេចពេជ ព្រះអង្គកវុណា ស្រឡាញ់ស្នេហ៍ស្នង អាសូរគោធ-សត្វ
វិសេសហោង លើសលែងអ្នកផង តាំងឡាយនា ។ ។- ឯពុទ្ធន្តរ
តន្ទុកបណ្តុល សតិជ្ញសាស្តា ព្រះអង្គតែងទៅ តាលហ្វាកជា
តាងព្រាហ្មណ៍ហោក ជាអ្នកច្រាជ្រាយ ។ រីឯបុរេហិត ហោក-

ព្រាហ្មណ៍ត្រឹទ្ធ នៅសុខសប្បាយ រក្សាព្រះអង្គ ទ្រើសទ្រង់នោមទាយ
ក្សត្រថ្ងៃពណ្ណាយ នៅទឹងព្រាហ្មណ៍ណា ។ ព្រះបាទឥសូរ ក្សត្រា
ត្រកូល ព្រះចៅបញ្ចាល់ ស្តេចមានបុត្រី ស្រស់ស្រីសោភា នាងទ្រង់
នាមា បទុមកេសរ ។ នាងនាថនារី តបបញ្ចាតន្ត្រីយ នោមទាយ
បវរ ដូចបន្ទូលចង់ចាំង ទូតាំងអម្ពរ ជាឆ្នើមនគរ បញ្ចាលបូរី ។
នាងល្អកន្ទុង ទ្រទេសធ្លាវង ទ្រទន់សល់ស្រី រវាអង្គវិលក្ខណ៍ រវាកត្រូ
សោភ័ ជាមកុដអស់ស្រី តាំងវិត្រតភជង ។ គោះបីស្រីសួគ៌ ប្រៃពៃ
គាប់គួរ ថ្លាថ្លៃកន្ទុង នៅត្រៃត្រឹង្សា សួគ៌នាយហោង គោះទឹងផ្ទុមផង
នាងតុំចាន់ណា ។ សម្តេចជនទី ជនកបតី កូនស្ងួនតុំងា ស្តេចឲ្យស្រី
ថ្លៃ នៅព្រះថ្នាំង្រួ-សាទសួគ៌សោភា មាសមៃព្រោងព្រាយ ។ ស្តេច
ឲ្យស្រាលស្រី ស្រស់ស្រៀបប្រិមប្រិយ (១)ភ័ស្តៀងតាំងឡាយ ឲ្យចាំ
រក្សា បុត្រក្សាទោមទាយ នៅសុខសប្បាយ លើប្រាសាទសម ។
រតន៍ពាជធ៌តា ទោមទាយសោភា ពាលពេញក្រមុំ ស្រីស្រស់ថ្លាថ្លៃ ល្មម
ល្មៃក្រៀវកំភ្លឹ នាងនាថឧត្តម សោឡសឆ្នាំណា ។ នាងនៅប្រាសាទ
ប្រសើរស្អាងស្អាត មាសមៃសោភា ទឹងអស់ស្រីគ្នា បរិពារនាងណា
ក្សេមក្សាន្តសុខស-ប្បាយបរិបូណ៌ត្រៃ ។ ហេតុតែបុណ្យនាង បរិបូណ៌
បានសាង ជាអសង្ខ្យេយ្យ ទឹងព្រះពោធិ សត្វវិសេសថ្លៃ ទឹងបាន

---

១ ពាក្យសៀម ប្រែថា បងចិញ្ចឹម ។

មួលមៃ ត្រែត្រគងដង្គា ។ មានកាលមួយថ្ងៃ ស្រីរតនថ្ងាថ្ងៃ ចេក ព្រះគៀវគា តេយល់ព្រះអង្គ តួជតង្ស្យក្សត្រា វិស្ណងស្តេចលីលា ទ័ម ច្រោសាទថ្ងៃ ។ ទើបនាងចិត្តា ក្នុងព្រះទ័យា ថាអ្នកនេះនៃ មកពី ឋានណា ថ្ងៃកនាសត្វថ្ងៃ ខានរូបប្រពៃ ស្មុស្តិ៍សមសោភា ។ ទើប នាងច្រាប់ទៅ តែលៀងមួយនៅ ខាងនាងធីតា បងអើយបងមើល តេដើរនោះណា រូបនោមនាយា ចំណាប់តេកក្រៃ ។ នាងនាថជាយា ខ្លួវតែលៀងគ្នា តយតន់រំពៃ ហើយសឹងសរសើរ ដំណើរក្សត្រថ្ងៃ ទាំងព័រនាក់នៃ តុំលែងឡើយណា ។ នាងតយតន់មើល ព្រះរាជ ដំណើរ លុះអស់នេត្រា នាងនារីរតន៍ ចង់ចិត្តស្នេហា តែតព្រះរាជា ពិត តុំក្លេចឡើយ ។ នាងនាថនោមនាយ ធ្វើជានិយាយ ឯទៀតត្រើយ ធ្វើតុំនាំពា ហាក់ជាគោះតើយ តែមោះតុំស្ទើយ ក្នុងព្រះទរ ។

បទត្រឡាកតិត

លុះចូលដួបកត្រី នាងនារីរតនទេវី ទ្រង់ព្រះរាជចិត្តា រំពឹងព័ត្រះ អង្គថ្ងៃ ។ ថាតុអង្គីកល នាអញ្ជើយល់អំពីថ្ងៃ ប្រុសនោះល្អប្រពៃ តើគាត់ មកពីឋានណា ។ បើដោយដៃលតញ្ជើយល់ រូបនិមិលនោមសោភា សម គាត់កូនក្សត្រា ត្រាច់មកពីឋានចម្ងាយ ។ តុំតែកូនសេនា ពស្ត្រប្រជា នៅស្រុកអាយ បើកូនអ្នកក្សិណក្ស័យ មិនមានរូបដល់ម្ល៉ះណា ។ ល្អ ថ្ងៃកនាលោកិយ ហាក់មកពីត្រៃត្រឹង្សា ព្រះតក្កដួចច្រើ តួចះចែង

ពេញបូណ៌មី ។ តន់ឯអស់ព្រះអង្គ សឹងរវៃសមសោភ័ ល្អល្អះអស់
ឥន្ទ្រិយ រូបល្អញល្អៅពាលប្រពៃ ។ នាងទ្រង់ព្រះចន្ទា រវៃយាព្រួយ
ព្រះទ័យ តិតវិលវៃគាល់យ អាលោះលន់ពាន់ប្រមាណ ។ ឥអញឥឡូវ
អើយ ធ្វើម្តេចឡើយកំនើនជាន អ្នកនោះមកមួមហាន ជាស្វាមីអញស្ងួ
ថ្លៃ ។ អញចង់ឲ្យទៅសួរ យល់តុំគួរពេកណាស់នៃ តិតទៅវៃត្រូវក្រែ
តតអ្នកណានឹងជួយចាត់ ។ បើអញស្ងៀមទេទៅ ក្រែងតាត់ទៅឯមុខជាត់
ឥក្តីខ្លះក្រែតាត់ នឹងធ្វើម្តេចឥឡូវណា ។ រូបអ្នកល្អពិសិ ដូចបូណ៌មីព្រះ
ចន្ទា តួនុងសិខស្មេហា ជាស្វាមីអញនេះសម ។ កំឡឹងពត្រីហ្មាត់ នាវ៉ែតន៍
រែងជាម្តេ នាងនាថតុំបានដូច ឡើយនាងតិតព្រះរាជា ។ លុះព្រឹកព្រហាម
ស្រាង ស្រេចហើយនាងនាថជាយា នាងតែនចាកក្រឡា បន្ទំនែនទិព្វវរ្ណ៍ ។
ទើបនាងសោយព្រះស្ងួរ ស្រេចស្រុតន់សោយព្រះស្រី ហើយនាងនាថ
ទៅបើកព្រះគៅតាទៀត ។ នាងឆ្លុកតិតអាល័យ ក្នុងព្រះទ័យវៃចង្អៀត
នាងតយតន់មើលទៀត នាងពុំយល់ព្រះភូមិ ។ នាងតង់ឯងសញ្ជប់
ស្ងើមស្ងួតស្ងប់ព្រះតក្តែស្រៀ នាងនាថតុំស្រដី ជាចាំចែងដល់តំបូណ៌ ។
តំរៀងជំងឺតនាងី ចូលទាងនាងកងធីតា យល់នាងងាក់តក្តា ស្រោនន
តំដូចសត្វជង ។ តំរៀងអញ្ជាស្រើយ ថាស្រីថ្ងៃមានេះបើចង់ នឹងអ្នកប្រុស
ណាហោង ទើបជាទុក្ខគន្ធីក្តី ។ តំរៀងទូលស្ងើថា នាងធីតាអង្គ្រកអ្វី
ស្រោនព្រះតក្តែស្រៀ ប្លែអ្នកថ្ងៃច្រាប់ខ្ញុំពិ ។ ទើបនាងថាបងអើយ ឥឡូវ

ហើយអញ្ជើញអ្នកមហា- ព្រួយចិត្តពន់ពេកណា៎ បងមិនដួយគិតអ្នកឡើយ ។
តើលៀងទូលវាងវៃ ព្រួយព្រះទ័យអ្វីមាសអើយ កុំអ្នកថ្លែលាក់ឡើយ ប្រាប់
ឲ្យបងបានដឹង៉ា ។ ទើបនាងត្រាស់ថាវៃ បងឯងនៃស្រាប់ហើយ
ណា៎ ស្មើកើតឯកមាតា តើអ្នកនឹងលាក់ធ្វើអ្វី ។ បងអើយអ្នកបងឆ្ងល់
ដ្បិតអ្នកយល់ប្រុសពិសី ពីមុំលែងគ្នីគ្នី តើគាត់មកពីហានណា ។ បងអើយ
អញ្ជើញអ្នកថប់ គិតទៅត្រូវហើយវែងជា ព្រួយចិត្តពេកមិនត្រា ស្បើយពី
ទ្រូងជល់តែបន្តិយ ។ បើអ្នកណាទៅជល់ សួរឲ្យយល់ពាក្យគាត់ហើយ
អ្នកនោះណាបង៉ាអើយ អញនឹងឲ្យរង្វាន់ផង ។ នាងចរចាបញ្ឆៀង ទើប
តើលៀងទូលនឹងស្នង អ្នកនោះខុកងារបង កុំព្រួយចិត្តណា៎មាសថ្លៃ ។
នាងស្តាប់តើលៀងថា ទូលជានាដូច្នោះនៃ ទើបនាងត្រាស់ថាវៃ បើបង
ទៅសួរឲ្យជាក់ ។ សួរឈ្មោះម្តាយអាពុក សួរពាំងស្រុកពាំងនាមអ្នក បង
សួរឲ្យជាក់លាក់ ក្រែងគាត់មានប្រតន្ទហើយ ។ តើលៀងក្រួញក្រមល
នាងធ្វើតាពុលង៉ៃឡើយ ទៅហានព្រះក្រោណត្រើយ ចាំមើលផ្លូវព្រះពជា ។
កាលនោះពោធិសត្វ បុរសវ័ន្តស្តេចលីលា ឱងទៅគាល់ក្សត្រា ដួច
ឱងនាងតើលៀងនោះ ។ ឯនាងតើលៀងណា ដណ្តឹងថាអ្នកកំព្លោះ ឱង
ទៅឯណាច្នោះ ឈប់ខ្ញុំឱងសួរសិន៉ា ។ រីឯព្រះជៀស្ដជ័យ សង៌សម័យ
ត្រាស់ទៅថា អញឱងអាលយាត្រា អញមិនឈប់ណា៎នាងអើយ ។
តើលៀងលោមចរចា អ្នកកុំថាដូច្នោះឡើយ ឥឡូវនេះអ្នកអើយ មានគេ

ប្រើខ្ញុំមកណ៎ា ។ ស្តេចស្រាប់ដូច្នោះនៃ ក្សត្រិណក្សត្រថ្លែឈប់រេក តែលឿន
នោះម្ល៉ោម ចូលទៅទូលព្រះជៀស្ដជ័យ ។ នាងថាតួអ្នកអើយ ឥឡូវហើយ
ក្សត្រិថ្លែ នៅប្រាសាទមាសមៃ បុត្រីព្រះថៅបញ្ចាល់ ។ នាងទ្រង់ឆោម
ពិស លើសលែងស្រីទេពសួគ៌ នាងទ្រង់ព្រះនាម ឈ្មោះបទុមកេសរ ។
នាងប្រើខ្ញុំមកណ៎ា នាងធ្លាតែន៎បវរ បង់ប្រាបទាមកវ ឈ្មោះអ្នក
ឯងណ៎ាអ្នកអើយ ។ មួយសោតក្រែងអ្នកមាន តួបុកណាជាស្រែច
ហើយ ឬមួយអ្នកគ្មានឡើយ នាងបង់ដំដែងដោយទំនង ។ ហើយសួរ
ពីនាគា ខ្ញុំបិតាអ្នកឯងធំធង ឯឈ្មោះស្រុកនោះហោង លំនៅតើនៅហ៊ាន
ណា ។ ក្សិណៈនោះព្រះភូមី ក្រាបសីរឿនទូលថា ពីនាងនោមសោកា
ឲ្យដណ្តឹងដូច្នោះហើយ ។ ស្តេចគិតក្នុងព្រះទ័យ អរពេកក្រៃទើបស្តេច
ទ្វើយ ស្នងថ្លែងថាបងអើយ អញអរបងនាំពាក្យគ្នាន ។ ពីនាងឲ្យ
មកសួរ សាកបរិបូណ៌ហើយអញថ្លាន ដឹងពាក្យពិតល្បាណ ចែងសាយ
សព្វប្រការធង ។ បងអើយឯមាគា ខ្ញុំបិតាអញនេះហោង ជាស្តេច
ស្តេងត្រែប់ត្រង ក្រែងភាពទេវាប្ញី ។ ឯអង្គអញនេះណ៎ា ឥតជាយោ-
ធជនទេព៌ ទើបអញត្រាប់ចរលើ មកស្រុកអាយណ៎ាបងអើយ ។ អញ
មកប្រយោជន៍ណ៎ា រកជាយាណ៎ាអ្នកអើយ នៅអាស្រ័យនៅឡើយ
ផ្ទះព្រោហ្មណ៍ប្រាជ្ញប្រាយនោះហោង ។ ឯឈ្មោះអញនេះណ៎ា ក្នុង
ព្រះបាលិជាមគ្គ ថាព្រឹត្យប្រសើរឆង វែងតែងសៀតព្រះកេសី ។

ឈ្មោះអញ្ជលីដូច្នោះណា៎ បងយាត្រាវិលវិនខ្ញុំ ទៅខូលនាងទេវី តាម-ប្រាថ្នានាងគំតយល់ ។ តាំលៀងសោតស្តែងស្តាប់ ព្រះអង្គប្រាប់ប្រការ កល ដើម្បីព្រះទេសពល ជាស្តេចវែងឆ្ងាយហោង ។ អរឯង ឧទិសសោ បង្គំមហាក្សត្រជាប្អូន លុតលាវិលវិនស្នង ទៅប្រាសាទ ប្រសើរសល់ ។ ឯព្រះបាទពាជា ស្តេចសីលាឡើងទៅដល់ រោងរ័តន៍ពាជមណ្ឌល តង់តាល់ព្រះចៅបញ្ជាល់ ។ ស្រេចហើយព្រះពោធិ-សត្វចុះពីតាល់ពាជា ទៅថ្នាទព្រាហ្មណ៍ហោរា ស្តេចនិត្យនៅដូចសព្វ-ជន ។ ឯតាំលៀងនោះណា ទៅប្រាង្គប្រាសាទនោះហោង ម្ចាស់ឡើងទៅធ្លុង គ្រាបខូលនាងនាថជាយា ។ បតិត្រអ្នកអម្ចាស់ ឥឡូវនេះខ្ញុំយាត្រា ទៅជួបដូចប្រាថ្នា បាននិយាយសព្វសេចក្តី ។ ម្ចាស់អើយអ្នកនោះណា៎ មិនគឺជាកូនមន្ត្រី មិនគឺកូនសេដ្ឋី មិនគឺកូនព្រាហ្មណ៍ហោរា ។ ព្រះអង្គជាត្រកូល ជាអម្ចាស់បុត្រក្សត្រា សោយរាជ្យត្រង់តាម នគរឈ្មោះទេពបុរី ។ ព្រះអង្គឥតជាយា ប្រសើរជាអគ្គមហេសី នោះ ទើបព្រះភូមី ស្តេចត្រាច់មកដល់ស្រុកគាយ ។ ស្តែងស្តេចគាល់ឃ នា នៅគ្រឹហាព្រាហ្មណ៍ក្រៅជ្រុងជ្រាយ ប៉ុន្តែដ៏មកពីឆ្ងាយ ប្រយោជន៍រកពាជ ទេព័ ។ រីឯព្រះនាមា ស្តេចប្រាប់ជាព្រះចាលី ជាព្រៃប្រសើរវិ-សេសវែងសៀតព្រះកេសា ។ ព្រះអង្គប្រាថ្នាមក ឲ្យនាងរកតាម ប្រាថ្នា ព្រះនាមព្រះពាជា ក្នុងព្រះចាលីឯនិនៃ ។ នាងជ្រាបសព្វប្រការ

ហើយទាំងនាថព្រះហ្ឫទ័យ ត្រេកអរឯណាពេកក្រៃ ទើបថ្លែងថ្វីធំពុំ
ចាន់ណា ។ ទាំងពឹងថាព្រះអង្គ ប្រសើរពេញក្នុងឥស្សរ ឥតបាន
សង្ឃឹម ក្នុងព្រះទ័យជល់តិចឡើយ ។ ទើបទាំងទ្រង់ចិត្តា ដោះប្រស្នា
ព្រះគ្រាណាត្រើយ ឃើញឈ្មោះពុំលង់ឡើយ ទើបទាំងទាថបន្ទូលថា ។
បងអើយអញអាក្តាត់ បងឯងឥតឲ្យប្អូនក្លា បងអើយឯប្រស្នា នោះប្អូន
ស្រាយឲ្យបងស្តាប់ ។ ចាំទ្រត្យឈ្លប្រពៃ ប្រសើរក្រៃលោកវែងកប់
វែងស្ពានវែងជ្រងាប់ សៀតកេសតីសៀតសក់ ។ នេះឯងទ្រត្យប្រពៃ
មានតម្លៃពុំអាក្រក់ បងអើយឯស្មៀតសក់ សោតសឹងមាសឯងហោង
ណា ។ អស់មនុស្សសឹងហៅមាស ហៅតាំងផ្កាសសឹងដូចគ្នា ថា
បើឯងហៅដាំ ព្រោលឹថាសុវណ្ណ ។ ទាមអ្នកជួញប្តូរហោង កុំបី
ឯងតិតន្តៃគាន់ ស្តីបាឈ្មោះព្រះសុវណ្ណ- កុមារឯងមិនខេខ្សោយ ។ ទាន
ទាថមានជ្រាបជ្រាជ្រួ ដោះប្រស្នាព្រះគ្រាណាត្រើយ ស្តាប់ព្រះនាមស្រួច
ចាំយ ទាងរៃឯតោញព្រះហ្ឫទ័យ ។ តែលឿងសឹងស្រមៃ ថាមាសថ្លៃ
មានច្រើនជ្រាជ្រួ ដោះសោតចិត្តប្រស្នា រំតេចពុំតម្រង់ឡើយ ។ ទន្ទឹងព្រះ
សុរិយោ ទាងធីតាឥតឯស្បើយ ទាងថាយៃបងអើយ ងើងជួយតិតប្អូន
ទាប់ពំ ។ តែលឿងខិតជិតទាង ទូលសោមទាងទាថជាយោ ម្តាយអើយ
កុំទាងថា- រម្ភតិតព្រះរៀមពេកឡើយ ។ កំសាន្តព្រះទ័យោ ទាងតង់
ជាសុខម្តាស់តើយ ទុកជាខ្ញុំឯងហើយ ខំឆ្លើតតួរថ្លាយម្តាស់ថ្លៃ ។ ខ្ញុំ

ទឹងចុះទៅដល់ ឲ្យបានយល់ព្រះចមរត្រៃ អញ្ជើញអ្នកបងរៃ រួមណ្តាលទឹងនាងណា ។ នាងស្តាប់តំលៀងទូល នាងដួចចូលព្រះទ័យ ទើបនាងបន្ទូលថា តាមតែបងឯងគិតរៃ ។ តំលៀងក្រួញក្រាបលា នាងហើយយាត្រាជាប់រៃ ទៅដល់ព្រះចមរត្រៃ ថ្វាយបង្គំព្រះរាជា ។ ក្សិណនោះព្រះកូម៉ យល់ឥសីដល់ហើយណា ស្តេចត្រេកអរមនស្សា បន្ទូលនូវពាក្យមេត្រី ។ បងមកឥឡូវណា នាងធ្វើតារប្រើប្តូអ្វី ចូលបងថ្លែងពាក្យពី បង្គាប់នាងឲ្យរួសរាំ ។ តំលៀងសោតស្តេងស្តាប់ ទៀងទូលច្រាប់ព្រះរាជា ថ្វាថ្លែងដោយច្រាស្យា ចំណេះនាងជាងសំដី ។ ខ្ញុំម្ចាស់មកក្រាបទូល ព្រះឥសូរខ្ពស់ជាតិ ជាមកុដលើសិរសី ឲ្យបានជ្រាបព្រះទ័យា ។ ព័នានិទ្ទនទៅ មានស្វាម៉ឥតក្តិរាជា អនុដស្ងួនពុំជា នាងក្រួញក្រាបថ្វាយបង្គំ ។ មកអង្គព្រះជៀស្ងជ័យ ឲ្យក្សត្រៃថ្លៃស្តេចស្តែងផ្ទំ ឯកឯងកុំបារម្ភ សូមក្រសាលព្រះហឫទ័យ ។ ថាបើព្រះអង្គផ្ទំ ឯកឯងពុំលក់ឡើយនៃ ស្តេចយកព្រះពាស្ត្រៃថ្លៃ ជណ្តាប់ផ្ទំឲ្យលក់ណា ។ ស្តែងស្តាប់តំលៀងទូល ព្រះឥសូរមនស្សា ព្រឺព្រួចព្រះទ័យា ហើយហាក់យល់រំពេចពិត ។ សម្តេចព្រះរាជា ទ្រង់ចិន្តាថារំមិត្រ នាងនាឋព្រមចូលចិត្ត នាងឲ្យហៅអញ្ជើទៅហោង ។ ក្សិណនោះព្រះរាជា ថន្ទូលថាបៃអ្នកបង បងអើយចូរវិលផ្ទង ទៅទូលនាងនាឋទៅ ។ ថាអញបង្គាប់ទៅនាងអ្នកនោះ ។ ពិសី អញ្ជើរង់ចូលរាត្រី ហើយគង់ទៅថ្កូននាងហោង ។

តិលៀងក្រួញក្រាបលា ព្រះអង្គមហាក្សត្រជាប្អូន លើលាវិលវិនផ្គងដល់ប្រាសាទនាងទេវី ។ តិលៀនិតចូលខាង ក្រាបទូលនាងនាថនារី ថ្វាថ្លៃដ៏អស់សេចក្តី ដូចបណ្តាំព្រះពជា ។ នាងជ្រាបដូច្នោះនៃ ក្សត្រីថ្លៃសោមនស្ស អរឯដ៏តតណា ទើដថ្លៃដ៏ថ្នឹងពុំបានឡើយ ។ កាលនោះពោធិសត្វ បុរសតែន៍ក្សត្រគ្រាណាត្រើយ ស្តេចភៅថ្វាយព្រាហ្មណ៍ហើយ ព្រះអង្គថ្លៃដ៏ក្រុងព្រាហ្មណ៍ថា ។ ម្នៃអ្នកគាតុកអើយ ឥឡូវអើយថ្ងៃនេះណា ខ្ញុំទៅចាំសិលា កុំអ្នកកេអញខ្ញុំឡើយ ។ ព្រាហ្មណ៍ក្រែងស្តួរវៃ ថាមាសថ្លៃតប់ចិត្តអើយ សិលសត្វនេះឯងហើយ ជាត្រើយគ្រាណាអ្នកសត្វថ្លៃ ។ ក្សត្រាណោះព្រះពជា ព្រះអង្គលាព្រាហ្មណ៍នោះនៃ ស្តែងស្តេចគ្រាច់ដល់ព្រៃ ឃើញដែលទុកយន្តនោះណា ។ កាលនោះឯព្រះអង្គ ឡើងដល់បុងដើមព្រីក្ស គង់លើយន្តនោះណា ស្តេចស្រាវឡៃស្រេចហើយវៃ ។ ភក្ត្រីពន់ពាសា កាលហើយណាព្រះជៀស្តជ័យ ស្តេចកើចយន្តមាសមៃ ហោះអណ្តែតដោយវេហាស៍ ។ កាលនោះឯក្សត្រី រតន៍ទេវីកដធីតា នាងនាថពុំទិត្រា ឡើយនាងចាំព្រះចមរត្រែ ។ នាងកំងឹងក្នាក្រោសាទ ប្រសើរស្អាតខ្លាប់តេកត្រែនាងនាថនារីថ្លៃ នាងចង់ឈ្នងព្រះក្រោដ្ឋា ។ ឯពស្ស្រពោធិសត្វ បុរសរតន៍ស្តេចលីលា ហើចហោះដោយវេហាស៍ ដល់ប្រាសាទនាងទេវី ។ ស្តេចចុះចាកពីហង្ស ហើយព្រះអង្គព្រះភូមិ ស្តែងស្តេចគ្រាច់ឡើងមាន

ប្រាសាទប្រសើរសព្វ ។ ស្តេចយកព្រះហស្តថ្វៃ ៗសៀរច្រានទ្វៃទ្វារទាំង
គ្រប់ ឃលរំងឹតឹងសាយសព្វ សោតសឹងកំងន្ធាប់ក្លាំងក្លិត ។ ស្តេចទ្រង់ព្រះ
ចិន្តា ពិចារណាដងគន់គិត ថាអែនាងរមិត្ត នាងចង់ឆ្លើយនឹងប្រាជ្ញា ។
បើដោយអញគិតទៅ គួរអញហៅនាងជាយោ ស្តេចទ្រង់ពិចារណាក្នុង
កំឡុងព្រះហឫទ័យ ។ ទ្រង់ព្រះចិន្តាស្រេច ទើបសែងស្តេចគ្រាស់ថាអែ
ប្អូនមាសមិត្តថ្មើមថ្វៃ បងនាងមកដល់ហើយណា ។ ឯប្អូនៅពន្លក ប៉ែក
ទ្វារយកបងរួសក មាសអើយបងរំងាំ តែម្ចាក់ឯណាប្អូនស្រី ។ នាង
ស្តាប់ព្រះបន្ទូល នាងអាសូរព្រះភូមិ ស្រយុតអស់តន្ត្រីយ រែងចងចិត្តជាប់
ស្នេហា ។ គឺមោះនាងខំអត់ ខំសង្កត់ត្រង់ទ័យ បង់ដីនព្រះប្រាជ្ញា ទើប
នាងនាថដណ្តឹងទៅ ។ ជាអ្នកណាស្រដី ថ្លែងថាអ្វីមកពីក្រៅ ស្តេច
ឆ្លើយស្នងប្អូនៅ ជាបងឯណាប្អូនស្រី ។ នាងសងស្រមៃថា ខ្ញុំបុត្រ
ភ្លាត់ទៅបូរី តើតតែឯកឥន្ត្រីយ ឥតបងប្អូនជាពិរឡើយ ។ ទើបស្តេចបន្ទូល
ថា អែប្អូនភ្លាមាសបងអើយ កុំថាដូច្នោះឡើយ នាងស្តាប់បងនឹងប្រាយ
ប្រាប់ ។ អង្គប្អូនជាបុត្រី ក្សត្រតាំងត្រង់ស្រុកអាយ បងនេះណាប្អូន
អាយ សឹងកូនស្តេចដែលដូចទៅ ។ ឥតបងប្អូនឡើយណា អង្គឯកាដូច
ប្អូនៅ ឮនាមនាងប្អូនៅ ដល់ស្រុកបងឯនាយណា ។ ជាប្អូនល្អពិសី
លើសលែងស្រីទេពសួគ៌ា តែខ្លួននាងប្អូនភ្លា អង្គឯកាដូចខ្លួនបង ។
ទ្រើបបងសូរស្ងែមក សង្ឃឹតរកប្អូនឯងរំហោង ចំនួកប្រាជ្ញាបង យកជា

អាយិអគ្គមហេសី ។ ប្អូនអើយបងចប់មា យើងនេះណាដូចអគ្គី បើ
អង្គុតទុសមួយនៃ ធុំកម្រនឹងនេះធាប់ ។ ប្អូនអើយបើយើងយក ទុស
ពីរមកគុំគុំផ្តាប់ ជាពីរផ្ទុំនេះធាប់ រំពេចពុំកម្រឡើយ ។ ដូចកលអង្គប្អូន
ស្រី ខ្លួនបងក្តីណាប្អូនអើយ ចូរប្អូនកុំព្រងើយ កុំគោះតើយណាមាស
៣៧ ។ ថាបើប្អូនស្រីស្រួល នានខ្លួលយកមងឹនៅ ជាពីរនាក់នឹងចៅ
សើខ្លួនមួយនឹងប្អូនស្រី ។ មាសអើយគោះបីបើ តិតសារពើការផងក្តី
បងក្មេងមានប្អូនស្រី បើប្អូនក្មេងមាសមានបង ។ ទើបនាងសង្ស័យមៃ
ថាតាចវៃចព្រះអង្គហោង ដួយតិតឲ្យប្អូនផង ខ្ញុំម៉ែនក្មេងជោយកជា ។
អញ្ជើញព្រះអង្គស្តេច យាត្រាត្រាច់ទៅម្ដុំមា វិលវិលក្តាន់សីមា ស្រុក
ព្រះអង្គឯងាយនៃ ។ ស្តេចធ្វើយស្នងប្អូនទៅ បងម៉ែនទៅឡើយមាសថ្ងៃ
បងនឹងនៅនេះនៃ ចាំយកប្អូនឯងឲ្យបាន ។ ថាបើនាងប្អូនតន់ ស្នូន
ទីនឹងផ្ទំនមាសម៉ែនក្បាន្ត បងឲ្យបងវិលក្តាន ត្រឡប់ទៅស្រុកនាយណា ។
ចូរប្អូនមាសត្រកាល ។ មកបើតក្បាធ្លាប់ស្លេក បងអ្នកនឹងយាត្រា ទៅ
ឲ្យបានយល់មុខទៅ ។ សោះតែអត់ភ្លូតែក្នុង ដល់ថ្ងៃស្អែកបងនឹងទៅ
កុំឲ្យត្រួយចិត្តចៅ តែនឹងបណ្តេញចំបងបេនិ ។ នានសង្ស័យមៃថា
ខ្ញុំកុណាតែនឹងផ្តោះផ្តង ជន្ទដន្ទេញលង ហាក់ដូចខ្ញុំសហាយស្នំ ។
ពុំគាតពុំតិតខ្លាច យល់អំណាចណាស់ពេកតន់ ហាក់ហ៊ានតុំគួនលន់
ពុំគិតខ្លួនក្រែងក្រក្រើ ។ ទើបព្រះអង្គថ្នាស់ឆ្លើយ ថាមាសអើយបងនេះនៃ

តុំគិតតុំអាល័យ តុំខ្ញាចខ្លួនស្លាប់ឡើយណា ។ ឃ្លានតែប្អូនព្រលឹង ឲ្យ
ចាន់ខឹងចិត្តចំពោ បើចាន់ដូចច្រាថ្នា នោះប្រសើរនាលោកិយ ។ ខ្លួនបង
ដូចមមាច តុំគិតខ្ញាចនូវអគ្គី ឃើញភ្លើងហើរចូលខ្នី ដូចបងឃើញប្អូន
ស្នេហា ។ អ្ហ៎ះហើយបងនឹងនៅ ចាំយកពៅស្លួនតុំណា ឲ្យចាន់ដូច
ច្រាថ្នា បងមិនមានស្តាយដែរ ។ ស៊ូស្លាប់តូវចាន់ខ្ញាត លើច្រាសាខ
នាងប្អូនស្រី ឱនរស់នៅធ្លើអ្វី បើប្អូនពៅពុំត្រមង ។ សូវស្លាប់
ពេញជាប្រុស ខុតជារស់កាលនេះម្តង ខ្ញាសប្អូនបរាភ្លាតបង ឲ្យមក
ដល់ហើយប្រែវិញ ។ តេជៈបង់ចាន់សាង សូមឱនាងព័ន្ធមុខមិញ
ផាករយោសំឡាញ់ ពីបុពណមែនពិតណា ។ សូមឲ្យគ្រារច្រាសាខ
រមែតស្លាតចាតចេញក៏ ច្រាកដដូចសច្ចា– អធិដ្ឋានកាលនេះវៃ ។ ឯនាង
នាថឧងវង បន្ទូលផ្សងដូចក្សត្រៃថ្ងៃ ហេតុបុណ្យព្រះចមត្រៃ ឱនាង
នាថព័ន្ធមិញ ។ មកជ្រោមជួយព្រះចាន ច្រាសាខរមែតចេញ
នាងនាថវែងគោរពញ ចិត្តដឿងាចារមិន ។ ក្សត្រិណានោះព្រះរាជ
ស្តេចលីលាចរចូលថ្ងាន ខៀបនាងនាថកល្យាណ ទើបនាងយល់ព្រះ
រាជ ។ នាងខ្ញាសនាងអៀនអាក់ រំប្រែព្រះតក្តួនាងចេញណា នាង
យកព្រះពស្ត្រា មកខ្ទរហើយនាងផ្ទំ ។ ខៀនយាមភ្លឺព្រោងព្រាត
ក្តងច្រាសាខច្រសើរសម នារីរតន៍ទត្តម នាងនិច្រលក់សេយ្យាសន៍ ។
ក្សត្រិណានោះព្រះរាជ ស្តេចលីលាដើរយោងយាស ទៅដល់ត្រែខនមាស

ទៅកូបខ្ញុំទានឆ័ន្ទមិល ។ ស្តេចបើកកំឆ័ននណា ព្រះពជាទត់ទៅយល់ នាងផ្ទុលក់សុខសល់ ពុំកម្រើកព្រះអង្គា ។ ស្តែងស្តេចទៅតចូលដំន ព្រះអគ្គបិតភាឆ័នាងណា ព្រះនុស្តថ្ងៃបរបា ថ្វាថ្ងៃនខ្លួរៀងក្យមេត្រី ។ ថាហៃបួនត្រលឺឆ័ មានបើឱឆ័អាក់អន់អ្វី បួនមាសមិនស្រដី មកឆ័ឆបឆ័ ដល់តិចឡើយ ។ បួនមួយបួនភ្លក្រក បួនថ្ងំលក់ណាទានអើយ បងមកដល់នេះហើយ ម្តេចបួនមាសមិនទាំា ។ ស្តេចបើកទូវព្រះពស្ត្រ ព័ស្រើស្រស់អង្គីនាងណា ឯនាងនាថធ្លើជា ពុំឮកព្រះស្មារតើ ។ ស្តេចទត សព្វសព៌ាង្គ រូបនៃនាងនាថនារី សម្តេចព្រះភូមី សព្វព្រះទ័យមឆ័នាងណាស់ ។ ស្តេចទ្រង់ព្រះចិន្តា តិតឯងឆ័ថាបើអញជាស់ នាងឮកឡើងឆ្ងល់ តុំបានតន់សព្វតទ្រូយ ។ ទើបព្រះអគ្គីតណាទា អស់អគ្គាព្រះបួនស្រី ព្រះនុស្តថ្ងៃថ្ងៃមប្រិយ ថ្ងៃនសរសើព្រះបួនកូា ។ ឥឡូវបងឆ័មកដល់ បងំបានយប់បួនពុំរា បងំមានច័ត្តស្នេហា បួនតាំសីយ៉ាឆ័ក្រៃលែង ។

បន្ត ភា ភាគតិ

នេះបរភាគាគត - តាំទើបបរបា និតានបាយបៃឆ ដំណើរអំពី តោឆ័ ជាក់ស្តែង បើកព្រះនុស្តថ្ងៃឆ សរសើរស្នេនកូា ។ រៀមរៃតិតតន់ អស់អគ្គីបួនតន់ សូស្តីសមសោភា បងតន់តិតតំ តេសំបួនកូា ដូចស្នាបកមក ភ្នៅនាដុតដំន ។ រៀមកែវស្នេហា តន់ព្រះសិរសោ ខ្លួនមាសមៃមិត្ត ហាក់ដូចពពាល ស្រស់ស្រិលពិចិត្រ មាសគ្គិនទឹមខាត់ ព្រោងព្រាយស្មើ ។

ភមោជ្ជនគន់ ទ្រខេសទ្រខន់ ទ្រលន់ស្រស់ស្រី បង្ហិយកៅឈ្ន
សុវណ្ណមណី ស្រស់ស្រេចឥតបី គ្មានឆ្គងឡើយណា ។ បងគន់ព្រះ
ស្រួល ក្រពុំមាត់ម្ជូល ស្ងួស្តីសមនេត្រា ព្រះទន្ធស្រស់ស្រី ប្រិម-
ប្រិយជិតស្លា ផ្កាល់ដូចផលា មាក់ប្រាងមាសមៃ ។ ព្រះកក្តែប្អូនស្រី
ដូចចន្ទបូណ៌មី ពែនចាំងឯព្ញ មណ្ឌលអាកាស រោចសនាយពែន ក្តី
ខូតំងផ្ទៃ ក្រោមក្រំភាព ។ បងគន់សូរង មួលម៉ដ្ឋឥតឆ្គង ស្ងួស្តី
សមសោភា ផ្តត់ចីដាន់ដុំ ក្លៀវភ្លុំថ្លៃថ្លា សមព្រះកត្តែ ស្រេចស្រស់
ប្រពៃ ។ ឯអង្គ៌ស្នាគង គាងគួសមពង ពងរៀលួមលៃ ចង្កេះ
ក្លៀវភ្លុំ សួស្តីសមណាស់ពែន អស់អង្គ៌ប្អូនថ្លៃ ស្រស់ស្រេចសោភា ។
តាំងសងសុជន់ ដោះទាងប្អូនគន់ បងទឹងទុបមា ជួបផ្ទៃខ្ទាប់ មាស
ផ្ទាប់នៅនា ទ្រង់ទ្រង់ទុក ខ្ទួនទាងប្អូនស្រី ។ ប្អូនស្អូតឥតឆ្គង ត្រូវ
ទឹងក្តែកងេង គ្រប់បញ្ចូតន្ទ្រីយ មានតែប្អូនហោង កន្ទុងលែងស្រី ខ្ញុ
តាងលោកយ ជម្ពូទ្វីបណា ។ សម្តេចភូមី សារសើរប្អូនស្រី ន្ទូពាក្យ
ស្នេហា សត្វសពាង្គ្រេច សម្តេចពាងា យកព្រះហត្ថា ស្តេចស្ទួប
ព្រះកត្តែ ។ រួចដល់សុជន់ ទើបព្រះប្អូនគន់ ទាងធ្វើជាក្បាក់ ស្ទើរ
យល់សត្វសាយ ពយមាយពុំផាត់ ប្រែប្រាណហើយអ្នក ទាងធ្លុះឆ្លៀត
ទៅ ។ ស្តេចយល់ប្អូនមាស ធ្លុះលាក់សេយ្យាសូន ទើបព្រះចមទៅ
រចីបថ្ងៃព្រះកត្តែ ផ្កាល់អ្នកប្អូនទៅ ថ្នមដាក់លើក្បៅ ទង្ហែលទក ។ (មានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

បរិយាយពីវត្តជាត្រៀងតំណាង

ឈោក ស្រ៊ុ–អ៊ូ រៀបរៀង

បុព្វបុរសរបស់ខ្មែរតែត្រូវនាយ ធ្វើការអ្វីទីមួយ ។ ត្រូវតែធ្វើ ក្រោកឮជល់ហេតុដើម ឬធ្វើតំណាងរបស់ដើម ដូចយ៉ាងខ្មែរបុកណាធ្វើ គ្រឹះស្ថានសម្រាប់នៅ គឺផ្ទះសម្បែង ព្រះវិហារ កុដិ សាលាជាដើម ត្រូវតែធ្វើបែរមុខទៅទិសខាងកើត ពុំសូវធ្វើបែរមុខទៅទិសខាងលិចទេ ។ គេតូរប្តូរទាក់ក្បាច់ជាផ្កាឈូក ៩ ផ្កាឈូក ៤ រែក ផ្កាមួយក្រតុំជាដើម ។ កិច្ចការពាំនេះបញ្ជាក់ឲ្យឃើញថាទំនៀមខ្មែរបុកណាធ្វើអ្វីទីមួយ ។ គេមិនមែនធ្វើយកតែលំអមួយមុខទេ គេធ្វើឲ្យល្អផង ធ្វើឲ្យព្រះឮជល់ហេតុដើម ឬធ្វើជាតំណាងរបស់ដើមផង ដែលទាំងអស់នេះតាមពីបុកណាត្រូវនាយមក ហើយធ្លាប់ឃើញគេធ្វើ មិនមែនជាទំនៀមទម្លាប់ថ្មីតែបន្តិចទេ គឺជាទំនៀមសាកលរបស់ទេមរដ្ឋ ហើយហាក់ដូចជាប្រស្នា ទុកឲ្យកូនចៅជំនាន់ក្រោយត្រិះរិះដោះស្រាយដោយវិចារណញ្ញាណចុះ ។

ពេលនេះ ខ្ញុំសូមដោះស្រាយ តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ មានសេចក្តីដូចតទៅនេះ ៖

– គេធ្វើគ្រឹះស្ថានផងពាំងពួន បែរមុខទៅទិសខាងកើត ជាការសំដែងនូវសេចក្តីគោរពចំពោះព្រះអាទិត្យ ព្រោះលទ្ធិខ្មែរបុកណាត្រូវនាយ

គេយល់ថា ព្រះអាទិត្យជាទេវបុត្រមួយអង្គ ជាបុត្រអាទិតិ ឈ្មោះអាទិត្យ ឬសុរិយាទិត្យ ជាទេវបុត្រចំភ្លឺលោកឲ្យភ្លឺត្រចះ គេយកព្រះអាទិត្យទើបនឹងរះមកពីទិសបូពិជាទីគោរព ជាសិរីមង្គលសួស្តី ចានជាគេធ្វើគ្រឹះស្ថានផងតាំងពួង ឈរមុខទៅទិសបូពិ សូម្បីគេធ្វើផ្ទុំកូនប្រុសស្រីឲ្យមានគូស្រករបង់មានមង្គលសួស្តី កំគេយកពេលព្រះអាទិត្យទើបនឹងរះជាមង្គលសួស្តី ចានជាគេឲ្យកូនប្រុសក្រាបសំពះព្រះអាទិត្យ ទើបនឹងរះពេជង ហើយពាយឈ្មោះជាសញ្ញាថា ពេលចានហើយ ទើបគេហៅកូនប្រុសឡើងទៅធ្លឹម ។

- គេតំកល់ព្រះពុទ្ធរូបក្នុងព្រះវិហារខាងកើត បែរព្រះភក្ត្រទៅទិសខាងកើត ជាវត្តតំណាង កាលព្រះបរមគ្រូមុនចានត្រាស់ ទ្រង់គង់ខាងកើតគល់ពោធិព្រឹក្ស បែរព្រះភក្ត្រឆ្ពោះទៅកាន់ទិសបូពិ ។

- គេសាងព្រះពុទ្ធរូប ទ្រង់ពែនព្រះហ្ម្នតម្រួតត្រះហស្តស្តាំលើព្រះហស្តឆ្វេង ជាវត្តតំណាងកាលព្រះអង្គទ្រង់កំពុងឆ្លងសមាធិ ។

- គេសាងព្រះពុទ្ធរូប ទ្រង់ប្រតិស្ឋានលើផ្កាឈូងរីក ជាវត្តតំណាងកាលព្រះអង្គចានសម្រេចពោធិញ្ញាណ រីកជាព្រះពុទ្ធពេញទី ដូចផ្កាឈូករីកហើយដូច្នោះ ។

- គេសាងព្រះពុទ្ធរូបអំពីប្រាក់ក្តី មាសក្តី ស៊ីម៉ងត៍ឬថ្មក្តី មានភាពជារូបនាគកាជមួយ ពែនព័ទ្ធរូបកាយព្រះអង្គ ហៅថាព្រះពុទ្ធរូបនាគប្រក់ ជាវត្តតំណាង កាលព្រះសក្យមុនីចានត្រាស់អស់

រយៈ ៣៥ ថ្ងៃរួចហើយ មានទាគាជមួយឈ្មោះមុចលិន្ទ មកបើកពិធី
គ្រប់ប្រក់ពីលើព្រះអង្គ ដើម្បីការពារកំដៅថ្ងៃនឹងខ្យល់ជាដើម ជាការគោ-
រពចំពោះព្រះសម្ពុទ្ធរៀងរាល់ ៧ ថ្ងៃ ។ សូម្បីតែធ្វើព្រះវិហារតំកល់ព្រះពុទ្ធ-
រូប ក៏មានជាក់រូបទានៅដំបូលព្រះវិហារ ដែរមានន័យថា ជហ្វាជធិគ្គារ ។

– ជហ្វាជាកន្ធុយទាន ដែលគេជាក់ក្លាប់នៅពុងមេដំបូល , ជធិ
គ្គារជាតួន្ធុនទាន គេជាក់ក្លាប់ពីតល់ជហ្វាមក សណ្តកន្ធុនមានក្បាល
ចេញមកខាង ។ ដែលគេធ្វើដូច្នោះ ជាវត្តុតំណាងការសម្តែចលិន្ទទាគាជ
មកសំដែងការគោរពចំពោះព្រះបរមគ្រូអស់ ៧ ថ្ងៃនោះដែរ ។

ចុះគេជាក់រូបគ្រុឌ ក្រោមសំយោបគ្រប់ជ្រុងចែងគាំងអស់ តើជា
តំណាងអ្វីដែរ ?

– គេជាក់រូបគ្រុឌត្រង់ចែងខាងក្រោមនោះ ជាវត្តុតំណាង ការ
គ្រុឌប្បាំងគ្នាទឹងនាគ ។

ចុះគេជាក់កណ្តឹងនៅដំបូលព្រះវិហារជាតំណាងអ្វីដែរ ?

– គេជាក់កណ្តឹងនៅដំបូលព្រះវិហារ ជាគ្រឿងពុទ្ធបូជាតំណាង
ជួបជុំគ្នា ដែលទៅប្រគេនថ្វាយចំពោះព្រះសម្ពុទ្ធ ព្រោះកណ្តឹងនេះ
ការត្រូវខ្យល់ចត់មកលាន់ឮសូរឮងឹង ហាក់ដូចជាគេប្រគំថ្វាយព្រះពុទ្ធបូជា
នៅក្នុងព្រះវិហារនោះ ។

– គេតូរប្តូរជាក់ក្បាច់ជាផ្កាឈូក ៥ ជាតំណាងព្រះសម្ពុទ្ធ ៥ ព្រះអង្គ

តឺ ព្រះកកុសន្ធោ គោនាគមនោ កស្សបោ គោតមោ អរិយមេតេយ្យា ។

-គេតូរឫទ្ធាក់ជាផ្កាឈូក ៤ រឹក ជាប្រស្នាថា ព្រះពុទ្ធ ៤ ព្រះអង្គបាន ត្រាស់ហើយ ដូចផ្កាឈូករីកហើយដែរ ផ្កាឈូកមួយនៅក្រៅ ជាប្រស្នាថា ព្រះពុទ្ធមួយព្រះអង្គទៀត ពុំទាន់បានត្រាស់ដឹងនៅឡើយ ។

បុព្វបុរសជាន់ដើម មានការពិសោធន៍ដ៏ជ្រាលជ្រៅ ដែលនឹងឆ្លើម ធ្វើរបស់អ្វីនិមួយ ។ ឡើង ច្រើនតែធ្វើប្រាប្តជល់ហេតុដើម ហើយហាក់ ដូចជាប្រស្នាឆង សូម្បីតែឯកសព្ទបច្ចុប្បសុភាសិតផ្សេង ។ ក៏ហាក់ដូចជា ប្រស្នាដែរ តែប្រស្នានោះងាយដោះស្រាយ ហើយបានសេចក្តីខ្លឹម ខ្លាយពន់ពេក ដូចសុភាសិតមានដើមថា :

ប្រើត្រាប់កុកសាប់ កុំប៉ឺត្រាប់កុកស
ប្រើត្រាប់ឫស្សីលែ កុំប៉ឺត្រាប់ស្នាយកន្ទ្រាញ ។

ពាក្យថា "ប្រើត្រាប់កុកសាប់" គឺឲ្យយកតម្រាប់លំនាំតាម កុកសាប់ ព្រោះកុកសាប់ ជាសត្វមានពេមសនោងឆ្ងាក់ មានពេមប្រឆេះ ជុះត្រែបនៅពីលើ កាលបើឧទ្ធះស្ទាបហើរឡើង ទើបឃើញពណ៌ស សំពោងនេះយ៉ាងណា មនុស្សយើងបើមានចំណេះច្រើនយ៉ាង តែប្រើ ឫកពារមៃ៉ង មិនបញ្ចេញឫកលលោលាំ តែធ្វើហាក់ដូចជាមនុស្ស សាមញ្ញ កាលបើមានគេចោទអាថ៌ប្រស្នាអ្វីមក ទើបបានបញ្ចេញឫទ្ធិ

អាទុកាពតម្រិះប្រុងជាកណ្តាលប្រដុំជនយ៉ាងស្រួលស្រែង ដូចកុតសាច់ខ្នះ
ស្នាបខ្លែងសសំគោរដូច្នោះ ។

ពាក្យថា « កុំបីត្រាប់កុតស » គឺកុំឲ្យយកតម្រាប់តាមលំនាំកុតស
ព្រោះកុតសទំនៅស្ងៀម ក៏សសំគោរ ខ្នះស្នាបហើរខ្លែង ក៏នៅតែស
ដដែល ឃាតដល់មនុស្សខ្លះមិនមានវិជ្ជាអ្វីមាំមួនទៅក្នុងខ្លួនសោះ តែធ្វើ
ឫកពាហាក់ដូចជាគ្រាន់ម៉ោណាស់ តែបើមានគេសួរប្រស្នាទីមួយ ក៏ឆ្ងល់
គាល់តុំគាចហ៊ានមាត់ឆ្លើយបានឡើយ ។

ពាក្យថា "ប្រើត្រាប់ឫស្សីលែ" គឺឲ្យយកតាមលំនាំឫស្សីដែលរលំ
ពាំនឹងគ្នាចុះក្នុងព្រាំងខ្នេរ ទឹកដន់មកលិចអស់នៅសល់តែមួយដើម លិច
ពុំបង្កែត ។ ដល់តាមទៅឃើញច្រើន ដូចមនុស្សចំពូកខ្លះ មើលទៅដូចជា
មានចេះអ្វីប៉ុន្មាន ដល់សួរដេញដោលទៅ ស្រាប់តែឃើញចំណេះវិជ្ជា
ច្រើន ។

ពាក្យថា « កុំត្រាប់ស្នាយកន្ទ្រាញ " គឺកុំឲ្យយកតាមលំនាំដើម
ស្នាយតណ្តែតទឹក ដែលមានតែសំណុំមែកសាឆ ញ៉ាំង ហើយមានតែ
ដើមតូចមួយ ដូចមនុស្សចំពូកខ្លះ គេក្រឡេកមើលទៅដូចជាមានចំណេះ
វិជ្ជាខ្លាំងពូកែណាស់ ដល់គេល្បងមើល ឥតបានការសោះដូច្នោះ ។

កណ្ដាទី ៣៦

ខកញ៉ាវិបុលរាជសេខា ង្វ-កិង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
នឹងបេះខុបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

តាំងពីបុរាណ ចាត់ថែងឃេកតាមអំពើចិត្តឯងដូច្នេះ ឯងនឹងធ្វើឲ្យផែនដីស្រុកកេងជាវ ខឹងអាណាខេត្តដែលដាំណុំរនាសអត្តពយនៅកងកណ្ដាប់ដៃអ្នកដទៃឬ ? ឯងនឹងចិត្តខឹងអ្នកដែលមានវាសនាហើយស្លាប់ទៅនោះ មិនរៀមកកាច់កឯងឲ្យស្លាប់តាមទៅឬ ? ។ ឈ្មួញបានឮដូច្នោះខឹងណាស់ ទើបបង្គាប់ឲ្យតហានចាប់ខ្លួនលីតុយទៅសម្លាប់ចេញ ។ លីតុយក៏ស្រែកផ្ដេរឈ្មួញមិនដាច់ពាក្យមួយម៉ាត់សោះ តាលំតែតហានកាប់ដាច់កស្លាប់ ។

កាលឈ្មួញ តាំងខ្លួនឡើងជារាជាហ្វាយស្រុកកេងជាវ ជំទួសខ្លួនប៉ែរនោះ ក៏ចាត់ថែងស្ដ្រីបម្រុងក្នុងក្រុង ដែលជាសែជាមួយគ្នានោះ ឲ្យ

លើកវេហ៍ពលសកលយោធាចេញទៅរក្សាត្រង់ដំបន់ ក្នុងស្រុកកេងជីវ៉ាំងមូល ហើយឲ្យខៀនយីនីងឡៅសៀន ដែលជានាម៉ឺនធំនៅរក្សាស្រុកកេងជីវ៉ា ឈ្លបកំនាំទាំងឈ្លបហ៊ូយិនឧនីងឡៅចង ខ្លួវអស់នាម៉ឺនទាំងពួងទៅតាំងទីក្រុងនៅស្រុកសុងយ៉ុង ប្រាថ្នានឹងបានតស៊ូនឹងឡៅតន្ធូវឡៅគីវ។

ខណៈនោះ មានបំរើសេះមកប្រាប់ថា ឥឡូវចូនូលើកទ័ពធំចេញពីស្រុកហ៊ូគោនីងធ្វើមកតាមផ្លូវត្រង់លើស្រុកសុងយ៉ុងនេះ។ ឡៅចងបានឮដូច្នោះ ក៏ភ័យណាស់ ទើបប្រឹក្សានឹងឈ្មួញនីងកេងអួតថា ឥឡូវចូនូលើកទ័ពមកហើយ អ្នកពស់គ្នានឹងជួយរិះគិតការពារប្រការម្តេច? ។ ហ៊ូសួនឆ្លើយថា ខេះដោយសារចូនូលើកទ័ពមក លោកកំបានដឹងច្បាស់នឹងការពារឥឡូវ បើប្រសិនជាចូនូមិនលើកទ័ពមកទេ គង់តែឡៅតន្ធូនីងឡៅគីលើកទ័ពមកជាក្រាកជ ព្រោះយើញធ្វើការស្មើសតាមអំពើចិត្ត មិនបានប្រាប់ឲ្យឡៅតន្ធូនីងឡៅគីដឹងឆង បើសិនណាឡៅតន្ធូឡៅគីមានសេចក្តីសូចចិត្ត ក៏ទំនងលើកទ័ពមកវាយខ្លួចាំតែម្ខាង មុនជាលោកនឹងបានសេចក្តីអន្តរាយ គួរឲ្យរបស់ខ្ញុំ គិតឃើញមួយយ៉ាងដោយឆ្លើតាម បណ្តាអ្នកស្រុកក៏មិនមានខ្មុកខ្មៅក្រហាយ ទាំងខ្លួនលោកសោត ក៏បានសេចក្តីសប្បាយ ត្រូវត្រង់ស្រុកក៏មិនមានខ្មុកខ្មៅក្រហាយ ។

ឡៅចងសួរថា គួរឲ្យរបស់អ្នកនឹងធ្វើប្រការម្តេច? ។ ហ៊ូ

ស្ងួនធ្វើយថា សូមឲ្យលោកលើកស្រុកកេងដីវ៉ា ខ្ញុំនឹងអាណាខេត្តឯកចាំនឹង
ឲ្យទៅបួងឆុះ មុខជាបួងខ្ញុំនឹងមានសេចក្តីត្រេកអរ ខ្ញុំនឹងជម្រាបលោក
ឲ្យបានសេចក្តីសុខវែងឆ្ងាយ ។ ឡៅបងឮដូច្នោះ ក៏ខឹងណាស់ ស្រែក
គំហកឲ្យហ៊ូសួនថា ម៉ែគាខ្ញុំទើបតែនឹងឆន់ចកម្មៅថ្មី ។ ឥឡូវខ្ញុំបានត្រូវ
ស្រុកជំនួសមិនទាន់បានប៉ុន្មានថ្ងៃផង លោកមកទាំងត្រៃឡើលើកស្រុក
ឲ្យទៅបួងឆ្ងល់ខ្លះ ខ្លោះព្រោះហេតុអ្វី ? ។ កេងអួត ធ្វើយតបទៅឡៅបងថា
ដែលហ៊ូសួនឱយយោងនោះត្រូវណាស់ ព្រោះកើតមកជាមនុស្ស ត្រូវតែ
ពាក្រោះឲ្យដឹងការធ្ងន់ការស្រាលទើបគួរ ដូចសព្វថ្ងៃនេះ បួងបានដាំ
មហាទុមកជ មានរំខំអំណាចមន៌ធ្វើការឡើយកព្រះដម្រាស់ព្រះបាទហ្នឹងតែ
ជាប្រមាណ ស្មែងក្រោមបានស្រុកទេសជាចំណុះច្រើនណាស់មក
ហើយ ឥឡូវទើបនឹងបានតាំងខ្លួនឡើងជាធំ សូមឲ្យតែការពាក់កណ្តាលនឹង
ប្អូនរបស់លោក ក៏នៅមិនទាន់ជាប្រក្រតីនឹងគ្នាសោះ ដែលនឹងរិតតែធ្វើ
សឹកសង្គ្រាមខាងក្រៅ ក៏ឃើញថាជាទម្ងន់ណាស់ទៅហើយ បើបួងឆ្ង
លើកទ័ពមកដល់ហើយ មុខជាបណ្តាក្រុងតាំងពួនឆ្នឹងកោតខ្លាចបបួល
គ្នារត់ទៅបួលនឹងបួងតាំងអស់ ឃើញថាលោកនឹងតស៊ូម្តេចបាន ! ។

ឡៅបងបានស្តាប់ហើយតបថា ដែលលោកនិយាយនេះត្រូវហើយ
តែថាចិត្តាខ្ញុំ ប្រគល់ស្រុកពុកឲ្យមិនទាន់បានប៉ុន្មានថ្ងៃ នឹងលើកទៅ
ឲ្យអ្នកដទៃទៀតនោះ ក៏ឃើញដូចជាក្បាលក្តៅមេតកមាតាចិត្តាមិនបាន

ទំនឹមមិនជាតែហាន់ខ្លាដល់ហើយឬ ? ។ អង្គសាននៃដែលជាចៅប្រឹក្សាក៏ទូលឆ្លើយទៅព្រះចន្ទថា ដែលបាំងសួនទំនឹងកេងអួតនិយាយនោះត្រូវណាស់ ហេតុម្តេចបានជាលោកមិនយល់ត្រមះឆ្លើតាម លោកប្រមាណចិត្តរបស់លោកយើញថា តស៊ូទំនឹងបួងឆ្លងបានឬ ? ឥឡូវបួងឆ្លងក៏មានចៅប្រឹក្សាទំនឹងសេនាគាហានមានថ្វីដៃច្រើនណាស់ សូម្បីតែលិវ៉ាំ អួនសៀវ ទំនឹងអ៊ួនសុតដែលមានសត្រូវជាមឹងកំឡាំងគ្រាន់បើ ម្តេចបួងឆ្លងថាលែងតែអន្តរាយកំចាត់ចេញអស់ រំលងនេះរឹតតែមានចិត្តកំរើកឡើងទៀត ឥឡូវបួងឆ្លងលើកទ័ពមកកំចាត់អាណាខេត្តខាងទិសខាងត្បូណា ដែលលោកទំនឹងនិងគិតប្បាំងតស៊ូមិនបានចំណុះបុះបួលបួងឆ្លងនោះ យូរទៅលោកទំនឹងដឹងច្បាស់ប្រាកដព្រោះលោកមិនបានស្តាប់ចៅប្រឹក្សាទាំងពួង ។ ឡៅចងតបថាដែលលោកនិយាយគឿនរំពឹកស្មារតីខ្ញុំនោះត្រូវណាស់ហើយ តែខ្ញុំនឹងសូមនាំសេចក្តីយល់ឃើញរបស់អស់លោកទៅពិគ្រោះនឹងម្តាយខ្ញុំសិន ។

ខណៈនោះ ខ្ទួលនាងឈ្មួញហ៊ីយ៉ងដើរចេញមកពីខាងក្នុង ឮខ្ទួលហើយក៏សួរឡៅចងថា អ្នកទាំងពីរប្រឹក្សាគ្នាយើញត្រូវគ្នាហើយឬ? បានជានិយាយដូច្នេះ ចៅមិនបាច់នាំយកសេចក្តីនោះមកពិគ្រោះនឹងម៉ែធ្វើអ្វីទៀតទេ ចូរប្រព្រឹត្តទៅតាមអធ្យាស្រ័យនៃអ្នកលក់គ្នាចុះ ។ ឡៅចន៍ឮម្តាយថាដូច្នោះ ក៏ត្រេកអរ ទើបសរសេរសំបុត្រសូមចំណុះបួងឆ្លង ។ ច្បាប់ស្រេចហើយក៏ប្រើសុងតុងកាន់ទៅឲ្យបួងឆ្លង ខ្ទួលជួបនឹងបួងឆ្លងលើកទ័ពមកដល់ដែនស្រុកអ៊ួនសៀ សុងតុងក៏ជូនសំបុត្រទៅឲ្យបួងឆ្លង ។ ខ្ទួល

ម៉ែលដឹងសេចក្តីគ្មានអំណរណាស់ ទើបឲ្យបំណាច់ឆ្អាន់ដល់សុរិន្តុង តាមសមគួរហើយផ្តាំថា បើអ្នកឯងត្រឡប់ទៅវិញ ឲ្យប្រាប់ឡាចឆ្នុះថា ដែលមានសំបុត្រមកនោះ យើងបានទទួលព្រមហើយ ត្រូវឲ្យឡាចឆ្នុះចេញមកតំនាប់យើងតាមប្រវៃណា យើងនឹងជួយទំនុកបំរុងឲ្យបានសេចក្តីសុខតទៅ ។ សុរិន្តុងទទួលបណ្តាំហើយ កំភូចឆ្លូចេញទៅ លុះទៅដល់ទន្លេនឹងឆ្លង កំប្រទះនឹងពួកឥហានគួនអ៊ូរកំចាប់ខ្លួនសុរិន្តុងបានទើបសួរថា កូនឆ្លងដែនការស្រុកគេដ៏ជាអនោះ ជាប្រការម្តេច ? ។ សុរិន្តុងតំឆ្លើយមិនត្រឹមត្រូវ លុះគួនអ៊ូបន្ទឹងសួរខ្លាំង ឃើញថាលាក់មិនបានគំប្រាប់ដោយពិតថា ឥឡូវឡាចប៉ៀវដល់ទូរសេចក្តីស្លាប់ហើយ ឯស្រុកខេមរាំងតួង នាងឈូហ៊ូយិន ទើងឈូម៉ីរិតតគ្នាទើងឡាចឆ្លើតទៅឲ្យបួងទាំងអស់ហើយ ។ គួនអ៊ូឮដូច្នោះក៏តក់ស្លុតស្មារតី ទើបនាំខ្លួនសុរិន្តុងទៅស្រុកសិនអៀ ហើយអធិប្បាយដំកបឡាចឆ្នុះ តាមពាក្យសុរិន្តុងគ្រប់ប្រការ ។

ឡាចឆ្នុះដឹងថាឡាចប៉ៀវស្លាប់ដូច្នោះ កំយំសោកាល័យពាល់តែដួលសន្លប់ ។ លុះឡាចឆ្នុះភ្ញាក់ដឹងខ្លួនឡើង ទៀរហ៊ុយកំនិយាយថា លោកនីដ៏មកទោមនស្សដូច្នេះមិនគួរទេ សុំឲ្យយកសុរិន្តុងទៅសម្លាប់ចេញទើបត្រូវ រួចសឹមលើកទ័ពទៅវាយយកស្រុកសុរិន្តុងយ៉ាង សម្លាប់ឡាចឆ្នុះនឹងឈូម៉ីឲ្យបាន ទើបធ្វើការសង្គ្រាមតទៅមុខទៀត ។ ឡាចឆ្នុះក៏យល់ថា

ខ្ញុំឯងនៅក្មេងសេចក្តីណាស់ ទើបចេះដឹងជាឆាប់មិនគួរទេ ចូរបិទមាត់កុំអាលនិយាយសិន ឯកិច្ចការទាំងអម្បាលនេះ បងក៏បានត្រិះរិះអស់ហើយ រួចឡើងក៏សួរសុធនតុងថា ខ្ញុំអ្នកឯងក៏មានដម្រេះប្រាជ្ញាដែរ បើអ្នកឯងឆ្លៀតគិតមិនត្រូវ ហេតុម្តេចមិនយកសេចក្តីនោះមកប្រាប់ឲ្យយើងដឹងសិន បើយើងនឹងសម្លាប់ខ្ញុំឥឡូវនេះ ក្រែប៉ុយើងក៏ប្រឡាក់ឈាមទេវតាប្រយោជន៍ ចូរអ្នកឯងស្រែតរត់ទៅស្រុកសុធយ៉ុធ្យាប់ ហើយប្រាប់ថា យើងចាប់បានខ្ញុំលែងមកវិញ ។ សុធនតុងមានសេចក្តីត្រេកអរណាស់ គំនាប់ឡើងហើយក៏លាចេញទៅ ។

ខណៈនោះ នាយគ្រាបាលចូលមកប្រាប់ឡើងថា ឥឡូវឡើងគឺប្រើអ៊ុចៀមកគំនាប់លោក ។ ឡើងឮដូច្នោះ ក៏ត្រេកអរណាស់ គិតដល់គុណអ៊ុចៀ ដែលបានប្រាប់ហេតុផលមកពីថ្ងៃមុនខោះ ក៏ចេញទៅទួលដល់ត្រើគ្រានាំចូលមកខាងក្នុង អ៊ុចៀគំនាប់ឡើងហើយដំណថា ឥឡូវឡើងប្រើខ្ញុំបាទមកដំណបលោក ព្រោះឡើងបៀវជាបិតាទួលអនិច្ចកម្មទៅហើយ នាងឈូហ៊ូយិនទើងឈូម៉ គិតគំនិតត្រូវគ្នាបិទបាំងសេចក្តីនេះពុំមិនបានដំណបមកលោកឲ្យជ្រាប ទើងប្រាប់ឡើងឲ្យដឹងសោះ រួចលើកឡើងឲ្យធ្វើដាវទៅហ្វាយស្រុកតាមអំពើចិត្ត ខុសអំពីខម្លាប់ទំនៀមពីបុរាណ ឥឡូវឡើងថែមទាំងលះបង់ចោលស្រុកកេដាវ លើកទៅនៅស្រុកសុធយ៉ុធ្យាវិញ សុំឲ្យលោកលើកកងទ័ពទៅបញ្ចូលគ្នាទើង

ឡៅគីវយកស្រុកកេនដីវឡៅបាន ឡៅពីបានស្តាប់ ក៏ច្រាប់អ៊ុះចៀថា សេចក្តីនេះ អ្នកដំនីតែត្រឹមឡៅចនឯងតាំងខ្លួនឡើងធ្លុំធំ ដែលឈ្លួមខ្លឹងខាងឈ្លួហ្លួយឯងគិតត្រូវតំនិតគ្នា លើកយកស្រុកទាំង ៤ មណ្ឌលទៅឡៅបួនអស់លើងនោះ អ្នកមិនដឹងសោះទេ ។ អ៊ុះចៀឮដូច្នោះ ក៏ភ័យស្ងុតស្មារតីឆ្លើយថា សេចក្តីទាំងអម្បាលនេះ ហេតុម្តេចបានជាលោកជ្រាប ។ ឡៅពីច្រាប់ថា គួនអ្វីចាប់ខ្លួនសុដ៏តុងបានយកមកសាកសួរឆ្លើយច្រាប់រឿងពីរោងអស់ បានជាយើងដឹង ។ អ៊ុះចៀថា ដូច្នោះ ក៏ឃើញថាសាការត្រូវហើយ សូមឱ្យលោកលើកតាហានទៅច្រាប់ថា ខ្ញុំលើកមកគំនាប់សពឡៅប៉ើរតាមប្រពៃណី បណ្តោតឱ្យឡៅចនចេញមកឧលួចត្រូចាប់ខ្លួនសម្លាប់ឱ្យស្លាប់ចេញ ក៏ខ្ញុំដឹងបានស្រុកនោះដោយងាយ ។

ខុងបេងំកៈឡៅពីថា ដែលអ៊ុះចៀនិយាយនោះគឺឃើញថាត្រូវមែនហើយ សូមឱ្យលោកធ្វើតាមចុះ ។ ឡៅពីបានឮខុងបេងនិយាយដូច្នោះ ក៏ឃំសោកាល័យថា ឡៅប៉ើរបងខ្ញុំ កាលកំពុងឈឺខ្លាំងបានហៅខ្ញុំទៅនិយាយផ្តាំនេក្នុងចាំងពួង ឥឡូវមិតពីឡៅប៉ើរទៅមិនទាន់បានប៉ុន្មានថ្ងៃ ខ្ញុំនឹងទៅតែនៃប្រពួសព័យដលបុត្រកាយជាណ្តើមយកស្រុកទេសនោះមិនគួរសោះ បើដឹងទៅមិនទាន់ស្លាប់ក៏នឹងមើលមុខគេមិនពេញភ្នែក ។ ខុងបេងឆ្លើយថា ឥឡូវនេះ ចូរឆ្លៀកលើកកងទ័ពមកដល់ស្រុកអ្នកសិរ៉ៅយ ដែលលោកនឹងគិតការទៅអលែកមិនទៅវាយយកស្រុកសុដ៏ឃ្លុងនោះ លោកនឹងគិតការពោរប្រការម្តេច ? ។ ឡៅពីថា បើដូច្នោះយើង

ត្រូវតែទៅពួនទៅក្នុងស្រុកអ៊ូនសៀ ។ កាលឡៅពីកំពុងចរចាដូច្នោះ មាន
បំរើសេះបួលមកប្រាប់ថា ចួនធូលើកទ័ពមកដល់ដំបន់វាលកុកបន្ទរហើយ
ឡៅតីឆឺដូច្នោះ កឹមឆ្នំឲ្យអ៊ុចៀត្រូវប្រញាប់ទៅស្រុកកាំងហែ ឡៅតីនឹងពុន
បេង កំពាត់ចៃដន្យត្រឹមតួកពលរេហ៍ដែលត្រូវតែតាំងចាំវាំងនឹងចួនធូ ។

ពុនបេងដឹកបង្គៀតីថា ដែលចួនធូលើកទ័ពមកគ្រានេះ ជាធុរៈបស់
ខ្ញុំទាបចុះ លោកកុំព្រួយបារម្ភឡើយ គ្រាកាលហែហួខ្ញុំនលើកមកមុនតែ
តបះភ្លើងមួយ យើងក៏ដុតភាហានតាំងអស់ឲ្យនៅសល់ក៏ជំនះបាន ចួនធូ
បើកមកគ្រានេះតន់តែខ្ញុំបាទនឹងធ្វើកលឲ្យចួនធូទៅក្នុងកន្ទុលរបស់ខ្ញុំទាទ ជា
ក្រុកដ តែថាយើងនឹងតាំងវាំងទៅក្នុងស្រុកបុំវាអៀនេះមិនបាន សុំលោកឲ្យ
ទៅប្រកាសប្រុងប្រយ័ណ្ឌអ្នកស្រុក តាំងប្រុសស្រីក្មេងចាស់តាំងប៉ុន្មានថា
ឥឡូវគេនឹងតួចួនធូលើកមកនឹងម្ដើរតន្តុកយហើយ យើងនឹងទៅក្នុងទីនេះមិន
បានទេ នឹងទៅនៅស្រុកអ៊ូនសៀ បើនរណានឹងទៅជាមួយនឹងយើង ក៏ឲ្យ
បំរុងខ្លួនឲ្យស្រេច បើយើងលើកទៅវេលាណា ក៏នឹងបានទៅជាមួយ
គ្នា បើនរណាមិនចូលចិត្តទៅទេ នឹងនៅក្នុងស្រុកស៊ុនអៀនេះចុះ បើមាន
ទុក្ខភ័យប្រការម្ដងទៅថ្ងៃមុខ ក៏កុំឲ្យបន្ទោសយើងថា រតយកតែខ្លួនឯង
ឡើយ ។ ឡៅតីឃល់ឃើញត្រូវផង ក៏ប្រើឲ្យមនុស្សទៅស្រែកប្រកាស
ប្រាប់អាណាប្រជានុកស្ត្រុកនឹងស្រុកនោះឲ្យបានដឹងគ្រប់គ្នា ហើយចាត់ប្រើ

ចឺតុកជាអ្នកសម្រាប់បញ្ជូនគ្រប់គ្រងសារពាហនទាំងពួង លើកទៅស្រុកអ្នួន
សៀ ។

ខុងបេងកំចាត់ឲ្យតួនអ្នទាំពាហន ១ ពាន់ លើកទៅនៅលើដើមទឹក
ព្រែកប៉ែះហា ឲ្យយកការពារក្រែងដីឡូចចំអ្នកចំបង់ធ្វើទំនប់ បិទទប់ទឹកពុក
ឲ្យខាងចុងទឹកនោះរាក់ ហើយបង្គាប់ថា បើពាហនចូលមែកទឹកតមកពុះទ្វេង
ទឹកស្ទឹងនោះ បើឃាតឮសំឡេងអឺងកងឡើងហើយ ចូរបើកទំនប់ចេញ
ឲ្យទឹកធ្លាក់ចុះទៅត្រូវលើពាហន ដែលកំពុងដើរឆ្លងនោះលិចលង់ស្លាប់
រួចត្រូវលើកពាហនតាមទៀតនោះវាយរួចចុះទៅ ហើយឲ្យពាហុយ
ទាំពាហន ១ ពាន់ លើកទៅតួនបង្គប់ទៅដំបន់ផាក់ឡេងខាងក្រោមទឹក
ហើយបង្គាប់ពុកថា បើឃើញពាហនចូលលើកឆ្លងត្រើយមក ឲ្យវាយរួប
ឡើងទៅប្រសព្វគ្នាទីងតួនអ្នី ខ្ញុំបចាត់ដូឡេងឲ្យទាំពាហន ៣ ពាន់ ព្រោក
គ្នាជាពួកឯ បង្គាប់ឲ្យយករំសេវចាបទៅលើដំបូលផ្ទះ អាណាប្រជា
ន្ទុកស្ត្រី ដែលរត់ចាលជាច្រើននោះ ហើយលើកពាហនទៅបង្គប់នៅ
ក្រៅស្រុកខាងទិសឯជើង ទិសឯត្បូង ទិសឯលិច ជាពួកឯ ឯព្រួញធ្នូ
នោះ ឲ្យចងប្រឆេះរំសេវគ្រប់ព្រួញ បើឃើញពាហនចូលចូលស្រុក
ក្នុងគេលកណ្តាលយប់ព្រមហើយ ក៏ឲ្យពាហនអុចប្រឆេះនោចុងព្រួញ
ចាញ់ទៅក្នុងស្រុក ឲ្យភ្លើងឆេះខ្លាំង ហើយឲ្យស្រែកហ៊ោតាក្រៅស្រុក
ពាហនចូលតំទីងមែកទៅសំដៅឆ្លងស្ទឹងប៉ែះហាដូចយើងគិតពុក អ្នកចូល

ស្រុតលើកទៅបញ្ចូលគ្នានឹងខៀវហ៊ុយដួយគ្នា ទើបចាត់ឲ្យប៊ីហាន៦ នឹងឡៅហាន ២នាក់នេះនាំគាហាន ១ពាន់ម្នាក់ កាន់ទង់ក្រហម ១កង កាន់ទង់ខៀវ ១កង លើកទៅបង្កប់នៅដំបន់វាលឆប្ញួយដោ ក្រៅស្រុកសុំនអៀចម្ងាយ ផ្លូវប្រហែល ៣០០សិន (១២គ.ម.) ហើយបង្គាប់ថា បើឃើញកងទ័ពចូនូ លើកមក ត្រូវឲ្យកងស្ពាំលើកធ្នូនទៅខាងកងគ្រួង ឲ្យកងគ្រួងលើកធ្នូនទៅខាងកងស្ពាំ ផ្ញាស់ប្តូរគ្នាទៅវិញទៅមកកុំឲ្យឈប់ កងទ័ពចូនូមិនដឹងគំនាល់ថាគាហានកងទ័ពយើងច្រើន កំនឹងរំនៅមិនអាចចូលទៅក្នុងស្រុកក្នុងពេលថ្ងៃ នឹងឲ្យគាហានលើកចូលស្រុកក្នុងពេលយប់វិញ បើនឹងមិនត្រូវគ្នាដូចេ្នះ គាហានចូនូចូលស្រុកបានក្នុងពេលថ្ងៃហើយ ការរបស់យើងគឺតធ្វើនានាគំនឹងមិនសម្រេច បើដល់ពេលយប់ត្រូវឲ្យអ្នកថយចេញឲ្យអស់ បើឃើញភ្លើងនេះឡើងក្នុងស្រុកហើយ អ្នកចូរជួយដូឡឹងស្រែកហ៊ោសន្ធាប់ទៅ បើឃើញកងទ័ពចូនូបែកទៅហើយ អ្នកចូរនាំគាហានស្រុតទៅបញ្ចូលគ្នានឹងទ័ពគួនអ៊ូឯស្ទឹងប៉ែះហា ។

លុះទុងប៉ះបង ចាត់ចែងរៀបកងទ័ពឲ្យលើកទៅហើយ ក៏នាំឡៅពីចេញពីស្រុកសិនអៀ ទៅឡើងលើកំពូតស់មួយអន្ទៀចាំលបមើលគាហានតំងពួង ។ ឯទៅដួដែលជានាយទ័ពស្រួចបេស់ចូនូលើកគាហាន ៣ ពាន់មកមុន លុះលើកមកដល់វាលឆប្ញួយដោ ក្រឡេកឃើញកងទ័ពប៊ីហានឡៅហានតាំងនៅដូចេ្នះ ក៏បរគលចូលបំពារទៅមុខនឹងប្រយុទ្ធគ្នា ។

ជំហាន, ខ្លៅហង៍ឃើញទៅចូដេញតាហានចូលមក ក៏ឲ្យតាហានផ្ងាស់
កងស្តាំទៅឆ្វេង ផ្ងាស់កងឆ្វេងទួនទៅស្តាំ ប្រឆ្ងាស់គ្នាទៅវិញទៅមក
មិនឈប់ ។ ទៅធូឃើញដូច្នោះ ក៏យាត់តាហានតាំងពួនថា យើង
នឹងចូលទៅច្បាំងក្នុងពេលនេះ មិនទាន់បានទេ ខ្លាចក្រែងខ្មាំងប្រើកល
ចាយបង្កាប់តាហានខ្លះច្រែនកង ទៅធូក៏ស្រូតត្រឡប់វិលមក
ប្រាប់ចាយ៉ងចាហង ។ ចាយ៉ងនិយាយថា ដែលខ្មាំងធ្វើបែបនេះ
ជាកលចាយបញ្ឆោតយើងទេ អ្នកមិនដឹងក៏កិតភ័យ នឹងខ្លាចអ្វីចូរស្រូត
លើកទៅចុះ សឹមយើងលើកទ័ពជំនួនទៅតាមក្រោយ ។

ឯទៅធូក៏លើកតាហានចូលទៅដល់ចុងវាល ខ្លួលពេលជិតព្រលប់
ទើបឃើញកងទ័ពលើកវត់ទៅចូលព្រៃគាំងអស់ ទៅធូរៀបតាហានឲ្យ
តាមទៅបញ្ឆោនវក ខ្លួលឮស្នូរសំឡេងមនុស្សស្រែកហោទៅលើភ្នំ
ទើបងើយឡើងមើល ឃើញខ្លៅតិនឹងខ្មាំងបេនជាំនសប្បធនអគ្គិបេនីក
ស្រាជាមួយគ្នា ទៅធូខឹងណាសដេញតាហានឹងឡើងទៅចាប់យកខ្លួន
ខ្មាំងបេង ។ ក៏ឲ្យតាហានតាំងពួនប្រមៀលដុំថ្មខំលាក់ចុមក ត្រូវតាហាន
ទៅធូពិការស្លាបអស់ជាច្រើន ឡើងទៅមិនបាន ក៏ថយត្រឡប់មកវិញ
រីឯខ្លៅឮស្នូរសំឡេងមនុស្សស្រែកហៅពីក្រោយភ្នំ ទៅធូបំរុងនឹងលើកតា-
ហានឡើង ទាត់ច្បាំង ខ្លួលចាយ៉ងនិងលើកទ័ពជំនួយមកដល់ឃាត់ថា ពាល

នេះយប់ឆាប់តណាស់កុំគាលចូលចង្កាំង យើងត្រូវលើកទៅវាយយកស្រុកស៊ុនអៀសិន ត្រូវបង្គាប់ឲ្យគាហានសំពាកកំឡាំងបន្តិច ហាមដូច្នោះហើយក៏នាំទៅធ្លូលើកស្រុតទៅដល់ដើងកំពែងស្រុកស៊ុនអៀ យើញកូវរបើកចំហាំង ៨ ទិស មិនបានឃើញមនុស្សដល់ម្នាក់សោះ ចោយិនមានអំណរណាស់ក៏លើកទ័ពចូលទៅក្នុងស្រុក ។ ចោហាន់ឱយាយនឹងចោយិនថា គ្រានេះយើញថា ខុងបេងនឹងឡៅតាលប៉ះផ្ទាំតខ្លួនណាស់ហើយ ទើបលើកចោលស្រុកនាំគ្រប់គ្រួតទៅអស់ យើងត្រូវបង្គាប់ឲ្យគាហានសំពាកកម្ចាំងទៅ ១ យប់សិន ព្រឹកស្អែកសឹមលើកទៅតាមព័ទ្ធចាប់យកខ្លួន ខុងបេង នឹងឡៅពីឲ្យបាន ។ ចោយិននឹងចោហាន់ គំនាំគ្នាចូលទៅក្នុងឆកខ្ទែងលំនៅឡៅតី គាហានតាំងពួងគំជាក់ដេកវៀងគ្នាគ្រប់ចឹកខ្ទែង ខ្លះវែលទៀយហត់ណាស់ក៏ប្រែលក់ទៅ ។

លុះដល់ពេលប្រហែលយាម ៣ គើតឃ្លាំញុះធំបោកបក់ជាខ្លាំង ដួងវុងឃើញបានចំណាប់ កំឲ្យគាហានអុចប្រឆេះទៅចុងព្រួញតាំងអស់ហើយលើកធ្នូញ៉ាំត្រមគ្នាចូលទៅក្នុងស្រុក មនុស្សដែលអង្គុយយាមយើញកូនឆេះគ្រប់ដំបូលផ្ទះ ក៏រត់ចូលទៅជាស់ចោយិន ចោហាន់ថា ឥឡូវគើតកូនឆេះគ្រប់ដំបូលផ្ទះហើយ ។ ចោយិនឮដូច្នោះក៏ថា ដែលកូនឆេះនេះ ព្រោះគាហានតាំងពួងដុតដាំបាយប្រហែលបានជាកលនេះ អ្នកតាំងអស់គ្នាកុំភ័យបារម្ភអ្វីឡើយ ចូរប្រញាប់នាំគ្នាជួយលត់ឲ្យអស់ទៅ

ការលោយ៉ងខ្លាំងដូច្នោះ មិនខាន់ផុតមាត់ ក្តៅឆ៍កឆេះត្រមគ្នាគ្រប់តាំង ៣ ទិសតន្ទឺក្តីប៉ដូចជាថ្ងៃ ។

លោយ៉ងឃើញដូច្នោះក៏ភ័យតក់ស្លុត ស្រែកហៅខាហានតាំងអស់មកប្រជុំគ្នា ហើយលោយ៉ង លោហាន ក៏ឡើងសេះរកតក់ក្តៅឆួលទៅតាមផ្លូវទិសឯកើត ការខណៈលោយ៉ងតែពីក្តៅចេញទៅនោះ ខាហានតាំងពួនក៏ប្រជ្រៀតគ្នាចេញទៅតាមជាន់គ្នាស្ទាប់ជាច្រើនណាស់ ។ ដូច្នឹងក៏ឲ្យខាហានស្រែកហៅសន្ធាប់ ប៉ដូចនឹងដេញតាមសម្លាប់ពីក្រោយ ។ ខាហានលោយ៉ង ក៏ភ្ញាក់ផ្អើលបណ្តោយបែកទៅប្រតាក់ប្រតួនលើគ្នា ។ ប៉ីហាង, ឡៅហានដែលលើតទៅបន្តប់ ឃើញថាខានចំណាប់ដូច្នោះ ក៏ដេញខាហានតាខំលាឃចូលទៅ ស្លាត់រាយចាក់កាប់សម្លាប់ខាហានលោយ៉ងខូចខាតជាច្រើនណាស់ ។ ខាហានលោយ៉ង ក៏រឹតតែបែកចាក់ប្រតាក់ប្រតួនលើគ្នាជាច្រើបលប់ លុះដល់តេលយាមខាងថ្ងាយ ក៏លើកគ្នាទៅដល់ស៊ុងម៉ែះហោ ខាហានតាំងពួន ក៏ចុះឆ្លងស៊ុងនឹងទៅត្រើយខាងនាយ សំឡេងដែលស្តីនិយាយ ក៏លាន់ឮកក្រើកញាប់ញ័រខ្លាំងដែនដី ។

ឯគ្លួនអ្វីដែលនាំខាហានពួនបង្គប់នៅលើដើមទឹក ក៏ឲ្យខាហានលាឃខំនប់ដែលខប់នោះតាំងអស់ ទឹកក៏ហូរចាក់ធ្លាក់ចុះទៅ ខាហានលោយ៉ងនឹងឆ្លងមិនខាន់ ក៏លិចលង់ស្លាប់សើសល់ចំនឹកចំនួនណាតុំចាន គ្លួនអ្វីក៏ដេញខាហានចំការទៅចាក់កាប់ សម្លាប់ខាហានលោយ៉ង ។ ឃើញ

ដូច្នោះកំព័យណាស់ប្រើឯស្ទុះរត់ទន្ទឹងលើទឹកទៅដល់ត្រើយម្ខាង ហើយរត់វាងទៅដល់ពលតុកបង ខ្លៀវហ៊ុយកំលើកតាហានចេញមកស្លាក់ព័ម្ខាងយ៉ូមប្រសព្វគ្នា ហើយស្រែកថាទ័ត្រង់នេះ ពួកអាចោរនឹងស្លាប់អស់ហើយចោយិន, ចោរហង, ទៅធ្លាយើញខ្លៀវហ៊ុយលើកតាហានចេញមកដូច្នោះ កំសុតស្មាតើព័យស្លាងកាំងមិនបានប្រុងនឹងតស៊ូ កំនាំតាហានតាំងពួងស្ទុះរត់ចេញទៅ ខ្លៀវហ៊ុយកំលើកតាហានដេញតាមដួចនឹងខ្លៅពី, ខុងបេង, កំនាំគ្នាត្រឡប់មកឯស្ទឹងប៉ែះហោវិញ ខុងបេងកំឲ្យបឹតុកបង្ខិចមួងតាហានតាំងពួងពីស្ទឹងប៉ែះហោ ស្រុតទៅស្រុកអ៊ួនសៀតស់ស្រេច ហើយកំឲ្យពុះពំលាយទូកនឹងផែតាំងអស់បេញ ។

ឯចោយិន រួមតាហានដែលសល់ពីស្លាប់នឹងខ្លាត់ក្លាត់មកនោះបានហើយ កំលើកទ័ពត្រឡប់ទៅតាំងទៅស្រុកស៊ុនអៀវិញ ខើបចាត់ឲ្យចោបាឈ្មោះដាំដ៏ឈឺងទៅដំកបទូឆ្លងនឹងណាស់ ឲ្យលើកតាហានស្រុតមកខ្លៀតជុះដល់ស្រុកស៊ុនអៀហ៊ើយ កំឲ្យតាហានជាន្លងដើរលើកឆ្លើចំនប់រប់ស្ទឹងប៉ែះហោ ហើយកំបាត់តាហានថាដកធ មិនឲ្យលើតទៅតាមខ្លៅពីស្រាប់តែនឹងដាន់សង្កឹត់ស្រុកអ៊ួនសៀឱ្យបាន ។

ខ្លៅហ៊ូចិ៍ប៊ីតក្រុកគិមយ៉ាងនឹងចូងថា ដែលមហាទបពាដលើកមកនឹងស្រាប់ត្រាមអាណាខេត្ត ខានចំសេចក្សិណាត្រានេះ គួរនឹងប្រយុកចិត្តតាណាប្រដាទុកស្រួតាំងពួង ឲ្យមានសេចក្តីមេត្រីស្រឡាញ់លោកសំង

ទោះលោកនឹងបង្ខំលើកទៅដោយកំឡាំងក្រោធឥឡូវនេះក៏គង់ចាន តែថា
អាណាប្រជាទុកស្ត្រីទាំង២ស្រុកនឹងចានសេចក្តីទុក្ខក្តៅក្រហាយស្ងាប់ខ្លួនខ្លាយអស់ ព្រោះឡៅតីជាតួអាទិដ្ឋមហេតុ ហេតុនេះសុំឲ្យលោកសំកកងន័ពទុកសិន ហើយប្រើឲ្យចំអើលៅនិយាយល្បួងយកចិត្តឡៅតីឲ្យចូលមកស្នំត្រស្មាតមវិញល្អជាជាង ទោះបីបើឡៅតីនឹងមិនមកក្តី អាណាប្រជាទុកស្ត្រីទាំងពួង ក៏នឹងក្រឡេកឃើញថា លោកនៅមានចិត្តអាណិតអ្នកស្រុកមែន ។ បើឡៅតីមកលំអុតលំនួនដល់លោកហើយ អាណាទេត្តដែលជាចំណុះស្រុកគេងដាំនោះ ក៏នឹងបានមកជារបស់លោកទាំងអស់ដោយងាយ មិនចាប់នឹងបង្ខំឲ្យលំបាកតាលតាហានទាំងពួងឡើយ ។

ចូនធូបានស្តាប់ក៏យល់ចូលចិត្ត ទើបសួរថា បើដូច្នោះយើងនឹងប្រើឲ្យអ្នកឯណាទៅចរចាដោយស្អ ? ឡៅហ៊ូឆ្លើយថា ដែលនឹងប្រើឲ្យអ្នកដទៃទៅនិយាយបញ្ចុះបញ្ចូលឡៅតីនោះ ឃើញជាមិនបានទេ មានតែឈ្មោះស៊ីមួយ ដែលអាចនឹងទៅនិយាយបាន ព្រោះឈ្មោះស៊ីនេះ ពីដើមជាមនុស្សក្រាប់គាននឹងឡៅតីជាទីពុកចិត្តឥតដែលខាស់គជ្ជាស្រ័យ សូមឲ្យលោកច្រើបាស៊ីនេះទៅចុះ មុខជានិយាយឲ្យបានការ ។ ចូនធូថា អ្នកគិតនេះត្រូវណាស់ តែថាឈ្មោះស៊ីនោះ ជាមនុស្សត្រូវអគជ្ជាស្រ័យនឹងឡៅតី បើប្រើទៅហើយឈ្មោះស៊ីត្រឡប់ជាមិនវិលមកវិញ យើងមិនខ្លួចការ

ឬ ? ។ ខ្លៅហ៊ូឆ្លើយថា ឯឈើស៊ុនោះជាមនុស្សសុចរិតណាស់ ដែលប្រើគេហើយ ខឹងមិនត្រឡប់មកវិញនោះមិនមែនទេ ព្រោះមនុស្សនេះ ជាអ្នកខ្វាចសេចក្តីខិន្ទាណាស់ លោកកុំសង្ស័យឡើយ ចូរប្រើឲ្យឈើស៊ុទៅចុះ គង់តែលែត្រឡប់មកវិញជាក្រាកដ ។

ចូតូពុទ្ធថ្លែងដូច្នោះ ក៏ឲ្យហៅឈើស៊ុចូលមកហើយនិយាយថា ឥឡូវយើងមានសេចក្តីត្រូវចិត្តនឹងខ្លៅពីណាស់ គិតនឹងលើកឲ្យទៅជាន់សង្កត់ស្រុកអ៊ូនសៀឲ្យល្អតជាងលើ តែមកគិតអាណិតដល់អាណាប្រជានុកស្ត្រីពាំងពួង ខឹងបណ្តោយឲ្យខូចរៀបរាលខេត ។ ទៅមិនគួរសោះ សព្វថ្ងៃនេះយើងកំដឹងថា ខ្លួនអ្នកនឹងខ្លៅពីជាមនុស្សត្រៃគំនត់គ្នា ទើបឲ្យអ្នកទៅបរទាន់យាយនឹងខ្លៅពី ឲ្យចូលមកលន់តួអង្វរយើងដោយល្អ កុំឲ្យមានសេចក្តីក្តៅក្រហាយដល់បណ្តាពស្ត្រឡើយ ខ្លួនយើងក៏មិនយកទោសខ្លៅពីដែរ ឥឡូវនេះបំរុងឲ្យឯងតាមសេចក្តីប្រាថ្នា ប៉ើឥឡូវប្រើអ្នកដទៃឲ្យទៅនិយាយការ ខ្លាចគ្រងខូចសេចក្តីដែលគិតខុក ឃើញតែអ្នកដែលមានសេចក្តីខំនុកខុកចិត្តល្អត្រង់សុចរិត ចូរអ្នកគិតទៅនិយាយនឹងខ្លៅពីតាមសំដីយើងចុះ ។ ឈើស៊ុទទួលពាក្យចូតូហើយ ក៏លាចេញទៅដល់ស្រុកអ៊ូនសៀ ។

ខណៈនោះខ្លៅពី ខុងបេងដឹងថា ឈើស៊ុមកក៏មានអំណរណាស់

ចេញទៅទទួលនាំចូលមក ហើយសាកសួរសុខទុក្ខតាមទំនុកដែលនិកស
ព្រះសព្ទាកគ្នាពីគ្រាមុនរហូតមកតាមប្រពៃណី ហើយឈើសុីគិនិយាយថា
ដែលខ្ញុំបាទមកនេះ ព្រោះចូរឆ្លៀតមកនិយាយលួងលោមឲ្យលោក
ទៅចំណុះចុះចូល បើខ្ញុំបាទមិនទទួលមកនិយាយគឺមិនបាន តែតាមការ
ដែលខ្ញុំបាទប្រមាណយើញាតិត ចិត្តចូរនោះព្រួញាទនឹងយកចិត្តអស់អ-
ណាប្រជានុកស្រុកគាំនឹតួងនេ ដើម្បីឲ្យអាណាប្រជានុកស្រុកគាំនអស់នោះ
ស្មោះស្ម័គ្រស្រឡាញ់ចូរ ខ្លីបានត្រង់អស់អញទនឹងលោកនោះក៏ឥតអង្គី
មាន ឥឡូវចូរតែតធ្វើការធំណាស់តែណ្ហូតលរហែឲ្យលើកទំនប់ចប់ពីកស្ទឹង
ថែះរហាគាំងមូល រហើយប្រមូលមាហានលើតក្បែកទុកជា ៨កង ប៉ងនឹង
មកកំចាត់លោកចេញឲ្យបាន ឯស្រុកអ្នកនេះជាទីតួចបង្អែតណាស់
ឃើញថាទទួលកំឡាំង ចូរ មិនបាន ចូរឲ្យលោកនិះតែតអានប្រែប្រួល
ទៅឲ្យឆាប់ ។ ឡៅតែតបថា ដែលអ្នកមកនិយាយដាស់តឿនស្មោះតែឲ្យដឹង
ធ្ងន់ស្រាលគាំងអម្បាលនេះពេញចិត្តខ្ញុំណាស់ ខ្លួនអ្នកនឹងខ្ញុំបែកបាកគ្នាទៅ
យូរហើយគ្រានេះខ្ញុំឃើញមុខអ្នកហើយ តែតិបុណ្យក៏ពួតួរតែអ្នកនឹងខោឲ្យ
ជាប់កុំត្រឡប់ទៅក្បែរឡើយ ។ ឈើសុីឮហើយក៏ឆ្លើយតបថា ខ្ញុំបាទនឹងទៅ
នឹងលោកមិនត្រឡប់ទៅកចូរនេះ ក៏ទឹងជាខ្ញុំតរហានិន្ទាដល់មនុស្ស
គាំងពួងថា ជាមនុស្សគ្មានសេចក្តីតតញ្ញូ មួយវិតសត់មាតាក៏ធ្លាក់ទៅ
ទៅក្នុងស្រុកហ្វីតា ត្រូវតែត្រឡប់ទៅវិញសិន ដែលលោកនឹងធ្វើការ

តទឹងចូលទោះមិញ ទុងបេងមកនៅជាបង្គោលមាំមួនហើយ លោកទឹងភ័យថារម្ដងថ្មី តារអ្វីកំតង់តែចាន់សម្រេចដូចប្រាថ្នាទាំងអស់ ឈើស៊ីថាដូច្នោះហើយ កំលាខ្លៅតាទុងបេងត្រឡប់ទៅប្រាប់ចូលវិញ លុះទៅដល់ស្រុកស៊ុនអៀ កំចួលទៅដំកបចូលថា ខ្ញុំចាន់ចាន់ទៅនិយាយលួងខ្លៅពីរដងយូរតាហើយ តែខ្លៅតាមិនព្រមចូលមកលំអុតលំនួនដល់លោកទេ ។ ចូលឮដូច្នោះ កំទឹងណាស់ ទើបឲ្យលើកកងទ័ពស្រុតទៅទឹងជាន់សង្កត់ស្រុកម៉ិនសៀឲ្យចាន់ ។

ឯខ្លៅពីក៏សួរទុងបេងថា ដែលយើងតតាំងច្បាំងទឹងចូលលើកនេះតើត្រូវគិតប្រការម្ដេច ? ។ ទុងបេងថា យើងនឹងតតាំងច្បាំងទឹងកងទ័ពចូលក្នុងស្រុកម៉ិនសៀនេះមិនចាន់ទេ ត្រូតែចាលស្រុកម៉ិនសៀនេះរំទោះទៅឯស្រុកសុងយ៉ាងដែលជាទីមាំទើបចាន ។ ខ្លៅពីថា ដែលទឹងចាលស្រុកម៉ិនសៀទៅទៅឯស្រុកសុងយ៉ាងនោះ កំគួរណាស់ហើយ តែបាំខ្ញុំមានសេចក្ដីព្រួយទឹងការណាប្រជាទុកស្ដេចទាំងពួងបងកំច្បាំងប្រឹងតាមយើងមកផង យើងនឹងនិះបានចាលគ្នាតែស្រួតយកតែខ្លួនក៏ដូចជាគ្មានធម៌សប្បុរស គួឲ្យការណ៍តអាថណាស់ ។ ទុងបេងថា បើដូច្នោះត្រូវឲ្យចំរើទៅស្រែកប្រកាសថា តទៅតែងទ័ពចូលើកមកធ្វើអន្តរាយស្រុកយើងនេះទៀតហើយ យើញជាលើកកំច្បាំងទឹងគ្រាំទៅពុំចាន យើងត្រូវតែប្រជ្រុលបបួលគ្នាលើកទៅទៅស្រុកសុងយ៉ាង អ្នកទាំងឡាយទឹងទៅ

តាមយើងគំពោ បើមិនពៅទំនិស្ត្រីចង់នៅក្នុងស្រុកនេះគំតាមអញ្ជាស្រេយចុះ ។ ឡៅព័ត្តដូច្នោះគំប្រើគួនអ្នពៅចាត់ចែងរកទូកសម្រាប់ចំឡងគ្នាពៅស្រុកសុនយ៉ុង ហើយគំឲ្យស៊ុនខៀនទីឆ្ងាយយ៉ុងពៅស្រែកប្រកាសប្រាប់ប្រជាជនគាំងពួនតាមពាក្យខុងជេង ។

ខណៈនោះ បណ្តាអ្នកស្រុកដឹងដូច្នោះគំឆ្ងើយថា យើងខ្ញុំនឹងនៅក្នុងស្រុកអ្នខសៀនោះ ស៊ូឲ្យស្លាប់ដីវិត មិនពៅជាជាប់ខាត បើឡៅព័ពៅនៅទីណា យើងខ្ញុំពាល់គ្នាគំសុំពៅតាមជាមួយ អ្នកស្រុកគាំងពួងគំស្រុះស្រួលគ្នាត្រមោលទីលំនៅគាំងអស់ លើកគ្រប់គ្រួចេញពៅតាមឡៅព័ ខ្លះគំយំស្រែកជេងជូរពៅ លុះឡៅព័ឆ្ងនពៅដល់កណ្តាលទឹកស៊ឹងក្រឡែកមើលមកក្រោយ ឃើញបណ្តាកស្តេយំស្រែកអឺងកងតាមត្រើយគាំងសង្វាង កំនន់ចិត្តអាណិតអាសូរណាស់ ឡៅព័គំយំសោកថា មនុស្សគាំងអស់នេះនាំគ្នាមក ជាខសចក្តីលំបាកត្រាត់ប្រាសទីកន្លែង គំព័ត្រោះយើងនេះឯង ឡៅព័ថាដូច្នោះហើយ គំក្រោកឈរឡើងគិតនឹងលោតទឹកសម្លាប់ តាហានគំស្ទុះពៅចាប់ឃាត់ទុកហើយយំសោកគាំងអស់គ្នា ។

លុះឆ្ងនពៅដល់ត្រើយម្ខាងហើយ ឡៅព័គំនៅមិនទាន់ពៅឡើងរារាំងបង្អង់គាំពួកអ្នកស្រុកឲ្យឆ្ងនពៅរួចគាំងអស់គ្នា បង្គំឲ្យគួនអ៊ីយកទូក

(នៅមានត)

ផ្នែកកំណាត់ដំណើរប្រវត្តិការណ៍

ពិធីបើកការសិក្សានៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពិធីសម្ពោធគ្រឹះស្ថានព្រះសីហនុ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ.

លោក ៩៥-៥៦ រៀបរៀង

កាលពីព្រឹកថ្ងៃពុធ ៤ កើត ខែជេស្ឋ ឆ្នាំកុរឯកស័ក ព.ស ២៥០២ (ទ១-៤-៥៩) មានធ្វើពិធីសម្ពោធបើកការសិក្សានៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ និងពិធីសម្ពោធគ្រឹះស្ថានព្រះសីហនុរាជ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជ មានឯកឧត្តមត្រី ។

នៅម៉ោង ៨-៣០ មានការជួបជុំព្រះសង្ឃគាំង់ពីគណៈ និងពុទ្ធបរិស័ទ ។ ម៉ោង ៨ ៤៥ សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្ត ព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា ជាតំណាងនៃសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ប្រជានសភាគាំង ២ សមាជិករដ្ឋកិច្ចាល សមាជិកសភាគាំង ២ ព្រមគាំងមន្ត្រីអភិក្រាជការគ្រប់តំណែង និមន្ត ស្តេចយាង អញ្ជើញមកដល់ ។

ម៉ោង ៨-៩០ អង្គខួតនានា ប្រធានគណៈកម្មការអន្តរជាតិ ចូនអញ្ជើញ
មកប្រជុំកងពិធីនេះ ។

ទៅម៉ោង ៩ សម្តេចព្រះមហាក្សត្រីយោនី នឹងសម្តេចព្រះទេបយុវរាជ
នាយករដ្ឋមន្ត្រី ដោយមានទតួមប្រុមប្រឹក្សានៃព្រះរាជា នឹងព្រះពជមរិតារ
ផ្ទាល់ព្រះអង្គតាមបែបធន ចូនស្តេចយាងមកដល់កន្លែងប្រកបពិធី ដែល
នៅពីនោះ មានកងឥស្សរជនប្រុមរក្សាព្រះអង្គ ប្រុមជន្ត្រីព្រះពជទ្រព្យចូន
ធ្វើតារវិតិច្ចជាព្រះពជកិត្តិយស ។ តមក ប្រុមជន្ត្រីព្រះពជទ្រព្យបន្ទុំខួបមេ
នតរពជថ្វាយជាពីតារេត ។ ក្រោយដែលព្រះនរបតី តង់ប្រថាប់លើព្រះ
សុវណ្ណគោច្ចះហើយ លោក អ៊ុំ-ហ៊ុនសាង រដ្ឋលេខាធិការក្រសួងធម្មការ
ចូនថ្លែងសុន្ទរកថា មានសេចក្តីដូចតទៅនេះ-

សូមព្រះតេជៈដ៏កល់លើត្បូង,

សូមព្រះពជគនគ្រាបបង្គំទូល សម្តេចព្រះមហាក្សត្រីយោនី នឹង
សម្តេចព្រះទេបយុវរាជ-

សូមទ្រង់ជ្រាបក្រាមល្អងធួលីព្រះចុង ។

ក្នុងនាមនៃក្រសួងធម្មការ នឹងសាសនសិក្សាធិការ នឹងក្នុងនាមផ្ទាល់
នៃខ្ញុំព្រះបង្គំជាខ្ញុំ, ខ្ញុំព្រះបង្គំជាខ្ញុំ សូមព្រះពជគនថ្លែងនូវសេចក្តី
សោមនស្សរីករយជាបំផុត ព្រមទាំងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ នឹង

ដោយគោរពបំផុតរបស់ខ្ញុំលោកព្រះបង្គំជាខ្ញុំ ចំពោះព្រះករុណាថ្វៃវិសេស ដែលទ្រង់សព្វព្រះកដហ្ឫទ័យស្តេចយាងមកជាព្រះពជាធិបតី ក្នុងពិធីបើក ការសិក្សា នៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ នឹងពិធីសម្ពោធធ្វើ ព្រឹះស្ថានព្រះសីហនុ ដែលតើបនឹងសង់រួចថ្មីៗនេះ ។

ម៉្យាងទៀត ខ្ញុំលោកព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្វៃ ន្ទូរំលេចក្តីអំណរយ៉ាងក្រៃលែង ចំពោះសម្តេចព្រះសង្ឃនាយក ព្រះ ថេរានុត្តរៈភាំងឡាយ ទ្រង់ ឯកទត្តម អស់លោក ទឹងអស់អ្នក ដែលនិមន្ត យាង អញ្ជើញមកជួយលើកតំកើងពិធីនេះ ឲ្យបានរុងរឿងជាពិសេសក្នុងវេលានេះ ។

សូមទ្រង់ព្រះមេត្តាប្រោស,

ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដែលកើតឡើងដោយអំណាច នៃព្រះរាជក្រមលេខ ៨៧៤ ន-ស-បុ ចុះថ្ងៃទី ១ កក្កដា ១៩៥៤ គឺជាវិទ្យា-ល័យខាងផ្នែកព្រះពុទ្ធសាសនា បើតទៅក្នុងព្រះបរមរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ ពុទ្ធិកវិទ្យាល័យនេះ តាំងពីកើត ឡើងរហូតដល់ឥឡូវនេះ មានអាយុ ៥ ឆ្នាំហើយ តែក្នុងរយៈកាលដែល កន្លងទៅនេះ ពុំមានការសិក្សាទៅឡើយ ដោយហេតុមកពីពុំមានព្រឹះស្ថានសិក្សា ពុំមានច្បាប់រៀបចំកម្មវិធីនៃការសិក្សា ព្រមទាំងពុំមាន

មានសមណនិស្សិត ដែលមានការចេះដឹងគ្រប់គ្រាន់ល្មមនឹងចូលមកសិក្សា ប្រាន់ផង ។

ក្នុងរយៈកាល ៥ ឆ្នាំ ដែលកន្លងទៅនេះ ជាពេលដែលត្រូវរៀបចំបណ្តុះបណ្តាលសមណនិស្សិត ដែលសិក្សាក្នុងពុទ្ធិកវិទ្យាល័យ ព្រះសុពម្រឹត អស់កាល ៤ ឆ្នាំ ឲ្យមានចំណេះវិជ្ជាការចេះដឹងគ្រប់គ្រាន់ល្មមអាចចូលមកសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យបាន តាំងកម្មវិធីនៃការសិក្សាក៏បានរៀបចំហើយស្រេច តាំងគ្រឹះស្ថានសិក្សា គ្រឹះស្ថានសម្រាប់ចាត់ការនឹងបណ្ណាល័យ ព្រមទាំងគ្រឿងសម្ភារៈផ្សេង ។ ក៏បានស្ថាបនាបានបង្កើតឲ្យមានសព្វគ្រប់ ។

· សូមទ្រង់ព្រះមេត្តាប្រោស,

កិច្ចការគ្រប់យ៉ាងដូចមានរំលេចខ្លះនេះ ក្នុងរយៈកាល ៥ ឆ្នាំ ដែលកន្លងទៅនេះ ក្រសួងធម្មការបានផ្ញើកផ្ញាក់លើព្រះតេជព្រះគុណព្រះពោធិវង្ស សូមឲ្យលោកចាត់ការគ្រប់យ៉ាង ដរាបដល់ហើយស្រេច ។ ព្រះតេជ-ព្រះគុណព្រះពោធិវង្ស លោកបានខំប្រឹងចាត់ការគ្រប់យ៉ាង មានការស្ថាបនាគ្រឹះស្ថានជាដើម ដោយផ្តល់អង្គុលាភ មិនបានប្រគល់ដល់សង្ឃគ្រាសណាមួយឲ្យខ្វល់ខ្វាយឡើយ ដើម្បីឲ្យជួរវិញ្ញធ ឲ្យបានធាប់ហើយស្រេចផង ។

ហេតុនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបារមីជានុញ្ញាតនិមន្តព្រះ-ពោធិវង្ស ជាអគ្គាធិការពុទ្ធិកសិក្សា ធ្វើសេចក្តីរាយការណ៍អំពីកិច្ចការ

សព្វសារពើ ក្រាបបង្គំទូលព្រះករុណាថ្វៃពិសេស ដើម្បីទ្រង់ជ្រាបក្រោម
ល្អង់ធូលីព្រះបាទ ។

ទីបំផុត ទូលព្រះបង្គំជាខ្ញុំ សូមទទួសព្រះពរជ័យសួស្តី ថ្វាយចំពោះ
ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងពាន់ពីព្រះអង្គ នឹងសម្តេចព្រះទេពយុវ-
រាជ សូមព្រះអង្គបានប្រកបដោយសុភមង្គល នឹងសិរីសួស្តីគ្រប់យ៉ាង
នឹងសិរីពោជសម្បត្តិអស់កាលជាអង្វែងតរៀង ។

សូមព្រះគេជ:តំកល់លើត្បូង

បន្ទាប់មកព្រះសោធិវង្ស ហួត-គាត អគ្គាធិការពុទ្ធិសាសនា បាន
ថ្លែងសុទ្ធរកថាតមកទៀត មានសេចក្តីដូចតរៀងនេះ :

សូមថ្វាយព្រះពរ ព្រះករុណាជាអម្ចាស់ជីវិត សម្តេចព្រះមហា-
ក្សត្រីយានី នឹងសម្តេចព្រះទេពយុវរាជ,

សូមថ្វាយបង្គំសម្តេចសង្ឃនាយក,

សូមថ្វាយព្រះពរសម្តេច ទ្រង់ សូមចំរើនពរ ឯកទត្តម នឹងអស់
លោកទាំងឡាយ ,

ដោយនេះ ខ្ញុំព្រះករុណា អគ្គាគាត មានបីតិសោមនស្សរីករាយ
ជាពន់ពេកលើង ចំពោះព្រះករុណាជាអម្ចាស់ជីវិត សម្តេចព្រះមហាក្សត្រី-
យានី សម្តេចព្រះទេពយុវរាជ សម្តេចសង្ឃនាយក ទ្រង់ ឯកទត្តម នឹង
អស់លោកទាំងឡាយ ដែលបានស្តេចមក និមន្តមក អញ្ជើញមក

ជាព្រះពុទ្ធជាធិបតី ខ្ញុំជាកត្តិយសក្នុងនាមជាធិបតីបើកការសិក្សានៃពុទ្ធិក-មហាវិទ្យាល័យព្រះសីហនុរាជ ខ្ញុំពិធីសម្ពោធធ្វើឡើងនៅស្ពានព្រះសីហនុ ដែលចាប់ផ្តើមសង់ក្នុងថ្ងៃ ១ ខែ ៥

សូមក្រាបទូលព្រះមេត្តាប្រោស ,

អម្បាញ់មិញនេះ លោកអគ្គលេខាធិការក្រសួងធម្មការ ខ្ញុំសាសនា-សិក្សាធិការ បានថ្លែងសេចក្តីថ្លាយ អំពីការកសាងនៃពុទ្ធិកមហា-វិទ្យាល័យនេះរួចហើយ ។

ឥឡូវនេះ អាត្មាភាព សូមព្រះពុទ្ធគុណព្រះពុទ្ធវរៀងគាស់បន្តិច ថ្លែង សេចក្តីថ្លាយ អំពីការស្ថាបនាត្រឹស្ថានៃពុទ្ធិកមហាវិទ្យាល័យ ខ្ញុំជាអគ្គ-កិច្ចការខ្លះ ដែលទាក់ទងជាមួយពុទ្ធិកមហាវិទ្យាល័យនេះ ដើម្បីក្រាប ជូនមានសេចក្តីតទៅនេះ :

នៅពេលបញ្ចប់អំពីការកសាង នៃពុទ្ធិកមហាវិទ្យាល័យព្រះ សីហនុរាជនេះ សម្តេចព្រះឧបយុវរាជ កាលគង់លើព្រះពុទ្ធបល្ល័ង្កនៅ ឡើយ ទ្រង់ប្រទានព្រះពុទ្ធានុញ្ញាតនេះ ឲ្យសង់ត្រឹស្ថានសិក្ស សម្រាប់ពុទ្ធិកមហាវិទ្យាល័យនេះ ។ បន្ទាប់ពីនោះមកទៀត ទ្រង់ប្រទាន ព្រះពុទ្ធានុ ព្រះពុទ្ធត្រៃពីរលើក គឺលើកទីមួយ ចំនួន ១០ ហ៊ុន រៀល លើកទីពីរចំនួន ១៥០ ហ៊ុនរៀល មកក្រសួងធម្មការ ឲ្យចាត់ចែង កសាងត្រឹស្ថានៃពុទ្ធិកមហាវិទ្យាល័យ ។ ក្រសួងធម្មការបានប្រគល់ការ:

កសាងមកអាត្មាភាព អាត្មាភាព ក៏បានទទួលរៀបចំស្ថាបនាគ្រឹះស្ថាន
ពាំងអស់កុងច៏ខេះ តាំងពីឆ្នាំ ១៩៥៤ រហូតមកដល់ចុងឆ្នាំ ១៩៥៨ បាន
ហើយស្រេច ដូចមានសេចក្តីរៀបរាប់ថ្វាយតទៅនេះ :

១- គ្រឹះស្ថានសិក្សា ១ ខ្នងមានលិច ទទឹង ១០ ម៉ែត្រ បណ្តោយ
៤០ ម៉ែត្រ មានបន្ទប់សិក្សាពាំងថ្នាក់ក្រោម ពាំងថ្នាក់លើ ១០ បន្ទប់ ។
គ្រឹះស្ថាននេះ គឺគហបតី បេ-យាន មានសទ្ធាជ្រះថ្លា បានបរិច្ចាគទ្រព្យ
របស់ខ្លួនកសាងកុងឆ្នាំ ១៩៥៤ ។ កុងឆ្នាំនោះ គហបតី បេ-យាន កសាង
បានតែត្រឹម ៦ បន្ទប់ អស់តម្លៃ ៧០ ហ្មឺនរៀល ហើយបានធ្វើបុណ្យឆ្លង
គ្រឹះស្ថាននោះ មកពរជ្ជាកិច្ចល ឲ្យដំកល់ទុកជាសម្បត្តិរដ្ឋសម្រាប់ធ្វើជា
កន្លែងសិក្សាខាងព្រះពុទ្ធសាសនា ។ លុះដល់មកឆ្នាំ ១៩៥៧ បុត្រប្រុសារ
ទីឯណ្ឌតាបង្កើតនៃគហបតី បេ-យាន បានកសាងបន្ថែមទៀត គឺលោក
តាន-អៀមគន់ ទីឯនាង បេ-ស៊ុកាង សាងពីរបន្ទប់ទៅខាងជើង លោក
លី-ជិនលឹម នាង បេ-ស៊ុកាត សាងពីរបន្ទប់តទៅខាងត្បូង រួមពាំង
មុនដែរ ១០ បន្ទប់ ។ រួមតម្លៃពាំងមុខពាំងក្រោយ ១១០ហ្មឺនរៀល បើគិត
ពាំងតម្លៃតុរៀនគ្រប់ថ្នាក់ ៥ ហ្មឺនរៀលទៀត ត្រូវជា ១១៥ហ្មឺនរៀល ។

២- គ្រឹះស្ថានមួយខ្នងមានជើង ជាគ្រឹះស្ថានសិក្សាទទឹង ១០ ម៉ែត្រ
បណ្តោយ ២៤ ម៉ែត្រ ធ្វើជាបន្ទប់សិក្សាបាន ៦ បន្ទប់ ។ គ្រឹះស្ថាននេះ

សាងក្នុងឆ្នាំ ១៩៥៦ ដោយប្រាក់ថវិកាជាតិ ៥០ ហ្មឺនរៀល និងប្រាក់ព្រះរាជទ្រព្យសម្តេចព្រះនរបយុវរាជ ២០ ហ្មឺនរៀល ដែលដកយកពីក្នុងចំនួន ១៦០ ហ្មឺនរៀល រួមប្រាក់ទាំងពីរផ្នែកនេះ ចំនួន ៧០ ហ្មឺនរៀល, សាងអស់តែ ៦៧ ហ្មឺនរៀល នៅសល់ ៣ ហ្មឺនរៀល ។ ៣ ហ្មឺនរៀលដែលសល់នេះ ចំណាយជាវត្ថុទូន្មឹងគ្រឿងបរិភោគ រៀបចំធ្វើបណ្ណាល័យបរណ្ណាល័យអាសន្នមួយសម្រាប់ពុទ្ធិកមហាវិទ្យាល័យ ។

៣-គ្រឹះស្ថាន ១ខ្នងមានត្បូង ទទឹង ១១ម៉ែត្រ បណ្តោយ ២៥ម៉ែត្រ។ គ្រឹះស្ថាននេះ សាងក្នុងដើមឆ្នាំ ១៩៥៨ ដោយប្រាក់ព្រះរាជទ្រព្យសម្តេចព្រះនរបយុវរាជ ដែលទ្រង់ប្រោសព្រះរាជទាន ១៦០ ហ្មឺនរៀល ប៉ុន្តែបានដកយក ២០ ហ្មឺនរៀល ទៅបំពេញការកសាងគ្រឹះស្ថានខាងដើមនៅសល់តែ ១៤០ ហ្មឺន។ នេះ យកមកចំណាយក្នុងការកសាងគ្រឹះស្ថានថ្មី ១ និងឃ្លាំង ១ អស់ចំនួនប្រាក់ ១.៣១៤.២៩១,០០ (មួយរយសាមសិបមួយហ្មឺនបួនពាន់ពីរយកៅសិបមួយរៀល) ។

គ្រឹះស្ថាននេះ សាងអស់ចំនួនប្រាក់ច្រើនជាងគ្រឹះស្ថានខាងដើមដោយហេតុគ្រឹះស្ថាននេះ ជំហូលធ្វើតាមប្រពៃណីបុរាណ ហើយថ្នាក់ខាងក្រោមបានរៀបចំធ្វើកន្លែងសម្រាប់ចាត់ការទៅពុទ្ធិកមហាវិទ្យាល័យផង ធ្វើជាកន្លែងសម្រាប់ចាត់ការ ខាងពុទ្ធិកសិក្សាក្នុងព្រះរាជអាណាចក្រផង ទើបត្រូវធ្វើឲ្យមានបន្ទប់ច្រើន ។ ឯថ្នាក់ខាងលើធ្វើជាបណ្ណាល័យនៃពុទ្ធិកមហា-

វិទ្យាល័យ ។ ក្រៅពីនេះ មានការចំណាយទៀតក្នុងការរៀបចំជាក់ក្តឹង ការ
រៀបចំការិយាល័យគ្រប់ចន្លប់ ព្រមទាំងចំណាយក្នុងការចាត់ដីបំពេញគ្រង់
កន្លែងទំនាបឲ្យបានរាបស្មើ អស់ចំនួនប្រាក់៧២.៨៨០រ៉ូ០០ (ប្រាំពីរហ្មឺន
ពីរពាន់ប្រាំបួនរយប៉ែតសិបរៀល) រួមរួមទាំងអស់ ១.៣៨៧ ៤៧០រ៉ូ០០
(មួយរយសាមសិបប្រាំបីហ្មឺនប្រាំពីរពាន់ពីរយប៉ែតសិបមួយរៀល) ។

សូមទ្រង់ព្រះមេត្តាប្រោស

ព្រះសង្ឃ គ្រហស្ថជាពុទ្ធបរិស័ទទាំងឡាយ មានសេចក្តីរីករាយ
ក្រៃលែង ចំពោះព្រះរាជអំណោយ ដែលសម្តេចទ្រង់បានប្រោសព្រះរាជ
ទាន មកជួយបំពេញកិច្ចស្ថាបនាពុទ្ធិកមហាវិទ្យាល័យនេះ ឲ្យបានសម្រេច
ដោយប្រពៃ ។ ប្រសិនបើពុំមានព្រះរាជអំណោយ ដែលមានចំនួនដូចមាន
លើនេះទេ ការស្ថាបនាគ្រឹះស្ថាន មុខជានឹងមានការអាក់អួលពុំខាន ។

ដោយហេតុនេះ ពុទ្ធបរិស័ទទាំងឡាយមានកតញ្ញូតាធម៌ចំពោះព្រះ
គុណដ៏ខ្ពង់ខ្ពស់នេះ ឥតមានក្តេះសោះឡើយ ព្រះគុណមួយទៀត គឺទឹក
ព្រះទ័យដ៏បរិសុទ្ធរបស់សម្តេច កាលក្នុងឧកាសដែលគង់លើព្រះរាជបល្ល័ង្ក
ទៅឡើយ ទ្រង់បានប្រោសព្រះរាជទានព្រះរាជានុញ្ញាត ឲ្យបង្កើតពុទ្ធិក-
មហាវិទ្យាល័យនេះឡើង, ព្រះគុណនេះ ខុតុង្គ ត្តមណាស់ ព្រោះព្រះរាជា-
នុញ្ញាតឲ្យបង្កើតពុទ្ធិកមហាវិទ្យាល័យនេះឡើង ប្រៀបដូចជាទ្រង់
ប្រោសព្រះរាជទាន ឲ្យបង្កើតគ្រឿងចក្រមួយ យ៉ាងមានសម័យ សម្រាប់

ជណ្តុះជណ្តាលឲ្យកើតច្រើនជាភ្លឹស្មាន ដល់មជ្ឈដ្ឋានខាងព្រះសទ្ធម្មសាសនាកក្នុងប្រទេស ។ លុះតមក សម្តេចព្រះនៅតែមានព្រះទ័យអនុគ្រោះដួយទបត្ថម្ភឲ្យពុទ្ធិកមហាវិទ្យាល័យ មានដំណើរប្រព្រឹត្តទៅស្រួលហូតដល់មកថ្ងៃនេះ ដែលជាថ្ងៃត្រូវបើកការសិក្សាជាផ្លូវការតទៅ ។

ពុទ្ធិកមហាវិទ្យាល័យនេះ តាំងពីកើតឡើង ៥ ឆ្នាំហើយ តោះប៉ុន្តែពុទ្ធិកមហាវិទ្យាល័យ អាចទ្រាន់ទប់ទួលផលបណ្តើរៗ មកដែរ រហូតដល់ពេលនេះគឺ:

១-ការជាកំរិតវិសេស ខាងផ្នែកវប្បធម៌ បានជួយផ្តល់សាស្ត្រាចារ្យជាតិជាកំរិតវិសេស១នាក់ ឲ្យជួយបង្រៀនភាសាជាកំរិតវិសេស នៅពុទ្ធិកវិទ្យាល័យព្រះសុពន្ធ្រឹត ដល់មកបើកការសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យនេះ បានជួយផ្តល់សាស្ត្រាចារ្យជាតិជាកំរិត១នាក់ទៀត ព្រមទាំងជួយផ្តល់សៀវភៅសិក្សាជាច្រើន ។

២-មូលនិធិអាស៊ីជាអង្គការសមាគមអាមេរិកាំង បានជួយផ្តល់សាស្ត្រាចារ្យ ២ នាក់ ជាតិអាមេរិកាំង ១ នាក់ ជាតិវៀត១នាក់ ឲ្យជួយបង្រៀនភាសាអង់គ្លេស នៅពុទ្ធិកវិទ្យាល័យនិងនៅពុទ្ធិកមហាវិទ្យាល័យនេះ ព្រមទាំងសៀវភៅសម្រាប់សិក្សាពាក់ព័ន្ធសៀវភៅ ហើយជួយផ្តល់ឲ្យបោះពុម្ពសៀវភៅសម្រាប់សិក្សាជាអក្សរខ្មែរផងដែរ ។

៣-ការផ្សាយ បានជួយផ្តល់សាស្ត្រាចារ្យមួយនាក់ជាតិផ្សាយ

ឲ្យជួយបង្រៀនភាសាសំស្ក្រឹត នៅពុទ្ធិកវិទ្យាល័យ ឥឡូវនៅពុទ្ធិកមហា-
វិទ្យាល័យនេះ ត្រូវតាំងជួយផ្តល់សៀវភៅសំស្ក្រឹតជាច្រើនសៀវភៅ ។

សាស្ត្រាចារ្យឯទៀតៗក្រៅពីដំនួយបរទេស ដែលបង្រៀនវិជ្ជាខាង
ផ្លូវព្រះពុទ្ធសាសនា ឥឡូវខាងផ្លូវលោក ជាការៈលើកជម្លោកិច្ចការជាតិ គឺ
រដ្ឋាភិបាលនៃសង្គមកម្ពុជាយើង ដែលមានអគ្គិសម្តេចជាព្រះមគ្គុទ្ទេសក៍ ។

ម្យ៉ាងទៀត ក្នុងពុទ្ធិកមហាវិទ្យាល័យនេះ បានបង្កើតបណ្ណាល័យ ១
ជាបណ្តោះអាសន្ន ៤ខ្នាំហើយ ឥឡូវនេះ កំពុងរៀបចំឲ្យមានរបៀបរៀប
រយ ។ បណ្ណាល័យនេះ ទោះបីនៅជាបណ្តោះអាសន្នក៏ដោយ តែបាន
ទទួលផលល្អយ៉ាងលំដាប់ គឺបានទទួលអំណោយសៀវភៅពីបរទេសមាន
អគ្គិការនៃមូលនិធិអាស៊ីជាដើម ។ មានសៀវភៅឯទៀតខ្លះ ក្រៅពីដំនួយ
បរទេស ច្រើនជាសៀវភៅអក្សរខ្មែរនោះ បានចំណាយប្រាក់ថវិកា
ស្ទើរតែទាំងពុទ្ធិកមហាវិទ្យាល័យបន្តិចបន្តួច ជាយកមកដាំកល់ទុក ។

សព្វថ្ងៃនេះ បណ្ណាល័យមានសៀវភៅភាសាខ្មែរ ភាសាបារាំង
វិសេស ភាសាអង់គ្លេស ភាសាបាលី ភាសាសំស្ក្រឹត ភាសាថៃ ភាសា
រុស្ស៊ីខ្លះ និងភាសាចិនខ្លះ រួមទាំងអស់ប្រមាណ ៩.០០០ សៀវភៅ ។

ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ សូមសំដែងនូវកតញ្ញូតាធម៌
ចំពោះពរជ័យដ៏ថ្លៃវិសេសសង្គម ដែលបានជួយជ្រោមជ្រែង ជួយផ្តល់ការខ្វះ

ខាត ឲ្យមានដំណើរត្រង់ទៅរកវឌ្ឍនភាពក្នុងអនាគត ម្យ៉ាងទៀត សូមអរគុណចំពោះអស់លោក ដាំតំណាងរដ្ឋភិបាលនៃប្រទេសនានា ដែលបានជួយផ្តល់ដល់ពុទ្ធិកមហាវិទ្យាល័យដោយសម្ភារៈ ទឹងបុគ្គលិក ឬគ្រឿងសិក្ខា ។

ម្យ៉ាងទៀត កិច្ចការចាំបាច់ក្នុងពុទ្ធិកមហាវិទ្យាល័យនេះ ដែលបានចំរើនតៗ មក ដោយអាស្រ័យទឹងលោកអគ្គលេខាធិការ ដែលជាអ្នកគាំគាប់ផ្គាល់ :

អគ្គលេខាធិការទី១ គឺលោក អ៊ុច-វ៉ែន លោកបានទំយកចិត្តទុកដាក់ណាស់ ទាំងឲ្យបានចំរើន ។

អគ្គលេខាធិការទី២ គឺលោក សុខ-សេន ក៏លោកទំប្រឹងចំពេញកិច្ចការនេះណាស់ដែរ ទាំងឲ្យបានចំរើនតមកទៀត ។

អគ្គលេខាធិការទី៣ គឺលោក អៀង-គុណ សាគី សព្វថ្ងៃនេះ ។

លោកអគ្គលេខាធិការទាំង ៣នេះ លោកមានវិជ្ជា ទឹងសមត្ថភាពបរិបូណ៌ លោកបានចំពេញកិច្ចការ ក្នុងមហាវិទ្យាល័យនេះ ដោយយកចិត្តទុកដាក់ជាបំផុត ទាំងដំណើរការក្នុងមហាវិទ្យាល័យ ចេះតែបានប្រព្រឹត្តទៅមុខជាជាប ។

អាត្មាភាពជាតំណាងបុគ្គលិកខាងពុទ្ធិកសិក្ខា សូមថ្លែងនូវអំណរគុណចំពោះក្រសួងធម្មការ ដែលបានជួយខ្នះខ្នែងក្នុងកិច្ចការជាសាធារណៈ

នៃពុទ្ធកមហាវិទ្យាល័យនេះ ដាក់សេសសល់ខៀត មានអំណោគុណចំពោះ
ក្រសួងសិក្សាធិការជាតិ ដែលបានជួយផ្តល់ទូសាស្ត្រាចារ្យនិងគ្រូបង្រៀន
ព្រមទាំងបុគ្គលិកបច្ចេកទេស ឲ្យមកជួយកិច្ចពុទ្ធកមហាវិទ្យាល័យនេះ ។

នៅអវសានៈនេះ គាត្មាភាពសូមលើកគុណព្រះតេនត្រ័យ និងសូម
សំបូងសម្រួលចំពោះខេត្តាដែលមានចិត្តសប្បុរស សូមជួយអភិបាលក្បា
ព្រះករុណាជាអម្ចាស់ជីវិត សម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះ
ឧបយុវរាជ ព្រមទាំងព្រះពជវង្សានុវង្ស មួយអន្ទឹងដោយឯកឧត្តមនឹងអស់
លោកអ្នកទាំងឡាយ ឲ្យបានប្រកបតែនឹងសេចក្តីសុខសួស្តីជ័យមង្គល
ដ៏ប្រសើរគ្រប់ពីពរត្រីអស់កាលជាអង្វែងតទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

ជាទីបំផុត សម្តេចព្រះនរោត្តម-សីហនុ នាយករដ្ឋមន្ត្រី ព្រះអង្គ
បានថ្វែងព្រះពជសុន្ទរកថា មានអត្ថន័យដ៏ជ្រាលជ្រៅ ដូចមានតទៅនេះ:

សូមតាតពុទ្ធដីកា សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក សម្តេច
ព្រះសុធម្មាធិបតីសង្ឃនាយក ព្រះសង្ឃគ្រប់ព្រះអង្គ សូមជ្រាប ។

សូមជំពាក់ពុទ្ធបរិស័ទ ដែលបានមកជួបជុំក្នុងទីនេះ ។

នៅឧកាសដ៏ប្រសើរនេះ ខ្ញុំព្រះករុណាខ្ញុំ មានហឫទ័យរីករាយ
សោមនស្សយ៉ាងលើសលុប ដោយមានកិត្តិយសបានតាមដង្ហែសម្តេច
ព្រះមហាក្សត្រិយានី ជាអម្ចាស់លើត្បូងដ៏ ស្តេចយាងមកកាន់ពិធីបើកការ

សិក្សាខាងពុទ្ធិកមហាវិទ្យាល័យ ឧទ្ទិសជូនចំពោះស្តេចព្រះសីហនុក្រោមអធិបតីភាពនៃព្រះអង្គ ។

ព្រះគុណម្ចាស់គ្រប់ព្រះអង្គ !

អស់លោក !

ខ្ញុំព្រះករុណាខ្ញុំ មានសេចក្តីអរព្រះគុណយ៉ាងជ្រាលជ្រៅ ចំពោះសម្តេចព្រះមហាសុមេធាធិបតី ដែលព្រះអង្គមានទតុមតតិដ៏ប្រសើរ បានរំណាំស្ថាបនាមហាវិទ្យាល័យនេះ ការស្ថាបនានេះ បានសម្រេចដោយសារពលិកម្មរបស់ពុទ្ធបរិស័ទជួយទបត្ថម្ភ ។

ចំណែក ខ្ញុំព្រះករុណាខ្ញុំ ដែលបានធ្វើពលិកម្មរួបរួមជាមួយ ក៏មានសោមនស្សរេចតនាជាតន្ទឹកពេកណាស់ ។

ការដែលប្រទេសកម្ពុជាយើង បានបង្កើតឲ្យមានពុទ្ធិកមហាវិទ្យាល័យនេះ ជាការដ៏ប្រសើរមួយ ដែលត្រូវតែគ្រាទុកក្នុងប្រវត្តិសាស្ត្រនៃជាតិយើងនៃប្រទេសយើង ដែលអំណោះតទៅ សាកលលោកសន្មតបានថា មានវឌ្ឍនធម្មដ៏ខ្ពស់ក្នុងពុទ្ធិកសិក្សា ស្មើហានៈនឹងការប្រទេសឯទៀត ដែលកាន់លទ្ធិសាសនាដូចគ្នា ។

ពាជរដ្ឋាភិបាលបានជួយទបត្ថម្ភដំណើរមហាវិទ្យាល័យថ្មីនេះ ដោយផ្តល់ឲ្យនូវប្រាក់ថវិកាទឹងសាស្ត្រាចារ្យ សូមបវារណា ទឹងព្រះតេជព្រះគុណព្រះពោធិវង្ស ជាអគ្គាធិការពុទ្ធិកសិក្សា ហើយព្រះអង្គជាវីរៈបុរស បានទ

ស្តាបនាមហាវិទ្យាល័យដោយព្រះហស្តថា ទីធីដួយទេបត្តមហាវិទ្យាល័យ
នេះ តើដែលអាចដួយបានតទៅ តើដូចជាបំនែមសាស្ត្រាចារ្យក្តី
ប្រគេនអាហារូបករណ៍សម្រាប់ព្រះត្រៃអង្គខ្លះ ដែលមានការណីយកិច្ចទៅ
ធ្វើការពិសោធន៍ ទីធីបំពេញវិជ្ជាទានគរុកោសល្យទៅក្រៅប្រទេសក្តី ។

ខ្ញុំព្រះករុណា សូមទុកាសចំពោះបង្គំបង្គំទាំងពីរព្រះអង្គ ព្រះសង្ឃ
សមណាទិស្សរៀត ដើម្បីប្រគេនទុក់ខ្លះ សម្រួលតាមកម្មវិធី ពោះបីមាន
ឆ្នាំគ្នាខ្លះ សូមមេត្តាអភ័យទោស ។

ព្រះតេជព្រះគុណគ្រប់ព្រះអង្គ !

ខ្ញុំព្រះករុណា មានហួសចិត្តរីករាយពន់ពេកណាស់ ដោយបានឃើញ
ថា អំណោះតទៅ សមណាទិស្សរៀត ដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ក្លាហានដែរ
អាចបន្តវិជ្ជាជាន់ខ្ពស់បានយ៉ាងវែងឆ្ងាយតទៅទៀត ដូចមានចែងក្នុងកម្ម
វិធីមហាវិទ្យាល័យស្រាប់ ។ ដូច្នេះហើយ កិត្តិនាមព្រះពុទ្ធសាសនាខ្មែរ
ទីធីបានទទួលផលចំរេនតទៅមុខ ។

ស្រៀតីការសិក្សាខាងព្រះពុទ្ធសាសនា ទីធីមគធភាសា ដែលមាន
ចែងក្នុងកម្មវិធីមធ្យមសិក្សា ទីធីទុតិយសិក្សាស្រាប់ហើយ កម្មវិធីនេះ មាន
តាំងចែងអំពីការបង្រៀនភាសាគលទិយម ដែលជាយានសម្រាប់ជាតំ
ទង្គក្នុងការអនុវត្តជាតិ សព្វថ្ងៃនេះ ហើយទីធីវិទ្យាសាស្ត្រសម័យថែមទៀត
ផង ។

តំណែងនេះជាការមានប្រយោជន៍ពិតប្រាកដណាស់ ព្រោះតំណែងសង្ឃយើង ដែលជាអ្នកដឹកនាំខាងចិត្តធម៌លើសលធម៌នៃប្រទេសជាតិ ត្រូវតែដាក់ខ្លួនជាអ្នកមានចេតនារម្មណ៍ដែលភ្ជាប់ខ្ជាប់ជាងគេ ។

ចំពូកមួយទៀត ជាការផ្គុំយន៍ឯសាសនាឯទៀត, សាសនាព្រះពុទ្ធនេះ ទោះបីមានផលដែលរកឃើញក្នុងវិទ្យាសាស្ត្រក្រោយ ។ មកទៀត យ៉ាងដូចម្តេចក៏ដោយ ក៏អាចតម្កល់នៅបីតថេរចិរកាលជាដរាបបានដោយព្រះធម៌នៃព្រះពុទ្ធអង្គ ពុំមានគ្រាំគ្រាឡើយនឹងវិទ្យាសាស្ត្រសម័យថ្មី ។

ទោះបីនៅក្នុងសម័យបរមាណូយើងនេះក៏ដោយ ព្រះពុទ្ធសាសនាក៏នៅតែមានឱកាសដដែលនឹងជាក់ស្តែងដដែល ។

ពិភពលោកសព្វថ្ងៃនេះ ដែលបីតនៅក្នុងការព្រួយបារម្ភ ដោយអនាគតមិនភ្លឺស្វាង បើមិនជាប្រញាប់យកធម៌ព្រះពុទ្ធមកពិចារណាអនុវត្តដោះស្រាយអស់ពាំងបញ្ហាគ្រប់យ៉ាងរបស់ខ្លួនបាន ទុកជាបញ្ហាទោះស្មុគស្មាញយ៉ាងណាក៏ដោយ ។ នេះហើយដែលជាសេចក្តីជឿជាក់នៃប្រជាជាតិ ដែលមានចំនួនកាន់តែច្រើនឡើងក្នុងលោក សូម្បីតែជនអ្នកកាន់សាសនាដទៃ ក៏ចាប់ផ្តើមសិក្សាលទ្ធិពុទ្ធសាសនាដែរ ។ ស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោក មានអ្នកចាប់អារម្មណ៍សមាគមអ្នកពិនិត្យស្រាវជ្រាវនូវធម៌នៃព្រះពុទ្ធអង្គ ។

ចំណែកខាងការកែប្រែ នីតិការរៀបចំពុទ្ធិកសិក្សា ឲ្យបានតាម

សម័យ យើងគិតជាចូលក្នុងមាគ៌ាដ៏ត្រូវ ។

ក៏ប៉ុន្តែ ខ្ញុំករុណា សូមរំលឹកដល់ព្រះគុណម្ចាស់ ទីឯសមណៈទំាងឡាយ គាំងរឭយថា ការដែលយើងដើរតាមសម័យថ្មីនេះ តម្រូវជាកាតព្វកិច្ច ដល់យើងគាំងឡាយ កុំធ្វើឱ្យព្រះពុទ្ធសាសនាដាក់ចេញចាកពីពុទ្ធចំណង ដែលជាហេតុទាំឱ្យពុទ្ធសាសនាសាបសូន្យអស់ទំនុកសារ ។

ព្រះពុទ្ធសាសនាមានសាខាពីរ ដែលទីឯកាចដុះជាលក្ខណ៍វិសិដ្ឋ ភាពបាន លុះណាតែសាខាទាំងពីរ ប្រាន្តប្រួលការគ្គត់ធ្លន់ដោយស្មើភាគគ្នា គឺវិជ្ជាទីឯវិន័យ ។

ការប្រតិបត្តិតឹងតែង ដោយឥតវិជ្ជា ដោយមិនស្គាល់ជម្រៅ ព្រះពុទ្ធសាសនាជាកិច្ចប្រតិបត្តិឥតប្រាន្តផល ។

ឯវិជ្ជាទីឯវិទ្យាសាស្ត្រខ្លៀតសោត ក៏លែងមានប្រយោជន៍ខាងផ្លូវចិត្ត ទីឯផ្លូវសាសនា ការបើវិជ្ជាទីឯវិទ្យាសាស្ត្រមិនពឹងផ្អែកលើគុណធម៌ ទីឯការប្រតិបត្តិវិន័យដោយម៉ឺងម៉ាត់ (គោលបំណងនៃសាសនារបស់យើងគឺវិសិដ្ឋភាពនៃមនុស្សជាតិ ១ ការលើកទីឯសំអាតចិត្ត ១ ការសែងរកសុភមង្គលទីឯសេចក្តីស្ងប ១ ការប្រយុទ្ធទីឯកោតាភទីឯទុគ៌តភាព ១ ការកែលម្អជីវិតព្រះនិព្វានបើមិនទាន់ប្រាន្តដល់ ១) ។

ព្រះពុទ្ធសាសនាពិតប្រាកដ ប្រាន្តដល់អរិយមគ្គគឺមាឯហិនយាន ។ យើងជាអ្នកកាន់ព្រះពុទ្ធសាសនាបែកខាងមហាយាន ។ ហេតុនេះ ការដុះ

ដាលខាងវិជ្ជារបស់យើង ដើម្បីនឹងឱ្យបានប្រយោជន៍ដល់ព្រះពុទ្ធសាសនានឹងជាតិ ត្រូវតែបំពេញក្នុងក្របខ័ណ្ឌនៃការប្រតិបត្តិនិយមបែបហ៊ានយោនដែលជាលក្ខណៈព្រះពុទ្ធសាសនាមានក្រឹត្យនិយមយ៉ាងតឹងរ៉ឹង ពុំមែនជាខសប្បនវិជ្ជាឥតគោលចំណងដ៏ជាក់លាក់ឡើយ ។

ក្នុងបេសកកម្មពិសិដ្ឋ ខាងការដឹកនាំប្រជាជាតិយើងទៅកាន់សន្តិភាព សាមគ្គីភាព សុភមង្គល ព្រោះតែកុសឋ្ឋជាតិយើងដែលមានព្រះសង្ឃជេះដងជ្រៅជ្រះជាងគេជាដើម មិនគ្រាន់តែជាទីប្រឹក្សាប៉ុណ្ណោះទេ គឺជាចៅក្រមសំរេចវិនិច្ឆ័យដោយយុត្តិធម៌ ដល់អ្នកបំរើប្រទេស អ្នកទទួលបន្ទុកការទុសត្រូវ ក្នុងវិជ្ជាជីវៈក្នុងរដ្ឋហួតដល់រាជបល្ល័ង្កផង ។

រាជបល្ល័ង្ក តែងមានសេចក្តីទុកចិត្តលើយុត្តិធម៌នៃសាសនា ហើយតែងតែបំរើនឹងការពារព្រះពុទ្ធសាសនា ដោយសមានចិត្ត ចាប់តាំងអំពីដើមកំណើតនៃរដ្ឋកម្ពុជមក ។

ក្នុងប៉ុន្មានឆ្នាំនេះ មានជនខ្លះដែលច្រើនតែរស់នៅឯបរទេស គិតទំបញ្ចុះបញ្ចូលឱ្យព្រះកិកុសង្ឃយើងកាន់ដើងខ្លួន ព្រោះគេដឹងថា ព្រះកិកុសង្ឃយើង មានអានុភាពលើប្រជាពលរដ្ឋរបស់យើងជាពិត ។

គោលចំណងអ្នកទាំងនេះ គឺចង់រំលំរាជបល្ល័ង្ក ហើយតាំងសាធារណរដ្ឋជំនួស ដើម្បីចានគេជាអ្នកកាន់ចង្កឹតជាកំពូល ។

ដើម្បីនឹងសម្រេចគោលចំណងនេះ គេធ្វើដូចម្តេចឱ្យកិកុសង្ឃដួយ

នេ តីជួយដោយដើរថ្វែងអាកាសមួលបង្កិចពីកដបល្ង្ហិ ដែលគេចោទអំពី បទអាក្រក់គ្រប់យ៉ាងប្រាប់ប្រជាកស្ត្រ ។

គេបង្កិចថា កដបល្ង្ហិជាស្តេចធ្វើការប្រទាំងនឹងឯកភាជ្យរបស់ ប្រទេស ប្រទាំងនឹងឯកភាពជាតិ ។

បច្ចុប្បន្នសម័យនេះ យុត្តិធម៌នៃត្រះភុទ្ធជាម្ចាស់បានបង្ហាញដល់ព្រះ តិក្ខុសង្ឃ នឹងដល់ឃុវជនឲ្យយើញការពិតលើវត្ថុធាតុទាំងពីរ គឺឯកភាជ្យ និងឯកភាព ។

ក្នុងបច្ចុប្បន្នកាលនេះ គេពុំអាចរកឃើញមានប្រទេសឯណាមួយ ដែលមានឯកភាជ្យបរិបូណ៌ដាច់ដោយឡែកតែម្យ៉ាងឯក (Bloces) ប្រទាំង គ្នាដោយសេរីទេ នឹងប្រយោជន៍ចុងក្រោយ ត្រូវទាំងជាប់ពាក់ព័ន្ធដល់ មហាអំណាចចក្រពត្តិនិយម ទាំងវាងវិលិច ទាំងភាងកើត ឲ្យស្មើនឹង ប្រទេសកម្ពុជាបានឡើយ ។

ប្រជាជាតិយើងដឹងច្បាស់ថា ឯកភាជ្យនឹងអព្យាក្រិតភាពបានមកពី អ្នកណា ? ហើយអ្នកណាចង់បំផ្លាញឯកភាជ្យនឹងអព្យាក្រិតរបស់ជាតិខ្លួន ដើម្បីជាគុណប្រយោជន៍ឲ្យបរទេសវិញ ។

ឯកភាពជាតិខ្មែរសោត ក៏បានលូតលាស់ជាលំដាប់ពីកាន់ខ្លួន ភាពតាំងពីឆ្នាំ ១៩៥៣ មក ហើយបានគេញបរិបូណ៌ក្នុងសម័យនេះ ទើប មានដនក្សត់ជាតិខ្លះ ដោយប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន បានចូលដៃនឹង

មហាអំណាចបរទេស ដែលចង់ចំផ្លាញប្រទេសកាត ឯកភាព អធិបតេយ្យភាព នៃព្រះរាជអាណាចក្រ ។

ដល់គេរំលំរាជបល្ល័ង្កមិនបាន គេរកសម្លាប់អ្នកទ្រទ្រង់រាជបល្ល័ង្កនេះ គឺខ្ញុំកុណានេះឯង ។ ហើយគេញុះញង់មហាជនដ៏ច្រើនកុះករ ដើម្បីឲ្យទៅផ្សាយដល់ប្រជារាស្ត្រថា ការចំរើន ការល្អគ្រប់យ៉ាងនៃប្រទេស ដែលធ្លាក់ក្រោមឧត្តមខ្ញុំកុណាមានតែលើក្រដាសទេ ហើយថា សហការីដែលបំរើខ្ញុំកុណាខ្លះ សុទ្ធតែជាអ្នកពុករលួយ ចេះតែបន្លោះប៉ុណ្ណោះ ។

ខ្ញុំកុណា សុំឲ្យព្រះគុណម្ចាស់ ព្រមទាំងតំណក្នុងឱ្យទាំងឡាយមេត្តាកេរុណាធម៌ឲ្យខានផងទៅចុះ ។ តាំងពីយើងបានឯករាជ្យមក ហើយជាតិសាសន តាំងពីបានចលនាសង្គមមក ខ្ញុំកុណាតាងនាមប្រជាជាតិដែលបានធ្វើសេចក្តីខុសចំពោះលើខ្ញុំកុណា ហើយដែលបានតម្រូវ ឲ្យខ្ញុំកុណាគាន់គាប់ការប្រទេសយើង បានបញ្ជាជាងាយតដល់ភ្នាក់ងាររាជការទាំងអស់ ឲ្យចំណេះការតាមកម្មវិធីដែលយើងបានគ្រោងទុក ឲ្យអស់ពីកំលាំងចិត្ត ទំងំកំលាំងកាយ ត្រង់ខាងអស់ ។

ខ្ញុំកុណា បានទទួលគណៈប្រតិភូសង្ឃទាំងពីរគណៈ ទៅពិនិត្យមើលលទ្ធផលរបស់យើង ដែលបានកើតឡើង តាំងពីក្រុងរហូតដល់និគមជនបទជាច្រើនយ៉ាល ។

ព្រះសង្ឃច្រើនព្រះអង្គ ដែលប្រកបដោយព្រះទ័យសុទ្ធចិត្ត ទំនុកក្តុ

ធម៌ បានមានពុទ្ធដីកាថា ស្រាប់តែភ្ញាក់ខឹងលទ្ធផលតាំងធំតាំងតូចរបស់
សង្គម ហើយថាមិនអាចនឹងខតលទ្ធផលតាំងខោះបានគ្រប់សព្វ ដោយ
ឥតសំកុកយ៉ាំយ៉ូរក្នុងរវាងខ្សែនតិច្ចម្ពង ។ ពួកមហាអណាចបរទេស
ដែលមានអ្នកតំណាង នឹងអ្នកសង្កេតការខៅក្នុងទីនេះស្រាប់ ប្តូរជ្រុបុរស
របស់គេ ដែលបានអញ្ជើញមកទស្សនាប្រទេសយើង មានរដ្ឋមន្ត្រីជប៉ុន
ក្រសួងនានាប្រទេស ដែលបានអញ្ជើញមកគាំទ្រប្រទេសយើងក្នុងវេ
ទិសភាន្ទាំនេះជាដើម បានបញ្ជាក់ចំពោះមិត្តភក្តិជាតិ ថាយើងបានធ្វើ
ការឲ្យមានសេចក្តីចំរើនដល់ប្រទេសមានលទ្ធផលល្អច្រើនដ៏ពិតប្រាកដ ។

ព្រះតេជព្រះគុណ ! ធម្មតាប្រទេសទីមួយ ។ ប្រទេសយើងក៏ដូច
ប្រទេសគេ យើងខៅមានខ្វះចន្ទោះដែលនឹងត្រូវបំពេញក្នុងអនាគត យើង
ខៅមានគុណវិបត្តិមិនខុសពីបរទេសទាំងឡាយ ដែលមនុស្សលោកធ្វើខោះ
ខេ ហើយជួនកាលយើងជួបប្រទះនឹងទុបសគ្គស្ទើរធ្ងន់មិនរួច ទាន ទុប-
សគ្គនៃពួកក្បត់ជាតិនឹងពួកបរទេសជាខៅវាហ្វាយនាយរបស់គេជាដើម ។ ក៏
ប៉ុន្តែ បើយើងតែងឲ្យដល់មធ្យោបាយដ៏ស្ងួចស្តើងរបស់ប្រទេសយើងៗអាច
មើលមុខប្រទេសជាតិឯទៀតដោយឥតអៀនខ្មាស ក្នុងករណីដែលយើង
សាងជាតិយើងខេះ ។ ឯរឿងដែលគេចោទថា សហការីរបស់ខ្ញុំកុណា
ពុករលួយ ហើយថាបេះតែបញ្ចើចបញ្ចើខេះ ខ្ញុំករុណាសូមព្រះគុណ
ម្ចាស់ ទំនឹងយុសមណៈមេត្តាពិនិត្យឲ្យសមសព្វគាន ធនធនចុះ ។

ខ្ញុំករុណា សូមខ្ញុលពុទ្ធដីកាឲ្យបានជ្រាបដូចតទៅនេះ : កន្លងសម័យ
ចុះឆ្នោតសាកលជាប្រចាំក្នុងឆ្នាំ ១៩៥៨ ពួកវរជនចំណាន ។ ដែលជាប់
ឆ្នោតនឹងគណបក្សប្រជាំង មានគណបក្សប្រជាធិបតេយ្យជាដើម ព្រមទាំង
ពួកយុវជនចេះដឹង ឥឡឹងមានសញ្ញាបត្រខ្ពង់ខ្ពស់ ចូលរួមក្នុងសង្គម
ហើយ ក្នុងពាក្យសុំចូលរបស់គេនោះ គេបញ្ជាក់ថា គេស្របតាម
នយោបាយខាងក្នុងនឹងខាងក្រៅប្រទេស ព្រមទាំងទទួលស្គាល់ថា ការ
គ្រប់គ្រងប្រទេសរបស់សង្គម ជាការត្រឹមត្រូវដ៏ប្រសើរ ។ តាមសេចក្តីស្នើ
របស់សង្គម ការរំលាយរដ្ឋសភាសង្គមទី ១ ដោយមានសមាជិកច្រើន
នាក់ បានប្រតិកម្មកំហុសខាងការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ដូចជាពួក
គណបក្សក្នុងរដ្ឋសភាមុន ការរំលាយនេះ ទាំងឲ្យពួកប្រជាំងពីដើម
ឃើញថាសង្គមមិនការពារគួនចេញដែលមានកំហុសរបស់ខ្លួនឡើយ ។

ម្យ៉ាងទៀត ក្នុងពេលដែលផ្ទាស់ប្តូរគណៈរដ្ឋមន្ត្រីម្តង ។ ខ្ញុំករុណា
តែងតែទំនាស់ប្តូរមនុស្សដែលត្រូវកាន់តំណែងរដ្ឋមន្ត្រីមួយ ។ តាមគោល
ការណ៍តែម្យ៉ាងគឺ : សមត្ថភាព, កិរិយាមារយាទល្អ, អតីតកាលស្អាតស្អំ ។

ក្នុងសម័យនេះ សូមព្រះគុណម្ចាស់សួរដល់លេខាធិការដ្ឋានទៅទី
ស្តីការនាយករដ្ឋមន្ត្រី ឲ្យមកាត់បញ្ជាក់ឲ្យនាមរដ្ឋមន្ត្រី រដ្ឋលេខាធិការ
អនុរដ្ឋលេខាធិការ នាយក្រុម នាយក្រសួងពាក់ការពាំងអស់ក្នុងព្រះពុទ
អាណាចក្រ ព្រមទាំងសមាជិករដ្ឋសភា ព្រះអង្គទ្រង់ឃើញថា អស់លោក

ទាំងនោះ ភាគច្រើនសុទ្ធតែយុវជនស្អាតបរិសុទ្ធ គ្មានរឿងហេតុកង្វល់ពាក់ព័ន្ធ ឬជាអតីតគណៈបក្សប្រឆាំងពីដើម ដែលពុំបានជួយខ្ញុំកុណាក្នុងការប្រឹងប្រែងដើម្បីធ្វើឲ្យសង្គមមានជ័យជំនះ ហើយដែលក្នុងពេលនេះទៀតក៏មិនចេះបញ្ចើចបញ្ចើខ្ញុំកុណាដែរ ។ ថ្វីបើដូច្នោះ ខ្ញុំកុណានៅតែរើសយក ហើយប្រគល់តំណែងទទឹងអគ្គិការដ្ឋមន្ត្រីញ៉ាំងសំខាន់ៗ ដែលជាអាយុជីវិតនៃប្រទេសឲ្យកាន់កាប់ ។ ហិរញ្ញវត្ថុ សេដ្ឋកិច្ចជាតិ - ធនាគារ ។ ល ។ ខ្ញុំកុណាបានប្រគល់ឲ្យសហជីវិន ដែលទើបទទឹងចូលសង្គមថ្មីៗ ហើយមិនដែលជាន់ជួយសង្គម ត្រមាំងមិនដែលបានបញ្ចើចបញ្ចើខ្ញុំកុណាផង ។

សហជីវិន ថ្នាក់ថ្នាំងទាំងនោះ ដែលមានខ្លះបានទាំងទិនទៀនដោះប្រមាថមើលងាយខ្ញុំកុណាខ្ញុំពីដើមផង អាចពិតពុទ្ធដីកាព្រះគុណម្ចាស់បានថា ដើម្បីធ្វើឲ្យខ្ញុំកុណាខុកចិត្ត ពុំចាំបាច់ធ្វើអ្វីដទៃក្រៅពីធ្វើការដោយម៉ឺងម៉ាត់ ហើយសុចរិតជូនប្រទេសទទឹងនោះទេ ។

ខ្ញុំកុណាពុំអាចអួតថា ខ្ញុំកុណា បានតំបាត់ពួកអ្នកកាជការ ឬសហការីដែលក្បត់សេចក្តីខុកចិត្ត របស់ខ្ញុំកុណាបានទាំងអស់នោះទេ ។ ក៏ប៉ុន្តែ ព្រះគុណម្ចាស់ ដែលថ្លាឆន្ទវាគាំនៃមនុស្សលោកច្បាស់ជាងខ្ញុំកុណាទាំងអស់ អាចយល់បានថា តើមានរដ្ឋកិច្ចណាមួយ ដែល

ត្រូវតែប្រើរបៀបប្រជាធិបតេយ្យ ហើយពុំអាចយករបៀបបង្ក្រាបយ៉ាងម៉ឺងម៉ាត់សាហាវតាមលទ្ធកុម្មនិស្តមកប្រើឆាំង អាចធ្វើឱ្យបានប្រសើរជាងនេះ ក្នុងការចោទសំអាងបានឬទេ ?

ចំណែកខ្លួនខ្ញុំកុណា មិនធ្លាប់ការពារអ្នកពាក់ព័ន្ធអំពើក្រក់នោះឡើយ គោះបីជាមនុស្សស្និទ្ធស្នាលក៏ដោយ ។

ខ្ញុំកុណា ឥតរួញរានឹងផ្តន្ទាទោសចំពោះកំហុសទាំងអស់ ដែលរកឃើញនោះទេ ។ ខ្ញុំកុណាស្គាល់ច្បាស់ថា ក្នុងចំណោមពួកដែលចោទប្រកាន់ពីបទឧក្រិដ្ឋ ដោយមានមនុស្សពុករលួយ ក្នុងព្រះរាជអាណាចក្រខ្លះ អ្នកចោទខ្លាំងជាងគេ គឺខ្លួនអ្នកនោះឯងតែម្តង (គឺពួកសម-សារី) ដែលភស្តុតាងប្រាប់ជនបានខាត់ចេញពីសង្គមជាតិ ដោយអំពើពុករលួយតែពុំខ្លៅដែរបស់ខ្លួន ហើយដែលក្នុងពេលនេះ ឆ្លាក់ខ្លួនពៅធ្លាប់ជាអ្នកសច្ចំកន្ធដែនដីបរទេស ដើរពោលមួលបង្កាច់តែប្រទេសខ្លួនដោយឥតអៀនខ្មាសដើម្បីទិដ្ឋលាភសក្ការៈលុយកាក់ នឹងបានបន្តបំណងទ្រង់ជ្រប់របស់ខ្លួន ។

នៅទីបំផុតនេះ ខ្ញុំកុណាសូមប្រសិទ្ធពរប្រគេនដល់ព្រះគុណម្ចាស់គ្រប់ព្រះអង្គជាសាស្ត្រាចារ្យទេវតា ហើយសុំឱ្យមហាវិទ្យាល័យនេះតាំងនៅបឋមថេរចរិកាលជាប្រយោជន៍ដល់មនុជនពៅអនាគត សុំឱ្យជម្ងឺឆ្លងរាតត្បាតកុំបានមកបៀតបៀនព្រះពុទ្ធជាម្ចាស់មានប្រសិទ្ធិភាពដ៏ជាក់ស្តែង សមណៈនិស្សិតពាល់អង្គ

សូមបានទទួលផល នៃការសិក្សាព្រះពុទ្ធសាសនា ក្នុងមហាវិទ្យាល័យ
ជាកិយ្យាភាពតទៅ ។

លុះចប់ព្រះពុទ្ធសុន្ទរកថាហើយ សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់
ដ៏វិតលើត្បូង ដោយមានសម្តេចព្រះទេពយុវតី ទីឥស្សរជនខ្មែរ-បរទេស
តាមហែអមព្រះអង្គផង ក៏បានស្តេចយាងគាត់ខ្សែបូ ជាទិន្នន័យនៃការបើក
ការសិក្សាគ្រឹះស្ថានខាងទិសទក្ខិណ រួចព្រះអង្គបានស្តេចយាងទតកន្លែង
សិក្សាដែលមានសមណនិស្សិត ៤០ រូប ។

បន្ទាប់មកទៀត ព្រះពោធិវង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សា
សំដែងនូវនាមសាស្ត្រាចារ្យថ្វាយព្រះអង្គទ្រង់ជ្រាប ដែលពេលនោះ
ព្រះសង្ឃជានិស្សិត បានស្វាធ្យាយធម៌ជយន្តោ ប្រសិទ្ធពរថ្វាយព្រះអង្គ
ដើម្បីទ្រង់ប្រកបដោយព្រះបរមសុខសួស្តីក្នុងព្រះពុទ្ធសម្បត្តិ ។

បន្ទាប់ពីនោះ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ដ៏វិតលើត្បូង និង
សម្តេចព្រះទេពយុវតី ដែលមានព្រះពុទ្ធបរិពារដដែលហែអមព្រះអង្គផង
បានស្តេចយាងគាត់ខ្សែបូ:នៅគ្រឹះស្ថានព្រះសីហនុ ហើយព្រះអង្គទ្រង់បាន
ទស្សនាពីផ្សែងៗក្នុងគ្រឹះស្ថាននោះ រួចស្តេចយាងឡើងទតនូវបណ្ណាល័យ
ខាងលើ ដែលទណ្ឌនោះ សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ដ៏វិតលើ
ត្បូងនិងសម្តេចព្រះទេពយុវតី ទ្រង់សព្វព្រះរាជហឫទ័យ ឈ្លាក្រយេះហត្ថ-
លេខាលើសៀវភៅមាស ។ ឯសមាជិកអង្គទូតនានា ក៏បានចុះហត្ថលេខា

លើសៀវភៅមាសនោះជាបន្តាប់បន្តគ្នា ដើម្បីរុកជាអនុស្សាវរីយ៍ ។

លុះចប់កិច្ចទស្សនានេះហើយ ក៏មានការថ្វាយកេសជ្ជៈ ចំពោះសម្តេចព្រះមហាក្សត្រិយានី នឹងសម្តេចព្រះនុបយុវភជ ព្រមទាំងជូនកេសជ្ជៈចំពោះក្មួយកិត្តិយសទាំងឡាយ សោយនឹងទទួលទាន ក្នុងបរិយាកាសដ៏រីករាយយ៉ាងក្រៃលែង ដើម្បីជាកិច្ចបញ្ចប់ពិធី ។

នៅវេលាម៉ោង ១១ ១៥ សម្តេចព្រះមហាក្សត្រិយានីនឹងសម្តេចព្រះនុបយុវភជ ដោយមានព្រះភជបរិតារដែលតាមបែបព្រះអង្គផង ចូលទ្រង់ស្តេចយាងទៅកាន់ព្រះបរមភជកំណាក់វិញ ដោយក្រុមភាហានធ្វើតាវ-កិច្ចថ្វាយជាព្រះភជកិត្តិយស ដូចកាលស្តេចយាងមកដល់ ។

លុះដល់ពេលរសៀល មានការសម្ពោធធ្វើឆ្នាំគ្រឹះស្ថានព្រះសីហនុតាមរបៀបព្រះពុទ្ធសាសនា ។ ការបុណ្យនេះ ចាត់ចែងធ្វើឡើងដើម្បីថ្វាយព្រះពរកុសល ចំពោះសម្តេចព្រះនុបយុវភជ ជាកិច្ចចំរើនព្រះជន្មាយុនៃសម្តេច ដោយព្រះពោធិវំស្ស ហួត - តាត អគ្គាធិការនៃពុទ្ធិកសិក្សាបុគ្គលិកក្រុមពុទ្ធសាសនបណ្ឌិត្យ បុគ្គលិកកង៏អគ្គាធិការដ្ឋាន ក្នុងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ នឹងក្នុងពុទ្ធិកវិទ្យាល័យព្រះសុកម្រិត ព៌ាង ព្រះសង្ឃព៌ាងគ្រហស្ថ ព្រមទាំងសាស្ត្រាចារ្យ នឹងសមណនិស្សិតព៌ាង

អស់កង់តារទេបត្តម្ភនៃក្រសួងធម្មការ ដែលមានលោក អ៊ុង-ហុង សាធ រដ្ឋលេខាធិការជាប្រធានក្រសួង ។

នៅម៉ោង ១៩-៣០ ឯកឧត្តម ព្រះសង្ឃ ៣៩ អង្គ ចំរើនព្រះបរិត្តនៅទីគ្រឹះស្ថានព្រះសីហនុថ្នាក់ខាងលើ ។ ម៉ោង ២០-៣០ ឯកឧត្តម ព្រះតេជ-ព្រះគុណ ព្រះធម្មលិខិត ម៉ឹង សៃស ចៅអធិការ វត្តមហាមន្ត្រី សំដែងធម៌ទេសនា ។ បន្ទាប់មក

(តទៅ)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អជ្ញាន នបុ. អញាណៈ សេចក្តីល្ងង់ខ្លៅ ។ គុ. ដែលមិនដឹង, ដែលមិនពិសោធ ។

អជ្ញាត្ត បុ. ការមិនមែនដាបង; គុ. ដែលមិនឮឆ្ងាយ ។ – **ភូត** បុ. ដែលមិនប្រព្រឹត្តទៅជាបង ។

អញ្ជ ជាគុ. អស្លូត; អច្បារ; អក្ខយតិ; អក្ខិត (អខិត) : ទៅថ្ងាយបង្គំ ជំនាប់; បញ្ចមីវិភក្តិ ដល់ត; ង:ឡើង; (សក់) ពន្លាភ្ញៀ; អញ្ជិតៈ ខ្ពង់ខ្ពស់, ខ្ពាំងក្លា ។

អញ្ជន នបុ. កិរិយាធ្វើឲ្យង:ឡើង ។

អញ្ជល បុ. ដាយសំពត់ ដាយក្រមា; ការក្រាឡោកភ្នែក, រមិលភ្នែក ។

អញ្ជិ ជាគុ. អនត្តិ អង្គិ; អនុរតេ; អញ្ជិយតិ; អក្ត អញ្ជិត : លាបលេន, រិត ស្រឡាប ។

អញ្ជន នបុ. កិរិយាលាប, ថ្នាំសម្រាប់លាប (កែរភ) ថ្នាំឈឺភ្នែក, ថ្នាំលាបឲ្យមានពន្លឺ (សម្រាប់ភ្នែក) ។ បុ. មិគនៃព្រះភគវន្ត; ឈ្មោះភ្នំ; ដើមឈើ ឬ ដំរី ។ អញ្ជនា, ស្ត្រី. មាតានៃហនុមន្ត ។ – **ភគ-ភគិ** គុ. ដែលមានសក់ខ្មៅដូចអញ្ជន ។ – **គិរិ, បវិត, អញ្ជនចល, អញ្ជនាភ** បុ. ឈ្មោះភ្នំ ។ – **បវិន** បុ. ឈ្មោះភក្សៈ ។

(ទៅមានត)